
របត់នយោបាយ

សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ហ៊ុន សែន





៩ វិច្ឆិកា ១៩៥៣

៧ មករា ១៩៧៩

ភាគ ២





១៨ មីនា ១៩៧០

១៧ មេសា ១៩៧៥

ឈឹម សេរីភ្ជួន



រមត៌នយោបាយ

សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ហ៊ុន សែន

ភាគ ៣

ហាមថតចម្លង

ស្នាដៃនេះត្រូវបានចុះបញ្ជីលេខ ® ៦៨៣/២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ នៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិ ប្រហាក់ប្រហែល នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

-ទីប្រឹក្សា

វេជ្ជ. អ៊ុន សុវណ្ណា

-អ្នកពិនិត្យអក្ខរាវិរុទ្ធ

វេជ្ជ. អ៊ុន សុវណ្ណា

ង៉ែត សោភ័ណ

ង៉ែត ជិនបុត្រ

-អ្នករចនាទំព័រ

ហែម សិទ្ធា

-ការីកុំព្យូទ័រ

ប៉ោ កុសល

សេង រ៉ានី

ឈឹម មករា

រក្សាសិទ្ធិ© ឈឹម សេរីភ្លឺន គ.ស.២០២២

ISBN-13 : 978-9924-930-006

អារម្ភកថា

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសជាតិយើងធ្លាក់ចូលក្នុងរបត់នយោ បាយ មួយដែលមិននឹកស្មានដល់ គឺរបបរាជានិយមខ្មែរ មានអាយុរាប់ពាន់ ឆ្នាំមកហើយ និង ចលនាសង្គមរាស្ត្រនិយមអព្យាក្រឹតរបស់សម្តេចសីហនុ បង្កើតឡើងនៅក្នុងឆ្នាំ១៩៥៥ ត្រូវឧត្តមសេនីយ៍លន់ នល់ ជាមេទ័ពកំពូល និងចាត់ទុកជាដៃស្តាំរបស់ព្រះអង្គ បានធ្វើ រដ្ឋប្រហារផ្តួលរំលំ ហើយបង្កើតរបបគ្រប់គ្រង ថ្មីមួយតាមបែបប្រជាធិបតេយ្យសេរី ក្រោម ការជួយឧបត្ថម្ភគាំទ្រទាំងស្រុងពីសហរដ្ឋអាមេរិក គឺរបបសាធារណរដ្ឋខ្មែរជំនួសវិញ ខណៈភ្លើងសង្គ្រាមក៏ចាប់ផ្តើម ឆាបឆេះប្រទេសកម្ពុជា យ៉ាងសន្ធោសន្ធៅ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបសាធារណរដ្ឋខ្មែរ ត្រូវដួលរលំដោយ សារចាញ់សង្គ្រាម។ មេដឹកនាំខ្មែរក្រហម ប៉ុល ពត ឡើងកាន់អំណាច បានបង្កើតរបប គ្រប់គ្រងតាមបែបកុម្មុយនិស្ត ម៉ៅ សេទុង ថ្មីមួយទៀត គឺរបបកម្ពុជាប្រជាធិបតេយ្យ ដែល របបនេះគ្មានអ្វី ក្រៅតែការកាប់សម្លាប់ពូជសាសន៍ខ្លួនឯងដ៏មហាព្រៃផ្សៃនោះឡើយ។

នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បើកការវាយលុកតែប៉ុន្មានថ្ងៃប៉ុណ្ណោះ រំដោះបានទីក្រុងភ្នំពេញ របបកម្ពុជាប្រជាធិបតេយ្យ ត្រូវដួលរលំប្រទេសជាតិយើងបាន ឈានដល់របត់នយោបាយថ្មីមួយទៀត គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា តាមបែប កុម្មុយនិស្តសហភាពសូវៀត ហើយរបបកុម្មុយនិស្តមួយនេះ បានប្តូរឈ្មោះថា រដ្ឋកម្ពុជា វិញ នៅក្នុងឆ្នាំ១៩៨៩ ខណៈកងទ័ពវៀតណាម បានដកថយពីកម្ពុជាវិញ ហើយភ្នក់ភ្លើង សង្គ្រាមរវាងភាគីរដ្ឋកម្ពុជា (ហ៊ុន សែន) និងរដ្ឋាភិបាល ចម្រុះត្រីភាគី (សីហនុ, សឺន សាន, ប៉ុល ពត)នៅភាគខាងលិចប្រទេស មិនទាន់បាត់ហុយផ្សែងនៅឡើយ។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដោយមានការជួយជ្រោមជ្រែងពីសហគមន៍ អន្តរ-ជាតិផង ភាគីជម្លោះខ្មែរ បានឈានដល់កិច្ចព្រមព្រៀងសន្តិភាព ក្រុងប៉ារីស ។

រឿងរ៉ាវពិតនៃព្រឹត្តិការណ៍របត់នយោបាយខាងលើនេះ មានជនមួយចំនួន ពិសេស

ពួកអ្នកនយោបាយ យកមកក្លែងបំភ្លៃបំប៉ោងប្រតិដ្ឋតៗគ្នា ប្រាសចាកពីការពិតទាំងស្រុង។

ប្រការនេះ ធ្វើឲ្យប្រជាពលរដ្ឋខ្មែរយើងមួយចំនួន លង់គំនិតជឿតាម ដោយគ្មានការពិចារណារកហេតុផលឬសគល់ឱ្យបានគ្រប់ជ្រុងជ្រោយ បង្កជាការស្អប់ខ្ពើម ការរើសអើង ការចោទប្រកាន់ ការលាបពណ៌គ្នា ការប្រមាថមាក់ងាយទៅលើមេដឹកនាំប្រទេស និងឥស្សរជនសម័យមុនៗ ក៏ដូចជាសម័យបច្ចុប្បន្នផងដែរ។

ដូច្នេះ ដើម្បីជាពន្លឺខ្លះៗនៅក្នុងការពិចារណា ដើម្បីរកហេតុផល និងឫសគល់នៃព្រឹត្តិការណ៍នយោបាយសំខាន់ៗ ដែលកើតមានឡើងតាំងពីសម័យអាណានិគមបារាំង ពិសេសចាប់ពីសម័យសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ រហូតដល់សម័យហ៊ុន សែន បច្ចុប្បន្ននេះ ខ្ញុំបាទបានព្យាយាមសិក្សាស្រាវជ្រាវឯកសាររបស់បរទេស និងខ្មែរ អស់រយៈពេលជាច្រើនឆ្នាំ ទម្រាំចងក្រងបានជាសៀវភៅ របត់នយោបាយ សីហនុ - លន់ នល់ - ប៉ុល ពត - ហ៊ុន សែន នេះឡើង។

ពិសេស **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមេដឹកនាំប្រកបដោយគតិបណ្ឌិត បានជួយឧបត្ថម្ភគាំទ្រក្នុងការបោះពុម្ពសៀវភៅនេះ ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រមួយសម្រាប់ប្រជាពលរដ្ឋខ្មែរយើងគ្រប់មជ្ឈដ្ឋាន ប្លឹងថ្លែង ពិចារណាតាមការគួរ។

ជាមួយគ្នានេះដែរ ប្រសិនបើមានការខ្វះខាតខុសឆ្គងលើសលស់ត្រង់ចំណុចណាមួយ ក៏សូមមេត្តាខន្តីអភ័យទោស ដោយក្តីអនុគ្រោះ៕

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២

អ្នកសិក្សាស្រាវជ្រាវ

ឈឹម សេរីភ្លែន

មាតិកា

●៣៦ សឺង ង៉ុកថាញ់ ចូលស្រុកវិញ 1
●៣៧ សឺង ង៉ុកថាញ់ រត់ទៅតស៊ូនៅភ្នំដងរែក.....12
●៣៨ ឡឹក សំអឿន ចេញដំណើរទៅតស៊ូនៅភ្នំដងរែក 17
●៣៩ ដំណើរតស៊ូកាត់ព្រៃភ្នំ ពីស្រុកបារាយណ៍ ទៅជំរំចុងកាល់ 21
●៤០ ប៉ក់ មេខ្មែរឥស្សរៈឈ្មោះ រីម៉ែន កេណ្ឌផែនដី ឥសីអគ្គិនេត្រក្រឡេកឆេះ..... 25
●៤១ ឡឹក សំអឿន ឡើងឋានៈជាមេបញ្ជាការភាគឧត្តរទិស 30
●៤២ ឡឹក សំអឿន ដើរយោសនាផង និងរៃអង្គាសប្រាក់ផង 35
●៤៣ ព្រះមហាក្សត្រសីហនុ រំលាយរាជរដ្ឋាភិបាល និងរដ្ឋសភា 42
●៤៤ សឺង ង៉ុកមិញ ពង្រឹងកម្លាំងតស៊ូ យុទ្ធជនប៉ែន សុវណ្ណ ត្រូវរបួស 52
●៤៥ សឺង ង៉ុកថាញ់ ចុះកិច្ចព្រមព្រៀងជាមួយសឺង ង៉ុកមិញ..... 57
●៤៦ ឆ្នាំ១៩៥២ ហ៊ុន សែន ចាប់កំណើត.....61
●៤៧ មេខ្មែរឥស្សរៈ ប្រាប់ប្រជារាស្ត្រថា កុំជឿតាមការសន្យារបស់សម្តេចសីហនុ.....64
●៤៨ និស្សិតខ្មែរនៅប្រទេសបារាំង និងលទ្ធិម៉ាក្សនិយម 69
●៤៩ សាឡុត ស សរសេរបទវិភាគ៖ "រាជាធិបតេយ្យ ឬប្រជាធិបតេយ្យ?" 77
●៥០ ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ 85
●៥១ បារាំងថា ការទាមទារឯករាជ្យ មិនសមស្របតាមកាលៈទេសៈ 91
●៥២ បើបារាំងមិននៅជួយការពារ កម្ពុជានឹងធ្លាក់ទៅក្នុងកណ្តាប់ដៃពួកកុម្មុយនិស្ត ..96
●៥៣ មេខ្មែរឥស្សរៈ ពុត ឆាយ ចុះចូលក្នុងសង្គមជាតិវិញ.....103
●៥៤ ថៃ ចាត់ទុកថា ព្រះមហាក្សត្រសីហនុ ជាជននិរទេស.....107
●៥៥ សឺង ង៉ុកថាញ់ មិនព្រមមកចូលរួមជាមួយ ព្រះមហាក្សត្រសីហនុ 110
●៥៦ បារាំងមិនខ្លាចព្រះមហាក្សត្រសីហនុ ទេ គឺខ្លាចពួកវៀតមិញ 116
●៥៧ អនុប្រធានាធិបតី រីឆាដ និចសុន មកបំពេញទស្សនកិច្ចនៅកម្ពុជា.....122

●៥៨ កម្ពុជា ទទួលបានឯករាជ្យបរិបូណ៌ 126
●៥៩ ពួកខ្មែរឥស្សរៈ និងពួកវៀតមិញ មិនទទួលស្គាល់ឯករាជ្យ ថ្ងៃទី៩វិច្ឆិកា 132
●៦០ ទ្រង់ចន្ទរង្សី ចុះចូលជាមួយរាជរដ្ឋាភិបាល 135
●៦១ ជូ អេនឡាយ មិនឱ្យទ័ពវៀតមិញ ២កងពលទៀត ចូលមកក្នុងទឹកដីកម្ពុជា... 139
●៦២ សង្គ្រាមនៅឧៀនបៀនកូ 143
●៦៣ មេបញ្ជាការកងទ័ពបារាំង បាក់ស្មារតី 148
●៦៤ មេទ័ពវៀតមិញ រំ ង្វៀងយ៉ាប់ បញ្ជាឱ្យជីករូងក្រោមដី 153
●៦៥ ជោគជ័យនៅឧៀនបៀនកូ 158
●៦៦ សង្គ្រាមនៅឧបទ្វីបកូរ៉េ 162
●៦៧ កូរ៉េទាំងពីរ ឈ្លានពានគ្នាទៅវិញទៅមក 166
●៦៨ ជម្លោះនៅឧបទ្វីបកូរ៉េ នៅតែគ្មានដំណោះស្រាយ 170
●៦៩ សន្និសីទក្រុងហ្សឺណែវ សម សារី ឡើងជំទាស់នឹង ផាំ វ៉ាន់ដុង 175
●៧០ ផាំ វ៉ាន់ដុង នៅតែទាមទារឱ្យ ម៉ី ផូ និងកែវ មុនី ជាតំណាងភាគីខ្មែរឥស្សរៈ.... 180
●៧១ ទេព ផន សុំឱ្យដកចេញ ទាំងកងទ័ពវៀតមិញ ទាំងកងទ័ពបារាំង 182
●៧២ ប្រទេសលោកខាងលិច មិនទទួលស្គាល់ចលនាតស៊ូខ្មែរឥស្សរៈ
និងចលនាតស៊ូប៉ាថេតឡាវ 185
●៧៣ កម្ពុជា សន្យាប្រកាន់នយោបាយអព្យាក្រឹត 189
●៧៤ ចិន ខ្លាចអាមេរិក បង្កើតមូលដ្ឋានកងទ័ព នៅកម្ពុជា និងឡាវ 193
●៧៥ ពិធីចុះហត្ថលេខា លើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ 200
●៧៦ សហរដ្ឋអាមេរិក អូសទាញកម្ពុជា ឱ្យចូលអង្គការសេអាតូ (SEATO) 206
●៧៧ ប៉ែន សុវណ្ណ និងខ្មែរឥស្សរៈជាង១០០០នាក់
ចេញទៅជាមួយកងទ័ពវៀតមិញ 212
●៧៨ សម្តេចសីហនុ មិនព្រមឱ្យ សឺង ង៉ុកថាញ់ ចូលជួប 216

●៧៩ ព្រះមហាក្សត្រសីហនុ យាងទៅបំពេញព្រះរាជទស្សនកិច្ច
នៅប្រទេសថៃ និងភូមា ឆ្នាំ១៩៥៤ 222
●៨០ សម សារី បង្កឱ្យរាំងស្ទះដល់កិច្ចប្រជុំ សន្និសីទចតុភាគី
ស្តីពីបញ្ហារូបិយវត្ថុនៅឥណ្ឌូចិន 227
●៨១ កែវ មាស, នង សួន, និងប៉ែន យុទ្ធ បង្កើតគណបក្សប្រជាជន..... 230
●៨២ កេង វ៉ាន់សាក់ និងជួន មុម្ម ក្លាយជាមនុស្សសំខាន់
របស់គណបក្សប្រជាធិបតេយ្យ 234
●៨៣ គណបក្សប្រជាធិបតេយ្យ ចុះឃោសនារកសំឡេងឆ្នោត.....239
●៨៤ មូលហេតុអ្វី គណបក្សប្រជាធិបតេយ្យ ធ្លាប់តែឈ្នះឆ្នោត បែរជាត្រូវបរាជ័យ ? .. 243
●៨៥ គម្រោងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវបរាជ័យ.....248
●៨៦ ព្រះមហាក្សសីហនុ ប្រកាសដាក់រាជ្យ បង្កើតចលនាសង្គមរាស្ត្រនិយម 252
●៨៧ ក្រោយពីជួបនាយករដ្ឋមន្ត្រីឥណ្ឌា ព្រះមហាក្សត្រសីហនុ
ប្រកាន់យកគោលជំហរអព្យាក្រឹត..... 255
●៨៨ សឺង ង៉ុកថាញ់ រៀបផែនការបង្កអសន្តិសុខ.....259
●៨៩ អំពើក្បត់របស់មេក្រុមឈ្មោះ ស្វី អឿន 266
●៩០ ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ត្រូវរលាយទាំងស្រុង.....272
●៩១ សម្តេចសីហនុ ជួប ជូ អេនឡាយ ជាលើកដំបូង.....277
●៩២ យុទ្ធនាការឃោសនា កេង វ៉ាន់សាក់ រងការបាញ់ប្រហារ..... 280
●៩៣ ចលនាសង្គមរាស្ត្រនិយមឈ្នះឆ្នោត ទទួលបានអាសនៈក្នុងសភា ៩១លើ៩១ .. 284
●៩៤ សម សារី ឡើងតំណែង ឧបនាយករដ្ឋមន្ត្រី បានតែ៣ខែ 289
●៩៥ សភាឯកបក្សរបស់សង្គមរាស្ត្រនិយម ធ្វើអ្វីបានតាមចិត្ត.....293
●៩៦ ហ្វីលីពីន អូសទាញសម្តេចសីហនុ ឱ្យចូលអង្គការសេអាតូ 297

ក្បាច
សឺង ង៉ុកថាញ់ ចូលស្រុកវិញ



ប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល (Vincent Auriol)

ក្រោយពីត្រលប់មកគ្រប់គ្រងប្រទេសខ្មែរវិញ បារាំង បានចាប់នាយករដ្ឋមន្ត្រី សឺង ង៉ុកថាញ់ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៤៥ បញ្ជូនទៅទីក្រុងព្រៃនគរ ហើយតុលាការបារាំង នៅទីនោះ បានផ្តន្ទាទោសគាត់ជាក់ពន្ធនាគាររយៈពេល២០ឆ្នាំ និងបង្ខំឱ្យធ្វើការជាទម្ងន់។

តែព្រះមហាក្សត្រសីហនុ បានស្នើសុំបន្ធូរបន្ថយទោសរបស់គាត់ ដោយគ្រាន់តែសុំឱ្យនិរទេសគាត់ ទៅប្រទេសបារាំង និងសុំឱ្យគ្រាន់តែឃុំខ្លួនគាត់ នៅក្នុងលំនៅឋានមួយដែលមានការយាមកាមជាធម្មតាប៉ុណ្ណោះ។

នៅពេលមានការចុះហត្ថលេខាលើសន្ធិសញ្ញា ជាមួយបារាំងក្នុងឆ្នាំ១៩៤៩ ព្រះអង្គក៏បានឆ្លៀតឱកាសធ្វើព្រះរាជសារស្នើសុំទៅអគ្គទេសាភិបាលបារាំង, ទៅរដ្ឋមន្ត្រីទទួលបន្ទុកទំនាក់ទំនងជាមួយសមាគតរដ្ឋ(រដ្ឋដែលស្ថិតនៅក្រោមការត្រួតត្រា)របស់បារាំង និងទៅប្រធានាធិបតីបារាំង ចំនួន៤ដង ជាបន្តបន្ទាប់ ដើម្បីស្នើសុំឱ្យបារាំង លើកលែងទោសសឺង ង៉ុកថាញ់ ទាំងស្រុង និងឱ្យគាត់បានវិលត្រលប់មកមាតុប្រទេសវិញ។

ព្រះមហាក្សត្រសីហនុ បានលើកហេតុផលនៃការសុំសម្រាលទោសនោះថា ដោយសារ សឺង ង៉ុកថាញ់ ធ្លាប់ជានាយករដ្ឋមន្ត្រីរបស់ព្រះអង្គនៅក្នុងឆ្នាំ១៩៤៥ (ពីខែសីហា ដល់ខែតុលា) ពិសេស គាត់ជាមនុស្សជិតស្និទ្ធជាមួយព្រះមាតា និងព្រះបិតា ព្រមទាំងព្រះអយ្យកោ នរោត្តម សុធារស រៀងព្រះអង្គ ផងដែរ។

ព្រះរាជសារទី១ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៤៩ មហាក្សត្រសីហនុ ផ្ញើជូនស្នងការនៃសាធារណរដ្ឋបារាំង ប្រចាំប្រទេសកម្ពុជា មានខ្លឹមសារជាអាទិថាៈ ព្រះអង្គសូមផ្ញើជូនលិខិតចម្លងមួយច្បាប់របស់សឺង ង៉ុកថាញ់ ដែលបានស្នើសុំអនុញ្ញាតវិលត្រលប់មកប្រទេសកម្ពុជាវិញ ក្នុងពេលឆាប់ៗ តាមដែលអាចធ្វើទៅបាន ហើយគាត់សន្យាថា នឹងឈប់ធ្វើសកម្មភាពនយោបាយទាំងអស់។

ក្នុងករណីបានវិលត្រលប់មកមាតុប្រទេសវិញ គាត់ស្នើសុំឱ្យរាជរដ្ឋាភិបាល បើកប្រាក់ខែរម្លឹក(ប្រាក់ខែអ៉ាប់ប៉ែល)សរុប រយៈពេល៦ឆ្នាំ គឺគិតចាប់តាំងពីពេលដែលគាត់ត្រូវចាប់បញ្ជូនយកទៅឃុំឃាំង នៅប្រទេសបារាំង ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៥១ ឡើងវិញផង ដើម្បីយកទៅជួយផ្គត់ផ្គង់ដល់ជីវភាពគ្រួសារគាត់ ដែលកំពុងជួបការលំបាកខ្វះខាត។

ចុងក្រោយនៃព្រះរាជសារនេះ ព្រះមហាក្សត្រសីហនុ បានស្នើសុំឱ្យស្នងការនៃសាធារណរដ្ឋបារាំង ប្រចាំប្រទេសកម្ពុជា ជួយអន្តរាគមន៍ទៅរដ្ឋាភិបាលបារាំង ដើម្បីឱ្យ សឺង ង៉ុកថាញ់ បានវិលត្រលប់មកមាតុភូមិវិញ តាមការស្នើសុំរបស់គាត់ផង។

ចំណែក សឺង ង៉ុកថាញ់ ក៏បានសរសេរលិខិតមួយ ពីទីក្រុងប៉ារីស មកថ្វាយព្រះមហាក្សត្រសីហនុ ដោយគាត់បានសម្តែងនូវការគោរពដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះអង្គ និងសូមសម្តែងនូវកតវេទិតាចំពោះព្រះករុណា ដែលបានជួយធ្វើអន្តរាគមន៍ ដើម្បីឱ្យបារាំងដោះលែងគាត់ឱ្យបានរួចពីការឃុំឃាំង នៅក្នុងគេហដ្ឋាន នៅទីក្រុងប៉ារីស។

ជាមួយគ្នានោះ គាត់ក៏សូមស្នើព្រះមហាក្សត្រ ជួយធ្វើអន្តរាគមន៍បន្តទៀត ឱ្យគាត់បានវិលត្រលប់មកប្រទេសកម្ពុជាវិញ ដើម្បីចាប់ផ្តើមកសាងជីវិតថ្មី ជាមួយប្រពន្ធកូន ហើយគាត់បានសន្យាថា នឹងឈប់ធ្វើសកម្មភាពនយោបាយអ្វីទាំងអស់ ផងដែរ។

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៩ សឺង ង៉ុកថាញ់ បានសរសេរលិខិតមួយទៀតថ្លែងអំណរព្រះគុណដល់ព្រះមហាក្សត្រសីហនុ។ នៅក្នុងលិខិតនោះ គាត់បានទូលព្រះអង្គថា បន្ទាប់ពីគាត់បានទទួលព្រះរាជសារចម្លងរបស់ព្រះករុណាចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៤៩ ដែលផ្ញើទៅជូនលោកស្នងការនៃសាធារណរដ្ឋបារាំង ប្រចាំប្រទេសកម្ពុជា ស្តីពីការស្នើសុំរបស់គាត់ ដើម្បីដោះលែងគាត់ឱ្យបានរួចពីការឃុំឃាំង នៅក្នុងគេហដ្ឋាននាទីក្រុងប៉ារីស នោះមកថ្ងៃនេះ គាត់បានទទួលលិខិតជូនដំណឹងមួយ ស្តីពីឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរបស់រដ្ឋាភិបាលបារាំង បានសម្រេចដោះលែងគាត់ចេញពីការរស់នៅដោយបង្ខំ នៅក្នុងលំនៅឋាននោះវិញ ហើយគាត់ត្រូវបានគេអនុញ្ញាតឱ្យធ្វើដំណើរដោយសេរី នៅក្នុងប្រទេសបារាំង ទៀតផង។

សឺង ង៉ុកថាញ់ បានសម្តែងនូវកតវេទិតាដ៏ខ្ពង់ខ្ពស់ចំពោះព្រះករុណា ដែលបានជួយធ្វើអន្តរាគមន៍ដោយស្និតស្នាញ រហូតអាជ្ញាធរបារាំង ព្រមដោះលែងគាត់ដែលជាអ្នកដែលបម្រើព្រះរាជាណាចក្រកម្ពុជា និងព្រះមហាក្សត្រដោយស្មោះត្រង់ ឱ្យមានសេរីភាពវិញ។

ព្រះរាជសារទី២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៥០ ព្រះមហាក្សត្រសីហនុ ផ្ញើជូនលោកស្នងការបារាំង ប្រចាំប្រទេសកម្ពុជា មានខ្លឹមសារជាអាទិ៍ថា ព្រះអង្គសូមអំពាវនាវជាថ្មីម្តងទៀតចំពោះលោកស្នងការ ស្តីពីបញ្ហាអតីតនាយករដ្ឋមន្ត្រីសឺង ង៉ុកថាញ់ សូមលោកមេត្តាស្នើទៅលោកស្នងការជាន់ខ្ពស់បារាំង ប្រចាំនៅឥណ្ឌូចិន ដើម្បីឱ្យលោកជួយធ្វើអន្តរាគមន៍ទៅរដ្ឋាភិបាលបារាំង សុំឱ្យលើកលែងទោសចំពោះសឺង ង៉ុកថាញ់ ទាំងស្រុង។

ក្នុងព្រះរាជសារទី២នេះ ព្រះអង្គបានរម្លឹកលោកស្នងការបារាំង ប្រចាំប្រទេសកម្ពុជាថា ករណីស្នើសុំលើកលែងទោសនេះ ត្រូវបានពិនិត្យរួចហើយ នៅក្នុងអំឡុងពេលព្រះអង្គយាងទៅបំពេញទស្សនកិច្ច នៅក្រុងប៉ារីស កន្លងមកនេះ ដែលពេលនោះ រដ្ឋាភិបាលបារាំងបានយល់ព្រមឈប់ឱ្យមានការតាមឃ្លាំមើលសឺង ង៉ុកថាញ់ ទៀតហើយ។ ឯសឺង ង៉ុកថាញ់វិញ ក៏បានសន្យាថា នៅពេលវិលត្រលប់មកមាតុប្រទេសវិញ គាត់នឹងបោះបង់ចោលជាស្ថាពរ នូវគ្រប់សកម្មភាពនយោបាយទាំងអស់។

ក្នុងព្រះរាជសារទី២នេះដែរព្រះអង្គបញ្ជាក់ថាព្រះអង្គឈ្វេងយល់ថាព្រះរាជាណាចក្រកម្ពុជា ត្រូវការចាំបាច់នូវវីរជនដែលមានសមត្ថភាព ហើយព្រះអង្គជឿជាក់ថា ពេលសឺង ង៉ុកថាញ់ ត្រលប់មកវិញ គាត់នឹងមិនធ្វើសកម្មភាពអ្វីបន្តទៅទៀត ដែលនាំឱ្យខាតបង់ដល់ផលប្រយោជន៍របស់ប្រទេសបារាំង និងសហភាពបារាំង ឬបង្កឧបសគ្គអ្វីមួយដល់រដ្ឋាភិបាលកម្ពុជា នោះដែរ។

នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ សឺង ង៉ុកថាញ់ បានសរសេរលិខិតមួយស្នើឱ្យព្រះមហាក្សត្រសីហនុ ជួយធ្វើអន្តរាគមន៍ ដើម្បីឱ្យមានការដោះលែងគាត់ដោយគ្មានលក្ខខណ្ឌ និងបានវិលត្រលប់មកមាតុប្រទេសវិញ ដោយគាត់បានធានាអះអាងពីទឹកចិត្តស្វាមីភក្តិរបស់គាត់ចំពោះព្រះអង្គ ជាថ្មីម្តងទៀតផងដែរ។

ព្រះរាជសារទី៣ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ ព្រះមហាក្សត្រសីហនុ ផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទំនាក់ទំនងជាមួយសមាគតរដ្ឋ មានខ្លឹមសារដោយសង្ខេបថា ជាច្រើនលើកមកហើយ ដែលព្រះអង្គបានធ្វើអន្តរាគមន៍សុំឱ្យអាជ្ញាធរបារាំង លើកលែងទោសចំពោះសឺង ង៉ុកថាញ់ ពិសេស នៅដើមឆ្នាំ១៩៥០ខាងមុខនេះ សូមឱ្យអាជ្ញាធរបារាំង មេត្តាលើកលែងទោសទាំងស្រុងទៅលើវីរជនកម្ពុជា រូបនេះ។

ព្រះអង្គសង្ឃឹមថា ពេលវេលាបានមកដល់ហើយ ដើម្បីរម្លឹកឡើងវិញ ពីបញ្ហាស្នើសុំឱ្យសឺង ង៉ុកថាញ់ បានវិលត្រលប់មកកម្ពុជា វិញ ដោយឥតលក្ខខណ្ឌ។ ព្រះអង្គជឿជាក់ថាការទុកចិត្តគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងសឺង ង៉ុកថាញ់ នោះ ត្រូវបានវាយតម្លៃជាពិសេសដោយប្រជារាស្ត្រកម្ពុជា ទាំងអស់។

ជាមួយគ្នានោះ ព្រះអង្គក៏សូមសម្តែងនូវក្តីសង្ឃឹម និងដឹងគុណចំពោះរដ្ឋមន្ត្រីបារាំងទទួលទំនាក់ទំនងជាមួយសមាគតរដ្ឋថា លោកនឹងជួយដោះស្រាយបញ្ហានេះឱ្យបានសម្រេចផងដែរ។

ព្រះរាជសារទី៤ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៥១ ព្រះមហាក្សត្រសីហនុ ផ្ញើជូនប្រធានាធិបតីបារាំង មានខ្លឹមសារជាអាទិថា លោកប្រធានាធិបតី! ខ្ញុំសូមអំពាវនាវជាថ្មី

សូមលោកប្រធានាធិបតីមេត្តាសន្តោសប្រណីរលើកលែងទោសទាំងស្រុងចំពោះសឺង ង៉ុកថាញ់ និងសុំឱ្យគាត់បានវិលត្រលប់មកប្រទេសកម្ពុជា វិញ។

ព្រះអង្គបានបញ្ជាក់នៅក្នុងព្រះរាជសារទី៤នោះថា សំណុំរឿងរបស់សឺង ង៉ុកថាញ់ បានផ្ញើជូនលោកប្រធានាធិបតីរួចហើយ តាមឋានានុក្រម នៅដំណាច់ខែធ្នូ ឆ្នាំ១៩៥០ ហើយព្រះអង្គបានយកបញ្ហានេះជម្រាបជូនលោករដ្ឋមន្ត្រី ទទួលបន្ទុកទំនាក់ទំនងជាមួយសមាគតរដ្ឋ តាមរយៈលិខិតចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ រួចហើយដែរ។

តបតាមការស្នើសុំម្តងហើយម្តងទៀតរបស់ព្រះមហាក្សត្រនរោត្តម សីហនុ រដ្ឋាភិបាលបារាំង ក៏បានអនុញ្ញាតឱ្យសឺង ង៉ុកថាញ់ វិលត្រលប់មកប្រទេសកម្ពុជា វិញ។

តែមជ្ឈដ្ឋានខ្លះ យល់ថា ក្រោយពេលសឺង ង៉ុកថាញ់ បានវិលត្រលប់មកមាតុប្រទេសវិញ គាត់អាចរម្ងាប់ចិត្តបានខ្លះ ក្នុងការប្រឆាំងនឹងបារាំង និងព្រះមហាក្សត្រសីហនុ ព្រមទាំងអាចធ្វើឱ្យគណបក្សប្រជាធិបតេយ្យ កាន់តែមានការរង្គោះរង្គើបែកបាក់ ចុះខ្សោយថែមទៀតផងដែរ។

នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៥១ ពេលសឺង ង៉ុកថាញ់ ធ្វើដំណើរមកដល់មាតុប្រទេសវិញ មានមនុស្សរាប់ម៉ឺននាក់នាំគ្នាភ្លូកទឹកភ្លូកដីទៅទទួលស្វាគមន៍គាត់ នៅអាកាសយានដ្ឋានពោធិ៍ចិនតុង និងតាមសងខាងផ្លូវ ចូលមកកណ្តាលទីក្រុងភ្នំពេញ។

ពួកគេចាត់ទុកសឺង ង៉ុកថាញ់ ជាវីរបុរសស្នេហាជាតិ សូម្បីតែហ៊ុយ កន្ទុល ជានាយករដ្ឋមន្ត្រី ព្រមទាំងសមាជិកគណៈរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាធិបតេយ្យទាំងអស់ ក៏នាំគ្នាជិះរថយន្តប្រមាណ៣០០គ្រឿងទៅហែហមសឺង ង៉ុកថាញ់ យ៉ាងអធិកអធមបំផុតដែរ។

នៅសម័យនោះពុំសូវមានរថយន្ត និងមនុស្សច្រើនប៉ុន្មានទេ ក្នុងចម្ងាយប្រមាណជាង១០គីឡូម៉ែត្រ ពីអាកាសយានដ្ឋានពោធិ៍ចិនតុង មកដល់ក្រុងភ្នំពេញ ដែលធម្មតា ការធ្វើដំណើរតាមរថយន្ត ត្រូវចំណាយពេលប្រមាណតែ១០នាទីប៉ុណ្ណោះ ប៉ុន្តែ នៅពេលនោះក្បួនរថយន្តដង្ហែ សឺង ង៉ុកថាញ់ បានចំណាយពេលប្រមាណជាង១ម៉ោងឯណោះ។

របត់នយោបាយ

នៅថ្ងៃដែលសឹង ង៉ុកថាញ់ ត្រលប់មកដល់មាតុភូមិប្រទេសវិញនោះ ក៏មានហេតុការណ៍ភ្ញាក់ផ្អើលមួយ ដោយស្នងការជាន់ខ្ពស់បារាំង ប្រចាំប្រទេសកម្ពុជា ហ្សង់ ឡេអុង ដឺ រ៉ាយម៉ុង (Jcan Leon de Raymond) ត្រូវអ្នកបម្រើជាជនជាតិវៀតណាម លួចធ្វើឃាត។ ឃាតករជាអ្នកបម្រើជាជនជាតិវៀតណាមនេះ ត្រូវបានគេសង្ស័យជាកម្លាំងបង្កប់របស់ពួកវៀតមិញ។



ផ្នូវពីអាកាសយានដ្ឋានពោធិ៍ចិនតុង ចូលមកក្រុងភ្នំពេញ សម័យមុន

ក្រោយពីបានដឹងរឿងឃាតកម្មនេះ ទា ឆាយ តំណាងរាស្ត្រ នៅមណ្ឌលជ្រៃវៀន ខេត្តកំពង់ចាម ដែលជាអ្នកជួយការពារសន្តិសុខដំណើរមាតុភូមិនិវត្តន៍របស់សឺង ង៉ុកថាញ់ តាមផ្លូវពីអាកាសយានដ្ឋានពោធិ៍ចិនតុង ចូលមកក្រុងភ្នំពេញ បានបបួលតំណាងរាស្ត្រ ម្នាក់ទៀត នៅមណ្ឌលកណ្តោលជ្រុំ ខេត្តកំពង់ចាម ឈ្មោះង៉ែត ហៀន កំពុងអង្គុយនៅក្នុង រថយន្តជាមួយគ្នា ទៅមើលសាកសពស្នងការជាន់ខ្ពស់បារាំង នោះដែរ តែ ង៉ែត ហៀន បដិសេធថា ពួកយើងជាអ្នកនយោបាយ កុំទៅមើលធ្វើអ្វី ខ្លាចគេសង្ស័យ នាំអំពល់ទុក្ខ អត់ប្រយោជន៍។ ម្យ៉ាងគណបក្សបានប្រគល់ភារកិច្ចឱ្យយើងជួយមើលការខុសត្រូវ ក្នុងការ ការពារសន្តិសុខដល់សឺង ង៉ុកថាញ់ ផងដែរ។

ពេលនោះ តំណាងរាស្ត្រ ទា ឆាយ ក៏យល់ព្រម ហើយគាត់ក៏និយាយទៅកាន់ តំណាងរាស្ត្រ ង៉ែត ហៀន ថា សឺង ង៉ុកថាញ់ ជាមនុស្សមានបុណ្យអស្ចារ្យណាស់ ព្រោះនេះ ជាប្រផ្នូលល្អ ដោយពួកវៀតមិញ ចេះរើសថ្ងៃសម្លាប់ស្នងការជាន់ខ្ពស់បារាំង ចំថ្ងៃដែលសឺង ង៉ុកថាញ់ ត្រូវមានសេរីភាព មកធ្វើនយោបាយវិញ។ ម្តងនេះខ្ញុំជឿថា ប្រទេសយើងពិតជា បានឯករាជ្យបរិបូរណ៌ហើយ។

តំណាងរាស្ត្រ ង៉ែត ហៀន ក៏តបវិញថា នេះគ្រាន់តែជាជំនឿតាមផ្លូវចិត្តរបស់លោក ប៉ុណ្ណោះ តែការពិត មិនទាន់បង្ហាញឱ្យយើងឃើញនៅឡើយទេ។

នៅក្នុងរថយន្ត ពួកគាត់និយាយគ្នាបណ្តើរ និងមើលសភាពការណ៍ ដើម្បីការពារ សន្តិសុខបណ្តើរ ចាប់ពីក្រុងភ្នំពេញ រហូតដល់អាកាសយានដ្ឋានពោធិ៍ចិនតុង។ ពេលទៅ ដល់អាកាសយានដ្ឋានពោធិ៍ចិនតុង ពួកគាត់ពុំទាន់ឃើញមានវត្តមានមន្ត្រីជាន់ខ្ពស់ណាម្នាក់ នៅឡើយ។

មួយសន្ទុះក្រោយមក ទើបឃើញ ប៉ែន នុត ដែលធ្លាប់កាន់តំណែងជានាយករដ្ឋមន្ត្រី កាលពីខែកុម្ភៈ ឆ្នាំ១៩៤៩ បានអញ្ជើញដល់ ។

មន្ត្រីគ្រប់លំដាប់ថ្នាក់ និងប្រជារាស្ត្រគ្រប់មជ្ឈដ្ឋាន បាននាំគ្នាមកទទួល សឺង ង៉ុក ថាញ់ កាន់តែច្រើនឡើងៗណែនណាន់តាន់តាប់។ តែដល់ម៉ោងត្រូវមកដល់ហើយ មិន

ឃើញយន្តហោះមកសោះ តំណាងរាស្ត្រ ទា ឆាយ មានការព្រួយបារម្ភជាខ្លាំងថា ដូចជាចម្លែកណាស់ ប្រហែលបារាំង ចាប់សឺង ង៉ុកថាញ់ ទៅវិញ ក៏មិនដឹង? ឮដូច្នេះ ប៉ែន នុត បានប្រាប់ថា ចាប់ម្តេចកើត? យន្តហោះចេញផុតមកហើយ គ្រាន់តែយឺតដំណើរ ពេលឈប់សំចតតាមផ្លូវប៉ុណ្ណោះ កន្លះម៉ោងទៀត នឹងឃើញយន្តហោះមកដល់ហើយ។

ប្រហែលកន្លះម៉ោងក្រោយមក យន្តហោះបានមកដល់មែន សឺង ង៉ុកថាញ់ បានចេញមកមុនគេ លើកដៃសំពះមន្ត្រីគ្រប់លំដាប់ថ្នាក់ និងប្រជារាស្ត្រ ដែលមើលទៅប្រៀបដូចសមុទ្រមនុស្ស នាំគ្នាទះដៃស្វាគមន៍គាត់ ដោយក្តីរំភើបរីករាយបំផុត។

ចំពោះព្រឹត្តិការណ៍ទទួលស្វាគមន៍ការត្រលប់មកវិញ របស់សឺង ង៉ុកថាញ់ យ៉ាងអធិកអធមបំផុតនេះ គឺជាការបញ្ជាក់ឱ្យឃើញច្បាស់ថា ប្រជារាស្ត្រខ្មែរបាននាំគ្នាគាំទ្របុព្វ-ហេតុតស៊ូដណ្តើមឯករាជ្យពីបារាំង របស់សឺង ង៉ុកថាញ់ កាន់តែខ្លាំងក្លាជាងមុនទៅទៀត ហើយសូម្បីតែព្រះមហាក្សត្រសីហនុ ក៏មិននឹកស្មានថា ប្រជាប្រិយភាពរបស់មេដឹកនាំប្រឆាំងនឹងបារាំង ម្នាក់នេះ បានកើនឡើងខ្ពស់ដូចនេះសោះ។

ចំណែកពួកនិស្សិតខ្មែរ នៅឯប្រទេសបារាំង ភាគច្រើន នាំគ្នាសង្ឃឹមជឿជាក់ថា សឺង ង៉ុកថាញ់ នឹងទាមទារឯករាជ្យពីប្រទេសបារាំង ដោយជោគជ័យ ក្នុងពេលឆាប់ៗ ខាងមុខនេះជាមិនខាន។

តំណាងរាស្ត្រ ទា ឆាយ និងតំណាងរាស្ត្រ ង៉ែត ហៀន បានជិះរថយន្តដង្ហែក្បួនជូន សឺង ង៉ុកថាញ់ ដល់ខាងមុខផ្ទះនៅកណ្តាលក្រុងភ្នំពេញ ក៏បង្ហួសទៅផ្ទះពួកគាត់វិញតែម្តងទៅ។

ក្រោយពីបានចូលដល់ក្នុងគេហដ្ឋាន បានបន្តិច សឺង ង៉ុកថាញ់ បានសរសេរលិខិតមួយ ដើម្បីថ្វាយអំណរព្រះគុណចំពោះព្រះមហាក្សត្រសីហនុ ដែលបានជួយអន្តរាគមន៍ឱ្យគាត់បានវិលត្រលប់មកមាតុភូមិវិញ ក្រោយពីរស់នៅនិរទេសខ្លួន អស់រយៈពេល៦ឆ្នាំកន្លងមកនោះ ហើយគាត់ក៏បានទូលសុំចូលក្រាបបង្គំគាល់ ដើម្បីសម្តែងនូវកតញ្ញូតាធម៌ចំពោះព្រះអង្គ និងមាតុភូមិផងដែរ។

ស្អែកឡើង តំណាងរាស្ត្រ ទា ឆាយ និងតំណាងរាស្ត្រ ង៉ែត ហៀន បាននាំគ្នាមកសុំចូលជួបសម្តែងការគួរសម និងសំណេះសំណាលសួរសុខទុក្ខ សឺង ង៉ុកថាញ់។

ក្រោយពីបានស្តាប់តំណាងរាស្ត្រ ង៉ែត ហៀន រៀបរាប់ពីរឿងបោកគ្រាប់បែកសម្លាប់អៀវ កើស និងសភាពការណ៍ផ្សេងៗទៀត នៅក្នុងប្រទេសមក សឺង ង៉ុកថាញ់ បាននិយាយថា ស្តាយណាស់ ព្រោះជាតិយើងមិនចេះរួបរួមគ្នា តែបើយើងធ្វើបាននៅពេលនេះ មតិសាកលលោក ពិតជាមានការភ្ញាក់ផ្អើលជាមិនខាន។

តំណាងរាស្ត្រ ង៉ែត ហៀន បានជម្រាបសឺង ង៉ុកថាញ់ ថា ប្រទេសយើងសព្វថ្ងៃនេះ ក្រណាស់ សូមលោកនាយកមេត្តារកមធ្យោបាយជួយរាជរដ្ឋាភិបាលលោកហ៊ុយ កន្ទុល ផង ព្រោះរដ្ឋាភិបាលនេះកំពុងបន្តសកម្មភាពទាមទារឯករាជ្យបរិបូណ៌ តាមទិសដៅគណបក្សប្រជាធិបតេយ្យ ដែលមានលោកអៀវ កើស ដឹកនាំពីមុនមក។

សឺង ង៉ុកថាញ់ បានតបមកវិញថា យើងពិបាករៀបចំស្រុកទេសបន្តិចហើយ ព្រោះប្រទេសយើងមិនទាន់បានឯករាជ្យបរិបូណ៌។ បើជាតិយើងបានឯករាជ្យបរិបូណ៌ ហើយយើងធ្វើនយោបាយបានល្អត្រឹមត្រូវទៀត ជាតិយើងពិតជាគ្មានអីដែលត្រូវក្រទៀតទេ។ តែបើយើងមិនទាន់បានឯករាជ្យទេ យើងគ្មានសិទ្ធិធ្វើអ្វីបានឡើយ ហើយបារាំង មិនព្រមឱ្យបរទេសណាចូលមករកស៊ី នៅក្នុងប្រទេសយើងដែរ មានន័យថា ខេមរជាតិយើងនៅតែខ្ទុំកញ្ជះគេដដែលហ្នឹង ដូច្នេះយើងត្រូវប្រឹងតស៊ូមួយកម្រិតទៀត។

ពេលនោះ សឺង ង៉ុកថាញ់ ត្រូវគេបើកប្រាក់បៀវត្សរ៍ម្លឹក (ប្រាក់ខែរ៉ាប់ប៉ែល) រយៈពេល១០ឆ្នាំ ដែលគាត់អវត្តមានពីការងារជាមន្ត្រីបណ្ណារក្ស នៅពុទ្ធសាសនបណ្ឌិត្យ តាមការស្នើសុំរបស់គាត់ផងដែរ។

ក្រោយពេលមកដល់មាតុប្រទេសវិញ ព្រះមហាក្សត្រសីហនុ ក៏ដូចជារាជរដ្ឋាភិបាលដែលមានហ៊ុយ កន្ទុល ជានាយករដ្ឋមន្ត្រីដែរ មានបំណងឱ្យសឺង ង៉ុកថាញ់ ចូលមកកាន់តំណែងជារដ្ឋមន្ត្រីមួយរូប នៅក្នុងរដ្ឋាភិបាលដែរ តែគាត់មិនព្រមទទួលយកតំណែងជារដ្ឋមន្ត្រី នៅក្រសួងណាមួយនោះឡើយ ព្រោះពេលនោះសឺង ង៉ុកថាញ់ យល់ឃើញថា

ប្រជាប្រិយភាពរបស់គាត់បានឡើងដល់កំពូល បន្ទាប់ពីឃើញមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងប្រជារាស្ត្រខ្មែរ ភ្លូកទឹកភ្លូកដីទៅទទួលស្វាគមន៍គាត់ពីអាកាសយានដ្ឋានពោធិ៍ចិនតុង ដោយសង្ឃឹមថា វត្តមានរបស់គាត់អាចជួយដោះស្រាយបញ្ហាប្រទេសជាតិ បានដោយជោគ-ជ័យ ពិសេសបញ្ហាទាមទារឯករាជ្យពីបារាំង។

ពេលនោះ សឺង ង៉ុកថាញ់ បានក្បត់ពាក្យសន្យាជាមួយសម្តេចសីហនុ និងបារាំង ដែលថា នៅពេលបានវិលត្រលប់មកមាតុប្រទេសវិញ គាត់នឹងបោះបង់ចោលរាល់សកម្មភាព នយោបាយទាំងអស់។ គាត់ចាប់ផ្តើមសិក្សាស្វែងយល់ពីសភាពការណ៍នយោបាយរបស់ ប្រទេសជាតិ ក្នុងរយៈពេលដែលគាត់ត្រូវគេយកទៅឃុំឃាំងនៅប្រទេសបារាំង អស់រយៈ ពេល៦ឆ្នាំនោះ។ គាត់ និងសហការីជំនិតៗ ពីមុនមួយចំនួន ដូចជា ប៉ាច ឈឺន ជាអតីត អ្នកទោសគុកកោះត្រឡាច ដែលពេលនោះជារដ្ឋមន្ត្រីក្រសួងព័ត៌មាន, ប៊ុណ្ណ ចន្ទម៉ុល, អៀ ស៊ីចូវ (ទើបបញ្ចប់ការសិក្សា នៅប្រទេសបារាំង), ប៊ូ ហ៊ាង (មន្ត្រីព្រះបរមរាជវាំង), ហង្ស ធុនហាក់, អ៊ីវ យ៉ាង និងអនុសេនីយ៍ទោដួង ចន្ទសាវាត ជាដើម បាននាំគ្នាធ្វើដំណើរ ចេញទៅតាមបណ្តាខេត្តនានា ដោយយកលេសថា ពួកគាត់ទៅទាក់ទងពួកមេខ្មែរឥស្សរៈ ផ្សេងៗទៀត នៅក្នុងព្រៃ ដែលមិនមែនជាសម្ព័ន្ធមិត្តរបស់ពួកវៀតមិញ ឱ្យវិលត្រលប់មក រួបរួមក្នុងសង្គមជាតិវិញ។ តែការពិត ពួកគាត់នាំគ្នាទៅឃោសនាបំផុសប្រជារាស្ត្រ ឱ្យរួបរួម គ្នាជាមួយពួកគាត់ ដើម្បីតស៊ូទាមទារឯករាជ្យពេញលេញពីបារាំង ទៅវិញ។

សឺង ង៉ុកថាញ់ បានឃោសនាថា បញ្ហាចម្បងដែលត្រូវដោះស្រាយជាបន្ទាន់នោះ ពុំមែនគ្រាន់តែជាការទាមទារឯករាជ្យពីបារាំង ប៉ុណ្ណោះទេ គឺត្រូវចាត់វិធានការទប់ទល់នឹង ពួកវៀតមិញ ដែលកំពុងអនុវត្តផែនការរបស់គេ នៅលើទឹកដីខ្មែរ ផងដែរ។ ដូច្នេះ ខ្មែរយើង គ្រប់និន្នាការនយោបាយ ត្រូវរួមសាមគ្គីគ្នាជាធ្លុងមួយ ដូចដែលបានធ្វើសកម្មភាពប្រឆាំង បារាំង កាលពីឆ្នាំ១៩៤៥ ទើបសម្រេចបានជោគជ័យ បើពុំនោះសោត ខ្មែរយើងច្បាស់ជា ធ្លាក់ក្នុងរណ្តៅ ដែលគេជីកទុកជាមុនរួចហើយនោះ ជាមិនខាន។ យើងត្រូវមានអ្នកតស៊ូ ខាងនយោបាយនៅក្នុងស្រុកផង និងមានអ្នកតស៊ូដោយកម្លាំងអាវុធ នៅក្នុងព្រៃផង។

គាត់បញ្ជាក់ថា គាត់ពុំមែនជាសត្រូវរបស់នរណាម្នាក់ឡើយ ហើយគាត់ក៏មិនធ្វើឱ្យប្រជារាស្ត្រណាម្នាក់រងគ្រោះ ក្នុងដំណើរឆ្ពោះទៅរកឯករាជ្យនោះដែរ ប៉ុន្តែ ប្រសិនបើពួកខ្មែរឥស្សរៈ និងពួកវៀតមិញ ប្រព្រឹត្តអំពើឆក់ប្លន់មកលើប្រជារាស្ត្រ គាត់ត្រូវតែទប់ស្កាត់។

នៅទីរួមខេត្តតាកែវ ដោយមាន ហ៊ុយ កន្ទុល ជានាយករដ្ឋមន្ត្រី និងប៉ាច ឈឺន ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន អមដំណើរផងនោះ សឺង ង៉ុកថាញ់ បានឃោសនាថា យើងត្រូវតែទាមទារឱ្យបារាំង ដកកងទ័ពចេញឱ្យអស់ ទើបប្រទេសយើងមានឯករាជ្យពេញលេញ។

នៅដើមឆ្នាំ១៩៥២ សឺង ង៉ុកថាញ់ និងអៀ ស៊ីចូវ បានបង្កើតកាសែតថ្មីមួយឈ្មោះ "ខ្មែរក្រោក" សរសេរបំផុសគំនិតជាតិនិយម ឱ្យប្រជារាស្ត្រខ្មែរក្រោកឡើងតស៊ូប្រឆាំងនឹងពួកអាណានិគម។ តែនៅក្នុងបទវិចារណកថារបស់កាសែតនេះ ឆ្លុះបញ្ចាំងឱ្យឃើញជំហរផ្សេងគ្នាពីគណបក្សប្រជាធិបតេយ្យ ទៅវិញ។

កាសែតនេះចេញផ្សាយបានរយៈពេលមួយខែ ក៏ត្រូវរាជរដ្ឋាភិបាលរបស់គណបក្សប្រជាធិបតេយ្យ បិទលែងឱ្យចេញផ្សាយតទៅទៀត។

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៥២ សឺង ង៉ុកថាញ់ គ្រោងរៀបចំធ្វើបាតុកម្មមហាជនមួយ ដើម្បីទាមទារឯករាជ្យពីបារាំង តែត្រូវបារាំង រារាំងមិនឱ្យធ្វើ។

៥ថ្ងៃក្រោយមក គឺនៅថ្ងៃទី២២ ខែកុម្ភៈ ដោយសារមានការសម្របសម្រួលពីចៅហ្វាយខេត្តសៀមរាប សឺង ង៉ុកថាញ់ ក៏បានជួបប្រជុំជាសម្ងាត់ជាមួយប៉ុក គុណ ហៅតាត្រឡាច និងកៅ តក់ ជាមេឥស្សរៈ ដែលមិនមែនពួកកុម្មុយនិស្ត នៅប៉ែកខាងលិចប្រទេស។

មូលហេតុដែលអនុញ្ញាតឱ្យ សឺង ង៉ុកថាញ់ បានជួបប្រជុំជាសម្ងាត់ជាមួយជាមេឥស្សរៈ ប៉ុក គុណ ហៅតាត្រឡាច និងកៅ តក់ នេះ ដោយសារពេលនោះ ចៅហ្វាយខេត្តសៀមរាប បានដឹងថា កៅ តក់ កំពុងត្រៀមខ្លួនចុះចូលជាមួយព្រះមហាក្សត្រ ហើយដែរ។

៣៧
សឺង ង៉ុកថាញ់ រត់ទៅតស៊ូនៅភ្នំដងរែក



សឺង ង៉ុកថាញ់

នៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៥២ ជាខួប៧ឆ្នាំនៃថ្ងៃជប៉ុន ចាប់បារាំង នៅឥណ្ឌូចិន (ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥) សឺង ង៉ុកថាញ់, អៀ ស៊ីចូវ, ប៉ាច ឈឺន ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងគ្រូអាចារ្យខៀវ ដុំ ដោយនាំទាំងម៉ាស៊ីនវិទ្យុផ្សាយសំឡេងចល័តមួយគ្រឿងនៅក្រសួងព័ត៌មាន ទៅជាមួយផង បាននាំគ្នារត់ចេញពីទីក្រុងភ្នំពេញ ទៅតំបន់សំរោងចុងកាល់ ដែលជាមូលដ្ឋានរបស់ចលនាតស៊ូខ្មែរឥស្សរៈ ដឹកនាំដោយកៅ តក់ ដើម្បីរួមកម្លាំងគ្នាតស៊ូទាមទារឯករាជ្យពីបារាំង បន្តទៀត។

ពេលនោះ តំណាងរាស្ត្រទា ឆាយ បានមកបបួលតំណាងរាស្ត្រ ង៉ែត ហៀន រត់ទៅតាមសឺង ង៉ុកថាញ់ ចូលព្រៃដើម្បីតស៊ូដែរ តែតំណាងរាស្ត្រ ង៉ែត ហៀន បានបដិសេធថា ជើងគាត់ពិការ កាលគេគប់គ្រាប់បែកនៅក្នុងស្នាក់ការគណបក្សប្រជាធិបតេយ្យ ជាមួយ

អៀវ កើស នោះ មិនទាន់ជាស្រួលបួលទេ បើរត់ចូលព្រៃតស៊ូ គាត់ច្បាស់ជាត្រូវស្លាប់ជាមិនខាន។

ពេលនោះ សឺង ង៉ុកថាញ់ បានបង្កើតចលនាខ្មែរឥស្សរៈថ្មីមួយ ដោយដាក់ឈ្មោះថា ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ដោយមានរូបគាត់ជាប្រធាន, អៀ ស៊ីចូវ ជាអនុប្រធាន, លោកគ្រូអាចារ្យខៀវ ជុំ ជាសមាជិក ទទួលបន្ទុកជាអគ្គលេខាធិការ, ហង្ស ធុនហាក់ ជាសមាជិក ទទួលបន្ទុកខាងការអប់រំ និងឃោសនាការ។

នៅតំបន់សំរោងចុងកាល់ សឺង ង៉ុកថាញ់ បានធ្វើសេចក្តីអំពាវនាវមួយ ចាក់ផ្សាយតាមវិទ្យុ ដែលគាត់ឱ្យឈ្មោះថា វិទ្យុសំឡេងភ្នំដងរែក បំផុសឱ្យប្រជាពលរដ្ឋទូទាំងប្រទេសនាំគ្នាក្រោកឡើងកាន់អាវុធប្រយុទ្ធ ដើម្បីដណ្តើមយកឯករាជ្យបរិបូណ៌ពីបារាំង។ តាមការអំពាវនាវរបស់ សឺង ង៉ុកថាញ់ តាមរយៈវិទ្យុសំឡេងភ្នំដងរែក នោះ ក៏មានមន្ត្រីរាជការស៊ីវិលទាហាន និងសិស្សានុសិស្សវិទ្យាល័យ ប្រមាណ៨០នាក់ នៅក្រុងភ្នំពេញ និងខេត្តមួយចំនួន បាននាំគ្នារត់ទៅចូលរួមក្នុងចលនាតស៊ូរបស់គាត់ជាបន្តបន្ទាប់ ក្នុងនោះអនុសេនីយ៍ទោដួង ចន្ទសាវាត និងអនុសេនីយ៍ត្រីលាវ ធានស៊ី បានដឹកនាំកូនទាហានរបស់ខ្លួន១ កងអនុ-សេនាធំ ព្រមទាំងសម្ភារសឹកមួយចំនួនផងដែរ។

នៅដើមខែតុលា ឆ្នាំ១៩៥២ យុវសិស្សម្នាក់ ឈ្មោះអ៊ូ អន ដែលធ្លាប់ជាមិត្តភក្តិរៀនជាមួយគ្នា តាំងពីនៅសាលាបឋមសិក្សា ខេត្តស្វាយរៀង រហូតដល់វិទ្យាល័យព្រះស៊ីសុវត្ថិ នៅភ្នំពេញ បានបបួលឡឹក សំអឿន ឲ្យទៅចូលរួមជាមួយចលនាតស៊ូ ដែលសឺង ង៉ុកថាញ់ ទើបបង្កើតឡើង នៅភ្នំដងរែក នោះ ។ ពេលនោះ ឡឹក សំអឿន ក៏បានយល់ព្រមភ្លាម ព្រោះគាត់មានបំណងតាំងពីថ្ងៃ ដែលឮព័ត៌មានថា សឺង ង៉ុកថាញ់ រត់ចូលព្រៃ ដើម្បីតស៊ូទាមទារឯករាជ្យពីបារាំង មកម្ល៉េះ តែគាត់មិនដឹងទាក់ទងជាមួយនរណា។ អ៊ូ អន ប្រាប់ឡឹក សំអឿន ថា បើសម្រេចចិត្តលះបង់ ទៅតស៊ូហើយ មិនចាំបាច់គិតអ្វីច្រើនទេ ត្រៀមតែខ្លួនរង់ចាំតែដល់ថ្ងៃដែលត្រូវធ្វើដំណើរទៅបានហើយ។

គាប់ជួនពេលនោះ ក្រសួងវុឌ្ឍាប្រមាញ់ បានប្រកាសបើកការប្រលងជ្រើសរើស

បេក្ខជន ឲ្យចូលរៀនខាងផ្នែករុក្ខាប្រមាញ់ ឡឹក សំអឿន និងមិត្តរួមថ្នាក់២នាក់ទៀត គឺ គឹម ឆេង និងមិន សារិន ក៏បានដាក់ពាក្យប្រលងដែរ។ ក្រោយពីបានដឹងលទ្ធផលនៃការប្រលង នោះថា ពួកគាត់បានប្រលងជាប់ជាស្តាពរ ពេលវេលាដែលត្រូវធ្វើដំណើរចេញទៅតស៊ូ នៅភ្នំដងរែកនោះ ក៏កាន់តែជិតមកដល់ គាត់ក៏សម្រេចចិត្តបោះបង់មុខងារជាមន្ត្រីរាជការ ដែលគាត់បានប្រលងជាប់ហើយនោះ ចោលទៅ។ តែអ្វីដែលជាបំណងចុងក្រោយរបស់គាត់នោះ គឺត្រូវតែទៅជួបឪពុកម្តាយបងប្អូន ឯកូមិកំណើតនៅឃុំមេ.ស.ថ្ងក(មេសថ្ងក) ស្រុកស្វាយទាប (បច្ចុប្បន្នស្រុកចន្ទ្រា) ខេត្តស្វាយរៀង ដែលជាតំបន់កំពុងមានការប្រទាញប្រទង់រវាងពួកវៀតមិញ និងពួករាជការខ្មែរ-បារាំង។ អ៊ូ អន បញ្ជាក់ប្រាប់ឡឹក សំអឿន ថា យ៉ាងយូរត្រឹមមួយសប្តាហ៍ទៀតប៉ុណ្ណោះ ត្រូវចេញដំណើរហើយ បើចង់ទៅជួបឪពុកម្តាយបងប្អូន នៅឯស្រុកកំណើត អាចទៅបានយ៉ាងយូរ៥ថ្ងៃ ត្រូវត្រលប់មកឱ្យដល់ក្រុងភ្នំពេញ វិញ។ វេលាម៉ោង ៦ព្រឹក ឡឹក សំអឿន ក៏ទៅជិះរថយន្តឈ្នួល នៅក្បែរផ្សារធំថ្មី ចេញដំណើរពីភ្នំពេញទៅខេត្តស្វាយរៀង ហើយបានស្នាក់នៅទីរួមខេត្តស្វាយរៀង មួយយប់។ ស្អែកឡើង គាត់ក៏ខ្ចីម៉ូតូមិត្តកក្តិម្នាក់ ដើម្បីជិះបន្តដំណើរទៅកូមិកំណើត ព្រោះពីទីរួមខេត្តស្វាយរៀង ទៅផ្ទះរបស់គាត់មានចម្ងាយ៣៥គីឡូម៉ែត្រ ហើយក្នុងកូមិកំណើតរបស់គាត់ ក៏អសន្តិសុខ ដោយមានពួកវៀតមិញ ចេញចូលជារៀងរាល់យប់ និងគ្មានរថយន្តឈ្នួលរត់ទៅមកទៀតផង។ ដោយសារផ្លូវក្រាលក្រួសក្រហម ពីទីប្រជុំជនជីភូ ទៅកូមិកំណើតរបស់គាត់ មានជង្ហុកក្រហោងក្រហូងច្រើនពេក មិនអាចធ្វើដំណើរឱ្យបានលឿនដូចបំណង រហូតនៅវេលាម៉ោង៥ល្ងាចទើបទៅដល់ផ្ទះម្តាយឪពុករបស់គាត់ ដែលនៅចម្ងាយប្រមាណកន្លះគីឡូម៉ែត្រ ពីបន្ទាយទាហានរាជការខ្មែរ-បារាំង។

ពេលចូលទៅដល់ផ្ទះ មិនទាន់ទាំងបានអង្គុយស្រួលបួលផង ឪពុកគាត់ក៏សួរថា កូនឯងមកធ្វើអ្វី? មិនដឹងថា សព្វថ្ងៃនេះ ស្រុកកូមិយើងលុបចោលអសន្តិសុខ ពួកវៀតមិញចូលមកក្នុងកូមិស្ទើរាល់ថ្ងៃ ដើម្បីអប់រំអ្នកកូមិឱ្យជួយបម្រើកិច្ចការរបស់ពួកគេទេឬ? ឡឹក សំអឿន ក៏តបទៅឪពុកវិញថា គាត់ដឹងរឿងហ្នឹងដែរ តែគាត់ត្រូវតែមកជម្រាបម្តាយឪពុក

បងប្អូន ឱ្យបានដឹងថា គាត់បានប្រលងជាប់ចូលបម្រើការងារ ជាមេព្រៃហើយ ។ នេះជាបំណងធំរបស់ឪពុកគាត់ ដែលផ្តុងផ្តើមឱ្យគាត់រៀនសូត្រ តាំងពីក្មេងមកនោះ គឺចង់ឱ្យគាត់បានធ្វើជាមន្ត្រីរាជការ ដូចនេះឯង ។

ឡឹក សំអឿន បានបន្ថែមថា ម្យ៉ាងទៀត ផ្ទះយើងនៅឆ្ងាយពីបន្ទាយទាហានរាជការខ្មែរ-បារាំង ចម្ងាយតែ៥០០ម៉ែត្រប៉ុណ្ណោះ គាត់គិតថា ប្រហែលជាពួកវៀតមិញ មិនហ៊ានចូលមកអុកឡុកទេ។

ឮដូច្នេះ ឪពុកគាត់តបវិញថា កុំសង្ឃឹមឱ្យសោះ ព្រោះឱ្យតែពេលយប់ឡើង ពួកទាហានរាជការខ្មែរ-បារាំង ទាំងនោះរួញនៅតែក្នុងបន្ទាយប៉ុណ្ណោះ។ ក្រោយពេលទទួល-ទានបាយល្ងាចរួច ក្រុមគ្រួសារគាត់ និងអ្នកជិតខាង ក៏សំណេះសំណាលគ្នាយ៉ាងសប្បាយរីករាយ ព្រោះគាត់បានប្រលងជាប់ធ្វើមេព្រៃ។ លុះដល់ម៉ោង១០យប់ មានពួកវៀតមិញមួយក្រុម មានគ្នាប្រហែល១០នាក់ ដឹកនាំដោយខ្មែរកម្ពុជាក្រោមម្នាក់ បាននាំគ្នាដើរចូលមកក្នុងរបងផ្ទះ។ ភ្លាមៗនោះ បរិយាកាសសប្បាយរីករាយនៅក្នុងគ្រួសារគាត់ ប្រែទៅជាស្ងប់ស្ងាត់វិញ ហើយម្នាក់ៗធ្លាក់ទឹកមុខ លែងហ៊ាននិយាយស្តីអ្វីតទៅទៀត។ តែក្នុងចំណោមពួកវៀតមិញទាំងនោះ ភាគច្រើនសុទ្ធសឹងតែជាជនជាតិយួន ដែលធ្លាប់ជាមិត្តភក្តិរួមថ្នាក់របស់ឡឹក សំអឿន កាលរៀននៅសាលាបឋមសិក្សាមេសថូកនោះដែរ។ ដោយឃើញបរិយាកាសស្ងាត់ស្ងៀម ហើយម្នាក់ៗធ្លាក់ទឹកមុខស្រងូតស្រងាត់ដូច្នោះ មេវៀតមិញជាខ្មែរកម្ពុជាក្រោមនោះ បាននិយាយទៅកាន់ឪពុកគាត់ថា សូមលោកពូកុំមានការព្រួយបារម្ភអ្វី ពួកខ្ញុំមកនេះ គ្រាន់តែចង់ជួបកូនលោកពូតែប៉ុណ្ណោះ ព្រោះអ្នកដែលមកនេះ ភាគច្រើនជាអតីតសិស្សរួមថ្នាក់ជាមួយកូនលោកពូ ទេតើ!

បន្ទាប់មក មេវៀតមិញម្នាក់នោះ ក៏បានហៅពួកគេជាអតីតមិត្តរួមថ្នាក់ជាមួយឡឹក សំអឿន ចំនួន៤នាក់ ឲ្យចូលមកជួបនៅក្នុងផ្ទះ ហើយឡឹក សំអឿន ក៏បានសំណេះសំណាលសួរសុខទុក្ខគ្នា ទៅវិញទៅមក។ ពួកគេបាននិយាយអប់រំឡឹក សំអឿន ពីការគេស៊ីរបស់ពួកគេដើម្បីទប់ទល់នឹងពួកអាណានិគមនិយមបារាំង ព្រមទាំងសាកសួរគាត់ពីរឿងសឹង ង៉ុកថាញ់

រត់ចូលព្រៃទៅបង្កើតចលនាឥស្សរៈតស៊ូ ដើម្បីទាមទារឯករាជ្យពីបារាំង នោះដែរ ។

ពួកគេបានសួរថា តើគាត់មានយោបល់ដូចម្តេច ហើយបានគិតថា នឹងទៅចូលរួមជាមួយចលនាតស៊ូរបស់សឺង ង៉ុកថាញ់ នោះដែរឬទេ? ព្រោះបញ្ហាវន្តខ្មែរនៅកម្ពុជាក្រោមទាំងអស់ សុទ្ធតែស្រលាញ់ និងចាត់ទុកសឺង ង៉ុកថាញ់ ថាជាវីរបុរសស្នេហាជាតិពិតប្រាកដ ហ៊ានប្តូរជីវិត ដើម្បីប្រជាពលរដ្ឋ និងប្រទេសជាតិ ។

ឡឹក សំអឿន បានឆ្លើយតបវិញភ្លាមថា មិនមែនតែគាត់ម្នាក់ទេ គឺប្រជាពលរដ្ឋខ្មែរទូទៅ ជាពិសេសសិស្សានុសិស្ស និងអ្នកចេះដឹងភាគច្រើន បានចាត់ទុកសឺង ង៉ុកថាញ់ ជាអ្នកស្នេហាជាតិយ៉ាងមោះមុត ជាអ្នកដឹកនាំដ៏ឆ្នើម ក្នុងការបម្រើប្រទេសជាតិ និងប្រជាពលរដ្ឋខ្មែរ។

ក្រោយពីសំណេះសំណាលគ្នាអស់រយៈពេលប្រហែលមួយម៉ោង ពួកគេក៏លាត្រលប់ទៅវិញ តែមេរៀតមិញ ម្នាក់នោះបានផ្តាំគាត់ថា ពេលប្អូនត្រលប់ទៅភ្នំពេញ វិញ សូមឲ្យបានសម្រេចក្នុងការសិក្សា ហើយសង្ឃឹមថា ប្អូនច្បាស់ជាអនុវត្តនូវគោលដៅរបស់ប្អូន រហូតដល់បានសម្រេចជាមិនខាន ហើយគាត់ក៏ជូនពរតបទៅពួកគេវិញដូចគ្នាដែរ។

ស្អែកឡើង ក្រោយស្រស់ស្រូបបាយពេលព្រឹករួច ឡឹក សំអឿន ក៏ត្រលប់ទៅក្រុងស្វាយរៀងវិញ រួចបន្តដំណើរទៅក្រុងភ្នំពេញ ដោយសុវត្ថិភាព ហើយបណ្តាញតស៊ូសម្ងាត់របស់សឺង ង៉ុកថាញ់ ក៏បានមកប្រាប់ថា នៅតែពីរថ្ងៃទៀតប៉ុណ្ណោះ គាត់នឹងត្រូវចេញដំណើរពីភ្នំពេញ ទៅភ្នំដងរែកហើយ។

៣៨
ឡឹក សំអឿន ចេញដំណើរទៅតស៊ូនៅភ្នំដងរែក

មុនពេលត្រូវចេញដំណើរ មួយថ្ងៃ នៅពេលយប់ គណៈកម្មការខ្សែរយៈតស៊ូសម្ងាត់របស់សឹង ង៉ុកថាញ់ បានរៀបចំពិធីជប់លៀងមួយ នៅភោជនីយដ្ឋានលី ម៉ៅ ដោយមានតំណាងខ្សែរយៈសម្ងាត់របស់មេឥស្សរៈ ២នាក់ចូលរួម គឺម្នាក់ជានាយការិយាល័យនៅសាលាក្រុងភ្នំពេញ និងម្នាក់ទៀត ជាភ្នាក់ងារនគរបាល នៅគីឡូម៉ែត្រលេខ៦ ព្រមទាំងនារីជាអ្នកនាំផ្លូវម្នាក់ មកពីក្រុមឥស្សរៈងួន ហុង ផងដែរ។ ពេលនោះ ឡឹក សំអឿន នឹកស្មានថាមានតែរូបគាត់ និងអ៊ូ អន ពីរនាក់ប៉ុណ្ណោះ ផ្ទុយទៅវិញ គាត់ឃើញមិត្តកក្តិគាត់ជាសិស្សចំនួន៨នាក់ទៀត គឺ អ៊ឹង ម៉េងគ្រុយ, ដុង តាល់, ថាច់ ចេន និងសឺន ស៊ិន ក៏បានស្ម័គ្រចិត្តទៅចូលរួមចលនាតស៊ូនៅភ្នំដងរែក នោះដែរ។

ស្អែកឡើង វេលាម៉ោង៦ព្រឹក ពួកគាត់ទាំង៦នាក់ បានទៅជួបនារីជាអ្នកនាំផ្លូវ នៅចំណតរថយន្តក្បែរផ្សារធំថ្មី ដើម្បីឡើងរថយន្តឈ្នួល១០បាំង ចេញដំណើរ ដោយពួកគាត់ទាំង៦នាក់អង្គុយនៅបាំងទី២ រីឯនារីនាំផ្លូវអង្គុយនៅបាំងទី១ ជាមួយអ្នកបើកបរ ហើយធ្វើជាមិនស្គាល់គ្នា ផងដែរ។ ពេលរថយន្តទៅដល់កន្លែងត្រួតពិនិត្យ នៅត្រង់គីឡូម៉ែត្រលេខ៦ ឫស្សីកែវ ស្រាប់តែឃើញភ្នាក់ងារនគរបាលម្នាក់ដែលបានចូលរួមក្នុងពិធីជប់លៀងកាលពីយប់នោះ ដើរមកពិនិត្យមើលជុំវិញរថយន្ត ហើយមុនពេលរថយន្តចេញដំណើរទៅមុខទៀត ភ្នាក់ងារនគរបាលនោះ ក៏បានជូនពរពួកគាត់ថា សូមឲ្យប្អូនៗទាំងអស់គ្នា ដែលធ្វើដំណើរថ្ងៃនេះ ប្រកបតែនឹងសេចក្តីសុខ សេចក្តីចម្រើន ហើយសូមកុំឲ្យមានឧបសគ្គអ្វីនៅតាមផ្លូវឱ្យសោះ។

រថយន្តក៏បើកបន្តទៅទៀត រហូតដល់ប្រហែលវេលាម៉ោង៧កន្លះ បានទៅដល់ទី-ប្រជុំជនតាំងគោក មានប៉ុស្តិ៍ត្រួតពិនិត្យមួយទៀត ដាក់ឈើរែងមួយ រាំងទទឹងផ្លូវ ។ នារីជាអ្នកនាំផ្លូវ ក៏ចុះពីរថយន្តដើរសំដៅទៅរកភ្នាក់ងារត្រួតពិនិត្យ ដែលនៅក្នុងប៉ុស្តិ៍យាម ហើយ

មិនដឹងជានិយាយអ្វីជាមួយនោះទេ។ មួយសន្ទុះក្រោយមក ក៏ឃើញភ្នាក់ងារត្រួតពិនិត្យ ដែលនៅក្នុងប៉ុស្តិ៍យាម លើកឈើវែងរាំងទទឹងផ្លូវនោះ ឲ្យរថយន្តបើកឆ្លងប៉ុស្តិ៍ត្រួតពិនិត្យ បន្តដំណើរទៅមុខទៀត ដោយមិនមានការត្រួតពិនិត្យអ្វីឡើយ។

លុះទៅដល់ពាក់កណ្តាលផ្លូវ ពីទីប្រជុំជនតាំងគោក និងទីប្រជុំជនរំលង នារីនាំផ្លូវ បានឲ្យអ្នកបើកបរឈប់រថយន្ត រួចឲ្យពួកគាត់ទាំង៦នាក់ចុះពីលើរថយន្ត ធ្វើឱ្យអ្នករួមដំណើរផ្សេងៗទៀត នៅក្នុងរថយន្តមានការងឿងឆ្ងល់ជាខ្លាំង ព្រោះកន្លែងនោះជាកន្លែងស្ងាត់ ដែលពួកឥស្សរៈតែងតែមកពួនស្នាក់រថយន្ត ជាញឹកញាប់។

ក្រោយពីពួកគាត់ចុះអស់ រថយន្តក៏បើកបន្តដំណើរទៅមុខទៀត រហូតបាត់ស្រមោល។ នារីនាំផ្លូវ ក៏បាននាំពួកគាត់ដើរទៅទិសខាងត្បូងផ្លូវជាតិលេខ៦ បានចម្ងាយប្រមាណ៥ គីឡូម៉ែត្រ ក៏ទៅដល់ដើមភូមិមួយ មានអ្នកយាមប្រដាប់អាវុធ៣នាក់ ស្រែកប្រាប់គ្នីគ្នារបស់ពួកគេថា ចៃចេង ត្រលប់មកវិញហើយ!

ពេលនោះ ទើបពួកគាត់ស្គាល់ឈ្មោះនារីនាំផ្លូវនោះ ហើយដឹងថា នារីនោះជាកូនចៅចិនទៀតផង។ ពួកគេបាននាំពួកគាត់ទៅស្នាក់នៅផ្ទះមួយ ស្ថិតនៅកណ្តាលផ្លូវភូមិ ដោយមានយុទ្ធជន៣នាក់មានអាការៈស្រវឹងស្រា នៅរង់ចាំទទួល។ ក្រោយពីទទួលទាន បាយថ្ងៃត្រង់រួច គេឱ្យពួកគាត់សម្រាកនៅលើផ្ទះនោះ ដើម្បីរង់ចាំជួបមេបញ្ជាការខ្មែរឥស្សរៈ ឈ្មោះ ងួន ហុង និងនាយស្នងការនយោបាយ ឈ្មោះសាឡុត ឆាយ (បងប្រុសបង្កើតរបស់សាឡុត ស)។

នៅពេលរង់ចាំយុទ្ធជនទាំង៣នាក់ដែលមានអាការៈស្រវឹងស្រានោះ នាំគ្នានិយាយអួតអាងផ្តេសផ្តាសតែរៀងៗខ្លួន ដែលស្តាប់ទៅវាមិនសមស្របនឹងសម្តីអ្នកតស៊ូមានឧត្តមគតិស្នេហាជាតិទាល់តែសោះ។

លុះដល់ពេលល្ងាច ប្រហែលម៉ោង៦ ពួកគេក៏បាននាំពួកគាត់ទៅកន្លែងថ្មីមួយទៀត តែនៅក្នុងភូមិដដែលនោះដែរ ដោយមានអ្នកភូមិរៀបចំបាយទឹកទទួលរួចជាស្រេច។ ពេលនោះហើយ ដែលពួកគាត់បានជួបមេបញ្ជាការខ្មែរឥស្សរៈ ឈ្មោះងួន ហុង និងនាយស្នងការ

នយោបាយ ឈ្មោះសាឡុត ឆាយ ព្រមទាំងសហការីមួយចំនួនទៀត។ មេខ្មែរឥស្សរៈឈ្មោះ ងួន ហុង នេះ កំពុងត្រួតត្រាកាន់កាប់តំបន់រំលង និងតាំងគោក ក្នុងស្រុកបារាយណ៍ ខេត្ត កំពង់ធំ។

ប៉ុន្តែ នៅវេលាម៉ោង៨យប់ ស្រាប់តែពួកគាត់ឃើញម្តាយរបស់សឺន ស៊ន ព្រមទាំង វេជ្ជបណ្ឌិតអ៊ឹង ពាង ជាបងប្រុសបង្កើតរបស់អ៊ឹង ម៉េងគ្រុយ បានធ្វើដំណើរមកតាមអង្វរ អ្នកទាំង២នេះ ឱ្យវិលត្រលប់ទៅផ្ទះវិញ។

ដោយសារម្តាយយំអង្វរខ្លាំងពេក សឺន ស៊ន ក៏សុខចិត្តត្រលប់ទៅតាមម្តាយវិញ។ ចំណែកអ៊ឹង ម៉េងគ្រុយ មិនព្រមត្រលប់ទៅតាមបងប្រុសគាត់វិញ ជាជាប់ខាត។ ពេលនោះ មេបញ្ជាការងួន ហុង បានសម្តែងនូវការរំភើបរីករាយ ចំពោះឡឹក សំអឿន និងគ្នាគាត់ ទាំងអស់ ដែលបានស្ម័គ្រចិត្តមករួបរួមជាមួយចលនាតស៊ូ ក្រោមការដឹកនាំរបស់សឺង ង៉ុក ថាញ់ ហើយក្រុមរបស់គាត់ ដែលតស៊ូយូរហើយនោះ ក៏បានត្រៀមខ្លួនទៅចូលរួមជាមួយ សឺង ង៉ុកថាញ់ ផងដែរ។

ងួន ហុង បញ្ជាក់ថា ពេលនេះ ពួកយើងរង់ចាំតែអ្នកនាំផ្លូវដែលសឺង ង៉ុកថាញ់ បញ្ជូនឱ្យមកនាំពួកយើងធ្វើដំណើរទៅកាន់ភ្នំដងរែក ជាមួយគ្នាប៉ុណ្ណោះ។ ចំណែក សាឡុត ឆាយ ក្រោយពីបានថ្លែងអំណរសាទរចំពោះវត្តមានរបស់ពួកគាត់មក ក៏បានពន្យល់អំពី សភាពការណ៍នយោបាយស្រុកទេសយ៉ាងក្បោះក្បាយ រហូតដល់យប់ជ្រៅ ក៏នាំគ្នាដេក នៅក្នុងភូមិនោះ ទាំងអស់គ្នា។ លុះដល់យប់ស្មែក ពួកគាត់ត្រូវគេឱ្យទៅនៅក្នុងក្រុមបញ្ជា ការកណ្តាល រួចចេញពីភូមិ ទៅដេកនៅក្នុងរោងប្រក់ស្លឹកគ្នោត៣ខ្នងមួយកន្លែង ស្ថិតនៅ ក្នុងព្រៃរបោះ មានត្រពាំងទឹកធំមួយ ចម្ងាយពីភូមិប្រមាណ១គីឡូម៉ែត្រ។

ពេលនោះ ទើបឡឹក សំអឿន ដឹងថា ចលនាតស៊ូខ្មែរឥស្សរៈងួន ហុង នេះ គ្មាន ទីតាំងច្បាស់លាស់ទេ គឺត្រូវផ្លាស់ប្តូរទីតាំងពីកន្លែងមួយទៅកន្លែងមួយ នៅក្នុងតំបន់ដែល ពួកគេចូលទៅគ្រប់គ្រងជាបណ្តោះអាសន្ន ហើយពួកគេអាចរស់បាន ដោយសារការជើរ យោសនា សុំការជួយឧបត្ថម្ភប្រាក់កាស បាយទឹក ពីអ្នកភូមិប៉ុណ្ណោះ។ ក្នុងរយៈពេលរង់ចាំ

ចេញដំណើរទៅភ្នំដងរែកនោះ ក្រុមឡឹក សំអឿន ក៏បានទៅចូលធ្វើប្រតិបត្តិការយោសនា និងរកស្បៀងអាហារប្រាក់កាស ដើម្បីត្រៀមទុកសម្រាប់ធ្វើដំណើរទៅភ្នំដងរែក ជាមួយងួនហុង នោះដែរ។

មួយថ្ងៃ មុនពេលត្រូវចេញដំណើរទៅភ្នំដងរែក មានសិស្ស៨នាក់ទៀត មកពីវិទ្យាល័យព្រះសីហនុ ទីរួមខេត្តកំពង់ចាម រួមមាន ម៉ៅ ខេន, យុន ហ៊ាង, ឃី តាំងលឹម និងស្ពាន់ សំដឹម ព្រមទាំងគ្រូពីរនាក់ទៀត គឺគ្រូពៅ និងគ្រូធាន បានមកដល់កន្លែង ដែលគាត់ស្នាក់នៅ ដើម្បីចេញដំណើរទៅភ្នំដងរែក ជាមួយពួកគាត់ដែរ។

៣៩
ដំណើរតស៊ូកាត់ព្រៃភ្នំ ពីស្រុកបារាយណ៍ ទៅជំរំចុងកាល់



មេខ្មែរស្បៃ: ឈ្មោះកៅ តក់

ស្អែកឡើង ពេលចាប់ផ្តើមចេញដំណើរ មេបញ្ជាការងួន ហុង និងនាយស្នងការនយោបាយសាឡុត ឆាយ ចែកគ្នាជា៣ក្រុម គឺក្រុមទី១ និងក្រុមទី២ ជាក្រុមយុទ្ធជន និងក្រុមទី៣ ជាក្រុមបញ្ជាការ ដែលមានឡឹក សំអឿន និងសិស្សវិទ្យាល័យផ្សេងៗចំនួន១០នាក់ និងគ្រូបង្រៀន២នាក់ទៀត។

ក្រុមទី១ ជាក្រុមយុទ្ធជនត្រូវដើរជាជួរ មួយខ្សែ ចេញដំណើរទៅមុនគេ។ បន្ទាប់មក គឺក្រុមទី៣ ជាក្រុមបញ្ជាការត្រូវដើរជាជួរមួយខ្សែដែរ តែនៅកណ្តាលគេ និងក្រុមទី២ ជា

ក្រុមយុទ្ធជនត្រូវដើរជាជួរ មួយខ្សែ នៅខាងក្រោយគេ។

ក្នុងក្រុមនីមួយៗមានឆ្នាំងបាយ១ ឆ្នាំងសម្ល១ ផែនទី១ ត្រីវិស័យ១ ហើយម្នាក់ៗត្រូវស្ពាយទៃអង្គរមួយ ចំណុះ២០កំប៉ុង ត្រីងៀត ប្រហុក និងអំបិល សម្រាប់ការហូបចុករយៈពេលមួយសប្តាហ៍ ដើម្បីធ្វើដំណើរកាត់តាមព្រៃជ្រៅមួយដាច់ស្រយាល ឆ្ងាយពីភូមិអ្នកស្រុក ចៀសវាងការជេញតាម ឬស្ទាក់ផ្លូវរបស់កងកម្លាំងរាជការខ្មែរ-បារាំង ។

ពួកគាត់ចាប់ផ្តើមធ្វើដំណើរពីម៉ោង៦ល្ងាច រហូតដល់ម៉ោង៧ ទៅ៨ព្រឹក ទើបឈប់ចម្អិនម្ហូបអាហារ រួចសម្រាករហូតដល់ពេលបាយល្ងាច ទើបបន្តដំណើរទៅមុខទៀត។ រយៈពេល៥ថ្ងៃ នៃការធ្វើដំណើររបស់ពួកគាត់ នៅលើទឹកដីខេត្តកំពង់ធំ ពួកគាត់បានដើរឆ្លងកាត់ព្រៃស្រោងដ៏ធំមួយ ដែលសម្បូរទៅដោយ ហ្វូងសត្វទន្សោង គោព្រៃ ប្រើស ឈ្លួស ខ្លា ជ្រូកព្រៃ ដំរី ច្រើនអនេក។

២ថ្ងៃបន្ទាប់មក ពួកគាត់បានធ្វើដំណើរទៅដល់ទឹកដីនៃខេត្តសៀមរាប ពួកគាត់បានចាត់គ្នាមួយចំនួន ឱ្យចូលក្នុងភូមិមួយ នៅក្នុងស្រុកស្វាយលើ ស្ថិតនៅខាងជើងធៀងខាងកើតភ្នំគូលែន ដើម្បីរកស្បៀងបន្ថែមទៀត។

ពេលនោះ ពួកគាត់ត្រូវដេកក្នុងព្រៃ ក្បែរភូមិនោះ អស់រយៈពេល២ថ្ងៃ១យប់ ព្រោះអ្នកភូមិមិនអាចផ្តល់អង្ករ ឲ្យបានគ្រប់គ្រាន់ដល់ពួកគាត់ភ្លាមៗ ព្រោះត្រូវចំណាយពេលមួយថ្ងៃទៀត ដើម្បីបុកស្រូវយកអង្ករឱ្យបានច្រើនគ្រប់គ្រាន់ តាមសំណូមពររបស់ពួកគាត់។ ពេលនោះដែរ ពួកគាត់ក៏បានទិញគោ១ក្បាល និងជ្រូក១ក្បាល ពីអ្នកភូមិ ដើម្បីកាប់ពន្លះយកសាច់ប្រឡាក់អំបិល ហាលធ្វើងៀត ផងដែរ។

ល្ងាចថ្ងៃទី២ ក្រោយបាយល្ងាចរួច ពួកគាត់បានលាអ្នកភូមិបន្តដំណើរទៅមុខទៀត ដោយដើរកាត់ព្រៃ តាំងពីព្រលប់ រហូតដល់ម៉ោង៩ព្រឹក ទើបឈប់សម្រាកដាំបាយ នៅតាមដងអូរមួយ។

ប្រហែល១ម៉ោងក្រោយមក ពេលពួកគាត់កំពុងដាំបាយ ស្រាប់តែឮស្នូរកាំភ្លើងផ្ទុះលាន់ឡើង នៅខាងក្រោយក្រុមទី២ ។ ភ្លាមនោះ មេបញ្ជាការ ងួន ហុង ក៏បញ្ជាឲ្យក្រុមទី២

រាយគ្នាជាខ្សែ ដើម្បីត្រៀមទប់ទល់ រួចបញ្ជាឲ្យក្រុមទី១ និងក្រុមបញ្ជាការ ធ្វើដំណើរទៅមុខបន្តទៀត។

ពេលនោះ ពួកគាត់ខ្លះកំពុងដាំបាយ និងខ្លះកំពុងដេកសម្រាក ក៏ប្រញាប់ប្រញាល់រត់ចោលឆ្នាំង ដែលបាយកំពុងពុះ។ មួយសន្ទុះក្រោយមក ទើបក្រុមទី២ ដកថយមកតាមក្រោយពួកគាត់ដែរ។

ពួកគាត់បានធ្វើដំណើរហូតដល់ម៉ោង២រសៀល ក៏ឈប់នៅត្រង់ត្រពាំងទឹកមួយនៅខាងជើងភូមិអូរ នាភាគឦសានភ្នំគូលែន ប្រមាណ១គីឡូម៉ែត្រ ដើម្បីសម្រាកដាំបាយជាថ្មីម្តងទៀត។

នៅទីនោះ ដោយសារបាត់ឆ្នាំងបាយអស់ ពួកគាត់បានយកក្រមាមកវេចខ្ចប់អង្ករយកទៅត្រាំទឹក រួចដឹករណ្តៅមួយ។ លុះអង្ករក្នុងក្រមានោះ រីកល្មម ក៏យកទៅកប់ក្នុងរណ្តៅនោះ រួចដុតគំនរអុសពីលើ ប្រហែលកន្លះម៉ោងក្រោយមក ក៏កាយយករងើកភ្លើងចេញ ហើយកាយដីទាញយកកញ្ចប់ក្រមា ដែលដាក់អង្ករកប់ក្នុងដីនោះ ចេញមកវិញ ឃើញអង្ករនោះឆ្អិន ក្លាយជាបាយ ដូចគេដាក់ដាំក្នុងឆ្នាំងដែរ។

លើកនេះ ក្រោយពីទទួលទានបាយរួច មេបញ្ជាការ ងួន ហុង ឱ្យពួកគាត់សម្រាកហូតដល់ម៉ោង៨យប់ ទើបឱ្យធ្វើដំណើរទៅមុខទៀត គឺសំដៅទៅភូមិអន្លង់រែង។

បន្ទាប់ពីធ្វើដំណើរ រហូតដល់ថ្ងៃត្រង់ ពួកគាត់ពុំបានជួបកន្លែងមានទឹកសោះ ក៏ដើរវង់ចុះវង់ឡើង ស្រាប់តែមកដល់ត្រង់កន្លែងដដែលវិញ។

ពេលនោះ អ្នកនាំផ្លូវប្រាប់ថា ពួកយើងវង្វេងក្នុងព្រៃនេះហើយ ដោយសារមានពួកយើងខ្លះខុសមាត់ខុសក ប្រើពាក្យសម្តីអ្វីមិនគប្បី ធ្វើឱ្យអារក្ខអារក្ស អ្នកតាថែរក្សាព្រៃភ្នំនេះខឹងសម្បា ទើបបានជាបណ្តាលឲ្យពួកយើងវង្វេង រកផ្លូវចេញមិនរួច។

ដោយសារអត់បាយផង អត់ទឹកផង ពួកគាត់ម្នាក់ៗស្ងៀមស្ងាត់ ធ្វើមុខស្រងូតស្រងាត់គ្រប់ៗគ្នា តែអ្នកនាំផ្លូវនៅតែព្យាយាមនាំរុកកាត់ព្រៃ ប្រហែល២០០ម៉ែត្រ ក៏បានទៅដល់មាត់ស្ទឹងជំមួយ ឈ្មោះស្ទឹងស្រែង ដែលអ្នកនាំផ្លូវនោះ ធ្លាប់បាននាំក្បួនឈើទៅឱ្យ

រោងចក្រអារឈើ នៅកំពង់ថ្កូវ។

ពួកគាត់បានឈប់សម្រាកនៅទីនោះ រួចអ្នកនាំផ្លូវ និងយុទ្ធជន២នាក់ទៀត ស្លៀក ពាក់ជាអ្នកភូមិធម្មតាចូលទៅស៊ើបការណ៍ក្នុងភូមិអន្លង់វែង ហើយបានជួបអ្នកភូមិតាមផ្លូវ ប្រាប់ថា មានកម្លាំងរបស់ កៅ តក់ មួយក្រុម កំពុងរង់ចាំទទួលពួកគាត់ នៅក្នុងភូមិនេះ ដែរ។

អ្នកនាំផ្លូវ ក៏នាំមេបញ្ជាការ ងួន ហុង និងនាយស្នងការនយោបាយ សាឡុត ឆាយ ចូលទៅជួបក្បួយរបស់គាត់ម្នាក់ ជាមេក្រុមរបស់កម្លាំងកៅ តក់ ដែលមកនៅរង់ចាំទទួល ពួកគាត់នោះ និងបានសុំឲ្យមេភូមិជួយរៀបចំបាយទឹកទទួលពួកគាត់ទាំងអស់ ដែលមាន គ្នាចំនួន៨០នាក់ រួចហើយពួកគាត់ក៏នាំគ្នាចូលទៅដល់ក្នុងភូមិនោះ ដោយក្តីរីករាយបំផុត។ លុះទទួលទានបាយល្ងាចរួច ប្រហែលម៉ោង៨យប់ ពួកគាត់ក៏ចេញដំណើរពីភូមិអន្លង់វែង តម្រង់ទៅភូមិតារ៉ាក់ បន្តទៀត រហូតដល់ម៉ោង១រំលងអធ្រាត្រ ទើបបានទៅដល់ និងបាន នាំគ្នាសម្រាកនៅភូមិតារ៉ាក់ នោះតែម្តងទៅ។

លុះព្រឹកឡើង ម៉ោង៩ មេខ្មែរឥស្សរៈ ឈ្មោះកៅ តក់ ក៏បានមកទទួលស្វាគមន៍ ពួកគាត់ រួចហើយក៏នាំពួកគាត់ធ្វើដំណើរចេញពីភូមិអន្លង់វែង ទៅភូមិចុងកាល់ ដែលជាទី បញ្ជាការធំរបស់កៅ តក់ ដោយបានរៀបចំទទួលពួកគាត់យ៉ាងអធិកអធម។

ពួកគាត់សម្រាកនៅភូមិចុងកាល់ អស់រយៈពេល៣ថ្ងៃ ទើបមានលិខិតមួយមកពី សឹង ង៉ុកថាញ់ ឱ្យមេបញ្ជាការ ងួន ហុង និងសាឡុត ឆាយ ព្រមទាំងសិស្សវិទ្យាល័យ ៩នាក់ គឺ ឡឹក សំអឿន, អ៊ឹង ម៉េងគ្រុយ, ថាច់ ចេន, អ៊ូ អន , ដុង តាល់ ដែលមកពីវិទ្យាល័យព្រះ ស៊ីសុវត្ថិ និងម៉ៅ ខេន, យុន ហ៊ាង, ឃី តាំងលឹម និងស្ពាន់ សំជឹម មកពីវិទ្យាល័យព្រះសីហនុ កំពង់ចាម ព្រមទាំងគ្រូពីរនាក់ទៀត គឺគ្រូពៅ និងគ្រូជាន ឡើងទៅជំរំអូរស្មាច់។ ចំណែក កងកម្លាំងដែលនៅសេសសល់ទាំងប៉ុន្មាន ត្រូវនៅជំរំចុងកាល់ នោះសិន។

៤០
ប៉ក់ មេខ្មែរឥស្សរៈឈ្មោះ រីម៉ែន កេណ្ឌផែនដី ឥសីអគ្គិនេត្រក្រឡេកឆេះ

ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥២ ពួកគាត់បានទៅដល់ជំរំអូរស្មោច់ និងបានសម្រាកនៅទីនោះមួយយប់។ ស្អែកឡើង ងួន ហុង និងសាឡុត ឆាយ ក៏បានចូលទៅជួបសឹង ង៉ុក ថាញ់ ហើយសឹង ង៉ុកថាញ់ បានតែងតាំងមេខ្មែរឥស្សរៈងួន ហុង នៅតំបន់រំលង តាំងគោកនោះ ជាមេបញ្ជាការភាគឧត្តរទិស (ខេត្តសៀមរាប) ដែលមានសាង សាវាត (អ្នកនិពន្ធសៀវភៅរឿង មហាចោរទល់ដែន) ជាស្នងការនយោបាយ ពីមុនមកហើយ។ ចំណែកសាឡុត ឆាយ ត្រូវតែងតាំងជាមេបញ្ជាការភាគឦសានទិស និងត្រូវបញ្ជូនឱ្យត្រលប់ទៅបោះទីតាំងឈរជើង នៅខេត្តកំពង់ធំ វិញ។

ក្រោយពីចលនាតស៊ូខ្មែរឥស្សរៈរបស់ទ្រង់នរោត្តម ចន្ទរង្សី នៅតំបន់ច្បារមន ខេត្តកំពង់ស្ពឺ និងអនុសេនីយ៍ទោដួង ចន្ទសាវាត ដែលបាននាំកម្លាំងទាហានរាជរដ្ឋាភិបាលមកចូលរួមចលនាតស៊ូនោះដែរ ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ បានរៀបចំកែសម្រួលរចនាសម្ព័ន្ធក្បាលម៉ាស៊ីនដឹកនាំថ្មីបន្ថែមទៀត គឺ៖ សឹង ង៉ុកថាញ់ ជាប្រធានគណៈកម្មាធិការកណ្តាលប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ដដែល, អៀ ស៊ីចូវ ជាអនុប្រធាន ដដែល, លោកគ្រូអាចារ្យខៀវ ជុំ ជាសមាជិក ទទួលបន្ទុកជាអគ្គលេខាធិការ ដដែល, ហង្ស ធុន ហាក់ ជាសមាជិក ទទួលបន្ទុកខាងការអប់រំ និងឃោសនាការ ដដែល, អ៊ីវ យ៉ា ជាសមាជិក ទទួលបន្ទុកខាងសន្តិសុខ និងជាមេបញ្ជាការភាគបស្ចិមទិស, ដួង ចន្ទសាវាត ជាសមាជិក ទទួលបន្ទុកខាងយោធា, កៅ តក់ ជាសមាជិក ទទួលបន្ទុកជាមេបញ្ជាការយោធាភាគបស្ចិមទិស, ងួន ហុង ជាសមាជិក ទទួលបន្ទុកជាមេបញ្ជាការភាគឧត្តរទិស និងទ្រង់ចន្ទរង្សី ជាសមាជិក ទទួលបន្ទុកជាមេបញ្ជាការ និងជានាយស្នងការនយោបាយ ភាគទក្សិណទិស។

ដោយឡែក ក្រុមឡឹក សំអឿន ទាំង៩នាក់ ជាសិស្សមកពីវិទ្យាល័យព្រះស៊ីសុវត្ថិ

និងវិទ្យាល័យព្រះសីហនុ កំពង់ចាម ត្រូវបានហង្ស ធុនហាក់ មកជួបប្រជុំសំណេះសំណាល និងឱ្យពួកគាត់ស្នាក់នៅកន្លែងទទួលភ្ញៀវ ក្នុងជំរំអូរស្មោច់ ចំនួនបីថ្ងៃ ទើបសឺង ង៉ុកថាញ់ ចាត់ឱ្យអៀ ស៊ីចូវ មកបង្ហាត់បង្រៀនខាងផ្នែកនយោបាយ រដ្ឋបាល និងសេដ្ឋកិច្ច ដល់ពួកគាត់រយៈពេល៣សប្តាហ៍។

លុះចប់វគ្គសិក្សា គណៈកម្មាធិការនាយកបានឯកភាពគ្នា តែងតាំងពួកគាត់ឱ្យមានតួនាទីក្នុងចលនាតស៊ូប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ នោះដែរ គឺ៖ ១. អ៊ូ អន ជាជំនួយការរបស់អ៊ីវ យ៉ាង ជានាយស្នងការនយោបាយ នៅកាគបស្ចិមទិស។ ២. អ៊ឹង ម៉េង គ្រុយ ទទួលបន្ទុកអប់រំពួកយុវជន នៅសាលាបឋមសិក្សា ចាប់ពីអាយុ១៣ឆ្នាំ ដល់១៥ឆ្នាំ ដែលរត់មកចូលរួមបម្រើចលនាតស៊ូនេះដែរ។ ៣. ដុង តាល់ និងថាច់ ចេន ទទួលភារកិច្ចខាងវិទ្យុផ្សាយសំឡេងភ្នំដងរែក។ ៤. ម៉ៅ ថេន, យុន ហ៊ាង និងស្ពាន់ សំជឹម ជាជំនួយការនៅអគ្គលេខាធិការដ្ឋាន។ ៥. ឃី តាំងលឹម ជាលេខាធិការផ្ទាល់របស់អៀ ស៊ីចូវ ។ ៦. ឡឹក សំអឿន ជាស្នងការនយោបាយ ប្រចាំកងកម្លាំងរក្សាសន្តិសុខ នៅទីបញ្ជាការកណ្តាលជំរំអូរពក ដែលមានមេឥស្សរៈជើងចាស់ម្នាក់ ឈ្មោះប៉ក់ រីម៉ែនកេណ្ឌផែនដី ឥសីអគ្គិនេត្រ ក្រឡេកឆេះ ជាមេបញ្ជាការ។

ប៉ក់ រីម៉ែន មានដើមកំណើតនៅខេត្តពោធិ៍សាត់ បានប្រលងជាប់សញ្ញាបត្របឋម-សិក្សា នៅក្រុងពោធិ៍សាត់ កាលសម័យតស៊ូប្រឆាំងបារាំង តាំងពីឆ្នាំ១៩៤២។ ពេលកងទ័ពជប៉ុន ចូលមកដណ្តើមអំណាចកាន់កាប់ប្រទេសខ្មែរ ជំនួសបារាំង ក្នុងឆ្នាំ១៩៤៥ កងទ័ពជប៉ុន លើកសឺង ង៉ុកថាញ់ ឱ្យឡើងធ្វើនាយករដ្ឋមន្ត្រី (ពីខែសីហា ដល់ខែតុលា ឆ្នាំ១៩៤៥) គាត់បានចូលធ្វើទាហានស្ម័គ្រចិត្តដែលសឺង ង៉ុកថាញ់ បង្កើតឡើងនោះ ជាមួយទ្រង់ចន្ទរង្សី ដែរ ។

លុះបារាំងត្រលប់មកត្រួតត្រាប្រទេសខ្មែរ វិញ ហើយចាប់សឺង ង៉ុកថាញ់ យកទៅឃុំឃាំង នៅប្រទេសបារាំង គាត់ក៏បានរត់គៀសខ្លួន ទៅចូលរួមក្នុងចលនាតស៊ូខ្មែរឥស្សរៈដឹកនាំដោយកៅតក់ នៅឯខេត្តបាត់ដំបង ដែលសម័យនោះ កំពុងស្ថិតនៅក្រោមការត្រួតត្រា

របស់សៀម នៅឡើយ។

ក្រោយមក គាត់ត្រូវបានតែងតាំងជាមេកង និងមានរហស្សនាមថា ប៉ក់ រីម៉ែន កេណ្ឌផែនដី ឥសីអគ្គិនេត្រក្រឡេកឆេះ។ អ្នកស្រុកអ្នកភូមិ ឲ្យតែឮឈ្មោះនេះភ្លាម នរណាក៏ភ័យខ្លាចដែរ ព្រោះល្បីថា គាត់មានបារមីពូកែសក្តិសិទ្ធិ កាប់មិនមុត ដុតមិនឆេះ បាញ់មិនត្រូវ។ គាត់តែងតែធឹកស្រាស្រវឹងរាល់ថ្ងៃ ហើយភ្នែកគាត់ឡើងក្រហមជានិច្ច ដោយសារគាត់ខូចចិត្ត ដ្បិតឃើញមេដឹកនាំចលនាតស៊ូខ្មែរឥស្សរៈជំនាន់នោះ ភាគច្រើនពុំមែនតស៊ូដើម្បីដណ្តើមឯករាជ្យពីបារាំង ទេ គឺពួកគេគិតតែផលប្រយោជន៍ លាភសក្ការៈខ្លួនឯង ប្រព្រឹត្តអំពើសាហាវយង់ឃ្នងទៅលើប្រជាពលរដ្ឋ និងគ្មានគោលជៅ គ្មានគោលនយោបាយច្បាស់លាស់ ហើយចេះតែបែកបាក់ ដណ្តើមអំណាចគ្នាប៉ុណ្ណោះ។

តែយ៉ាងណា គាត់គិតថា នៅក្នុងចំណោមចលនាតស៊ូខ្មែរឥស្សរៈទាំងអស់ មានតែក្រុមឥស្សរៈដឹកនាំដោយ កៅ តក់ មួយទេ ដែលមានវិន័យ និងគោលនយោបាយល្អគ្រាន់បើជាងគេ។ ដោយឃើញគាត់ធ្លាក់ទឹកចិត្ត គិតតែធឹកស្រាដូច្នេះ កៅ តក់ ក៏បានបញ្ជូនគាត់ទៅឲ្យរស់នៅឯខេត្តសុរិន្ទ ក្នុងប្រទេសថៃ វិញ។

លុះដល់ខែមីនា ឆ្នាំ១៩៥២ ក្រោយពេលសឺង ង៉ុកថាញ់ រត់ចេញពីក្រុងភ្នំពេញ ទៅភ្នំដងរែក បង្កើតប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ កៅ តក់ ក៏បានទៅយកប៉ក់ រីម៉ែន កេណ្ឌផែនដី ឥសីអគ្គិនេត្រក្រឡេកឆេះ ពីខេត្តសុរិន្ទ ឱ្យមកចូលរួមចលនាតស៊ូវិញ ព្រោះគាត់ធ្លាប់ជាកូនទាហានស្មគ្រចិត្តរបស់សឺង ង៉ុកថាញ់ កាលពីឆ្នាំ១៩៤៥ នៅភ្នំពេញ នោះដែរ។

តែក្រោយពីធ្វើការជាមួយគ្នា មិនបានប៉ុន្មានខែផង ប៉ក់ រីម៉ែន ជាអ្នកតស៊ូជើងចាស់យូរហើយនោះ ហាក់ដូចជាមានការច្រណែននិន្ទាចំពោះក្រុមឡឹក សំអឿន ជាអតីតសិស្សដែលទើបមកពីក្រុងភ្នំពេញ មកចូលរួមតស៊ូ មិនទាន់បានចូលប្រយុទ្ធក្នុងសមរភូមិម្តងណាផង ត្រូវថ្នាក់ដឹកនាំដំឡើងបុណ្យស័ក្តិ ឋានៈតួនាទីខ្ពស់ៗ ជាងពួកគាត់ជាអ្នកតស៊ូជើងចាស់យូរហើយនោះទៅវិញ ។

ថ្ងៃមួយ នៅក្នុងអង្គប្រជុំ ដើម្បីដោះស្រាយបញ្ហាទំនាស់សតិអារម្មណ៍រវាងអ្នកតស៊ូ

ជើងចាស់ និងអ្នកតស៊ូទើបមកថ្មីៗ ប៉ក់ រីម៉ែន បានលើកឡើងក្នុងអង្គប្រជុំថា មានអ្នកខ្លះមិនទាន់ជ្រុះពន្លៃអស់ពីលើក្បាលផង មកចូលរួមជាមួយចលនាតស៊ូ មិនទាន់បាន៣ខែស្រាប់តែតែងតាំងឱ្យកាន់តំណែងធំៗ ជាហេតុធ្វើឱ្យអ្នកតស៊ូចាស់ៗ មិនសប្បាយចិត្ត។ ប៉ក់ រីម៉ែន បាននិយាយដៀមជាមថា អ្នកតស៊ូក្មេងៗ ទើបមកថ្មីៗ គ្មានបទពិសោធអ្វី ក្នុងការប្រយុទ្ធទេ ប្រសិនបើមានហេតុការណ៍កើតឡើង រកតែកែកាំភ្លើង មិនឃើញផង។ ពេលនោះ ឡឹក សំអឿន បានតបទៅវិញថា តើលោកចង់និយាយឲ្យពួកណា? តើចង់ថាឱ្យពួកយើងខ្ញុំឬ? ខ្ញុំសូមជម្រាបអង្គប្រជុំថា ពួកយើងខ្ញុំ ដែលជាសិស្សសាលា មុននឹងចូលមករួមក្នុងចលនាតស៊ូនេះ បានគិតយ៉ាងល្អិតល្អន់ពីការលំបាកវេទនា រហូតដល់លះបង់អាយុជីវិត ដើម្បីបុព្វហេតុប្រទេសជាតិ ដោយមិនបានគិតថា មកនេះ មានបំណងប្រាថ្នាចង់បានបុណ្យស័ក្តិ ឋានៈ តួនាទីអ្វីនោះទេ។

ឡឹក សំអឿន បញ្ជាក់បន្ថែមថា បើពួកយើងខ្ញុំមិនគិតដល់ប្រទេសជាតិទេនោះ ពួកយើងខ្ញុំនៅឯក្រុងភ្នំពេញ ច្បាស់ជាមានបុណ្យស័ក្តិប្រាក់ខែច្រើន អាចរស់បានយ៉ាងសប្បាយគ្រប់បែបយ៉ាង។ ដូចនេះ សូមអស់លោកកុំមានការភ្ញាន់ច្រឡំជាមួយពួកយើងខ្ញុំឲ្យសោះ។ ពួកយើងខ្ញុំមកនេះ គឺហ៊ានពុះពារគ្រប់ឧបសគ្គមិនខ្លាចស្លាប់ ទោះបីដឹងថា បេសកកម្មនោះត្រូវស្លាប់ក៏ដោយ ក៏ពួកយើងខ្ញុំមិនរួញរាដែរ ដូច្នេះលោកមិនគួរនិយាយពាក្យមិនគប្បីក្នុងអង្គប្រជុំដូចនេះសោះ។

ឮដូច្នោះ ប៉ក់ រីម៉ែន ក៏ញញឹម រួចនិយាយថា គាត់និយាយលេងទេ និងសូមអភ័យទោសផង ព្រោះបញ្ហានេះធ្លាប់កើតមានតាំងពីជំនាន់មុនៗមកម្ល៉េះ។ រួច ប៉ក់ រីម៉ែន និយាយលើកទឹកចិត្តថា ពួកប្អូនៗជាយុវជនក្មេងៗដែលជាអ្នកចំណូលថ្មី មានការរៀនសូត្រចេះដឹង មានកម្រិតវប្បធម៌ខ្ពស់ជាងពួកខ្ញុំ គ្រាន់តែព្យាយាមដកស្រង់បទពិសោធពីពួកខ្ញុំចាស់ៗទៅ គឺអាចដឹកនាំគេបានហើយ។

ចាប់ពីពេលនោះមក ប៉ក់ រីម៉ែន តែងហៅឡឹក សំអឿន ថា អាប្អូនភ្លើៗ និងចាប់ផ្តើមចុះសម្រុងគ្នាគ្រប់ការងារទាំងអស់ ដោយមិនមានការច្រណែននិន្ទាអ្វីទៀតឡើយ ហើយ

ឡឹក សំអឿន បានរៀនសូត្រ និងដកស្រង់បទពិសោធកលល្បិច នៅក្នុងការប្រយុទ្ធតស៊ូ បានជាច្រើន ពីប៉ក់ រីម៉ែន ផងដែរ។ មិនតែប៉ុណ្ណោះ ប៉ក់ រីម៉ែន ថែមទាំងឲ្យថង់ទៃមន្តអាគម មានកន្សែងយ័ន្ត ខ្សែគាថា និងព្រះពុទ្ធប្បដិមាមួយអង្គរបស់គាត់ មកឲ្យឡឹក សំអឿន ជាអ្នកស្គាយជាប់នឹងខ្លួនទៀតផង។ ប៉ក់ រីម៉ែន បានផ្តាំផ្ញើឡឹក សំអឿន ថា ទៅថ្ងៃក្រោយ បើបានជួបគ្រូមន្តអាគមល្បីឈ្មោះថា ខ្លាំងពូកែ ត្រូវសុំធ្វើជាសិស្ស ហើយឲ្យគ្រូនោះចារបញ្ចុះមាសសន្លឹកនៅក្នុងខ្លួនឱ្យបាន បើទោះបីប្អូនមិនជឿក៏ដោយ ចាំបាច់ត្រូវតែធ្វើដែរ បើចង់ក្លាយជាមេដឹកនាំគ្រប់គ្រងកងកម្លាំងតស៊ូ ទទួលបានជោគជ័យ។

នៅក្នុងព្រៃ ឡឹក សំអឿន ក៏បានធ្វើតាមបណ្តាំរបស់ប៉ក់ រីម៉ែន យ៉ាងខ្ជាប់ខ្ជួន ដោយបានស្គាយថង់ទៃមន្តអាគមកន្សែងយ័ន្ត ខ្សែគាថា និងព្រះពុទ្ធប្បដិមា តាមជាប់ជានិច្ច រហូតធ្វើឱ្យមិត្តភក្តិមួយចំនួន នាំគ្នាសើចចំអកគ្រប់ៗគ្រប់គ្នា។ តែយ៉ាងណា ឡឹក សំអឿន នៅតែជឿជាក់លើបារមីនៃមន្តអាគម កន្សែងយ័ន្ត ខ្សែគាថា និងព្រះពុទ្ធប្បដិមានោះ ព្រោះគាត់បានរួចផុតពីគ្រោះថ្នាក់ក្នុងការវាយប្រយុទ្ធគ្នា ជាមួយគូសត្រូវគ្រប់សមរភូមិ រហូតដល់បានឡើងតំណែងតួនាទីជាបន្តបន្ទាប់ទៀតផង។

៤១
ឡឹក សំអឿន ឡើងឋានៈជាមេបញ្ជាការភាគឧត្តរទិស

នៅថ្ងៃដែលអនុសេនីយ៍ទោដួង ចន្ទសាវាត នាំកម្លាំងទាហានរាជរដ្ឋាភិបាលមកចូលរួមចលនាតស៊ូនោះ គឺកងកម្លាំងរក្សាសន្តិសុខរបស់គាត់នៅទីបញ្ជាការកណ្តាលនេះហើយដែលមានភារកិច្ចរៀបចំទទួលកម្លាំងទាហានទាំងនោះ នៅភូមិផ្អុង។

ក្រោយពីអនុសេនីយ៍ទោ ដួង ចន្ទសាវាត នាំទាហានរបស់គាត់ មួយកងអនុសេនាធំមកចុះចូលជាមួយប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ បានមួយសប្តាហ៍ សឺង ង៉ុកថាញ់ ក៏បានបង្កើតសាលាហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រ ជំនាន់ទី១ ដោយបានបញ្ជូនមេបញ្ជាការនិងស្នងការនយោបាយក្មេងៗ ឱ្យមករៀនសូត្រ ក្នុងនោះក៏មានឡឹក សំអឿន ម្នាក់ដែរ។

តែក្រោយពេលបើកវគ្គរៀនសូត្រក្បួនយុទ្ធសាស្ត្រនោះ បានប្រហែលមួយអាទិត្យ សម្តេចសីហនុ បានបញ្ជាឱ្យទាហានរាជរដ្ឋាភិបាល បើកប្រតិបត្តិការសឹកមួយ ដើម្បីវាយកម្ទេចចលនាតស៊ូរបស់សឺង ង៉ុកថាញ់ នៅលើភ្នំដងរែក ព្រោះព្រះអង្គពិរោធខ្លាំងនឹងនាយទាហានជំនិតរបស់ព្រះអង្គ គឺអនុសេនីយ៍ទោដួង ចន្ទសាវាត ដែលក្បត់ព្រះអង្គ នាំពលទាហានរាជរដ្ឋាភិបាល មួយកងអនុសេនាធំ មកចុះចូលជាមួយសឺង ង៉ុកថាញ់។

ពេលនោះ នាយទាហានតស៊ូជំនាន់ទី១ ដែលកំពុងតែហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រស្រាប់ ក៏បានចេញទៅប្រយុទ្ធទប់ទល់ និងបានវាយកម្ចាត់កម្លាំងទាហានរាជរដ្ឋាភិបាល ឱ្យដកថយអស់ពីលើភ្នំដងរែក វិញ។ ៣ថ្ងៃក្រោយមក សម្តេចសីហនុ ក៏បានឲ្យកងទ័ពបាវាំងបើកយន្តហោះទៅទម្លាក់គ្រាប់បែក នៅលើជំរំអូរស្មោច់ បណ្តាលឲ្យឆេះរោងស្នាក់នៅមួយកន្លែង តែមិនបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជីវិតអ្នកតស៊ូណាម្នាក់ឡើយ។

នៅពេលបិទបញ្ចប់វគ្គសិក្សាក្បួនយុទ្ធសាស្ត្រ ដែលមានរយៈពេលកន្លះខែនោះ ឡឹក សំអឿន និងមិត្តកក្តិគាត់ បានក្លាយជានាយទាហានជំនាន់ទី១ ហើយត្រូវបានរៀបចំពិធីបំពាក់ស័ក្តិ តាមក្បួនច្បាប់យ៉ាងត្រឹមត្រូវ ដោយមានលោកគ្រូអាចារ្យខៀវ ជុំ ជាអគ្គលេខា

ជិការប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ បានសម្តែងធម្មទេសនា អប់រំឱ្យគោរពក្រឹត្យវិន័យ របស់កងកម្លាំងតស៊ូ និងត្រូវប្រតិបត្តិតាមសីល៥របស់ព្រះពុទ្ធជាព្រះបរមគ្រូ ឱ្យបានខ្ជាប់ខ្ជួន ផងដែរ។

បន្ទាប់មក ឡឹក សំអឿន ត្រូវបានតែងតាំងជាមេបញ្ជាការរងយោធាភាគឧត្តរទិស និងសាង សាវាត ត្រូវបានតែងតាំងជានាយរងស្នងការនយោបាយ ភាគឧត្តរទិស ហើយ ត្រូវទៅធ្វើការជាមួយ ងួន ហុង មេបញ្ជាការយោធា និងថាច់ ចេន នាយស្នងការនយោបាយ ភាគឧត្តរទិស នៅទីតាំងជំរំទឹកថ្លា ស្ថិតនៅលើទីទួលភូមិចាស់មួយ ជាប់នឹងបឹងធំ មាន ទឹកថ្លាឆ្វង់ មើលទៅឃើញដល់បាតដី ព្រមទាំងមានសត្វក្រពើរស់នៅទៀតផង។

ទីតាំងនេះមានចម្ងាយ៥គីឡូម៉ែត្រ នៅទិសខាងលិចភូមិចុងកាល់ មានចម្ងាយ ១០ គីឡូម៉ែត្រ នៅទិសខាងត្បូងភូមិជើងទៀន មានចម្ងាយ១៥គីឡូម៉ែត្រ នៅទិសខាងជើងភូមិ តាវ៉ាក់ និងមានចម្ងាយ៣គីឡូម៉ែត្រ នៅទិសខាងកើតភូមិស្រីស្នំ និងស្ទឹងស្រែង។ ក្រោយពី បានទទួលតំណែងនោះមក ឡឹក សំអឿន និងសាង សាវាត បានធ្វើដំណើរជាមួយមេបញ្ជា ការងួន ហុង ចុះឃោសនាអប់រំ និងរៃអង្គាសប្រាក់ពីអ្នកភូមិ អស់រយៈ ពេល២សប្តាហ៍ ដើម្បីយកមកទ្រទ្រង់ដល់ចលនាតស៊ូ។

បន្ទាប់មក ងួន ហុង មេបញ្ជាការយោធា និងថាច់ ចេន នាយស្នងការនយោបាយ ភាគឧត្តរទិស ត្រូវអគ្គលេខាធិការតែងតាំងឱ្យទៅទទួលមុខតំណែងថ្មី នៅទីបញ្ជាការកណ្តាល នៅលើភ្នំដងរែក ឡឹក សំអឿន ត្រូវបានដំឡើងឋានៈជាមេបញ្ជាការយោធាភាគឧត្តរទិស និងសាង សាវាត ត្រូវបានដំឡើងថានៈ ជានាយស្នងការនយោបាយភាគឧត្តរទិស បន្តទៀត។

ពេលនោះ ដោយទើបចេញពីសាលាហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រថ្មីៗ ឡឹក សំអឿន ក៏ ចាប់ផ្តើមពង្រឹងការអនុវត្តក្រឹត្យវិន័យ និងសីលធម៌របស់កងកម្លាំងតស៊ូ ឱ្យកាន់តែរឹងមាំ ថែមទៀត ដោយត្រូវរក្សាសីល៥របស់ព្រះពុទ្ធជាព្រះបរមគ្រូ ឱ្យបានខ្ជាប់ខ្ជួន បើយុទ្ធជន ណាម្នាក់ប្រព្រឹត្តល្មើសក្រឹត្យវិន័យ ឬសីលធម៌របស់កងកម្លាំងតស៊ូនោះ ត្រូវតែទទួលទោស ឬដាក់វិន័យ។

ក្រោយពីទទួលបានការតែងតាំងជាមេបញ្ជាការយោធាភាគឧត្តរទិស បាន២សប្តាហ៍ ឡឹក សំអឿន និងសាំង សាវាត បានដឹកនាំកម្លាំងពីជំរំទឹកថ្លា ចេញទៅឃោសនានៅភូមិគុមភ្នៀង ជិតភូមិស្ពានស្រែង ក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប។

ថ្ងៃនោះ ពួកគាត់ក៏បានបន្តដំណើរទៅភូមិស្ពានស្រែង ដើម្បីទទួលស្វាគមន៍ទាហានជាប ឈួន ចំនួន៦នាក់ ដែលបានរត់ចោលជួរ មកចុះចូលជាមួយកងកម្លាំងតស៊ូរបស់គាត់ផងដែរ ហើយគាត់បានបញ្ជូនពួកទាហានជាប ឈួន ទាំង៦នាក់នោះ ទៅជំរំក្បាលខ្លា ជាជំរំសម្រាប់ទទួលអ្នកចំណូលថ្មី ស្ថិតនៅតាមដងស្ទឹងស្រែង ចម្ងាយ២គីឡូម៉ែត្រ ពីភូមិតា៉ាក់។

ពេលត្រលប់មកពីភូមិស្ពានស្រែងវិញ ស្រាប់តែមានដំណឹងអាក្រក់មួយថា យុទ្ធជនតស៊ូ៣នាក់នៅក្រោមបញ្ជារបស់គាត់ បានផឹកស្រាស្រវឹង ហើយបាញ់កាំភ្លើង បង្កឱ្យមានការភ្ញាក់ផ្អើលពេញភូមិគុមភ្នៀង រួចហើយនាំគ្នារត់ចេញទៅភូមិរោគ ដែលមានចម្ងាយ ២គីឡូម៉ែត្រ ពីភូមិគុមភ្នៀងនោះ។ មួយសន្ទុះក្រោយមក ព្រះគ្រូចៅអធិការវត្តរោគ ក៏និមន្តមកដល់ និងមានថេរដីកាថា ពួកគេទាំង៣នាក់នោះ ប្រាកដជាទៅចុះចូលជាមួយរាជការខ្មែរ-បារាំង នៅបន្ទាយក្នុំស្រុក ហើយ។ ដូច្នេះ ព្រះអង្គប្រាប់ឲ្យឡឹក សំអឿន ធ្វើយ៉ាងណាដើម្បីឱ្យពួកគេវិលត្រលប់មកវិញ។

ឡឹក សំអឿន ទូលទៅព្រះគ្រូចៅអធិការវិញថា គាត់មិនអាចទៅតាមអង្វរឱ្យពួកនោះវិលត្រលប់មកវិញបានទេ ព្រោះថា បើគាត់ទៅអង្វរពួកគេ ដែលបានប្រព្រឹត្តល្មើសនឹងក្រឹត្យវិន័យនោះ តើគាត់អាចដឹកនាំបញ្ជាពួកនេះ ទៅថ្ងៃមុខទៀតបានដែរឬទេ ? ដូច្នេះគាត់នឹងមិនទៅអង្វរពួកនេះជាដាច់ខាត។

ព្រះគ្រូចៅអធិការ ក៏ងាកព្រះភក្ត្រទៅរកសាង សាវាត ជានាយស្នងការនយោបាយឲ្យជួយសម្របសម្រួលរឿងនេះជាបន្ទាន់ បើពុំនោះទេ ពួកគេទាំង៣នាក់នោះ នឹងទៅចុះចូលជាមួយរាជរដ្ឋាភិបាល មិនខាន។ សាង សាវាត ក៏សុខចិត្តយល់ព្រមរួមដំណើរជាមួយលោកគ្រូចៅអធិការ ទៅជួបនិយាយជាមួយពួកយុទ្ធជនខិលខូចទាំង ៣នាក់នោះ ឱ្យវិល

ត្រលប់មកវិញដែរ តែពុំបានសម្រេច ដោយពួកនោះប្រាប់ថា ពួកគេត្រូវការជួបតែមេបញ្ជាការឡឹក សំអឿន ម្នាក់ប៉ុណ្ណោះ ហើយពួកគេគ្មានបំណងអ្វី ក្រៅតែចង់កាច់បំបាក់មេក្រុមរបស់គេផ្ទាល់ ដែលមានជម្លោះជាមួយគ្នាតែប៉ុណ្ណោះ។

ព្រឹកស្អែកឡើង ព្រះគ្រូចៅអធិការ ក៏និមន្តមកជួបឡឹក សំអឿន ជាលើកទី២ ហើយប្រាប់ថា ពួកឃុទ្ធជនខិលខូចទាំង៣នាក់នោះ នឹងធ្វើដំណើរទៅចុះចូលជាមួយទាហាននៅបន្ទាយភ្នំស្រុក ក្នុងថ្ងៃនេះ ប្រសិនបើគាត់មិនព្រមទៅជួបពួកគេទេ។

ឡឹកសំ អឿន នៅតែប្រកាន់ជំហររឹងប៉ឹងដដែល ហើយទូលទៅព្រះគ្រូចៅអធិការថា សូមព្រះតេជគុណកុំឃាត់ឃាំងពួកគេតទៅទៀតអី ទុកឲ្យពួកគេនាំគ្នាទៅចុះ តែគាត់ គ្រាន់តែសុំផ្តាំផ្ញើពាក្យពីរបីម៉ាត់ទៅពួកគេទាំងនោះថា សូមឲ្យពួកគេចេះគិតដល់គ្រួសារ និងប្រទេសជាតិរបស់ខ្លួនខ្លះផង។

លុះដល់រសៀល វេលាម៉ោង២រសៀលថ្ងៃដដែល ពួកគេទាំង៣នាក់ ក៏បានមកសុំជួបឡឹក សំអឿន សូមទោស កុំឲ្យប្រកាន់ពួកគេ ហើយពួកគេសន្យាថា លែងធ្វើផ្តេសផ្តាសរបៀបនេះទៀតហើយ។

ឡឹក សំអឿន ក៏តបទៅវិញថា គាត់មិនមានបំណងដាក់ទោសដល់អ្នកណាម្នាក់ឡើយ គ្រាន់តែគាត់មិនព្រមជួបពួកគេតែប៉ុណ្ណោះ។ ឥឡូវ បើពួកគេទទួលសារភាពថា ខ្លួនបានប្រព្រឹត្តខុសវិន័យ ហើយព្រមកែខ្លួនឲ្យបានត្រឹមត្រូវ សមជាកម្លាំងអ្នកតស៊ូ គាត់ក៏ទុកពេលឱ្យពួកគេកែខ្លួន ដោយមិនយកទោសពៃអ្វីឡើយ។

ឡឹក សំអឿន បានបន្ថែមថា រឿងប្រតិព័ទ្ធស្នេហារវាងប្រុស និងស្រី ទោះបីជារឿងធម្មជាតិរបស់សត្វលោកមែន ប៉ុន្តែដាច់ខាតគាត់មិនឱ្យកងទ័ពរបស់គាត់ ប្រើអំណាចគំរាមកំហែងបង្ខិតបង្ខំទៅលើនារីណាម្នាក់ឡើយ។ ប្រសិនបើកងទ័ពរបស់គាត់ចាប់ចិត្តស្រលាញ់លើនារីជាកូនចៅអ្នកភូមិណាម្នាក់ ត្រូវប្រាប់មេកោយរបស់ខ្លួន ហើយសុំឲ្យជួយធ្វើមេបាចៅមហាចូលស្តីដណ្តឹង រួចរៀបការតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ដោយមានរូបគាត់ផ្ទាល់ជួយដឹងឮ ឬទៅធ្វើជាអធិបតីក្នុងពិធីមង្គលការនោះផងដែរ។

របត់នយោបាយ

ក្រោយពីវិលមកដល់ជំរំទឹកថ្លា វិញ ឡឹក សំអឿន បានទទួលលិខិតមួយច្បាប់ពីអគ្គលេខាធិការដ្ឋាន នៅភ្នំដងរែក បញ្ជាឱ្យគាត់ជ្រើសរើសនាយទាហានរង និងអ្នកចំណូលថ្មី ចំនួន២០នាក់ ឱ្យទៅចូលរៀនវគ្គនាយទាហានរង ជំនាន់ទី១ នៅទីបញ្ជាការធំ លើភ្នំដងរែក។ ពេលនោះគាត់ក៏បានបញ្ជូនសហការី ចំនួន២០នាក់ ក្នុងនោះមានអ្នកចំណូលថ្មី ១៧នាក់ និងពលទាហាន៣នាក់ ដែលបានបង្ករឿងបាញ់បោះសេរី កាលពីថ្ងៃមុននោះ ផងដែរ។

បន្ទាប់ពីមានហេតុការណ៍ដូចរៀបរាប់ខាងលើនេះមក ឡឹក សំអឿន និងសាង សាវាត បានសម្រេចបើកសាលាអប់រំយុទ្ធជន និងគណៈកម្មការភូមិឃុំស្រុក រយៈពេល ៣សប្តាហ៍ នៅជំរំសុខសាន្ត ដែលស្ថិតក្នុងព្រៃស្រោងមួយ នៅខាងលើភូមិគោករមៀត តាមដងស្ទឹងស្រែង។

ជាមួយគ្នានោះ គាត់បានជ្រើសរើសយុទ្ធជនថ្មី មានអាយុចាប់ពី១៨ឆ្នាំ ទៅដល់ ២៥ឆ្នាំ នៅតាមភូមិនានា ព្រមទាំងអ្នកចំណូលថ្មី នៅជំរំក្បាលខ្លា ចំនួន៣០នាក់ទៀត ឱ្យចូលមករៀននៅសាលាអប់រំនោះ ដើម្បីដាក់ជំនួសយុទ្ធជនដែលបានបម្រើចលនាតស៊ូយូរមកហើយ ឱ្យទៅទទួលមុខនាទី ជាមេក្រុមរក្សាសន្តិសុខ នៅតាមភូមិកំណើតរបស់ពួកគេវិញ។

នៅជំរំក្បាលខ្លានោះដែរ ឡឹក សំអឿន បានជ្រើសរើសកូនចៅអ្នកភូមិ វ័យជំទង់ៗ មានអាយុពី១៣ ទៅ១៥ឆ្នាំ មកបណ្តុះបណ្តាលជាកម្លាំងស្នូល (កម្លាំងបង្កប់) ព្រោះរាជការពុំសូវចាប់អារម្មណ៍ និងសង្ស័យទៅលើពួកក្មេងៗទាំងនោះទេ។

៤២
ឡឹក សំអឿន ដើរយោសនាផង និងរៃអង្គាសប្រាក់ផង

ទន្ទឹមគ្នានោះ ឡឹក សំអឿន បានតាំងមូលដ្ឋានប្រតិបត្តិការធំ ២កន្លែងទៀត គឺ១. មូលដ្ឋានរាជសីហ៍ តាំងនៅជិតភូមិសង្កែស្នួល មានវិសាលភាព ចាប់ពីថ្នល់ជាតិលេខ៦ ទៅទិសខាងជើង រហូតទល់នឹងភ្នំគូលែន។ ២.មូលដ្ឋានពស់វែកក្របី មានវិសាលភាព ចាប់ពីព្រៃរនាម ខាងត្បូងដងស្ទឹងស្រែង និងដងស្ទឹងសង្កែ រហូតដល់មាត់ទន្លេសាប។ នៅរដូវប្រាំង មានប្រជារាស្ត្រនៅខាងជើងផ្លូវជាតិលេខ៦ នាំគ្នាចុះមកសង់រោងស្នាក់នៅតំបន់ព្រៃរនាម ដើម្បីធ្វើស្រែប្រាំង និងរកត្រីសាច់ធ្វើប្រហុក ផ្អក ត្រីងៀត ត្រីឆ្អែ ដើម្បីត្រៀមទុកសម្រាប់ផ្គត់ផ្គង់ជីវភាពពេលរដូវវស្សា និងលក់ដូរខ្លះផងដែរ។

ពីមុនមក តំបន់នេះ ជាតំបន់កាន់កាប់ដោយមេខ្មែរឥស្សរៈស័ក្តិ៣ ឈ្មោះអ៊ូច តែក្រោយពីគាត់ដាក់អាវុធ ទៅចុះចូលជាមួយរាជរដ្ឋាភិបាលមក ពួកខ្មែរវៀតមិញ នៅបាត់ដំបងក៏មានបំណងចង់ចូលមកកាន់កាប់តំបន់នេះដែរ។

បន្ទាប់ពីរៀបចំមូលដ្ឋានប្រតិបត្តិការធំៗ ២កន្លែងនេះរួច ឡឹក សំអឿន ក៏ចាប់ផ្តើមចុះទៅជួបប្រជារាស្ត្រ ដែលនាំគ្នាមកសង់រោងស្នាក់នៅជាក្រុមៗ ដោយក្នុង១ក្រុមៗ មានគ្នាពី២០ ទៅ៣០គ្រួសារ ដើម្បីធ្វើស្រែប្រាំង និងរកត្រីនៅក្នុងតំបន់ព្រៃរនាមឱ៉ម៉ាល់បាត្រង់ រហូតដល់ព្រៃរនាមពួក និងស្ទឹងកំបុត ព្រមទាំងស្ទឹងសង្កែ ទៅដល់ព្រែកទាល់ នៅមាត់ទន្លេសាប។

ឡឹក សំអឿន គិតថា ប្រជារាស្ត្រពី២០ ទៅ៣០គ្រួសារ ចាត់ទុកដូចជាភូមិមួយដែរ ដូច្នេះក្រៅពីមានទំនាក់ទំនងជិតស្និទ្ធជាមួយប្រជារាស្ត្រទាំងអស់នោះ គាត់បានធ្វើការអប់រំផ្សព្វផ្សាយពីគោលនយោបាយរបស់ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ឱ្យប្រជារាស្ត្រទាំងអស់នោះ បានយល់ជ្រួតជ្រាបផង និងជួយថែរក្សាសន្តិសុខឱ្យប្រជារាស្ត្រនៅតាមរោងស្នាក់នៅជាក្រុមៗនោះ រហូតដល់រដូវវស្សា ទើបប្រជាពលរដ្ឋទាំងនោះ ត្រលប់ទៅភូមិស្រុកវិញ។

ជាមួយគ្នានោះដែរ គាត់បានដើរឃោសនានៅតាមភូមិនានានៅជិតផ្សារពួក និងនៅស្ទឹងកំបុត នៅជាប់មាត់ទន្លេសាប ដែលនៅទីនោះ មានប៉ុស្តិ៍កងរាជតម្រួតមួយ មានគ្នាចំនួន ១២នាក់។ ពេលនោះ គាត់បានផ្ញើលិខិតមួយ ទៅចៅហ្វាយស្រុកពួក សុំឲ្យជួយរៃអង្គាសប្រាក់ពីប្រជារាស្ត្រនៅផ្សារពួក ឱ្យបានប្រាក់ចំនួន៥៣ន់រៀល ដើម្បីយកមកជួយឧបត្ថម្ភដល់កម្លាំងរបស់គាត់។ តែចៅហ្វាយស្រុកនោះ បានតបមកវិញថា បើអស់លោកចង់រៃអង្គាសប្រាក់កាសពីប្រជារាស្ត្រនៅផ្សារពួក សូមទៅរៃអង្គាសដោយខ្លួនឯងចុះ។

ឡឹក សំអឿន នឹកថា ប្រហែលជាចៅហ្វាយស្រុកនោះគិតថា សាលាស្រុកពួកស្ថិតនៅជិតទីរួមខេត្តសៀមរាប ដែលមានកងកម្លាំងទាហានរបស់រាជរដ្ឋាភិបាលច្រើន ពួកគាត់មិនហ៊ានធ្វើអី ទើបប្រើសម្តីបែបនេះ តបមកវិញ? តែគាត់មិនទាន់មានប្រតិកម្មអ្វីតបទៅចៅហ្វាយស្រុកនោះវិញទេ ហើយពួកគាត់ក៏នាំគ្នាត្រលប់ទៅមូលដ្ឋានវិញ។

៣ថ្ងៃក្រោយមក ពួកគាត់បានចេញទៅឃោសនា នៅតាមដងស្ទឹងសង្កែ ចាប់ពីភូមិទ្រាយ ទៅដល់ទីប្រជុំជនព្រែកទ័ល នាមាត់ទន្លេសាប។ ពួកគាត់ទៅដល់ភូមិទ្រាយ ប្រហែលម៉ោង៦ល្ងាច ហើយសុំឱ្យមេភូមិជួយរកទូកចំណុះមនុស្ស៦នាក់ ចំនួន៣គ្រឿង និងទូកចំណុះមនុស្ស១២នាក់ ចំនួន៤គ្រឿង ត្រៀមទុកជាស្រេច។

លុះដល់៣ក់កណ្តាលអធ្រាត្រ កម្លាំងគាត់ចំនួន១៨នាក់ ធ្វើដំណើរទៅទីប្រជុំជនព្រែកទ័ល ចំណែក១២នាក់ទៀត ទុកឲ្យនៅក្នុងភូមិទ្រាយ ដើម្បីចាំស្ទាក់ផ្លូវ ក្រែងមានកម្លាំងទាហានរបស់រាជរដ្ឋាភិបាល ពីបន្ទាយបាក់ព្រា មកវាយប្រហារពួកគាត់។

លុះទៅដល់ភូមិបែកថ្លាង ដែលនៅចម្ងាយ៥គីឡូម៉ែត្រ ពីភូមិទ្រាយ គាត់បានទុកយុទ្ធជន៣នាក់ ព្រមទាំងទូកចំណុះមនុស្ស១២នាក់ ទាំង៤គ្រឿង ឲ្យសំចតនៅក្នុងភូមិបែកថ្លាង នោះសិន ដើម្បីរង់ចាំកម្លាំងគាត់ ដែលទៅទីប្រជុំជនព្រែកទ័ល ត្រលប់មកវិញ។ នៅសល់យុទ្ធជន១៥ នាក់ទៀត គាត់ឱ្យជិះទូក ចំនួន៣គ្រឿង ទៅទីប្រជុំជនព្រែកទ័ល នៅមាត់ស្ទឹងសង្កែ ក្បែរបឹងទន្លេសាប ដើម្បីចូលទៅក្នុងវត្តមួយ នៅជើមភូមិ ដោយនៅចម្ងាយប្រហែល៥០០ម៉ែត្រ ពីវត្តនោះ មានបន្ទាយកងតម្រួតមួយ មានគ្នាតែជាង១០នាក់ប៉ុណ្ណោះ

នៅរក្សាការពារសុវត្ថិភាព។

វត្ត និងទីតាំងបន្ទាយកងតម្រួតនោះ ខណ្ឌចែកគ្នាដោយព្រៃស្នាតមួយ ហើយផ្លូវចុះទៅមាត់ទន្លេ មានផ្ទះអ្នកស្រុក និងមានផ្សារមួយនៅលើផៃ នៅមាត់ច្រាំងខាងស្តាំដៃ គេឃើញសុទ្ធតែផ្ទះសម្បែងរបស់អ្នកស្រុក លើកលែងតែនៅមុខបន្ទាយប្រហែល១០០ម៉ែត្រជាព្រៃស្នាតដែរ។ ពួកគាត់បានទៅដល់ទីប្រជុំជនព្រែកទ័ល ប្រហែលម៉ោង៥ភ្លឺ ហើយឈប់ត្រង់ដើមកូមិ រួចចែកកម្លាំងជាពីរពួក គឺពួកទី១ មានគ្នា៧នាក់ មានគាត់ (ឡឹក សំអឿន) ជាអ្នកដឹកនាំផ្ទាល់ ដើរប្រមែប្រមូលអ្នកភូមិ ឱ្យចូលទៅក្នុងវត្ត ដើម្បីបើកអង្គប្រជុំឃោសនា។ ឯពួកទី២ មានគ្នា៨នាក់ ត្រៀមចាំនៅមាត់ច្រាំងខាងស្តាំ ដើម្បីការពារ ក្រែងពួកតម្រួត ចេញពីបន្ទាយ ដែលនៅចម្ងាយប្រហែល៥០០ម៉ែត្រ ពីវត្តនោះ វាយប្រហារពួកគាត់។

ឡឹក សំអឿន បានតាំងកាំភ្លើងយន្តមួយដើម នៅចំមុខខ្លោងទ្វារវត្ត តម្រង់ទៅកបន្ទាយកងតម្រួតនោះ ហើយចាត់គ្នាមួយចំនួន ឱ្យដើរប្រមូលប្រជាពលរដ្ឋនៅក្នុងភូមិ ឲ្យមកស្តាប់ការឃោសនារបស់គាត់ និងរៃអង្គាសប្រាក់ពីប្រជាពលរដ្ឋដែលមានរាយឈ្មោះក្នុងបញ្ជីជាស្រេច ក្នុងនោះភាគច្រើនជាពួកអ្នកមានជីវភាពធូរធារ ព្រមទាំងអ្នកជំនួញ និងដង្កៀជាដើម។

នៅវេលាម៉ោង៧ព្រឹក ឡឹក សំអឿន កំពុងស្ថិតនៅក្នុងវត្ត បានប្រើអ្នកភូមិម្នាក់ ឱ្យយកលិខិតមួយទៅជូនមេកងតម្រួត ដែលកំពុងនៅក្នុងបន្ទាយនោះ។

លិខិតនោះមានខ្លឹមសារថា កងកម្លាំងតស៊ូយើងដែលចូលទីនេះ គឺមានបំណងត្រឹមតែឃោសនាអប់រំប្រជាពលរដ្ឋឱ្យយល់ពីគោលនយោបាយទាមទារឯករាជ្យរបស់យើង ពីពួកអាណានិគមបារាំង និងរៃអង្គាសប្រាក់កាសសម្រាប់ឧបត្ថម្ភកងកម្លាំងតស៊ូយើង ដែលមានសឹង ង៉ុកថាញ់ ជាប្រមុខដឹកនាំប៉ុណ្ណោះ។ យើងគ្មានបំណងវាយប្រហារខ្មែរគ្នាឯងទេ ហេតុនេះ សូមលោកជាមេតម្រួត កុំធ្វើសកម្មភាពអ្វីដែលនាំឲ្យប៉ះទង្គិចគ្នា ជាមួយកម្លាំងតស៊ូរបស់យើងឲ្យសោះ បើពុំនោះទេ កម្លាំងតស៊ូយើងចាំបាច់ត្រូវប្រយុទ្ធការពារខ្លួនវិញ

ជាមិនខាន។

ក្រោយពីបានទទួលលិខិតនោះមក វេលាម៉ោង៩ព្រឹក ក៏មានឮសំឡេងផ្លុំត្រែ ប្រមូលកម្លាំងនៅក្នុងបន្ទាយ ហើយតម្រួតបីបួននាក់ ដែលបម្រុងដើរទៅផ្សារនៅលើផៃ ខាងមុខបន្ទាយនោះ ក៏នាំគ្នារត់ចូលបន្ទាយវិញអស់។ បន្ទាប់ពីគ្មានប្រតិកម្មអ្វីពីពួកតម្រួតទាំងនោះឡឹក សំអឿន ក៏ចាប់ផ្តើមឡើងមានមតិឃោសនាអប់រំប្រជាពលរដ្ឋក្នុងភូមិ ដោយប្រើឧគ្ឃោសនសព្ទរបស់វត្តេ ជះសំឡេងរំពងពេញទាំងភូមិ រហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបបិទអង្គប្រជុំ។

វេលាម៉ោង១រសៀល ពួកគាត់ក៏ធ្វើដំណើរតាមទូក វិលត្រលប់ទៅវិញ។ រហូតដល់ម៉ោង៥ ទើបទៅដល់ភូមិបែកថ្លាង ហើយនាំគ្នាឡើងគោក ក៏បានឮដំណឹងថា មានទាហានរាជរដ្ឋាភិបាល មកពីបន្ទាយបាក់ព្រា បានចុះមករកវាយប្រហារពួកគាត់ដែរ តែពេលមកដល់ភូមិទ្រាយ ដោយដឹងថា កងទ័ពគាត់មានគ្នាច្រើនទូក ក៏នាំគ្នាត្រលប់ទៅបន្ទាយបាក់ព្រា វិញអស់។ ទីបំផុត ពួកគាត់ក៏នាំគ្នាដើរពីភូមិបែកថ្លាង ទៅដល់ជំរំទឹកថ្លា វិញ ដោយសុវត្ថិភាព។

ក្រោយពីសម្រាកក្នុងជំរំបាន៣ថ្ងៃ ឡឹក សំអឿន ក៏នាំកម្លាំងចេញទៅធ្វើការឃោសនា និងរៃអង្គាសប្រាក់ពីប្រជាពលរដ្ឋនៅស្រុកពួក ជាលើកថ្មីម្តងទៀត។ លើកនេះ គាត់បានផ្ញើលិខិតមួយច្បាប់ទៅចៅហ្វាយស្រុកពួក សុំឱ្យគេធ្វើតាមសំណើរបស់គាត់ កាលពីថ្ងៃមុន គឺសុំឱ្យជួយរៃអង្គាសប្រាក់ពីប្រជារាស្ត្រនៅផ្សារពួក ឱ្យបាន៥ពាន់រៀល ដើម្បីយកមកទ្រទ្រង់ចលនាតស៊ូរបស់គាត់។ ជាមួយគ្នានេះ គាត់បានព្រមានថា បើមិនបានទេ សុំឲ្យលោកចៅហ្វាយស្រុក រើសាលាស្រុក ទៅតាំងនៅឯក្រុងសៀមរាប វិញទៅ! ហើយលោកចៅហ្វាយស្រុកឯង ព្រមទាំងគ្រួសារ កុំធ្វើដំណើរចេញពីក្រុងសៀមរាប ឱ្យសោះ បើពុំនោះទេ ប្រាកដជាជួបគ្រោះថ្នាក់ធំមិនខាន ព្រោះសូម្បីតែទីប្រជុំជនព្រៃកទ័ល គ្មានផ្លូវដើរទៅផង មានតែជិះទូក និងមានកងតម្រួតមួយបន្ទាយ នៅការពារផង ក៏កម្លាំងគាត់នៅតែអាចចូលទៅបានទាំងថ្ងៃ ចុះទម្រាំផ្សារពួក មានកងរាជតម្រួតមួយជំបស្ងា កុំស្មានថា កម្លាំងគាត់មិន

ហ៊ានវាយឱ្យសោះ។ ហេតុនេះ បើលោកចៅហ្វាយស្រុក ចង់សុខ និងមិនចង់ឲ្យមានគ្រោះថ្នាក់ដល់ប្រជារាស្ត្រទេ សូមធ្វើតាមសំណើគាត់ជាបន្ទាន់។

នៅវេលាម៉ោង២រសៀល តំណាងចៅហ្វាយស្រុក ពីរនាក់បានមកសុំជួបឡឹក សំអឿន នៅក្នុងព្រៃរនាម ហើយប្រាប់ថា ចៅហ្វាយស្រុក សុខចិត្តធ្វើតាមសំណើនោះហើយ តែរយៈពេល២អាទិត្យទៀត ទើបអាចប្រមូលប្រាក់បាន ៥ពាន់រៀលនោះ មកជូនឱ្យគ្រប់ចំនួន។ ពេលនោះ ឡឹក សំអឿន ក៏ឆ្លៀតឱកាសឃោសនាអប់រំតំណាងចៅហ្វាយស្រុកទាំងពីរនោះ អស់រយៈពេលមួយម៉ោង ហើយបានផ្តាំឱ្យទៅជម្រាបចៅហ្វាយស្រុក ផងថា កងកម្លាំងតស៊ូគាត់ សូមថ្លែងអំណរគុណចំពោះលោកចៅហ្វាយស្រុក ដែលមានចិត្តសប្បុរសក្នុងការជួយរៃអង្គាសប្រាក់ ដើម្បីយកមកជួយឧបត្ថម្ភដល់កងកម្លាំងតស៊ូគាត់ផងដែរ។

ឡឹក សំអឿន បញ្ជាក់បន្ថែមថា សូមឲ្យលោកចៅហ្វាយស្រុក ចាត់តំណាងឱ្យយកប្រាក់ដែលរៃអង្គាសបាននោះ ទៅប្រគល់ឲ្យគាត់នៅត្រង់ស្ពានស្រែង ក្នុងតំបន់ដែលគាត់គ្រប់គ្រង ក្នុងរយៈពេល១អាទិត្យយ៉ាងយូរ ព្រោះកងកម្លាំងតស៊ូរបស់គាត់ត្រូវចេញទៅបំពេញបេសកកម្មនៅកន្លែងជាច្រើនផ្សេងៗទៀត។

មួយសប្តាហ៍ក្រោយមក តំណាងចៅហ្វាយស្រុកពួក ទាំង២នាក់ ក៏បានយកប្រាក់ចំនួន៥ពាន់រៀល ទៅប្រគល់ឲ្យគណៈកម្មការចលនាតស៊ូប្រចាំស្រុកក្រឡាញ់ នៅត្រង់កន្លែងដែលបានកំណត់ទុក ដូចការសន្យា។

ពេលចាប់ផ្តើមធ្លាក់ភ្លៀងចូលរដូវវស្សា ប្រជារាស្ត្រស្នាក់នៅតាមរោងនានា ក៏បាននាំគ្នាត្រលប់ទៅផ្ទះសម្បែង នៅឯភូមិស្រុករបស់ពួកគេវិញអស់ កម្លាំងតស៊ូនៅជំរំពស់វែកក្របី ត្រូវដកទៅរួមគ្នានៅជំរំរាជសីហ៍ ដោយទុកគ្នាតែ១២នាក់នៅចាំជំរំ ព្រោះក្នុងរដូវវស្សាត្រូវរស់នៅលើក្បូន និងនៅទូកតែប៉ុណ្ណោះ។ ចំណែកភារកិច្ច ក៏គ្មានអ្វី ក្រៅតែពីបង្ហាញខ្លួនឲ្យប្រជារាស្ត្រមើលឃើញថា កម្លាំងតស៊ូបានឈរជើងប្រចាំជាអចិន្ត្រៃយ៍នៅទីនោះ និងជាកន្លែងដែលកម្លាំងតស៊ូត្រូវដកថយទៅសំងំលាក់ខ្លួន នៅពេលណាទាហានរាជរដ្ឋាភិបាលបើកប្រតិបត្តិការវាយប្រហារនៅទីតាំងផ្សេងៗទៀតដែលនៅតំបន់ក្បែរៗនោះ។

ក្នុងខែកញ្ញា ឆ្នាំ១៩៥៣ សាង សារ៉ាត ជានាយស្នងការនយោបាយភាគឧត្តរទិស ត្រូវអគ្គលេខាធិការដ្ឋានផ្លាស់ប្តូរឲ្យទៅទទួលតំណែងថ្មី នៅទីបញ្ជាការកណ្តាល លើភ្នំដងរែក ព្រោះតាំងពីខែកក្កដា មក អៀ ស៊ីចូវ, អ៊ឹង ម៉េងគ្រុយ, ស្រី ឫទ្ធី, ឃី តាំងលឹម និងគ្រូ អឹម មិនដឹងជាទៅទីណាបាត់អស់។

ជាមួយគ្នានោះ ក៏មានឮពាក្យចចាមអារ៉ាមថា សឺង ង៉ុកថាញ់ និងអៀ ស៊ីចូវ មានជម្លោះ ដោយសារខ្វែងគំនិតគ្នាក្នុងការដឹកនាំ។ ពេលនោះ ឡឹក សំអឿន ក៏ធ្វើដំណើរឡើងលើភ្នំដងរែក ទៅជួបលោកគ្រូអាចារ្យខៀវ ជុំ ជាអគ្គលេខាធិការនៃចលនាតស៊ូ ដើម្បីចង់ដឹងច្បាស់ពីរឿងនេះ តើពិតដែរឬទេ?

ពេលគាត់ទៅដល់ជំរំអូរស្មាច់ មិត្តរួមជំនាន់តស៊ូជាមួយគ្នា ឈ្មោះស្ពាន់ សំជឹម ក៏យកសំបុត្ររបស់អៀ ស៊ីចូវ មួយច្បាប់ មកប្រគល់ឲ្យគាត់។ ក្នុងសំបុត្រនោះ អៀ ស៊ីចូវ បានសរសេរប្រាប់គាត់(ឡឹក សំអឿន) ឱ្យទៅជួបគ្នា នៅឯក្រុងបាងកក។ ជាមួយគ្នានោះ ស្ពាន់ សំជឹម ក៏បានប្រាប់ឡឹក សំអឿន ថា ការបែកបាក់រវាងសឺង ង៉ុកថាញ់ និងអៀ ស៊ីចូវ គឺជារឿងពិតប្រាកដណាស់។

ព្រឹកស្អែកឡើង ឡឹក សំអឿន ក៏ចូលទៅថ្វាយបង្គំលោកគ្រូអាចារ្យខៀវ ជុំ ដើម្បីសួរបញ្ជាក់រឿងនេះ ឱ្យកាន់តែច្បាស់ថែមទៀត លោកគ្រូអាចារ្យខៀវ ជុំ បានមានថេរដីកាថា ការបែកបាក់គ្នានេះ មានប្រាកដមែន ឥឡូវអៀ ស៊ីចូវ និងសហការីមួយចំនួន បានធ្វើដំណើរចេញទៅបាត់ហើយ។

ឮដូច្នោះ ឡឹក សំអឿន មានការខកចិត្តយ៉ាងខ្លាំង ហើយក៏សុំលាឈប់ពីតំណែងភ្លាមៗដែរ តែលោកគ្រូអាចារ្យខៀវ ជុំ មិនព្រម ហើយប្រាប់ថា ចាំជួបសឺង ង៉ុកថាញ់ ជាអ្នកសម្រេចសិន។ លុះដល់ល្ងាចថ្ងៃដដែលនោះ សឺង ង៉ុកថាញ់ ក៏បានហៅឡឹក សំអឿន ឲ្យទៅជួបនៅកន្លែងរបស់គាត់តែពីរនាក់ស្ងាត់ៗ រួចសឺង ង៉ុកថាញ់ ក៏បាននិយាយរឿងពិតប្រាប់គាត់ថា អៀ ស៊ីចូវ, អ៊ឹង ម៉េងគ្រុយ, ស្រី ឫទ្ធី, ឃី តាំងលឹម និងគ្រូអឹម ត្រូវចេញទៅបំពេញបេសកកម្មពិសេសមួយ គឺរកផ្លូវទៅទាក់ទងមេដឹកនាំចិនប្រជាមានិត ដើម្បីរកជំនួយ។

ដោយសាររឿងនេះ ជារឿងដែលត្រូវលាក់ការណ៍សម្ងាត់បំផុត ដូច្នេះត្រូវតែប្រតិដ្ឋថា គាត់ (សឺង ង៉ុកថាញ់) និងអៀ ស៊ីចូវ មានជម្លោះបែកបាក់គ្នា ហើយអៀ ស៊ីចូវ បាននាំសហការី មួយចំនួន ចេញពីចលនាតស៊ូនៅភ្នំដងរែក នេះហើយ។

លុះប្រាប់ការពិតហើយ សឺង ង៉ុកថាញ់ ក៏បានហាមឡឹក សំអឿន កុំឲ្យនិយាយរឿងនេះប្រាប់នរណាទៀតឲ្យសោះ ហើយបើមានគេសួររឿងនេះ ត្រូវប្រាប់គេវិញថា គាត់(សឺង ង៉ុកថាញ់) និងអៀ ស៊ីចូវ ពិតជាមានការបែកបាក់គ្នាដោយសារបញ្ហាមិនចុះសម្រុងគ្នាក្នុងការដឹកនាំពិតប្រាកដមែន។ លុះស្អែកឡើង ពេលឡឹក សំអឿន ចូលទៅថ្វាយបង្គំលាលោកគ្រូអាចារ្យខៀវ ជុំ ត្រលប់មកមូលដ្ឋានទឹកថ្លា វិញ ព្រះគ្រូអាចារ្យក៏បានហុចលិខិតតែងតាំងគាត់ជាមេបញ្ជាការយោធាផង ជានាយស្នងការនយោបាយភាគឧត្តរទិសផង ព្រមទាំងបានប្រគល់សហការី៣នាក់ទៀត គឺ ស្ពាន់ សំដឹម, ញឹក ញ៉ុក និងស កាពុន ដែលជានាយទាហានជំនាន់ទី២ ឲ្យទៅបម្រើការងារជាមួយគាត់ផងដែរ។

ទាក់ទងរឿង អៀ ស៊ីចូវ និងសហការី៤នាក់ទៀត ចេញទៅបំពេញបេសកកម្មពិសេស ដើម្បីទាក់ទងមេដឹកនាំចិនប្រជាមានិតនេះ ប្រហែលពីរបីខែក្រោយមក ក៏ឮដំណឹងថា ពួកគាត់ត្រូវពួកវៀតមិញ ចាប់បាននៅវៀតណាមខាងជើង ក្បែរព្រំដែនប្រទេសចិន រួចបានបញ្ជូនឱ្យត្រលប់មកប្រទេសខ្មែរ វិញហើយ។

៤៣
ព្រះមហាក្សត្រសីហនុ រំលាយរាជរដ្ឋាភិបាល និងរដ្ឋសភា



ទ្រង់សិរិមត: ព្រះអគ្គម្ចាស់ក្សត្រី ម៉ែឧប៉ោះយុគន្ធរ និងព្រះមហាក្សត្រសីហនុ

ក្រោយពីសឹង ង៉ុកថាញ់ ប្រកាសបង្កើតប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ មក នៅក្នុងខែឧសភា ឆ្នាំ១៩៥២ ក៏មានបាតុកម្មប្រឆាំងនឹងបារាំង នៅទីក្រុងភ្នំពេញ នៅទីរួមខេត្តបាត់ដំបង និងនៅទីរួមខេត្តកំពង់ចាម ជាបន្តបន្ទាប់។ នៅអនុវិទ្យាល័យព្រះសីហនុ ទីរួមខេត្តកំពង់ចាម សាស្ត្រាចារ្យបារាំង ម្នាក់ ត្រូវសិស្សគប់នឹងដុំថ្ម។

ប៉ុន្មានសប្តាហ៍ក្រោយមកទៀត ព្រះមហាក្សត្រសីហនុ បានដឹងថា គណបក្សប្រជាធិបតេយ្យ បានបញ្ជាឱ្យសុន វ៉ឺនសៃ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារជាតិ លួចដឹកជញ្ជូនថ្នាំពេទ្យ អាវុធ និងគ្រាប់រំសេវមួយចំនួន ដែលប្រទេសបារាំង ផ្តល់ជាជំនួយដល់កងយោធពលខេមរភូមិន្ទរបស់ព្រះអង្គ យកទៅផ្តល់ឱ្យចលនាតស៊ូរបស់សឹង ង៉ុកថាញ់ ។

ព្រះអង្គបានដឹងទៀតថា នៅស្រុកសំរោង និងស្រុកចុងកាល់ ស្ថិតនៅភាគខាងជើង

ក្រុងសៀមរាប និងនៅស្រុកព្រះនេត្រព្រះ ក្នុងខេត្តបាត់ដំបង (បច្ចុប្បន្នជាខេត្តបន្ទាយមានជ័យ) កងទ័ពរបស់សឺង ង៉ុកថាញ់ មានសុទ្ធតែកាន់កាំភ្លើង និងគ្រាប់រំសេវថ្មីៗ ហើយសុខភាពរបស់ពួកគេក៏ល្អប្រសើរទៀតផង ទោះបីជាពួកគេកំពុងឈរជើងនៅក្នុងតំបន់មានជំងឺគ្រុនចាញ់ក៏ដោយ។

ចំណែកកងយោធពលខេមរភូមិន្ទរបស់ព្រះអង្គ បែរជាកាន់កាំភ្លើងចាស់ៗ ឯគ្រាប់រំសេវក៏មិនសូវមានគុណភាព ហើយត្រូវជំងឺគ្រុនចាញ់រាតត្បាតទៀត សូម្បីតែថ្នាំគីនីន ក៏គ្មានសម្រាប់ព្យាបាលផង។

ព្រះអង្គខ្វាល់យ៉ាងខ្លាំង តែពេលនោះ ព្រះអង្គជាព្រះមហាក្សត្រពុំមានអំណាចអ្វីដើម្បីដកសុន វ៉ឺនសៃ ចេញពីតំណែងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារជាតិ ព្រមទាំងនាយទាហានមួយចំនួនទៀត នៅអគ្គសេនាធិការដ្ឋាន បានដែរ ព្រោះសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យ និងសមាជិកគណៈរដ្ឋមន្ត្រី ស្ទើរតែទាំងមូល បានគប់គិតគ្នាធ្វើរឿងមួយនេះ។

ដូច្នេះបើព្រះអង្គហ៊ានរករឿងចំពោះរដ្ឋមន្ត្រី ដែលក្បត់នឹងមុខងារតួនាទីខ្លួនម្នាក់នេះ សមាជិកសភារបស់ពួកគេប្រាកដជាប្រឆាំងជំទាស់នឹងព្រះអង្គមិនខាន ពិសេស សភារបស់ពួកគេប្រាកដជានឹងមិនព្រមអនុម័តផ្តល់សច្ចាប័នលើខ្លឹមសារអត្ថបទនៃសន្ធិសញ្ញាបារាំង-ខ្មែរ ដែលព្រះអង្គបានខិតខំប្រឹងប្រែងបង្កើតឡើង ដើម្បីទាមទារឯករាជ្យបរិបូណ៌ មកជូនប្រទេសជាតិនោះ ជាមិនខាន។

ទាក់ទងបញ្ហាទាមទារឯករាជ្យពីបារាំង នេះដែរ ព្រះមហាក្សត្រសីហនុ ធ្លាប់បានជំរុញទៅរាជរដ្ឋាភិបាលរបស់គណបក្សប្រជាធិបតេយ្យ ដែលកំពុងកាន់អំណាចនៅក្នុងដៃស្រាប់នោះថា ប្រសិនបើពួកគេមិនចង់ឱ្យព្រះអង្គចេញមុខក្នុងការទាមទារឯករាជ្យពេញ-លេញពីបារាំងទេ ព្រះអង្គសុំឱ្យពួកគេប្រញាប់ប្រញាល់ចាប់ផ្តើមចរចាជាមួយរដ្ឋាភិបាលបារាំងដើម្បីទាមទារឯករាជ្យពេញលេញ មកជូនប្រទេសជាតិយើងភ្លាមៗទៅ ព្រោះពេលនេះ សភាក៏ជារបស់ពួកគេដែរនោះ នឹងអនុម័តគាំទ្រពួកគេជាមិនខាន។

តែពួកអ្នកប្រជាធិបតេយ្យ បែរជាឆ្លើយតបមកព្រះអង្គវិញ ដោយរាក់កំភែលថា ពេលនេះ មិនទាន់ដល់ពេលវេលាដែលពួកគេត្រូវធ្វើបែបនេះទេ។ ព្រះអង្គបានសួរទៅពួកគេវិញទៀតថា៖ "តាមពិត! តើពួកអស់លោកចង់បានអ្វីទៅវិញ? អស់លោកបដិសេធមិនព្រមផ្តល់សច្ចាប័នសន្ធិសញ្ញាឆ្នាំ១៩៤៩ ដែលខ្ញុំបានខិតខំប្រឹងប្រែងបង្កើតឡើង ដើម្បីទាមទារឯករាជ្យមកជូនប្រទេសជាតិនោះ តែទន្ទឹមនឹងនេះ អស់លោកក៏មិនព្រមចរចាជាមួយប្រទេសបារាំងដែរ ឬមួយអស់លោកសង្ឃឹមជឿជាក់លើចលនាតស៊ូរបស់សឹង ង៉ុកថាញ់ ឬមួយក៏អស់លោកសង្ឃឹមលើពួកវៀតមិញ និងខ្មែរឥស្សរៈផ្សេងទៀត ជាសម្ព័ន្ធមិត្តរបស់ពួកវៀតមិញ ដើម្បីឱ្យបារាំងប្រគល់ឯករាជ្យមកវិញ ដោយពួកអស់លោកមិនចាំបាច់ធ្វើអ្វីទាំងអស់? "។

ពួកអ្នកប្រជាធិបតេយ្យ មិនឆ្លើយតបនឹងព្រះអង្គវិញទេ តែពួកគេនៅតែបន្តលួចយកអាវុធ គ្រាប់រំសេវ និងថ្នាំពេទ្យជារបស់ជាតិ ទៅផ្តល់ឱ្យចលនាតស៊ូសឹង ង៉ុកថាញ់ យ៉ាងងងើលដងែល។

ពេលនោះដែរ ក៏មានលេចឮពាក្យចចាមអារ៉ាមថា ដោយសារខឹងសម្បានឹងអំពើក្បត់របស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាធិបតេយ្យ លួចយកអាវុធ គ្រាប់រំសេវ និងថ្នាំពេទ្យទៅឱ្យចលនាតស៊ូសឹង ង៉ុកថាញ់ អតីតមេខ្មែរឥស្សរៈដាប ឈួន ជាមេបញ្ជាការតំបន់ប្រតិបត្តិសឹករងខេត្តសៀមរាប បានត្រៀមដឹកនាំកងទ័ពរបស់គាត់ចូលមកក្រុងភ្នំពេញ ដើម្បីបណ្តេញរាជរដ្ឋាភិបាល ដឹកនាំដោយគណបក្សប្រជាធិបតេយ្យនេះ ឱ្យចុះចេញពីអំណាចផងដែរ។

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៥២ មេដឹកនាំគណបក្សនយោបាយ មាននិន្នាការស្តាំនិយម៤នាក់ ក្នុងនោះមានលន់ នល់ ម្នាក់ដែរ ត្រូវបានកម្លាំងសមត្ថកិច្ចរាជរដ្ឋាភិបាលរបស់គណបក្សប្រជាធិបតេយ្យ នាំគ្នាឆែកឆេរផ្ទះ និងឃាត់ខ្លួន ដោយសង្ស័យថា បានបាចខិត្តប័ណ្ណបំផុសឱ្យពួកនាយទាហានធ្វើរដ្ឋប្រហារ ទម្លាក់រាជរដ្ឋាភិបាល។

ប៉ុន្តែប៉ុន្មានម៉ោងក្រោយមក ដោយមានព្រះរាជបញ្ជាពីព្រះមហាក្សត្រសីហនុ មេដឹកនាំ

គណបក្សស្តាំនិយម ៣នាក់ ត្រូវបានដោះលែងវិញ នៅសល់តែអតីតនាយករដ្ឋមន្ត្រី យ៉ែម សំបូរ ត្រូវឃាត់ខ្លួនមួយយប់ ដោយសារសមត្ថកិច្ចឆែករកឃើញគ្រាប់បែកដៃមួយហឹប នៅក្នុងផ្ទះរបស់គាត់។ កាលពីឆ្នាំ១៩៥១ អតីតនាយករដ្ឋមន្ត្រី យ៉ែម សំបូរ ត្រូវមន្ត្រីគណបក្សប្រជាធិបតេយ្យខ្លះសង្ស័យថា គាត់ជាអ្នកនៅពីក្រោយខ្នងការគប់គ្រាប់បែកសម្លាប់អៀវ កើសប្រធានរដ្ឋសភា ម្តងរួចមកហើយ។

ឃើញសភាពការណ៍បែបនេះ តំណាងរាស្ត្រង៉ែត ហៀន ប្រាប់តំណាងរាស្ត្រទា ឆាយ ថា ម្តងនេះរដ្ឋាភិបាលដឹកនាំដោយហ៊ុយ កន្ទុល និងរដ្ឋសភា ដែលមានសឺន សាន ជាប្រធាន ច្បាស់ជាត្រូវរលំរលាយជាមិនខាន។

តែតំណាងរាស្ត្រទា ឆាយ លើកហេតុផលថា ព្រះករុណាសីហនុ បានស្បថនៅមុខព្រះភក្ត្រសម្តេចព្រះសង្ឃរាជក្នុងវត្តឧណ្ណាលោម រួចហើយថា ព្រះអង្គនឹងមិនរំលាយរដ្ឋសភាជាដាច់ខាត តែបើរាជរដ្ឋាភិបាល គឺព្រះអង្គអាចរំលាយមែន។

តំណាងរាស្ត្រ ង៉ែត ហៀន បានតបវិញថា ព្រះករុណាសីហនុ មិនមែនស្ថិតនៅក្រោមអំណាចរបស់សម្តេចព្រះសង្ឃរាជនោះទេ គឺព្រះអង្គស្ថិតនៅក្រោមអំណាចរបស់បារាំង ពិសេសរឿងសឺង ង៉ុកថាញ់ វិលត្រលប់មកមាតុប្រទេសវិញនេះ ព្រះអង្គបានធានាអះអាងចំពោះប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល (Vincent Auriol) ច្បាស់ណាស់ថា ក្រោយពេលបានវិលត្រលប់មកមាតុប្រទេសវិញ សឺង ង៉ុកថាញ់ នឹងមិនធ្វើនយោបាយប្រឆាំងនឹងបារាំង ទៀតទេ។ ដូច្នេះបើព្រះករុណាសីហនុ មិនរំលាយរាជរដ្ឋាភិបាល និងរដ្ឋសភា ដឹកនាំដោយគណបក្សប្រជាធិបតេយ្យ ដែលកំពុងសហការជាមួយចលនាតស៊ូរបស់សឺង ង៉ុកថាញ់ នោះទេ ច្បាស់ជាបារាំង ចោទប្រកាន់ថា ព្រះអង្គបោកបញ្ឆោតរដ្ឋាភិបាលបារាំង ដើម្បីយកសឺង ង៉ុកថាញ់ ឱ្យមកប្រឆាំងនឹងបារាំង បន្តទៀតជាមិនខាន។

ទីបំផុត ដោយមានការឯកភាពពីបារាំង ផងដែរ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ ព្រះមហាក្សត្រសីហនុ មិនអាចអត់ធ្មត់បានតទៅទៀត ព្រះអង្គក៏សម្រេចរំលាយរាជរដ្ឋាភិបាល របស់គណបក្សប្រជាធិបតេយ្យ ដែលមានហ៊ុយ កន្ទុល ជានាយករដ្ឋមន្ត្រីនោះ



ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ប៉ែនប៉ោះយុគន្ធរ

ចោល។ មួយថ្ងៃក្រោយមក គឺនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥២ ព្រះអង្គ បានរៀបចំសមាសភាពរាជរដ្ឋាភិបាលថ្មីមួយ ដោយមានព្រះអង្គជានាយករដ្ឋមន្ត្រី ផ្ទាល់តែម្តង, ព្រះអង្គម្ចាស់នរោត្តម សុង ជេត ជារដ្ឋមន្ត្រីការបរទេស, ព្រះអង្គម្ចាស់ក្សត្រីនរោត្តម ប៉ែងប៉ោះ យុគន្ធរ ជារដ្ឋមន្ត្រីអប់រំ កីឡា និងយុវជន, តុង អ៊ួនម៉ម ជារដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ, ជឺ ឡូប៉ែស ជារដ្ឋមន្ត្រីយុត្តិធម៌, ជាញ់ សួង ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ស៊ឹម វ៉ា រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ, នូ ហាច (អ្នកនិពន្ធរឿងផ្កាស្រពោន) រដ្ឋលេខាធិការសាធារណសិក្សា និងគមនាគមន៍, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជារដ្ឋលេខាធិការការពារជាតិ និងអ៊ុម សម ជារដ្ឋលេខាធិការសាធារណសុខាភិបាល និងសង្គមកិច្ច។

តែការរំលាយរដ្ឋាភិបាលរបស់គណបក្សប្រជាធិបតេយ្យ ដែលកើតចេញពីឈ្នះឆ្នោតនោះ គឺមិនខុសពីការធ្វើរដ្ឋប្រហារនោះទេ ព្រោះពេលនោះ គេឃើញបារាំង បានបញ្ជូនរថក្រោះ និងរថពាសដែកជាច្រើនគ្រឿង ឱ្យបើកល្បាតចុះឡើងតាមមហាវិថីនានា ពាសពេញទីក្រុងភ្នំពេញ ដើម្បីគំរាមពួកមន្ត្រីគណបក្សប្រជាធិបតេយ្យ និងសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ មិនឱ្យធ្វើបាតុកម្មប្រឆាំងតវ៉ាចំពោះការរំលាយរាជរដ្ឋាភិបាលនោះ។

ពេលនោះដែរ ហ្សង់ ឡឺ ទួណូ (Jean Le Tourneau) រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋជា

សមាជិកសហភាពបារាំង ក៏បានប្រកាសយ៉ាងច្បាស់ថា បារាំង នឹងមិនធ្វើសម្បទានអ្វីទាំងអស់ ចំពោះគណបក្សប្រជាធិបតេយ្យ ជាដាច់ខាត។ ការរំលាយរាជរដ្ឋាភិបាលនេះ មិនមែនគ្រាន់តែជារឿងខឹងសម្បារបស់ព្រះមហាក្សត្រ សីហនុ ចំពោះគណបក្សប្រជាធិបតេយ្យប៉ុណ្ណោះទេ តែក៏ជាការវាយបំបាក់របស់ពួកបារាំង មកលើគណបក្សប្រជាធិបតេយ្យ ដែលប្រឆាំងនឹងបារាំង តាំងពីសម័យព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុគន្ធរង្ស ជាប្រធាន ផងដែរ។

តែទោះបីជាយ៉ាងណា មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បានចែងថា ព្រះមហាក្សត្រជាអគ្គប្រមុខនៃរដ្ឋ។ អង្គព្រះមហាក្សត្រ ជាទីគោរពសក្ការៈ នរណានឹងល្មើសពុំបាន ហើយមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនេះ ក៏បានចែងដែរថា ព្រះមហាក្សត្រ ទ្រង់មានព្រះរាជសិទ្ធិរំលាយរដ្ឋសភាបាន ហើយបើមានការរំលាយរដ្ឋសភា ការបោះឆ្នោតជ្រើសតាំងសភាជាថ្មី ត្រូវធ្វើឡើងក្នុងរយៈពេលពីរខែ យ៉ាងយូរ។

ក្រោយពីរំលាយរាជរដ្ឋាភិបាល របស់គណបក្សប្រជាធិបតេយ្យមក ដើម្បីទប់ទល់ជាមួយចលនាតស៊ូប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ របស់សឺង ង៉ុកថាញ់ រាជរដ្ឋាភិបាលដែលមានសម្តេចសីហនុ ជានាយករដ្ឋមន្ត្រី បានដាក់គម្រោងស្នើសុំថវិកា៣០ភាគរយ នៃថវិកាជាតិប្រចាំឆ្នាំ ដើម្បីទុកសម្រាប់ទិញអាវុធ និងស្នើសុំដំឡើងពន្ធអាករផ្សេងៗទៀត ដើម្បីសុំការអនុម័តពីសភា ដែលសមាជិកភាគច្រើនលើសលប់ មកពីគណបក្សប្រជាធិបតេយ្យ។

ដើម្បីជាការឆ្លើយតបចំពោះការរំលាយរាជរដ្ឋាភិបាលរបស់ខ្លួននោះ ពួកមន្ត្រីគណបក្សប្រជាធិបតេយ្យ ក៏មិនសុខចិត្តចុះចាញ់ព្រះមហាក្សត្រសីហនុ ដោយងាយៗដែរ គឺតំណាងរាស្ត្ររបស់ពួកគេនៅក្នុងសភា និងមានសឺន សាន ជាប្រធានផងនោះ ក៏មិនព្រមអនុម័តតាមគម្រោងស្នើសុំថវិកា៣០ភាគរយ នៃថវិកាជាតិប្រចាំឆ្នាំ ដើម្បីទុកសម្រាប់ទិញអាវុធ និងសុំដំឡើងពន្ធអាករផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលរបស់ព្រះអង្គបានស្នើសុំនោះវិញដែរ។

តែលទ្ធផលដែលគណបក្សប្រជាធិបតេយ្យ ទទួលបានមកវិញនោះ គឺនៅថ្ងៃទី១៣

ខែមករា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ ប្រកាសរំលាយសភាដែលមានសឺន សាន ជាប្រធាននោះចោល ដោយប្រែក្លាយសភានេះ ឱ្យទៅជាសភាពិគ្រោះវិញ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានប្រកាសដាក់ប្រទេសក្នុងគ្រាមានអាសន្ន ថែមទៀតផង។

ភ្លាមៗនោះ យ៉ែម សំបូរ និងបក្ខពួកគាត់បានធ្វើញត្តិគាំទ្រថ្វាយព្រះមហាក្សត្រសីហនុ ដែលបានប្រកាសរំលាយសភា មានតំណាងរាស្ត្រភាគច្រើនលើសលប់ មកពីគណបក្សប្រជាធិបតេយ្យនោះផងដែរ។

ចំណែកមន្ត្រីគណបក្សប្រជាធិបតេយ្យ បានរួមគ្នាជាមួយនិស្សិតនៅវិទ្យាស្ថានគរុ-កោសល្យ និងសិស្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ធ្វើបាតុកម្មប្រឆាំងនឹងការរំលាយសភានោះវិញដែរ។

បន្ទាប់មក តំណាងរាស្ត្រមកពីគណបក្សប្រជាធិបតេយ្យ ចំនួន៧នាក់ ក្នុងនោះមាន ទា ឆាយ, ប៊ុណ្ណ ចន្ទម៉ុល និងអ៊ឹម ផន (ជាបងប្អូនជីដូនមួយរបស់ខៀវ ប៊ុណ្ណារី) ព្រមទាំងមន្ត្រីគណបក្សប្រជាធិបតេយ្យ ឈ្មោះ ង្វ សុចាយ , ញឹក សួង , កញ្ញាវណ្ណ ស៊ី និងមួយចំនួនទៀត សរុបទាំងអស់ ប្រហែល៤០នាក់ ត្រូវចាប់ខ្លួនយកទៅដាក់ពន្ធនាគារ (គុកធំ) នៅខាងក្រោយវត្តឧណ្ណាលោម ធ្វើទារុណកម្មសួរចម្លើយ ពីបទបង្កចលាចលដល់សង្គមជាតិ ដោយចូលដៃចូលជើងជាមួយពួកសឹង ង៉ុកថាញ់, ពួកវៀតមិញ និងពួកខ្មែរឥស្សរៈជាសម្ព័ន្ធមិត្តរបស់ពួកវៀតមិញ។

ក្រោយបានចេញពីពន្ធនាគារវិញ តំណាងរាស្ត្រទា ឆាយ ធ្លាក់ខ្លួនឈឺជាទម្ងន់ រហូតត្រូវបញ្ជូនទៅសង្គ្រោះនៅពេទ្យខេមរា ហើយត្រូវបាត់បង់ជីវិតនៅលើភ្លៅតំណាងរាស្ត្រង៉ែត ហៀន ដែលជាមនុស្សជិតស្និទ្ធនឹងគ្នា។

ពេលនោះ តំណាងរាស្ត្រ ងួន ឆាយគ្រី មកពីគណបក្សប្រជាធិបតេយ្យ ក៏បានមកលួចប្រាប់សឺន សាន ប្រធានរដ្ឋសភា ជាមិត្តភក្តិថា ក្នុងពេលឆាប់ៗនេះ នឹងដល់វេនត្រូវចាប់ខ្លួនគាត់ (សឺន សាន) ហើយ។

សឺន សាន ប្រធានរដ្ឋសភា ក៏បានប្រាប់ទៅងួន ឆាយគ្រី វិញថា៖ " សូមផ្តាំទៅអ្នក

មករកចាប់ខ្ញុំផងថា បើចង់មកចាប់ខ្ញុំ នៅពេលថ្ងៃ គឺសូមមកចាប់នៅផ្ទះរបស់ខ្ញុំផ្ទាល់ ឬនៅហាងអូប៊ឹទីបារាំង ព្រោះខ្ញុំមានការិយាល័យមួយ នៅក្នុងហាងនោះដែរ។ តែបើចង់មករកចាប់ខ្ញុំ នៅពេលល្ងាច បើមិនឃើញខ្ញុំសម្រាកនៅផ្ទះទេ សូមទៅរកខ្ញុំនៅរោងកុន នឹងបានឃើញហើយ"។

ប៉ុន្តែដំណឹងនៃការតាមរកចាប់សឺន សាន នោះ គ្រាន់តែជាពាក្យចចាមអារ៉ាមប៉ុណ្ណោះ។ ផ្ទុយទៅវិញ មានឥស្សរជនម្នាក់ជាមនុស្សជិតស្និទ្ធនឹងព្រះមហាក្សត្រសីហនុ បានព្យាយាមមកទាក់ទងគាត់ នៅហាងអូប៊ឹទីប៉ារីស នោះ ចំនួន៣លើក ដើម្បីឱ្យគាត់យល់ព្រមទៅចូលរួមជាមួយព្រះអង្គ ដើម្បីទាមទារឯករាជ្យពីបារាំង នោះដែរ។

ដំបូង សឺន សាន គិតថា គាត់លែងចង់ប្រឡូកនឹងឆាកនយោបាយទៀតហើយ ប៉ុន្តែក្រោយមក គាត់ក៏យល់ព្រម ព្រោះគិតឃើញថា ព្រះមហាក្សត្រសីហនុ ប្រហែលជាមានព្រះរាជតម្រិះ ចង់ធ្វើការសម្របសម្រួលជាមួយអ្នកប្រជាធិបតេយ្យ វិញហើយ មើលទៅ?

ពេលនោះ ព្រះមហាក្សត្រសីហនុ ជានាយករដ្ឋមន្ត្រី បានប្រកាសប្រាប់ប្រជារាស្ត្រខ្មែរថា ប្រសិនបើដល់ឆ្នាំ១៩៥៥ ព្រះអង្គមិនអាចទាមទារឯករាជ្យពេញលេញពីប្រទេសបារាំង បានមកវិញតាមការសន្យាទេ ព្រះអង្គនឹងដាក់ព្រះកាយឱ្យប្រជារាស្ត្រខ្មែរជាអ្នកវិនិច្ឆ័យតាមរយៈធ្វើប្រជាមតិ ដោយបោះឆ្នោតជាសកល និងដោយសម្ងាត់ទៀតផង។

បើតាមប្រភពស៊ើបអង្កេតការណ៍សម្ងាត់របស់បារាំង បានឱ្យដឹងថា ក្រោយពីសឺង ង៉ុកថាញ់ ទៅចូលរួមជាមួយកៅ តក់ បង្កើតប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិមក ពួកគាត់មានកងទ័ពប្រមាណ៥០០នាក់ និងអាវុធ៣០០ដើម។ សឺង ង៉ុកថាញ់ ក៏បានសរសេរលិខិតមួយផ្ញើទៅសារ៉ាង វង្ស និងព្រះអង្គម្ចាស់នរោត្តម ចន្ទរង្សី ដើម្បីសុំឱ្យមេខ្មែរឥស្សរៈមិនមែនកុម្មុយនិស្ត ទាំង២នាក់នេះ មករួមកម្លាំងជាមួយពួកគាត់ ដើម្បីសហការជាមួយពួកវៀតមិញ វាយបារាំង ដណ្តើមឯករាជ្យឱ្យប្រទេសជាតិ មកវិញ។

ពេលនោះ មេខ្មែរឥស្សរៈ ឈ្មោះពុត ធាយ ដែលបាត់មុខមួយរយៈកន្លងមក ក៏បានចេញមុខមកប្រកាសគាំទ្រសឺង ង៉ុកថាញ់ ជាមេដឹកនាំល្បីឈ្មោះខាងប្រឆាំងនឹងពួកអាណា

និគមបារាំង តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៣០ មកនោះដែរ។

តែក្រោយពីវិទ្យុផ្សាយសំឡេងភ្នំដងរែក របស់សឺង ង៉ុកថាញ់ បានផ្សាយព័ត៌មានថា ពួកវៀតមិញ សន្យានឹងផ្តល់ជំនួយយោធាដល់ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ និងផ្សាយព័ត៌មានពីទំនាក់ទំនងរវាងសឺង ង៉ុកថាញ់ ជាមួយមេដឹកនាំហូ ជីមិញ មក នៅដើមខែឧសភា ឆ្នាំ១៩៥២ អតីតសិស្សវិទ្យាល័យមួយចំនួន ដែលទើបនឹងរត់ចេញពីក្រុងភ្នំពេញ ទៅតាមសឺង ង៉ុកថាញ់ នៅភ្នំដងរែក ទើបតែបានជាងមួយខែ មានការខកចិត្តយ៉ាងខ្លាំង ក៏នាំគ្នារត់ចេញពីជំរំតស៊ូនៅភ្នំដងរែក នោះ ត្រលប់ទៅផ្ទះសម្បែងពួកគេ នៅឯក្រុងភ្នំពេញ វិញ។

នៅពេលនោះដែរ ស្ត្រីឈ្មោះលាត មួន ហៅម៉ែមួន និងស៊ីវ ហេង ជាមេដឹកនាំចលនាឥស្សរៈស្និទ្ធនឹងពួកវៀតមិញ បានទៅធ្វើទស្សនកិច្ច នៅក្នុងជំរំតស៊ូរបស់សឺង ង៉ុកថាញ់ ក្នុងបំណងចង់រួមសហការគ្នាឱ្យកាន់តែជិតស្និទ្ធថែមទៀត។

ប៉ុន្តែចំពោះលាវ កែវមុនី និងមេទ័ពខ្មែរឥស្សរៈ ២នាក់ទៀត គឺ ទុម សុខ និងអ៊ូ ដិលពេជ្រ បានបដិសេធ មិនរួបរួមជាមួយសឺង ង៉ុកថាញ់ ជាដាច់ខាត។

ថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៥២ ទាហានរាជការខ្មែរ-បារាំង បានបើកប្រតិបត្តិការសឹកធំមួយហៅថា ប្រតិបត្តិការសឹកផ្លេកបន្ទោរ វាយប្រហារទៅលើជំរំតស៊ូរបស់សឺង ង៉ុកថាញ់ និងកៅ តក់ បណ្តាលឱ្យរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ។

បើតាមការបញ្ជាក់របស់ស្នងការរងប៉ូលិសថៃ នៅខេត្តសុរិន្ទ បានឱ្យដឹងថា ក្រោយពីទាហានរាជការខ្មែរ-បារាំង បើកប្រតិបត្តិការសឹកផ្លេកបន្ទោរនោះមក កងទ័ពរបស់សឺង ង៉ុកថាញ់ និងកៅ តក់ នៅសល់គ្នា ប្រហែល២៥០នាក់ប៉ុណ្ណោះ ហើយមេខ្មែរឥស្សរៈទាំង២នេះ ក៏បានចាប់ផ្តើមជ្រើសរើសកូនចៅប្រជារាស្ត្រ នៅក្នុងស្រុកសំរោង ឱ្យចូលបម្រើក្នុងជួរកងទ័ពរបស់ខ្លួនបន្ថែមទៀត ដើម្បីពង្រីកកម្លាំងឡើងវិញ។

សឺង ង៉ុកថាញ់ ជាមេដឹកនាំចលនាតស៊ូ ដែលប្រជារាស្ត្រនៅប៉ែកខាងជើង និងពាយ័ព្យប្រទេស ពិសេសនៅខេត្តសៀមរាប និងបាត់ដំបង ភាគច្រើនស្រលាញ់គោរព និងជឿជាក់។ ប៉ុន្តែមេដឹកនាំថ្នាក់ក្រោមរបស់គាត់ម្នាក់ នៅក្នុងខេត្តបាត់ដំបង ពេលនាំកងទ័ព

ទៅដល់ស្រុក ភូមិណាហើយ គេតែងតែបង្ខំទារពន្ធពីអ្នកភូមិ ក្នុងមួយភូមិៗ ឱ្យបានពី ៥០០០ ទៅ ១០០០០រៀល ជាកំហិត ខណៈចលនាតស៊ូខ្មែរឥស្សរៈផ្សេងៗទៀត មិនដែលទារពន្ធពីអ្នកភូមិច្រើនដូចនេះទេ។

ក្រោយពេលសឺង ង៉ុកថាញ់ និងកៅ តក់ ពង្រីកកម្លាំងបានរឹងមាំឡើងវិញ ព្រះអង្គម្ចាស់នរោត្តម ចន្ទរង្សី និងសារ៉ាង វង្ស ក៏ចាប់ផ្តើមមានទំនាក់ទំនងល្អជាមួយសឺង ង៉ុកថាញ់ទៅវិញទៅមក។

តែទោះបីជាយ៉ាងនេះក៏ដោយ ក៏សារ៉ាង វង្ស ដែលគេសង្ស័យថា ជាមេខ្មែរឥស្សរៈមានពួកបារាំង នៅពីក្រោយខ្នងនោះ ចាប់ផ្តើមធ្វើទំនាក់ទំនងជាមួយចៅហ្វាយខេត្តកំពង់ស្ពឺជាថ្មីឡើងវិញ។ ដោយឡែក ពុត ឆាយ ជាមេខ្មែរឥស្សរៈ មានគំនិតស្អប់ពួកវៀតមិញ និងអាណិកជនវៀតណាមតាំងពីដើមមកនោះ ក៏មានបំណងចង់ទម្លាក់អាវុធ ដើម្បីចុះចូលជាមួយព្រះមហាក្សត្រសីហនុដែរ។

៤៤
សឺង ង៉ុកមិញ ពង្រឹងកម្លាំងតស៊ូ
យុទ្ធជនប៉ែន សុវណ្ណ ត្រូវរបួស



មេខ្មែរឥស្សរៈ សឺង ង៉ុកមិញ ទូ សាមុត ស៊ីវ ហោង និង ចាន់ សម័យ

នៅក្នុងខែឧសភា ឆ្នាំ១៩៥២ ប្រភពស៊ើបការណ៍សម្ងាត់របស់បារាំង បានរាយការណ៍ថា នៅប៉ែកបូព៌ាប្រទេស កងទ័ពរបស់រណសិរ្សឯកភាពឥស្សរៈ (UIF) ដែលពង្រាយទីតាំងនៅក្នុងខេត្តព្រៃវែង រួមមាន កងទ័ពរបស់កែវ មុនី, កងទ័ពវៀតមិញ និងកងទ័ពរបស់សោ កឹម ដែលឱ្យឈ្មោះថា កងទ័ពអាចារ្យ ហែម ចៀវ នោះ បានច្របាច់បញ្ចូលគ្នា បង្កើតជាកងទ័ពចល័ត ចំនួន៤អង្គភាពធំៗ ដើម្បីបើកការវាយប្រហារទៅលើបុស្តិ៍ការពារសាលាស្រុកនានា នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង។

រហូតដល់ចុងខែកញ្ញា ឆ្នាំ១៩៥២ នៃ សាវ៉ាន់ ហៅយ៉ា ជាអ្នកដឹកនាំលំដាប់ទី៣ របស់គណៈកម្មាធិការរំដោះប្រជាជនភូមិភាគបូព៌ា បន្ទាប់ពីទូ សាមុត និងកែវ មុនី ក៏បានបញ្ជូនកងទ័ពរបស់គាត់ ពីវាលត្រែងលិចទឹក ក្នុងទឹកដីវៀតណាម ចូលមកនៅភាគខាងត្បូង

នៃខេត្តព្រៃវែង។

នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៥២ នៅក្នុងសន្និបាតរបស់គណបក្សប្រជាជនបដិវត្តន៍ខ្មែរ នៅប្រជុំជនហាទៀង ខេត្តកៀងយ៉ាង គណៈកម្មាធិការមជ្ឈិមបក្ស ដែលមានសឹង ង៉ុកមិញ ជាលេខា បានសម្រេចឱ្យបង្កើតសាលាហ្វឹកហ្វឺនយោធា នៅតាមភូមិភាគនីមួយៗ ទូទាំងប្រទេស ដើម្បីបង្ហាត់បង្រៀនយុទ្ធសាស្ត្រធ្វើសង្គ្រាម និងអប់រំបំពាក់បំប៉នគោលជំហរបដិវត្តដល់កងទ័ពរបស់ខ្លួន ដោយមានពួកជំនាញការវៀតមិញ ចេះភាសាខ្មែរ ជួយបង្ហាត់បង្រៀន ខណៈសឹង ង៉ុកមិញ និងទូ សាមុត ត្រូវបានគេដឹងថា ពួកគាត់ទាំង២នាក់នេះ ចេះនិយាយភាសាវៀតណាមយ៉ាងស្ទាត់។

ក្នុងខែកក្កដា ឆ្នាំ១៩៥២ អាជ្ញាធររាជការខ្មែរ-បារាំងខេត្តកំពត បានរាយការណ៍ថា នៅក្នុងខេត្តរបស់ខ្លួន ពួកខ្មែរ-វៀតមិញ បានបង្កើតសាលាហ្វឹកហ្វឺនយោធា ចំនួន២កន្លែង ហើយមានយុវជនជាកូនចៅកសិករ ចំនួន៨០នាក់ បានចូលរៀនក្បួនយុទ្ធសាស្ត្រធ្វើសង្គ្រាម នៅក្នុងសាលាហ្វឹកហ្វឺនយោធានោះ។

នៅក្នុងឆ្នាំ១៩៥២នោះដែរ លក្ខន្តិកៈរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ត្រូវបានអនុម័តដោយខ្លឹមសារនៃលក្ខន្តិកៈនោះ គឺដូចគ្នានឹងលក្ខន្តិកៈរបស់បក្សពលករវៀតណាម ស្ទើរតែទាំងស្រុង ដោយគ្រាន់តែនៅក្នុងលក្ខន្តិកៈបក្សប្រជាជនបដិវត្តន៍ខ្មែរ មិនមានសរសេរអ្វី ពីលទ្ធិកុម្មុយនិស្តនោះទេ គឺគ្រាន់តែសរសេរពីប្រជាធិបតេយ្យ របស់ប្រជាជនតែប៉ុណ្ណោះ ហើយថា បក្សប្រជាជនបដិវត្តន៍ខ្មែរនេះ គ្រាន់តែជាអ្នកបង្រួបបង្រួមប្រជាជនទាំងមូល នៅក្នុងរណសិរ្សឯកភាពឥស្សរៈ(UIF) និងសហការគ្នាជិតស្និទ្ធជាមួយប្រជាជនវៀតណាម និងឡាវ ដើម្បីតស៊ូប្រឆាំងនឹងពួកអាណានិគមនិយមបារាំង និងអន្តរាគមន៍របស់អាមេរិក ព្រមទាំងពួកអាយ៉ងរបស់វាតែប៉ុណ្ណោះ។

នៅក្នុងឯកសារនយោបាយមួយធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ១៩៥២ ហើយត្រូវបានកងទ័ពរាជការខ្មែរ-បារាំង រឹបអូសនោះ បានសរសេរថា បក្សប្រជាជនបក្សបដិវត្តន៍ខ្មែរ ពុំមែនជាបក្សឈានមុខរបស់វណ្ណៈកម្មករទេ តែជាបក្សឈានមុខរបស់ប្រជាជាតិមួយ ដែលប្រមូល

ផ្តុំពីគ្រប់សមាសភាពអ្នកស្នេហាជាតិ និងសមាសភាពចម្រើនរបស់ប្រជាជនកម្ពុជា។

នេះអាចបញ្ជាក់បានថា មុននឹងជួយតាក់តែងគោលនយោបាយខាងលើនេះ មេដឹកនាំវៀតមិញ ប្រាកដជាដឹងច្បាស់ថា កម្ពុជា មិនអាចធ្វើបដិវត្តន៍ ឆ្ពោះទៅរកបបកុម្មុយនិស្តបានភ្លាមៗទេ គឺត្រូវធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដោយសន្សឹមៗសិន ព្រោះនៅកម្ពុជា វណ្ណៈកម្មករដៃលចាត់ទុកជាកងឈានមុខរបស់បក្សកុម្មុយនិស្តនោះ មានចំនួនតិចតួចណាស់ ហើយចលនារបស់វណ្ណៈអធន ក៏មិនទាន់មានការរីកចម្រើនដែរ។

នៅក្នុងរបាយការណ៍របស់សមត្ថកិច្ចប៉ូលិសខេត្តកំពត ក្នុងខែមិថុនា ឆ្នាំ១៩៥២ បានឱ្យដឹងថា ពួកខ្មែរឥស្សរៈ និងពួកវៀតមិញ បានធ្វើសកម្មភាពស្ទើរគ្រប់ទិសទីក្នុងខេត្ត កំពត ហើយ នង សួន ត្រូវបានសឹង ង៉ុកមិញ ចាត់តាំងឱ្យធ្វើជាប្រធានរណសិរ្សឯកភាពឥស្សរៈ (UIF) ប្រចាំភូមិភាគនិរតី។

ក្នុងឆ្នាំ១៩៥២ នៅជំរំប្រមូលផ្តុំធំមួយ ក្នុងខេត្តកំពត មានកងទ័ពឥស្សរៈ ប្រមាណ ៨០០នាក់ ដឹកនាំដោយញ៉ែម ស៊ុន ហើយក្នុងចំណោមកងទ័ពទាំងនោះ ក៏មានយុទ្ធជន ប៉ែន សុវណ្ណ ម្នាក់ដែរ។

ក្នុងការវាយប្រយុទ្ធជាមួយកងទ័ពរាជការខ្មែរ-បារាំង នារដូវប្រាំង ឆ្នាំ១៩៥២ នោះ បណ្តាលឱ្យប៉ែន សុវណ្ណ ត្រូវរបួសជើងឆ្វេងយ៉ាងធ្ងន់ធ្ងរ និងសន្លប់បាត់ស្មារតី។ ពេលដឹងខ្លួនឡើង គាត់ស្ថិតនៅក្នុងមន្ទីរពេទ្យ ក្នុងព្រៃមួយ។ គ្រូពេទ្យនៅទីនោះ បានជួយព្យាបាលមុខរបួសរបស់គាត់យ៉ាងយកចិត្តទុកដាក់បំផុត។ ប្រហែលជាងកន្លះខែ ក្រោយមក ទើបគាត់បានធូរស្រាលបន្តិចម្តងៗ និងលែងព្រួយបារម្ភពីរឿងគ្រូពេទ្យបម្រុងកាត់ជើងឆ្វេងរបស់គាត់ចោល។

ក្រោយពីចាកចេញពីមន្ទីរពេទ្យ ប៉ែន សុវណ្ណ បានទៅរស់នៅក្នុងជំរំប្រមូលផ្តុំធំនោះដូចមុនវិញ។ ពេលនោះមានមេឥស្សរៈម្នាក់ ដែលគាត់មិនទាន់ស្គាល់ច្បាស់នៅឡើយ ដោយគ្រាន់តែដឹងថា ជាមេឥស្សរៈម្នាក់នោះ ទើបតែមកទទួលតួនាទីជាប្រធាននយោបាយ នៅជំរំប្រមូលផ្តុំធំនោះ បានមកជួបសំណេះសំណាល និងសួរសុខទុក្ខគាត់ក្នុងភាពស្និទ្ធស្នាល



រូបថត កាល់ម៉ាក្ស, អង់ហ្គែល, លេនីន និងស្តាលីន

បំផុត។

បន្ទាប់មក មេឥស្សរៈម្នាក់នោះ បាននិយាយមកកាន់គាត់ថា៖ "ខ្ញុំសូមប្រគល់រូបថតមួយសន្លឹកនេះ ឱ្យសមមិត្ត ដើម្បីទុកជាអនុស្សាវរីយ៍"។

និយាយបណ្តើរ មេឥស្សរៈម្នាក់នោះ លូកដៃយករូបថតដែលរុំដោយក្រណាត់ពណ៌ក្រហម ចេញពីក្នុងបាឡូរបស់គាត់បណ្តើរផងដែរ។

ដំបូង ប៉ែន សុវណ្ណ នឹកស្មានថា រូបថតនោះ គឺជារូបរបស់មេឥស្សរៈម្នាក់នោះផ្ទាល់ ប៉ុន្តែពេលយកមកមើល បែរជាមិនមែនរូបថតគាត់ទេ គឺជារូបថតរបស់ជនជាតិបរទេសដែលមានពុកមាត់ស្រមូមចំនួន៤នាក់ទៅវិញ។

ដោយមិនចាំបាច់ឱ្យប៉ែន សុវណ្ណ មានចម្ងល់ និងសួរនាំវែងឆ្ងាយ គាត់ក៏ប្រាប់ប៉ែន សុវណ្ណ ថា ជនបរទេសទាំង៤នាក់នេះ គឺជារូបកាល់ម៉ាក្ស, អង់ហ្គែល, លេនីន និងស្តាលីន។

របត់នយោបាយ

ពេលនោះ ប៉ែន សុវណ្ណ ក៏មិនដឹងថា ជនបរទេសទាំង៤នាក់ នៅក្នុងរូបថតនោះ មានជាប់ទាក់ទងអ្វីជាមួយចលនាតស៊ូខ្មែរឥស្សរៈនោះដែរ គឺគាត់គ្រាន់តែដឹងថា ប្រជាជនទាំង៣ប្រទេស គឺវៀតណាម កម្ពុជា និងឡាវ កំពុងរួបរួមគ្នាតស៊ូប្រឆាំងនឹងពួកអាណានិគមនិយមបារាំង តែប៉ុណ្ណោះ ហើយមេដឹកនាំតស៊ូនៅប្រទេសកម្ពុជា គាត់ដឹងថា ឈ្មោះសឺង ង៉ុកមិញ ហៅអាចារ្យមៀន ជាលេខាបក្ស និងទូ សាមុត ជាអនុលេខាបក្ស, ស៊ីវ ហោង ជាប្រធានយោធា និងចាន់ សម័យ ជាសមាជិកអចិន្ត្រៃយ៍គណៈកម្មការមជ្ឈិមបក្ស ពិសេសមេដឹកនាំដែលគាត់ស្គាល់ច្បាស់ជាងគេ គឺព្រ័ម ស៊ុន ជាមេបញ្ជាការធំរបស់គាត់ផ្ទាល់។

ចំណែកនៅវៀតណាម ប៉ែន សុវណ្ណ ដឹងថា មេដឹកនាំធំជាងគេ ឈ្មោះហូ ជីមិញ និងនៅឡាវ មេដឹកនាំធំជាងគេ ឈ្មោះ សុផានវង្ស តែប៉ុណ្ណោះ។

៤៥
សឺង ង៉ុកថាញ់ ចុះកិច្ចព្រមព្រៀងជាមួយសឺង ង៉ុកមិញ

ដោយឡែក សាវ៉ាង វង្ស ជាមេដឹកនាំចលនាតស៊ូខ្មែរឥស្សរៈដែលធ្វើសកម្មភាពប្រឆាំងនឹងពួកវៀតមិញផង និងបានទាក់ទងសម្ងាត់ ជាមួយចៅហ្វាយខេត្តកំពង់ស្ពឺ របស់រាជការខ្មែរ-បារាំង ផងនោះ ត្រូវបានគេសង្ស័យថា អាចទាក់ទងសម្ងាត់ ជាមួយចៅហ្វាយខេត្តតាកែវ ផងដែរ ព្រោះនៅតាមផ្លូវនានា ក្នុងខេត្តតាកែវ មានបាចខិត្តប័ណ្ណចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ ១៩៥២ ចុះហត្ថលេខា ដោយសាវ៉ាង វង្ស ជាច្រើនសន្លឹក ដោយនៅផ្នែកខាងលើនៃខិត្តប័ណ្ណទាំងអស់នោះ មានរូបសញ្ញាទង់ជាតិ មានផ្ទៃពណ៌ក្រហម និងរូបប្រាសាទអង្គរវត្ត កំពូលបី ពណ៌លឿង នៅចំកណ្តាល បានសរសេរអំពាវនាវ ឱ្យប្រជាជនខ្មែរទាំងអស់ រួបរួមគ្នាប្រឆាំងនឹងយួនវៀតមិញ។

នៅពេលព្រះមហាក្សត្រសីហនុ ចាប់ផ្តើមធ្វើសកម្មភាពទាមទារឯករាជ្យពីបារាំង ព្រះអង្គបានប្រកាសថា សាវ៉ាង វង្ស នេះ គឺជាកូនជីងរបស់បារាំង ហើយមូលហេតុដែលគាត់រត់ចោលមុខតំណែង និងឋានន្តរស័ក្តិជាអនុសេនីយ៍ ក្នុងជួរកងទ័ពរាជការខ្មែរ-បារាំង នៅស្រុកលើកដែក (ខេត្តកណ្តាល) កាលពីខែមីនា ឆ្នាំ១៩៤៩ ទៅចុះចូលជាមួយពួកឥស្សរៈខ្មែរ-វៀតមិញនោះ គឺបារាំង ជាអ្នករៀបចំឆាកល្ខោននេះឡើង ដើម្បីឱ្យសាវ៉ាង វង្ស ចូលទៅក្តាប់សភាពការណ៍ និងបំបែកបំបាក់ផ្ទៃក្នុងរបស់ពួកខ្មែរឥស្សរៈ តែប៉ុណ្ណោះ។

ជាមួយគ្នានោះដែរ បារាំងបានលួចបញ្ជូនអាវុធ និងសម្ភារសឹកមួយចំនួនទៅកងទ័ពរបស់សាវ៉ាង វង្ស នេះទៀតផង។

តែទោះបីយ៉ាងនេះក៏ដោយ ក៏នៅក្នុងតំបន់ដែលសាវ៉ាង វង្ស កាន់កាប់ត្រួតត្រានោះ ប្រសិនបើគាត់ចង់សម្លាប់អ្នកភូមិណាម្នាក់ គឺគាត់សម្លាប់អ្នកភូមិនោះ តាមអំពើចិត្ត ដូចពួកមេខ្មែរឥស្សរៈនៅកន្លែងផ្សេងៗទៀតដែរ។

នៅភូមិភាគបូព៌ា ទូ សាមុត ហៅអាចារ្យសុខ និងកែវ មុនី ហៅអាចារ្យម៉ៅ បានបំផុស

ចលនាតស៊ូ នៅក្នុងជួរព្រះសង្ឃយ៉ាងសកម្មបំផុត។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥២ ព្រះសង្ឃចំនួន៤០អង្គ មកពីវត្តមួយចំនួន នៅក្នុងភូមិភាគបូព៌ា បាននិមន្តមកប្រជុំជាមួយទូ សាមុត និងកែវ មុនី ហើយព្រះសង្ឃទាំង៤០អង្គនោះ បានប្រកាសគាំទ្ររណសិរ្សឯកភាពឥស្សរៈ (UIF) ទាំងស្រុង។

នៅក្នុងខែមេសា ឆ្នាំ១៩៥២ វិទ្យុផ្សាយសំឡេងរបស់វៀតមិញ នៅកម្ពុជាក្រោមឈ្មោះសំឡេងណាំបូ បានដកស្រង់ថេរដីការបស់ព្រះសង្ឃខ្មែរស្មោះស្ម័គ្រនឹងពួកវៀតមិញមួយអង្គ ដែលបាននិមន្តទៅប្រទេសវៀតណាម នោះថា ព្រះអង្គសូមបដិសេធចំពោះការឃោសនារបស់បារាំង ដែលថា ពួកវៀតមិញ គឺជាអ្នកបង្កើតចលនាតស៊ូខ្មែរឥស្សរៈសឹង ង៉ុកមិញ និងជាអ្នកចូលមកឈ្លានពានទឹកដីខ្មែរនោះ ជាការមិនពិតទេ។

មិនតែប៉ុណ្ណោះ ព្រះសង្ឃអង្គនោះបានទាំងថ្លែងថា គឺពួកបារាំង នៅក្នុងប្រទេសខ្មែរឯណោះវិញទេ ជាអ្នកធ្វើគុតព្រះសង្ឃជាច្រើនអង្គនោះ។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៥២ វិទ្យុសំឡេងណាំបូ ដដែលនោះ ក៏បានផ្សាយព័ត៌មាន ស្តីពីការប្រារព្ធខួបលើកទី២ នៃការប្រកាសប្រទេសកម្ពុជា ទទួលបានឯករាជ្យ កាលពីឆ្នាំ១៩៥០ របស់សឹង ង៉ុកមិញ ហើយបានធ្វើអត្ថាធិប្បាយបន្ថែមថា បុព្វហេតុតស៊ូប្រយុទ្ធរបស់ប្រជាជនខ្មែរ ជារឿងត្រឹមត្រូវ និងស្របតាមទ្រឹស្តីរបស់ព្រះពុទ្ធសាសនាទៀតផង។

បើតាមប្រភពស៊ើបការណ៍សម្ងាត់របស់បារាំង បានឱ្យដឹងថា នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៥២ សឹង ង៉ុកថាញ់ បានធ្វើដំណើរទៅកាន់តំបន់កាន់កាប់ដោយពួកវៀតមិញ និងបានចុះកិច្ចព្រមព្រៀងជាមួយសឹង ង៉ុកមិញ ដើម្បីសហការគ្នាប្រយុទ្ធប្រឆាំងនឹងពួកបារាំង។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៥២ គឺ៣ថ្ងៃ ក្រោយពីមានរបាយការណ៍សម្ងាត់នេះកៅ តក់ ក៏បានផ្ញើលិខិតអញ្ជើញមួយទៅឱ្យមេឥស្សរៈខ្មែរ-វៀតមិញ ឈ្មោះ ហុង ឈុន ជាសហការីជំនិតរបស់សឹង ង៉ុកមិញ ដើម្បីឱ្យមកចូលរួមពិភាក្សាគ្នាពីកិច្ចព្រមព្រៀងមួយ នៅក្នុងស្រុកសំរោង ជាមូលដ្ឋានតស៊ូធំរបស់គាត់។ ប៉ុន្តែ ដោយសារហុង ឈុន មានកិច្ចការច្រើនពេក ក៏ចេះតែពន្យារពេលជួបគ្នានោះរហូតមក។ តែរឿងនេះ មិនដឹងថា ជាការពិត ឬ

យ៉ាងណានោះទេ។

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៥២ សឺង ង៉ុកថាញ់, កៅ តក់ និងអៀ ស៊ីចូវ បានជួបពិភាក្សាគ្នា ជាមួយលាវ កែវមុនី មេដឹកនាំគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) ដែលពេលនោះ គាត់កំពុងបើកវគ្គហ្វឹកហាត់កងទ័ពថ្មីរបស់គាត់ ចំនួន៣០០នាក់ បន្ថែមទៀត។

ក្នុងជំនួបនោះ លាវ កែវមុនី មានសហការី៣នាក់ទៀតដែរ គឺ ទុម សុខ, អ៊ូជ និល ពេជ្រ និងត្រឡាច តែជំនួបពិភាក្សាគ្នានោះ មិនបានឈានដល់កិច្ចព្រមព្រៀងណាមួយ ឱ្យបានច្បាស់លាស់ទេ ព្រោះសឺង ង៉ុកថាញ់ ហាក់ដូចជាចង់សហការជាមួយពួកវៀតមិញដោយផ្ទាល់ច្រើនជាង ព្រោះគាត់ឃើញកម្លាំងកងទ័ព និងគ្រឿងសព្វាវុធរបស់ពួកវៀតមិញមានច្រើនសន្ធឹកសន្ធាប់ អាចសង្ឃឹមបាន។

ចាប់ពីខែកក្កដា ឆ្នាំ១៩៥២ មក កែវ មុនី, សុះ ម៉ាន់, នង សួន, នៃ សាវ៉ាន់, និងម៉ី ផូ ត្រូវបានបញ្ជូនឱ្យទៅសិក្សាពីក្បួនយុទ្ធសាស្ត្រ នៅសាលាសង្គ្រាមឈ្លបតាយង្វៀន នៅវៀតណាមភាគកណ្តាល។

ចំណែកនៅខេត្តកំពង់ធំ ក្នុងស្រុកបារាយណ៍ មានក្រុមខ្មែរឥស្សរៈមួយក្រុមតូចដឹកនាំដោយងួន ហុង និងសាឡុត ឆាយ កាន់កាប់ត្រួតត្រាតំបន់តាំងគោក និងរំលង ។ ក្រោយពីពួកគាត់ទៅចូលរួមសហការជាមួយមេខ្មែរឥស្សរៈ ឈ្មោះសាវ៉ាង វង្ស បានប៉ុន្មានខែស្រាប់តែ ងួន ហុង និងសាឡុត ឆាយ ក៏បែរទៅទាក់ទងសហការជាមួយមេឥស្សរៈខ្មែរ-វៀតមិញ ឈ្មោះមាស វង្ស នៅក្នុងខេត្តកំពង់ឆ្នាំង វិញ។

តែក្រោយទទួលដំណឹងថា សឺង ង៉ុកថាញ់ រត់ចេញពីក្រុងភ្នំពេញ ទៅបង្កើតចលនាតស៊ូ ឈ្មោះប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ នៅព្រំដែនថៃ មក ងួន ហុង និងសាឡុត ឆាយ ក៏បានប្តូរគំនិតលែងទាក់ទងសហការជាមួយមេឥស្សរៈខ្មែរ-វៀតមិញ ឈ្មោះមាស វង្ស ហើយទាក់ទងទៅចូលរួមជាមួយសឺង ង៉ុកថាញ់ និងកៅ តក់ នៅឯមូលដ្ឋានតស៊ូនៅស្រុកសំរោងចុងកាល់ វិញ។

នៅក្នុងខែតុលា ឆ្នាំ១៩៥២ ងួន ហុង និងសាឡុត ឆាយ បានដឹកនាំកម្លាំងរបស់

របត់នយោបាយ

ពួកគាត់ ព្រមទាំងគ្រូបង្រៀន និងសិស្សមកពីវិទ្យាល័យព្រះស៊ីសុវត្ថិ នៅក្រុងភ្នំពេញ និង សិស្សមកពីវិទ្យាល័យព្រះសីហនុ នៅខេត្តកំពង់ចាម ជាង១០នាក់ទៀត ដែលស្ម័គ្រចិត្តទៅ ចូលរួមតស៊ូជាមួយសឺង ង៉ុកថាញ់ ដែរ សរុបទាំងអស់ ចំនួន៨០នាក់ ធ្វើដំណើរចេញពី ស្រុកបារាយណ៍ កាត់តាមព្រៃភ្នំ អស់រយៈពេលជាច្រើនថ្ងៃ ទើបបានទៅដល់ជំរុំតស៊ូរបស់ សឺង ង៉ុកថាញ់ នៅភ្នំដងរែក។

៤៦
ឆ្នាំ១៩៥២ ហ៊ុន សែន ចាប់កំណើត



ទាហានបារាំង បើកប្រតិបត្តិការបោសសម្អាតពួកខ្មែរឥស្សរៈ នៅខេត្តកំពត ឆ្នាំ១៩៥២

នៅថ្ងៃអង្គារ ទី០៥ ខែសីហា ឆ្នាំ១៩៥២ គ្រួសារកសិករមានជីវភាពធូរធារមួយ មានប្តីឈ្មោះ ហ៊ុន នាង និងប្រពន្ធឈ្មោះ ឌី ប៉ុក រស់នៅភូមិពាមកោះស្នា ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានសម្រាលកូនទី៣ ឈ្មោះ ហ៊ុន ប៊ុនណាល់ ឬហ៊ុន ណាល់ (ក្នុងប្រវត្តិរូបផ្លូវការ កើតថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៥១)។ ហ៊ុន ប៊ុនណាល់ មានបងប្រុស២នាក់គឺ បងទី១ ឈ្មោះ ហ៊ុន ឡុងសាន និងបងទី២ ឈ្មោះ ហ៊ុន ឡុងសេង។

ក្រោយមកទៀត ហ៊ុន ប៊ុនណាល់ ក៏មានប្អូនស្រី៣នាក់ទៀត គឺហ៊ុន សេងនី, ហ៊ុន ស៊ីណាត និងហ៊ុន ធឿន។

ក្នុងឆ្នាំ១៩៤១ លោកហ៊ុន នាង បួសជាសង្ឃ និងបានមកគង់រៀនសូត្រនៅវត្ត ឧណ្ណាលោម នាក្រុងភ្នំពេញ។

ក្រោយពីព្រឹត្តិការណ៍បង្ក្រាបព្រះសង្ឃរាប់រយអង្គ ដែលនាំគ្នាធ្វើបាតុកម្មនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤២ ដើម្បីទាមទារឱ្យបារាំង ដោះលែងអាចារ្យហែម ចៀវ និងនួន ឌួង នោះមក ព្រះសង្ឃព្រះនាមហ៊ុន នាង បានលាចាកសិក្ខាបទ ហើយបានទៅចូលរួមជាមួយ ចលនាតស៊ូខ្មែរឥស្សរៈ ដើម្បីរំដោះប្រទេសជាតិ ឱ្យរួចផុតពីការត្រួតត្រារបស់បារាំង នឹងគេ ដែរ។

ប៉ុន្តែក្រោយមក គ្រួសារត្រកូលហ៊ុន បានរងនូវការឈឺចាប់ ដោយសារមានពួកខ្មែរ ឥស្សរៈមួយក្រុមផ្សេងទៀត នាំគ្នាមកចាប់ជីដូនខាងម្តាយរបស់ហ៊ុន ប៊ុនណាល់ យកទៅ ជំរិតទារប្រាក់ ព្រោះពួកវាដឹងច្បាស់ថា គ្រួសារនេះមានប្រាក់កាសមាសប្រាក់ច្រើន។

ដើម្បីអាយុជីវិតរបស់ជីដូនរបស់ហ៊ុន ប៊ុនណាល់ នោះ ជីតារបស់គាត់ ក៏ប្រញាប់ ប្រញាល់លក់ទ្រព្យសម្បត្តិ និងប្រមូលមាសប្រាក់ទាំងប៉ុន្មាន យកទៅឱ្យពួកខ្មែរឥស្សរៈ មួយក្រុមនោះ ជាថ្នូរនឹងការដោះលែងជីដូនរបស់គាត់ ត្រលប់មកផ្ទះវិញ។

ក្រោយពីការចាប់ជំរិតនោះ ជីវភាពគ្រួសាររបស់គាត់ ចាប់ផ្តើមធ្លាក់ដុនដាបជា-លំដាប់។ ដោយមានការឈឺចាប់ជាមួយពួកខ្មែរឥស្សរៈជាចោរប្លន់ ចាប់ម្តាយរបស់គាត់ជំរិត ទារប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់នោះមក លោកហ៊ុន នាង ក៏បានស្ម័គ្រចិត្តចូលធ្វើជាកងជីវពល របស់រាជរដ្ឋាភិបាលសម្តេចសីហនុ និងទទួលបានការហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រពីពួកទាហាន បារាំង រួចហើយ ក៏ចាប់ផ្តើមនាំគ្នាទៅវាយពួកឥស្សរៈនោះវិញ។

លុះពេល ហ៊ុន ប៊ុនណាល់ ហៅហ៊ុន ណាល់ ពេញវ័យជាយុវជន គាត់ក៏បានដើរ តាមគន្លងឪពុកគាត់ដែរ ពោលគឺក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គាត់បាន ស្ម័គ្រចិត្តចូលព្រៃម៉ាគី តាមការអំពាវនាវរបស់សម្តេចសីហនុ ដែលកាលនោះ ជាព្រះប្រធាន

រណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីចូលរួមតស៊ូធ្វើសង្គ្រាមប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ របស់លន់ នល់ ដោយបានដូរឈ្មោះមកជា ហ៊ុន សែន វិញ។ ក្រោយមក ហ៊ុន សែន បានក្លាយទៅជាមេដឹកនាំខ្មែរ ដ៏ល្បីល្បាញម្នាក់នៅលើសាកលលោក ដែលបានកាន់អំណាចបានយូរជាងគេទៀតផង។

៤៧
មេខ្មែរឥស្សរៈ ប្រាប់ប្រជារាស្ត្រថា កុំជឿតាមការសន្យារបស់សម្តេចសីហនុ



កែវ មាស មេដឹកនាំខ្មែរឥស្សរៈ

នៅពាក់កណ្តាលខែសីហា ឆ្នាំ១៩៥២ ដោយយោងទៅតាមប្រភពមិនសូវច្បាស់ការណ៍មួយ ចៅហ្វាយខេត្តសៀមរាប បានរាយការណ៍ថា សឺង ង៉ុកថាញ់ បានព្រមព្រៀងឱ្យកងទ័ពវៀតមិញ ចំនួន៥០០នាក់ មកបោះទីតាំងឈរជើងនៅប៉ែកខាងជើង នៃទឹកដីខេត្តបាត់ដំបង និងក្នុងខេត្តសៀមរាប ដើម្បីជាជំនួយដល់កងទ័ពគាត់។

តែ លាវ កែវមុនី ប្រធានគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) កំពុងត្រួតត្រាកាន់កាប់នៅតំបន់នោះដែរ មិនឯកភាពជាមួយសឺង ង៉ុកថាញ់ ពីបញ្ហានេះទេ ព្រោះប្រហែលជាគាត់ខ្លាចបាត់បង់ឥទ្ធិពលរបស់គាត់ ក៏មិនដឹង?

ភ្នាក់ងារប៉ូលិសសម្ងាត់ ខេត្តបាត់ដំបង បានរាយការណ៍ថា នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ

១៩៥២ លាវ កែវមុនី, អាចារ្យទុម សុខ , អាចារ្យប៊ូ , អាចារ្យរ៉ែន និងមេរៀតមិញ ៩នាក់ទៀតបានប្រជុំកងទ័ពចំនួន១០០នាក់ដើម្បីពិភាក្សាគ្នាស្តីពីការសន្យារបស់ព្រះមហាក្សត្រ សីហនុ ក្នុងការទាមទារឯករាជ្យពីប្រទេសបារាំង ក្នុងរយៈពេល៣ឆ្នាំនោះ។

នៅក្នុងខែតុលា ឆ្នាំ១៩៥២ ព្រះសង្ឃមកពីវត្តចំនួន៣ នៅក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ក៏បានចូលមកប្រជុំតាមការនិមន្តរបស់ទូ សាមុត និងកែវ មុនី មេដឹកនាំរណសិរ្សឯកភាពឥស្សរៈ (UIF) នៅភូមិភាគបូព៌ា។ ក្រោយពីបានស្តាប់ការឃោសនារបស់ទូ សាមុត និងកែវ មុនី មក ព្រះសង្ឃដែលមកពីវត្តទាំង៣នោះ ក៏បានប្រកាសគាំទ្ររណសិរ្សឯកភាពឥស្សរៈ (UIF) ដូចកាលពីប្រជុំព្រះសង្ឃចំនួន៤០អង្គ កាលពីលើកទី១ដែរ។

ក្រោយមកទៀត មានរបាយការណ៍មួយ បានឱ្យដឹងថា មានព្រះសង្ឃចំនួន៧០០អង្គ មកពីវត្តចំនួន២៤ ក្នុងខេត្តព្រៃវែង ត្រូវបានចុះឈ្មោះជាសមាជិករណសិរ្សឯកភាពឥស្សរៈ (UIF) ហើយក្នុងនោះ ក៏មានព្រះសង្ឃមួយចំនួនតូច ត្រូវបានបញ្ចូលជាបក្ខជនត្រៀម របស់បក្សប្រជាជនបដិវត្តន៍ខ្មែរផងដែរ។ តែមុននឹងក្លាយទៅជាបក្ខជនពេញសិទ្ធិ ព្រះសង្ឃទាំងនោះ ត្រូវនៅជាបក្ខជនត្រៀមរយៈពេល៩ខែសិន ទើបបំពេញឱ្យទៅជាបក្ខជនពេញសិទ្ធិ ព្រោះព្រះសង្ឃត្រូវបានបក្សចាត់ទុកជាវណ្ណៈជិះជាន់ពលកម្មគេ (ដេកចាំតែស៊ីស្រាប់)។ ដោយឡែក បក្ខជនត្រៀម ជាអ្នកតស៊ូចេញមកពីវណ្ណៈកសិករ-កម្មករ ដែលជាអ្នកបញ្ចេញពលកម្មលំបាកធ្ងន់ធ្ងរជាងគេ ត្រូវនៅជាបក្ខជនត្រៀម ក្នុងរយៈពេលតែ៣ខែទៅ៦ខែប៉ុណ្ណោះ នឹងបានក្លាយទៅជាបេក្ខជនពេញសិទ្ធិ។

នៅក្នុងឆ្នាំ១៩៥២ នៅលើផ្ទាំងផែនទីកម្ពុជា មានតែខេត្តចំនួន១៣ប៉ុណ្ណោះ ហើយក្រុមស៊ើបការណ៍សម្ងាត់របស់បារាំង បានបង្ហាញឱ្យឃើញថា ទឹកដី២ភាគ៥ នៃផ្ទៃប្រទេសទាំងមូល ជាតំបន់អសន្តិសុខ។

នៅខេត្តកំពង់ចាម ក្នុងចំណោមស្រុកទាំង១០ មានស្រុក៥ ជាតំបន់អសន្តិសុខ។ ទឹកដី៣ភាគ៥ នៃខេត្តបាត់ដំបង ជាតំបន់អសន្តិសុខ។ ទឹកដី១ភាគ២ នៃខេត្តកំពង់ឆ្នាំង ជាតំបន់អសន្តិសុខ។ ទឹកដី៤ភាគ៥ នៃខេត្តកំពត និងកំពង់ធំ ជាតំបន់អសន្តិសុខ។

របត់នយោបាយ

ចំណែកទឹកដី២ភាគ៣ នៃខេត្តសៀមរាប ក៏ជាតំបន់អសន្តិសុខដែរ ដោយមួយផ្នែកត្រួតត្រាដោយពួកសឹង ង៉ុកថាញ់ និងកៅ តក់ និងមួយផ្នែកទៀត ត្រួតត្រាដោយជាប ឈួន ដែលបានចុះចូលជាមួយព្រះមហាក្សត្រសីហនុ និងបារាំង កាលពីខែតុលា ឆ្នាំ១៩៤៩។

ទឹកដី១ភាគ៥ នៃខេត្តព្រៃវែង ជាតំបន់គ្រោះថ្នាក់ខ្លាំង ហើយទឹកដី១ភាគ៥ទៀត ជាតំបន់គ្រោះថ្នាក់បង្គួរ។ ទឹកដី៤ភាគ៥ នៃខេត្តស្ទឹងត្រែង និងពោធិ៍សាត់ ព្រមទាំងទឹកដី១ភាគ២ នៃខេត្តក្រចេះ និងទឹកដី១ភាគ៥ នៃខេត្តស្វាយរៀង ត្រូវបានចាត់ទុកជាតំបន់អសន្តិសុខ។

ចំណែកតំបន់ទាំងឡាយនៅតាមបណ្តោយព្រំប្រទល់ខេត្តតាកែវ ជាប់ព្រំដែនវៀតណាម ត្រូវចាត់ទុកជាតំបន់អសន្តិសុខ។

ឯខេត្តកំពង់ស្ពឺ នៅជុំវិញទីរួមខេត្ត និងតាមបណ្តោយអនាគតផ្លូវជាតិលេខ៤ និងចុះទៅសង ខាងផ្លូវចម្ងាយប្រមាណ១៥គីឡូម៉ែត្រ ជាតំបន់គ្រប់គ្រងដោយរាជរដ្ឋាភិបាល។ ក្រៅពីនោះ ជាតំបន់ត្រួតត្រាដោយកងទ័ពវៀតមិញ និងចលនាខ្មែរឥស្សរៈ ក្នុងនោះ កងទ័ពវៀតមិញ កាន់កាប់២ភាគ៥, ពួកខ្មែរឥស្សរៈ ពុត ឆាយ ត្រួតត្រា១ភាគ៥ និងពួកឥស្សរៈទ្រង់ចន្ទរង្សី ត្រួតត្រា១ភាគ៥ ។

នៅរដូវប្រាំង ឆ្នាំ១៩៥២ ទាហានរាជការខ្មែរ-បារាំង បានបើកប្រតិបត្តិការសឹកវាយប្រហារទៅលើជំរំតស៊ូរបស់ចលនាខ្មែរឥស្សរៈជាបន្តបន្ទាប់ ធ្វើឱ្យចលនាឥស្សរៈមួយចំនួនជួបការលំបាកជាខ្លាំង។

ក្រោយព្រះមហាក្សត្រសីហនុ សន្យាទាមទារឯករាជ្យពីប្រទេសបារាំង ឱ្យបានក្នុងរយៈពេលយ៉ាងយូរ៣ឆ្នាំនោះមក មេឥស្សរៈឈ្មោះចាន់ ដាវ៉ា បានប្រមូលប្រជារាស្ត្រនៅក្នុងតំបន់ដែលគាត់ត្រួតត្រា មករួមប្រជុំជាមួយកងទ័ពនៅក្រោមបញ្ជាគាត់ទាំងអស់ ឱ្យបានដឹងពីការប្រកាសទាមទារឯករាជ្យរបស់ព្រះមហាក្សត្រសីហនុ ។

គាត់បានស្នាបស្នង់ ដឹងថា ប្រជារាស្ត្រ និងកងទ័ពដែលមានដើមកំណើតនៅកម្ពុជាកណ្តាលទាំងអស់ បានឯកភាពគ្នាគាំទ្រការប្រកាសទាមទារឯករាជ្យព្រះមហាក្សត្រសីហនុ

១០០ភាគរយ ព្រោះបំណងដ៏ធំបំផុតរបស់ពួកគេ គឺចង់បានឯករាជ្យនេះឯង។ ប៉ុន្តែនៅក្នុងចំណោមកងទ័ពរបស់គាត់ ដែលមានដើមកំណើតមកពីទឹកដីកម្ពុជាក្រោមមានពាក់-កណ្តាលគាំទ្រការប្រកាសទាមទារឯករាជ្យរបស់ព្រះមហាក្សត្រសីហនុ និងពាក់កណ្តាលទៀតមិនទាន់ហ៊ានសម្រេចចិត្តយ៉ាងណានៅឡើយ។

ចាន់ ដាវ៉ា បានស្នើសុំឱ្យអង្គប្រជុំស្ងៀមស្ងាត់សិន និងឱ្យត្រៀមខ្លួនបន្តការតស៊ូទៅមុខទៀត ដោយគាត់បានលើកហេតុផលថា សម្តេចសីហនុ បានឡើងសោយរាជសម្បត្តិពីឆ្នាំ១៩៤១មកនោះ ក៏ដោយសារតែពួកបារាំង ជាអ្នកលើកបន្តុបដែរ។ ដូច្នេះ តើឱ្យព្រះអង្គទាមទារឯករាជ្យពីបារាំង យ៉ាងដូចម្តេចទៅ?

ចាន់ ដាវ៉ា បានពន្យល់ប្រាប់អង្គប្រជុំទៀតថា សម្តេចសីហនុ ត្រូវរ៉ូវគ្នាជាមួយបារាំង ហើយបារាំង ប្រាកដជាមិនព្រមប្រគល់ឯករាជ្យឱ្យព្រះអង្គដោយងាយៗ តាមការទាមទារនោះទេ។ ដូច្នេះ យើងត្រូវតែរួបរួមគ្នាប្រយុទ្ធប្រឆាំងជាមួយបារាំង បន្តទៀត ហើយកុំជឿតាមការសន្យារបស់សម្តេចសីហនុ ឱ្យសោះ ព្រោះនេះគ្រាន់តែជាល្បិចបោកបញ្ឆោតរបស់ព្រះអង្គ និងបារាំង តែប៉ុណ្ណោះ។

ចាន់ ដាវ៉ា បានសន្យានៅក្នុងអង្គប្រជុំថា គាត់នឹងដឹកនាំតស៊ូដណ្តើមឯករាជ្យពីបារាំង មកជូនមាតុភូមិប្រទេសវិញ ឱ្យបានក្នុងរយៈពេល៣ឆ្នាំទៀតយ៉ាងយូរ ដូចការសន្យារបស់សម្តេចសីហនុ ដែរ។

ប៉ុន្តែក្រោយពីការប្រកាសដូច្នេះ មិនបានប៉ុន្មានសប្តាហ៍ផង នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៥២ ចាន់ ដាវ៉ា បាននាំសហការីជំនិតចំនួន៧នាក់ទៀត ទៅចុះចូលជាមួយព្រះមហាក្សត្រសីហនុ ទៅវិញ ហើយពួកឥស្សរៈជាក្រុមតូចៗផ្សេងៗទៀត ក៏បាននាំគ្នាពិចារណាក្នុងការទម្លាក់អាវុធ ចុះចូលជាមួយព្រះមហាក្សត្រសីហនុ ដូចចាន់ ដាវ៉ា ដែរ។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏ពួកខ្មែរឥស្សរៈផ្សេងៗទៀត ពិសេសកងទ័ពឥស្សរៈដែលនៅក្រោមការដឹកនាំរបស់សឹង ង៉ុកមិញ និងទូ សាមុត នៅតែបន្តសហការយ៉ាងជិតស្និទ្ធជាមួយកងទ័ពវៀតមិញ ដើម្បីប្រឆាំងនឹងបារាំង ជាដៃល។


របត់នយោបាយ

ចំណែកពួកមេដឹកនាំវៀតមិញ ចាត់ទុកថា ការសន្យាទាមទារឯករាជ្យពីប្រទេសបារាំង របស់ព្រះមហាក្សត្រសីហនុ ឱ្យបានក្នុងរយៈពេលយ៉ាងយូរ ៣ឆ្នាំនោះ គឺជាការបោកប្រាស់ទាំងស្រុង ហើយការប្រកាសទាមទារនេះ នឹងធ្វើឱ្យចលនាខ្មែរឥស្សរៈ ត្រូវខាតបង់យ៉ាងធ្ងន់ធ្ងរផងដែរ។

នៅរដូវប្រាំង ឆ្នាំ១៩៥៣ ងិន ហោ បានដឹកនាំកងទ័ពខ្មែរ-វៀតមិញ ចំនួន២០០នាក់ ចាកចេញពីភូមិភាគបូព៌ា ទៅស្រុកព្រៃកប្បាស ខេត្តតាកែវ ភូមិភាគនិរតី។

ជាមួយគ្នានោះ ក៏មានកងទ័ពចល័តលេខ១៦០, លេខ១៧០ និងលេខ១៨០ របស់ឥស្សរៈខ្មែរ-វៀតមិញ កំពុងធ្វើសកម្មភាពនៅក្នុងខេត្តកំពត, ខេត្តកំពង់ស្ពឺ និងភាគខាងត្បូងនៃខេត្តតាកែវ ផងដែរ ក្នុងនោះ ញ៉ែម ស៊ុន ជាមេដឹកនាំកងទ័ពឥស្សរៈខ្មែរ-វៀតមិញ ប្រចាំខេត្តកំពត និងជាមេបញ្ជាការធំរបស់ប៉ែន សុវណ្ណ បានទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយ មាស វង្ស ជាមេដឹកនាំកងទ័ពខ្មែរ-វៀតមិញ មានកងទ័ពប្រមាណ ២០០នាក់ ប្រចាំនៅភាគខាងជើងខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។

៤៨
និស្សិតខ្មែរនៅប្រទេសបារាំង និងលទ្ធិម៉ាក្សនិយម



អគារស្នាក់នៅរបស់និស្សិតខ្មែរនៅក្រុងប៉ារីស ប្រទេសបារាំង ពេលកំពុងសាងសង់

នៅដើមឆ្នាំ១៩៤៦ ព្រះមហាក្សត្រសីហនុ បានជ្រើសរើសនិស្សិតខ្មែរ ចំនួន៧នាក់ ឱ្យទៅបន្តការសិក្សានៅប្រទេសបារាំង។តែនេះមិនមែនជាលើកទី១ទេដែលព្រះមហាក្សត្រ បានបញ្ជូននិស្សិតឱ្យទៅបន្តការសិក្សា នៅប្រទេសបារាំង នោះ ពីមុនមក ព្រះអង្គបានបញ្ជូន និស្សិតខ្មែរមួយចំនួន ឱ្យទៅបន្តការសិក្សានៅប្រទេសបារាំង ជាបន្តបន្ទាប់ រួចមកហើយ។

និស្សិតខ្មែរទាំង៧នាក់នោះ រួមមាន៖ ១.ជួន ជឿន ត្រូវទៅបន្តការសិក្សាផ្នែកវេជ្ជសាស្ត្រ, ២.ជួន ជុំ ត្រូវទៅបន្តការសិក្សាផ្នែកនីតិសាស្ត្រ, ៣.ជួន មុម្ម ត្រូវទៅបន្តការសិក្សាផ្នែកវិស្វករ និងវិទ្យាសាស្ត្រ, ៤.អៀ ស៊ីចូវ ត្រូវទៅបន្តការសិក្សាផ្នែកពាណិជ្ជសាស្ត្រ, ៥.យ៉ែម សារុង ត្រូវទៅបន្តការសិក្សាផ្នែកវិទ្យាសាស្ត្រ និងស្ថិតិសាស្ត្រ, ៦.ផ្លែក ឆាត ត្រូវទៅបន្តការសិក្សាផ្នែកវិស្វករ និងវិទ្យាសាស្ត្រ និង៧.ញ៉ែម សុផល ត្រូវទៅបន្តការសិក្សាផ្នែកឱសថសាស្ត្រ។

ក្នុងចំណោមនិស្សិតទាំង៧នាក់នេះ ជួន ជឿន, ជួន ជុំ និងជួន មុម្ម ជាបងប្អូន

បង្កើតនឹងគ្នា ហើយត្រូវជាចៅរបស់ឧកញ៉ាចៅហ្វាវាំង ជួន និងមានឪពុកឈ្មោះជួន ហ៊ិល និងម្តាយឈ្មោះប៊ុណ្ណ ចន្ទម៉ូលី (ជាបងស្រីបង្កើតរបស់ ប៊ុណ្ណ ចន្ទម៉ុល អតីតអ្នកទោសគុកកោះត្រឡាច)។

នៅក្នុងឆ្នាំ១៩០៦ ជួន ហ៊ិល (ឪពុករបស់ ជួន ជឿន, ជួន ជុំ និងជួន មុម្ម) បានធ្វើដំណើរតាមនាវាជាមួយឧកញ៉ាចៅហ្វាវាំង ជួនជាឪពុកអមព្រះរាជដំណើរព្រះមហាក្សត្រ ស៊ីសុវត្ថិ យាងទៅបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសបារាំង។

លុះដល់ពេលព្រះមហាក្សត្រស៊ីសុវត្ថិ យាងត្រលប់មកមាតុប្រទេសវិញ ជួន ហ៊ិល មិនបានវិលមកវិញទេ គឺគាត់គេចកៀច ដើម្បីបន្តការសិក្សានៅប្រទេសបារាំង អស់រយៈពេល ៩ឆ្នាំ រហូតទទួលបានសញ្ញាបត្របរិញ្ញាបត្រច្បាប់ ទើបគាត់វិលត្រលប់មកមាតុប្រទេសវិញ ក្នុងឆ្នាំ១៩១៦។

លុះ៣០ឆ្នាំក្រោយមកទៀត គឺថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៤៦ ព្រះមហាក្សត្រសីហនុ យាងទៅបំពេញព្រះរាជទស្សនកិច្ច នៅប្រទេសបារាំង តាមនាវាចម្បាំងបារាំង មួយគ្រឿងឈ្មោះគ្រ័រហ្សឺរ ឡឺ គ្លរ (Croiseur Le Gloire)។

និស្សិតខ្មែរទាំង៧នាក់ ដែលត្រូវទៅបន្តការសិក្សា នៅប្រទេសបារាំង នោះ ក៏បានធ្វើដំណើរតាមនាវាចម្បាំង ឈ្មោះគ្រ័រហ្សឺរ ឡឺ គ្លរ (Croiseur Le Gloire) នោះដែរ។ តែពួក គេត្រូវដេកលើអង្រឹងនៅបាតនាវា ជាមួយសិស្សទាហានជើងទឹកបារាំង រាប់រយនាក់ទៀត។ ដោយឡែក ព្រះមហាក្សត្រសីហនុ គង់នៅបន្ទប់ជាមួយមន្ត្រីយោធាជាន់ខ្ពស់បារាំង ដោយ មាននិស្សិតម្នាក់ឈ្មោះប៉ុក ជីសកុមារ នៅអមជាមួយផង។

និស្សិតឈ្មោះប៉ុក ជីសកុមារ ក៏ជាចៅរបស់ឧកញ៉ាចៅហ្វាវាំង ជួន ដែរ។ គាត់មានម្តាយ ឈ្មោះជួន យ៉ង់ (ជាបងស្រីរបស់ជួន ហ៊ិល) និងឪពុក ឈ្មោះ ប៉ុក ហ៊ែល ហើយប៉ុក ហ៊ែល នេះ ជាឪពុកក្មេករបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីវ៉ែត ។ ដូច្នេះ និស្សិតឈ្មោះប៉ុក ជីកុមារ នេះ ត្រូវជាបងប្អូនជីដូនមួយរបស់ជួន ជឿន, ជួន ជុំ និងជួន មុម្ម ផងដែរ។

ក្រោយធ្វើដំណើរតាមសមុទ្រ អស់រយៈពេលប្រហែលមួយខែ ទើបនាវាចម្បាំងនោះ



នាវាចម្បាំងបារាំង ឈ្មោះគ្រ័រហ្សឺរ ឡឺ ក្លរ (Croiseur Le Gloire)

ចូលចតនៅកំពង់ផែទូឡុង (Toulon) ដែលស្ថិតនៅភាគខាងត្បូង នៃប្រទេសបារាំង។ នៅកំពង់ផែទូឡុង (Toulon)នោះ មានអ្នកមុខអ្នកការបារាំង ជាច្រើន បាននាំគ្នាមកទទួលព្រះមហាក្សត្រសីហនុ យ៉ាងអធិកអធម។ ចំណែកពួកនិស្សិតទាំង៧នាក់ គេឱ្យឡើងជិះរថភ្លើងឆ្ពោះទៅទីក្រុងប៉ារីស បន្តទៀត។

ក្រោយពីសម្រាកនៅអគារស្នាក់នៅរបស់និស្សិត មកពីឥណ្ឌូចិន ក្នុងបរិវេណបុរីសកលវិទ្យាល័យអន្តរជាតិ ក្រុងប៉ារីស មួយរយៈខ្លីមក ពួកនិស្សិតទាំង៧នាក់នោះ ត្រូវបានក្រសួងអប់រំបារាំង អនុញ្ញាតឱ្យចូលសិក្សាជាមួយនិស្សិតជាជនជាតិបារាំង និងជនជាតិផ្សេងៗទៀត នៅសាកលវិទ្យាល័យនោះ។

បន្ទាប់ពីបានចូលសិក្សាមិនយូរប៉ុន្មានខែផង ពួកគេក៏បានមូលមតិគ្នាបង្កើតឱ្យមានសមាគមមួយ ឈ្មោះសមាគមខេមរនិស្សិត (AEK)។ មុនដំបូង ជួន មុម បានស្នើសុំនិស្សិតជារៀមច្បងម្នាក់ ឈ្មោះ អូ ឈៀង ដែលមករៀនយកសញ្ញាបត្របណ្ឌិតបុរាណវិទ្យា មុនពួកគេនោះ ឱ្យចូលរួម និងធ្វើជាប្រធានសមាគមនេះ។ តែ អូ ឈៀង ប្រាប់ថា ទាល់តែមានការតែងតាំងពីព្រះករុណាព្រះមហាក្សត្រសីហនុ ទើបគាត់យល់ព្រមចូលរួម និងធ្វើជាប្រធានសមាគមនេះ។

តែទោះបី អូ ឈៀង មិនព្រមចូលរួមក៏ដោយ ក៏និស្សិតផ្សេងៗទៀត បានរួបរួមគ្នាបង្កើតសមាគមខេមរនិស្សិត (AEK) នេះ ទាល់តែបាន ហើយបានជ្រើសរើស អៀ ស៊ីចូវ

ជានិស្សិតខ្មែរទី២ បន្ទាប់ពីសឺន សាន ដែលបានទៅរៀនជំនាញសេដ្ឋកិច្ចជាន់ខ្ពស់ និងជាមនុស្សមានគំនិតជាតិនិយម ធ្វើជាប្រធានសមាគមខេមរនិស្សិត (AEK) និងយ៉ែម សារុង ជាអគ្គលេខាសមាគម ។

ចំណែកសមាជិកសមាគម រួមមាន ជួន ជឿន, ជួន មុម្ម, វ័ណ្ណ មោលីវ័ណ្ណ, សម សារី, តាន់ គឹមហួន, ព្រះអង្គម្ចាស់នរោត្តម កន្តុល, ម៉ៅ សាយ, កន្តារ ដឺម៉ង់តេរ៉ូ, ផ្លែក ឆាត និងទុនចូត ស៊ីរិន ជាដើម។

និស្សិតខ្មែរទាំងនោះ ស្នាក់នៅរួមគ្នាជាមួយនិស្សិតឡាវ និងនិស្សិតវៀតណាម ក្នុងអគារមួយ មានឈ្មោះថា ផ្ទះឥណ្ឌូចិន។

លុះដល់ឆ្នាំ១៩៤៨ ម៉ៅ សាយ បានសុំឱ្យសមាគមខេមរនិស្សិត(AEK) នេះ ជ្រើសរើសគាត់ឱ្យធ្វើជាតំណាងនិស្សិតខ្មែរ នៅក្នុងអគារស្នាក់នៅ ដែលមានឈ្មោះថា ផ្ទះឥណ្ឌូចិន នោះ។ និស្សិតទាំងអស់ ក៏បានឯកភាពយល់ព្រមដែរ តែបានដាក់លក្ខខណ្ឌមួយ គឺមិនឱ្យមានការរៀបចំធ្វើពិធីបុណ្យប្រពៃណីចូលឆ្នាំខ្មែរ នៅក្នុងអគារស្នាក់នៅនេះ ជាដាច់ខាត ព្រោះនៅក្នុងអគារនេះ មានតាំងសុទ្ធតែរូបភាព រូបចម្លាក់ និងគ្រឿងសង្ហារិមផ្សេងៗជាច្រើនទៀត បង្ហាញពីវប្បធម៌ប្រពៃណីរបស់វៀតណាម។

ស្រាប់តែដល់ថ្ងៃធ្វើពិធីបុណ្យប្រពៃណីចូលឆ្នាំខ្មែរ ម៉ៅ សាយ និងសម សារី បានរៀបចំពិធីនេះ នៅក្នុងអគារស្នាក់នៅរួមគ្នាជាមួយនិស្សិតឡាវ និស្សិតវៀតណាម នោះទៅវិញ ដោយបានអញ្ជើញរដ្ឋមន្ត្រីទទួលបន្ទុកដែនដីបារាំងនៅឯនាយសមុទ្រ មកចូលរួមជាអធិបតីទៀតផង ធ្វើឱ្យនិស្សិតខ្មែរឯទៀត នៅក្នុងសមាគមខេមរនិស្សិត(AEK) មិនសប្បាយចិត្ត និងមិនព្រមចូលរួមក្នុងពិធីនោះ ទៀតផង។

ក្រោយបញ្ចប់ពិធីបុណ្យប្រពៃណីចូលឆ្នាំខ្មែរនោះមក និស្សិតខ្មែរមួយចំនួន បានលើកឡើងថា ម៉ៅ សាយ និងសម សារី ដែលបានអញ្ជើញរដ្ឋមន្ត្រីទទួលបន្ទុកដែនដីបារាំង នៅឯនាយសមុទ្រ មកចូលរួមជាអធិបតីនៅក្នុងពិធីនោះ គឺក្នុងបំណងយកមុខយកមាត់ ដើម្បីឱ្យរដ្ឋមន្ត្រីបារាំងនោះ បានស្គាល់ពួកគាត់ទាំង២នាក់កាន់តែច្បាស់ ហើយសង្ឃឹមថា ក្រោយ

ពេលបញ្ចប់ការសិក្សា វិលត្រលប់មកស្រុកវិញ រដ្ឋមន្ត្រីបារាំងនោះ ជួយផ្តល់បុណ្យស័ក្តិតួនាទីខ្ពង់ខ្ពស់ដល់ពួកគាត់ទាំង២នាក់ តែប៉ុណ្ណោះ។ មិនយូរប៉ុន្មាន ដោយសារតែការមិនចុះសម្រុងគ្នា ម៉ៅ សាយ និងសម សារី ក៏សម្រេចចិត្តដកខ្លួនចេញពីសមាគមខេមរនិស្សិត (AEK)នោះទៅ។

ក្នុងខែសីហា ឆ្នាំ១៩៤៩ និស្សិតខ្មែរចំនួន២១នាក់ទៀត ត្រូវរាជរដ្ឋាភិបាល ដឹកនាំដោយគណបក្សប្រជាធិតេយ្យ បញ្ជូនឱ្យទៅបន្តការសិក្សានៅប្រទេសបារាំងទៀត ក្នុងនោះរួមមាន៖ ចៅ សេង, សាឡុត ស, ជួន ប្រាសិទ្ធ (ជាប្អូនពៅរបស់ជួន ជឿន, ជួន ជុំ និងជួន មុម្ម), ម៉ី ម៉ាន់, ម៉ី ផាត និងអ៊ុច វ៉ែន ជាដើម។

សាឡុត ស ក៏ដូចជានិស្សិតផ្សេងៗទៀត មានឱកាសបានទៅបន្តការសិក្សា នៅប្រទេសបារាំងនោះក៏ដោយសារតែពួកគេជាសកម្មជនរបស់គណបក្សប្រជាធិបតេយ្យដែរ។

ក្រោយពីគណបក្សប្រជាធិបតេយ្យ ឈ្នះឆ្នោត បានឡើងកាន់អំណាច គណបក្សនេះបានតបស្នងចំពោះពួកគេវិញ ដោយបានបញ្ជូនពួកគេឱ្យទៅសិក្សានៅប្រទេសបារាំងបន្តទៀត។

ក្រោយពីធ្វើដំណើរតាមនាវា អស់រយៈពេលប្រមាណជិតមួយខែ និស្សិតអាហារូបករណ៍ទាំង២១នាក់នេះ បានមកដល់កំពង់ផែក្រុងម៉ាសេ ប្រទេសបារាំង នៅក្នុងខែកញ្ញា ឆ្នាំ១៩៤៩។

នៅឆ្នាំ១៩៥០ អៀង សារី ក៏ទទួលបានអាហារូបករណ៍ ទៅរៀននៅក្រុងប៉ារីស ដែរតែក្រោយ សាឡុត ស មួយឆ្នាំ។ អៀង សារី ក៏មិនខុសពីនិស្សិតផ្សេងៗទៀតដែរ ពួកគេបានទទួលអាហារូបករណ៍ ទៅបន្តការសិក្សា នៅប្រទេសបារាំង ក៏ដោយសារពួកគេជាសកម្មជនរបស់គណបក្សប្រជាធិបតេយ្យ តាំងពីសម័យបោះឆ្នោតឆ្នាំ១៩៤៦ នោះ មកដែរ។

ដោយមានការជួយផ្តល់យោបល់ពីអគ្គលេខាបក្សកុម្មុយនិស្តបារាំង ឈ្មោះ ម៉ូរីស ថូរ៉េ (Maurice Thorez) ផងដែរ នៅក្នុងខែមិថុនា ឆ្នាំ១៩៥០ និស្សិតជំនាន់មុន និងជំនាន់ក្រោយ ដូចជា ជួន មុម្ម, ជួន ជឿន, អៀង សារី, សាឡុត ស, ហ៊ូ យន់, កេង វ៉ាន់សាក់, ជួន ប្រាសិទ្ធ, ខៀវ ធីរិទ្ធ (ស្រី),ខៀវ ប៉ុណ្ណារី (ស្រី) ,ម៉ី ផាត, ម៉ី ម៉ាន់ ព្រមទាំងវត្ថុ សាមឿន

ជាដើម បានមូលមតិគ្នាបង្កើតក្លឹបម៉ាក្សស៊ីស(Marxism) ក្នុងបំណងសិក្សាស្វែងយល់ពីលទ្ធិកុម្មុយនិស្ត ដែលកំពុងពេញនិយមនៅលើពិភពលោក។

នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៥០ វ័ណ្ណ មោលីវ័ណ្ណ ត្រូវបាននិស្សិតជាសមាជិកសមាគមខេមរនិស្សិត (EAK) បោះឆ្នោតជ្រើសតាំងជាប្រធានសមាគម, កេង វ៉ាន់សាក់ ជាអនុប្រធាន, ស៊ឹម ខៃមកូ ជាអគ្គលេខាធិការ, ផូ បូពិន ជាអគ្គលេខាធិការរង, អ៊ុង ប៉ោឡេង ជាហិរញ្ញិក និងហូ តុងលីម ជាបណ្ណារក្ស។

អំឡុងពេលនោះ ជួន មុឌ្ត ត្រូវទៅព្យាបាលជំងឺប្រចាំកាយនៅតំបន់កុំព្លូ(Comploux) ក្បែរព្រំដែនប្រទេសអ៊ីតាលី រយៈពេលមួយឆ្នាំ មិនបានចូលរួមការបោះឆ្នោតនោះទេ។

វ័ណ្ណ មូលីវ័ណ្ណ កើតនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩២៦ នៅឃុំវាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលកាលសម័យនោះ ស្រុកព្រៃនប់ ស្ថិតនៅក្នុងខេត្តកំពត។

នៅក្នុងឆ្នាំ១៩៤៤គាត់បានបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ(បាក់ឌុប) នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ។

ក្នុងឆ្នាំ១៩៤៦ គាត់បានទទួលអាហារូបករណ៍ទៅបន្តការសិក្សាផ្នែកច្បាប់ នៅប្រទេសបារាំង។ ប៉ុន្តែបន្ទាប់ពីបានសិក្សាផ្នែកច្បាប់ បាន១ឆ្នាំ គាត់ក៏ប្តូរចិត្ត ទៅសិក្សាជំនាញផ្នែកស្ថាបត្យកម្ម នៅសាកលវិទ្យាល័យវិចិត្រសិល្បៈ របស់ប្រទេសបារាំង វិញ។

លុះដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៥០ គាត់ត្រូវបានជ្រើសតាំងជាប្រធានសមាគមនិស្សិតខ្មែរ (AEK)។

ពេលប្រកាសតែងតាំង វ័ណ្ណ មោលីវ័ណ្ណ ជាប្រធានសមាគមនិស្សិតខ្មែរ (AEK) នៅក្នុងសាលប្រជុំរបស់សាកលវិទ្យាល័យ នាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៥០ នោះ អៀ ស៊ីចូវ ដែលជារៀមច្បង និងធ្លាប់ជាប្រធានសមាគមនិស្សិតខ្មែរ កាលពីឆ្នាំ១៩៤៦ បានឡើងមានមតិណែនាំដល់និស្សិតជាសមាជិកសមាគមទាំងអស់ ឱ្យយកចិត្តទុកដាក់ពង្រឹងសាមគ្គីភាព ឯកភាពគ្នា និងមានទំនាក់ទំនងផ្សេងៗជាមួយបណ្តាមិត្តទាំងអស់ឱ្យបានល្អ ដោយយកការអត់ឱន ប្រឆាំងទល់នឹងការព្យាបាទឈ្នានីស និងយកការយោគយល់ មកទប់ទល់នឹង

ការមិនយោគយល់ ជាដើម។

ពេលនោះដែរ គាត់បានក្រើន រម្លឹកឱ្យនិស្សិតជាសមាជិកទាំងអស់ បង្កើនការខិតខំរៀនសូត្រឱ្យបានលទ្ធផលកាន់តែល្អប្រសើរទ្វេឡើងថែមទៀត ដើម្បីឱ្យស័ក្តិសមនឹងការបញ្ចេញពលកម្មដ៏ធំធេងរបស់ប្រជារាស្ត្រ និងរាជរដ្ឋាភិបាលផងដែរ។


ង័ណ្ណ មោលីង័ណ្ណ

ង័ណ្ណ មោលីង័ណ្ណ កាន់មុខតំណែងជាប្រធានសមាគមនិស្សិតខ្មែរ បានតែក្នុងរយៈពេលមួយឆ្នាំប៉ុណ្ណោះ គាត់ក៏ត្រូវនិស្សិតនៅក្លឹបម៉ាក្សស៊ីស នាំគ្នាទាមទារឱ្យមានការបោះឆ្នោតជ្រើសតាំងប្រធានសមាគមជាថ្មី ហើយហ៊ូ យន់ ត្រូវបានជ្រើសតាំងជាប្រធានសមាគមនិស្សិតខ្មែរ (AEK) ជំនួសង័ណ្ណ មោលីង័ណ្ណ វិញ។

ពេលនោះ និស្សិតខ្មែរនៅប្រទេសបារាំង មានការបែងចែកនិន្នាការគ្នា ជា៣ក្រុម គឺ៖ ទី១.ជាក្រុមមាននិន្នាការកណ្តាលនិយម រួមមាន ង័ណ្ណ មោលីង័ណ្ណ, យ៉ែម សារុង, ហង្ស ធុន ហាក់ និងតាន់ គឹមហួន ជាដើម។

ទី២.ជាក្រុមមាននិន្នាការសេរីនិយម រួមមាន ម៉ៅ សាយ, សម សារី, លី ជីនលី, ឌុក ប៉ាស៊ី, ឡុង ប៉ែត និងព្រំ ថុស ជាដើម។

ទី៣.ជាក្រុមមាននិន្នាការកុម្មុយនិស្តនិយម រួមមាន ជួន មុម្ម, ជួន ជឿន, អៀង សារី, សាឡុត ស, ហ៊ូ យន់, កេង វ៉ាន់សាក់, ជួន ប្រាសិទ្ធ, ខៀវ ធីរិទ្ធ (ស្រី), ខៀវ ប៉ុណ្ណារី (ស្រី), មុី ផាត, មុី ម៉ាន់, សុន សេន ព្រមទាំងវត្ថ សាមឿន ជាដើម ហើយពួកនេះភាគច្រើន បានចូលជាសមាជិកបក្សកុម្មុយនិស្តបារាំង ផងដែរ។

វបត់នយោបាយ

ក្រោយពីបង្កើតក្លឹបម៉ាក្សស៊ីស នោះមក អៀង សារី និងសាឡុត ស ព្រមទាំងនិស្សិតមួយចំនួនទៀត ពុំសូវយកចិត្តទុកដាក់ក្នុងការសិក្សាប៉ុន្មានឡើយ ដោយពួកគេបានចំណាយពេលវេលាគិតតែរឿងនយោបាយ និងងប់ងុលនឹងលទ្ធិកុម្មុយនិស្តទៅវិញ។

៤៩
សាឡុត ស សរសេរបទវិភាគ៖
“ រាជាធិបតេយ្យ ឬប្រជាធិបតេយ្យ ?”



សាឡុត ស

ក្រោយពេលសិក្សានៅប្រទេសបារាំង មិនបាន១ឆ្នាំផង សាឡុត ស ក៏បានជួបនិស្សិតនារីខ្មែរម្នាក់ អតីតសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(បាក់ឌុប)ជំបូងគេបង្អស់ នៅប្រទេសកម្ពុជា។

នារីខ្មែរម្នាក់នោះ គឺខៀវ ប៉ុណ្ណារី បានទៅបន្តការសិក្សាផ្នែកអក្សរសាស្ត្រ ជាមួយប្អូនស្រីរបស់នាងម្នាក់ទៀតឈ្មោះខៀវ ធីរិទ្ធ ដែលទៅបន្តការសិក្សាផ្នែកអក្សរសាស្ត្រអង់គ្លេស ។

មិនយូរប៉ុន្មាន សាឡុត ស និងខៀវ ប៉ុណ្ណារី បានផ្សារទំនាក់ទំនងស្នេហាជាមួយគ្នា ហើយអៀង សារី និងខៀវ ធីរិទ្ធ ជាប្អូនរបស់ខៀវ ប៉ុណ្ណារី ក៏ទាក់ទងស្នេហាជាមួយគ្នា រហូតបានក្លាយទៅជាគូស្វាមីភរិយានឹងគ្នាដែរ។

នៅក្នុងអំឡុងវិស្សមកាលរដូវក្តៅ ឆ្នាំ១៩៥០ សាឡុត ស និងអៀង សារី រួមជាមួយ

និស្សិតខ្មែរ១៦នាក់ផ្សេងទៀត នៅក្នុងក្លឹបម៉ាក្សស៊ីស(Marxism) បានស្ម័គ្រចិត្តទៅចូលរួមបំពេញការងារពលកម្ម ដោយប្រើកម្លាំងសុទ្ធសាធជាមួយប្រជាជនយូហ្គោស្លាវី រយៈពេល១ខែ នៅប្រទេសយូហ្គោស្លាវី។

យូហ្គោស្លាវី ជាប្រទេសកុម្មុយនិស្តមួយ ស្ថិតនៅអឺរ៉ុបខាងកើត បានក្លាយជាប្រទេសឯកោ ក្រោយពីផ្តាច់សម្ព័ន្ធភាពជាមួយសាធារណរដ្ឋសង្គមនិយម សហភាពសូវៀត ពីឆ្នាំ ១៩៤៨ មក ។ ដូច្នេះ ដើម្បីកសាងប្រទេសដោយឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនឡើងវិញ ដោយមិនចាំបាច់ពឹងផ្អែកលើសាធារណរដ្ឋសង្គមនិយម សហភាពសូវៀត ជាសសរទ្រូងរបស់លទ្ធិកុម្មុយនិស្ត នៅលើពិភពលោក ដូចមុនទៀត ប្រធានាធិបតីទីតូ បានប្រមូលកម្លាំងប្រជាជនរបស់ខ្លួននៅទូទាំងប្រទេស ឱ្យមកធ្វើការក្នុងការដ្ឋានធំៗ ដោយប្រើកម្លាំងមនុស្សជាសំខាន់។

នៅក្នុងឆ្នាំ១៩៥១ ខៀវ ប៉ុណ្ណារី បានវិលត្រលប់ពីប្រទេសបារាំង មកមាតុប្រទេសវិញ ហើយគាត់បានបង្កើតទស្សនាវដ្តីមួយ ឈ្មោះទស្សនាវដ្តី "នារី" ចុះផ្សាយពីវិធីធ្វើម្ហូបវិធីថែរក្សាសម្រស់ វិធីស្លៀកពាក់ បញ្ហាសង្គម និងបកប្រែរឿងរបស់បារាំង ដូចជារឿងកសិករ និងកូនប្រុស ជាភាសាខ្មែរ យកមកចុះផ្សាយផងដែរ។

នៅរដូវក្តៅ ឆ្នាំ១៩៥១ ជួន មុឺ បានដឹកនាំគណៈប្រតិភូនិស្សិតខ្មែរមួយក្រុម ក្នុងក្លឹបម៉ាក្សស៊ីស(Marxism) ក្នុងនោះមាន សាឡុត ស ម្នាក់ដែរ ទៅចូលរួមក្នុងពិធីមហោស្រពយុវជនអន្តរជាតិ នៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់ខាងកើត។

ពេលនោះហើយ ដែលធ្វើឱ្យ សាឡុត ស កាន់តែមានជំនឿជឿជាក់លើលទ្ធិកុម្មុយនិស្តខ្លាំងឡើងៗ ហើយគាត់ចំណាយពេលវេលាយ៉ាងច្រើនលើសលប់ ទៅលើការអានសៀវភៅដែលទាក់ទងនឹងទ្រឹស្តីកុម្មុយនិស្ត និងទាក់ទងនឹងការធ្វើបដិវត្តន៍។

សាឡុត ស ចងចាំនូវទ្រឹស្តីរបស់ស្តាលីន ដែលបានលើកឡើងថា បើគ្មានការរៀបចំបក្សមួយឱ្យបានរឹងមាំ និងគ្មានការដឹកនាំឱ្យបានម៉ឺងម៉ាត់ត្រឹមត្រូវទេនោះ ក៏គេមិនអាចអនុវត្តទ្រឹស្តីណាមួយបានដែរ ហើយពេលនោះ ពួកខ្មាំងសត្រូវរបស់លទ្ធិសង្គមនិយម នឹង

ឆ្លៀតឱកាសទាញយកផលប្រយោជន៍ ជំនួសការដឹកនាំរបស់បក្ស ជាមិនខាន។

នៅក្នុងឆ្នាំ១៩៥២ សាឡុត ស បានសម្រេចចិត្តចូលជាសមាជិកបក្សកុម្មុយនិស្ត បារាំង ជាមួយ សៀង អាន, យុន សឿន, មុី ម៉ាន់, ហ៊ូ យន់, និងតូច កឿន ដែរ។

មិនមានអ្នកណាម្នាក់ដឹងច្បាស់ថា សាឡុត ស ចូលបក្សកុម្មុយនិស្តបារាំង នៅថ្ងៃណា ខែណា ឱ្យបានពិតប្រាកដនោះទេ ហើយអ្នកឧទ្ទេសនាម សាឡុត ស ឱ្យចូលបក្សកុម្មុយនិស្ត បារាំង នោះ គេសង្ស័យថា ជួន មុម្ម ដែលបានចូលបក្សកុម្មុយនិស្តបារាំង មួយឆ្នាំមុន សាឡុត ស។ តែ ជួន មុម្ម បានបដិសេធថា គាត់មិនដែលបានចូលជាសមាជិកបក្សកុម្មុយនិស្តបារាំង ម្តងណាទេ។

នៅក្នុងឆ្នាំ១៩៥២ នោះដែរ ជួន ហ៊ិល ជាឪពុករបស់ជួន ជឿន, ជួន ជុំ, ជួន មុម្ម និងជួន ប្រាសិទ្ធ ដែលរស់នៅក្រុងភ្នំពេញ ទទួលមរណភាព។ តែពួកគាត់ជាកូនៗ មិនបាន មកចូលរួមបុណ្យសពឪពុកទេ ដោយសារសម័យនោះ ការធ្វើដំណើរពីប្រទេសបារាំង មក ប្រទេសខ្មែរ ទាល់តែមាននាវាចម្បាំងធំៗ ត្រូវចេញដំណើរមកប្រទេសខ្មែរ កាត់តាមមហាសមុទ្រ ទើបអាចមកជាមួយបាន ដោយចំណាយពេលប្រហែលមួយខែ។

ក្រោយពេលព្រះមហាក្សត្រសីហនុ ប្រកាសរំលាយរាជរដ្ឋាភិបាល និងសភារបស់ គណបក្សប្រជាធិបតេយ្យ នៅក្នុងខែមិថុនា ឆ្នាំ១៩៥២ សមាគមនិស្សិតខ្មែរ (AEK) បាន សរសេរលិខិតមួយ សម្តែងការប្រឆាំងប្តោលទោសចំពោះព្រះអង្គ យ៉ាងធ្ងន់ធ្ងរបំផុត។ លិខិតនោះ គឺកេង វ៉ាន់សាក់ ជាអ្នកតាក់តែងឡើង ហើយហ៊ូ យន់ ជាអ្នកចុះហត្ថលេខា ក្នុង នាមប្រធានសមាគម។

ទាក់ទងដល់រឿងព្រះមហាក្សត្រសីហនុ រំលាយរាជរដ្ឋាភិបាល និងសភារបស់គណបក្ស ប្រជាធិបតេយ្យ នេះដែរ សាឡុត ស បានសាកល្បងនិពន្ធអត្ថបទបែបវិភាគនយោបាយ មួយ មានចំនួន៨ទំព័រ និងបានដាក់ចំណងជើងជាសំណួរថា៖ "រាជាធិបតេយ្យ ឬប្រជាធិប-តេយ្យ?" យកទៅចុះផ្សាយនៅក្នុងព្រឹត្តិបត្ររបស់សមាគមនិស្សិតខ្មែរ លេខពិសេស នៅ ក្រុងប៉ារីសនោះ ដោយប្រើរហស្សនាមថា "ខ្មែរដើម"។

ខ្លឹមសារអត្ថបទនោះ សាឡុត ស បានធ្វើការវិភាគថា មានតែរដ្ឋសភា តាមបែបលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះ ដែលធ្វើឱ្យប្រជាជនខ្មែរមានលទ្ធភាពដកដង្ហើមបានខ្លះ ដូចកាលសម័យរដ្ឋាភិបាលរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស។

សាឡុត ស បានសរសេរចោទប្រកាន់ថា៖ "សីហនុ ជាស្តេចផ្តាច់ការ កំពុងបង្ហាញឱ្យឃើញច្បាស់ថា របបរាជាធិបតេយ្យ ជារបស់មួយកំពុងផ្តល់សិទ្ធិអំណាចទៅឱ្យមនុស្សមួយក្រុមតូច ដែលគ្មានបានធ្វើការរកស៊ីអ្វី ដើម្បីចិញ្ចឹមជីវិតខ្លួនឯងបន្តិចទាល់តែសោះ គឺចាំតែជិះជាន់កេងប្រវ័ញ្ចកម្លាំងញើសឈាមពីប្រជាជនប៉ុណ្ណោះ "។

សាឡុត ស បានសរសេរបន្តថា៖ "របបរាជាធិបតេយ្យ គឺជារបបអយុត្តិធម៌ និងជារបបស្អុយរលួយ មានក្លិនអាក្រក់បំផុត ដូច្នេះ ជនស្រលាញ់យុត្តិធម៌ទាំងឡាយ ត្រូវតែរួបរួមគ្នាក្រោកឈរឡើង ដើម្បីតស៊ូកម្ចាត់របបស្អុយរលួយនេះ...។ របបរាជាធិបតេយ្យ ជាសម្ព័ន្ធមិត្តរបស់ចក្រពត្តិនិយម ប៉ុន្តែជាសត្រូវរបស់ប្រជាជន, ព្រះពុទ្ធសាសនា និងការចេះដឹងពិសេស បណ្តាព្រះមហាក្សត្រខ្មែរ ចុងក្រោយនេះ សុទ្ធតែជ្រើសរើសឡើង ដោយពួកអាណានិគមបារាំង ហើយពួកនេះ ចាត់ទុកជាប្រជាជនខ្មែរ ជាសត្វធាតុ ដោយបង្ខំឱ្យធ្វើទាហាន ឱ្យធ្វើជាទាសករ ឱ្យធ្វើការទាំងយប់ ទាំងថ្ងៃ ដើម្បីចិញ្ចឹមពួកស្តេច និងបរិវារ"។

សាឡុត ស បានសរសេរបន្តទៀតថា៖ "នៅប្រទេសរុស្ស៊ី ប្រទេសបារាំង និងប្រទេសចិន របបរាជាធិបតេយ្យ ត្រូវបានគេផ្តួលរំលំ ដោយគ្មានទុកស្លាកស្នាមអ្វីបន្តិចឡើយ ហើយរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេយកមកជំនួសវិញ។ លទ្ធិប្រជាធិបតេយ្យ គ្មានអ្វីអាចមកប្រៀបផ្ទឹមបានទេ ព្រោះវាមានភាពបរិសុទ្ធ និងភ្លឺថ្លាដូចពេជ្រចរណៃ..."។

តែទោះបីស្អប់ខ្ពើមរបបរាជាធិបតេយ្យ ដូចអ្វីដែល សាឡុត ស បានសរសេរបទវិភាគដូចខាងលើនេះ ក៏ពិតមែន ក៏ សាឡុត ស មានបងស្រីជីដូនមួយម្នាក់ឈ្មោះមាយ ជាមហេសីរបស់ព្រះមហាក្សត្រមុនីវង្ស ក្នុងទសវត្សរ៍ឆ្នាំ១៩៣០ ហើយបងប្រុសគាត់ម្នាក់ទៀតឈ្មោះសាឡុត សួង ជាមន្ត្រីក្នុងការិយាល័យពិធីការរបស់ព្រះបរមរាជវាំង ពិសេស បងស្រីបង្កើតរបស់គាត់ម្នាក់ទៀត ឈ្មោះសាឡុត រឿង ក៏ជាស្នំឯករបស់ព្រះមហាក្សត្រមុនីវង្ស ផង

ដែរ។


ជួន ប្រាសិទ្ធ

ក្រោយពីព្រឹត្តិបត្ររបស់សមាគមនិស្សិត ខ្មែរ នៅប្រទេសបារាំង បានចេញផ្សាយអត្ថបទវិភាគរបស់សាឡុត ស ដោយប្រើរហស្សនាមថា "ខ្មែរដើម" នោះមក ព្រះមហាក្សត្រសីហនុ ពិរោធយ៉ាងខ្លាំង ព្រះអង្គបានត្រាស់បង្គាប់ឱ្យ ប៉ែន នុត ដែលពេលនោះ ជាទីប្រឹក្សារបស់ព្រះអង្គ ធ្វើដំណើរទៅប្រទេសបារាំង ដើម្បីដកហូតអាហារូបករណ៍ពីនិស្សិតទាំងឡាយណា ដែលជាប់ពាក់ព័ន្ធជាមួយអត្ថបទ មានចំណងជើងថា ៖ "រាជាធិបតេយ្យ ឬប្រជាធិបតេយ្យ?" នោះ និងស្រាវជ្រាវរកមុខនិស្សិតទាំងឡាយណាដែលប្រឆាំងនឹងព្រះអង្គផងដែរ។

ពេលនោះ សាឡុត ស, អៀង សារី, សុន សេន, ហ៊ូ យន់, សៀង អាន, រ័ត្ន សាមឿន, ម៉ី ម៉ាន់, យន់ សឿង និងជួន ប្រាសិទ្ធ ត្រូវបានដកហូតអាហារូបករណ៍ ដោយសារអ្នកខ្លះជាប់ពាក់ព័ន្ធជាមួយអត្ថបទមានចំណងជើងថា ៖ " រាជាធិបតេយ្យ ឬប្រជាធិបតេយ្យ?" និងអ្នកខ្លះទៀត ពាក់ព័ន្ធពីការធ្វើសកម្មភាពប្រឆាំងរបបរាជានិយម ប្រឆាំងនឹងព្រះមហាក្សត្រសីហនុ។ ក្រោយពីព្រះមហាក្សត្រសីហនុ ដកហូតអាហារូបករណ៍មក ធ្វើឱ្យនិស្សិតទាំងនោះជួបការលំបាកខ្វះខាតក្នុងជីវភាពរស់នៅជាខ្លាំង ដោយពេលខ្លះ ពួកគេត្រូវបង្ខំចិត្តខ្ចីប្រាក់កាសពីអ្នកដទៃ ពេលខ្លះត្រូវបង្ខំចិត្តរកការងារកំប៉ិកកំប៉ុកធ្វើ ដើម្បីបានប្រាក់ គ្រាន់នឹងចាយវាយ។

ដោយឡែក ជួន ប្រាសិទ្ធ ដែលទទួលបានអាហារូបករណ៍ពាក់កណ្តាល មិនចោទជាបញ្ហាអ្វីប៉ុន្មានទេ ព្រោះក្រុមគ្រួសាររបស់គាត់ជាត្រកូលអភិជន អាចផ្តល់ប្រាក់កាសឱ្យ

គាត់នៅបន្តការសិក្សាជាមួយបងៗរបស់គាត់ គឺ ជួន ជឿន, ជួន ជុំ និងជួន មុម្ម បន្តទៀត។

ចំណែក កេង វ៉ាន់សាក់ បានរួចផុតពីការផ្តាច់អាហារូបករណ៍នោះ ដោយសារគាត់ជាប់ខ្សែរលោហិតរាជវង្សជាមួយម្ចាស់ក្សត្រីនរោត្តម ប៉ែងប៉ោះយុគន្ធរ ជារដ្ឋមន្ត្រីអប់រំ កីឡា និងយុវជន។

ទោះបីយ៉ាងនេះក៏ដោយ កេង វ៉ាន់សាក់ ត្រូវគេបង្ខំឱ្យវិលត្រលប់មកប្រទេសវិញ មុនពេលគាត់ត្រូវបញ្ចប់និក្ខេបបទដើម្បីយកសញ្ញាបត្រដែរ។

ពេលនោះ សាឡុត ស ក៏ដូចជា សៀង អាន, រ័ត្ន សាមឿន, ម៉ី ម៉ាន់ និងយន់ សឿង ក៏មិនចង់រស់នៅក្នុងប្រទេសបារាំង បន្តទៀតដែរ ។ ផ្ទុយទៅវិញ ពួកគាត់មានចិត្តអន្ទះសាចង់វិលត្រលប់មកមាតុប្រទេសវិញ ដើម្បីចូលរួមក្នុងចលនាតស៊ូជាមួយពួកខ្មែរឥស្សរៈកុម្មុយ-និស្ត ជាសម្ព័ន្ធមិត្តរបស់ពួកវៀតមិញ ផងដែរ។

ក្រោយពីព្រះមហាក្សត្រសីហនុ ឱ្យប៉ែន នុត ទៅដកហូតអាហារូបករណ៍មក នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៥២ សាឡុត ស, យុន សឿន និងរ័ត្ន សាមឿន ជាដើម បានចាកចេញពីក្រុងប៉ារីស ទៅកាន់កំពង់ផែក្រុងម៉ារសេ ជាមួយនិស្សិតខ្មែរ មួយចំនួនទៀត ដែលត្រូវដកហូតអាហារូបករណ៍ដែរនោះ ដើម្បីឡើងនាវាចម្បាំងមួយ ឈ្មោះហ្សាម៉ាអ៊ិច ដែលត្រូវចេញដំណើរទៅទីក្រុងព្រៃនគរ (ក្រុងសៃហ្គន) ដោយត្រូវឆ្លងកាត់មហាសមុទ្រឥណ្ឌា អស់រយៈពេលប្រហែល១ខែ ទើបមកដល់កំពង់ផែក្រុងព្រៃនគរ រួចពួកគាត់បានបន្តដំណើរមកក្រុងភ្នំពេញបន្តទៀត។

ចំណែកនិស្សិតមួយចំនួន ដូចជា អៀង សារី, ហ៊ូ យន់ និងសុន សេន ជាដើម បានសម្រេចបន្តការសិក្សានៅប្រទេសបារាំង តទៅទៀត។

ក្រោយពីបានចំណាយពេលវេលាសិក្សាអស់រយៈពេលជាង៣ឆ្នាំ នៅប្រទេសបារាំង សាឡុត ស បានវិលត្រលប់ទៅប្រទេសកម្ពុជា វិញ ដោយគ្មានទទួលបានសញ្ញាបត្រអ្វីសូម្បីតែមួយសន្លឹក ក្រៅតែពីលទ្ធិកុម្មុយនិស្ត ណែនពេញក្នុងខួរក្បាលគាត់នោះឡើយ។

ពេលមកដល់ទីក្រុងភ្នំពេញ គាត់បានស្នាក់នៅផ្ទះបងប្រុសរបស់គាត់ឈ្មោះសាឡុត

សួង ដែលជាមន្ត្រីបម្រើការងារនៅក្នុងព្រះ-បរមរាជវាំង។

ក្រោយស្នាក់នៅផ្ទះបងប្រុសនោះ បានប្រហែលមួយខែ គាត់បានចាកចេញពីក្រុង ភ្នំពេញ បាត់មួយរយៈ។

លុះត្រលប់មកវិញ គាត់បាននិយាយប្រាប់សាឡុត សួង ជាបងប្រុសថា រយៈពេលប្រហែលមួយខែនេះ គាត់បានសាក-ល្បងធ្វើដំណើរទៅទាក់ទងមេដឹកនាំចលនាតស៊ូមិនមែន កុម្មុយនិស្ត ២ក្រុម គឺក្រុមទ្រង់ចន្ទរង្សី ដែលនៅក្នុងខេត្តកំពង់ស្ពឺ និងក្រុមសឺង ង៉ុកថាញ់ ដែលនៅក្នុងខេត្តសៀមរាប។



វ័ត្ត សាមឿន

ការពិត សាឡុត ស មានគំនិតលាក់លៀម មិនឱ្យបងប្រុសគាត់ដឹងថា គាត់មាននិន្នាការនយោបាយងប់ងុលទៅខាងកុម្មុយនិស្តនោះឡើយ។ ដូច្នេះហើយ ទើបបានជាគាត់កុតកុហកបងប្រុសថា គាត់បានទៅទាក់ទងទ្រង់ចន្ទរង្សី និងសឺង ង៉ុកថាញ់ ជាមេដឹកនាំចលនាតស៊ូខ្មែរឥស្សរៈ មិនមែនកុម្មុយនិស្ត ទៅវិញ។

នៅខែសីហា ឆ្នាំ១៩៥៣ សាឡុត ស និងមិត្តភក្តិ ២នាក់ទៀត មកពីប្រទេសបារាំងជាមួយគ្នា គឺ វ័ត្ត សាមឿន និងយុន សឿន បានលួចទៅទាក់ទងជាមួយផាំ វ៉ាន់បា ជាតំណាងគណៈចាត់តាំង របស់បក្សកុម្មុយនិស្តឥណ្ឌូចិន ប្រចាំប្រទេសកម្ពុជា កំពុងស្ថិតនៅបញ្ជាការដ្ឋានតស៊ូមួយ នៅភូមិភាគបូព៌ា ដើម្បីចូលរួមក្នុងចលនាតស៊ូឥស្សរៈបក្សប្រជាជនបដិវត្តន៍ខ្មែរ ក្រោមដឹកនាំផ្ទាល់របស់សឺង ង៉ុកមិញ, ទូ សាមុត និងទាមទារឱ្យទទួលស្គាល់ឋានៈពួកគាត់ជាបក្ខជន ផងដែរ។

សាឡុត ស តវ៉ាជាមួយផាំ វ៉ាន់បា ថាៈ កាលនៅប្រទេសបារាំង ពួកគាត់បានចូលជា

បក្ខជនរបស់បក្សកុម្មុយនិស្តបារាំង រួចហើយ ចុះហេតុអ្វីបានជាពេលត្រលប់មកប្រទេសកម្ពុជាវិញ មិនព្រមទទួលស្គាល់ និងផ្ទេរជើវាភាពបក្សរបស់ពួកគាត់ជាបក្ខជន ផង?

ពេលនោះ ផាំ វ៉ាន់បា បានទាក់ទងទៅតំណាងបក្សកុម្មុយនិស្តឥណ្ឌូចិន នៅក្រុងប៉ារីស ដើម្បីសុំការបញ្ជាក់ពីបក្សកុម្មុយនិស្តបារាំង ថា តើសាឡុត ស, ឆ្នែ សាមឿន និងយុន សឿន បានចូលជាបក្ខជនរបស់បក្សកុម្មុយនិស្តបារាំង ពិតប្រាកដមែនឬទេ?

រយៈពេល១៥ថ្ងៃ ក្រោយមក ផាំ វ៉ាន់បា ក៏ទទួលស្គាល់ពួកគាត់ជាបក្ខជនរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ព្រោះបក្សកុម្មុយនិស្តបារាំង បានបញ្ជាក់មកថា ពួកគាត់ពិតជាបានចូលជាបក្ខជនរបស់បក្សកុម្មុយនិស្តបារាំង ពិតប្រាកដមែន។

ក្រោយមក សាឡុត ស ក៏ផ្ទេរពីបក្ខជនរបស់បក្សកុម្មុយនិស្តបារាំង មកជាបក្ខជនរបស់បក្សប្រជាជនបដិវត្តខ្មែរ វិញ ដូចបំណងប្រាថ្នា។

ពួកគាត់ស្នាក់នៅក្នុងមន្ទីរគណៈកម្មាធិការមជ្ឈិមបក្ស លួចលាក់មួយ នៅក្នុងព្រៃក្បែរព្រំដែនវៀតណាម (ខេត្តកំពង់ចាម និងខេត្តតែនិញ)។ នៅទីនោះ កងទ័ពខ្មែរ និងកងទ័ពវៀតមិញ មានចំនួនប្រហាក់ប្រហែលគ្នា។ តែសាឡុត ស មិនដឹងពីរបៀបប្រើប្រាស់អាវុធសូម្បីបន្តិចឡើយ។

តែមេដឹកនាំខ្មែរ និងវៀតណាម នៅទីនោះ មិនបានប្រគល់ភារកិច្ចអ្វី ឱ្យសមស្របតាមចំណេះដឹង ដែលពួកគាត់ទាំង៣នាក់ បានទៅរៀន នៅប្រទេសបារាំង ក្រៅតែពីភារកិច្ចដាំស្ល និងជញ្ជូនដីដាក់រងដាំបន្លែ នោះឡើយ។

៥០
ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ



ព្រះមហាក្សត្រសីហនុ និងប្រធានាធិបតីបារាំង ឌុំងសង់ អូរីយ៉ូល

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ បានរុះរើផ្លាស់ប្តូរគណៈរដ្ឋមន្ត្រីរបស់ព្រះអង្គ ដោយបង្កើតឱ្យមានតំណែងរាជប្រតិភូនាយករដ្ឋមន្ត្រីទីស្តីការរាជរដ្ឋាភិបាល ១រូប និងនាយករដ្ឋមន្ត្រីបម្រុង ១រូប ព្រមទាំងផ្លាស់ប្តូរសមាសភាពគណៈរដ្ឋមន្ត្រីមួយចំនួន។

រាជរដ្ឋាភិបាលថ្មីនោះ ព្រះអង្គនៅតែគង់ជានាយករដ្ឋមន្ត្រី ដដែល និងបានតែងតាំង ប៉ែន នុត ជារាជប្រតិភូនាយករដ្ឋមន្ត្រីទីស្តីការរាជរដ្ឋាភិបាល និងជារដ្ឋមន្ត្រីអប់រំ និងយុវជន, អូ ឈឺន ជានាយករដ្ឋមន្ត្រីបម្រុង - រដ្ឋមន្ត្រីក្រសួងការបរទេស និងធម្មការ, ម្ចាស់ក្សត្រីនរោត្តម ប៉េងប៉ោះយុគន្ធរ ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីសាធារណសិក្សា និងវិចិត្រសិល្បៈ, អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជារដ្ឋមន្ត្រីការពារជាតិ ប្រៃសណីយ៍ និងទូរគមនាគមន៍, តុង អ៊ួនម៉ម ជា

រដ្ឋមន្ត្រីយុត្តិធម៌, ស៊ីម វ៉ា ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងសាធារណការ, ជាញ់ សួង ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ប្រាក់ សារិន ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងស្វ័យការពារ ព្រមទាំង សាមសុង ហ៊ឹណង់ដេស ជារដ្ឋមន្ត្រីសាធារណសុខាភិបាល សង្គមកិច្ច និងការងារ។

ពិសេស ក្រោយពីប្រគល់តំណែងប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ ថ្វាយព្រះបិតានរោត្តម សុរាម្រិត មក នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៥៣ ប៉ែន នុត រាជប្រតិភូនាយករដ្ឋមន្ត្រីទីស្តីការរាជរដ្ឋាភិបាល និងសម សារី បានរៀបចំឯកសារសម្រាប់ការចរចា ស្តីពីបញ្ហាទាមទារឯករាជ្យ រួចរាល់ហើយ ព្រះមហាក្សត្រសីហនុ បានចាកចេញទៅប្រទេសបារាំង ជាបន្ទាន់។

នៅប្រទេសបារាំង ព្រះអង្គគង់នៅកន្លែងមួយ ឈ្មោះឡាណាពូល (La Napoule) នៅក្បែរទីក្រុងកាន ព្រះអង្គបានស្នើសុំឱ្យរដ្ឋាភិបាលបារាំង រំលាយសមាគមនិស្សិតខ្មែរ (AEK) ដែលមានហ៊ូ យន់ ជាប្រធាននោះ ចោល។

បន្ទាប់មក ព្រះអង្គក៏បានធ្វើព្រះរាជសារយ៉ាងវែងមួយ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៣ ផ្ញើទៅជូនប្រធានាធិបតីបារាំង វ៉ុំងសង់ អូរីយ៉ូល ។

ព្រះរាជសារនោះ មានខ្លឹមសារជាអាទិថាៈ " លោកប្រធានាធិបតី! ថ្ងៃនេះ ខ្ញុំសូមផ្ញើសារជូនលោក ដើម្បីស្នើសុំលោកមេត្តាពិនិត្យនូវហេតុការណ៍ និងអំណះអំណាងទាំងឡាយដែលត្រូវបានរាយការណ៍។ បន្ទាប់ពីនេះ អាស្រ័យដោយមានការកែប្រែខ្លះនូវគោលការណ៍ដឹកនាំនយោបាយបច្ចុប្បន្ន របស់ប្រទេសបារាំង ចំពោះប្រទេសកម្ពុជា តាមយោបល់របស់ខ្ញុំពេលនេះ អាចមានច្រកចេញ ដោយគ្មានការប្រយុទ្ធ ដើម្បីធានាអត្ថិភាពនៃឯករាជ្យរបស់ព្រះរាជាណាចក្រកម្ពុជា។

នយោបាយរបស់ប្រទេសបារាំង នៅឥណ្ឌូចិនបច្ចុប្បន្ន គោលដៅសំខាន់ គឺត្រូវយកជ័យជម្នះ ក្នុងការប្រយុទ្ធប្រឆាំងនឹងពួកវៀតមិញ ហើយបញ្ហាដទៃទៀតដែលបានចោទឡើងក៏នឹងអាចដោះស្រាយបាន ដោយងាយស្រួលបង្ហូរដែរ។

ប្រជារាស្ត្រកម្ពុជា ទោះបីជាថ្នាក់ដឹកនាំ ឬក៏រាស្ត្រសាមញ្ញក៏ដោយ មិនអាចគិតតែពីលទ្ធផលនៃយុទ្ធសាស្ត្រដែលទទួលបាននោះទេ តែវាមានកាតព្វកិច្ច ដើម្បីពិចារណានូវ

ធាតុទាំងអស់នៃបញ្ហា ដែលជាចំណុចអត្ថិភាព និងអនាគតរបស់ប្រទេសខ្លួន។ តែគេពិនិត្យ ឃើញថា បញ្ហានេះស្ថិតនៅដដែលទាំងស្រុង ហើយវាមិនត្រឹមតែមិនជឿនលឿនទៅមុខ នោះទេ ផ្ទុយទៅវិញ វាកាន់តែមានសភាពធ្ងន់ធ្ងរទៅៗថែមទៀតផង។

គេដឹងហើយថា នៅឥណ្ឌូចិន ខ្ញុំគឺជាព្រះមហាក្សត្រ ដែលរក្សាទំនាក់ទំនងបានល្អ បំផុត ជាមួយប្រជារាស្ត្ររបស់ខ្លួន ហើយនៅក្នុងអំឡុងដំណើរទស្សនកិច្ចជាញឹកញាប់នៅ ប្រទេសបារាំង ខ្ញុំមិនបានបញ្ឈប់នូវគោលបំណងរបស់ខ្ញុំ ដើម្បីធ្វើឱ្យជនរួមជាតិរបស់ខ្ញុំ មានការទុកចិត្តទៅលើការសន្យាទាំងឡាយរបស់បារាំង ដែលគេមិនអាចបំភ្លេចបាន និង ការធានារបស់ខ្ញុំ ជូនប្រជារាស្ត្រខ្ញុំ ក្នុងការទាមទារឯករាជ្យពេញលេញ និងសន្តិភាព ជូន ប្រទេសជាតិខ្ញុំបានឡើយ។

ការដឹកនាំរបស់រាជរដ្ឋាភិបាលខ្ញុំ ពុំមានទម្ងន់ណាមួយឡើយ ដរាបណាវិស័យតុលាការ យោធា ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច នៅមានការខ្វះចន្លោះប្រហោង មិនទាន់មានស្វ័យភាព ដូច សព្វថ្ងៃនេះ។

លោកប្រធានាធិបតី! ហេតុនេះខ្ញុំមានកាតព្វកិច្ច ដើម្បីជម្រាបជូនលោកដោយខ្លី និងសំខាន់បំផុត នូវការខ្វះចន្លោះប្រហោងទាំងនេះ ហើយខ្ញុំជឿថា បញ្ហានេះត្រូវតែដោះស្រាយ ជូនប្រជារាស្ត្ររបស់ខ្ញុំ ចាប់ពីពេលនេះទៅ។

ដំណោះស្រាយនោះ គឺតម្រូវឱ្យខ្ញុំជាព្រះមហាក្សត្រ និងជាប្រមុខរាជរដ្ឋាភិបាល ជា អ្នកទទួលខុសត្រូវសំខាន់បំផុតនោះគឺ ការផ្ទេរបុព្វសិទ្ធិនានា ដែលរហូតមកដល់បច្ចុប្បន្ន នេះ បារាំង នៅតែរក្សាទុកខ្លួនឯងដដែល។ ដោយហេតុនេះ កាតព្វកិច្ចរបស់ខ្ញុំ គឺត្រូវរក ដំណោះស្រាយដោយខ្លួនឯង តាមគ្រប់មធ្យោបាយទាំងឡាយ ដែលខ្លួនមាន ដើម្បីសម្រេច ឱ្យបានជោគជ័យ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

ការទាមទារ (ឯករាជ្យ) នេះ ជាការចាំបាច់សម្រាប់ខ្ញុំ ហើយខ្ញុំព្រមទទួលយកនូវ ការប្រឈមមុខនឹងបញ្ហានេះ ជាមួយនឹងការជ្រោមជ្រែងពីរដ្ឋាភិបាលរបស់ខ្ញុំ ព្រោះខ្ញុំអាច ទុកចិត្តទៅលើការរួបរួមទាំងស្រុង និងការគាំទ្រដ៏ល្អប្រសើរពីប្រជារាស្ត្រខ្ញុំ។

ម្យ៉ាងទៀត ខ្ញុំជឿថា ប្រជារាស្ត្ររបស់ខ្ញុំនឹងអាចចៀសផុតចំពោះការស្តីបន្ទោស និងការមិលគុណចំពោះប្រទេសបារាំង នៅក្នុងពេលអនាគត។ ប៉ុន្តែបច្ចុប្បន្ននេះ បារាំង នៅតែក្តោបក្តាប់អំណាចភាគច្រើន នៅប្រទេសកម្ពុជា ដើម្បីការពារនូវផលប្រយោជន៍របស់ខ្លួនដដែល គឺមិនខុសពីអ្វីដែលគេគ្រប់គ្នាបាននិយាយថា បារាំង នៅតែអនុវត្តនយោបាយមួយគឺ បែងចែកអំណាច ដើម្បីគ្រប់គ្រង។

តែវាមិនអាចទៅជាដូច្នេះបានទេ ប្រសិនបើព្រះរាជាណាចក្រកម្ពុជា ទទួលឯករាជ្យដោយពិតប្រាកដ និងបានធ្វើជាម្ចាស់នៃជោគវាសនារបស់ខ្លួន ហើយកម្ពុជា នៅតែបន្តទទួលជំនួយដ៏សប្បុរសពីប្រទេសបារាំង ដោយប្រទេសបារាំង គ្មានប្រាថ្នាប្រយោជន៍របស់ខ្លួននោះ។

ជាងនេះទៅទៀត ប្រសិនបើប្រទេសកម្ពុជា អាចលះបង់ចោលនូវជំហរជាធម្មតារបស់ខ្លួន ដែលធ្វើជាអ្នកស្នើសុំចំពោះបារាំង ជានិច្ចនោះ វីរជនទាំងឡាយរបស់គេ នឹងត្រូវបានរួចខ្លួនដោយដាច់ស្រឡះពីភាពថោកទាបដែលបណ្តាលមកពីគ្មានអធិបតេយ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជា នោះ ប្រទេសកម្ពុជា ដែលស្ថិតនៅលើគម្រោងដ៏ឧត្តុង្គឧត្តមមួយ នឹងមិនរួញរាក្នុងការស្នើសុំប្រទេសបារាំង ដើម្បីរក្សាទុកនូវជំនួយរបស់ខ្លួន និងស្នើសុំការយល់ព្រមពីសាធារណរដ្ឋបារាំង ជាមិត្ត នូវឯកសិទ្ធិទាំងឡាយ ដែលត្រូវបានវិនិច្ឆ័យដោយការធ្វើពលីកម្មទាំងឡាយ ចំពោះចិត្តសប្បុរសរបស់ប្រទេសបារាំង និងទំនាក់ទំនងមិត្តភាព ដែលនឹងថែរក្សាឱ្យបានស្ថិតស្ថេរ ជាមួយព្រះរាជាណាចក្រកម្ពុជា។

បញ្ហានេះ នឹងអាចលើសពីធម្មតាទៅទៀត ព្រោះប្រទេសកម្ពុជា ចូលចិត្តវប្បធម៌និងអរិយធម៌នៃប្រទេសបារាំង ដែលបានចង្អុលបង្ហាញពីប្រជារាស្ត្ររបស់ខ្លួន នូវស្លាកស្នាមមួយ ដែលមិនអាចសាបសូន្យទៅបាន និងចូលចិត្តផងដែរ នូវសមត្ថភាពដែលបារាំង មានដើម្បីជួយប្រទេសកម្ពុជា ដោយមិនធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យភាពរបស់ខ្លួននោះ។

ចំពោះប្រជារាស្ត្រខ្ញុំ បើសិនគេច្រានចោលនូវអនាធិបតេយ្យភាព និងស្អប់ខ្ពើមនូវអសន្តិសុខនោះ គឺដោយសារគេមានបំណងចង់បានឯករាជ្យទាំងស្រុង ជាឯកច្ឆន្ទ និងដ៏

ខ្លាំងក្លាបំផុត។ ប្រជារាស្ត្រខ្ញុំគិតថា ជាការល្អប្រសើរណាស់ បើសិនជាពួកគេត្រូវតស៊ូ ដើម្បីថែរក្សារបៀបរៀបរយ និងសន្តិភាពនោះ។ ប៉ុន្តែ តើគេអាចជឿបានទេថា សន្តិភាពនោះ នឹងនាំមកឱ្យយើងជាប្រជារាស្ត្រកម្ពុជា នូវសេចក្តីចម្រុងចម្រើន បើសិនភាពសម្បូរដោយកោតផលធនធានធម្មជាតិ នៅក្នុងប្រទេស មិនមែនជារបស់យើង ក្នុងហានៈយើងជាម្ចាស់ទឹកដីនោះ?

លោកប្រធានាធិបតី! ខ្ញុំសូមបញ្ជាក់បន្ថែមថា ខ្ញុំធ្វើសារនេះ គឺដើម្បីស្នើសុំសាធារណរដ្ឋបារាំង ជាមិត្ត ប្រគល់នូវឯករាជ្យដ៏ទូលំទូលាយ នៅពេលនេះ គឺមិនមែនដោយសារគំនិតប្រជាភិថុតិ ឬក៏ដោយសារផលប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ ព្រោះថា ការស្នើសុំនេះ បានធ្វើឡើងនៅចំពោះមុខជំនាន់មនុស្សជឿនលឿននិយម និងមនុស្សមានគំនិតសាធារណរដ្ឋនិយម ពិសេស គឺនៅចំពោះមុខពួកកុម្មុយនិស្តនោះ របបរាជាធិបតេយ្យ ដែលខ្ញុំជាតំណាង មុខជានឹងបាត់បង់បន្តិចម្តងៗ បន្ទាប់ពីប្រទេសកម្ពុជា ទទួលបាននូវឯករាជ្យបរិបូណ៌ទាំងស្រុងរបស់ខ្លួន។

ប៉ុន្តែក្នុងហានៈខ្ញុំជាតំណាងឱ្យប្រជាជាតិខ្មែរ ហើយត្រូវបានស្នើសុំដោយប្រជាជាតិខ្មែរ ខ្ញុំសូមស្នើសុំឯករាជ្យបរិបូណ៌ ពីប្រទេសបារាំង មកវិញ ហើយសង្ឃឹមថា ប្រជាជាតិបារាំងមិនបានចាត់ទុកការស្នើសុំនេះ ប្រៀបដូចជាការប្រយុទ្ធតស៊ូរំដោះយកឯករាជ្យនោះទេ ហើយខ្ញុំនឹងធ្វើឱ្យគេចូលរួមពេញទំហឹងចំពោះការតស៊ូនេះបាន ក៏ដោយសារប្រទេសបារាំង នឹងចូលរួមធ្វើពលីកម្មដ៏ធំធេង ដោយពុំធ្វើឱ្យខូចអត្ថប្រយោជន៍របស់ខ្លួនដែរ។

ប្រសិនបើប្រជាជាតិបារាំង បដិសេធ មិនគាំទ្រនូវការតស៊ូមួយ ដែលប្រហែលជានឹងមានផលប្រយោជន៍ចំពោះប្រទេសបារាំង និងចំពោះសហភាពបារាំង ផងដែរនោះ វានឹងពុំអាចឈានទៅដល់ការសង្គ្រោះកម្ពុជា បានឡើយ។ ប៉ុន្តែ ប្រសិនបើប្រជាជាតិបារាំង ភ្ជាក់រឭកទទួលយកហេតុផលដូចខាងលើនេះ ប្រជារាស្ត្រខ្ញុំអាចសង្ឃឹមថា នៅពេលខាងមុខមាតុភូមិកម្ពុជា នឹងបានឃើញនូវភាពប្តុំប្តើង រុងរឿង មានសន្តិភាព រួចពីទុក្ខភ័យ ដោយសារទទួលបានឯករាជ្យបរិបូណ៌នេះ។

បន្ទាប់ពីសារនេះ បើសិនជាត្រូវការ ខ្ញុំត្រៀមខ្លួនជាស្រេចហើយ ដើម្បីបញ្ជូនឯកឧត្តម ប៉ែន នុត ជារាជប្រតិភូនាយករដ្ឋមន្ត្រីរបស់ខ្ញុំ ទៅទីក្រុងប៉ារីស ដើម្បីផ្តល់នូវការពន្យល់បន្ថែម ឱ្យកាន់តែច្បាស់នូវបញ្ហាទាំងឡាយ ដែលត្រូវសិក្សាបន្ថែមទៀត។

ជាមួយគ្នានេះដែរ ខ្ញុំក៏បានត្រៀមខ្លួនជាស្រេច ប្រសិនជាលោកប្រធានាធិបតី ចង់ឱ្យរូបខ្ញុំធ្វើដំណើរទៅកាន់ទីក្រុងប៉ារីស ដើម្បីជួបមុខគ្នាផ្ទាល់ "។

៥១
បារាំងថា ការទាមទារឯករាជ្យ មិនសមស្របតាមកាលៈទេសៈ



ហ្សង់ ឡឺ ទួរណូ រដ្ឋមន្ត្រីទទួលបន្ទុកប្រទេសជាសមាជិកសហព័ន្ធបារាំង

(រូបនៅមុខក្បាលមេក្រូ)

ក្រោយពីធ្វើព្រះរាជសារដែលមានខ្លឹមសារដូចខាងលើនេះ អស់រយៈពេលជិត២ សប្តាហ៍ កន្លងផុតទៅ ប្រធានាធិបតីបារាំង វ៉ុំងសង់ អូរីយ៉ូល មិនបានឆ្លើយតបមកវិញ សូម្បីបន្តិចឡើយ ហើយសភាពការណ៍នៅក្នុងប្រទេសកម្ពុជា រឹតតែអាក្រក់ឡើងៗនោះ ព្រះមហាក្សត្រ សីហនុ ក៏បានសម្រេចព្រះទ័យសរសេរព្រះរាជសារទី២ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៣ ធ្វើទៅជូនប្រធានាធិបតីបារាំង រូបនេះ មួយច្បាប់ទៀត។

ព្រះរាជសារទី២នេះ មានខ្លឹមសារសំខាន់ៗជាអាទិថាៈ" លោកប្រធានាធិបតី! ខ្ញុំសូមទាញការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីលោក ចំពោះសភាពការណ៍ដ៏គ្រោះថ្នាក់ ដែលលោកសង្ឃឹមជឿជាក់ ដោយមិនសមហេតុផលថា អ្វីដែលបានប្រព្រឹត្តទៅ នៅក្នុង

ព្រះរាជាណាចក្រកម្ពុជា សុទ្ធតែល្អនោះ គឺយើងកំពុងស្ថិតនៅក្នុងសភាពទាល់ច្រកហើយ។

តែ ខ្ញុំបានរកឃើញច្រកចេញតែមួយគត់ ដែលខ្ញុំអាចធានាថា នឹងសង្គ្រោះសភាពការណ៍ដ៏គ្រោះថ្នាក់នោះ វិញបាន គឺលុះត្រាតែយើងព្រមទទួលយកទាំងអស់គ្នា។ ប៉ុន្តែ ដាច់ខាតវាមានសភាពជាធម្មជាតិតែម្តងនោះ គឺការបើកចំហទុកឱ្យខ្ញុំដឹកនាំប្រទេសដោយខ្លួនឯង ដោយប្រគល់ឱ្យខ្ញុំជាស្ថាពរនូវការទទួលខុសត្រូវសំខាន់ៗ ពិសេសបញ្ហាយោធា ត្រូវតែដោះ-ស្រាយជាមុនសិន ព្រោះវាមានលក្ខណៈចម្បង និងសំខាន់ជាងបញ្ហាដទៃទៀតទាំងអស់ តែបើយើងបណ្តែតបណ្តោយឱ្យមានការយឺតយ៉ាវតែបន្តិចនោះ មុខជាកងជីវពលរបស់ព្រះរាជា-ណាចក្រ ចាប់ផ្តើមធ្វើការតស៊ូ ដោយអាវុធនៅគ្រប់ទិសទីជាមិនខាន។

ពេលនេះ ប្រជារាស្ត្រកម្ពុជា មិនបានដឹងថា ខ្ញុំបានចាកចេញមកក្រៅប្រទេស ដើម្បីដោះស្រាយបញ្ហាឯករាជ្យពីប្រទេសបារាំង នោះទេ ហើយអ្នកខ្លះទំនងជាមានការគិតថា ខ្ញុំទៅដើរលេងសប្បាយតាមឆ្នេរសមុទ្រ នៅប្រទេសបារាំង ខណៈដែលទាហានរបស់ខ្ញុំត្រូវស្លាប់ ដោយការប្រយុទ្ធគ្នាជាមួយពួកវៀតមិញ នៅក្នុងប្រទេស។

ខ្ញុំសូមស្នើយ៉ាងទទូច ចំពោះលោកប្រធានាធិបតី និងចំពោះរដ្ឋាភិបាលនៃសាធា-រណរដ្ឋបារាំង សូមចេញសេចក្តីសម្រេចជាបន្ទាន់បំផុតមួយ ដើម្បីឱ្យរួចផុតពីភាពទាល់ច្រកនេះ និងចៀសវាង កុំឱ្យមានផលវិបាកដ៏ធ្ងន់ធ្ងរបំផុតនោះ កើតឡើងជាថ្មីម្តងទៀត។

សូមលោកប្រធានាធិបតី ទទួលនូវសេចក្តីរាប់អាន ដ៏ជ្រាលជ្រៅពីខ្ញុំ "។

មួយថ្ងៃក្រោយមក ព្រះមហាក្សត្រសីហនុ ក៏បានទទួលលិខិតឆ្លើយតបមួយចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៥៣ ពីប្រធានាធិបតីបារាំង ភូ៉ងសង់ អូរីយ៉ូល។

លិខិតឆ្លើយតបនោះ មានខ្លឹមសារថា " សម្តេច! ទូលបង្គំបានទទួលរួចហើយ នូវព្រះរាជសាររបស់ព្រះអង្គ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៣ និងមួយទៀត ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៣។

ទូលបង្គំ បានអានដោយយកចិត្តទុកដាក់បំផុត ហើយទូលបង្គំបានបញ្ជូនព្រះរាជសារ នេះទៅឱ្យរដ្ឋាភិបាល របស់ទូលបង្គំ ពិនិត្យសិក្សាលើខ្លឹមសារ នៃព្រះរាជសារនោះ ដោយ

ផ្ទៃតផ្ដង់ពីបញ្ហានេះ។

ជាមួយគ្នានេះ ទូលបង្គំមានសេចក្ដីរីករាយ សូមយាងព្រះអង្គមកសោយក្រយាថ្ងៃត្រង់ជាមួយគ្នា នៅវិមានអេលីហ្សេ នៅវេលាម៉ោង១១ ថ្ងៃទី២៥ ខែមីនា ផងដែរ។

សូមសម្ដេចទទួលនូវការស្រលាញ់រាប់អានដ៏ជ្រាលជ្រៅ និងមិត្តភាពដ៏ស្មោះស្ម័គ្រ ពីទូលបង្គំ "។

នៅវេលាថ្ងៃត្រង់ ទី២៥ ខែមីនា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ ក៏បានយាងទៅសោយព្រះក្រយា ជាមួយប្រធានាធិបតីបារាំង វ៉ុងសង់ អូរីយ៉ូល តាមកម្មវិធីដែលបានគ្រោងទុក។

ពេលសោយក្រយានោះដែរ ព្រះអង្គបានឆ្លៀតឱកាសពិភាក្សាគ្នាពីបញ្ហាទាមទារឯករាជ្យនេះ ជាមួយប្រធានាធិបតីបារាំង ដែរ តែពុំទទួលបានលទ្ធផលអ្វីបន្តិចឡើយ។

បន្ទាប់មក ព្រះអង្គក៏បានប្ដូរកន្លែងគង់នៅពីឡាណាពូល (La Napoule) នៅក្បែរទីក្រុងកាន នោះ ទៅគង់នៅក្រុងហ្វុងតែនប្លូ (Fontainebleau) ដែលមានចម្ងាយប្រមាណ ៥៥គីឡូម៉ែត្រ ពីក្រុងប៉ារីស វិញ។

ក្រោយពេលមកដល់ហ្វុងតែនប្លូ (Fontainebleau) ព្រះអង្គបានផ្ញើព្រះរាជសារមួយច្បាប់ទៀត ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៥៣ ទៅជូនប្រធានាធិបតីវ៉ុងសង់ អូរីយ៉ូល ដើម្បីទាមទារស្វ័យភាពខាងតុលាការ ដោយសង្ឃឹមថា ប្រធានាធិបតីបារាំងរូបនេះ នឹងយល់ព្រមចរចាជាមួយព្រះអង្គ ពីបញ្ហាតុលាការនេះ ជាមិនខាន។ តែប្រធានាធិបតីបារាំង វ៉ុងសង់ អូរីយ៉ូល មិនបានឆ្លើយតបអ្វីសូម្បីបន្តិចដដែល។

នៅទីបំផុត នៅក្នុងសណ្ឋាគារដឺគ្រីយ៉ុង ព្រះអង្គបានត្រឹមតែជួបសន្ទនាជាមួយរដ្ឋមន្ត្រីទទួលបន្ទុកប្រទេសជាសមាជិកសហព័ន្ធបារាំង ហ្សង់ ឡឺ ទួរណូ (Jean Le Tourneau) ដែលទើបតែត្រូវបានតែងតាំងឱ្យទៅបំពេញតួនាទីជាអគ្គស្នងការបារាំងប្រចាំនៅឥណ្ឌូចិន នៅថ្ងៃ២៧ ខែមេសា ខាងមុខនោះ ប៉ុណ្ណោះ។

ពេលនោះ ហ្សង់ ឡឺ ទួរណូ (Jean Le Tourneau) បានទូលព្រះអង្គថា ការដែល

ព្រះអង្គទាមទារចង់បានឯករាជ្យបរិបូណ៌នេះ គឺចំកាល:ទេស:មិនសូវល្អចំពោះប្រទេសបារាំង ក៏ដូចជាប្រទេសកម្ពុជា ខ្លួនឯងផងដែរ ព្រោះពេលនោះ កងទ័ពបារាំង នៅក្នុងប្រទេសកម្ពុជា កំពុងតែប្រយុទ្ធទប់ទល់ជាមួយកងទ័ពវៀតមិញ។ ចុះបើកងទ័ពបារាំង ត្រូវដកចេញពីកម្ពុជា អស់នោះ តើប្រទេសកម្ពុជា មានសមត្ថភាពអ្វីអាចទប់ទល់ជាមួយពួកវៀតមិញ ដែលកំពុងមានកម្លាំងខ្លាំងក្លា និងមានការគាំទ្រពីមហាអំណាចកុម្មុយនិស្ត ផងនោះ?

ហ្សង់ ឡឺ ទួរណូ (Jean Le Tourneau) បានទូលព្រះអង្គថា សំណើរបស់ព្រះអង្គទាំងប៉ុន្មាន គឺមិនសមស្របតាមកាល:ទេស:ទេ ហើយការលំបាកទាំងឡាយ ដែលព្រះអង្គបានសរសេរក្នុងព្រះរាជសារទាំងអស់នោះ នឹងត្រូវបាត់ទៅវិញ ក៏អាស្រ័យលើព្រះអង្គដែរ។

ព្រះអង្គតបវិញថា ក្នុងកាល:ទេស:បច្ចុប្បន្ននេះ ផលប្រយោជន៍របស់ប្រជារាស្ត្រខ្មែរ ក៏ដូចជាផលប្រយោជន៍របស់សមាគមបារាំង-ខ្មែរ ដែរ គឺតម្រូវឱ្យប្រទេសកម្ពុជា ពង្រីកឯករាជ្យរបស់ខ្លួនជាបន្ទាន់ និងដាច់ខាតបំផុត។

ហ្សង់ ឡឺ ទួរណូ បានណែនាំព្រះអង្គថា ព្រះអង្គគ្រាន់តែធ្វើយ៉ាងណា ឱ្យប្រជារាស្ត្ររបស់ព្រះអង្គយល់ពីហេតុផលនេះឱ្យច្បាស់លាស់ទៅ ប្រជារាស្ត្ររបស់ព្រះអង្គនឹងធ្វើតាមព្រះអង្គ ជាមិនខាន។

តែព្រះមហាក្សត្រសីហនុ បានលើកហេតុផលតបទៅហ្សង់ ឡឺ ទួរណូ វិញថា ប្រជា-រាស្ត្ររបស់ព្រះអង្គ អាចធ្វើតាមព្រះអង្គបាន តែនៅពេលណាព្រះអង្គស្មោះត្រង់នឹងផល-ប្រយោជន៍ប្រទេសជាតិរបស់ពួកគេ តែប៉ុណ្ណោះ។

ពេលវេលាចេះតែកន្លងផុតទៅ ព្រះមហាក្សត្រសីហនុ គ្មានសង្ឃឹមថា រដ្ឋាភិបាលបារាំង យកសំណុំឯកសារនៃការស្វែងរកការចរចាស្តីពីបញ្ហាឯករាជ្យរបស់ព្រះអង្គ ទៅពិនិត្យសិក្សាអ្វីនោះឡើយ។

ដូច្នេះព្រះអង្គគ្មានវិធីអ្វី ក្រៅតែពីសម្រេចព្រះទ័យធ្វើយុទ្ធនាការឃោសនា នៅលើឆាកអន្តរជាតិ ដើម្បីឱ្យពិភពលោកបានដឹងពីបំណងប្រាថ្នារបស់ព្រះអង្គ ក៏ដូចជាបំណង

ប្រាថ្នារបស់ប្រជារាស្ត្រខ្មែរទាំងមូល ដែលកំពុងអន្ទះសាចង់បានឯករាជ្យ មកវិញនោះឡើយ ហើយសង្ឃឹមថា រដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងជួយធ្វើអន្តរាគមន៍ក្នុងការជំរុញឱ្យប្រទេសបារាំង ជាសម្ព័ន្ធមិត្តរបស់ខ្លួន ប្រគល់ឯករាជ្យមកកម្ពុជា ជាមិនខាន។


ដោយបានដឹងថា ព្រះមហាក្សត្រខ្មែរ មានគម្រោងយាងចេញពីប្រទេសបារាំង ឆ្ពោះទៅកាន់សហរដ្ឋអាមេរិក បន្តទៀតនោះ ហ្សង់ ឡឺ ទួរណូ (Jean Le Tourneau) ដែលទើបតែទទួលការតែងតាំងឱ្យទៅបំពេញតួនាទីជាអគ្គស្នងការបារាំង ប្រចាំឥណ្ឌូចិន ក៏បានកោះហៅតំណាងរបស់ប្រទេសកម្ពុជា ប្រចាំក្រុងប៉ារីស គឺព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉ែត ឱ្យទៅជួបនៅក្នុងការិយាល័យរបស់គាត់ ដើម្បីស្វាបស្វង់ចង់ដឹងថា តើព្រះមហាក្សត្រសីហនុយាងទៅសហរដ្ឋអាមេរិក ក្នុងគោលបំណងអ្វី?

ពេលនោះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉ែត ប្រាប់តាមត្រង់ថា ទ្រង់ក៏មិនបានដឹងថា ព្រះមហាក្សត្រសីហនុ យាងទៅសហរដ្ឋអាមេរិក នោះ ក្នុងគោលបំណងអ្វី សូម្បីបន្តិចឡើយ។

ក្រោយពីជួបពិភាក្សាគ្នា អស់រយៈពេលប្រហែល៣ម៉ោង ហ្សង់ ឡឺ ទួរណូ បានស្នើសុំឱ្យព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉ែត ពាំនាំនូវការថ្វាយព្រះពររបស់គាត់ ដល់ព្រះមហាក្សត្រសីហនុ សូមមានសុវត្ថិភាពក្នុងការធ្វើដំណើរយាងទៅសហរដ្ឋអាមេរិក នោះផងដែរ។ តែហ្សង់ ឡឺ ទួរណូ ក៏បានធ្វើការព្រមានផ្តាំផ្ញើទៅព្រះមហាក្សត្រសីហនុ ថា មុននឹងធ្វើអ្វីមួយ សូមឱ្យព្រះអង្គមានការប្រុងប្រយ័ត្ន និងគិតគូរពិចារណាឱ្យបានល្អិតល្អន់ ពីព្រោះរឿងនេះ វាពាក់ព័ន្ធនឹងការគ្រងរាជសម្បត្តិរបស់ព្រះអង្គ ។

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៥៣ ព្រះអង្គបានផ្ញើសារទូរលេខមួយ ពីប្រទេសបារាំង ទៅថ្វាយព្រះបិតា និងព្រះមាតាជាទីស្រលាញ់ដ៏ជ្រាលជ្រៅ ឱ្យបានដឹងថា នៅថ្ងៃស្អែក (១០ ខែមេសា) ព្រះអង្គនឹងយាងទៅប្រទេសកាណាដា និងបានសម្តែងនូវការទុកព្រះទ័យទាំងស្រុងលើព្រះបិតា និងព្រះមាតា ជាក្រុមប្រឹក្សារាជានុសិទ្ធិ និងរាជរដ្ឋាភិបាល ក្នុងការរ៉ាប់រងនូវស្ថានភាពសុខសាន្តរបស់ប្រទេសជាតិ ឱ្យបានល្អប្រសើរ។

៥២
បើបារាំង មិននៅជួយការពារ កម្ពុជា នឹងធ្លាក់ទៅក្នុងកណ្តាប់ដៃពួកកុម្មុយនិស្ត



ទាហានបារាំង នៅបន្ទាយកំពង់ត្រាច ខេត្តកំពត

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ បានយាងចាកចេញពីប្រទេសបារាំង ទៅដល់ប្រទេសកាណាដា ។ នៅទីក្រុងម៉ុងរ៉េអាល់ ព្រះអង្គឈ្វេងយល់ថា កាណាដា ជាប្រទេសកូមិផងរបងជាមួយសហរដ្ឋអាមេរិក ពិសេសពលរដ្ឋនៅខេត្តកេបិច (Quebec) មានចិត្តគំនិតដូចពលរដ្ឋបារាំង ដែរនោះ ប្រាកដជាមិនអាចធ្វើព្រងើយកន្តើយចំពោះបញ្ហាឧបទ្វីបឥណ្ឌូចិន ដែលកំពុងរងការគំរាមកំហែងពីពួកកុម្មុយនិស្តផង និងកំពុងធ្វើការតស៊ូ ដើម្បីឯករាជ្យរបស់ខ្លួនផងនោះឡើយ។

ដំបូង ព្រះអង្គចាប់ផ្តើមធ្វើឱ្យសារព័ត៌មានទាំងឡាយ នៅទីក្រុងម៉ុងរ៉េអាល់ ចាប់អារម្មណ៍ និងចុះផ្សាយពីព័ត៌មានពាក់ព័ន្ធដល់រឿងប្រទេសកម្ពុជា កំពុងទាមទារឯករាជ្យពីបារាំង នោះ។

ជាមួយការផ្សព្វផ្សាយបទសម្ភាស នៅលើទំព័រសារព័ត៌មាននានា ព្រះអង្គក៏ត្រូវបានវិទ្យុកាណាដា ធ្វើសម្ភាសផងដែរ។

ពេលបុគ្គលិកវិទ្យុកាណាដា ចោទសួរថា តើបញ្ហាអ្វី ដែលជាបញ្ហាចម្បង និងសំខាន់ជាងគេ នៅក្នុងប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ? ព្រះអង្គមានបន្ទូលថា បញ្ហាចម្បង និងសំខាន់ជាងគេ នៅក្នុងប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ គឺបញ្ហាសន្តិសុខកាន់តែធ្លាក់ដុនដាបទៅៗ ដោយសារសេកម្មភាពរបស់កងទ័ពវៀតមិញ និងខ្មែរឥស្សរៈ ហើយការយោសនារបស់ពួកគេពីការរំដោះជាតិ និងទាមទារឯករាជ្យ ពីបារាំងនោះ គឺកាន់តែមានឥទ្ធិពលទៅលើប្រជារាស្ត្រខ្មែរខ្លាំងឡើងៗ។ ប៉ុន្តែ កន្លងមក កងទ័ពព្រះអង្គខិតខំពុះពារការពារប្រជារាស្ត្រឱ្យបានល្អប្រសើរ ហើយក៏បានប្រឹងប្រែងយោសនាពីបញ្ហានយោបាយឱ្យប្រជារាស្ត្រខ្មែរ យល់ច្បាស់ថា ការប្រយុទ្ធ ដើម្បីរំដោះជាតិ និងដើម្បីទាមទារឯករាជ្យរបស់ពួកវៀតមិញ និងខ្មែរឥស្សរៈនោះ គឺគ្រាន់តែជាល្បិចកលនៃការយោសនាបោកប្រាស់របស់ពួកគេ តែប៉ុណ្ណោះ។

វិទ្យុកាណាដា បានទូលសួរព្រះអង្គថា តើបញ្ហាកុម្មុយនិស្តនៅក្នុងកម្ពុជា មានសភាពធ្ងន់ធ្ងរ ដូចនៅក្នុងប្រទេសវៀតណាម ឬទេ?

ព្រះអង្គមានបន្ទូលតបវិញថា ចំពោះលទ្ធិកុម្មុយនិស្ត នៅកម្ពុជា ប្រជារាស្ត្រខ្មែរមិនសូវយកចិត្តទុកដាក់ប៉ុន្មានទេ ព្រោះលទ្ធិនេះ វាផ្ទុយនឹងប្រពៃណី វប្បធម៌ និងសាសនារបស់ពួកគេ ដែលជាទូទៅសុទ្ធតែជាពុទ្ធសាសនិក និងសុទ្ធតែជាប្រជាកសិករ មានដីធ្លីស្រែចម្ការរៀងៗខ្លួន ដូច្នេះពួកគេមិនសូវមានជំនឿលើលទ្ធិកុម្មុយនិស្ត ប៉ុន្មានទេ។ ប៉ុន្តែអ្វីដែលប្រជារាស្ត្រខ្មែរយកចិត្តទុកដាក់បំផុត គឺឆន្ទៈទាមទារឯករាជ្យ ដែលកំពុងពុះកញ្ជ្រោលនោះ ត្រូវបានគេរាំងខ្ទប់។

ក្រោយពីព្រះអង្គធ្វើសកម្មភាពយោសនានយោបាយតាមប្រព័ន្ធផ្សព្វផ្សាយ នៅក្នុងប្រទេសកាណាដា មួយរយៈខ្លីមក ព្រះអង្គបន្តព្រះរាជដំណើរយាងទៅសហរដ្ឋអាមេរិក ទៀត។

នៅទីក្រុងវ៉ាស៊ីងតោន ព្រះអង្គមិនបានទទួលការលើកទឹកចិត្តពីរដ្ឋាភិបាលអាមេរិក

ដូចការរំពឹងទុករបស់ព្រះអង្គ សូម្បីបន្តិចទាល់តែសោះ។

ប្រធានាធិបតីអាមេរិក ដ្វៃត៍ ឌី. អៃសិនហាវើរ (Dwight D. Eisenhower) មិនអនុញ្ញាតឱ្យព្រះអង្គចូលជួបឡើយ។ ប៉ុន្តែយ៉ាងណា ក៏មានសារព័ត៌មានអាមេរិក ជាច្រើនបានចុះផ្សាយព្រោងព្រាតពីព្រះរាជវត្តមាន និងគោលបំណងនៃការទាមទារឯករាជ្យរបស់ព្រះអង្គ ។ បន្ទាប់មក ព្រះអង្គក៏មានឱកាសជួបពិភាក្សាជាមួយរដ្ឋមន្ត្រីការបរទេសអាមេរិក ហ្វូស្ទ័រ ឌុលេ្លស (Foster Dulles) ផងដែរ។

ពេលនោះ ព្រះមហាក្សត្រសីហនុ សង្កេតឃើញច្បាស់ថា គោលជំហររបស់សហរដ្ឋអាមេរិក បានបង្កប់នូវគោលជំហរពីរ ខុសស្រឡះពីគ្នា ព្រោះរដ្ឋមន្ត្រីការបរទេសអាមេរិក ហ្វូស្ទ័រ ឌុលេ្លស (Foster Dulles) យល់ស្របតាមព្រះមហាក្សត្រសីហនុ ដែលថា ប្រទេសបារាំង គួរតែប្រគល់ឯករាជ្យទៅឱ្យប្រទេសកម្ពុជា វិញ ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះដែរ។ ប៉ុន្តែអ្វីដែលគាត់មិនយល់ស្របតាមព្រះមហាក្សត្រសីហនុ នោះ គឺក្រោយពេលទទួលបានឯករាជ្យហើយនោះ ប្រទេសកម្ពុជា មិនអាចមានសមត្ថភាពក្នុងការបង្ក្រាបចលនាតស៊ូរបស់ពួកកុម្មុយនិស្ត បានឡើយ។

ប្រមុខការទូតអាមេរិក រូបនេះ បានទូលព្រះមហាក្សត្រសីហនុ ថា ជនរួមជាតិរបស់គាត់ ដែលតែងតែគាំទ្រដល់ចលនារំដោះជាតិនានា ពីពួកអាណានិគមនោះ បានយល់ច្បាស់ពីបំណងប្រាថ្នាដ៏ត្រឹមត្រូវរបស់ព្រះអង្គ។ ប៉ុន្តែ នៅពេលណា ការគំរាមកំហែងរបស់ពួកកុម្មុយនិស្ត ត្រូវបានបញ្ចៀសចេញពីកម្ពុជា ហើយនោះ សហរដ្ឋអាមេរិក នឹងធ្វើអ្វីៗគ្រប់យ៉ាង តាមដែលអាចធ្វើបាន ដើម្បីជំរុញឱ្យប្រទេសបារាំង ព្រមប្រគល់ឯករាជ្យពេញលេញ ឱ្យកម្ពុជា វិញ។

តែពេលនេះ កំពុងមានសង្គ្រាម ដូច្នេះកម្ពុជា ត្រូវតែដណ្តើមជ័យជម្នះលើពួកកុម្មុយនិស្ត ឱ្យបានជាមុនសិន។ ដូច្នេះបើកម្ពុជា មិនព្រមសហការជាមួយបារាំងទេ បានន័យថា កម្ពុជាកំពុងជួយផ្តល់ជំនួយសំខាន់មួយ ដល់ពួកកុម្មុយនិស្ត ដោយមិនដឹងខ្លួន...។

រដ្ឋមន្ត្រីការបរទេសអាមេរិក ហ្វូស្ទ័រ ឌុលេ្លស (Foster Dulles) សង្កត់ធ្ងន់ថា



ប្រធានាធិបតី និងរដ្ឋមន្ត្រីការបរទេសអាមេរិក

ពេលនេះ កម្ពុជា មិនអាចដឹកនាំគ្រប់គ្រងប្រទេស ដោយខ្លួនឯង ជំនួសបារាំងបានទេ ពិសេស វិស័យកងទ័ព បើគ្មានវត្តមានកងទ័ពបារាំង ជាជំនួយនៅលើសមរភូមិនោះទេ កម្ពុជា នឹងធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកកុម្មុយនិស្តយ៉ាងឆាប់រហ័សបំផុត ជាមិនខាន ហើយ ឯករាជ្យ ដែលព្រះអង្គចង់បាននោះ ក៏នឹងត្រូវរលាយរលត់ដែរ។

ទីបំផុត រដ្ឋមន្ត្រីការបរទេសអាមេរិក ហ្វូស្ទ័រ ឌុលេស (Foster Dulles) សំណូមពរ ឱ្យព្រះអង្គព្យាយាមអត់ធ្មត់មួយរយៈបន្តទៀតសិន។

ព្រះមហាក្សត្រសីហនុ ចាត់ទុកឯករាជ្យ ប្រៀបដូចជាសត្វគោ ដែលអាចអូសទេះ មួយមានផ្ទុកដោយការធ្វើឱ្យមានសន្តិភាព និងជោគជ័យ ក្នុងការទប់ទល់ជាមួយពួកវៀតមិញ និងលទ្ធិកុម្មុយនិស្ត ផងដែរ។ តែសម្រាប់រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក យល់ឃើញថា សត្វគោនោះ គឺគ្មានអ្វី ក្រៅតែពីកងទ័ពបារាំង សម្ភារសឹក និងប្រាក់កាសរបស់អាមេរិក

ដែលធ្វើឱ្យមានសន្តិភាព និងជោគជ័យ ក្នុងការទប់ទល់ជាមួយពួកវៀតមិញ និងលទ្ធិកុម្មុយ-និស្ត នោះឡើយ។

ជាធម្មតា ក្នុងការទឹមរទេះ គេត្រូវដាក់គោនៅខាងមុខរទេះ តែពេលនោះ ក្នុងចំណោមមនុស្ស២នាក់ គឺព្រះមហាក្សត្រសីហនុ ជាមួយរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក មានម្នាក់ចង់យករទេះទៅដាក់ទឹម ពីខាងមុខគោ ទៅវិញ។

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ បានរាជានុញ្ញាតឱ្យអ្នកកាសែត "ញូវយ៉កថៃមស៍" ឈ្មោះ ម៉ៃឃើល ជេមដ៍ ចូលជួបធ្វើសម្ភាស នៅទីក្រុងញូវយ៉ក។

ស្អែកឡើង កាសែត "ញូវយ៉កថៃមស៍" (The New Yok Times) បានចេញផ្សាយនូវខ្លឹមសារនៃបទសម្ភាសនោះ ទាំងស្រុង ហើយអ្វីៗដែលព្រះអង្គមានបន្ទូល នៅក្នុងបទ-សម្ភាសនោះ បានជះឥទ្ធិពលកក្រើកដល់សាធារណមតិរបស់សហរដ្ឋអាមេរិក និងសាកល-លោក។

កាសែត "ញូវយ៉កថៃមស៍" បានដកស្រង់បន្ទូលរបស់ព្រះអង្គថា ប្រសិនបើបារាំង នៅតែមិនព្រមប្រគល់ឯករាជ្យពេញលេញ ឱ្យមកប្រទេសរបស់ព្រះអង្គ ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះទេ គ្រោះថ្នាក់មួយ នឹងត្រូវតែកើតមានឡើងយ៉ាងពិតប្រាកដ ដោយសារតែប្រជារាស្ត្ររបស់ព្រះអង្គ នឹងនាំគ្នាក្រោកឡើង ប្រឆាំងនឹងរបបគ្រប់គ្រងរបស់ព្រះអង្គ ហើយពួកគេនឹងនាំគ្នាទៅចូលរួមជាមួយចលនាតស៊ូឥស្សរៈខ្មែរ-វៀតមិញ ដែលដឹកនាំដោយពួកកុម្មុយនិស្ត ដើម្បីប្រយុទ្ធប្រឆាំងជាមួយពួកបារាំង ជាមិនខាន។

ព្រះអង្គមានបន្ទូលបញ្ជាក់ប្រាប់កាសែត "ញូវយ៉កថៃមស៍" ថា ការទាមទារឯករាជ្យមួយដែលមានលក្ខណៈពេញលេញនេះ គឺជាការឆ្លើយតបទៅនឹងសន្ធិសញ្ញាខ្មែរ-បារាំង ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ ដែលបារាំង ចាត់ទុកប្រទេសកម្ពុជា ជារដ្ឋឯករាជ្យមួយ ក្នុងក្របខ័ណ្ឌសមាជិកនៃសហព័ន្ធបារាំង ដូចគ្នានឹងប្រទេសប៉ាគីស្ថាន និងប្រទេសឥណ្ឌា ដែលនៅក្នុងក្របខ័ណ្ឌខុមមិនវែល (Commmenwealth) របស់ប្រទេសអង់គ្លេស ដែរ ពិសេស នៅពេលព្រះអង្គឡាយព្រះហស្តលេខាលើសន្ធិសញ្ញាខ្មែរ-បារាំង នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩

នោះ ព្រះអង្គបានថ្លែងប្រកាសប្រាប់ប្រជារាស្ត្ររបស់ព្រះអង្គថា យោងតាមសន្ធិសញ្ញានេះ ប្រទេសកម្ពុជា នឹងទទួលបានឯករាជ្យពេញលេញ យ៉ាងពិតប្រាកដ។

កាសែត "ញូវយ៉កថៃមស៍" បានដកស្រង់បន្ទូលរបស់ព្រះអង្គបន្តទៀតថា ព្រះអង្គជាអ្នកទទួលខុសត្រូវ ក្នុងការដាក់បញ្ចូលប្រទេសកម្ពុជា ឱ្យទៅជាសមាជិកសហព័ន្ធបារាំង ដូច្នេះបើព្រះអង្គមិនបានធ្វើអ្វីៗ តាមការសន្យារបស់ព្រះអង្គទេនោះ ប្រជារាស្ត្រខ្មែរត្រូវតែកាត់ទោសព្រះអង្គ ទើបមានយុត្តិធម៌។

ព្រះអង្គបញ្ជាក់ថា ការលំបាកបំផុត គឺបារាំង នៅតែរក្សាកងទ័ពខ្មែរ មួយផ្នែកធំ ឱ្យស្ថិតនៅក្រោមបញ្ជារបស់ពួកគេ និងនៅតែមិនអនុញ្ញាតឱ្យតុលាការខ្មែរ ជាអ្នកកាត់សេចក្តីទៅលើអ្នកទោសជាជនជាតិបារាំង និងជនបរទេសផ្សេងៗទៀត ដែលរស់នៅក្នុងប្រទេសខ្មែរ ហើយសមត្ថកិច្ចប៉ូលិសខ្មែរ ក៏មិនអាចប៉ះពាល់ដល់ពួកទាំងនេះ បានដដែល។ ចំណែកវិស័យសេដ្ឋកិច្ចខ្មែរ ត្រូវបារាំងរារាំងមិនឱ្យមាននាំចូលទំនិញពីបរទេសដោយសេរីឡើយ។

មួយថ្ងៃ ក្រោយមកទៀត កាសែត "វ៉ាស៊ីងតោនប៉ុស្ត៍" (The Wasington Post) ក៏បានចុះផ្សាយក្នុងបទវិចារណកថារបស់ខ្លួន ដោយបានធ្វើការវិភាគពីសភាពការណ៍នៅប្រទេសឡាវ និងផលប៉ះពាល់ ដែលធ្វើឱ្យខូចនយោបាយរបស់សហរដ្ឋអាមេរិក នៅឥណ្ឌូចិនផងដែរ។

វិចារណកថានេះ បានវិភាគថា៖ " ការចូលលុកលុយរបស់អាមេរិក នៅក្នុងប្រទេសឡាវ បានបង្កើតឡើងនូវការមន្ទិលសង្ស័យថា ហេតុអ្វីបានជាពួកវៀតមិញ មានទិសដៅទៅឆ្ងាយពីមូលដ្ឋានរបស់ខ្លួនដូច្នេះ? ប៉ុន្តែមានរឿងមួយដែលប្រាកដប្រជានោះ គឺប្រជាជនឡាវ ហាក់ដូចជាមិនមានសម្ទុះទឹកចិត្ត ចង់ធ្វើការតស៊ូប្រឆាំងនឹងពួកកុម្មុយនិស្តឱ្យអស់ពីចិត្តពីថ្លើមឡើយ ហើយសួរថា តើហេតុអ្វី បានជាយើង(អាមេរិក) ត្រូវទៅប្រយុទ្ធ ដើម្បីរក្សាការត្រួតត្រារបស់ប្រទេសបារាំង នៅឥណ្ឌូចិន អស់រយៈពេលជាយូរមកហើយ? ដូច្នេះវាល្មមដល់ពេលដែលយើងជាពលរដ្ឋអាមេរិក ត្រូវបញ្ចៀសចេញជាស្ថាពរ នូវសេចក្តីសង្ឃឹមក្លែងបន្លំរបស់មេដឹកនាំយើង ចាប់តាំងពីពេលចាប់ផ្តើមបញ្ជូនជំនួយទៅឥណ្ឌូចិន ជាលើកដំបូង

មកម្ល៉េះ។ ពេលនេះ មហាអំណាចលោកខាងលិច គប្បីពិចារណាពីព្រះរាជតម្រិះរបស់ព្រះមហាក្សត្រកម្ពុជា និងធ្វើសម្បទានឱ្យបានច្រើនដល់បណ្តាប្រទេស នៅក្នុងសហភាពបារាំងផងដែរ "។

បើទោះបីពេលនោះ រដ្ឋាភិបាលក្រុងវ៉ាស៊ីនតោន មិនផ្តល់ការគាំទ្រចំពោះព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យរបស់ព្រះមហាក្សត្រកម្ពុជា ក៏ពិតមែន តែតាមរយៈការផ្សព្វផ្សាយរបស់កាសែត" ញូវយ៉កថៃមស៍ " និងកាសែត "វ៉ាស៊ីងតោនប៉ុស្ត៍" នេះ យ៉ាងហោចណាស់ក៏សាធារណមតិអាមេរិក មានសមានចិត្តគាំទ្រចំពោះព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យរបស់ព្រះអង្គខ្លះៗដែរ រីឯរដ្ឋាភិបាលបារាំង ដែលគ្មានចេតនាជួបចរចាជាមួយព្រះអង្គនោះ ក៏លែងហ៊ានមើលស្រាលចំពោះព្រះរាជបូជនីយកិច្ចនេះ ដូចមុនៗទៀតដែរ។

៥៣
មេខ្មែរឥស្សរៈ ពុត ឆាយ ចុះចូលក្នុងសង្គមជាតិវិញ



មេខ្មែរឥស្សរៈ ពុត ឆាយ ចុះចូលក្នុងសង្គមជាតិវិញ

ក្នុងព្រះរាជដំណើរយាងត្រលប់មកមាតុប្រទេសវិញ នៅពេលយន្តហោះឈប់សំចតនៅក្រុងតូក្យូ នៅប្រទេសជប៉ុន ព្រះអង្គបានទទួលសារលិខិតមួយច្បាប់ ពីប៉ែន នុត រាជប្រតិភូនាយករដ្ឋមន្ត្រីទីស្តីការរដ្ឋាភិបាលរបស់ព្រះអង្គ។

ប៉ែន នុត បានផ្តល់ដំណឹងមកពីប្រទេសបារាំង ថា មេដឹកនាំបារាំង បានសុំយាងព្រះអង្គទៅក្រុងប៉ារីស ដើម្បីពិភាក្សា និងពិនិត្យលទ្ធភាពតាមការស្នើសុំទាមទារឯករាជ្យរបស់ព្រះអង្គ នៅពេលខាងមុខនេះហើយ។

ក្នុងរយៈពេលបីសប្តាហ៍ នៅទីក្រុងតូក្យូ ព្រះមហាក្សត្រសីហនុ ទទួលបាននូវព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានព្រះចៅអធិរាជ ហ៊ីរ៉ូហ៊ីតូ យាងទៅសោយទឹកតែ នៅក្នុងព្រះ

បរមរាជវាំង របស់ព្រះអង្គ។ តែព្រះរាជដំនួបនោះ ព្រះចៅអធិរាជរបស់ជប៉ុន អង្គនេះ បានសម្តែងនូវព្រះរាជឥរិយាបថយ៉ាងប្រុងប្រយ័ត្នបំផុត ដោយមិនបណ្តោយឱ្យព្រះមហាក្សត្រ សីហនុ អូសទាញព្រះអង្គឱ្យមានបន្ទូលពាក់ព័ន្ធក្នុងរឿងនយោបាយបន្តិចឡើយ ក្រៅតែពីថ្វាយព្រះពរ ឱ្យព្រះមហាក្សត្រសីហនុ ទទួលបានជោគជ័យក្នុងព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យនេះប៉ុណ្ណោះ។

នៅក្នុងខែឧសភា ឆ្នាំ១៩៥៣ ពុត ឆាយ, អ៊ូជ និលពេជ្រ និងគ្រូអ៊ុំ បានសម្រេចចិត្តទម្លាក់អាវុធ ចុះចូលជាមួយព្រះមហាក្សត្រសីហនុ។ បន្ទាប់មកទៀត ពិធីចុះចូលនេះ បានប្រារព្ធធ្វើឡើងជាផ្លូវការ នៅបន្ទាយត្មាតពង ខេត្តកំពង់ស្ពឺ ថ្ងៃទី៣ ឧសភា ឆ្នាំ១៩៥៤ ក្រោមព្រះរាជាធិបតីភាពរបស់សម្តេចបិតា ព្រះនរោត្តម សុរាម្រិត ដោយព្រះអង្គបានបំពាក់ឋានន្តរស័ក្តិវរសេនីយ៍ត្រី (ស័ក្តិ៤) ដល់ពុត ឆាយ ផងដែរ។

ក្រោយពីមកចុះចូលក្នុងសង្គមជាតិ វិញ ពុត ឆាយ ទទួលបានត្រឹមឋានន្តរស័ក្តិវរសេនីយ៍ត្រី (ស័ក្តិ៤) ប៉ុណ្ណោះ មិនមានតួនាទីអ្វីធំដុំ និងមានកេរ្តិ៍ឈ្មោះល្បីល្បាញ ដូចមេខ្មែរឥស្សរៈឈ្មោះដាប ឈួន សុំចុះចូលជាមួយសម្តេចសីហនុ កាលពីឆ្នាំ១៩៤៩ នោះទេ ហើយគាត់តែងតែមានវត្តមានជាអចិន្ត្រៃយ៍ នៅតាមសង្វៀនជល់មាន់នៅជាយៗក្រុងភ្នំពេញ និងត្រូវកម្លាំងកងរាជតម្រួតចុះទៅបង្ក្រាប ធ្វើឱ្យគាត់រត់បាតជើងសព្រាតជាញឹកញាប់ទៀតផង ។

ក្រោយកងទ័ពខ្មែរក្រហម វាយដណ្តើមបានទីក្រុងភ្នំពេញ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មានប្រភពមួយ បានអះអាងថា ពុត ឆាយ និងក្រុមគ្រួសារ បានជម្លៀសទៅរស់នៅខេត្តពោធិ៍សាត់ ហើយគាត់ត្រូវស្លាប់នៅទីនោះ។

នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ បានយាងមកដល់រាជធានីភ្នំពេញ វិញ។ ពេលនោះ គឺជាលើកទី១ហើយ ដែលចាប់ពីអាកាសយានដ្ឋានពោធិ៍ចិនតុង មកដល់ព្រះបរមរាជវាំង មានប្រជារាស្ត្រក្មេងចាស់ប្រុសស្រីយ៉ាងច្រើនកុះករ ឈរអមនៅតាមដងផ្លូវ នាំគ្នាទះដៃ និងស្រែកជ័យឃោស ធ្វើព្រះរាជបដិសណ្ឋារកិច្ចថ្វាយព្រះ



ពុត ឆាយ

អង្គយ៉ាងអធិកអធមបំផុត ។

ពេលយាងមកដល់ព្រះបរមរាជវាំង ប៉ែន នុត រាជប្រតិភូនាយករដ្ឋមន្ត្រីទីស្តីការរដ្ឋាភិបាល ទើបនឹងវិលត្រលប់មកពីប្រទេសបារាំង ដៃរនោះ បានចូលមកក្រាបបង្គំថ្វាយសំណុំឯកសារឆ្លើយតបមួយរបស់មេដឹកនាំបារាំង ដល់ព្រះអង្គ។

តែក្រោយពីពិនិត្យទតសំណុំឯកសារឆ្លើយតបនោះហើយ ព្រះអង្គមានការខកព្រះទ័យយ៉ាងខ្លាំង ព្រោះមេដឹកនាំបារាំង នៅតែមិនព្រមឱ្យកងទ័ពរបស់ព្រះអង្គមានឯករាជ្យ ក្នុងការបង្ក្រាបចលនាបះបោរ បង្កអសន្តិសុខរបស់ពួកវៀតមិញ និងខ្មែរឥស្សរៈដដែល ដោយមេដឹកនាំបារាំង គ្រាន់តែយល់ព្រមឱ្យបង្កើតសេនាធិការចម្រុះ(បារាំង-ខ្មែរ) នៅក្នុងអង្គភាពកងទ័ពទាំងឡាយណា មានសុទ្ធតែទាហានខ្មែរ ជំនួសសេនាធិការ ដែលពីមុនៗមក មានសុទ្ធតែនាយទាហានបារាំង នោះ។

ចំណែកនៅក្នុងវិស័យតុលាការ បារាំង នៅតែមិនព្រមផ្តល់សិទ្ធិឱ្យតុលាការខ្មែរជំនុំជម្រះរឿងក្តីណាដែលពាក់ព័ន្ធនឹងជនជាតិបារាំង ចិន វៀតណាម និងអាណិកជនផ្សេងៗ

ទៀត មកពីបណ្តាប្រទេសជាសមាជិកសហព័ន្ធបារាំង ដដែល។ មានន័យថា ជនជាតិទាំងនោះ នៅតែស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការបារាំង ដដែល។ ឯវិស័យហិរញ្ញវត្ថុ វិញ បារាំង បានស្នើសុំឱ្យដំណើរការដូចមុនដដែល ដោយគ្មានការកែប្រែអ្វីបន្តិច ទាល់តែសោះ។

ការឆ្លើយតបរបស់រដ្ឋាភិបាលបារាំងនេះ ព្រះមហាក្សត្រសីហនុ មិនអាចទទួលយកបានជាដាច់ខាត ព្រះអង្គក៏សម្រេចព្រះទ័យធ្វើការទាមទារឯករាជ្យនេះ ឱ្យកាន់តែល្បីខ្ចរខ្ចារនៅលើឆាកអន្តរជាតិ ជាថ្មីម្តងទៀត។

៥៤
ថៃ ចាត់ទុកថា ព្រះមហាក្សត្រសីហនុ ជាជនជាតិវេទេស



ព្រះមហាក្សត្រនរោត្តម សីហនុ

នៅពាក់កណ្តាលខែមិថុនា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រនរោត្តម សីហនុ បានយាងទៅទីក្រុងបាងកក ប្រទេសថៃ ក្នុងព្រះរាជបំណងទាក់ទងមន្ត្រីការទូតបណ្តាប្រទេសនានា និងសារព័ត៌មានបរទេសផ្សេងៗទៀត ដើម្បីឱ្យពួកគេបានយល់ច្រឹតច្រាបពីបុព្វហេតុ នៃការតស៊ូទាមទារឯករាជ្យជាតិពីបារាំង នេះ ផងដែរ។ ប៉ុន្តែនៅទីក្រុងបាងកក ព្រះមហាក្សត្រ ថៃ ភូមិពល អតុល្យតេជ (Bhumibol Adulyadej) មិនរាជានុញ្ញាតឱ្យព្រះអង្គចូលគាល់ឡើយ។

មិនតែប៉ុណ្ណោះ រដ្ឋមន្ត្រីក្រសួងការបរទេសថៃ បានមកទូលព្រះអង្គថា ប្រទេសថៃ មិនអាចផ្តល់ការគាំទ្រចំពោះព្រះរាជវត្តមានរបស់ព្រះអង្គបានទេ ព្រោះប្រទេសថៃ មិនចង់ឱ្យមានបញ្ហាខាងនយោបាយ និងបញ្ហាការទូត ជាមួយបារាំង។

ចំណែកនាយករដ្ឋមន្ត្រីថៃ សេនាប្រមុខ ផ្លែក ភិបូនសុង្គ្រាម (Plaek Phibunsongkhram) បានសម្តែងនូវឫកពាក្រអឺតក្រទម ដោយផ្តាំផ្ញើមកព្រះអង្គថា ប្រសិនបើ

ព្រះអង្គមានសំណូមពរអ្វីចំពោះគេ ព្រះអង្គអាចយាងទៅជួបរូបគេផ្ទាល់ នៅឧទ្ទកាល័យ របស់គេ ។

លើសពីនេះទៅទៀត រាជរដ្ឋាភិបាលថៃ បានហាមឃាត់ព្រះអង្គមិនឱ្យធ្វើសកម្មភាព នយោបាយអ្វីបន្តិចឡើយ ហើយហាមជួបអ្នកកាសែត ទៀតផង ពិសេស សូម្បីតែគេហដ្ឋាន របស់ឯកអគ្គរាជទូតខ្មែរ ប្រចាំទីក្រុងបាងកក ក៏រាជរដ្ឋាភិបាលថៃ ហាមព្រះអង្គមិនឱ្យ គង់នៅដែរ។

កាន់តែធ្ងន់ធ្ងរជាងនេះទៅទៀត រាជរដ្ឋាភិបាលថៃ ចាត់ទុកថា ព្រះអង្គគ្រាន់តែជា ជននិរទេសម្នាក់ប៉ុណ្ណោះ។

ទោះបីយ៉ាងនេះក៏ដោយ ក៏ពេលព្រះអង្គគង់នៅតែក្នុងសណ្ឋាគារ ដោយរាជរដ្ឋា-ភិបាលថៃ មិនឱ្យចេញទៅណាមកណា ដូចមនុស្សជាប់ឃុំនោះ ព្រះមហាក្សត្រថៃ ភូមិពល អតុល្យតេជ បានឱ្យចុងភៅពិសេស នៅក្នុងព្រះបរមរាជវាំង យកព្រះស្ងោយមកថ្វាយព្រះ អង្គដែរ។ តែព្រះស្ងោយនោះ ឡើងត្រជាក់ស្រេប សោយលែងឆ្ងាញ់ទៅហើយ។

មុនពេលយាងចាកចេញពីប្រទេសថៃ វិញ ព្រះអង្គបានសរសេរព្រះរាជសារមួយ ថ្លែងអំណរព្រះគុណចំពោះព្រះមហាក្សត្រថៃ ភូមិពល អតុល្យតេជ ដែលបានរាជា នុញ្ញាត ឱ្យព្រះអង្គស្នាក់នៅក្នុងក្រុងបាងកក នោះដែរ តែក្នុងព្រះរាជសារនោះ ព្រះអង្គមិន បាន ថ្លែងអំណរព្រះគុណចំពោះព្រះមហាក្សត្រថៃ ដែលបានឱ្យចុងភៅពិសេស នៅក្នុងព្រះបរម រាជវាំង យកព្រះស្ងោយដែលត្រជាក់ស្រេបហើយនោះ មកថ្វាយព្រះអង្គទេ។

នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ បានយាងតាមព្រះទីនាំង រថយន្ត ឆ្លងកាត់តាមក្រុងអារញ្ញប្រាថេត ត្រលប់មកមាតុប្រទេសវិញ ដោយមានប្រជារាស្ត្រ ថៃ មានដើមកំណើតខ្មែរ រាប់ពាន់នាក់ បាននាំគ្នាមកឈរង់ចាំស្វាគមន៍ព្រះរាជដំណើរព្រះអង្គ ដោយទឹកចិត្តស្វាមីភក្តិបំផុត។

មិនតែប៉ុណ្ណោះ ពួកគេមួយចំនួនបាននាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ និងសូមរាជានុញ្ញាត ចូលបម្រើក្នុងជួរកងទ័ពព្រះអង្គ ដើម្បីរួមចំណែកក្នុងការទាមទារឯករាជ្យពីបារាំង ជូនមាតុភូមិ

ដើមរបស់ពួកគេ ទៀតផង។

ភាគច្រើននៃប្រជារាស្ត្រថៃ ដើមកំណើតខ្មែរទាំងនោះ សុទ្ធសឹងតែមានជីវភាពសម្បូរណ៌ធូរធារ តែព្រះអង្គមិនចង់ឱ្យពួកគេចូលមកផ្សងព្រេង ក្នុងការចូលរួមទាមទារឯករាជ្យជាមួយព្រះអង្គទេ ដោយព្រះអង្គបានលើកហេតុផលប្រាប់ពួកគេវិញថា ព្រះអង្គមិនខ្វះកម្លាំងកងទ័ពឡើយ ហើយព្រះអង្គក៏នៅតែសង្ឃឹមក្នុងការស្វែងរកដំណោះស្រាយទាមទារឯករាជ្យពីបារាំង នៅពេលខាងមុខ ដោយសន្តិវិធី ផងដែរ ។

ពេលមកដល់ទីរួមខេត្តបាត់ដំបង ព្រះមហាក្សត្រសីហនុ បានប្រកាសអំពាវនាវឱ្យប្រជារាស្ត្រទូទាំងប្រទេស ចូលរួមក្នុងចលនាទាមទារឯករាជ្យពីបារាំង ជាមួយព្រះអង្គ។

មិនយូរប៉ុន្មាន ក៏មានប្រជារាស្ត្រគ្រប់មជ្ឈដ្ឋាន ប្រមាណ២០ម៉ឺននាក់ បានស្ម័គ្រចូលរួមក្នុងចលនាទាមទារឯករាជ្យនោះ ដោយមានកងជីវពល និងនារីក្លាហាន ដែលឱ្យឈ្មោះថា " កងទ័ពកាំភ្លើងឈើ " ក៏ចាប់ផ្តើមបង្កើតឡើង នៅទូទាំងប្រទេស ភ្លាមៗតែម្តង។

៥៥
សឺង ង៉ុកថាញ់ មិនព្រមមកចូលរួមជាមួយ ព្រះមហាក្សត្រសីហនុ



សម្តេចព្រះសង្ឃរាជ ហួត តាត និងសម្តេចព្រះសង្ឃរាជ ជួន ណាត

បន្ទាប់មក ព្រះមហាក្សត្រសីហនុ បានបន្តព្រះរាជដំណើរពីខេត្តបាត់ដំបង តាមព្រះទីនាំងរថយន្តឆ្ពោះទៅខេត្តសៀមរាប ដោយមានសម្តេចព្រះសង្ឃរាជហួត តាត គង់នៅជាមួយព្រះអង្គ ក្នុងព្រះទីនាំងរថយន្តនោះដែរ។

ដោយព្រះអង្គដឹងច្បាស់ថា សម្តេចព្រះសង្ឃរាជហួត តាត មានទំនាក់ទំនងជិតស្និទ្ធបំផុត ជាមួយសឺង ង៉ុកថាញ់ មេដឹកនាំប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ នៅភ្នំដងរែកនោះ ព្រះអង្គ ក៏បានស្នើឱ្យសម្តេចសង្ឃរាជជួយស្ទាបស្ទង់ជាសម្ងាត់ជាមួយសឺង ង៉ុកថាញ់ ថា តើគាត់យល់ព្រមមកចូលរួមព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ ជាមួយព្រះអង្គ ដែរឬទេ ?

ប៉ុន្មានថ្ងៃក្រោយមក សឺង ង៉ុកថាញ់ ក៏បានឆ្លើយតបមកព្រះអង្គ វិញដែរ ប៉ុន្តែមិនមែនតាមរយៈសម្តេចព្រះសង្ឃរាជ ហួត តាត នោះទេ គឺឆ្លើយតបតាមរយៈបទវិចារណកថា ដែលចាក់ផ្សាយតាមវិទ្យុផ្សាយសំឡេងប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ មានទីតាំង

នៅជើងភ្នំដងរែក ជាប់ព្រំដែនខ្មែរ-ថៃ នោះទៅវិញ។

បទវិចារណកថានោះ បានលើកឡើងថា របស់ដែលហៅថា ព្រះរាជបូជនីយកិច្ច ដឹកនាំដោយសីហនុ ដើម្បីទាមទារឯករាជ្យមកឱ្យមាតុប្រទេសនោះ គឺគ្រាន់តែជារឿងកំប្លុកកំប្លែង គួរឱ្យស្អប់ខ្ពើមមួយ ដែលសម្តែងឡើងដោយស្តេចក្បត់ ក្រោមបញ្ជាពួកបារាំង ជាចៅហ្វាយនាយរបស់ខ្លួន តែប៉ុណ្ណោះ។

បទវិចារណកថានោះ បានបញ្ជាក់ថា វីរបុរសរបស់ពួកគេ មានតែម្នាក់គត់ គឺសឺង ង៉ុកថាញ់ ដែលមិនចុះចូលជាមួយស្តេចសីហនុ ជាសត្រូវរបស់ប្រជាពលរដ្ឋនោះ ជាដាច់ខាត។

ដោយឡែក នៅក្រុងបាងកក ក៏ដូចជានៅក្រុងតូក្យូដែរ បើទោះបីជាមានការហាមប្រាម មិនឱ្យព្រះអង្គធ្វើសកម្មភាពនយោបាយយ៉ាងណា ក៏ព្រះអង្គបានបញ្ជូនឯកសារសំខាន់ៗទាំងឡាយ ដែលឆ្លុះបញ្ចាំងពីគោលជំហររបស់ព្រះអង្គ ក្នុងការទាមទារឯករាជ្យពីបារាំង ទៅដល់សារព័ត៌មានអន្តរជាតិនានា ព្រមទាំងដល់ស្ថានទូតបរទេសទាំងអស់ផងដែរ។

សាធារណមតិពិភពលោកនាំគ្នាចាប់អារម្មណ៍មកលើព្រះអង្គ ដោយអ្នកខ្លះទទួលស្គាល់ និងគាំទ្រសកម្មភាពទាមទារឯករាជ្យរបស់ព្រះអង្គ តែខ្លះទៀតក៏នាំគ្នារិះគន់ទិតៀនដែរ។

ទស្សនាវដ្តី "ប៉ារីសម៉ាត់" របស់បារាំង ចាត់ទុកដំណើរយោងទៅប្រទេសថៃ របស់ព្រះមហាក្សត្រសីហនុ ថា គ្រាន់តែជាដំណើរស្រើបស្រាលដ៏សោះកក្រោះ ឥតខ្លឹមសាររបស់ស្តេចចិត្តសាវាមួយអង្គ ដែលមិនចេះពិចារណារកហេតុផល តែប៉ុណ្ណោះ។

កាសែត "ឡូរ៉ូ" បានសរសេរថា នេះជាការទាមទារឯករាជ្យ គួរឱ្យអស់សំណើចរបស់មេដឹកនាំប្រទេសមួយ ដែលមានព្រះសង្ឃច្រើនជាងកងទ័ព ដល់ទៅ១០ដងនោះ តើអាចទទួលបានជ័យជម្នះដែរឬទេ?

ចំណែកនៅក្រុងឡុងដ៍ ប្រទេសអង់គ្លេស កាសែត "ដេលី តេឡេក្រាហ្វ" បានសរសេរចំអកថា តើស្តេចសីហនុ មានភ័ព្វសំណាងអ្វី នឹងទទួលបានឯករាជ្យមួយ ស្រដៀងគ្នានឹងឯករាជ្យរបស់ប្រទេសប៉ាគីស្តាន ទោះបីព្រះអង្គខំស្រែកទាមទារយ៉ាងណាក៏ដោយ។

កាសែតដដែល បានសរសេរថា បើគ្មានបារាំង មកគ្រប់គ្រងទេនោះ ម្ល៉េះសម ប្រទេសខ្មែរ នឹងក្លាយជាប្រទេសឯករាជ្យមួយដែលរណបចិនកុម្មុយនិស្ត តាំងពីយូរយារ ណាស់មកហើយ ។

ប៉ុន្តែយ៉ាងណា នៅប្រទេសបារាំង ក៏មានសាធារណមតិជាច្រើន បានសម្តែងការគាំទ្រ និងជួយជំរុញឱ្យរដ្ឋាភិបាលបារាំង យកចិត្តទុកដាក់ចំពោះការទាមទារឯករាជ្យរបស់ព្រះអង្គ យ៉ាងផុលផុសដែរ។

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៥៣ កាសែត " ឡឺហ្វីការ៉ូ " របស់បារាំង បានចុះ ផ្សាយអត្ថបទជាស្នាដៃរបស់អ្នកនិពន្ធបារាំង ដ៏ល្បីល្បាញម្នាក់ ឈ្មោះហ្សក ឌុយហាបែល ជាសមាជិកបណ្ឌិត្យសភាបារាំង ។

អត្ថបទនោះ បានសរសេរថា ការសម្រេចព្រះទ័យរបស់ព្រះមហាក្សត្រខ្មែរ កាលពី ពេលព្រះអង្គយាងទៅទីក្រុងបាងកក ប្រទេសថៃ ដែលមតិខ្លះចាត់ទុកថា ជាការធ្វើឱ្យ កាន់តែមានបញ្ហាស្មុគស្មាញច្របូកច្របល់នៅឥណ្ឌូចិន និងមតិខ្លះចាត់ទុកថា ជាលទ្ធផល នៃចិត្តសាវា ឬជាការរវើរវាយរបស់ស្តេចវ័យក្មេងនោះ គឺជាការយល់ខុសទាំងស្រុង ហើយអ្វី ដែលអ្នកសង្កេតការណ៍មួយចំនួនសង្ឃឹមថា វានឹងកើតមានឡើង ដូចពួកគេសន្និដ្ឋាននោះ វានឹងមិនអាចកើតមានឡើយ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ បានទៅគង់នៅតំបន់ស្វយ័ត ដែលរួមមានខេត្តបាត់ដំបង ខេត្តសៀមរាប និងកំពង់ធំ ហើយព្រះអង្គបានយកទីក្រុង សៀមរាប ធ្វើជាបញ្ជាការដ្ឋាន។

សូមបញ្ជាក់ថា ក្រោយពីដាប ឈួន ចុះចូលជាមួយព្រះមហាក្សត្រសីហនុ នៅ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ មក បារាំង បានដកកងទ័ពខ្លួនទាំងអស់ ចេញពីខេត្តសៀមរាប និងខេត្តកំពង់ធំ និងបានប្រគល់ខេត្តទាំង២នេះ ជាខេត្តស្វយ័ត ឱ្យខ្មែរ ជាអ្នកគ្រប់គ្រង ដោយខ្លួនឯង។ លុះដល់ឆ្នាំ១៩៥២ បារាំង បានប្រគល់ខេត្តបាត់ដំបង ជាខេត្តស្វយ័ត មួយទៀត។

នៅទីក្រុងសៀមរាប ព្រះអង្គបានប្រកាសជាសាធារណៈថា ព្រះអង្គនឹងយាងត្រលប់ចូលរាជធានីភ្នំពេញ វិញ នៅថ្ងៃណា ដែលបារាំង យល់ព្រមផ្ទេរអំណាចកាន់កាប់វិស័យកងទ័ព រដ្ឋបាល និងសេដ្ឋកិច្ច មកឱ្យរដ្ឋាភិបាលរបស់ព្រះអង្គ ជាអ្នកគ្រប់គ្រងវិញ។

នៅបញ្ជាការដ្ឋានរបស់ព្រះអង្គ នាទីក្រុងសៀមរាប នោះដែរ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៥៣ ព្រះអង្គបានរុះរើផ្លាស់ប្តូរសមាសភាពគណៈរដ្ឋមន្ត្រីរបស់ព្រះអង្គ ជាថ្មីម្តងទៀត ដោយក្នុងនោះ ព្រះអង្គនៅតែគង់ជានាយករដ្ឋមន្ត្រីដដែល, ប៉ែន នុត ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីហិរញ្ញវត្ថុ កីឡា យុវជន និងអប់រំមូលដ្ឋាន, អូ ឈឺន ជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីវិចិត្រសិល្បៈ សង្គមកិច្ច និងការងារ, ព្រះអង្គម្ចាស់ក្សត្រីនរោត្តម ប៉េងប៉ោះ យុគន្ធរ ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកសុខាភិបាល, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជារដ្ឋមន្ត្រីការបរទេស, ញឹក ជូឡុង ជារដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៍, ប្រាក់ សារិន ជារដ្ឋមន្ត្រីមហាផ្ទៃ និងស្វ័យការពារ, ស៊ឹម វ៉ា ជារដ្ឋមន្ត្រីការពារជាតិ, ជាញ់ សួង ជារដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ, តុង អ៊ួនម៉ម ជារដ្ឋមន្ត្រីយុត្តិធម៌, សម សារី (ឪពុកសម រង្ស៊ី) ជារដ្ឋមន្ត្រីអប់រំជាតិ និងសន្និសីទ, ប្រាក់ ប្រព្រឿង ជារដ្ឋលេខាធិការថវិកា, សាមសុង ហ៊ែរណង់ដេស ជាប្រតិភូព័ត៌មាន, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ឥស្សរ៉ូ ជាអនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកកីឡាយុវជន និងអប់រំមូលដ្ឋាន, ម៉ៅ ចយ ជាអនុរដ្ឋលេខាធិការសង្គមកិច្ច និងការងារ ទទួលបន្ទុកកិច្ចការកសិករ, ងិន នីផា ជាអនុរដ្ឋលេខាធិការរាជប្រតិភូព័ត៌មាន ទទួលបន្ទុកឃោសនា និងអប់រំប្រជារាស្ត្រ, ព្រះអង្គម្ចាស់នរោត្តម វិរិយ៉ា ជាអនុរដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកនគរបាល។

នៅទីក្រុងសៀមរាបនោះ ព្រះមហាក្សត្រសីហនុ បានប្រជុំជាមួយ ប៉ែន នុត និង សឺន សាន យ៉ាងសម្ងាត់បំផុត សូម្បីតែញឹក ជូឡុង និងលន់ នល់ ដែលបានចូលរួមនៅក្នុងការដឹកនាំទាមទារឯករាជ្យនោះ ក៏ព្រះអង្គមិនឱ្យដឹងដែរ ។

ព្រះអង្គបានគ្រាស់បង្គាប់ឱ្យ ប៉ែន នុត និងសឺន សាន រៀបចំព្រះរាជប្រកាសមួយ អំពាវនាវឱ្យរាជរដ្ឋាភិបាល និងប្រជារាស្ត្រខ្មែរទូទាំងប្រទេស នាំគ្នាចូលរួមព្រះរាជបូជនីយកិច្ច

នេះ ឱ្យបានគ្រប់គ្នា និងតាមគ្រប់មធ្យោបាយ ដែលមានរៀងៗខ្លួន។

នៅក្នុងការតាក់តែងព្រះរាជប្រកាសនេះ ប៉ែន នុត ជាឧបនាយករដ្ឋមន្ត្រី និងសឺន សាន បានព្យាយាមយកម៉ាស៊ីនអង្គុលីលេខមកវាយខ្លឹមសារអត្ថបទនៃព្រះរាជប្រកាសនោះ ដោយខ្លួនគាត់ផ្ទាល់។

តែដោយសារពួកគាត់មិនសូវចេះវាយអង្គុលីលេខនេះ ពួកគាត់បានសម្រេចទៅរកស្មៀន នៅសាលាខេត្តម្នាក់ចេះវាយអង្គុលីលេខស្ទាត់ជំនាញ មកវាយខ្លឹមសារអត្ថបទនោះវិញ ដើម្បីឱ្យលឿនរហ័ស ទាន់សភាពការណ៍។

ប៉ុន្តែស្មៀនសាលាខេត្តនោះ ត្រូវស្បថជាមុនថា នឹងលាក់ការណ៍សម្ងាត់នេះ មិនឱ្យអ្នកផ្សេងទៀតដឹងពីខ្លឹមសារនៃព្រះរាជប្រកាសនោះ ជាដាច់ខាត ។

ក្រោយពីពិនិត្យ និងឡាយព្រះហស្តលេខាលើព្រះរាជប្រកាសនោះរួចមក ព្រះមហាក្សត្រ សីហនុ ប្រញាប់ប្រញាល់ឱ្យសឺន សាន យកឯកសារសម្ងាត់នោះ ទៅថ្វាយមាតាបិតារបស់ព្រះអង្គ និងទៅជូន ស៊ឹម វ៉ា រដ្ឋមន្ត្រីក្រសួងការពារជាតិ ជានាយករដ្ឋមន្ត្រីស្តីទី ដើម្បីឱ្យចាត់ការតាមព្រះរាជប្រកាសនេះ ជាបន្ទាន់ ។


នៅពេលក្រាបបង្គំលាព្រះមហាក្សត្រសីហនុ ចេញដំណើរទៅភ្នំពេញ សឺន សាន ក៏បានឆ្លៀតឱកាសទូលសុំការសន្តោសប្រោសប្រណី លើកលែងទោសដល់មន្ត្រីរបស់គណបក្សប្រជាធិបតេយ្យមួយចំនួន កំពុងជាប់ឃុំនៅក្នុងពន្ធនាគារ(គុកធំ)នៅក្រោយវត្តឧណ្ណាលោមផងដែរ។

ពេលនោះ ព្រះអង្គក៏បានសម្រេចព្រះទ័យឱ្យគេដោះលែងមន្ត្រីគណបក្សប្រជាធិបតេយ្យទាំងអស់នោះ ឱ្យមានសេរីភាពវិញ តាមការទូលស្នើសុំរបស់សឺន សាន ដោយគ្មានស្ទាក់ស្ទើរព្រះទ័យបន្តិចឡើយ។

ក្រោយពីមានការប្រកាសអំពាវនាវរបស់ព្រះអង្គ ឱ្យរាជរដ្ឋាភិបាល និងប្រជារាស្ត្រខ្មែរទូទាំងប្រទេស នាំគ្នាចូលរួមព្រះរាជបូជនីយកិច្ចនេះ ឱ្យបានគ្រប់គ្នាមក ចាប់ពីចុងខែមិថុនាដល់ចុងខែកក្កដា ឆ្នាំ១៩៥៣ មាននាយទាហានជាន់ខ្ពស់៥នាក់ បាននាំពលទាហានរបស់

ខ្លួនចំនួន៦០០នាក់ រត់ចេញពីអង្គភាពកងទ័ពបារាំង ធ្វើដំណើរទៅខេត្តសៀមរាប ចូលរួម
ជាមួយព្រះអង្គ ដើម្បីទាមទារឯករាជ្យនេះដែរ។

៥៦
បារាំងមិនខ្លាចព្រះមហាក្សត្រសីហនុ ទេ គឺខ្លាចពួកវៀតមិញ



រថពាន្ដបារាំង នៅក្នុងប្រទេសកម្ពុជា កាលពីឆ្នាំ១៩៥២

ក្រោយពីមានទាហានខ្មែរវត់ចេញពីអង្គភាពកងទ័ពបារាំងមក បារាំងក៏បានដកនាយទាហានជាជនជាតិបារាំងរបស់ពួកគេ ចេញពីតួនាទីជាមេបញ្ជាការ នៅតាមកងវរសេនាតូចខ្មែរទាំងអស់ ក្នុងបំណងមិនឱ្យទាហានខ្មែរ មានការរើជើបរំជួល និងមានការវត់ចោលអង្គភាពរបស់ខ្លួនបន្តទៀត។

ជាមួយគ្នានោះ បារាំង ក៏បានបញ្ជូនកងទ័ពជើងគោករបស់ខ្លួន ចំនួន៣កងវរសេនាតូច និងកងរថក្រោះ ចំនួន៣កងទៀត ចូលមកក្នុងប្រទេសកម្ពុជា ដើម្បីត្រៀមទប់ទល់នឹងសភាពការណ៍អាក្រក់ណាមួយ ដែលអាចកើតឡើងជាយថាហេតុ ផងដែរ។

ការពិតទៅ បារាំង មិនមែនភ័យខ្លាចសកម្មភាពទាមទារឯករាជ្យរបស់ព្រះមហាក្សត្រ សីហនុ ប៉ុន្មានទេ តែអ្វីដែលបារាំង ត្រូវតែប្រុងប្រយ័ត្នបំផុតនោះ គឺខ្លាចពួកវៀតមិញ ឆ្លៀតឱកាសបើកការវាយប្រហារជាទ្រង់ទ្រាយធំ មកលើកងទ័ពរបស់ពួកគេ តែប៉ុណ្ណោះ។ តែពេលនោះ ពួកវៀតមិញ មិនបានធ្វើសកម្មភាពអ្វីធំដុំ គួរឱ្យព្រួយបារម្ភឡើយ។

ផ្ទុយទៅវិញ នៅទីក្រុងភ្នំពេញ បែរជាមានបញ្ហាតានតឹងមួយ ដោយសារកងទ័ពស្ថិតនៅក្រោមបញ្ជារបស់អតីតមេឥស្សរៈ ឈ្មោះពុត ឆាយ ទើបនឹងចុះចូលជាមួយព្រះមហា-ក្សត្រ បានបង្កើងជាមួយកងទ័ពបារាំង ទៅវិញ។

នៅពាក់កណ្តាលខែសីហា ឆ្នាំ១៩៥៣ កងទ័ពខ្មែរនៅក្រោមបញ្ជារបស់ពុត ឆាយ បានសម្លាប់មន្ត្រីកងអាវុធហត្ថបារាំង ម្នាក់ និងស្មៀនជាជនជាតិខ្មែរ ម្នាក់ទៀត។

លើសពីនេះទៅទៀត កងទ័ពរបស់ពុត ឆាយ បានបោះគ្រាប់បែកមួយគ្រាប់ ចូលក្នុងរង្គសាលមួយ ដែលមានពួកទាហានបារាំង ជាជនជាតិអាហ្វ្រិក ចូលទៅរាំកម្សាន្ត បណ្តាលឱ្យមានមនុស្សស្លាប់ និងរងរបួសជាច្រើននាក់។

ពេលព្រះមហាក្សត្រសីហនុ បង្កើនព្រះរាជសកម្មភាពទាមទារឯករាជ្យកាន់តែខ្លាំងនោះ បារាំងបានតែងតាំងឧត្តមសេនីយ៍ ដឺឡង់ក្លាដ (Delanglade) ឱ្យមកធ្វើជាអគ្គមេបញ្ជាការ នៅកម្ពុជា។

កាលពីឆ្នាំ១៩៤៨ ព្រះមហាក្សត្រសីហនុ បានយាងទៅសិក្សាមុខជំនាញខាងយោធា

នៅសាលាសូមៀរ ប្រទេសបារាំង ពេលនោះ ព្រះអង្គ គឺជាសិស្សសំណព្វរបស់ឧត្តមសេនីយ៍ ដឺឡង់ក្លាដ (Delanglade) នេះដែរ ។

ដូច្នេះ ពេលឧត្តមសេនីយ៍ ដឺឡង់ក្លាដ (Delanglade) ឱ្យមកធ្វើជាអគ្គមេបញ្ជាការ នៅកម្ពុជា ព្រះអង្គត្រូវស្ថិតនៅក្នុងស្ថានភាពមួយ គឺត្រូវប្រឈមមុខតតាំងរវាងគ្រូ និង សិស្ស។ តែព្រះអង្គបានរិះរកគ្រប់មធ្យោបាយ ធ្វើយ៉ាងណា ដើម្បីទប់ទល់នឹងគូសត្រូវម្នាក់ ដែលធ្លាប់ជាគ្រូបង្ហាត់បង្រៀនក្បួនយុទ្ធសាស្ត្រដល់ព្រះអង្គ កាលពី៤ឆ្នាំមុននោះ ដោយ សន្តិវិធីដែរ។

ជាមួយគ្នានោះ ព្រះអង្គក៏ត្រូវប្រឈមមុខជាមួយគូសត្រូវ ម្នាក់ទៀត ឈ្មោះ រីស្ទ័រ រុស្សុី (Risterucci) ជាស្នងការថ្មីនៃសាធារណរដ្ឋបារាំង ប្រចាំប្រទេសកម្ពុជា ជាមនុស្សមាន ប្រាជ្ញាឈ្លាសវៃ និងជាអ្នកចរចាដ៏ស្ងៀតស្ងាញល្អិតល្អន់បំផុត ផងដែរ។

ចំណែកមន្ត្រីជាន់ខ្ពស់បារាំង ទាំងពីរនាក់នេះ ក៏បានរិះរកគ្រប់វិធី ធ្វើយ៉ាងណា ដោះស្រាយបញ្ហាទាមទារឯករាជ្យនេះ ដោយមិនឱ្យមានការបង្ហូរឈាមគ្នា ដែលធ្វើឱ្យពួក វៀតមិញ ជាភាគីទី៣ ចាំទទួលផលចំណេញ ដោយងាយៗនោះ បានឡើយ។

ឧត្តមសេនីយ៍ ដឺឡង់ក្លាដ (Delanglade) និងរីស្ទ័ររុស្សុី បានបើកសិទ្ធិឱ្យនាយ ទាហាន និងពលទាហានខ្មែរទាំងឡាយ ស្ថិតនៅក្រោមបញ្ជារបស់បារាំង ទៅចូលរួមក្នុង ចលនាទាមទារឯករាជ្យរបស់ព្រះអង្គ នៅតំបន់ស្វយ័តខេត្តសៀមរាប ដោយសេរី ប្រសិនបើ ពួកគេចង់ទៅចូលរួមជាមួយព្រះអង្គ។

ដោយសារមានកម្លាំងចូលរួមកាន់តែច្រើនឡើងៗ តែគ្មានបន្ទាយ ឬអគារសម្រាប់ ស្នាក់នៅនោះ អ្នកចូលរួមភាគច្រើន បានម្ចាស់ការក្នុងការស្វែងរកទីជម្រករៀងៗខ្លួន ដោយ ខ្លះនាំគ្នាទៅស្នាក់នៅតាមផ្ទះអ្នកភូមិ នៅតាមតំបន់ជាយក្រុងសៀមរាប។

មិនយូរប៉ុន្មាន អង្គភាពវៀតមាសដែក នៅទីក្រុងភ្នំពេញ ក៏បានចូលរួមដែរ ហើយ ព្រះអង្គបានប្រគល់ភារកិច្ចឱ្យពួកគេទៅត្រៀមប្រយុទ្ធ នៅតាមបណ្តោយផ្លូវជាតិលេខ៦ ត្រង់ចំណុចព្រំប្រទល់ខេត្តកំពង់ធំ និងខេត្តកំពង់ចាម ជាតំបន់ខណ្ឌចែកគ្នា រវាងតំបន់

ស្វយ័តរបស់ព្រះអង្គ និងតំបន់ត្រួតត្រា ដោយពួកអាណានិគមបារាំង។

នៅទីនោះ ក្រុមរថពាសដែកខ្មែរ និងក្រុមរថពាសដែកបារាំង បានតម្រង់ចុងកាណុងដាក់គ្នា ក៏ពិតមែន តែកងទ័ពទាំងសងខាង នៅតែទាក់ទងរាប់រកគ្នា ក្នុងនាមជាមិត្តភាពដដែល។

ឧត្តមសេនីយ៍ដឺឡង់ក្លាដ (Delanglade) មេបញ្ជាការកងទ័ពបារាំង ប្រចាំនៅកម្ពុជាប្រកបដោយប្រាជ្ញាឈ្លាសវៃនោះ មិនបានដាក់ពង្រាយកងទ័ពរបស់គាត់ ឱ្យមកនៅក្បែរៗតំបន់ស្វយ័តសៀមរាប របស់ព្រះមហាក្សត្រសីហនុ ទេ។ ផ្ទុយទៅវិញ គាត់បានបើកប្រតិបត្តិការសឹក បោសសម្អាតកងទ័ពវៀតមិញ និងខ្មែរឥស្សរៈ នៅតាមបណ្តាខេត្តមួយចំនួនដែលនៅឆ្ងាយៗពីតំបន់ស្វយ័តនោះ ហើយព្រះមហាក្សត្រសីហនុ ក៏បានដឹងច្បាស់ពីចេតនាល្អរបស់មេបញ្ជាការកងទ័ពបារាំង ជាគ្រូរបស់ព្រះអង្គនោះដែរ។

នៅពេលកងទ័ពជាជនជាតិខ្មែរ នាំគ្នារត់ចោលមេបញ្ជាការជាជនជាតិបារាំង នៅទីក្រុងភ្នំពេញ ស្ទើរតែអស់ពីបន្ទាយនីមួយៗ ដើម្បីទៅចូលរួមតស៊ូទាមទារឯករាជ្យ នៅតំបន់ស្វយ័តខេត្តសៀមរាប នោះ បារាំងក៏បានបញ្ជូនកងទ័ពសហភាពបារាំង ភាគច្រើនជាជនជាតិអាហ្វ្រិកខាងជើង ជាច្រើនកងវរសេនាតូច មកពីវៀតណាមខាងត្បូង មកដាក់ពង្រាយ នៅតាមមហាវិថីនានា នៅក្នុងទីក្រុងភ្នំពេញ ជំនួសវិញ។

ចំណែក ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីវ៉ែត និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្ស ជាព្រះបិតុលារបស់ព្រះអង្គ ដែលនៅពេលនោះ មិនមានតំណែងអ្វីមួយ នៅក្នុងជួររាជរដ្ឋាភិបាល មិនត្រឹមតែមិនគាំទ្រព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យរបស់ព្រះអង្គទេ គឺថែមទាំងប្រកាន់ជំហរឈរនៅខាងបារាំង ទៅវិញ។

ព្រះអង្គម្ចាស់មុនីវ៉ែត ជាអតីតសិស្សនាយទាហាន នៅសាលាបារាំង មួយអង្គដែរនោះ បានសើចចំអកចំពោះចំណេះដឹងខាងក្បួនយុទ្ធសាស្ត្ររបស់ព្រះមហាក្សត្រសីហនុ ដោយបានវាយតម្លៃថា កងទ័ពរបស់ព្រះអង្គ សុទ្ធតែជាកងទ័ពទើបជ្រើសរើសថ្មីៗ គ្មានសមត្ថភាពក្នុងវិជ្ជាជីវៈជាកងទ័ព ដើម្បីប្រយុទ្ធនោះទេ គឺនៅខ្សោយជាងកងទ័ពបារាំង ជា



ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉ែត

មិត្តភក្តិរបស់ទ្រង់ ឆ្ងាយណាស់។

ព្រះមហាក្សត្រសីហនុ ឈ្វេងយល់ថា ការវាយតម្លៃរបស់ទ្រង់មុនីរ៉ែត ជាព្រះបិតុលារបស់ព្រះអង្គនោះ គឺពិតជាត្រឹមត្រូវ ព្រោះនៅពេលនោះ មន្ត្រីស៊ីវិលខ្លះ ត្រូវបានព្រះអង្គតែង-តាំងជាមេបញ្ជាការកងវរសេនាតូច ហើយមន្ត្រីជាន់ខ្ពស់មួយចំនួនទៀត មានតួនាទីជាចៅហ្វាយខេត្ត ដូចជា លន់ នល់ និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជាមន្ត្រីស៊ីវិល ត្រូវបានព្រះ-អង្គបំពាក់ឋានន្តរស័ក្តិជាវរសេនីយ៍ទោឆៅៗតែម្តង ដោយពុំបានរៀនសូត្រជំនាញខាងកងទ័ព អ្វីបន្តិចសោះ ពិតប្រាកដមែន ប៉ុន្តែព្រះអង្គត្រូវតែធ្វើបែបនេះ ទៅតាមសភាពការណ៍ជាក់ស្តែង។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្ស មានការអាក់អន់ព្រះទ័យជាមួយព្រះមហាក្សត្រ សីហនុ ដោយសារតែកាលពីឆ្នាំ១៩៥១ ព្រះអង្គបានតែងតាំងទ្រង់ឱ្យធ្វើនាយករដ្ឋមន្ត្រី បានតែរយៈពេល២ខែប៉ុណ្ណោះ គឺចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី២ ខែមីនា ក៏ដកទ្រង់ចេញវិញ ហើយពេលរៀបចំគណៈរដ្ឋមន្ត្រីថ្មី ជាបន្តបន្ទាប់ក្រោយមកទៀត ព្រះអង្គមិនបានតែងតាំងឱ្យទ្រង់កាន់តំណែងជារដ្ឋមន្ត្រី នៅក្រសួងណាមួយឡើយ ពិសេស នៅដើមឆ្នាំ១៩៥៣ ពេលព្រះមហាក្សត្រសីហនុ កាន់តំណែងជានាយករដ្ឋមន្ត្រី បន្តទៀត ព្រះអង្គបែរជាតែងតាំង ប៉ែន នុត ជារាជប្រតិភូនាយករដ្ឋមន្ត្រីទីស្តីការរាជរដ្ឋាភិបាលទៅវិញ។ បន្ទាប់មក ក្នុងពេលព្រះអង្គបំពេញព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ នោះ ព្រះអង្គបានតែងតាំងប៉ែន នុត ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីហិរញ្ញវត្ថុ កីឡា យុវជន និងអប់រំមូលដ្ឋាន ជាបន្តទៀត ផងដែរ។

ចំណែកព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉ែត បានមានបន្ទូលប្រាប់ឧត្តមសេនីយ៍ ដឺឡង់ក្លាដ (Delanglade) និងវីស្ទ័រអ៊ុស្សុី ថា ព្រះមហាក្សត្រសីហនុ ជាក្មួយរបស់ទ្រង់នេះ កំពុងវង្វេងវង្វាន់ក្នុងការស្រមើស្រមៃថា អស់ពីបារាំងទៅ ខ្លួនអាចយកជ័យជម្នះលើពួកកុម្មុយនិស្តវៀតមិញ ដែលកំពុងចូលមកឈ្លានពានលុកលុយព្រះរាជាណាចក្រកម្ពុជា នោះហើយមើលទៅ?

ពេលនោះ មានតែព្រះមាតាព្រះបិតារបស់ព្រះអង្គប៉ុណ្ណោះ បានសម្តែងការគាំទ្រព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យរបស់ព្រះអង្គ បើទោះបីព្រះអង្គទាំងទ្វេ ជាអ្នកនិយមបារាំងខ្លាំងយ៉ាងណាក៏ដោយ។ តែព្រះអង្គទាំងទ្វេ ក៏មានការព្រួយព្រះទ័យ ខ្លាចព្រះមហាក្សត្រសីហនុ ជាបុត្រា ធ្វើអ្វីៗហួសឆ្ងាយពីការទាមទារឯករាជ្យនោះផងដែរ។

៥៧
អនុប្រធានាធិបតី រីឆាដ និចសុន មកបំពេញទស្សនកិច្ចនៅកម្ពុជា



អនុប្រធានាធិបតីសហរដ្ឋអាមេរិក រីឆាដ និចសុន (Richard Nixon)

នៅដើមខែវិច្ឆិកា ឆ្នាំ១៩៥៣ អនុប្រធានាធិបតីសហរដ្ឋអាមេរិក រីឆាដ និចសុន (Richard Nixon) និងភរិយា ឈ្មោះប៉ាត និចសុន (Pat Nixon) ព្រមទាំងកូនស្រីតូចម្នាក់ អាយុប្រហែល១០ឆ្នាំ បានអញ្ជើញមកបំពេញទស្សនកិច្ច នៅរាជធានីភ្នំពេញ។

នៅក្នុងព្រះបរមរាជវាំង ព្រះបិតាសុរាម្រិត និងព្រះមាតាកុសមៈ បានទទួលជួបសំណេះសំណាលជាមួយអនុប្រធានាធិបតីសហរដ្ឋអាមេរិក រូបនេះ និងភរិយា ក្នុងភាពស្និទ្ធស្នាលរាក់ទាក់ និងរីករាយបំផុត។

បន្ទាប់មក រីឆាដ និចសុន (Richard Nixon) និងភរិយា ក៏បានធ្វើដំណើរទៅសម្តែងការគួរសមចំពោះព្រះមហាក្សត្រសីហនុ នៅក្នុងព្រះរាជដំណាក់របស់ព្រះអង្គ នៅក្នុង


ក្រុងសៀមរាប ជាតំបន់ស្វយ័តនោះដែរ។ តែ រីឆាដ និចសុន មិនបាននិយាយអ្វី ទាក់ទង ដល់បញ្ហាការទាមទារឯករាជ្យ រវាងព្រះអង្គ និងពួកបារាំង ដែលកំពុងប្រឈមមុខដាក់គ្នា នោះទេ ដោយគាត់គ្រាន់តែបានពាំនាំនូវសេមានចិត្ត និងការកោតសរសើរយ៉ាងកក់ក្តៅបំផុត ពីសំណាក់ប្រធានាធិបតីអាមេរិក ដ្វៃត៍ ឌី អៃសិនហាវើរ (Dwight D. Eisenhower) និង ពលរដ្ឋអាមេរិក មកថ្វាយព្រះអង្គតែប៉ុណ្ណោះ ហើយគាត់ក៏បានថ្វាយរូបថតប្រធានាធិបតី សហរដ្ឋអាមេរិក ដ្វៃត៍ ឌី អៃសិនហាវើរ ដល់ព្រះមហាក្សត្រសីហនុ ផងដែរ។

ចុងបញ្ចប់នៃដំណើរទស្សនកិច្ចនេះ អនុប្រធានាធិបតីអាមេរិក រីឆាដ និចសុន និង ភរិយា បានអញ្ជើញទៅទស្សនាប្រាង្គប្រាសាទបុរាណខ្មែរ ពិសេសប្រាសាទអង្គរវត្ត ដោយ គាត់បានសម្តែងនូវការស្ងើចសរសើរចំពោះសម្បត្តិវប្បធម៌ ជាកេរដំណែលរបស់បុព្វបុរស ខ្មែរទាំងនោះ ដោយស្មោះអស់ពីដួងចិត្ត។

អំឡុងពេលនោះដែរ មានការសែតជាច្រើន នៅលើពិភពលោក ពិសេស នៅប្រទេស បារាំង និងសហរដ្ឋអាមេរិក បានចុះផ្សាយអត្ថបទប្រមាថមើលងាយព្រះមហាក្សត្រសីហនុ ថា ព្រះអង្គបានក្លាយជាមនុស្សឆ្កួត ទៅហើយ ហើយនរណាក៏ដឹងដែរថា ការរំខានដល់ មនុស្សឆ្កួត គឺជាអំពើមិនល្អទេ។

ពិសេស នៅពេលព្រះអង្គប្រកាសបង្កើតកងជីវពល នារីភ្លាហាន មានសុទ្ធតែកាំភ្លើង ធ្វើពីឈើ តែដូចកាំភ្លើងមែនទែន ព្រមទាំងមាន កាំបិត ពូថៅ ដើម្បីត្រៀមប្រយុទ្ធជាមួយ កងទ័ពបារាំង នោះ ក៏មានការសែតមួយចុះផ្សាយថា ព្រះអង្គបានក្លាយទៅជាមនុស្សឆ្កួត មែនទែនហើយ ព្រោះមិនដែលមានប្រទេសណា យកកាំភ្លើងធ្វើពីឈើ និងកាំបិតពូថៅ ទៅ ធ្វើសង្គ្រាម វាយបណ្តេញកងទ័ពបរទេសជាគូសត្រូវឈ្លានពាន ឱ្យចេញពីប្រទេសវិញ ទទួល ជោគជ័យនោះទេ? រឿងរ៉ាវព្រះមហាក្សត្រសីហនុ បង្កើតកងជីវពលនារីភ្លាហាន កាន់កាំភ្លើង ធ្វើពីឈើនេះ ត្រូវបានការសែតបរទេសផ្សេងៗទៀត យកទៅចុះផ្សាយបន្ត បណ្តាលឱ្យកាន់តែ ល្បីសុសសាយខ្លាំងថែមទៀត។

ពាក់ព័ន្ធដល់ការបង្កើតកងជីវពល នារីភ្លាហាន មានតែកាំភ្លើងធ្វើពីឈើនេះ ទស្សនាវដ្តី



កងជីវពល នារីភ្លាហាន ហានតែកាំភ្លើងធ្វើពីឈើ

"ប៉ារីសម៉ាត់" របស់បារាំង បានចុះផ្សាយថា ព្រះមហាក្សត្រសីហនុ ប្រៀបដូចជាសត្វគួរឱ្យខ្លាច និងបានចោទប្រកាន់ព្រះអង្គ យ៉ាងអយុត្តិធម៌ថា ព្រះអង្គបានលក់កាំភ្លើងឈើ ទៅឱ្យកងជីវពល នារីក្លាហានរបស់ព្រះអង្គ ក្នុងតម្លៃដ៏ថ្លៃបំផុត ទៀតផង។

តែការពិត កាំភ្លើងឈើទាំងនោះ គឺកងជីវពល នារីក្លាហានខ្លួនឯង ឬអ្នកភូមិមានវ័យចំណាស់ៗ បានយកកំណាត់ឈើផ្សេងៗ មកចាំង ធ្វើជារាងដូចកាំភ្លើងមែនទែន ដោយខ្លួនឯង នៅភូមិស្រុករៀងៗខ្លួនតែប៉ុណ្ណោះ ដោយពុំបានទិញដូរនរណាឡើយ។

កាសែត "ថែម" (Time) នៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស បានចុះផ្សាយបញ្ជិតបញ្ជៀងថា បារាំង ប្រាកដជាជួបការលំបាកក្នុងការដោះស្រាយជាមួយយុវជន ជាមេដឹកនាំម្នាក់ ដែលមានចរិតសាវា មិននឹងនដូច្នេះ ជាមិនខាន។

នេះជាការសរសេរសំដៅទៅលើព្រះមហាក្សត្រសីហនុ យ៉ាងពិតប្រាកដ តែ ក៏មានកាសែតដ៏ធំមួយ នៅទីក្រុងញូវដេលី ប្រទេសឥណ្ឌា បានចុះផ្សាយអត្ថបទមួយ ដើម្បីតបតទៅកាសែត "ថែម" (Time) នោះវិញថា នេះគ្រាន់តែជាពាក្យសម្តីក្នុងន័យឈ្នានីស ព្យាបាទដើម្បីឱ្យសាធារណមតិសាកលលោក ប្រឆាំងនឹងអ្នកស្នេហាជាតិម្នាក់ ដែលស្រលាញ់មាតុភូមិខ្លួន ដូចជាជនជាតិអង់គ្លេស ឬបារាំង ដែលស្រលាញ់មាតុភូមិរបស់ខ្លួន យ៉ាងដូច្នោះដែរ ។

កាសែតដដែលនោះ ក៏បានដាក់ជាសំណួរថា កាលនៅក្នុងសង្គ្រាមលោកលើកទី២ កងទ័ពបារាំង ច្រើនម៉ឺននាក់ត្រូវពលីជីវិត ដើម្បីអ្វី? គឺមិនដើម្បីឯករាជ្យ និងសេរីភាពនេះទេឬ? ចុះហេតុអ្វី បានជាពេលនេះ មេដឹកនាំម្នាក់របស់កម្ពុជា ដឹកនាំការតស៊ូទាមទារឯករាជ្យ និងសេរីភាព ឱ្យប្រជាជាតិរបស់ខ្លួនមិនបាន? ។

៥៨
កម្ពុជា ទទួលបានឯករាជ្យបរិបូរណ៍



ព្រះមហាក្សត្រសីហនុ

ក្រោយការចរចាយ៉ាងតឹងសរសៃក រវាង ប៉ែន នុត ឧបនាយករដ្ឋមន្ត្រីកម្ពុជា ជាមួយ វីស្ទ័រ រុស្ស៊ី ស្នងការជាន់ខ្ពស់បារាំង និងឧត្តមសេនីយ៍ ដឺឡង់ក្លាដ(Delanglade) អគ្គបញ្ជាការយោធាបារាំង ប្រចាំប្រទេសកម្ពុជា មក កិច្ចព្រមព្រៀងដ៏ពេញលេញមួយ ត្រូវបានបង្កើតឡើង។

ក្នុងកិច្ចព្រមព្រៀងស្តីពីការផ្ទេរអំណាចរបស់បារាំង មកឱ្យខ្មែរវិញនោះ ពិធីសារនៃការផ្ទេរអំណាចតុលាការ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ បានចែងថា រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង បានសម្រេចផ្ទេរ និងប្រគល់អំណាចតុលាការ ឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាវិញ ហើយការផ្ទេរ និងប្រគល់អំណាចតុលាការនេះ នឹងត្រូវចូលជា

ជរមាន ចាប់ពីថ្ងៃចុះហត្ថលេខា នាថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ នេះតទៅ។

ពិធីសារនៃការផ្ទេរអំណាចប៉ូលិស និងសន្តិសុខ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ នោះដែរ បានចែងថា រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង បានសម្រេចផ្ទេរអំណាចប៉ូលិស និងសន្តិសុខគ្រប់បែបយ៉ាង ដែលខ្លួនកាន់កាប់តាំងពីដើម រហូតដល់សព្វថ្ងៃនេះ មកឱ្យ រាជរដ្ឋាភិបាលកម្ពុជា វិញ។

លិខិតលេខ២៧៥៦ / C ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ របស់អគ្គបញ្ជាការកង ទ័ពបារាំង ប្រចាំកម្ពុជា ឧត្តមសេនីយ៍ ដឺឡង់ក្លាដ (Delanglade) ផ្ញើជូនឧបនាយក រដ្ឋមន្ត្រីប៉ែន នុត មានខ្លឹមសារជាអាទិថា ខ្ញុំមានកិត្តិយសនឹងបញ្ជាក់ជូនលោកឧបនាយក រដ្ឋមន្ត្រីថា បន្ទាប់ពីការផ្ទេរអំណាចខាងតុលាការ ប៉ូលិស និងសន្តិសុខ មក តួនាទីទាំងឡាយ នៃកងអាវុធហត្ថរបស់បារាំង ក៏ត្រូវតែបញ្ចប់សកម្មភាពផងដែរ។

បន្ទាប់មក ពិធីសារនៃការផ្ទេរអំណាចយោធា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៥៣ បាន ចែងថា រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង បានសម្រេចផ្ទេរអំណាចទាំងអស់ ក្នុងវិស័យ យោធា មកឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យ៉ាងបរិបូរណ៌ ក្នុងអធិបតេយ្យជាតិ របស់ខ្លួន រួមទាំងកងឯកភាពយោធាទាំងអស់ផងដែរ។

ក្នុងខែតុលា ឆ្នាំ១៩៥៣ ទស្សនាវដ្តីប្រចាំសប្តាហ៍ របស់បារាំង ឈ្មោះ "ប៉ារីសម៉ាត់" បានចុះផ្សាយអត្ថបទវិភាគមួយ ទាក់ទងដល់ដំណាក់កាលទី២ នៃព្រះរាជបូជនីយកិច្ច ទាមទារឯករាជ្យរបស់ព្រះមហាក្សត្រសីហនុ ថា ឧត្តមសេនីយ៍ណារ៉ា (Narra) មេបញ្ជាការ កងទ័ពបារាំង ប្រចាំឥណ្ឌូចិនទាំងមូល កំពុងប្រឈមមុខនឹងសមរភូមិ២ គឺទី១. សមរភូមិ ដែលជាការគំរាមកំហែងរបស់កងទ័ពវៀតមិញ និងទី២. សមរភូមិ ដែលបង្កឡើង ដោយសារ ការរឹងរូសរបស់ស្តេចដ៏ចម្លែក បានបោះបង់ចោលរាជធានីភ្នំពេញ របស់ខ្លួន ទៅបោះទីតាំង នៅក្បែរប្រាសាទអង្គរវត្ត ក្នុងខេត្តសៀមរាប ដើម្បីទាមទារឯករាជ្យឱ្យប្រទេសជាតិ របស់ ព្រះអង្គ។ ប៉ុន្តែ រហូតមកដល់ពេលនេះ ទោះបីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀង បារាំង-ខ្មែរ ហើយក៏ដោយ ក៏ព្រះអង្គពុំទាន់ចាកចេញពីតំបន់ស្វយ័តនោះនៅឡើយ។

តាមការពិត ព្រះមហាក្សត្រសីហនុ គ្រោងនឹងយាងត្រលប់ចូលរាជធានីភ្នំពេញ វិញ ដែរ ព្រោះនៅក្នុងខែតុលា នោះ បារាំង បានយល់ព្រមតាមការទាមទាររបស់ព្រះអង្គគ្រប់យ៉ាង អស់ទៅហើយ។ ប៉ុន្តែ បើតាមការគន់គូររបស់ហោរាប្រចាំព្រះបរមរាជវាំង ដែលព្រះមាតា របស់ព្រះអង្គមានជំនឿជឿជាក់បំផុតនោះ បានកំណត់ថា ត្រូវយកថ្ងៃ៩ ខែវិច្ឆិកា ធ្វើជាថ្ងៃ នក្ខត្តឫក្ស នៃការយាងត្រលប់ចូលព្រះបរមរាជវាំង នោះវិញ។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នៅលើភ្នំដងរែក សឺង ង៉ុកថាញ់ មេដឹកនាំប្រជា ចលនាឥស្សរៈខ្មែរបម្រើជាតិ បានបើកសម័យប្រជុំមួយ ដើម្បីជជែកពិភាក្សាគ្នាពីបញ្ហាបារាំង ប្រគល់ឯករាជ្យឱ្យសម្តេចសីហនុ ផង និងពីបញ្ហាចូលរួមរស់ក្នុងសង្គមជាតិវិញផងដែរ។

អង្គប្រជុំបានសម្រេចថា៖ ១.ក្នុងរយៈពេលសម្តេចសីហនុ កំពុងទាមទារឯករាជ្យ ស្ថានការណ៍នៅក្នុងពិភពលោក និងក្នុងភូមិភាគ ជាពិសេស បញ្ហាសង្គ្រាមនៅឧបទ្វីបកូរ៉ េ និងបញ្ហាសង្គ្រាមនៅឧបទ្វីបឥណ្ឌូចិន ត្រូវតែមានដំណោះស្រាយ ដោយសន្តិសីទអន្តរជាតិ មួយ។ នៅឧបទ្វីបឥណ្ឌូចិន ពួកវៀតមិញ បានបង្កើនសកម្មភាពយោធា ដើម្បីវាយប្រហារ ផ្តាច់ព្រ័ត្រ នៅប្រទេសឡាវ ហើយពួកគេបានព្យាយាមពង្រឹងពង្រីកទីតាំងរបស់គេ នៅ លើទឹកដីខ្មែរ តាមរយៈចលនាតស៊ូរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ដឹកនាំដោយសឺង ង៉ុក មិញ ផងដែរ ។ សឺង ង៉ុកថាញ់ បានលើកឡើងថា នៅចុងខែមេសា ឆ្នាំ១៩៥០ តាមការ អំពាវនាវរបស់សឺង ង៉ុកមិញ ពួកវៀតមិញ បានបញ្ជូនកងទ័ពរៀបរយ ប្រមាណ៣ពាន់នាក់ ពីណាំបូ(កម្ពុជាក្រោម)ឲ្យចូលមកបោះទីតាំង នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង។

នេះជាគ្រោះថ្នាក់ធ្ងន់ធ្ងរ ដល់ប្រទេសកម្ពុជា យ៉ាងពិតប្រាកដ ដូច្នេះឯករាជ្យ ដែល សម្តេចសីហនុ ទទួលបានពីបារាំងនោះ ជាឯករាជ្យក្លែងក្លាយ ព្រោះនៅលើទឹកដីកម្ពុជា នៅតែមានមូលដ្ឋានកងទ័ពបរទេស គឺកងទ័ពបារាំង និងកងទ័ពវៀតមិញ នៅឡើយ។ តែបើទោះបីជាឃើញកស្តតាង ជាគ្រោះថ្នាក់ដ៏ធំដល់ប្រទេសជាតិ យ៉ាងនេះក៏ដោយ ក៏អង្គ ប្រជុំបានសម្រេចចិត្តថា នៅពេលខាងមុខ ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ត្រូវតែចូលរួម ជាមួយរាជរដ្ឋាភិបាល ជាចាំបាច់ ដើម្បីនាំគ្នាទប់ទល់នឹងគ្រោះមហន្តរាយ ដែលអាចនឹង



ក្បួនកងទ័ពសហគាមពាវាំង នៅមុខព្រះបរមរាជវាំង

កើតមានឡើង ដោយសារពួកវៀតមិញ នេះ។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រជារាស្ត្រទាំងឡាយរស់នៅតំបន់ដែលត្រូវក្បួនព្រះទីនាំងរថយន្តរបស់ព្រះមហាក្សត្រសីហនុ ត្រូវឆ្លងកាត់ពីខេត្តសៀមរាប មករាជធានីភ្នំពេញ មានចម្ងាយប្រមាណ៣០០គីឡូម៉ែត្រ បាននាំគ្នារង់ចាំទទួលស្វាគមន៍សម្តែងគារវភក្តី ចំពោះព្រះរាជដំណើរយ៉ាងអធិកអធម ក្រោមសម្រែកជ័យឃោសខ្លាំងៗថា ជយោ! ព្រះមហាក្សត្រ ជយោ!ព្រះមហាក្សត្រ ។

លុះមកដល់ក្នុងព្រះបរមរាជវាំង ព្រះសង្ឃរាប់រយអង្គបាននាំគ្នាសូត្រជយន្តោ ប្រសិទ្ធពរជ័យ ថ្វាយព្រះអង្គយ៉ាងកងរំពង។

ព្រឹកឡើង ថ្ងៃទី៩ វិច្ឆិកា ឆ្នាំ១៩៥៣ រីស្ទ័រុស្ស៊ី ស្នងការជាន់ខ្ពស់បារាំង និងឧត្តមសេនីយ៍ដឺឡង់ក្លាដ អគ្គមេបញ្ជាការកងទ័ពបារាំង ប្រចាំប្រទេសកម្ពុជា បានចូលរួមជាអធិបតី ជាមួយព្រះមហាក្សត្រខ្មែរ ក្នុងពិធីផ្ទេរអំណាចយោធាមកឱ្យកម្ពុជា វិញ ដោយមានក្បួនព្យុហយាត្រារបស់កងជីវពល នារីក្លាហាន ក្នុងឯកសណ្ឋានពណ៌គគីរ មកពីគ្រប់ទិសទី

ក្នុងព្រះរាជាណាចក្រកម្ពុជា ប្រមាណ១០០០នាក់ យ៉ាងគគ្រឹកគគ្រេង។

ជាមួយគ្នានោះ ក៏មានក្បួនកងទ័ពសហភាពបារាំង រួមមាន ជនជាតិសេណេហ្គាល់, ម៉ាដាហ្គាស្កា, អាល់ហ្សេរី, ទុយនីស៊ី និងម៉ារ៉ុក ដែលត្រូវចាកចេញពីប្រទេសកម្ពុជា ទៅបន្ត ការប្រយុទ្ធនៅប្រទេសវៀតណាម និងឡាវ បានចូលរួមក្នុងព្យុហយាត្រា នោះដែរ។

ទស្សនាវដ្តី "ប៉ារីសម៉ាត់" របស់បារាំង បានចុះផ្សាយបទអត្ថាធិប្បាយស្តីពីការចាកចេញរបស់បារាំង នោះដែរ ដោយស្តាប់ទៅ គួរឱ្យស្រងេះស្រងោចថា ក្រោមផ្ទៃមេឃខ្វែងខ្វាត់ដោយផ្លេកបន្ទោរ និងសូរសន្ធឹកផ្គរលាន់ ក្រោមក្រសែភ្នែកឥស្សរជន៣នាក់ គឺទី១. រីស្ស៊ារុស្ស៊ី អគ្គស្នងការជាន់ខ្ពស់បារាំង, ទី២. ឧត្តមសេនីយ៍ ដឺឡង់ក្លាដ អគ្គមេបញ្ជាការកងទ័ពបារាំង ប្រចាំប្រទេសកម្ពុជា និងទី៣. ព្រះមហាក្សត្រសីហនុ ដែលត្រូវបានគេលើកតម្កើងជាវីរបុរសជាតិនោះ គឺជាការស័ក្តិសមបំផុត ចំពោះព្រះអង្គ ក្នុងការលើកតម្កើងនេះ។

ប៉ុន្តែព្រះអង្គបានឈរគំនាប់ក្បួនដំណើរចាកចេញរបស់កងទ័ពបារាំង ដោយទឹកមុខក្រៀមក្រំ ដូចស្តេចហង់រីទី៤ នៃប្រទេសបារាំង ពេលឈរគំនាប់ក្បួនដំណើរចាកចេញរបស់កងទ័ពអេស្ប៉ាញ៉ុល កាលពីអតីតកាល តែខណៈនេះ ព្រះអង្គមិនមែនជាស្តេចហង់រីទី៤ ហើយប្រទេសបារាំង ក៏មិនមែនជាអ្នកឈ្លានពានប្រទេសកម្ពុជា នោះដែរ គឺគ្រាន់តែជាអ្នកការពារ និងជាអាណាព្យាបាលកម្ពុជា ប៉ុណ្ណោះ។

ក្រោយថ្ងៃធ្វើពិធីប្រកាសឯករាជ្យ បាន២សប្តាហ៍ គឺនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រសីហនុ បានរៀបចំរាជរដ្ឋាភិបាលថ្មីមួយទៀត ដោយបានតែងតាំង ចាន់ ណាក (ធ្លាប់ធ្វើជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលពីឆ្នាំ១៩៥០) ឱ្យឡើងធ្វើជានាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន, សុន វ៉ឺនសៃ (ជាអតីតរដ្ឋមន្ត្រីក្រសួងការពារជាតិរបស់គណបក្សប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៤៧) ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសន្និសីទ។

មូលហេតុនាំឱ្យព្រះអង្គតែងតាំងសុន វ៉ឺនសៃ ជាមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាធិបតេយ្យ ឱ្យធ្វើជាឧបនាយករដ្ឋមន្ត្រី នេះ ក៏ដោយសារតែសុន វ៉ឺនសៃ បានបង្ហាញពីភាពស្មោះត្រង់ចំពោះព្រះអង្គ ដោយបានរាយការណ៍ថ្វាយព្រះអង្គពីរឿងគាត់លួចបញ្ចេញអាវុធ

គ្រាប់រំសេវ ថ្នាំពេទ្យ តាមបញ្ជាមេដឹកនាំគណបក្សប្រជាធិបតេយ្យ ទៅឱ្យចលនាតស៊ូរបស់
សឺង ង៉ុកថាញ់ ពេលគាត់ធ្វើជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ កាលពីខែ
តុលា ឆ្នាំ១៩៥១ ដល់ខែមិថុនា ឆ្នាំ១៩៥២។

ជាមួយគ្នានេះ ព្រះអង្គបានតែងតាំង ហាក់ ម៉ុងសេង ជារដ្ឋមន្ត្រីក្រសួងការបរទេស,
ឃឹម ទិត ជារដ្ឋមន្ត្រីក្រសួងការពារជាតិ, ឡៅ ប៊ុនប៉ា ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ, យ៉ែម
សំបូរ (ធ្លាប់កកូរកកាយផ្ទៃក្នុងរបស់គណបក្សប្រជាធិបតេយ្យពីមុន) ជារដ្ឋមន្ត្រីក្រសួង
សេដ្ឋកិច្ច, ព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា ជារដ្ឋមន្ត្រីក្រសួងសាធារណសិក្សា កីឡា និង
យុវជន, ឃួន ណៃ ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល សង្គមកិច្ច និងការងារ, នាល ផ្លែង ជារដ្ឋ
មន្ត្រីក្រសួងសាធារណការ និងទូរគមនាគមន៍, សម ញាណ (ឪពុកសម សារី)ជារដ្ឋមន្ត្រី
ក្រសួងធម្មការ វិចិត្រសិល្បៈ និងពុទ្ធិកសិក្សា, ម៉ៅ ចយ ជារដ្ឋមន្ត្រីក្រសួងកិច្ចការកសិករ,
ប្រាក់ សារិន ជាអនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកព័ត៌មាន សារព័ត៌មាន
និងឃោសនាការ, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ឥស្សារ៉ូ ជាអនុរដ្ឋលេខាធិការអប់រំជាតិ ទទួលបន្ទុក
អប់រំមូលដ្ឋាន យុវជន និងកីឡា និងព្រះអង្គម្ចាស់នរោត្តម វិរីយ៉ា ជាអនុរដ្ឋលេខាធិការ
មហាផ្ទៃ ទទួលបន្ទុកនគរបាល។

៥៩
ពួកខ្មែរឥស្សរៈ និងពួកវៀតមិញ មិនទទួលស្គាល់ឯករាជ្យ ថ្ងៃទី៩វិច្ឆិកា



បក្សប្រជាជនបដិវត្តន៍ខ្មែរ ដឹកនាំដោយសឺន ង៉ុកមិញ និងណាត មួន ហៅម៉ៃមួន (រូបពាក់អាវខ្មៅ)

ទោះបីប្រទេសបារាំង បានប្រគល់ឯករាជ្យដល់កម្ពុជា ជាផ្លូវការ នៅថ្ងៃទី៩ ខែវិច្ឆិកា នោះ ក៏ពិតមែន តែកងទ័ពបារាំង ចំនួន៦០០០នាក់ កំពុងបោះទីតាំង នៅក្នុងខេត្តក្រចេះ ហើយទាហានខ្មែរ ចំនួន៣កងវរសេនាតូច និង១០កងអនុសេនាតូចទៀត នៅតែស្ថិតនៅក្រោមបញ្ជារបស់នាយទាហានជាន់ខ្ពស់បារាំងដដែល។ កម្លាំងទាហានទាំងអស់នោះ បានបោះទីតាំង នៅប៉ែកខាងកើតទន្លេមេគង្គ ដើម្បីត្រៀមទប់ស្កាត់សកម្មភាពវាយប្រហាររបស់ពួកវៀតមិញ និងខ្មែរឥស្សរៈ ។

ចំណែកពួកវៀតមិញ ពួកខ្មែរឥស្សរៈរបស់សឺង ង៉ុកមិញ និងពួកប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ របស់សឺង ង៉ុកថាញ់ នៅព្រំដែនថៃ ព្រមទាំងមន្ត្រីគណបក្សប្រជាធិបតេយ្យ មួយចំនួន នៅក្នុងទីក្រុងភ្នំពេញ មិនព្រមទទួលស្គាល់ថា ថ្ងៃទី៩ ខែវិច្ឆិកា ជាថ្ងៃព្រះមហាក្សត្រសីហនុ ទាមទារបានឯករាជ្យពីបារាំង នោះ ជាដាច់ខាត។ ពួកគេនៅតែ



ព្រះមហាក្សត្រសីហនុ បើកយុទ្ធនាការបោសសម្អាតកងទ័ពវៀតមិញ និងខ្មែរឥស្សរៈ

ចាត់ទុកថា បារាំង កំពុងបន្តធ្វើអាណានិគមត្រួតត្រាលើប្រទេសកម្ពុជា ដូចមុនដដែល ។

ពេលនោះដែរ បក្សប្រជាជនបដិវត្តន៍ខ្មែរ បានបង្កើតរដ្ឋាភិបាលតស៊ូមួយ ដោយមាន សឺង ង៉ុកមិញ ជានាយករដ្ឋមន្ត្រី, ចាន់ សម័យ ជាឧបនាយករដ្ឋមន្ត្រី, ទូ សាមុត ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, កែវ មុនី ជារដ្ឋមន្ត្រីក្រសួងការបរទេស, ស៊ីវ ហេង ជារដ្ឋមន្ត្រីក្រសួងការពារជាតិ, ចូវ យឺន ជារដ្ឋមន្ត្រីក្រសួងសិក្សាធិការ, លាវ កែវមុនី ជារដ្ឋមន្ត្រីក្រសួងកិច្ចការជនជាតិ និងសុះ ម៉ាន់ ជារដ្ឋមន្ត្រីកិច្ចការសាសនា ។

នៅក្នុងខែធ្នូ ឆ្នាំ១៩៥៣ កងទ័ពវៀតមិញ និងខ្មែរឥស្សរៈ ចាប់ផ្តើមធ្វើសកម្មភាពនៅគ្រប់ទិសទី។ ពេលនោះ កងខេមរភូមិន្ទរបស់ព្រះមហាក្សត្រសីហនុ ក៏បើកប្រតិបត្តិការសឹកជាបន្តបន្ទាប់ ដើម្បីបង្ក្រាបពួកនោះ វិញដែរ ។

ប្រតិបត្តិការសឹកមួយ ឈ្មោះ" ប្រតិបត្តិការសឹកជ្រូកព្រៃ " ត្រូវបានធ្វើឡើង ដើម្បីបោសសម្អាតកងទ័ពវៀតមិញ និងពួកខ្មែរឥស្សរៈ នៅក្នុងខេត្តកំពង់ស្ពឺ និងប្រតិបត្តិការសឹកមួយទៀត ឈ្មោះ" ប្រតិបត្តិការសឹកកន្ទេះ " ត្រូវបានធ្វើឡើងនៅក្នុងខេត្តតាកែវ និងខេត្តកំពត ។

ជាមួយគ្នានោះ ប្រតិបត្តិការសឹក២ទៀត គឺ "ប្រតិបត្តិការសឹកព្យាយាម" និង" ប្រតិបត្តិការសឹកប្រវឹក " ត្រូវបានធ្វើឡើង នៅក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង ហើយចុងក្រោយ

គឺ"ប្រតិបត្តិការសឹកសាមគ្គី" បានធ្វើឡើង នៅក្នុងខេត្តបាត់ដំបង ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៥៣ ក្រោមព្រះរាជកិច្ចដឹកនាំផ្ទាល់របស់ព្រះមហាក្សត្រ សីហនុ និងឧត្តមសេនីយ៍បារាំងម្នាក់ ឈ្មោះសេតា ព្រមទាំងមេទ័ពសំខាន់ៗដូចជា លន់ នល់, ដាប ឈួន និងពុត ឆាយ បានដឹកនាំកងទ័ពប្រមាណ៥០០០នាក់ បើកប្រតិបត្តិការ សឹកជាទ្រង់ទ្រាយធំមួយ ដោយមានយន្តហោះទម្លាក់គ្រាប់បែក ចូលរួមផង។ ប៉ុន្តែប្រតិបត្តិ ការសឹកទាំងប៉ុន្មានខាងលើនេះ ដូចជាមិនទទួលបានលទ្ធផលអ្វីជាជុំកំភួនឡើយ។

ចំណែក នៅខៀនបៀនភូ នៅភាគខាងជើងប្រទេសវៀតណាម ជាមូលដ្ឋានធំជាង គេរបស់កងទ័ពបារាំង ប្រចាំនៅតំបន់ឥណ្ឌូចិន ត្រូវបានកងទ័ពវៀតមិញ ធ្វើការឡោមព័ទ្ធ តាំងពីថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៥៤ មកម្ល៉េះ។

នៅប៉ែកខាងជើងប្រទេសកម្ពុជា ក៏មានកងទ័ពវៀតមិញ មួយកងវរសេនាតូច បាន ឆ្លងពីក្នុងទឹកដីប្រទេសឡាវ មកវាយប្រហារទៅលើកងទ័ពបារាំង កំពុងបោះទីតាំងនៅក្នុង ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដណ្តើមបានទីប្រជុំជនតូចៗមួយចំនួន។

ជាមួយគ្នានេះ កងទ័ពចម្រុះខ្មែរ-វៀតមិញ ជាច្រើន ក៏បានឆ្លងព្រំដែនពីប្រទេស វៀតណាមភាគខាងត្បូង ចូលមកប៉ែកខាងកើតប្រទេសកម្ពុជា វាយប្រហារទៅលើកងវរ-សេនាតូចថ្មើរជើងលេខ៩ របស់បារាំង បណ្តាលឱ្យអន្តរាយអស់មួយកងអនុសេនាតូច។



ដាប ឈួន និងពុត ឆាយ បានចូលរួមក្នុងប្រតិបត្តិការសឹក នោះដែរ

៦០
ទ្រង់ចន្ទរង្សី ចុះចូលជាមួយរាជរដ្ឋាភិបាល



ព្រះអង្គម្ចាស់នរោត្តម ចន្ទរង្សី

ក្រោយពីទាមទារបានឯករាជ្យបរិបូរណ៌មក ព្រះមហាក្សត្រសីហនុ បានចាត់ឱ្យមន្ត្រីនៅក្នុងព្រះបរមរាជវាំង ឈ្មោះ ប៊ូ ហ៊ាង ជាព្រះរាជតំណាងទៅជួបចរចាជាមួយព្រះអង្គ ម្ចាស់នរោត្តម ចន្ទរង្សី ដើម្បីឱ្យទ្រង់វិលត្រលប់មករួមរស់ក្នុងសង្គមជាតិវិញ។ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ១៩៥៤ ទ្រង់ចន្ទរង្សី បានសម្រេចចិត្តផ្តាច់ខ្លួនចេញពីចលនាតស៊ូប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ របស់សឺង ង៉ុកថាញ់ និងបោះបង់តួនាទីជាមេបញ្ជាការភាគទក្សិណទិស ហើយព្រមទម្លាក់អាវុធ ចុះចូលជាមួយព្រះមហាក្សត្រសីហនុ។

អតីតអ្នកតស៊ូជាមួយទ្រង់ចន្ទរង្សី ម្នាក់ ឈ្មោះ នី វ៉ាន់ធី បានអះអាងថា តាមពិតពេលនោះ កងទ័ពរបស់ទ្រង់មានរាប់ម៉ឺននាក់ ចំនួននេះសមនឹងទទួលបានឋានៈជាកងវរៈសេនាធំ ទើបជាការត្រឹមត្រូវ។ តែរាជរដ្ឋាភិបាលព្រមទទួលស្គាល់ និងបញ្ចូលកងទ័ពទ្រង់



ពិធីចុះចូលរបស់ទ្រង់ចន្ទរង្សី

ទៅក្នុងជួរកងយោធពលខេមរភូមិន្ទ ចំនួន១០០០នាក់ និងមានឋានៈត្រឹមតែជាកងវរសេនាតូចប៉ុណ្ណោះ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥៤ រាជរដ្ឋាភិបាល បានប្រារព្ធធ្វើពិធីចុះចូលជាផ្លូវការ នៅក្នុងបន្ទាយរបស់ទ្រង់ នៅក្នុងស្រុកច្បារមន ខេត្តកំពង់ស្ពឺ ដោយបានចែកឯកសណ្ឋានកងយោធពលខេមរភូមិន្ទ ក្នុងម្នាក់ ១សម្រាប់ ដល់កងទ័ពរបស់ទ្រង់ បានគ្រប់ទាំង១០០០នាក់ តែការបញ្ចូលឈ្មោះទៅក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ បានត្រឹមតែចំនួន៣០០នាក់ប៉ុណ្ណោះ។ នៅសល់៧០០នាក់ទៀត រាជរដ្ឋាភិបាលបានសន្យាថា នឹងបញ្ចូលក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទជាបន្តបន្ទាប់មកទៀតឱ្យអស់ យ៉ាងយូរក្នុងរយៈពេល៧ខែទៀត។

ដូចបានសន្យារបស់ព្រះមហាក្សត្រសីហនុ នៅពេលចរចាគ្នាដំបូង ជាមួយមន្ត្រីនៅក្នុងព្រះបរមរាជវាំង ឈ្មោះ ប៊ូ ហ៊ាង ជាព្រះរាជតំណាងនោះ ទ្រង់ចន្ទរង្សី ត្រូវបានរាជរដ្ឋាភិបាលបំពាក់ឋានន្តស័ក្តិ ជាវរសេនីយ៍ត្រី(ស័ក្តិ៤), ហម ខាន់ និងចាន់ តោត្រេស ត្រូវបានបំពាក់ឋានន្តស័ក្តិ ជាអនុសេនីយ៍ឯក(ស័ក្តិ៣), សុកសេង រឿងមុនី ត្រូវបានបំពាក់ឋានន្តស័ក្តិ ជាអនុសេនីយ៍ទោ (ស័ក្តិ២) និងនី វ៉ាន់ធី ត្រូវបានបំពាក់ឋានន្តស័ក្តិ ជាអនុសេនីយ៍ត្រី (ស័ក្តិ១)។

ក្នុងពិធីចុះចូលជាផ្លូវការនោះ អតីតកងទ័ពខ្មែរឥស្សរៈរបស់ទ្រង់ចន្ទរង្សី ទាំង១០០០

នាក់ ត្រូវបានប្រកាសជាកងវរសេនាតូចស្វយ័តលេខ៣ របស់កងយោធពលខេមរភូមិន្ទ។ ដោយសាររាជរដ្ឋាភិបាល បានបញ្ចូលអតីតកងទ័ពខ្មែរឥស្សរៈរបស់ទ្រង់ចន្ទរង្សី ក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ជាលើកទី១ បានត្រឹមតែចំនួន៣០០នាក់ប៉ុណ្ណោះ ដូច្នេះ រៀងរាល់ខែ កងទ័ពចំនួន៣០០នាក់ ដែលត្រូវបានបញ្ចូលក្នុងក្របខ័ណ្ឌ មានប្រាក់បៀវត្សរ៍ ហើយនោះ ត្រូវចែករំលែកប្រាក់ខែរបស់ខ្លួន ចំនួន២ភាគ៣ ដើម្បីយកទៅជួយឧបត្ថម្ភដល់ កងទ័ពដែលមិនទាន់បានបញ្ចូលក្នុងក្របខ័ណ្ឌ ចំនួន៧០០នាក់ទៀតនោះផងដែរ។

ពេលវេលាចេះតែកន្លងផុតទៅ ពិសេស ក្រោយពេលរាជរដ្ឋាភិបាល នាំអតីតមេខ្មែរឥស្សរៈ៤នាក់ គឺនរោត្តម ចន្ទរង្សី ,ដាប ឈួន, ពុត ឆាយ និងសារ៉ាង រង្ស ទៅចូលរួមប្រជុំនៅក្នុងសន្និសីទក្រុងហ្សឺណែវ ដើម្បីឱ្យអន្តរជាតិមើលឃើញថា នៅកម្ពុជា ទទួលបានឯករាជ្យ បរិបូរណ៌ហើយ គ្មានចលនាតស៊ូខ្មែរឥស្សរៈអ្វីទៀតទេ ពួកគេបានមកចុះចូលជាមួយរាជរដ្ឋាភិបាលអស់ហើយ គឺមានតែវត្តមានកងទ័ពវៀតមិញ ចូលមកឈ្លានពានកម្ពុជា ប៉ុណ្ណោះ ក៏រាជរដ្ឋាភិបាលនៅតែមិនព្រមបញ្ចូលកងទ័ពរបស់ទ្រង់ចន្ទរង្សី ដែលនៅសល់ ៧០០នាក់ទៀតនោះ ក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ តាមសន្យារបស់ខ្លួនដដែល។

ដោយមានការអាក់អន់ចិត្តពីបញ្ហានេះ និងបញ្ហាមួយចំនួនទៀត ពិសេស ដោយសារឮថា ទូតសហរដ្ឋអាមេរិក នៅទីក្រុងភ្នំពេញ សន្យាថា ជួយសម្ភារសឹក ផងនោះ ទ្រង់ចន្ទរង្សី បានរៀបចំផែនការឱ្យមានការធើបបះបោរមួយ។ ដោយសង្ឃឹមថា អាមេរិក នឹងទម្លាក់ជំនួយសម្ភារសឹកតាមឆត្រយោង ក្នុងពេលឆាប់ៗ ដើម្បីជាជំនួយដល់ការធើបបះបោរនោះ ទ្រង់ចន្ទរង្សី បានបញ្ជាឱ្យអនុសេនីយ៍ត្រី នី វ៉ាន់ធី រៀបចំឃ្លាំងផ្ទុកសម្ភារសឹក នៅក្នុងព្រៃជ្រៅមួយកន្លែង ក្បែរភ្នំព្រៃ ជាទីតាំងឃ្លាំងចាស់ សម្រាប់ដាក់សម្ភារសឹករបស់កងទ័ពទ្រង់ ពីមុនមក នៅប៉ែកខាងជើងខេត្តកំពង់ស្ពឺ ដើម្បីត្រៀមដាក់សម្ភារសឹក ដែលមន្ត្រីទូតសហរដ្ឋអាមេរិក សន្យាទម្លាក់ឱ្យតាមឆត្រយោងនោះ។

តែគម្រោងការបះបោរនេះត្រូវបែកការណ៍ ដោយសារឈ្មោះ ហ៊ិល សារ៉ែន ជាលេខាធិការផ្ទាល់ និងជាអ្នកកាន់ឯកសារសម្ងាត់របស់ទ្រង់ ដោយសារគេមានកំហឹងឈឺចាប់នឹង

ទ្រង់បានទះកំផ្លៀងគេ ព្រោះតែមានការខុសឆ្គងការងារបន្តិចបន្តួច គេបានរកវិធីយកគម្រោងការសម្ងាត់នេះ ទៅទូលសម្តេចសីហនុ ឱ្យបានដឹងជាមុន។

ឈ្មោះហ៊ុល សារ៉ែន ជាអតីតគ្រូបង្រៀន នៅខេត្តក្រចេះ បានមកសុំចូលធ្វើខ្មែរឥស្សរៈនៅច្បារមន ហើយទ្រង់ចន្ទរង្សី យល់ឃើញថា គាត់ជាអ្នកចេះដឹងម្នាក់ដែរ ក៏តែងតាំងឱ្យធ្វើជាលេខាធិការរបស់ទ្រង់ នៅសេនាធិការដ្ឋាន រហូតដល់ពេលមានរឿងបែកធ្លាយផែនការសម្ងាត់នោះ។ ក្រោយមក ឈ្មោះ ហ៊ុល សារ៉ែន បាននិរទេសខ្លួនទៅដល់រស់នៅសហរដ្ឋអាមេរិក ហើយបានដូរឈ្មោះថា ហ៊ុល និល និងបានក្លាយជាជន្លងរបស់ស្តេចក្រុមឃុននរោត្តម ចក្រពង្ស ផងដែរ។

ក្រោយពីដឹងគម្រោងការបះបោរនោះ សម្តេចសីហនុ បានឱ្យគេឃាត់ខ្លួនមេបញ្ជាការរងទាំងពីរនាក់ គឺអនុសេនីយ៍ឯក ហម ខាន់ និងចាន់ តោត្រេស។ ចំណែក ទ្រង់ចន្ទរង្សី ត្រូវបានសម្តេចសីហនុ បញ្ជាឱ្យទៅបំពេញបេសកកម្មនៅប្រទេសបារាំង។ តែមុនពេលចេញដំណើរ ទ្រង់ក៏សង្ស័យថា គម្រោងការបះបោររបស់ទ្រង់ត្រូវបែកការណ៍ ក៏ប្រគល់តួនាទីមេបញ្ជាការបណ្តោះអាសន្ន ទៅឱ្យអនុសេនីយ៍ទោ សុក សេង រឿងមុនី និងផ្តាំផ្ញើថា បើកងទ័ពរបស់ព្រះមហាក្សត្រ មករកចាប់ខ្លួន កុំទម្លាក់អាវុធឱ្យសោះ គឺត្រូវតែតបតវិញ។

ជាមួយគ្នានោះ សាវ៉ាង វង្ស និងនាយទាហាន ពលទាហានរបស់គាត់មួយចំនួន នៅកងវរសេនាតូចស្វយ័តលេខ២ ក៏ត្រូវឃាត់ខ្លួនដែរ ព្រោះសង្ស័យថា មានជាប់ពាក់ព័ន្ធក្នុងផែនការបះបោរនេះដែរ។ តែក្រោយមក សាវ៉ាង វង្ស, ចាន់ តោត្រេស និងនាយទាហានពលទាហានជាច្រើននាក់ទៀត ត្រូវបានដោះលែងវិញ។

ដោយឡែក ទ្រង់ចន្ទរង្សី ពេលត្រលប់មកពីបេសកកម្ម នៅប្រទេសបារាំងវិញ ត្រូវបានឃុំខ្លួនមួយរយៈ និងត្រូវបកស័ក្តិឱ្យធ្វើជាប្រជារាស្ត្រសាមញ្ញវិញ ហើយកងវរសេនាតូចស្វ័យភាពចលនាលេខ៣ របស់ទ្រង់ ក៏ត្រូវរាជរដ្ឋាភិបាលរំលាយចោលដែរ។

៦១
ជូ អេនឡាយ មិនឱ្យទ័ពវៀតមិញ ២កងពលទៀត ចូលមកក្នុងទឹកដីកម្ពុជា



ជូ អេនឡាយ នាយករដ្ឋមន្ត្រីចិន

នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៥៤ កែវ មុនី មេខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ នៅភូមិភាគបូព៌ា មិនទទួលស្គាល់ថា ប្រទេសកម្ពុជា បានឯករាជ្យពីបារាំង នៅឡើយនោះ បានប្រកាសថា ដោយសារសង្គ្រាមរំដោះកម្ពុជា កាន់តែបោះជំហានទៅមុខ ចក្រពត្តិអាមេរិក ក៏កាន់តែចូលមកធ្វើអន្តរាគមន៍ខ្លាំងឡើងៗ មកលើប្រទេសកម្ពុជា ដែរ។ លើសពីនេះទៅទៀត ចក្រពត្តិអាមេរិក ក៏បានទាញខ្សែញាក់ពីក្រោយខ្នងស្តេចសីហនុ ឱ្យសម្តែងឆាកល្ខោនទាមទារដណ្តើមឯករាជ្យ ឱ្យបារាំង ចេញទៅ ដើម្បីខ្លួនបានចូលមកបង្កសង្គ្រាមជំនួសបារាំង វិញ។

ការប្រកាសរបស់កែវ មុនី នេះ បានធ្វើឡើងចំថ្ងៃនាយអគ្គសេនាធិការកងទ័ពបារាំង បានប្រកាសប្រាប់ប្រធានាធិបតីអាមេរិក ដ្វៃត៍ ឌី. អៃសិនហាវើរ (Dwight D. Eisenhower) ថា មានតែអន្តរាគមន៍ជាទ្រង់ទ្រាយធំរបស់អាមេរិក ទេ ទើបអាចជួយបារាំង នៅ

សមរភូមិខៀនបៀនភូ នាភាគខាងជើងប្រទេសវៀតណាម បាន។

នៅក្នុងខែមេសា ឆ្នាំ១៩៥៤ កងវរសេនាតូចថ្មើរជើងលេខ២ ក្រោមបញ្ជាការវរសេនីយ៍លន់ នល់ បានបើកប្រតិបត្តិការសឹកបោសសម្អាតកងទ័ពវៀតមិញ និងខ្មែរឥស្សរៈ នៅតាមផ្លូវជាតិលេខ១០ (បច្ចុប្បន្នផ្លូវជាតិលេខ៥៧) ពីក្រុងបាត់ដំបង ទៅក្រុងប៉ៃលិន។ តែត្រូវកងទ័ពខ្មែរឥស្សរៈដឹកនាំដោយ ស៊ីវ ហេង និងលាវ កែវមុនី សហការជាមួយកងទ័ពវៀតមិញធ្វើការឡោមព័ទ្ធវាយបកវិញ ធ្វើឱ្យកងវរសេនាតូចថ្មើរជើងលេខ២នោះ វាយរំដោះខ្លួន ដើម្បីដកថយវិញ ស្ទើរតែមិនបាន។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៥៤ រដ្ឋាភិបាលអាមេរិក បានចេញរបាយការណ៍មួយ ស្តីពីលទ្ធភាពពង្រឹងសក្តានុពលខាងយោធា និងខាងនយោបាយរបស់ខ្លួន នៅតំបន់ឥណ្ឌូចិន ក្នុងរយៈពេល៣០ថ្ងៃ ខាងមុខ។

ពីសប្តាហ៍ក្រោយមក តាមការប៉ាន់ស្មានរបស់ភ្នាក់ងារសម្ងាត់របស់អាមេរិក បានឱ្យដឹងថា នៅក្នុងប្រទេសកម្ពុជា មានកងទ័ពវៀតមិញ ប្រមាណ៨៧០០នាក់ ក្នុងនោះមាន ២២០០នាក់ជាកងទ័ពរៀបរយ។ ប៉ុន្តែបើតាមឧត្តមសេនីយ៍បារាំង ឈ្មោះសេតា ជាទីប្រឹក្សាយោធារបស់ព្រះមហាក្សត្រសីហនុ បានឱ្យដឹងថា កងទ័ពវៀតមិញ ដែលមានវត្តមាននៅលើទឹកដីកម្ពុជា នៅក្នុងដើមឆ្នាំ១៩៥៤ មានចំនួន តែ២២០០នាក់ទេ ឯកងទ័ពបារាំងមានចំនួន៦០០០នាក់។

ប៉ុន្តែ បើតាមប្រភពពីទីក្រុងហាណូយ បានឱ្យដឹងថា កងទ័ពវៀតមិញ កំពុងស្ថិតនៅក្នុងប្រទេសកម្ពុជា មានចំនួន៣០០០នាក់ ហើយកងទ័ពរបស់រណសិរ្សឯកភាពឥស្សរៈ (UIF) មានចំនួន៥០០០នាក់ ដោយមិនរាប់បញ្ចូលចំនួនកងឈ្លប នៅតាមភូមិឃុំផងទេ។

ចំណែកខាងរាជរដ្ឋាភិបាលរបស់ព្រះមហាក្សត្រសីហនុ បានប្រកាសថា ខ្លួនមានកងទ័ពគ្រប់ប្រភេទចំនួន៣៣០០០នាក់ ដោយមានបារាំងជាអ្នកជួយផ្តល់អាវុធយុទ្ធភណ្ឌមួយចំនួនធំផងដែរ។

បើតាមឯកសារចារកម្មរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៥៤ បានធ្វើ



កងទ័ពបារាំង បើកយុទ្ធនាការបោសសម្អាតកងទ័ពវៀតមិញ និងខ្មែរឥស្សរៈ នៅខេត្តកំពត

ការវាយតម្លៃថា ប្រសិនបើលទ្ធផលនៃការចរចាគ្នា នៅក្រុងហ្សឺណែវ តម្រូវឱ្យកងទ័ពបារាំង និងកងទ័ពវៀតមិញ ដកចេញពីទឹកដីកម្ពុជា នោះ កងទ័ពរាជរដ្ឋាភិបាលអាចមានសមត្ថភាព ក្នុងការរក្សាសុវត្ថិភាពដោយខ្លួនឯង បន្តទៀត ប្រសិនបើបារាំង នៅតែផ្តល់ជំនួយអាវុធយុទ្ធ-ភណ្ឌមកឱ្យដូចមុន។

ជាមួយគ្នានោះ ឯកសារដដែលបានបង្ហាញឱ្យឃើញនូវការព្រួយបារម្ភដែរថា ប្រសិន បើកងទ័ពបារាំង ទាំង៦០០០នាក់នោះ ត្រូវដកចេញពីកម្ពុជា ដោយគ្មានការធានាថា កង ទ័ពវៀតមិញ ទាំង២២០០នាក់នោះ ត្រូវតែដកចេញដែរទេ ការចរចាកំពុងធ្វើឡើងនៅក្រុង ហ្សឺណែវ ប្រទេសស្វីសនោះ ក៏មិនអាចឈានដល់កិច្ចព្រមព្រៀងណាមួយដែរ តែបើកងទ័ព បារាំង ត្រូវដកចេញពីកម្ពុជា មែននោះ កម្លាំងប៉ូលិស និងកងយោធពលខេមរភូមិន្ទរបស់

ព្រះមហាក្សត្រសីហនុ ប្រហែលជាមិនអាចទប់ទល់ជាមួយពួកវៀតមិញ បានយូរអង្វែងឡើយ ហើយបើគ្មានការគាំទ្រ និងគ្មានជំនួយពីខាងក្រៅឱ្យបានគ្រប់គ្រាន់ទេ រាជរដ្ឋាភិបាលរបស់ព្រះមហាក្សត្រសីហនុ នឹងត្រូវរលំរលាយ ដោយពួកវៀតមិញ ជាមិនខាន។


នៅក្នុងខែមិថុនា ឆ្នាំ១៩៥៤ កងយោធពលខេមរភូមិន្ទ និងកងជីវពលរបស់ព្រះ-មហាក្សត្រសីហនុ ដោយមានការចូលរួមពីកងទ័ពថ្មើរជើង និងយន្តហោះចម្បាំងបារាំង បានបើកយុទ្ធនាការបោសសម្អាតកងទ័ពវៀតមិញ និងខ្មែរឥស្សរៈ នៅភូមិភាគឦសាន ដោយបានវាយប្រយុទ្ធគ្នាជាមួយកងវរសេនាតូចលេខ៤៣៦ និងកងវរសេនាតូចលេខ១០១ របស់វៀតមិញ នៅក្នុងខេត្តក្រចេះ ចំនួន២លើក។ បន្ទាប់មក បានបើកយុទ្ធនាការបោសសម្អាតកងទ័ពវៀតមិញ និងខ្មែរឥស្សរៈ នៅភាគខាងត្បូងប្រទេស បន្តទៀត។

ពេលនោះ កងទ័ពបារាំង បានប្រកាសថា កងទ័ពវៀតមិញ បាននាំគ្នាដកថយពីសមរភូមិទាំងអស់នោះ ដោយមិនហ៊ានប្រយុទ្ធតស៊ូអ្វី គួរឱ្យកត់សម្គាល់ឡើយ។

ប៉ុន្តែ បើតាមមេបញ្ជាការកងទ័ពវៀតមិញ ឈ្មោះហុង ទុង កំពុងស្ថិតនៅភាគកណ្តាលវៀតណាម បានឱ្យដឹងថា ពេលនោះ កងទ័ពវៀតមិញ មានផែនការបញ្ជូនកងទ័ពរបស់ខ្លួនចំនួន២កងពលទៀត ចូលមកក្នុងទឹកដីខ្មែរ ក្នុងបំណងជួយពង្រីកទឹកដីឱ្យរដ្ឋាភិបាលខ្មែរឥស្សរៈ ដឹកនាំដោយសឺង ង៉ុកមិញ ជាសម្ព័ន្ធមិត្តខ្លួន ត្រួតត្រាកាន់កាប់កាន់តែធំជាងមុនទៅទៀត ដើម្បីឱ្យសន្និសីទក្រុងហ្សឺណែវ ទទួលស្គាល់រដ្ឋាភិបាលរបស់សឺង ង៉ុកមិញ ជាភាគីចចារមួយដែរ។

តែផែនការបញ្ជូនកងទ័ពរបស់ខ្លួន ចំនួន២កងពលនេះ ត្រូវបានបញ្ឈប់ទៅវិញ ដោយសារជូ អេនឡាយ នាយករដ្ឋមន្ត្រីចិន បានផ្ញើសារទូរលេខមួយច្បាប់ពីក្រុងហ្សឺណែវ មកប្រាប់មេដឹកនាំវៀតមិញ ថា បើបញ្ជូនកងទ័ពវៀតមិញ ២កងពល ឱ្យចូលមកក្នុងទឹកដីប្រទេសកម្ពុជា ថែមទៀតនោះ វានឹងធ្វើឱ្យប៉ះពាល់ដល់កិច្ចព្រមព្រៀងក្រុងហ្សឺណែវ នោះជាមិនខាន។

៦២
សង្គ្រាមនៅឌៀនបៀនភូ



ផែនទីសមរភូមិឌៀនបៀនភូ

នៅក្នុងខែមីនា ឆ្នាំ១៩៥៤ ដោយមានជំនួយពីប្រទេសចិន និងសហភាពសូវៀតផងនោះ កងទ័ពវៀតមិញ បានចាប់ផ្តើមបើកប្រតិបត្តិការសឹកដ៏ធំមួយ មិនធ្លាប់មានពីមុនវាយប្រហារលើទីតាំងកងទ័ពបារាំង នៅបន្ទាយឌៀនបៀនភូ ជាមូលដ្ឋានកងទ័ពបារាំងធំជាងគេបង្អស់ នៅឥណ្ឌូចិន។

បន្ទាយឌៀនបៀនភូ ស្ថិតនៅលើផ្ទៃរាបនៃណ្ឌាងភ្នំដ៏ធំមួយ ស្ថិតនៅភាគខាងលិចទីក្រុងហាណូយ ក្បែរព្រំដែនឡាវ ហើយនៅមិនឆ្ងាយប៉ុន្មានពីព្រំដែនចិនផងដែរ។ ផ្ទៃរាបនៃណ្ឌាងភ្នំនេះ មានបណ្តោយ១៧គីឡូម៉ែត្រ ទទឹងប្រហែល៦គីឡូម៉ែត្រ ហ៊ុំព័ទ្ធដោយជួរភ្នំជារច្រើនដោយភ្នំខ្លះមានកម្ពស់ពី៦០០ទៅ៧០០ម៉ែត្រ និងភ្នំខ្លះទៀតខ្ពស់ជាង១០០០ម៉ែត្រ

ហើយអ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺខ្ពង់រាបឌៀនបៀនភូ នេះ មានទន្លេមួយ ឈ្មោះទន្លេណាំហ្សូម ហូរកាត់ទៀតផង។

ដើមឡើយ ទីតាំងឌៀនបៀនភូ ជាភូមិមួយរបស់កុលសម្ព័ន្ធថៃ ស្បែកខ្មៅ រស់នៅភូមិភាគខាងជើង នៃតំបន់តុងកឹង។ ជាតិកុលសម្ព័ន្ធថៃ ស្បែកខ្មៅនេះ ធ្លាប់ធើបបះបោរជាច្រើនលើកច្រើនសា ប្រឆាំងនឹងរដ្ឋអំណាចតុងកឹង។ លុះមកដល់សម័យសង្គ្រាមលោកលើកទី២ កងទ័ពជប៉ុន បានសាងសង់អាកាសយានដ្ឋានតូចៗ មួយចំនួនសម្រាប់បម្រើយុទ្ធសាស្ត្ររបស់ខ្លួន នៅចំកណ្តាលខ្ពង់រាបនេះ។

ក្រោយកងទ័ពជប៉ុន ចាញ់សង្គ្រាមលោកលើកទី២ ហើយត្រូវចាកចេញទៅប្រទេសពួកគេវិញ បារាំង ក៏បានយកមូលដ្ឋាននេះ ធ្វើជាមូលដ្ឋានយោធាដ៏ធំបំផុតរបស់ខ្លួន ដើម្បីបើកប្រតិបត្តិការសឹកកម្ចាត់កងទ័ពវៀតមិញ នៅឧបទ្វីបឥណ្ឌូចិន បន្តទៀត។

មូលដ្ឋានយោធានេះ មានលក្ខណៈអំណោយផលល្អបំផុត ចំពោះកងទ័ពបារាំង ដោយកងទ័ពវៀតមិញ មិនអាចបើកការវាយប្រហារបាន ដោយងាយស្រួលនោះឡើយ ហើយបារាំង បានសាងសង់វាលយន្តហោះដ៏ធំមួយ និងសាងសង់លេណដ្ឋាន សាងសង់ រូងសម្ងាត់ក្រោមដី ខ្វាត់ខ្វែងទៀតផង។

នៅបន្ទាយឌៀនបៀនភូ បារាំង មានកងទ័ពថ្មើរជើង ចំនួន២១កងវរសេនាតូច, កងកាំភ្លើងធំ ៣អនុសេនាធំ, កងកាំភ្លើងផ្លោងធុន១០៥មិល្លីម៉ែត្រ ចំនួន២៤ដើម, កាំភ្លើងផ្លោងធុន១២០មិល្លីម៉ែត្រ ចំនួន២០ដើម, កាំភ្លើងផ្លោងធុន១៥៥ មិល្លីម៉ែត្រ ចំនួន៤ដើម, រថក្រោះចំនួន១០គ្រឿង និងមានយន្តហោះ ចុះឡើងរាប់សិបជើង ក្នុងមួយថ្ងៃៗ ។

ចំណែក អង្គភាពកងទ័ពវៀតមិញ ដែលបើកយុទ្ធនាការវាយប្រហារទៅលើកងទ័ពបារាំង នៅបន្ទាយឌៀនបៀនភូ នោះ មានកម្លាំងសរុប ចំនួន៨០.០០០នាក់ ក្នុងនោះ មានកងពលថ្មើរជើងលេខ៣០៨, កងពលថ្មើរជើងលេខ៣១២, កងពលថ្មើរជើងលេខ៣១៦, កងវរសេនាធំលេខ៥៧ របស់កងពលធំលេខ៣០៤, កាំភ្លើងផ្លោងធុន៧៤មិល្លីម៉ែត្រ ចំនួន ១៦ដើម, កាំភ្លើងផ្លោងធុន៨២មិល្លីម៉ែត្រ ចំនួន៣៦ដើម, កាំភ្លើងធំធុន១០៥មិល្លីម៉ែត្រ

ចំនួន២៤ដើម, កាំភ្លើងធំធុន១២០មិល្លីម៉ែត្រ ចំនួន១៦ដើម, កាំភ្លើងបាញ់យន្តហោះ ដៅសេអា ធុន២៤មិល្លីម៉ែត្រ ចំនួន២៤ដើម។

ឯមធ្យោបាយដឹកជញ្ជូន វិញ កងទ័ពវៀតមិញ មានកម្លាំងដឹកជញ្ជូនរែកលើសែង ស្បៀង និងភស្តុភារ ចំនួន២៦.០០០នាក់ ប្រើកង់ដឹកជញ្ជូនចំនួន២០.០០០គ្រឿង ក្បូនឫស្សី ជាង១ម៉ឺនក្បូន ប្រើសេះដឹកជញ្ជូន ចំនួន៥០០ក្បាល និងរថយន្តកាំម៉ុងម៉ូតូឡូវ៉ា (Motolova) ជាជំនួយរបស់សហភាពសូវៀត ចំនួន៤០០គ្រឿង ។

មេបញ្ជាការបារាំង គិតថា កងទ័ពវៀតមិញ ប្រដាប់ដោយអាវុធធុនស្រាល មិនអាចដឹកជញ្ជូនកាំភ្លើងធំ ទំហំ ១០៥មិល្លីម៉ែត្រ យកឡើងទៅដល់លើកំពូលភ្នំ នៅជុំវិញទីតាំងបន្ទាយឌៀនបៀនភូ បានឡើយ។ ប៉ុន្តែ ដើម្បីដឹកជញ្ជូនកាំភ្លើងធំ ទំហំ១០៥មិល្លីម៉ែត្រ យកឡើងទៅដល់លើកំពូលភ្នំ កងទ័ពវៀតមិញ បាននាំគ្នាដោះគ្រឿងកាំភ្លើងធំមួយចំនួនចេញជាបំណែកៗ ដើម្បីងាយស្រួលក្នុងការលើសែងពីជើងភ្នំ ហើយយកទៅរៀបចំដំឡើងវិញ នៅលើកំពូលភ្នំតែម្តង។ រីឯកាំភ្លើងធំមួយចំនួនទៀត ពួកគេនាំគ្នាចងខ្សែអូសផង រុញ



កងទ័ពវៀតមិញ ដាំគ្នារុញកាំភ្លើងធំឡើងភ្នំ

ផង កាត់ព្រៃឡើងតាមជម្រាលភ្នំ។ ពេលខ្លះ ឡើងជម្រាលភ្នំចោតខ្លាំងពេក បណ្តាលឱ្យកង់កាំភ្លើងធំ ធុន១០៥មិល្លីម៉ែត្រ រអិលចុះមកក្រោមវិញ ពួកគេខ្លះ ស៊ូប្តូរស្លាប់ខ្លួន ដោយនាំគ្នាទៅដេកទប់កង់កាំភ្លើងធំនោះ មិនឱ្យរអិលចុះមកក្រោមវិញបានឡើយ។

នាព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៥៤ កងទ័ពវៀតមិញ ចាប់ផ្តើមបាញ់កាំភ្លើងធំជញ្ជាំទៅលើបញ្ជាការដ្ឋានប៊ីទ្រីស(Beatrice) របស់បារាំង រហូតដល់ពេលព្រលប់ កងពលថ្មើរជើងលេខ៣១២របស់វៀតមិញ នាំគ្នាសម្រុកចូលទៅដល់បញ្ជាការដ្ឋានប៊ីទ្រីស (Beatrice) នោះ ហើយបានបាញ់សម្លាប់វរសេនីយ៍ត្រី ប៉ូល ប៊ីហ្គោត (Paul Pegot) ជាមេបញ្ជាការនៅទីតាំងនោះ រួមទាំងពលទាហានរបស់គាត់ទាំងអស់។ ប៉ុន្មាននាទីក្រោយមក វរសេនីយ៍ឯកហ៊ុយល ហ្គោធ័រ (Jules Gaucher) មេបញ្ជាការនៅទិសខាងជើង ក៏ត្រូវបាត់បង់ជីវិតដោយសារត្រូវគ្រាប់ផ្លោងរបស់ពួកវៀតមិញ ដែរ។

បន្ទាប់មកទៀត នៅវេលាកណ្តាលអធ្រាត្រ កងពលធំលេខ៣១២ របស់វៀតមិញ បានបើកការវាយប្រហារស៊ីសាច់ហុតឈាមបន្តទៀត និងបានសម្លាប់កងទ័ពបារាំង ប្រហែល ៥០០នាក់។ ប៉ុន្តែខាងបារាំង ក៏បានរាយការណ៍ថា ក្នុងការប្រយុទ្ធគ្នាស៊ីសាច់ហុតឈាមនោះ កងពលធំលេខ៣១២ របស់ពួកវៀតមិញ ក៏មានស្លាប់ និងរងរបួសធ្ងន់ស្រាល រាប់ពាន់នាក់ដែរ។

នៅព្រឹកថ្ងៃទី១៤ ខែមីនា កងទ័ពបារាំង បានព្យាយាមវាយបកទៅលើកងទ័ពវៀតមិញវិញដែរ តែត្រូវបរាជ័យដោយសារកាំភ្លើងផ្លោងរបស់វៀតមិញ បាញ់ស្រោចមក ច្រើនពេក។ មិនយូរប៉ុន្មាន កងទ័ពវៀតមិញ ដណ្តើមទីតាំងប៊ីទ្រីស(Beatrice) បានទាំងស្រុង។

មេបញ្ជាការកងទ័ពបារាំង មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះសមត្ថភាពបាញ់កាំភ្លើងផ្លោង ជាហ្វូងៗរបស់ពួកវៀតមិញ ដែលមានការខុសប្លែកគ្នាពីមុនៗមក ជាហេតុធ្វើឱ្យពួកគេមិនអាចទប់ទល់បាននោះ។

ក្រោយមក ឧត្តមសេនីយ៍បារាំង ឈ្មោះហង់រី ណាវ៉ា(Hanri Navarre) បានធ្វើការកត់សម្គាល់ថា វិធីបាញ់កាំភ្លើងផ្លោងធ្ងុំគ្នាជាហ្វូងៗរបស់ពួកវៀតមិញ ខុសប្លែកពីពេលមុនៗ

នោះ គឺមានពួកទីប្រឹក្សាយោធាចិន ជាអ្នកជួយបង្ហាត់បង្រៀន។ ពួកទីប្រឹក្សាយោធាចិន បានបង្ហាត់បង្រៀនឱ្យពួកវៀតមិញ យកកាំភ្លើងធំដាក់តម្រៀបគ្នា នៅក្នុងលេណដ្ឋានធំៗ ដោយមានគ្របដំបូលពីលើ ហើយដាក់ចុងកាណុងកាំភ្លើងធំនោះ ចេញមកក្រៅតែបន្តិច ប៉ុណ្ណោះ។ ធ្វើបែបនេះ គឺដើម្បីការពារគ្រាប់កាំភ្លើងផ្លោងរបស់បារាំង ដែលបាញ់សងមកវិញ។ ឯកាំភ្លើងធំមួយចំនួនទៀត និងកាំភ្លើងបាញ់យន្តហោះ ពួកវៀតមិញ បានដាក់នៅក្នុងលេណដ្ឋានវែងៗ ដែលមានលក្ខណៈជាអន្ទាក់ស្រមោច។

យុទ្ធសាស្ត្រប្រើកាំភ្លើងធំរបស់កងទ័ពវៀតមិញ ដូចខាងលើនេះហើយ ដែលធ្វើឱ្យកងទ័ពបារាំង បាញ់កាំភ្លើងធំ តបតវិញ ពុំមានប្រសិទ្ធភាព ហើយយន្តហោះបារាំង ក៏ពិបាកក្នុងការទម្លាក់គ្រាប់បែក ដើម្បីកម្ទេចកងទ័ពវៀតមិញ នៅខាងក្រោមដែរ។

វរសេនីយ៍ឯកហ្សាល ពីរ៉ុត (Charles Piroth) មេបញ្ជាការកងកាំភ្លើងធំរបស់បារាំង នៅសមរភូមិឌៀនបៀនភូ បានសម្រេចចិត្តធ្វើអត្តឃាតបំផ្ទុះគ្រាប់បែកសម្លាប់ខ្លួនឯង នៅក្នុងលេណដ្ឋាន ដោយសារតែគាត់តូចចិត្ត ព្រោះមិនអាចបាញ់កម្ទេចកាំភ្លើងធំរបស់ពួកវៀតមិញ ដែលបាញ់ជាហ្វូងៗ មកសម្លាប់ពួកគាត់ឱ្យស្លាប់គរជើងលើគ្នា ដូចគេហាលងៀតនោះ មិនបាន។

សាកសពវរសេនីយ៍ឯក ហ្សាល ពីរ៉ុត (Charles Piroth) ត្រូវបានមេបញ្ជាការបារាំងផ្សេងទៀត នាំគ្នាយកទៅកប់ក្នុងលេណដ្ឋានដោយស្ងាត់ៗ ដើម្បីកុំឱ្យពួកពលទាហានដឹង ព្រោះខ្លាចពួកគេបាក់ទឹកចិត្តប្រយុទ្ធ។

៦៣
មេបញ្ជាការកងទ័ពបារាំង បាក់ស្មារតី



មេបញ្ជាការកងទ័ពបារាំង ថ្ងាក់ផ្កាយ៤ និងផ្កាយ៣ រិះរកវិធីនាយបកកងទ័ពវៀតមិញ

ក្រោយពីផ្ទុះកបាញ់កាំភ្លើងធំ ចាប់ពីវេលារំលងអធ្រាត្រមក នៅព្រឹកថ្ងៃទី១៥ ខែកញ្ញា កងទ័ពវៀតមិញ ក៏ចាប់ផ្តើមបាញ់កាំភ្លើងធំផ្លោងដាក់ទីតាំងវាលយន្តហោះបារាំង នៅក្នុងបន្ទាយឌៀនបៀនភូ បន្តទៀត ដូចថ្ងៃបើកការវាយប្រហារដំបូង ដែរ ធ្វើឱ្យយន្តហោះបារាំងដែលដឹកកងទ័ពជាជំនួយ រួមទាំងអាវុធគ្រាប់រំសេវផ្សេងៗ និងស្បៀងអាហារ មិនអាចចុះចតបាន គឺមានតែធ្វើឡើង តាមការទម្លាក់តាមឆត្រយោងតែប៉ុណ្ណោះ។

លុះដល់យប់ថ្ងៃទី១៥ ខែមីនា ដោយមានការបាញ់កាំភ្លើងធំផ្តុំគ្នា ជួយគាំទ្រផង កងវរសេនាតូចថ្មើរជើង នៃកងពលលេខ៣០៨ របស់វៀតមិញ បានធ្វើការវាយប្រហារទៅលើទីតាំងហ្គាប្រ៊ីយែល(Gabrielle) ដែលមានកងទ័ពបារាំង សុទ្ធតែជាជនជាតិអាល់ហ្សេរី ១

កងវរសេនាតូច ឈរជើងការពារទីនោះ។

វេលាម៉ោង៨ទៀបភ្លឺ ថ្ងៃទី១៦ ខែមីនា គ្រាប់កាំភ្លើងធំរបស់ពួកវៀតមិញ បានធ្លាក់ចំកណ្តាលបញ្ជាការដ្ឋានហ្គាប្រ៊ីយែល(Gabrielle) បណ្តាលឱ្យមេបញ្ជាការកងវរសេនាតូចរបស់បារាំង រងរបួសយ៉ាងធ្ងន់ធ្ងរ និងស្លាប់ពលទាហានជាច្រើនទៀត ក៏ត្រូវបង្ខំចិត្តដកថយពីទីតាំងនេះ។

ពេលនោះ ឧត្តមសេនីយ៍ទោ គ្រីស្ទៀន ដឺ កាស្ត្រី (Christian de Castrie) មេបញ្ជាការប្រចាំមូលដ្ឋានឌៀនបៀនភូទាំងមូល បានបញ្ជាឱ្យកងទ័ពគាត់វាយដណ្តើមយកទីតាំងហ្គាប្រ៊ីយែល(Gabrielle)នោះវិញ ដោយមានកងវរសេនាតូចលេខ៥ ទើបនឹងលោតឆត្រយោង ពីលើយន្តហោះចុះមក មុននេះមួយថ្ងៃ ជាជំនួយផង។

ប៉ុន្តែ ពេលទាហានទាំងនេះវាយបកទៅដល់ផ្នែកមួយចំនួននៃទីតាំងហ្គាប្រ៊ីយែល(Gabrielle) ត្រូវកាំភ្លើងធំរបស់ពួកវៀតមិញ បាញ់ស្រោចមកលើ ធ្វើឱ្យកងទ័ពបារាំង ស្លាប់និងរបួសប្រមាណ១០០០នាក់ ក៏ត្រូវបង្ខំចិត្តដកថយវិញ។ ឯកងទ័ពវៀតមិញ ក៏ត្រូវស្លាប់និងរបួស ប្រហែល១០០០នាក់ ទៅ២០០០នាក់ដែរ។

ដោយសារការបាត់បង់ទីតាំងប៊ីទ្រីស(Beatrice) និងទីតាំងហ្គាប្រ៊ីយែល (Gabrielle) ព្រមទាំងមានការកាត់ផ្តាច់កម្លាំងជំនួយ និងស្បៀងតាមផ្លូវអាកាសផងនោះ ធ្វើឱ្យកងទ័ពបារាំង ឈរជើងនៅទីតាំងផ្សេងៗទៀត ដែលពួកវៀតមិញ មិនទាន់បើកការវាយប្រហារ មានការបាក់ទឹកចិត្តយ៉ាងខ្លាំង។

មុនបើកការវាយប្រហារទៅលើទីតាំងបារាំង មួយ ឈ្មោះអាន ម៉ារី (Anne Marie) មានទាហានសុទ្ធតែជនជាតិតៃ (ជនជាតិភាគតិចវៀតណាម)នោះ វ៉ែ ង្វៀងយ៉ាប់ ជាមេទ័ពកំពូលរបស់ពួកវៀតមិញ បានឱ្យកងទ័ពរបស់គាត់បាចខិត្តប័ណ្ណអំពាវនាវឱ្យពួកទាហានបារាំង ជាជនជាតិភាគតិចតៃទាំងអស់ ទម្លាក់អាវុធចុះចូលជាមួយកងទ័ពគាត់ ដើម្បីដណ្តើមឯករាជ្យពីបារាំង មកវិញ ដោយមិនបាច់បង្ហូរឈាមគ្នាទេ។

ដោយសារការបាក់ទឹកចិត្តក្នុងការប្រយុទ្ធផងនោះ ពួកទាហានបារាំង ជាជនជាតិតៃ



កងទ័ពបារាំង រត់ចោលទីតាំង

ភាគច្រើន នៅទីតាំងអាន ម៉ារី (Anne Marie) ក៏នាំគ្នាចេញមកចុះចូលជាមួយពួកវៀតមិញ។ ចំណែកពួកគេជាជនជាតិតៃ នៅសេសសល់ និងទាហានជនជាតិបារាំងទាំងប៉ុន្មាន ត្រូវបង្ខំចិត្តដកថយពីទីតាំងអាន ម៉ារី (Anne Marie) នោះ នៅព្រឹកថ្ងៃទី១៧ ខែមីនា។

នៅថ្ងៃកងទ័ពវៀតមិញ វាយដណ្តើមបានទីតាំងអាន ម៉ារី (Anne Marie) នោះ ឧត្តមសេនីយ៍ឯក រ៉ឺណេ កូញ៉ី (Rene Cogny) ជាមេបញ្ជាការកងទ័ពបារាំង ប្រចាំតំបន់តុងកឹង(វៀតណាមខាងជើង) បានឡើងយន្តហោះទៅសមរភូមិឌៀនបៀនភូ ក្នុងគោលបំណងចុះទៅបញ្ជាកងទ័ពរបស់គាត់ ដោយផ្ទាល់តែម្តង ដើម្បីវាយបកទៅលើពួកវៀតមិញវិញដែរ ប៉ុន្តែ ដោយសារកាំភ្លើងបាញ់យន្តហោះរបស់ពួកវៀតមិញ បាញ់ស្រោចមកលើខ្លាំងពេក យន្តហោះមិនអាចចុះចតបាន អ្នកបើកបរត្រូវបង្ខំចិត្តហោះត្រលប់ថយក្រោយវិញ។

ពេលនោះ ឧត្តមសេនីយ៍ឯក រ៉ឺណេ កូញ៉ី (Rene Cogny) ចង់លោតឆត្រយោងពីលើយន្តហោះ ចុះទៅបញ្ជាកងទ័ពរបស់គាត់ឱ្យទាល់តែបានដែរ តែត្រូវសហការីរបស់គាត់នៅ

លើយន្តហោះជាមួយ ព្យាយាមរារាំង មិនឱ្យគាត់ប្រជុំយប្រជានជាមួយគ្រោះថ្នាក់បែបនេះឡើយ។

ចំណែកឧត្តមសេនីយ៍ទោ គ្រីស្ទៀន ឌឺ កាស្ត្រី (Christian de Castrie) មេបញ្ជាការប្រចាំបន្ទាយឌៀនបៀនភូ កំពុងអស់សង្ឃឹមក្នុងការរង់ចាំកងទ័ពជំនួយមកជួយធ្វើអន្តរាគមន៍ មិនបានរិះរកយុទ្ធសាស្ត្រអ្វី ដើម្បីវាយបកទៅលើកងទ័ពវៀតមិញវិញទេ គឺគាត់សំងំតែម្នាក់ឯងក្នុងបន្ទប់មួយ នៅក្នុងលេណដ្ឋានទៅវិញ។

នៅថ្ងៃទី២៤ ខែមីនា វរសេនីយ៍ឯក ព្យែរ ឡង់គ្លេស (Pierre Langlais) មេបញ្ជាការកងទ័ពធ្យោង នៅក្នុងបន្ទាយឌៀនបៀនភូ បានសាកល្បងស្តារស្ថានការណ៍ឡើងវិញ ដោយគាត់បាននាំកងទ័ពនៅក្រោមបញ្ជារបស់គាត់មួយចំនួន ចូលទៅគំនាប់ឧត្តមសេនីយ៍ទោ គ្រីស្ទៀន ឌឺ កាស្ត្រី (Christian de Castrie) កំពុង សំងំនៅក្នុងបន្ទប់លេណដ្ឋាន ហើយប្រាប់ថា បើលោកឧត្តមសេនីយ៍ទោ មិនព្រមចេញទៅបញ្ជាកងទ័ពទៀតទេ គាត់ត្រូវតែចេញមុខទៅបញ្ជាជំនួសវិញ។

ឧត្តមសេនីយ៍ទោ គ្រីស្ទៀន ឌឺ កាស្ត្រី(Christian de Castrie) ក៏យល់ព្រម ហើយគាត់ក៏បានចេញទៅបញ្ជាកងទ័ពជាមួយវរសេនីយ៍ឯកព្យែរ ឡង់គ្លេស (Pierre Langlais) ផងដែរ។ នៅពេលវរសេនីយ៍ឯក ព្យែរ ឡង់គ្លេស (Pierre Langlais) ឡើងបញ្ជាកងទ័ពបើកការវាយបកទៅលើកងទ័ពវៀតមិញ វិញនោះ ក៏មានយន្តហោះជាច្រើនគ្រឿង បានហោះមកទម្លាក់ស្បៀងអាហារតាមធ្យោង ឱ្យពួកគាត់ដែរ តែស្បៀងអាហារទម្លាក់តាមធ្យោងនោះ ខ្លះត្រូវរសាត់ទៅលើកងទ័ពវៀតមិញ ដែលចូលមកដល់ក្បែរៗវាលយន្ត-ហោះហើយនោះ គឺដូចយកទៅទម្លាក់ឱ្យកងទ័ពវៀតមិញ ផងដែរ ហើយយន្តហោះមួយចំនួនក៏ត្រូវរងការបាញ់រះបណ្តាលឱ្យមានការខាតបង់យ៉ាងធ្ងន់ធ្ងរ។

នៅថ្ងៃទី២៧ ខែមីនា ដោយមានការពញ្ជាក់ស្មារតីប្រយុទ្ធឡើងវិញ ពីសំណាក់វរសេនីយ៍ឯកព្យែរ ឡង់គ្លេស (Pierre Langlais)នោះ ឧត្តមសេនីយ៍ទោ គ្រីស្ទៀន ឌឺ កាស្ត្រី (Christian de Castrie) បានបញ្ជាឱ្យកងកាំភ្លើងធំបាញ់សំដៅទៅលើទីតាំងកាំភ្លើងបាញ់

យន្តហោះរបស់កងទ័ពវៀតមិញ ស្ថិតនៅភាគខាងលិចបន្ទាយខៀនបៀនភូ នោះចម្ងាយប្រមាណ២០គីឡូម៉ែត្រ ត្រូវចំគោលដៅ ធ្វើឱ្យកងទ័ពវៀតមិញ ប្រហែល៣៥០នាក់ត្រូវស្លាប់ និងកាំភ្លើងបាញ់យន្តហោះចំនួន១៧គ្រឿង ត្រូវខូចខាតទាំងស្រុង។ តែកងទ័ពបារាំងត្រូវស្លាប់២០នាក់ និងរបួសធ្ងន់ស្រាល ៩៧នាក់ដែរ។

តែទោះបីយ៉ាងនេះក៏ដោយ មិនយូរប៉ុន្មានកងទ័ពវៀតមិញ ក៏វាយដណ្តើមបានទីតាំងដូមីនិកទី១ និងដូមីនិកទី២ ដែលនៅទីតាំងទាំង២នេះ មានកងទ័ពចម្រុះជាតិសាសន៍ បារាំង វៀតណាម អាហ្វ្រិកខាងជើង និងជនជាតិភាគតិចតៃ ចំនួន៥វរសេនាតូច ។ ខណៈនោះ កងទ័ពបារាំង នៅសល់តែទីតាំងដូមីនិកទី៣ និងបញ្ជាការដ្ឋានធំ ក៏ត្រូវកងទ័ពវៀតមិញឡោមព័ទ្ធជាស្រេចហើយដែរ។

នៅទីតាំងចុងក្រោយនេះ កងវរសេនាធំកាំភ្លើងធំលេខ៥ របស់បារាំង មិនអាចបាញ់គ្រាប់ផ្លោងទៅធ្លាយដូចធម្មតាបានទេ ព្រោះកងទ័ពវៀតមិញ ចូលមកកៀកណាស់ទៅហើយ។ ដូច្នេះ ពួកគេត្រូវសារ៉េចុងកាណុងកាំភ្លើងធំ១០៥មិល្លីម៉ែត្រ ចុះមកក្រោមតម្រង់ទៅមុខត្រង់ ដូចកាំភ្លើងយន្ត ផ្សេងៗទៀត រួចបាញ់ទៅរកកងទ័ពវៀតមិញ ដែលនៅមិនធ្លាយប៉ុន្មានពីខាងមុខនោះ តែម្តង។

៦៤
មេទ័ពវៀតមិញ វ៉ ង្វៀងយ៉ាប់ បញ្ជាឱ្យជីករូងក្រោមដី



មេទ័ពវៀតមិញ ង្វៀងយ៉ាប់ ចុះជាប់នៅលើទីលានសមរភូមិ

ព្រលប់ថ្ងៃទី៣០ ខែមីនា កងពលធំថ្មើរជើងលេខ៣១៨ របស់វៀតមិញ វាយដណ្តើមបានទីតាំងអេលីយ៉ានទី១ ដែលមានទាហានបារាំងជាជនជាតិម៉ារ៉ុក ឈរជើងនៅទីនោះបានទាំងស្រុង។ លុះមកដល់វេលារំលងអធ្រាត្រ កងទ័ពវៀតមិញ ដណ្តើមបានទីតាំងអេលីយ៉ានទី២ បានពាក់កណ្តាលថែមទៀត។

ពេលនោះ វរសេនីយ៍ឯកព្យែរ ឡង់គ្លេស (Pierre Langlais) បានបញ្ជាតាមវិទ្យុទាក់ទងទៅវរសេនីយ៍ទោ ម៉ាសែល ប៊ីហ្គៀដ (Marcel Bigeard) ជាមេបញ្ជាការរងរបស់គាត់ នៅទីតាំងអេលីយ៉ានទី២ ឱ្យនាំពលទាហានដកថយតាមមាត់ទន្លេណាមយុម ទៅរកទីតាំងអេលីយ៉ានទី៤ ដែលពួកវៀតមិញ មិនទាន់វាយដណ្តើមបាន ដើម្បីគេចចេញពីការ

តាមកម្ទេចរបស់ពួកសត្រូវ។ ប៉ុន្តែវរសេនីយ៍ទោ ម៉ាសែល ប៊ីហ្គៀដ (Marcel Bigeard) បានបដិសេធថា ទោះបីនៅសល់កូនទាហានតែម្នាក់ក៏ដោយ ក៏គាត់មិនដកថយពីទីតាំងអេលីយ៉ានទី២ របស់គាត់ ទៅទីតាំងអេលីយ៉ានទី៤នោះ ជាដាច់ខាត។

នៅយប់ថ្ងៃទី៣១ ខែមីនា ពេលកងពលធំលេខ៣១៦ របស់ពួកវៀតមិញ វាយកម្ទេចទីតាំងអេលីយ៉ានទី២នោះ ស្ទើរតែអស់ទាំងស្រុងទៅហើយ ក៏មានរថក្រោះបារាំង មួយចំនួនបានចេញមកជួយធ្វើអន្តរាគមន៍ រុញច្រានកងពលធំលេខ៣១៦របស់ពួកវៀតមិញនោះ ឱ្យដកថយវិញអស់។

ចំណែក កងពលធំថ្មើរជើងលេខ៣០៨របស់ពួកវៀតមិញ កំពុងវាយប្រហារទៅលើទីតាំងអ៊ុយហ្គែត (Huguette) ជិតបានជោគជ័យទាំងស្រុងទៅហើយ ក៏ត្រូវកងទ័ពបារាំងវាយបកឱ្យដកថយវិញដែរ។

នៅព្រឹក ថ្ងៃទី១ ខែមេសា វរសេនីយ៍ឯកព្យែរ ឡង់គ្លេស (Pierre Langlais) បានបញ្ជាកងទ័ពពិសេស ឱ្យវាយដណ្តើមយកទីតាំងដូមីនិកទី២ និងអេលីយ៉ានទី១ ពីកងទ័ពវៀតមិញ មកវិញដែរ។ ប៉ុន្តែ មិនបានប៉ុន្មានម៉ោងផង ក៏ត្រូវកងទ័ពវៀតមិញ វាយដណ្តើមយកទីតាំងទាំងពីរនេះ បានវិញ ដោយសារកងទ័ពបារាំង នៅទីតាំងអ៊ីសាបែល(Isabelle) ស្ថិតនៅប៉ែកខាងជើងបន្ទាយឌៀនបៀនភូនោះ មកជួយធ្វើអន្តរាគមន៍ដែរ តែត្រូវកងទ័ពវៀតមិញស្ទាក់វាយប្រហារកាត់ផ្លូវមិនឱ្យមកជួយបាន ក៏ត្រូវបង្ខំចិត្តដកថយត្រលប់ទៅទីតាំងអ៊ីសាបែល(Isabelle)វិញ។

ចំណែកនៅទីតាំងអេលីយ៉ានទី៤ ត្រូវកងទ័ពវៀតមិញ វាយខ្ទប់ មិនឱ្យចេញទៅធ្វើអន្តរាគមន៍ជួយដល់ទីតាំងផ្សេងៗទៀតបាន។

នៅយប់ថ្ងៃទី៣១ ខែមីនា នោះដែរ កងទ័ពវៀតមិញ ក៏បានវាយប្រហារទៅលើទីតាំងអ៊ុយហ្គែត(Huguette)ទី៧ផងដែរ តែត្រូវកងទ័ពបារាំង វាយឱ្យដកថយទៅវិញ នៅព្រឹកថ្ងៃទី១ ខែមេសា។

ការប្រយុទ្ធដ៏ស៊ីសាច់ហុតឈាមគ្នានេះ នៅតែបន្តជាច្រើនថ្ងៃ ទៅមុខទៀត ប៉ុន្តែ



បារាំង ទម្លាក់កងឆ្មាំយោធ មកជួយអន្តរាគមន៍

យន្តហោះដឹកកងទ័ពជំនួយមិនអាចចុះចតបានឡើយ។ មធ្យោបាយមានតែមួយគត់ គឺ កងទ័ពជំនួយមានតែលោតឆ្មាំយោងពីលើយន្តហោះចុះមកជួយ។ តែទោះបីកងឆ្មាំយោង មួយចំនួនធំ បានចុះមកដល់ដី ក៏ពិតមែន ក៏វាមិនគ្រប់គ្រាន់ ដើម្បីជំនួសកងទ័ពបារាំង ដែលស្លាប់ និងរបួស ដ៏ច្រើនសន្ធឹកសន្ធាប់ហើយនោះ បានដែរ។

នៅថ្ងៃទី៥ ខែមេសា ដោយសារការបាញ់កាំភ្លើងធំ និងការគប់គ្រាប់បែកដៃរបស់កង ទ័ពបារាំង ធ្វើឱ្យកងវរសេនាធំរបស់កងទ័ពវៀតមិញ កំពុងព្យាយាមសម្រុកចូលទៅរក លេណដ្ឋាន នៅខ្សែត្រៀមរបស់បារាំង ត្រូវទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ។

ដោយសារយុទ្ធសាស្ត្រវាយសម្រុកដោយត្រង់ៗនោះ ត្រូវបរាជ័យ មេទ័ពកំពូលរបស់ វៀតមិញ វ៉ែ ង្វៀងយ៉ាប់ បានប្តូរយុទ្ធសាស្ត្រថ្មី ដោយបញ្ជាឱ្យកងទ័ពរបស់គាត់ ជីករូងនៅ ក្រោមដី សំដៅចូលទៅក្នុងទីតាំងកងទ័ពបារាំង និងបើកការវាយប្រហារតាមយុទ្ធសាស្ត្រ ផ្កាឫកក ដណ្តើមយកទីតាំងនៅប៉ែកខាងកើតទន្លេណាំហ្សូម ធ្វើឱ្យកងទ័ពបារាំងចុះខ្សោយ វិញបន្តិចម្តងៗ។

ក្រោយពីដណ្តើមបានទីតាំងអេលីយ៉ានទី១មក កងទ័ពវៀតមិញ ក៏មានលទ្ធភាពឡោមព័ទ្ធទីតាំងអេលីយ៉ានទី៤ បន្តទៀត។ ប៉ុន្តែដើម្បីកុំឱ្យកងទ័ពវៀតមិញ បើកការវាយប្រហារទៅលើទីតាំងអេលីយ៉ានទី៤នោះបាន នៅថ្ងៃទី១០ ខែមេសា កងទ័ពបារាំង បានបើកការវាយបកដណ្តើមយកទីតាំងអេលីយ៉ានទី១ បានមកវិញ ហើយនៅវេលាព្រលឹមស្រាងៗ ថ្ងៃទី១០ ខែមេសា នោះដែរ វរសេនីយ៍ទោ ម៉ាសែល ប៊ីហ្គៀដ (Marcel Bigeard) ក៏បានបញ្ជាឱ្យកងកាំភ្លើងធំបាញ់ស្រោចទៅលើទីតាំងអេលីយ៉ានទី១ ដែលកងទ័ពវៀតមិញ ទើបដណ្តើមបាននោះ រួចបញ្ជាឱ្យកងទ័ពថ្មើរជើងសម្រុកតាមមុខព្រួញតូចៗជាច្រើន ចូលទៅកម្ទេចពួកវៀតមិញ នៅក្នុងទីតាំងអេលីយ៉ានទី១នោះ ផងដែរ។

ក្រោយការវាយប្រយុទ្ធគ្នា អស់រយៈពេលជាច្រើនម៉ោងមក កងទ័ពបារាំង បានចូលទៅកាន់កាប់ទីតាំងអេលីយ៉ានទី១ វិញ។ ប៉ុន្តែដល់ល្ងាច ថ្ងៃទី១២ ខែមេសា កងទ័ពបារាំងត្រូវបង្ខំចិត្តដកថយវិញ ដោយសារកងទ័ពវៀតមិញ មានគ្នាច្រើនលើសលប់ បានវាយបកដណ្តើមទីតាំងអេលីយ៉ានទី១នោះវិញ ដោយជោគជ័យ។ តែកងទ័ពវៀតមិញ ក៏ត្រូវស្លាប់ និងរងរបួសមិនស្មើរដែរ។

តាមរយៈការចាប់សំឡេងតាមវិទ្យុទាក់ទង កងទ័ពបារាំង បានឱ្យដឹងថា ដោយសារត្រូវស្លាប់ និងរងរបួសច្រើនសន្ធឹកសន្ធាប់នោះ ហើយអ្នករងរបួស ក៏មិនមានការព្យាបាលឱ្យបានត្រឹមត្រូវផងនោះ ធ្វើឱ្យកងទ័ពវៀតមិញ ជាច្រើនបានប្រកែកនឹងបញ្ជា ដោយមិនព្រមធ្វើការប្រយុទ្ធបន្តទៀត តែត្រូវពួកមេៗរបស់ពួកគេ បង្ខំឱ្យសម្រុកទៅមុខដាច់ខាត បើមិនដូច្នោះទេ ពួកមេៗដែលនៅពីក្រោយនោះ នឹងបាញ់សម្លាប់ពួកគេចោលជាមិនខាន។

នៅព្រឹកថ្ងៃទី១១ ខែមេសា ដោយមានកងកាំភ្លើងធំ នៅទីតាំងក្លូឌីន (Claudine) បាញ់ជួយផង កងទ័ពបារាំង នៅទីតាំងអ៊ុយហ្គែត (Huguette) ទី១ បានបើកការវាយប្រហារទៅលើកងទ័ពវៀតមិញ កំពុងឡោមព័ទ្ធទីតាំងអ៊ុយហ្គែត (Huguette) ទី៦ ដើម្បីដឹកទឹក និងគ្រាប់រំសេវទៅឱ្យកងទ័ពបារាំង នៅទីតាំងអ៊ុយហ្គែត (Huguette) ទី៦ នោះដែរ តែមិនអាចវាយបំបាក់កងទ័ពវៀតមិញនោះ បានឡើយ។

កងទ័ពបារាំង បានចាប់ផ្តើមបើកការវាយបកជាថ្មីម្តងទៀត ចាប់ពីយប់ថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ ខែមេសា ទើបកងទ័ពវៀតមិញ បង្ខំចិត្តដកថយវិញ ហើយកងទ័ពបារាំង នៅទីតាំងអ៊ុយហ្គែត (Huguette) ទី១ បានចូលទៅចាប់ដៃកងទ័ពបារាំង នៅទីតាំងអ៊ុយ-ហ្គែត (Huguette) ទី៦ ដោយជោគជ័យ។

ប៉ុន្តែ ដោយសារការវាយប្រយុទ្ធនោះ ធ្វើឱ្យកងទ័ពបារាំង ស្លាប់ និងរបួសច្រើនពេក កងទ័ពវៀតមិញ ក៏ចាប់ផ្តើមឡោមព័ទ្ធទីតាំងអ៊ុយហ្គែត (Huguette) ទី៦នោះ ជាថ្មីម្តងទៀត។ នៅថ្ងៃទី១៨ ខែមេសា វរសេនីយ៍ឯក ពៀរ ឡង់គ្លេស (Pierre Langlais) បានសម្រេចចិត្ត បញ្ជាកងទ័ពរបស់គាត់ ឱ្យវាយបើកផ្លូវឈាម ដើម្បីដកថយពីទីតាំងអ៊ុយហ្គែត (Huguette) ទី៦ នោះវិញ ដោយត្រូវចំណាយជីវិតកងទ័ពរបស់គាត់ អស់ជាច្រើន ខណៈនោះ កងទ័ព វៀតមិញ វាយដណ្តើមបានទីតាំងអ៊ុយហ្គែត (Huguette) ទី១ ទៅហើយ។ ចំណែកវាល-យន្តហោះ ក៏ត្រូវបាត់បង់ស្ទើរតែទាំងស្រុងដែរ ពេលនោះ កងទ័ពបារាំង បានព្យាយាមវាយ ដណ្តើមយកទីតាំងអ៊ុយហ្គែត (Huguette) ទី១មកវិញដែរ តែមិនអាចធ្វើបាន។

យប់ថ្ងៃទី០១ ខែឧសភា កងទ័ពវៀតមិញ វាយដណ្តើមបានទីតាំងបារាំង នៅអេលី យ៉ានទី១ (Eliane 1) ដូមីនិក ទី៣ (Dominique 3) និងអ៊ុយហ្គែត (Huguette) ទី៥ ទៅ ហើយ។

៦៥
ជោគជ័យនៅឌៀនបៀនភូ



កងទ័ពវៀតមិញ ខាយសម្រុកយកជ័យជម្នះផ្តាច់ព្រ័ត្រ

៥ថ្ងៃបន្ទាប់មកទៀត គឺនៅថ្ងៃទី០៦ ខែឧសភា កងទ័ពវៀតមិញ បានបើកការវាយប្រហារដ៏ធំមួយទៀត ទៅលើទីតាំង អេលីយ៉ានទី២ ដោយប្រើគ្រាប់រ៉ុំកែតប្រភេទកាទ្យូស្ហា (Katyusha) ជាលើកដំបូង។ ចំណែក កងទ័ពបារាំង ក៏បានបាញ់កាំភ្លើងធំពីទីតាំងផ្សេងៗទៀត មកជួយទីតាំងអេលីយ៉ានទី២ នេះដែរ។

នៅព្រឹកថ្ងៃទី០៧ខែឧសភាវ៉ង្វៀងយ៉ាប់បានបញ្ជាឱ្យកងទ័ពស្រួចចំនួន២៥០០នាក់ និងកងទ័ពភូមិភាគប្រមាណ៦០០០នាក់ទៀត វាយលុកដណ្តើមទីតាំងបារាំង នៅសេសសល់ទាំងប៉ុន្មាន ឱ្យបានទាំងអស់។

នៅវេលាម៉ោង៥ល្ងាច ថ្ងៃទី០៧ ខែឧសភា ឧត្តមសេនីយ៍ទោ គ្រីស្ទៀន ឌឺ កាស្ត្រី (Christian de Castrie) មេបញ្ជាការនៅសមរភូមិឌៀនបៀនភូ បានរាយការណ៍តាមវិទ្យុ

ទាក់ទងទៅឧត្តមសេនីយ៍ឯករ៉ឺណេ កូញ៊ី (René Cogny) ជាមេបញ្ជាការកងទ័ពបារាំង ប្រចាំតំបន់តុងកឹង (វៀតណាមខាងជើង)ថា៖ កងទ័ពវៀតមិញ វាយដណ្តើមទីតាំងកងទ័ព យើងបានស្ទើរតែអស់រលីងទៅហើយ។ ស្ថានការណ៍កាន់តែដុនដាបណាស់ទៅហើយ កងទ័ព យើងកំពុងមានការជ្រួលច្របល់។ ខ្ញុំយល់ថា ទីបញ្ចប់ កាន់តែខិតចូលមកជិតហើយ ប៉ុន្តែ យើងត្រូវតែប្រយុទ្ធបន្តទៀត រហូតដល់តំណក់ឈាមចុងក្រោយ។

ឧត្តមសេនីយ៍ឯក រ៉ឺណេ កូញ៊ី បានប្រាប់ទៅឧត្តមសេនីយ៍ទោ គ្រីស្ទាន ដឺ កាស្ត្រី វិញ ថា ពិតណាស់ ដរាបណាទង់ស មិនទាន់លើក ហើយអ្នកនៅតែមានវីរភាពនោះ អ្នកត្រូវតែ តស៊ូប្រយុទ្ធបន្តទៀត រហូតដល់ទីបញ្ចប់។

វិទ្យុទាក់ទងរបស់ទីបញ្ជាការនៅឌៀនបៀនភូ របស់បារាំង បានរាយការណ៍ថា កងទ័ព សត្រូវបានសម្រុកចូលគ្រប់ទិស យើងបាក់ទ័ពគ្រប់មុខព្រួញហើយ...។

មិនយូរប៉ុន្មាន ទីបញ្ជាការកណ្តាលរបស់បារាំង នៅឌៀនបៀនភូ នោះ ត្រូវពួក វៀតមិញ ចូលទៅដល់ទាំងយប់ងងឹត។ កងទ័ពបារាំង ព្យាយាមវាយបកវិញយ៉ាងខ្លាំងក្លា



ទាហានបារាំង ដែលពួកវៀតមិញ ចាប់បានជាឈ្លើយសឹក

ដែរ តែមិនអាចទៅរួចឡើយ។ កងទ័ពបារាំង នៅទីតាំងអ៊ីសាបែល (Isabelle) ចំនួន៧០ នាក់ និងនៅទីតាំងផ្សេងៗទៀត ប្រមាណ១៧០០ នាក់ បានវាយបើកផ្លូវឈាម ដើម្បីរំដោះខ្លួនឆ្លងព្រំដែន ចូលទៅប្រទេសលាវ ដែលនៅមិនឆ្ងាយប៉ុន្មាន ពីភាគខាងលិចសមរភូមិឌៀនបៀនភូ នោះដែរ។

ទីបំផុត បារាំង គ្មានមធ្យោបាយអ្វី ដើម្បីទប់ទល់ជាមួយកងទ័ពវៀតមិញ ក្រៅតែពីស្នើសុំសហរដ្ឋអាមេរិក ជាសម្ព័ន្ធមិត្តឱ្យយកយន្តហោះបេ៥២ (B52) ឬគ្រាប់បែកនុយក្លេអ៊ែរ មកជួយអន្តរាគមន៍ប៉ុណ្ណោះ។ តែប្រទេសអង់គ្លេស ជាសម្ព័ន្ធមិត្តរបស់បារាំង និងសហរដ្ឋអាមេរិក ដែរនោះ បានព្យាយាមពន្យល់ប្រធានាធិបតីសហរដ្ឋអាមេរិក កុំឱ្យយកយន្តហោះបេ៥២ (B52) ឬគ្រាប់បែកនុយក្លេអ៊ែរ មកជួយអន្តរាគមន៍ តាមការស្នើសុំរបស់បារាំង នេះជាដាច់ខាត ។

ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៥៤ កងទ័ពវៀតមិញ វាយដណ្តើមបានបន្ទាយឌៀនបៀនភូ ទាំងស្រុង កងទ័ពបារាំង ចំនួន១១៧២១នាក់ (ក្នុងនោះ មានអ្នករបួសចំនួន ៤៤៣៦នាក់) បានក្លាយជាឈ្លើយសឹករបស់ពួកវៀតមិញ ហើយឈ្លើយសឹកទាំងឡាយណា ដែលមិនរងរបួស ឬមិនមានជំងឺអ្វី ត្រូវគេបង្ខំឱ្យដើរជាហ្វូងៗ ទៅកន្លែងឃុំឃាំង នៅទិសខាងជើង និងខាងកើត មានចម្ងាយរាប់រយគីឡូម៉ែត្រ ដោយនៅក្នុងពេលធ្វើដំណើរនោះ ឈ្លើយសឹកបារាំង ត្រូវស្លាប់ដោយជំងឺរាប់រយនាក់។

ចំណែកអ្នករងរបួសធ្ងន់ ចំនួន៨៥៨នាក់ ត្រូវបានអង្គការកាកបាទក្រហមអន្តរជាតិបញ្ជូនទៅព្យាបាល នៅកន្លែងផ្សេងៗទៀត។ ឯអ្នករងរបួសស្រាល ក្រោយពីគ្រូពេទ្យអង្គការកាកបាទក្រហមព្យាបាលរួច ត្រូវបញ្ជូនទៅដាក់នៅកន្លែងឃុំឃាំងជាមួយឈ្លើយសឹកបារាំងរាប់ម៉ឺននាក់នោះ ផងដែរ។

ពេលនោះ ហូ ជីមិញ មេដឹកនាំវៀតណាមកុម្មុយនិស្ត បានដាក់បញ្ជាដល់កងទ័ពរបស់គាត់ ហាមដាច់ខាតមិនឱ្យសម្លាប់ឈ្លើយសឹកបារាំងណាម្នាក់ឡើយ។ គាត់ឱ្យរក្សាទុកឈ្លើយសឹកទាំងអស់នោះ ធ្វើជាចំណាប់ខ្មាំង ដើម្បីដាក់សម្ពាធទៅលើកាគីបារាំង នៅឯ

តុចរចាក្នុងសន្និសីទ នៅក្រុងហ្សឺណែវ ដែលកំពុងចាប់ផ្តើមដើមខែឧសភា នោះដែរ។

លទ្ធផលនៃការវាយប្រយុទ្ធស៊ីសាច់ហុតឈាមគ្នា នៅសមរភូមិឌៀនបៀនភូ មានរយៈពេលតែ១ខែ ៣សប្តាហ៍ និង៣ថ្ងៃនោះ ខាងកងទ័ពបារាំង ត្រូវស្លាប់ចំនួន២២៩៣នាក់ បាត់ខ្លួនចំនួន១៧២៩នាក់ ចាប់បានជាឈ្លើយសឹក ចំនួន១១៧២១នាក់ ក្នុងនោះមានអ្នករបួសស្រាល ចំនួន៤៤៣៦នាក់ ហើយ២ភាគ៣ ក្នុងចំណោមឈ្លើយសឹកទាំង១១៧២១នាក់នោះ ត្រូវបានស្លាប់ជាបន្តបន្ទាប់ ។ ទីបំផុត នៅសល់តែឈ្លើយសឹកចំនួន៣២៩០នាក់ប៉ុណ្ណោះ ដែលពួកវៀតមិញ បានប្រគល់ទៅឱ្យរដ្ឋាភិបាលបារាំង។

ជាមួយគ្នានេះ យន្តហោះចម្បាំងរបស់បារាំង ចំនួន៦២គ្រឿង និងរថក្រោះ១០គ្រឿង ត្រូវបាត់បង់ ហើយយន្តហោះចម្បាំង១៦៧គ្រឿងទៀត ត្រូវខូចខាត។ ចំណែកកងទ័ពវៀតមិញ ស្លាប់ចំនួន៤០២០នាក់ របួសចំនួន៩១១៨នាក់ និងបាត់ខ្លួន ចំនួន៧៩២នាក់។

៦៦
សង្គ្រាមនៅឧបទ្វីបកូរ៉េ



កងទ័ពអាមេរិក ចូលធ្វើអន្តរាគមន៍ក្នុងសង្គ្រាមនៅកូរ៉េ

ឧបទ្វីបកូរ៉េ បានធ្លាក់ទៅក្រោមការត្រួតត្រារបស់ចក្រភពជប៉ុន ចាប់តាំងពីដើមសតវត្សរ៍ទី២០មកម្ល៉េះ ហើយបន្ទាប់ពីសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់ ឧបទ្វីបនេះបានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់សហរដ្ឋអាមេរិក និងសហភាពសូវៀត ជាអ្នកសម្រេចជោគវាសនាជាបន្តទៀត។

នៅក្នុងឆ្នាំ១៩៤៥ ពេលសង្គ្រាមលោកទី២ ហៀបនឹងបញ្ចប់ទៅហើយនោះ សហរដ្ឋអាមេរិក និងសហភាពសូវៀត ដែលពេលនោះជាសម្ព័ន្ធមិត្តនឹងគ្នា ក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងពួកណាហ្ស៊ី-ហ្វាស៊ិស្ត-ជប៉ុន (Nazi-Fascist-Japan) បានព្រមព្រៀងគ្នាបែងចែកឧបទ្វីបកូរ៉េ ជាពីរជាបណ្តោះអាសន្នសិន ដោយកំណត់យកខ្សែស្រេបទី៣៨ ធ្វើជាព្រំដែនរដ្ឋបាល ដោយពេលនោះ សហរដ្ឋអាមេរិក ជាអ្នកត្រួតត្រាកូរ៉េ ភាគខាងត្បូង រីឯសហភាពសូវៀត ជាអ្នកត្រួតត្រាកូរ៉េ ភាគខាងជើង។

ជាមួយគ្នានោះ មហាអំណាចទាំង២នេះ បានព្រមព្រៀងគ្នាថា ក្រោយពេលវាយឈ្នះជប៉ុន នឹងធ្វើការបង្រួបបង្រួមកូរ៉េ ឱ្យទៅជាប្រទេសតែមួយវិញដែរ។ ប៉ុន្តែ ក្តីសង្ឃឹមពី

ការបង្រួបបង្រួមកូរ៉េ នេះ ត្រូវរលាយទៅវិញ ក្រោយពីសហរដ្ឋអាមេរិក និងសហភាពសូវៀត ក្លាយជាគូសត្រូវនឹងគ្នា។

នៅក្នុងឆ្នាំ១៩៤៧ ពេលវិបត្តិកូរ៉េ គ្មានដំណោះស្រាយ សហរដ្ឋអាមេរិកក៏បានបញ្ជូនសំណុំរឿងនេះ ទៅឱ្យអង្គការសហប្រជាជាតិជាអ្នកជួយដោះស្រាយ។ តាមសេចក្តីសម្រេចចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៤៧ អង្គការសហប្រជាជាតិ បានកំណត់ឱ្យមានការបោះឆ្នោតសាកលទាំងនៅកូរ៉េ ភាគខាងជើង ទាំងនៅកូរ៉េ ភាគខាងត្បូង ដើម្បីធ្វើការបង្រួបបង្រួមប្រទេសកូរ៉េទាំង២ ឱ្យទៅជាប្រទេសតែមួយ ហើយកងទ័ពបរទេសទាំងអស់ គឺកងទ័ពសហរដ្ឋអាមេរិក និងសហភាពសូវៀត ក៏ត្រូវដកចេញពីប្រទេសកូរ៉េ ទាំង២ វិញដែរ។

នៅក្នុងខែឧសភា ឆ្នាំ១៩៤៨ ការបោះឆ្នោតសាកល នៅប្រទេសកូរ៉េខាងជើង និងនៅកូរ៉េខាងត្បូង ត្រូវបានរៀបចំឡើង ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ។ ប៉ុន្តែដោយសារមានការប្រឆាំងដំទាស់ពីសហភាពសូវៀត ការបោះឆ្នោតនោះ បានធ្វើឡើងតែនៅក្នុងប្រទេសកូរ៉េ ភាគខាងត្បូង ប៉ុណ្ណោះ។

ក្រោយលទ្ធផលនៃការបោះឆ្នោតនោះ នៅក្នុងខែសីហា ឆ្នាំ១៩៤៨ របបគ្រប់គ្រងតាមបែបលទ្ធិប្រជាធិបតេយ្យសេរីថ្មីមួយ នៅក្នុងប្រទេសកូរ៉េខាងត្បូង មានឈ្មោះថា សាធារណរដ្ឋកូរ៉េ ត្រូវបានបង្កើតឡើង ក្រោមការដឹកនាំរបស់ប្រធានាធិបតីជាប់ឆ្នោត ស៊ីងម៉ាន់ រី (Syngman Rhee) ។

១ខែក្រោយមក ប្រទេសកូរ៉េខាងជើង ក៏បានប្រកាសឈ្មោះរបបគ្រប់គ្រងខ្លួនឯងដែរថា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ ដឹកនាំដោយគីម អ៊ីលស៊ុង គ្រប់គ្រងតាមបែបលទ្ធិកុម្មុយនិស្តនិយម ដោយមានសហភាពសូវៀត ជាខ្នងបង្អែកយ៉ាងរឹងមាំ។

នៅក្នុងខែធ្នូ ឆ្នាំ១៩៤៨ អង្គការសហប្រជាជាតិ បានប្រកាសទទួលស្គាល់តែរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) តែមួយប៉ុណ្ណោះ ជារដ្ឋាភិបាលស្របច្បាប់។ ឯរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ (កូរ៉េខាងជើង) មានតែសហភាពសូវៀត, និងបណ្តាប្រទេសកុម្មុយនិស្តផ្សេងៗទៀត ជាអ្នកទទួលស្គាល់។ នៅក្នុងឆ្នាំ១៩៤៩



មេដឹកនាំកូរ៉េខាងជើង គីម អ៊ីលស៊ុង និងមេដឹកនាំសហភាពសូវៀត ស្តាលីន

សហរដ្ឋអាមេរិក និងសហភាពសូវៀត បានព្រមព្រៀងគ្នាដកកងទ័ពចេញពីប្រទេសកូរ៉េទាំង ២។

តែក្រោយពីសហរដ្ឋ-អាមេរិក ដកកងទ័ពចេញអស់មួយចំនួន ប្រទេសកូរ៉េខាងត្បូង មានកងទ័ពមិនដល់១០ម៉ឺននាក់ ហើយមិនសូវមានសមត្ថភាពប្រយុទ្ធទៀតផង។ ចំណែកប្រទេសកូរ៉េខាងជើង ក្រោយពីសហភាពសូវៀត ដកកងទ័ពចេញទៅ ពួកគេមានកងទ័ព ១៣៥០០០នាក់ បំពាក់ដោយអាវុធទំនើបៗ មានទាំងកាំភ្លើងធំ រថក្រោះ និងប្រព័ន្ធកាំជ្រួច ជាច្រើនទៀត។ ជាមួយគ្នានោះ សហភាពសូវៀត បានរក្សាទុកពួកជំនាញការយោធារបស់ខ្លួន នៅស្នើរគ្រប់អង្គភាពកងទ័ពរបស់កូរ៉េខាងជើង ទៀតផង។

ទោះបីមេដឹកនាំកូរ៉េទាំងពីរមាននិន្នាការនយោបាយផ្ទុយគ្នាទាំងស្រុង ក៏ពិតមែន ក៏ម្នាក់ៗ មានបំណងចង់បង្រួបបង្រួមកូរ៉េ ឱ្យទៅជាប្រទេសតែមួយ ក្រោមមហិច្ឆតាដឹកនាំតែរៀងៗខ្លួន។ បញ្ហានេះបានបង្កឱ្យមានជម្លោះព្រំដែន និងមានការប៉ះទង្គិចគ្នា ដោយអាវុធជាបន្តបន្ទាប់ នៅខ្សែបន្ទាត់ស្របទី៣៨ រហូតធ្វើឱ្យកងទ័ពគូសត្រូវជាពូជសាសន៍ឯងទាំងពីរត្រូវបាត់បង់ជីវិត សរុបជិត១ម៉ឺននាក់។

នៅក្នុងខែមីនា ឆ្នាំ១៩៤៩ មេដឹកនាំកូរ៉េខាងជើង គីម អ៊ីលស៊ុង (Kim Il Sung) បានធ្វើដំណើរទៅកាន់សហភាពសូវៀត ដើម្បីពិភាក្សា និងសុំការគាំទ្រពីមេដឹកនាំសហភាពសូវៀត គឺលោកស្តាលីន (Stalin) ក្នុងគោលបំណងវាយដណ្តើមយកកូរ៉េខាងត្បូង មកបង្រួបបង្រួមជាទឹកដីកូរ៉េតែមួយ។ តែស្តាលីន មិនគាំទ្រគំនិតរបស់មេដឹកនាំកូរ៉េខាងជើងនេះទេ ព្រោះពេលនោះកងទ័ព សហរដ្ឋអាមេរិក មិនទាន់ដកចេញអស់ពីកូរ៉េខាងត្បូង ទាំង



មេដឹកនាំកូរ៉េខាងជើង គីម អ៊ីលស៊ុង និងមេដឹកនាំចិន ម៉ៅ សេទុង

ស្រុងនៅឡើយ ហើយម្យ៉ាងទៀតមេដឹកនាំសហភាពសូវៀតខ្លាចសង្គ្រាមនៅកូរ៉េនោះ អូសទាញខ្លួនឱ្យធ្វើសង្គ្រាមផ្ទាល់ ជាមួយសហរដ្ឋអាមេរិកផងដែរ។

នៅក្នុងខែមិថុនា ឆ្នាំ ១៩៤៩ កងទ័ពសហរដ្ឋអាមេរិក ត្រូវដកចេញអស់ទាំងស្រុងពីកូរ៉េខាងត្បូង។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៤៩ សហភាពសូវៀត បានធ្វើការសោកល្បងអាវុធនុយក្លេអ៊ែរ ដោយជោគជ័យ។ ស្របពេលនោះដែរ សហរដ្ឋអាមេរិក បានបណ្តែតបណ្តោយឱ្យកងទ័ពបដិវត្តន៍ចិនដឹកនាំដោយម៉ៅ សេទុង វាយបណ្តេញកងទ័ពអ្នកជាតិនិយម ជៀង កៃជៀក ឱ្យរត់ទៅនៅកោះតៃវ៉ាន់ ដោយសហរដ្ឋអាមេរិក មិនបានជួយធ្វើអន្តរាគមន៍អ្វីបន្តិចនោះ ម៉ៅ សេទុង ក៏បានឡើងទៅជាមេដឹកនាំប្រទេសចិន ដោយបានបង្កើតនូវរបបគ្រប់គ្រងតាមបែបលទ្ធិកុម្មុយនិស្តមួយ មានឈ្មោះថា សាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ ។

នៅក្នុងខែមករា ឆ្នាំ១៩៥០ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក បានប្រកាសថា ឧបទ្វីបកូរ៉េ មិនមែនជាតំបន់យុទ្ធសាស្ត្រសំខាន់របស់ខ្លួននោះទេ។

លុះដល់ខែមេសា ឆ្នាំ១៩៥០ ដោយសារហេតុផលទាំង៤ខាងលើនេះហើយ ទើបមេដឹកនាំសហភាពសូវៀត ស្តាលីន ហ៊ានបើកភ្លើងខៀវឱ្យមេដឹកនាំកូរ៉េខាងជើង គីម អ៊ីលស៊ុង (Kim Il Sung) ឱ្យបើកការវាយប្រហារទៅលើប្រទេសកូរ៉េខាងត្បូង។

នៅខែឧសភា ឆ្នាំ១៩៥០ មេដឹកនាំកូរ៉េខាងជើង គីម អ៊ីលស៊ុង ក៏បានធ្វើដំណើរទៅក្រុងប៉េកាំង ដើម្បីជួបពិភាក្សា និងសុំការគាំទ្រពីមេដឹកនាំចិន ម៉ៅ សេទុង ពីបញ្ហាលើកកងទ័ពទៅវាយដណ្តើមយកកូរ៉េខាងត្បូង យកមកបង្រួបបង្រួមទឹកដីកូរ៉េ តែមួយវិញ។

៦៧
កូរ៉េទាំងពីរ ឈ្លានពានគ្នាទៅវិញទៅមក



ទាហានអាមេរិក ក្នុងសង្គ្រាមឧបទ្វីបកូរ៉េ

នៅព្រឹកព្រលឹម ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥០ ដោយមានការគាំទ្រពីសហភាពសូវៀត និងចិន ផងនោះ សង្គ្រាមនៅឧបទ្វីបកូរ៉េ ត្រូវបានចាប់ផ្តើមផ្ទុះឡើង។ គីម អ៊ីលស៊ុង (Kim Il Sung) មេដឹកនាំកូរ៉េខាងជើង បានបញ្ជាឱ្យកងទ័ពថ្មើរជើងរបស់ខ្លួន គាំទ្រដោយកងកាំភ្លើងធំ កងរថក្រោះ បើកការវាយលុកចូលទៅក្នុងទឹកដីកូរ៉េខាងត្បូង ហើយរយៈពេលតែ៣ថ្ងៃប៉ុណ្ណោះ ពួកគេបានដណ្តើមកាន់កាប់រដ្ឋធានីសេអ៊ូល របស់កូរ៉េខាងត្បូង ដោយជោគជ័យ។

មេដឹកនាំ និងកងទ័ពកូរ៉េខាងត្បូង នៅសល់តែប្រមាណ២ម៉ឺននាក់ បាននាំគ្នារត់ភៀសខ្លួនពីរដ្ឋធានីសេអ៊ូល ទៅក្រុងប៊ូសាន ដើម្បីទប់ទល់ជាមួយកងទ័ពកូរ៉េខាងជើងបន្តទៀត។

ពេលនោះប្រធានាធិបតីអាមេរិក ហារី ទ្រូម៉ាន់ (HARRY S. TRUMAN) យល់ឃើញថា មិនត្រូវបណ្តោយឱ្យពួកកុម្មុយនិស្តវាតទីឈ្លានពានប្រទេសកូរ៉េខាងត្បូង តាមអំពើចិត្តយ៉ាងដូច្នេះទេ និងមានបំណងចង់បញ្ជូនកងទ័ពរបស់ខ្លួនឱ្យមកជួយធ្វើអន្តរាគមន៍វាយបណ្តេញ

កងទ័ពកូរ៉េខាងជើង ឱ្យចេញពីទឹកដីកូរ៉េខាងត្បូង ភ្លាមៗវិញដែរ តែគាត់ចង់ឱ្យការជួយធ្វើអន្តរាគមន៍នេះ ស្ថិតនៅក្រោមឆត្ររបស់អង្គការសហប្រជាជាតិ វិញ ទើបមិនមានការថ្កោលទោសពីមតិសាកលលោក។

នៅថ្ងៃទី២៥ ខែមិថុនា នោះដែរ អង្គការសហប្រជាជាតិ ក៏បានប្រកាសថ្កោលទោសចំពោះការឈ្លានពានរបស់ប្រទេសកូរ៉េខាងជើង មកក្នុងទឹកដីកូរ៉េខាងត្បូង។ ២ថ្ងៃក្រោយមក អង្គការសហប្រជាជាតិ បានសម្រេចកោះប្រជុំប្រទេសមហាអំណាច ជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខ ដើម្បីពិភាក្សាគ្នាពីបញ្ហាបញ្ជូនកងទ័ពរបស់អង្គការសហប្រជាជាតិ ទៅវាយបណ្តេញកងទ័ពកូរ៉េខាងជើង ឱ្យដកចេញពីទឹកដីកូរ៉េខាងត្បូងវិញ។ ពេលនោះ ប្រទេសជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក រួមមាន ប្រទេសបារាំង អង់គ្លេស កាណាដា អូស្ត្រាលី ហ្វីលីពីន និងថៃ បានស្ម័គ្រចិត្ត ត្រៀមបញ្ជូនកងទ័ពខ្លួន សរុបជាង ៣០ម៉ឺននាក់ ក្នុងនោះ មានកងទ័ពអាមេរិក ប្រមាណ២៦ម៉ឺននាក់ និងកងទ័ពសម្ព័ន្ធមិត្តប្រមាណជាង៤ម៉ឺននាក់ទៀត ឱ្យទៅធ្វើអន្តរាគមន៍ វាយបណ្តេញកងទ័ពកូរ៉េខាងជើង ឱ្យចេញពីកូរ៉េខាងត្បូង ក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ ឌូក្លាស ម៉ាក់អាធ័រ (Douglas MacArthur) មេបញ្ជាការយោធាអាមេរិក ប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិកនោះ។

តែពេលនោះ សហភាពសូវៀត ក្នុងនាមជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែរនោះ បានធ្វើពហិការមិនចូលប្រជុំតាំងពីខែមករា ឆ្នាំ១៩៥០ មកម្ល៉េះ ដើម្បីប្រឆាំងតវ៉ានឹងអង្គការសហប្រជាជាតិ មិនព្រមទទួលស្គាល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន របស់ម៉ៅ សេទុង ដែលបានឡើងមកដឹកនាំប្រទេស តាំងពីខែតុលា ឆ្នាំ១៩៤៩ មកនោះ ថា ជារដ្ឋាភិបាលស្របច្បាប់របស់ចិន ហើយនៅតែបន្តទទួលស្គាល់រដ្ឋាភិបាលសាធារណរដ្ឋចិន របស់អ្នកជាតិនិយម ជ្យាង កៃជ្យាក ដែលចាញ់សង្គ្រាម រត់ទៅនៅលើកោះតៃវ៉ាន់ហើយនោះ ថាជារដ្ឋាភិបាលស្របច្បាប់របស់ចិន និងជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ដដែល។

ដោយសារអវត្តមានសហភាពសូវៀត នៅក្នុងកិច្ចប្រជុំសមាជិកអចិន្ត្រៃយ៍នៃក្រុម-



អង្គការសហប្រជាជាតិប្រជុំ ដោះស្រាយបញ្ហាសង្គ្រាមនៅកូរ៉េ

ប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ នោះហើយ ទើបក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ មិនអាចអនុម័តសេចក្តីសម្រេចក្នុងការបញ្ជូនកម្លាំងកងទ័ពសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត ក្នុងនាមជាកងទ័ពមួកខៀវរបស់អង្គការសហប្រជាជាតិ ទៅវាយបណ្តេញកងទ័ពកូរ៉េខាងជើង ឱ្យដកចេញពីទឹកដីកូរ៉េខាងត្បូងវិញ បានដូចការរំពឹងទុករបស់ប្រធានាធិបតីអាមេរិក ហារី ទ្រូម៉ាន់ (HARRY S. TRUMAN)។

តែទោះបីយ៉ាងនេះក៏ដោយ ក៏ឧត្តមសេនីយ៍ ឌូក្លាស ម៉ាក់អាធួរ (Douglas Mac-Arthur) មេបញ្ជាការយោធាអាមេរិក ប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិក កំពុងឈរជើងនៅសមុទ្រជប៉ុន ក៏បានបញ្ជូនកងទ័ពអាមេរិក ចេញពីមូលដ្ឋាននៅប្រទេសជប៉ុន ចំនួន៤ កងពល ដើម្បីទៅជួយវាយបណ្តេញកងទ័ពកូរ៉េខាងជើង កំពុងធ្វើការឡោមព័ទ្ធទីក្រុងប៊ូសាន របស់ប្រទេសកូរ៉េខាងត្បូង នោះដែរ ។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៥០ នៅពេលដែលកងទ័ពកូរ៉េខាងជើង កំពុងជាប់ដៃប្រយុទ្ធនៅក្នុងទឹកដីកូរ៉េខាងត្បូង ឧត្តមសេនីយ៍ ឌូក្លាស ម៉ាក់អាធួរ (Douglas Mac-Arthur) បានបញ្ជូនកងទ័ពអាមេរិក ចំនួនជាង៤ម៉ឺននាក់ និងកងទ័ពកូរ៉េខាងត្បូង ចំនួនជាង ៨ពាន់នាក់ តាមនាវា ចូលទៅវាយកំពង់ផែរបស់កូរ៉េខាងជើង ដើម្បីកាត់ផ្តាច់ការដឹកជញ្ជូនកងទ័ពជំនួយ និងភស្តុភារផ្សេងៗទៀត ធ្វើឱ្យកងទ័ពកូរ៉េខាងជើង នៅក្នុងទឹកដី

កូរ៉េខាងត្បូង ត្រូវបរាជ័យនៅគ្រប់សមរភូមិ ។

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៥០ កងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្តវាយដណ្តើមបានរដ្ឋធានីសេអ៊ូល មកវិញ ហើយកងទ័ពកូរ៉េខាងជើង ក៏បាននាំគ្នាដកថយឆ្លងកាត់ខ្សែស្របទី៣៨ ចូលទៅក្នុងទឹកដីកូរ៉េខាងជើង វិញអស់ដែរ។ មិនតែប៉ុណ្ណោះ កងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្ត បានបន្តបើកការវាយលុកចូលជ្រៅទៅក្នុងទឹកដីកូរ៉េខាងជើង និងបានបោះទីតាំងឈរជើង នៅលើទឹកដីកូរ៉េខាងជើង ថែមទៀតផង។

នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៥០ មេដឹកនាំសហភាពសូវៀត ស្តាលីន បានផ្ញើសារទូរលេខមួយទៅជូនមេដឹកនាំចិន ម៉ៅ សេទុង ឱ្យបញ្ជូនកងទ័ពចិន មកជួយកូរ៉េខាងជើង ជាបន្ទាន់ ព្រោះសហភាពសូវៀត មិនអាចបញ្ជូនកងទ័ពខ្លួនឱ្យមកជួយកូរ៉េខាងជើង ដោយផ្ទាល់បានទេ។ ដោយមេដឹកនាំចិន យល់ឃើញថា ប្រទេសកូរ៉េខាងជើង ជាទ្រនាប់ដ៏សំខាន់មួយរបស់ខ្លួន ក្នុងការការពារការគំរាមកំហែងរបស់សហរដ្ឋអាមេរិក ផងដែរ ហើយប្រសិនបើកងទ័ពអាមេរិក មកឈរជើងនៅតាមបណ្តោយព្រំដែនរបស់ខ្លួន ជាមួយប្រទេសកូរ៉េខាងជើង ទៀតនោះ កងទ័ពអាមេរិក នឹងបន្តការឈ្លានពានមកលើទឹកដីខ្លួន ជាមិនខាន។ ដូច្នេះចិន ត្រូវតែបញ្ជូនកងទ័ពរបស់ខ្លួនទៅជួយវាយបណ្តេញកងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្ត ឱ្យចេញពីទឹកដីកូរ៉េខាងជើង វិញ។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៥០ ពេលកងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្តវាយដណ្តើមបានរដ្ឋធានីព្យុងយ៉ាង របស់កូរ៉េខាងជើង ចិនក៏បានបញ្ជូនកងទ័ពរបស់ខ្លួនប្រមាណ ១៣ម៉ឺននាក់ ឆ្លងកាត់ទន្លេយ៉ាលូ ជាចំណុចព្រំដែន ចូលទៅប្រទេសកូរ៉េខាងជើង តែម្តង។

នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៥០ កងទ័ពចិន និងកូរ៉េខាងជើង បានសហការគ្នាបើកការវាយបណ្តេញកងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្តឱ្យចេញពីទឹកដីកូរ៉េខាងជើង ជាបន្តបន្ទាប់នៅគ្រប់សមរភូមិ ហើយក្នុងរយៈពេលប្រហែលតែ២ខែប៉ុណ្ណោះ កងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្ត បានបង្ខំចិត្តដកថយទៅកាន់ព្រំដែនត្រង់ខ្សែស្របទី៣៨ ចូលទៅក្នុងទឹកដីកូរ៉េខាងត្បូង វិញអស់។

៦៨
ជម្លោះនៅឧបទ្វីបកូរ៉េ នៅតែគ្មានដំណោះស្រាយ



កងទ័ពកុម្មុយនិស្តកូរ៉េខាងជើង អបអរជ័យជម្នះរបស់ពួកគេ

នៅទីក្រុងញូវយ៉ក ប្រទេសមហាអំណាចទាំង៥ ជាសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានបើកកិច្ចប្រជុំពិសេសមួយ ដើម្បីស្វែងរកដំណោះស្រាយបញ្ចប់សង្គ្រាមនៅឧបទ្វីបកូរ៉េ តែភាគីចិន មិនព្រមទទួលយកបទឈប់បាញ់គ្នា ដែលស្នើឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនោះទេ ពិសេស ដោយឃើញកងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្ត កាន់តែចុះខ្សោយនៅលើសមរភូមិ កងទ័ពចិនបានបន្តវាយលុកឆ្លងខ្សែស្របទី៣៨ ចូលទៅក្នុងទឹកដីកូរ៉េខាងត្បូង រហូតទៅដណ្តើមកាន់កាប់រដ្ឋធានីសេអ៊ូល នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៥១។

ពេលនោះ មេដឹកនាំសហរដ្ឋអាមេរិក ក៏បានពិចារណាពីការធ្វើសង្គ្រាម ដោយចេញមុខជាមួយនឹងប្រទេសចិន ដើម្បីជាការសងសឹកវិញដែរ។ តែក្រោយពីទទួលដំណឹងភ្លាម

រដ្ឋមន្ត្រីក្រសួងការបរទេសអង់គ្លេស ក៏បានធ្វើដំណើរទៅជួបប្រជានាធិតីអាមេរិកហារី ទ្រូម៉ាន់ (HARRY S. TRUMAN) ប្រាប់ពីការព្រួយបារម្ភរបស់ប្រទេសអង់គ្លេស និងបណ្តាប្រទេសផ្សេងៗទៀតជាសម្ព័ន្ធមិត្តរបស់អាមេរិកថា ប្រទេសចិន ជាសម្ព័ន្ធមិត្តជិតស្និទ្ធបំផុតរបស់សហភាពសូវៀត ដូច្នេះ បើសហរដ្ឋអាមេរិក ធ្វើសង្គ្រាមដោយចេញមុខជាមួយប្រទេសចិនមែននោះ សហភាពសូវៀត នឹងចូលមកជួយចិន ដែរនោះ ប្រាកដជាធ្វើឱ្យសង្គ្រាមលោកលើកទី៣ផ្ទុះឡើងជាមិនខាន។ តែប្រធានាធិបតីអាមេរិកហារី ទ្រូម៉ាន់ (HARRY S. TRUMAN) មិនបានឆ្លើយតបទៅរដ្ឋមន្ត្រីក្រសួងការបរទេសអង់គ្លេស ថាយ៉ាងណានោះទេ។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៥១ ខណៈសហរដ្ឋអាមេរិក មិនទាន់សម្រេចចិត្ត ស្តីពីការធ្វើសង្គ្រាមដោយចេញមុខជាមួយប្រទេសចិន នោះ កងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្ត ក៏បានវាយដណ្តើមបានរដ្ឋធានីសេអ៊ូល មកវិញ និងបានវាយបណ្តេញកងទ័ពចិន និងកូរ៉េខាងជើង នៅសមរភូមិផ្សេងៗទៀត ឱ្យដកថយឆ្លងកាត់ខ្សែស្របទី៣៨ ចូលទៅក្នុងទឹកដីកូរ៉េខាងជើង វិញអស់។

ពេលនោះ ប្រធានាធិបតីអាមេរិក ហារី ទ្រូម៉ាន់ (HARRY S. TRUMAN) ក្នុងនាមជាអគ្គមេបញ្ជាការកងទ័ព បានចេញបទបញ្ជា មិនឱ្យកងទ័ពអាមេរិក និងកងទ័ពសម្ព័ន្ធមិត្ត ឆ្លងកាត់ខ្សែស្របទី៣៨ ដេញតាមវាយកងទ័ពចិន និងកូរ៉េខាងជើង ចូលទៅក្នុងទឹកដីរបស់កូរ៉េខាងជើង ដូចមុនទៀតទេ ហើយក៏មិនធ្វើការវាយប្រហារណាមួយ ទៅលើប្រទេសចិន នោះដែរ។

ប្រធានាធិបតីអាមេរិក រូបនេះ ចង់ឱ្យសភាពការណ៍នៅឧបទ្វីបកូរ៉េ មានប្រក្រតីភាពឡើងវិញ ដូចមុន ពេលកងទ័ពកូរ៉េខាងជើង ចូលឈ្លានពានទៅក្នុងទឹកដីកូរ៉េខាងត្បូង ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥០ ព្រមទាំងចង់ឱ្យប្រទេសចិន និងកូរ៉េខាងជើង ចុះកិច្ចព្រមព្រៀងសន្តិភាពមួយ។

តែឧត្តមសេនីយ៍ ឌូក្លាស ម៉ាក់អាវ័ធួរ (Douglas MacArthur) មេបញ្ជាការយោធាអាមេរិក ប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិក បានប្រឆាំងជំទាស់នឹងគំនិតរបស់ប្រធានាធិបតី



ឧត្តមសេនីយ៍ឆ្មាយ៥ ឌូក្លាស ម៉ាក់អាធួរ និងប្រធានាធិបតី ហារី ទ្រូម៉ាន់

របស់ខ្លួន ដោយគាត់នៅតែមានៈ ចង់បន្តបើកការវាយប្រហារចូលទៅក្នុងទឹកដីរបស់កូរ៉េខាងជើងជាថ្មីម្តងទៀត ហើយគាត់ថែមទាំងបានទាមទារឱ្យប្រធានាធិបតី ហារី ទ្រូម៉ាន់ (HARRY S. TRUMAN) ចេញបទបញ្ជាឱ្យកងទ័ពអាកាសបើកការវាយប្រហារទៅលើប្រទេស ចិន និងប្រើអាវុធនុយក្លេអ៊ែរ ទៀតផង ប្រសិនបើចាំបាច់។

មិនតែប៉ុណ្ណោះ ឧត្តមសេនីយ៍ ឌូក្លាស ម៉ាក់អាធួរ (Douglas MacArthur) ក៏បានផ្ញើលិខិតទៅជូនព្រឹទ្ធសភា និងបណ្តាញព័ត៌មានអាមេរិក ឱ្យបានដឹងពីរឿងនេះ ផងដែរ។

ដោយសាររឿងនេះហើយ ទើបបានជានៅក្នុងខែមេសា ឆ្នាំ១៩៥១ ប្រធានាធិបតី ហារី ទ្រូម៉ាន់ (HARRY S. TRUMAN) បានសម្រេចដកតំណែងឧត្តមសេនីយ៍ ឌូក្លាស ម៉ាក់អាធួរ (Douglas MacArthur) ពីបទមិនស្តាប់បញ្ជាប្រធានាធិបតី ជាអគ្គមេបញ្ជាការកងទ័ពអាមេរិក។

ពីខែកក្កដា ដល់ខែសីហា ឆ្នាំ១៩៥១ ភាគីទាំងសងខាងនៅទ្រឹង មិនមានបង្ក ហេតុការណ៍អាក្រក់ណាមួយ គួរឱ្យកត់សម្គាល់ នៅតាមបណ្តោយខ្សែស្របទី៣៨ នោះទេ។ ប្រទេសមហាអំណាចទាំង៥ ជាសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក៏បានបើកការចរចាគ្នាពីបទឈប់បាញ់ជាបន្តបន្ទាប់ដែរ។ តែការចរចានោះត្រូវបរាជ័យជានិច្ច ហើយការប៉ះទង្គិចគ្នា នៅតាមបណ្តោយព្រំដែន ក៏ចាប់ផ្តើមកើតមានជាហូរហែបន្តមក។

រហូតមកដល់ខែមករា ឆ្នាំ១៩៥៣ ដ្វៃត៍ ឌី. អៃសិនហាវើរ (Dwight D. Eisenhower) ជាអ្នកចេញមុខប្រឆាំងនឹងសង្គ្រាមនៅឧបទ្វីបកូរ៉េ បានជាប់ឆ្នោតជាប្រធានាធិបតី

អាមេរិក បន្តពីហារី ទ្រូម៉ាន់ (HARRY S. TRUMAN) ដែលត្រូវចប់អាណត្តិនោះ គាត់បានរិះរក គ្រប់មធ្យោបាយធ្វើយ៉ាងណា ដើម្បីបញ្ចប់សង្គ្រាមនៅឧបទ្វីបកូរ៉េឱ្យបានឆាប់បំផុត។ គាត់ បានចាត់រដ្ឋមន្ត្រីការបរទេស ឱ្យទៅជួបចរចាជាមួយភាគីចិន ជាថ្មីឡើងវិញ ។ គាប់ជួនពេលនោះ មេដឹកនាំសហភាពសូវៀត ហ្សូសេហ្វ ស្តាលីន (Joseph Stalin) ជាបុរសខ្លាំងរបស់ប្លុកកុម្មុយនិស្ត ក៏បានទទួលមរណភាព នៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៣ ដែរ។

នៅចុងខែឧសភា ឆ្នាំ១៩៥៣ ប្រធានាធិបតីអាមេរិក ដ្វៃត៍ ឌី. អៃសិនហាវើរ (Dwight D. Eisenhower) បានគំរាមទៅមេដឹកនាំចិន ដោយត្រង់ៗថា បើសង្គ្រាមនៅឧបទ្វីបកូរ៉េ នេះមិនអាចបញ្ចប់បាន តាមរយៈការជួបចរចាគ្នានោះទេ គាត់នឹងប្រើអាវុធនុយក្លេអ៊ែរ ដើម្បីបញ្ចប់សង្គ្រាមនេះ។

សង្គ្រាមនៅឧបទ្វីបកូរ៉េ មានរយៈពេលតែជាង៣ឆ្នាំប៉ុណ្ណោះ សហរដ្ឋអាមេរិកបានចំណាយប្រាក់អស់ប្រមាណជា ៣០ពាន់លានដុល្លារ (សម័យនោះ ៣០ពាន់លានដុល្លារពិតជាមិនធម្មតាទេ)។ ជាមួយគ្នានោះ ក្នុងចំណោមទាហានអាមេរិក ប្រមាណជាជិត ២



គំនរសាកសពដោយសារសង្គ្រាមនៅឧបទ្វីបកូរ៉េ

លាននាក់ ត្រូវបញ្ជូនទៅធ្វើសង្គ្រាមនៅសមរភូមិកូរ៉េខាងត្បូង មានចំនួន ៣៦៥៧៤នាក់ បានពលីជីវិត និងរបួសប្រមាណ ១០០,០០០នាក់។

ចំណែកទាហានកូរ៉េខាងជើង រួមទាំងខាងត្បូង បានបាត់បង់អាយុជីវិតប្រហែលជា ៦២០,០០០នាក់ ហើយពលរដ្ឋកូរ៉េរហូតដល់ទៅប្រមាណ៤លាននាក់ បានស្លាប់បាត់បង់ជីវិត ។ ដោយឡែក ប្រទេសចិន នៅជាប់ព្រំដែនខាងកូរ៉េខាងជើង បានបាត់បង់អាយុជីវិតប្រជាជនខ្លួន អស់ប្រហែលជា ៩២០,០០០នាក់។

ទីបំផុត ក្រោយការខិតខំចរចាគ្នាអស់រយៈពេលជាង២ឆ្នាំមក នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៥៣ ប្រទេសមហាអំណាចទាំង៥ ជាសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក៏បានព្រមព្រៀងគ្នាលើបទឈប់បាញ់ ហើយតំបន់គ្មានកងទ័ព នៅតាមបណ្តោយព្រំដែនប្រទេសកូរ៉េទាំង២ មានទទឹងប្រវែងជាង៣គីឡូម៉ែត្រ ត្រូវបានបង្កើតឡើង។ រីឯកិច្ចព្រមព្រៀងនៃការបញ្ចប់សង្គ្រាមជាស្ថាពរ នឹងត្រូវចុះហត្ថលេខា នៅពេលក្រោយ។ ប៉ុន្តែរហូតដល់មានការចរចារកដំណោះស្រាយសន្តិភាពនៅឧបទ្វីបកូរ៉េ នៅក្រុងហ្សឺណែវ ប្រទេសស្វីស ចាប់ពីថ្ងៃទី២៦ ខែមេសា រហូតដល់ថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៥៤ បញ្ហាជម្លោះនៅឧបទ្វីបកូរ៉េ ក៏នៅតែគ្មានដំណោះស្រាយដដែល ។

៦៩
សន្និសីទក្រុងហ្សឺណែវ
សម សារី ឡើងជំទាស់នឹង ជាំ វ៉ាន់ដុង



សន្និសីទក្រុងហ្សឺណែវ

សន្និសីទនេះ បានធ្វើឡើងនៅប្រទេសស្វីស ចាប់ពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ក្នុងបំណងស្វែងរកដំណោះស្រាយសន្តិភាព នៅឧបទ្វីបកូរ៉េ និងនៅឥណ្ឌូចិន។ បញ្ហាសង្គ្រាមនៅឧបទ្វីបកូរ៉េ ត្រូវបានសន្និសីទនេះ លើកយកមកដោះស្រាយមុន តែត្រូវបរាជ័យ ពោលគឺនៅតែគ្មានដំណោះស្រាយ រហូតដល់សព្វថ្ងៃ។

មុនពេលបើកសន្និសីទក្រុងហ្សឺណែវ សឺង ង៉ុកថាញ់ បានផ្ញើលិខិតមួយប្រគល់ឱ្យគ្រប់តំណាងប្រតិភូបណ្តាប្រទេសដែលចូលរួមទាំងអស់ ព្រមទាំងប្រទេសជាអ្នកសង្កេតការណ៍ផងដែរ ដោយគាត់បានតវ៉ាថា បើអង្គសន្និសីទនេះអនុញ្ញាតឲ្យគណៈប្រតិភូរដ្ឋាភិបាលតស៊ូរបស់សឺង ង៉ុកមិញ ចូលប្រជុំនោះ សន្និសីទនេះ ក៏ត្រូវអនុញ្ញាតឲ្យគណៈប្រតិភូប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិរបស់គាត់ចូលប្រជុំផងដែរ។

បន្ទាប់ពីការស្វែងរកដំណោះស្រាយជម្លោះនៅឧបទ្វីបកូរ៉េ ត្រូវបរាជ័យ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៥៤ គឺរយៈពេល១ថ្ងៃ ក្រោយកងទ័ពវៀតមិញ ទទួលបានជ័យជម្នះដ៏ត្រចះត្រចង់លើកងទ័ពបារាំង នៅសមរភូមិឌៀនបៀនភូ បញ្ហាជម្លោះឥណ្ឌូចិន ត្រូវបានសន្និសីទក្រុងហ្សឺណែវ លើកយកមកធ្វើការពិភាក្សាដោះស្រាយ ដោយមានការចូលរួមពីគណៈប្រតិភូបណ្តាប្រទេសជាមហាអំណាចទាំង៥ រួមមានៈ គណៈប្រតិភូបារាំង ដំបូង ដឹកនាំដោយ ហ្សក ប៊ីដូល(Georges Bidault) ជារដ្ឋមន្ត្រីក្រសួងការបរទេស។ ក្រោយមកគណៈប្រតិភូបារាំងនេះ ត្រូវដឹកនាំដោយ ម៉ង់ដេស ហ្រង់ (Mandés. France) ជានាយករដ្ឋមន្ត្រីបារាំង (ពីខែសីហា ឆ្នាំ១៩៥៤ ដល់ខែកុម្ភៈ ឆ្នាំ១៩៥៥) វិញ។

គណៈប្រតិភូអាមេរិក ដឹកនាំដោយអនុរដ្ឋមន្ត្រីការបរទេស ប៊ីដែល ស្មីត (Bedell Smith) ជាអតីតនាយកទីភ្នាក់ងារស៊ើបការណ៍សម្ងាត់ សេអ៊ីអា (CIA = Central Intelligence Agency) ពីឆ្នាំ១៩៥០ ដល់១៩៥៣។ ប្រតិភូសហភាពសូវៀត ដឹកនាំដោយ ម៉ូឡូតូវ (Vyacheslav Mikhailovich Molotov) ជារដ្ឋមន្ត្រីក្រសួងការបរទេស, គណៈប្រតិភូចិន ដឹកនាំដោយជូ អេនឡាយ ជានាយករដ្ឋមន្ត្រី និងគណៈប្រតិភូអង់គ្លេស ដឹកនាំដោយអង់តូនី អេដេន (Anthony Eden) ជារដ្ឋមន្តីក្រសួងការបរទេស។

ចំណែកភាគីដែលពាក់ព័ន្ធផ្ទាល់ក្នុងជម្លោះនេះ រួមមាន៤ភាគី គឺសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ឡាវ កម្ពុជា និងរដ្ឋវៀតណាម (វៀតណាមខាងត្បូង) ដែលមានស្តេចបាវដាយ ជាប្រមុខរដ្ឋ។

គណៈប្រតិភូកម្ពុជា រួមមានៈ ទេព ផន រដ្ឋមន្ត្រីក្រសួងការបរទេស សន្និសីទ និងធម្មការ ជាប្រធាន, នង គីមនី , សម សារី និងសឺន សាន ជាសមាជិក។ គណៈប្រតិភូលាវ ដឹកនាំដោយសាណា និកន ជានាយករដ្ឋមន្ត្រី, គណៈប្រតិភូវៀតណាមភាគខាងត្បូង សុទ្ធតែជាមេធាវី មានការចេះដឹងច្បាប់ជ្រៅជ្រះ និងគណៈប្រតិភូសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដឹកនាំដោយផាំ វ៉ាន់ដុង ជាឧបនាយរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស។

ពេលនោះ ផាំ វ៉ាន់ដុង ក៏បាននាំមេខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ ២នាក់ គឺ ម៉ី ផូ



គណៈប្រតិភូអាមេរិក ដឹកនាំដោយអនុរដ្ឋមន្ត្រីការបរទេស ប៊ីដែល ស្មីត (Bedell Smith)

និងកែវ មុនី ទៅជាមួយដែរ ហើយបានទាមទារឱ្យសន្និសីទក្រុងហ្សឺណែវ ទទួលស្គាល់មេខ្មែរឥស្សរៈទាំង២នាក់នេះ ជាតំណាងភាគីរដ្ឋាភិបាលខ្មែរឥស្សរៈ ដើម្បីបានចូលរួមចរចាក្នុងសន្និសីទនោះដែរ។

ប៉ុន្តែ ប្រធានគណៈប្រតិភូអាមេរិក ប៊ីដែល ស្មីត (Bedell Smith) បានជំទាស់នឹងការទាមទាររបស់ ផាំ វ៉ាន់ដុង ដោយសំអាងថា បញ្ហាតំណាងប្រទេស ឬភាគី ដែលត្រូវចូលរួមក្នុងសន្និសីទនេះ ត្រូវបានគេកំណត់ពីមុនរួចជាស្រេចហើយ មិនអាចមកសុំដាក់បញ្ចូលបន្ថែម ក្នុងពេលសន្និសីទកំពុងដំណើរការនៅពេលនេះបានទេ។

បន្ទាប់មក ហ្សក ប៊ីដូល(Georges Bidault) ប្រធានគណៈប្រតិភូបារាំង ក៏បានឡើងថ្លែងចំអកទៅ ផាំ វ៉ាន់ដុង ប្រធានគណៈប្រតិភូវៀតមិញ ថា តើឱ្យអង្គប្រជុំសន្និសីទនេះ ពិភាក្សាចរចាជាមួយរដ្ឋាភិបាលខ្មោច (រដ្ឋាភិបាលខ្មែរឥស្សរៈ និងឡាវ) ឬយ៉ាងណា?

ផាំ វ៉ាន់ដុង ក៏តបវិញថា កាលពីមុន រដ្ឋមន្ត្រីការបរទេសបារាំង ហ្សក ប៊ីដូល (Georges Bidault) នេះ ក៏បានចាត់ទុករដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមថា ជារដ្ឋាភិបាលខ្មោចដែរ តែការពិត រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមរបស់គាត់ ជារដ្ឋាភិបាលពេញលក្ខណៈច្បាប់។



សម សារី (រូបកណ្តាល)នៅក្នុងសន្និសីទក្រុងហ្សឺណែវ

ពេលនោះ សម សារី សមាជិកគណៈប្រតិភូកម្ពុជា ក៏បានឡើងជំទាស់ដែរថា អ្វីដែលផាំ វ៉ាន់ដុង ហៅថារដ្ឋាភិបាលខ្មែរឥស្សរៈ ជារបស់ដែលពួកវៀតមិញបង្កើតឡើងនោះ គឺមានតែនៅក្នុងអារម្មណ៍របស់បណ្តាប្តូកកុម្មុយនិស្តតែប៉ុណ្ណោះ។

ទាក់ទងដល់បញ្ហា ដ៏ចម្រូងចម្រាសខាងលើនេះ ភាគីអាមេរិក ប៊ីដែល ស្មីត (Bedell Smith) និងភាគីអង់គ្លេស អង់តូនី អេដេន (Anthony Eden) បានស្នើសុំឱ្យកបញ្ហារដ្ឋាភិបាលរបស់ខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ ទៅពិភាក្សាគ្នានៅក្នុងកិច្ចប្រជុំនៃបណ្តាប្រទេសជាមហាអំណាច នៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់ នាពេលក្រោយវិញ។

ក្រោយពីការប្រកាសបើកអង្គប្រជុំដំបូង ថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៥៤ ផាំ វ៉ាន់ដុង បានឡើងថ្លែងពីមូលហេតុនៃការចូលរួមរបស់ខ្លួន នៅក្នុងសន្និសីទនោះ និងនៅតែទាមទារឱ្យពួកមេដឹកនាំខ្មែរឥស្សរៈទាំង២នាក់ គឺមុី ផូ និងកែវ មុនី ជាតំណាងភាគីរដ្ឋាភិបាលខ្មែរឥស្សរៈសឹង ង៉ុកមិញ និងពួកប៉ាថេតឡាវ ជាតំណាងភាគីពាក់ព័ន្ធ នៅក្នុងសន្និសីទនោះដែរ ដោយគាត់បានអះអាងថា ភាគីទាំង២នេះ ជាតំណាងប្រជាជននៃប្រទេសកម្ពុជា និងប្រទេសឡាវ ដែលកំពុងតស៊ូធ្វើសង្គ្រាមដណ្តើមឯករាជ្យពីពួកបារាំង ហើយពួកនេះថែមទាំងមានទឹកដីជាច្រើន កាន់កាប់ត្រួតត្រាផងដែរ។

បន្ទាប់មក ម៉ូឡូតូវ (Molotov) រដ្ឋមន្ត្រីក្រសួងការបរទេសសហភាពសូវៀត ក៏បាន

ឡើងថ្លែងការណ៍មួយយ៉ាងវែង សម្តែងការគាំទ្រដល់ចលនាតស៊ូរបស់ពួកវៀតណាម កម្ពុជា និងឡាវ កំពុងធ្វើសង្គ្រាមរំដោះជាតិខ្លួន និងស្នើឱ្យសន្និសីទទទួលយកតំណាងរដ្ឋាភិបាលខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ ចូលប្រជុំផងដែរ។

ជាមួយគ្នានោះ ជូ អេនឡាយ នាយករដ្ឋមន្ត្រីចិន ក៏ឡើងមានមតិគាំទ្រការទាមទារឱ្យអង្គសន្និសីទ ទទួលយកភាគីរដ្ឋាភិបាលខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ បានចូលរួមក្នុងការចរចានោះ ដូចដែលគណៈប្រតិភូសហភាពសូវៀត បានស្នើសុំដែរ។

មុនពេលបើកសន្និសីទនេះ ហ្វូស្ទ័រ ឌុលេស (Foster Dulles) រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក បានថ្លែងតាមវិទ្យុ និងទូរទស្សន៍ នៅទីក្រុងវ៉ាស៊ីងតោន ដោយបង្ហាញពីសេចក្តីសង្ឃឹមថា លទ្ធផលនៃសន្និសីទក្រុងហ្សឺណែវ អាចរកដំណោះស្រាយពីបញ្ហាជម្លោះនៅឥណ្ឌូចិន ឱ្យមានការជ្រះស្រឡះឡើងវិញ។ តែអាមេរិក ក៏មានការព្រួយបារម្ភផងដែរ ប្រសិនបើសន្និសីទនេះ ឈានទៅដល់កិច្ចព្រមព្រៀងណាមួយ ដែលបើកផ្លូវឱ្យពួកកុម្មុយនិស្តមកត្រួតត្រា ឬឈ្លានពានតំបន់ឥណ្ឌូចិន បន្តទៀត។ ប្រសិនបើដូច្នេះមែន អាមេរិកត្រូវតែចូលរួមទប់ស្កាត់។

ចំណែកប្រធានាធិបតីអាមេរិក ដ្វៃត៍ ឌី. អៃសិនហាវើរ (Dwight D. Eisenhower) បានបញ្ជាក់ហើយ បញ្ជាក់ទៀតថា គាត់នឹងមិនឱ្យសកម្មភាពខាងយោធាណាមួយរបស់អាមេរិក នៅឥណ្ឌូចិនទេ ប្រសិនបើគ្មានការគាំទ្រពីព្រឹទ្ធសភា។

ប៊ីដែល ស្មីត (Bedell Smith) អនុរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ជាប្រធានគណៈប្រតិភូអាមេរិក ក៏បានផ្ញើសារទូរលេខ ទៅប្រាប់រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ហ្វូស្ទ័រ ឌុលេស (Foster Dulles) ដែរថា គាត់បានជួបពិភាក្សាជាមួយរដ្ឋមន្ត្រីការបរទេសបារាំង ហ្សក ប៊ីដូល (Georges Bidault) និងបានលើកឡើងថា នៅអាស៊ីអាគ្នេយ៍ ចាំបាច់យើងត្រូវតែរួមគ្នាបង្កើតអង្គការមួយហៅថា អង្គការសេអាតូ (SEATO = SouthEast Asia Treaty Organization) ហើយរដ្ឋមន្ត្រីការបរទេសបារាំង រូបនេះ ក៏បានយល់ព្រមក្នុងការបង្កើតអង្គការនេះហើយដែរ។

៧០
ជាំ វ៉ាន់ដុង នៅតែទាមទារឱ្យ ម៉ី ជូ និងកែវ មុនី ជាតំណាងភាគីខ្មែរឥស្សរៈ



ម៉ូឡូតូវ រដ្ឋមន្ត្រីក្រសួងការបរទេសសូវៀត និង ជាំ វ៉ាន់ដុង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាមខាងជើង

បន្ទាប់មក ហ្វូស្ទ័រ ឌុលេស (Foster Dulles) ក៏បានផ្ញើសារទូរលេខទៅប្រាប់ ប៊ី-ដែល ស្មីត (Bedell Smith) ជាអនុរដ្ឋមន្ត្រីរបស់គាត់វិញថា បារាំង នឹងយល់ពីគោលបំណងរបស់យើង ក្នុងការបង្កើតអង្គការសេអាតូ(SEATO) នេះ ហើយពួកគេប្រាកដជាដឹងថា យើងបានត្រៀមខ្លួនជាស្រេច ដើម្បីពិភាក្សាជាមួយពួកគេ(បារាំង)ពីបញ្ហាធ្វើសង្គ្រាមនៅឥណ្ឌូចិន ឱ្យប្រែក្លាយទៅជាសង្គ្រាមមានលក្ខណៈជាអន្តរជាតិ។

នៅពេល ហ្វូស្ទ័រ ឌុលេស (Foster Dulles) មកថ្លែង នៅក្នុងសន្និសីទនោះ គាត់ចង់ឱ្យភាគីចិន ឈប់គាំទ្រ ជាំ វ៉ាន់ដុង ក្នុងការទាមទារឱ្យរដ្ឋាភិបាលខ្មែរឥស្សរៈ និងពួកប៉ាថេត

ឡាវ ចូលរួមក្នុងសន្និសីទនោះ តទៅទៀត ហើយហ្វូស្ទ័រ ឌុលេស (Foster Dulles) ក៏បានលើកឡើងពីបញ្ហាបង្កើតអង្គការសេអាតូ (SEATO)នោះ ឱ្យអង្គប្រជុំបានដឹងផងដែរ។


ពេលនោះ ដោយសារជូ អេនឡាយ មានការព្រួយបារម្ភខ្លាចអាមេរិកចូលធ្វើអន្តរាគមន៍ខាងយោធានៅឥណ្ឌូចិន ហើយគាត់ក៏មិនចង់ឱ្យអាមេរិក ទៅបង្កើតមូលដ្ឋានយោធានៅក្នុងប្រទេសកម្ពុជាដែរ គាត់ក៏បានធ្វើសម្បទានជាបន្តបន្ទាប់ ក្នុងការឈប់គាំទ្រ ផាំ វ៉ាន់ដុង ដែលនៅតែទទូចទាមទារឱ្យរដ្ឋាភិបាលខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ បានចូលរួមក្នុងសន្និសីទនោះ តទៅទៀត ។ តែទោះជាយ៉ាងណា ក៏ ផាំ វ៉ាន់ដុង នៅតែបន្តទាមទារឱ្យរដ្ឋាភិបាលខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ បានចូលប្រជុំនៅក្នុងសន្និសីទនោះ ដូចកាលពីដើមទីដដែល ខណៈភាគីសហភាពសូវៀត បន្ទន់ឥរិយាបថបន្តិចចំពោះរឿងនេះ ក៏ដោយ។

យុទ្ធសាស្ត្រសំខាន់របស់មហាអំណាច និងប្រទេសជាសមាជិកអង្គសន្និសីទ នៅពេលនោះ គឺសម្រេចឱ្យមានការពិភាក្សាពីបញ្ហាកម្ពុជា និងឡាវ ដាច់ដោយឡែកគ្នាពីបញ្ហាវៀតណាម។

តំណាងរដ្ឋាភិបាលខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ មិនត្រូវបានអនុញ្ញាតឱ្យចូលប្រជុំក្នុងសន្និសីទនោះ ក៏ពិតមែន តែគេចង់ឱ្យតំណាងរាជរដ្ឋាភិបាលកម្ពុជា និងឡាវ កំពុងកាន់អំណាចពេញច្បាប់ និងចាត់ទុកពួកវៀតមិញ ជាអ្នកឈ្លានពានប្រទេសរបស់ខ្លួននោះធ្វើការចរចាជាមួយពួកវៀតមិញ ដោយផ្ទាល់តែម្តង។

លុះដល់សម័យប្រជុំពេញអង្គលើកទី២ ក្នុងថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៥៥ គណៈប្រតិភូវៀតមិញ ក៏បានស្នើសុំឱ្យមានការដកកងទ័ពទាំងអស់ ពីប្រទេសទាំង៣ ហើយរៀបចំឱ្យមានកិច្ចចរចារវាងរដ្ឋាភិបាលទាំងសងខាង នៅតាមប្រទេសរៀងៗខ្លួន គឺកម្ពុជា វៀតណាម ឡាវ និងស្នើឱ្យមានការបោះឆ្នោតដោយសេរី ដើម្បីបង្កើតរដ្ឋាភិបាលចម្រុះនៅតាមប្រទេសនីមួយៗ ដោយមិនមានការជ្រៀតជ្រែកពីខាងក្រៅ។

៧១
ទេព ផន សុំឱ្យដកចេញ
ទាំងកងទ័ពវៀតមិញ ទាំងកងទ័ពបារាំង



ទេព ផន រដ្ឋមន្ត្រីការបរទេសកម្ពុជា

ក្នុងជំនួបក្រៅផ្លូវការ ជាមួយគណៈប្រតិភូសហរដ្ឋអាមេរិក នៅថ្ងៃទី១១ ខែឧសភា ទេព ផន រដ្ឋមន្ត្រីការបរទេសរាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ប្រាប់ប្រធានគណៈប្រតិភូសហរដ្ឋអាមេរិក ប៊ីដែល ស្មីត(Bedell Smith) ថា កម្ពុជា ចង់ឱ្យមានការគាបសង្កត់យ៉ាងណា ដើម្បីឱ្យការដកកងទ័ពវៀតមិញ ដែលកំពុងឈ្លានពានមកលើទឹកដីកម្ពុជា និងកងវរសេនាតូចទាំងឡាយរបស់បារាំង ដែលកំពុងមានវត្តមាន ដើម្បីជួយទប់ទល់ការឈ្លានពានរបស់កងទ័ពវៀតមិញ នោះ ដកចេញពីកម្ពុជា ទាំងពីរតែម្តង។

សំណើរបស់រដ្ឋមន្ត្រីការបរទេសកម្ពុជានេះ ក៏មិនខុសគ្នាប៉ុន្មានពីសំណើរបស់មេដឹកនាំវៀតមិញ ផាំ វ៉ាន់ដុង ដែលសុំឱ្យមានការដកកងទ័ពបរទេសចេញពីកម្ពុជា វៀតណាម និងឡាវ នោះដែរ គឺគ្រាន់តែខុសគ្នាពីកាលបរិច្ឆេទនៃការដកទ័ពនោះប៉ុណ្ណោះ។

ជាមួយគ្នានេះ ទេព ផន បានសម្តែងនូវការពេញចិត្តយ៉ាងកក់ក្តៅបំផុត ចំពោះ

សំណើរបស់រដ្ឋមន្ត្រីការបរទេសអាមេរិក ហ្វូស្ទ័រ ឌុលេស (Foster Dulles) បានស្នើសុំឱ្យ មានកតិកាសញ្ញាការពារគ្នាទៅវិញទៅមកមួយ សម្រាប់អាស៊ីអាគ្នេយ៍ ហើយគាត់ក៏បាន ស្នើសុំឱ្យសហរដ្ឋអាមេរិក ផ្តល់ជំនួយជាអាវុធយុទ្ធភណ្ឌមកឱ្យកម្ពុជា ដោយផ្ទាល់តែម្តង ដោយមិនបាច់ផ្តល់តាមរយៈប្រទេសបារាំង ដូចធ្លាប់ធ្វើពីមុនៗមកនោះទៀតទេ។

ប៉ុន្តែ ប៊ីដែល ស្មីត (Bedell Smith) អនុរដ្ឋមន្ត្រីការបរទេសអាមេរិក បានស្នើសុំឱ្យ ទេព ផន ថ្លែងបញ្ជាក់ជូនអង្គសន្និសីទថា ពេលនេះ កម្ពុជា បានទទួលឯករាជ្យទាំងស្រុងពី បារាំង ហើយ។

៣ថ្ងៃក្រោយមក ទេព ផន ក៏បានឡើងថ្លែងការណ៍ក្នុងសម័យប្រជុំសន្និសីទពេញអង្គ លើកទី៤ ដូចអ្វីៗដែល ប៊ីដែល ស្មីត (Bedell Smith) បានស្នើសុំឱ្យគាត់លើកឡើងថ្លែង នោះមែន ដោយគាត់បញ្ជាក់ជូនអង្គប្រជុំថា កម្ពុជា ពិតជាបានទទួលឯករាជ្យពីបារាំង ទាំងស្រុង ចាប់តាំងពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មក។ ការលើកឡើងនេះធ្វើឱ្យ ប៊ីដែល ស្មីត (Bedell Smith) ពេញចិត្តពេញថ្លើមយ៉ាងខ្លាំង។

លើសពីនេះទៅទៀត ទេព ផន ក៏បានបញ្ជាក់បន្ថែម ផ្ទុយពីការពិតថា ពេលនេះ កងទ័ពបារាំង បានដកចេញពីកម្ពុជា ទាំងស្រុងហើយ ដោយគាត់ភ្លេចគិតថា កាលក្នុង សម័យប្រជុំពេញអង្គលើកទី១ រដ្ឋមន្ត្រីការបរទេសបារាំង ប៊ីដូល (Bidault) បានគូស បញ្ជាក់ថា បារាំង ចង់ដកកងទ័ព របស់ខ្លួនចេញពីប្រទេសឡាវ និងកម្ពុជា ដែរ តែត្រូវមាន លក្ខខណ្ឌមួយចំនួន។

នៅថ្ងៃទី១៨ ខែឧសភា នៅក្នុងកិច្ចប្រជុំក្រៅផ្លូវការមួយ គណៈប្រតិភូរបស់ប្រទេស ប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត ចំនួន៦ប្រទេស បានព្រមព្រៀង និងឯកភាពគ្នាថា ពួកគេនឹង មិនព្រមឱ្យមានការបោះឆ្នោត ដោយសេរី នៅវៀតណាម កម្ពុជា និងឡាវ នោះទេ លើកលែង តែពួកគេចាញ់ប្រៀបនៅក្នុងកិច្ចចរចានោះ ហើយប្រសិនបើពួកកុម្មុយនិស្ត លើកឡើងពី ការដកកងទ័ពបារាំង ចេញពីកម្ពុជា និងឡាវ ពួកគេនឹងឱ្យភាគីរាជរដ្ឋាភិបាលកម្ពុជា និង ឡាវ តវ៉ាវិញថា កងទ័ពបារាំង អាចដកចេញពីប្រទេសទាំង២នេះបាន ដោយឈរលើស្មារតី

នៃសន្ធិសញ្ញារវាងបារាំង ជាមួយកម្ពុជា និងឡាវ តែប៉ុណ្ណោះ ឬត្រូវលើកឡើងថា កងទ័ពបារាំង អាចមានវត្តមាននៅលើទឹកដីកម្ពុជា និងឡាវ បន្តទៀត ប្រសិនបើមានការស្នើសុំរបស់ប្រទេសទាំង២នេះ។ ប៉ុន្តែ នៅក្នុងសម័យប្រជុំពេញអង្គជាថ្មីម្តងទៀត តំណាងប្រទេសកម្ពុជា នៅតែប្រកាសថា កងទ័ពបារាំង បានដកចេញពីកម្ពុជា អស់ហើយ។

ចំណែកឯតំណាងភាគីវៀតមិញ ក៏បានបដិសេធថា ពេលនេះ ពុំមានវត្តមានកងទ័ពរបស់ខ្លួន នៅលើទឹកដីកម្ពុជាទៀតទេ។ អង្គប្រជុំបានចំណាយពេលវេលាពិភាក្សាគ្នា អស់ជាច្រើនសប្តាហ៍បន្តទៀត តែពុំអាចស្វែងរកដំណោះស្រាយអ្វីបានឡើយ។

ផ្ទុយទៅវិញ ផែនការប្រែក្លាយសង្គ្រាមឥណ្ឌូចិន ឱ្យមានលក្ខណៈជាសង្គ្រាមអន្តរជាតិរបស់សហរដ្ឋអាមេរិកនោះ ក៏ចាប់ផ្តើមកើតឡើង។

រដ្ឋមន្ត្រីការបរទេសអាមេរិក ហ្វូស្ទ័រ ឌុលេ្លស (Foster Dulles) បានផ្ញើសារ ទូរលេខមួយទៅឱ្យ ប៊ីដែល ស្មីត (Bedell Smith) ជាអនុរដ្ឋមន្ត្រីរបស់គាត់ថា ឯកអគ្គរដ្ឋទូតបារាំង ប្រចាំសហរដ្ឋអាមេរិក បូណ្ណេត (Bonnet) បានសុំជួបគាត់ ដើម្បីចរចាគ្នា ហើយ គាត់ក៏បានប្រាប់ឯកអគ្គរដ្ឋទូតបារាំង វិញថា អាមេរិក ក៏បានត្រៀមខ្លួនចរចាជាមួយបារាំង ស្តីពីការធ្វើសង្គ្រាមនៅឥណ្ឌូចិន ឱ្យមានលក្ខណៈជាសង្គ្រាមអន្តរជាតិនោះ រួចហើយដែរ។

ចំណែករដ្ឋាភិបាលបារាំង ក៏យល់ថា ដល់ពេល អាមេរិក និងបារាំង ត្រូវពិភាក្សាគ្នាពីបញ្ហានេះហើយ តែរដ្ឋាភិបាលបារាំង មិនអាចរង់ចាំមើលគោលជំហរសហរដ្ឋអាមេរិក រហូតដល់មានលទ្ធផលចុងក្រោយរបស់សន្និសីទក្រុងហ្សឺណែវ នោះបានទេ ព្រោះបើនៅរង់ចាំដល់ពេលនោះ ស្ថានការណ៍យោធានឹងកាន់តែធ្លាក់ដុនដាបទៅៗ រហូតដល់បាត់បង់ឥណ្ឌូចិនទាំងមូលជាមិនខាន។

រដ្ឋមន្ត្រីការបរទេសអាមេរិក ហ្វូស្ទ័រ ឌុលេ្លស (Foster Dulles) ក៏បានប្រាប់ទៅឯកអគ្គរដ្ឋទូតបារាំង បូណ្ណេត (Bonnet) វិញថា អាមេរិកបានត្រៀមខ្លួនជាស្រេច ដើម្បីពិភាក្សាពីបញ្ហានេះជាមួយបារាំង។ តែមិនទាន់ដឹងថា តើជំនួបពិភាក្សានោះ ត្រូវធ្វើនៅកន្លែងណា?

៧២
ប្រទេសលោកខាងលិច មិនទទួលស្គាល់ចលនាតស៊ូខ្មែរឥស្សរៈ និងចលនាតស៊ូប៉ាថេតឡាវ



កងទ័ពវៀតមិញ និងកងទ័ពប៉ាថេតឡាវ

នៅថ្ងៃបន្ទាប់មកទៀត រដ្ឋមន្ត្រីការបរទេសអង់គ្លេស អង់តូនី អេដេន (Anthony Eden) បានប្រាប់មេដឹកនាំចិន ជូ អេនឡាយ ថា ប្រសិនបើកាគីវៀតមិញ នៅតែបន្តការទាមទារច្រើនពេក វានឹងធ្វើឱ្យសភាពការណ៍កាន់តែគ្រោះថ្នាក់ថែមទៀត។

នេះអាចចាត់ទុកថា ជាការគំរាមកំហែង ដោយផ្ទាល់ទៅលើប្រទេសចិន ដើម្បីឱ្យជូ អេនឡាយ ដាក់ការគាបសង្កត់ទៅលើ ផាំ វ៉ាន់ដុង មេដឹកនាំវៀតមិញ ដើម្បីឱ្យបន្ធន់ឥរិយាបថក្នុងការទាមទារនោះវិញទៅ។

រដ្ឋមន្ត្រីការបរទេសអង់គ្លេស អង់តូនី អេដេន (Anthony Eden) និងនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ក៏មើលឃើញថា ឥណ្ឌូចិន ក៏ជារបាំងការពារសន្តិភាពដ៏សំខាន់មួយរបស់ប្រទេសចិនផងដែរ។

ប៉ុន្តែ ម៉ូឡូតូវ (Molotov) ប្រធានគណៈប្រតិភូសហភាពសូវៀត យល់ច្បាស់ពីល្បិចកលនេះ ដោយនៅក្នុងកិច្ចប្រជុំពេញអង្គបន្ទាប់មក គាត់បានថ្លែងថា គេមិនអាចបំប្លែងការបញ្ចប់ជម្លោះនៅឥណ្ឌូចិន ឱ្យនៅជាការឈប់សម្រាកមួយ ដើម្បីឱ្យពួកគេយកពេលវេលាទៅរៀបចំពង្រឹកសង្គ្រាមនោះបានទេ។ តែគាត់ពុំបានធ្វើការពន្យល់បកស្រាយបំភ្លឺពីរឿងនេះឱ្យបានច្បាស់លាស់ ថាតើគាត់ចង់និយាយសំដៅទៅលើប្រទេសណាមួយនោះទេ។

ប៊ីដែល ស្មីត (Bedell Smith) តំណាងសហរដ្ឋអាមេរិក បានបន្តផ្ញើសារទូរលេខទៅប្រាប់ ហ្វូស្ទ័រ ឌុលេស (Foster Dulles) រដ្ឋមន្ត្រីការបរទេសរបស់ខ្លួនថា បំណងយើងចង់បានឥណ្ឌូចិន យកមកធ្វើជាមូលដ្ឋានយោធារបស់យើងនោះ នឹងមិនទទួល លទ្ធផល ល្អប៉ុន្មានទេ ព្រោះបណ្តាប្រទេសនានាមិនមែនកុម្មុយនិស្ត នៅអាស៊ី អាចចាត់ទុកថា នេះជាការធ្វើអាណានិគម ឬជាគំនិតចក្រពត្តិនិយម ក៏អាចថាបាន ហើយពួកកុម្មុយនិស្ត ក៏បានដឹងពីបំណងរបស់យើងនេះដែរ។

នៅថ្ងៃទី១៧ ខែឧសភា រដ្ឋមន្ត្រីការបរទេសអង់គ្លេស អង់តូនី អេដេន (Anthony Eden) បានផ្ញើសារទូរលេខមួយទៅទីក្រុងឡុងដ៍ ដើម្បីស្នើសុំឱ្យមានជំនួបចរចាថ្នាក់នាយអគ្គសេនាធិការរបស់ប្រទេសមហាអំណាចទាំង៥ (អាមេរិក ចិន សូវៀត បារាំង និងអង់គ្លេស) ជាបន្ទាន់ នៅទីក្រុងវ៉ាស៊ីងតោន។

ប៊ីដែល ស្មីត (Bedell Smith) តំណាងសហរដ្ឋអាមេរិក ក៏បានគូសបញ្ជាក់បន្ថែមពីការស្នើសុំរបស់រដ្ឋមន្ត្រីការបរទេសអង់គ្លេស អង់តូនី អេដេន (Anthony Eden) ថា ការស្នើសុំឱ្យមានជំនួបចរចាថ្នាក់នាយអគ្គសេនាធិការ របស់ប្រទេសមហាអំណាចទាំង៥នោះ គឺដើម្បីសិក្សាស្រាវជ្រាវពីផែនការយោធា ប្រឆាំងនឹងការឈ្លានពានរបស់ពួកកុម្មុយនិស្ត នៅឥណ្ឌូចិន ឬក៏ការជ្រៀតចូលរបស់ពួកនេះ ទៅក្នុងប្រទេសផ្សេងៗទៀតនៅអាស៊ី ផងដែរ។

នៅក្នុងកិច្ចប្រជុំពេញអង្គ ថ្ងៃទី១៩ ខែឧសភា តំណាងពួកវៀតមិញ បានប្រកាសថា រដ្ឋាភិបាលខ្មែរឥស្សរៈ កំពុងកាន់កាប់ទឹកដីមួយចំណែកធំ មិនមែនតែនៅតំបន់ក្បែរព្រំដែនវៀតណាម ប៉ុណ្ណោះទេ គឺនៅតំបន់ជាច្រើននៅក្នុងផ្ទៃប្រទេសកម្ពុជា ទៀតផង។

ជូ អេនឡាយ ក៏បានឯកភាព និងគាំទ្រការប្រកាសរបស់តំណាងពួកវៀតមិញ ខាងលើនេះដែរ។ ប៉ុន្តែ ក្នុងជំនួបជាមួយរដ្ឋមន្ត្រីការបរទេសអង់គ្លេស អង់តូនី អេដេន នៅថ្ងៃបន្ទាប់ ជូ អេនឡាយ ក៏បានធ្វើសម្បទានមួយទៀត ជាការបង់ខាតដ៏ធំរបស់ពួកកុម្មុយនិស្តខ្មែរ ដោយពេលនោះ អង់តូនី អេដេន បានលើកឡើងថា ប្រទេសលោកខាងលិចបានបដិសេធមិនទទួលស្គាល់របស់ដែលហៅថា រដ្ឋាភិបាលខ្មែរឥស្សរៈ និងរដ្ឋាភិបាលប៉ាថេតឡាវ (Pathet laos) ស្អីគេនោះទេ។

តែ ជូ អេនឡាយ បានលើកឡើងថា កងទ័ពរដ្ឋាភិបាលខ្មែរឥស្សរៈ និងរដ្ឋាភិបាលប៉ាថេតឡាវ ប្រាកដជាមានពិតមែន តែពួកគេប្រហែលជាមានចំនួនតិចតួចប៉ុណ្ណោះ ហើយគេក៏មិនអាចបោសសម្អាតពួកនេះឱ្យអស់ចេញពីប្រទេសទាំង២នេះ បានដោយងាយៗនោះដែរ។

បន្ទាប់មក អង់តូនី អេដេន បានប្រាប់ទៅប៊ីដែល ស្មីត ថា គាត់បានព្រមានទៅ ជូ អេនឡាយ ជាថ្មីម្តងទៀតថា ស្ថានភាពនៅឥណ្ឌូចិន កំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ហើយអាចនាំមកនូវលទ្ធផលកាន់តែអាក្រក់ធ្ងន់ធ្ងរថែមទៀត ដែលមិនអាចប៉ាន់ស្មានបាន។

ពេលនោះ ជូ អេនឡាយ ក៏បាននិយាយថា គាត់ពឹងផ្អែកទាំងស្រុងទៅលើអង់គ្លេសធ្វើយ៉ាងណា ដើម្បីកុំឱ្យស្ថានការណ៍អាក្រក់នោះកើតមានឡើង។

អង់តូនី អេដេន បានប្រាប់ទៅ ជូ អេនឡាយ វិញថា សូមកុំពឹងផ្អែកមកលើអង់គ្លេសឱ្យសោះ ព្រោះថា ពេលនេះ ទោះបីអង់គ្លេស ចង់ប្រកាន់ជំហរកណ្តាលក៏ពិតមែន ប៉ុន្តែប្រសិនបើមានហេតុការណ៍អាក្រក់ណាមួយ រហូតដល់ធ្វើឱ្យមានការប៉ះទង្គិចគ្នាដោយអាវុធនោះ អង់គ្លេសប្រាកដជាឈរនៅខាងសហរដ្ឋអាមេរិក ហើយ។

២ថ្ងៃក្រោយមក ប៊ីដែល ស្មីត តំណាងសហរដ្ឋអាមេរិក បានជួបគ្នាជាមួយម៉ូឡូតូវ តំណាងរបស់សហភាពសូវៀត ហើយ ប៊ីដែល ស្មីត បានរាយការណ៍ទៅរដ្ឋមន្ត្រីការបរទេសរបស់គាត់ថា រដ្ឋមន្ត្រីការបរទេសសហភាពសូវៀត មិនចង់ពាក់ព័ន្ធជ្រៅទៅក្នុងបញ្ហាឥណ្ឌូចិនដូច ជូ អេនឡាយ ទេ។ ប៉ុន្តែ គាត់មានជំនឿទៅលើឥទ្ធិពលចលនាតស៊ូខ្មែរឥស្សរៈ និងពួក

ប៉ាថេតឡាវ ច្រើនជាង ដូ អេនឡាយ។

ម៉ូឡូតូវ បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងភ្នំពេញ និងរាជរដ្ឋាភិបាលឡាវ នៅក្រុងវៀងចន្ទ គ្រប់គ្រងទឹកដីបានត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ។ ក្រៅពីនោះ គឺជាតំបន់ដែលចលនាតស៊ូខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ ជាអ្នកគ្រប់គ្រង ។

ក្រោយជំនួបជាមួយរដ្ឋមន្ត្រីការបរទេសសហភាពសូវៀត ម៉ូឡូតូវ(Molotov) ពីរថ្ងៃ អនុរដ្ឋមន្ត្រីការបរទេសអាមេរិក ប៊ីដែល ស្មីត(Bedell Smith) បានរាយការណ៍ទៅរដ្ឋមន្ត្រីការបរទេសរបស់គាត់ថា រដ្ឋមន្ត្រីការបរទេសសហភាពសូវៀត មិនចង់ពាក់ព័ន្ធក្នុងការពិភាក្សាពីបញ្ហាកម្ពុជា និងឡាវ ទេ។ តែគេបាននិយាយថា រាជរដ្ឋាភិបាលរបស់ប្រទេសទាំងពីរនេះ គ្រប់គ្រងទឹកដី បានត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ។ ក្រៅពីនោះគឺ ពួកខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ ជាអ្នកកាន់កាប់ត្រួតត្រា។

៧៣
កម្ពុជា សន្សាប្រកាន់នយោបាយអព្យាក្រឹត



ព្រះមហាក្សត្រសីហនុ

ល្ងាចមួយ ក្រោយសម្រាកពីអង្គប្រជុំ ជូ អេនឡាយ បានអញ្ជើញគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ចូលរួមពិសាអាហារក្នុងពិធីជប់លៀងមួយ នៅកន្លែងស្នាក់នៅរបស់គណៈប្រតិភូចិន។

ពេលនោះ គណៈប្រតិភូកម្ពុជា មិនទាន់ហ៊ានសម្រេចចិត្តយ៉ាងណានោះទេ គឺត្រូវផ្ញើសារទូរលេខមកសុំយោបល់ពីនាយករដ្ឋមន្ត្រី ប៉ែន នុត នៅក្រុងភ្នំពេញ ជាមុនសិន។

ក្រោយពីទទួលបានការអនុញ្ញាតពីនាយករដ្ឋមន្ត្រី ប៉ែន នុត នៅក្រុងភ្នំពេញ មក រថយន្តរបស់គណៈប្រតិភូចិន បានមកដឹកគណៈប្រតិភូកម្ពុជា យកទៅកន្លែងស្នាក់នៅរបស់គណៈប្រតិភូចិន ដើម្បីចូលរួមពិសាអាហារក្នុងពិធីជប់លៀងនោះ។

ពេលនោះ ស្រាប់តែឃើញវត្តមាន ផាំ វ៉ាន់ដុង និងសមាជិកគណៈប្រតិភូវៀតមិញមួយចំនួនទៀត ព្រមទាំងគណៈប្រតិភូឡាវ ផងដែរ កំពុងរង់ចាំគណៈប្រតិភូកម្ពុជា ហើយពួកគេក៏បានហុចដៃមកស្វាគមន៍។

ជំបូង គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែចាត់ទុកថា ពួកវៀតមិញ ជាសត្រូវប្រជារាស្ត្រកម្ពុជា ស្ទាក់ស្ទើរមិនចង់ចាប់ដៃជាមួយមេដឹកនាំវៀតមិញ នោះទេ។ ប៉ុន្តែពេលពួកគេហុចដៃមកស្វាគមន៍ទៅហើយ បើមិនចាប់ដៃស្វាគមន៍វិញទេ ដូចជាមិនសមរម្យឡើយ ហើយនៅទីនោះ ក៏ឃើញមានវត្តមានគណៈប្រតិភូរាជរដ្ឋាភិបាលឡាវ មកពីក្រុងវៀងចន្ទ ផងដែរ គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ក៏ចាប់ដៃស្វាគមន៍វិញ ទាំងទើសទាល់។

ខណៈមេដឹកនាំគណៈប្រតិភូចិន កម្ពុជា វៀតមិញ និងលាវ កំពុងអង្គុយជុំវិញតុមូលមួយទទួលទានអាហារ ជូ អេនឡាយ មិនបាននិយាយអ្វីជាសំខាន់ ក្រៅពីរវល់យកចង្កឹះចាប់ម្ហូបអាហារដាក់ជូនភ្ញៀវ ពីម្នាក់ទៅម្នាក់ទៀត តាមប្រពៃណីរបស់ចិន នោះឡើយ។

តែ ផាំ វ៉ាន់ដុង បាននិយាយយ៉ាងព្រហើនទៅកាន់ប្រធានគណៈប្រតិភូរាជរដ្ឋាភិបាលឡាវ សាណា នីកន ថា៖ " លោកដឹងទេ! អ្នកស្នេហាជាតិឡាវ ពិតប្រាកដ មិនមែននាយករដ្ឋមន្ត្រីរបស់លោក នៅក្រុងវៀងចន្ទ ទេ គឺ ទ្រង់សុផាវង្ស "។

គណៈប្រតិភូលាវ មិនបានតបតអ្វីទៅផាំ វ៉ាន់ដុង វិញ ក្រៅពីសើចញឹមៗនោះទេ។ ប៉ុន្តែ ទេព ផន ប្រធានគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ក៏បានសួរទៅផាំ វ៉ាន់ដុង ថា៖" តើឯកឧត្តមអាចប្រាប់ពួកយើងខ្ញុំបានទេ ថា៖ "តើអ្នកស្នេហាជាតិពិតប្រាកដរបស់ខ្មែរណាមួយដែលរស់នៅជាមួយពួកវៀតមិញ នោះ?"។ តែ ផាំ វ៉ាន់ដុង មិនបានឆ្លើយតបមកនឹងសំណួរនេះ វិញទេ។

នៅក្នុងសម័យប្រជុំលើកទី៦ នាថ្ងៃទី២៥ ខែឧសភា ផាំ វ៉ាន់ដុង ទាមទារឱ្យមានការទទួលស្គាល់គោលការណ៍នៃការរៀបចំឡើងវិញ នូវតំបន់ប្រមូលផ្តុំកងទ័ព ដែលគ្រប់គ្រងដោយភាគីនីមួយៗ។ តែ ប៊ីដែល ស្មីត (Bedell Smith) បានបដិសេធថា ការបែងចែកតំបន់ប្រមូលផ្តុំកងទ័ពនៅប្រទេសកម្ពុជា គឺមិនអាចទទួលយកបានឡើយ គឺមានតែនៅប្រទេសវៀតណាមទេ ដែលគេអាចធ្វើការពិចារណាពីការប្រមូលផ្តុំកងទ័ព ដែលគ្រប់គ្រងដោយភាគីនីមួយៗនោះ។

ក្រោយសម័យប្រជុំនេះ ប៊ីដែល ស្មីត(Bedell Smith) បានផ្ញើសារទូរលេខទៅ

ប្រាប់ ហ្វូស្ទ័រ ឌុលេស (Foster Dulles) រដ្ឋមន្ត្រីការបរទេសរបស់គាត់ថា ពួកកុម្មុយនិស្ត មិនទាន់បង្ហាញឱ្យឃើញនូវការបន្ធន់តវិយោបថណាមួយនៅឡើយទេ។

ក្រោយពីជួបប្រជុំគណៈប្រតិភូអង់គ្លេស និងបារាំង បានមួយថ្ងៃ ប៊ីដែល ស្មីត (Bedell Smith) ក៏បានរាយការណ៍ទៅហ្វូស្ទ័រ ឌុលេស (Foster Dulles) ថា អង់តូនី អេដេន (Anthony Eden) រដ្ឋមន្ត្រីការបរទេសអង់គ្លេស មានការងឿងឆ្ងល់ថា៖ "តើជំហរ របស់យើង (អាមេរិក) ចំពោះកម្ពុជា យ៉ាងដូចម្តេចដែរ? យើងប្រាប់ថា បញ្ហាកម្ពុជា និង លាវ ជាបញ្ហាដោយឡែកពីគ្នា វាជាបញ្ហាបន្ថែមទៅលើប្រទេសវៀតណាម ហើយរដ្ឋមន្ត្រី ការបរទេសអង់គ្លេស អង់ថូនី អ៊ីដេន គ្មានហេតុផលអ្វី ដែលត្រូវបដិសេធពីបទឈប់បាញ់ គ្នា ក្នុងពេលតែមួយ នៅប្រទេសទាំងពីរនេះទេ" ។

អង់តូនី អេដេន យល់ឃើញថា៖ " រូបមន្តអាចទទួលយកបាននោះ គឺ ១.បទឈប់ បាញ់គ្នា, ២.ដកថយកងទ័ពប្រទេសនីមួយៗឱ្យទៅនៅជិតតំបន់ព្រំដែន, ៣.ដកកងទ័ព បរទេសទាំងអស់ ចេញពីប្រទេសទាំងបី នៅឥណ្ឌូចិន ឱ្យអស់ យ៉ាងយូរ ក្នុងរយៈពេល៦ខែ "។

ប៊ីដែល ស្មីត(Bedell Smith) ក៏បានរាយការណ៍បន្តទៀតថា៖ " បារាំងយល់ថា យើង(អាមេរិក)នឹងមិនប្រឆាំងសំណើឱ្យមានការឈប់បាញ់គ្នា នៅឥណ្ឌូចិន ក្នុងពេល តែមួយនោះទេ។ យើងយល់ព្រមតាមសំណើនេះ តែយើងមិនសូវទុកចិត្តពួកកុម្មុយនិស្ត ប៉ុន្មានឡើយ "។

ប៉ុន្តែសំណើនេះ ត្រូវក្លាយជាបញ្ហាមិនចាំបាច់ទៅវិញ ព្រោះមុនកិច្ចប្រជុំលើកទី៧ មួយថ្ងៃ គណៈប្រតិភូចិន បានស្នើសុំឱ្យមានការរៀបចំឡើងវិញ នូវតំបន់កាន់កាប់ទាំងឡាយ របស់ពួកខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ នឹងត្រូវធ្វើការពិនិត្យដោយឡែកពីគ្នា ហើយស្នើឱ្យ ប្រទេសទាំងអស់ ដែលចូលរួមនៅក្នុងសន្និសីទក្រុងហ្សឺណែវ នេះ ជានាំចំពោះការអនុវត្ត កិច្ចព្រមព្រៀងមួយ ដាច់ដោយឡែក ផងដែរ។ ប៉ុន្តែក្នុងការចរចាដោយឡែកៗ ទាក់ទងនឹង ប្រទេសចិននោះ គណៈប្រតិភូចិន បានសន្យាថា មិនអនុញ្ញាតឱ្យពួកខ្មែរឥស្សរៈមានតួនាទី អ្វីឡើយ សូម្បីតែការចរចាដោយផ្ទាល់ នៅក្នុងប្រទេសកម្ពុជា ក៏ដោយ។

ក្រោយមក គណៈប្រតិភូកម្ពុជា បានបង្ហាញនូវគោលជំហរមួយ ធ្វើឱ្យគណៈប្រតិភូចិន មានការចាប់អារម្មណ៍ជាងមុន ដោយនៅថ្ងៃទី៣១ ខែឧសភា សមាជិកប្រតិភូកម្ពុជាម្នាក់ បានប្រាប់ទៅសមាជិកគណៈប្រតិភូអាមេរិក ថា បើសិនជាកងទ័ពវៀតមិញ មិនទាន់ដកកងទ័ពចេញឱ្យអស់ពីកម្ពុជា នោះទេ កម្ពុជា ក៏មិនអាចយល់ព្រមចំពោះបញ្ហាមិនឱ្យមានការដាក់កងទ័ពបរទេស និងការអនុញ្ញាតឱ្យមានការបញ្ជូនអាវុធយុទ្ធភណ្ឌបន្ថែមទៀតមកក្នុងប្រទេសរបស់ខ្លួនបានដែរ។

នៅក្នុងកិច្ចប្រជុំលើកទី១៤ នាថ្ងៃទី០៤ ខែមិថុនា គណៈប្រតិភូកម្ពុជា ក៏បានប្រកាសថា ក្នុងករណីពុំមានវត្តមានកងទ័ពបារាំង នៅក្នុងប្រទេសកម្ពុជា ទេនោះ កម្ពុជា នឹងត្រូវប្រឈមមុខជាមួយពួកវៀតមិញ មានអាវុធយុទ្ធភណ្ឌ ដ៏ច្រើនសន្ធឹកសន្ធាប់ ដែលប្រទេសចិនជាអ្នកផ្តល់ឱ្យនោះ ជាមិនខាន។ តែគណៈប្រតិភូកម្ពុជា បានសន្យាថា នៅពេលខាងមុខនេះ កម្ពុជា នឹងមិនឱ្យមានវត្តមានកងទ័ពបារាំង នៅលើទឹកដីខ្លួនបន្តទៀតទេ ហើយកម្ពុជានឹងប្រកាន់នយោបាយអព្យាក្រឹត ដែលនេះបង្ហាញឱ្យឃើញនូវការធ្វើសម្បទានមួយ ក្នុងការរួមចំណែកការពារសន្តិសុខដល់ប្រទេសចិន ផងដែរ។ ប៉ុន្តែគណៈប្រតិភូកម្ពុជា មិនបានធ្វើសម្បទានអ្វីដល់ពួកវៀតមិញ និងខ្មែរឥស្សរៈនោះឡើយ។

ពេលនោះ សាធារណមតិអន្តរជាតិខ្លះ បានធ្វើការវាយតម្លៃថា បើទោះជាការសន្យារបស់កម្ពុជា ប្រកាន់យកនយោបាយអព្យាក្រឹតនោះ ជាការពិត ឬមិនពិតក៏ដោយ ក៏កម្ពុជាដ៏ក្មេងខ្ចីនេះ បានបង្ហាញឱ្យឃើញពីឯករាជ្យម្ចាស់ការខាងការងារទូតរបស់ខ្លួនដែរ។

យូ អេ ចនសុន (U.A Johnson) អ្នកសម្របសម្រួលរបស់គណៈប្រតិភូអាមេរិក បានប្រាប់ ប៊ីដែល ស្មីត (Bedell Smith) ថា ប្រសិនបើយើងទទួលបានជោគជ័យនៅឥណ្ឌូចិន ដោយមិននាំមកនូវសង្គ្រាមលោកលើកទី៣នោះ ទីតាំងមូលដ្ឋានកងទ័ពរបស់យើងនៅអាស៊ី នឹងទទួលបានការអបអរសាទរយ៉ាងខ្លាំងជាមិនខាន។ តែប្រសិនបើសង្គ្រាមលោកលើកទី៣ កើតឡើងមែននោះ បណ្តាប្រទេសអាស៊ី នឹងថ្កោលទោស ហើយនាំគ្នាប្រឆាំងនឹងយើងជាមិនខាន។

៧៤
ចិន ខ្ពាចអាមេរិក បង្កើតមូលដ្ឋានកងទ័ព នៅកម្ពុជា និងឡាវ



ជូ អេនឡាយ នាយករដ្ឋមន្ត្រីចិន

២ថ្ងៃក្រោយមក ទេព ផន ប្រធានគណៈប្រតិភូកម្ពុជា បាននិយាយប្រាប់ អេដេន (Eden) រដ្ឋមន្ត្រីការបរទេសអង់គ្លេស ថា រាជរដ្ឋាភិបាលកម្ពុជា ពុំអនុញ្ញាតឱ្យមានមូលដ្ឋានកងទ័ពបរទេសណាមួយ នៅលើទឹកដីរបស់ខ្លួនឡើយ។ នៅក្នុងការចរចានោះ ភាគីកម្ពុជា និងឡាវ នៅតែនិយាយថា ពុំមានកងទ័ពបរទេសណាផ្សេង ក្រៅពីកងទ័ពវៀតមិញ ធ្វើសកម្ម-ភាពនៅលើទឹកដីរបស់ខ្លួនដដែល។

ក្រោយពីការចរចាគ្នាអស់ជាច្រើនថ្ងៃមក បញ្ហាទាក់ទិននឹងវៀតណាម និងឡាវ មានការរីកចម្រើនតិចតួចបំផុត។

ដោយមានការច្រាស់ច្រាល់ក្នុងចិត្ត ជាខ្លាំងនោះ ហ្វូស្ទ័រ ឌុលល្លេស (Foster Dulles) រដ្ឋមន្ត្រីការបរទេសអាមេរិក បានប្រាប់ ប៊ីដែល ស្មីត ថា សន្និសីទក្រុងហ្សឺណែវ ស្តីពីបញ្ហាឥណ្ឌូចិននេះ មិនដឹងជានាំយើងទៅណា ឱ្យពិតប្រាកដនោះទេ គឺមានតែនាំយើងដើរថយ

ក្រោយប៉ុណ្ណោះ។ តែចំពោះបញ្ហាអន្តរជាតូបនីយកម្មសង្គ្រាមវិញ យើងគួរតែប្រាប់ភាគីបារាំង ឱ្យច្បាស់ថា សំណើរបស់យើងមិនមែនស្ថិតនៅលើតុចរចា ដោយគ្មានពេលកំណត់នោះទេ។

ជាមួយគ្នានោះ ជំនួបចរចាសម្ងាត់ រវាងនាយអគ្គសេនាធិការកងទ័ពបារាំង និងនាយអគ្គសេនាធិការកងទ័ពវៀតមិញ ធ្វើឱ្យរដ្ឋមន្ត្រីការបរទេសអាមេរិក កាន់តែមានការតានតឹងក្នុងចិត្ត ថែមទៀត។ នាយអគ្គសេនាធិការកងទ័ពបារាំង ឈ្មោះសូវែល បានប្រាប់ ប៊ីដែល ស្មីត (Bedell Smith) ពីគោលជំហររបស់ភាគីនាយអគ្គសេនាធិការកងទ័ពវៀតមិញ ដែលលើកឡើងថា បើបារាំង នៅតែរក្សាជំហរដដែលៗចំពោះកម្ពុជា និងឡាវ បន្តទៀតនោះ បារាំង ក៏នឹងមិនបានទទួលផលអ្វី ពីភាគីវៀតមិញ ដែរ។ ដូច្នេះពួកវៀតមិញ បានត្រៀមខ្លួនលះបង់ផលប្រយោជន៍របស់ខ្លួនមួយចំនួន ដើម្បីទទួលបាននូវការធានាផល-ប្រយោជន៍ខ្លះៗ ចំពោះសម្ព័ន្ធមិត្តរបស់គេ គឺពួកខ្មែរឥស្សរៈ និងពួកប៉ាថេតឡាវ។

ប៊ីដែល ស្មីត (Bedell Smith) បានផ្ញើសារទូរលេខប្រាប់ ហ្វូស្ទ័រ ឌុលេស (Foster Dulles) ថា នៅក្នុងកិច្ចប្រជុំលើកទី១៣ ផាំ វ៉ាន់ដុង បានទទូចទាមទារឱ្យអង្គសន្និសីទទទួលស្គាល់នូវសេភាពការណ៍ពិត ជាមូលដ្ឋាន គឺអត្ថិភាពរបស់ចលនាតស៊ូខ្មែរឥស្សរៈ នៅប្រទេសកម្ពុជា និងអត្ថិភាពរបស់ចលនាតស៊ូពួកប៉ាថេតឡាវ នៅប្រទេសឡាវ។

ផាំ វ៉ាន់ដុង រង់ចាំពិភាក្សាបញ្ហាទាំងឡាយ ដោយឈរលើមូលដ្ឋាននេះជានិច្ច។ តែបើគ្មានការកែចម្រើនណាមួយទេ សន្និសីទនេះ ក៏នឹងមិនទទួលបានលទ្ធផលអ្វីដែរ។

ប៉ុន្តែទោះបីជាយ៉ាងណា ប្រសិនបើគ្មានការគាំទ្រពីប្រទេសចិន ទេនោះ ពួកវៀតមិញ មិនអាចបន្តការប្រយុទ្ធរបស់ខ្លួនទៅទៀតបានដែរ ។

ឯជំហរអាមេរិក វិញ គឺធ្វើយ៉ាងណាឱ្យពួកវៀតមិញ មើលឃើញថា វានឹងគ្មានការគាំទ្រពីប្រទេសចិន ទៀតឡើយ។

ហ្វូស្ទ័រ ឌុលេស (Foster Dulles) បានផ្ញើសារទូរលេខមកប្រាប់ប៊ីដែល ស្មីត (Bedel Smith) វិញថា ធ្វើយ៉ាងណា ទាញយកផលប្រយោជន៍ឱ្យបានមកខាងយើង នៅ ពេលបញ្ចប់សន្និសីទនេះ ហើយពុំត្រូវមានហេតុផលណាមួយ ដើម្បីឱ្យគេពន្យារពេល នៃ

ការចរចាជាសមូហភាព ស្តីពីការការពារអាស៊ីអាគ្នេយ៍ នោះទេ។

ប៉ុន្តែ ៥នាទីក្រោយមក ហ្វូស្ទ័រ ឌុលេ្លស ក៏បានផ្ញើសារទូលេខមកប្រាប់ ស្មីត (Smith) ម្តងទៀត ដោយគាត់បានសម្តែងការព្រួយបារម្ភពីរឿងបារាំង លួចចរចាសម្ងាត់ជាមួយពួកវៀតមិញ ថា អាចនឹងទទួលបាននូវដំណោះស្រាយដាច់ដោយឡែកមួយ។

ហ្វូស្ទ័រ ឌុលេ្លស បានលើកឡើងថា យើងមិនចង់ឃើញការចរចាក្រៅផ្លូវការណាមួយ រវាងបារាំង និងពួកវៀតមិញ នេះទេ ព្រោះវាអាចធ្វើឱ្យប្រឈមមុខភ្លាមៗ ទល់នឹងដំណោះស្រាយមួយ ដែលយើងមិនអាចទទួលយកបាន ហើយដំណោះស្រាយបែបនេះនឹងធ្វើឱ្យយើងនៅឆ្ងាយពីគេឯងផងដែរ។

ប៉ុន្តែមិនយូរប៉ុន្មាន គណៈប្រតិភូរបស់បារាំង បាននិយាយប្រាប់គណៈប្រតិភូអាមេរិក ថា ភាគីវៀតមិញ មានការព្រួយបារម្ភថា ក្រោយពីបញ្ចប់ជម្លោះនេះទៅ គេខ្លាចប្រទេសចិនក្លាយជាអ្នកគ្រប់គ្រងស្ថានភាពរបស់ប្រទេសវៀតណាម ។

នៅថ្ងៃទី១៦ ខែមិថុនា នៅពេលជួបពិភាក្សាគ្នាជាមួយគណៈប្រតិភូអង់គ្លេស ជូ អេនឡាយ បានលើកឡើងថា គាត់យល់ពីគោលជំហររបស់អង់គ្លេស ចំពោះបញ្ហានៅកម្ពុជា និងឡាវ ព្រោះបញ្ហានេះ អង់គ្លេស ក៏ធ្លាប់ជាប់ពាក់ព័ន្ធជាមួយប្រទេសម៉ាឡេស៊ី ផងដែរ។

ជូ អេនឡាយ បាននិយាយថា ចិន គ្មានបំណងចង់បានអ្វី ពីប្រទេសកម្ពុជា និងឡាវ ក្រៅពីចង់ទទួលស្គាល់ប្រទេសទាំង២នេះ ជាផ្លូវការនោះទេ។ តែអ្វីដែលចិន មានការព្រួយបារម្ភនោះ គឺបញ្ហាសហរដ្ឋអាមេរិក កំពុងតែព្យាយាមចង់បង្កើតមូលដ្ឋានកងទ័ព នៅក្នុងប្រទេសកម្ពុជា និងឡាវដែលជាការគំរាមកំហែងដល់សន្តិសុខរបស់ប្រទេសចិនតែប៉ុណ្ណោះ។

ការទទួលស្គាល់កម្ពុជា របស់ចិន នៅពេលនេះ វាមានសារៈសំខាន់ណាស់ ព្រោះសូម្បីតែឥណ្ឌា ប៉ាគីស្ថាន ភូមា ឥណ្ឌូណេស៊ី ហ្វីលីពីន និងស្រីលង្កា ក៏ពុំបានទទួលស្គាល់រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេចសីហនុ ដែរ។

ចំណែក ម៉ូឡូតូវ ប្រធានគណៈប្រតិភូសហភាពសូវៀត បានលើកឡើងថា គាត់មិនទទួលស្គាល់ថា ប្រទេសកម្ពុជា ទទួលបានឯករាជ្យហើយនោះទេ ខណៈ ជូ អេនឡាយ



កងទ័ពកុម្មុយនិស្ត ប៉ាថេតឡាវ

បានបញ្ជាក់ប្រាប់ អេដេន (Eden) ប្រធានគណៈប្រតិភូអង់គ្លេស ថា នៅកម្ពុជា ពួកកុម្មុយនិស្តមានកម្លាំងមិនខ្លាំងប៉ុន្មានទេ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជា នឹងអាចរកដំណោះស្រាយនយោបាយមួយ បានយ៉ាងងាយជាមួយពួកទាំងនោះ។ ប៉ុន្តែ នៅប្រទេសលាវ មានកម្លាំងកុម្មុយនិស្តធំជាងនៅកម្ពុជា គឺវាសំខាន់ណាស់ ក្នុងការបង្កើតតំបន់ប្រមូលផ្តុំកងទ័ព នៅតាមតំបន់ព្រំដែនវៀតណាម និងចិន។

អេដេន (Eden) រដ្ឋមន្ត្រីការបរទេសអង់គ្លេស បានធ្វើការសន្និដ្ឋានថា ជូ អេនឡាយ ពិតជាចង់បានដំណោះស្រាយមួយ ប៉ុន្តែគាត់មានការសង្ស័យខ្លះៗ ចំពោះកម្រិតនៃការគ្រប់គ្រង ដែលជូ អេនឡាយ អនុវត្តទៅលើពួកវៀតមិញ។

ថ្ងៃបន្ទាប់ នៅក្នុងជំនួបទ្វេភាគីរវាងចិន និងបារាំង ជូ អេនឡាយ បានបញ្ជាក់ប្រាប់ ប៊ីលឌូល (Bildault) រដ្ឋមន្ត្រីការបរទេសបារាំង ថា កងទ័ពវៀតមិញ ត្រូវដកចេញពីប្រទេសកម្ពុជា និងឡាវ។

អ្វីដែល ជូ អេនឡាយ បានលើកឡើងថា កម្លាំងកងទ័ពកុម្មុយនិស្តនៅប្រទេសកម្ពុជា មានចំនួនតិចតួច ហើយថា នៅប្រទេសឡាវ មានចំនួនច្រើនជាងនោះ គឺជាការត្រឹមត្រូវតាមសភាពជាក់ស្តែង ព្រោះថា វាស៊ីគ្នានឹងរបាយការណ៍របស់ក្រុមស៊ើបការណ៍សម្ងាត់អាមេរិក ដែលបានប៉ាន់ស្មានថា កម្លាំងកងទ័ពកុម្មុយនិស្ត នៅក្នុងប្រទេសកម្ពុជា មានចំនួនតែ៨៧០០នាក់ប៉ុណ្ណោះ។ ឯកម្លាំងកងទ័ពកុម្មុយនិស្ត នៅក្នុងប្រទេសឡាវ មានចំនួនដល់ទៅ ១៨៨០០នាក់ឯណោះ។ ប៉ុន្តែកម្លាំងកងទ័ពកុម្មុយនិស្ត នៅក្នុងប្រទេសកម្ពុជា ចំនួន៨៧០០នាក់នោះ មានប្រហែល២ភាគ៣ជាជនជាតិខ្មែរ។ ឯកម្លាំងកងទ័ពកុម្មុយនិស្តនៅក្នុងប្រទេសឡាវ កម្លាំងកងទ័ពកុម្មុយនិស្ត ច្រើនលើសលប់ ជាជនជាតិវៀតណាម។

ក្រៅពីការចរចាបញ្ហានយោបាយ នៅក្នុងសន្និសីទក្រុងហ្សឺណែវ ក៏មានការចរចាពីបញ្ហាយោធា ផងដែរ ។ ញឹក ជូឡុង ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ក៏បានដឹកនាំគណៈប្រតិភូយោធាមួយក្រុម ក្នុងនោះ រួមមាន ទ្រង់ចន្ទរង្សី, ពុត ឆាយ, ដាប ឈួន និងសាវ៉ាង វង្ស ជាអតីតមេខ្មែរឥស្សរៈទៅចូលរួមក្នុងកិច្ចចរចានោះដែរ។

មូលហេតុដែលរាជរដ្ឋាភិបាលកម្ពុជា នាំយកអតីតពួកមេដឹកនាំខ្មែរឥស្សរៈទាំង៤នាក់ ទៅចូលរួមក្នុងសន្និសីទ នៅក្រុងហ្សឺណែវ នោះ គឺចង់បង្ហាញឱ្យមតិអន្តរជាតិ មើលឃើញថា នៅកម្ពុជា គ្មានចលនាតស៊ូខ្មែរឥស្សរៈអ្វីទៀតទេ ព្រោះចលនាតស៊ូខ្មែរឥស្សរៈ ទ្រង់ ចន្ទរង្សី, ពុត ឆាយ, ដាប ឈួន និងសាវ៉ាង វង្ស បានទម្លាក់អាវុធចុះចូលក្នុងសង្គមជាតិវិញអស់ហើយ។ ពេលនេះ នៅសល់តែពួកវៀតមិញ ដែលកំពុងធ្វើសកម្មភាពចូលមករំលោភឈ្លានពានបូរណភាពទឹកដីខ្មែរ តែប៉ុណ្ណោះ។

ប្រទេសមួយចំនួនយល់ថា ពួកវៀតមិញ នៅតែបន្តការគាំពារដល់បុព្វហេតុតស៊ូរបស់ពួកខ្មែរឥស្សរៈសឹង ង៉ុកមិញ ខ្លាំងក្លាជាងមេដឹកនាំចិន ទៅទៀត ព្រោះនៅឥណ្ឌូចិន មានតែពួកវៀតមិញនេះទេ ដែលមានកម្លាំងខ្លាំងជាងគេ។ ប៉ុន្តែ ប្រទេសមួយចំនួនទៀតយល់ថា គឺប្រទេសចិន ឯណោះ ទេ ដែលមានឥទ្ធិពលនៅឥណ្ឌូចិន ខ្លាំងជាងពួកវៀតមិញ នេះទៅទៀត។

ចិន មានការព្រួយបារម្ភថា ប្រសិនបើសហរដ្ឋអាមេរិក ចូលជ្រៀតជ្រែកបានមែន នោះ វានឹងធ្វើឱ្យប៉ះពាល់ដល់ជ័យជម្នះរបស់ពួកកុម្មុយនិស្ត នៅឥណ្ឌូចិន ជាមិនខាន។

នៅក្នុងកិច្ចប្រជុំពេញអង្គលើកទី១៤ ប្រព្រឹត្តឡើងនៅថ្ងៃទី១៦ ខែមិថុនា ជូ អេនឡាយ ក៏បានជួបប្រជុំជាមួយ អេដេន ម្តងទៀត។

ចំណែក ទេព ផន ប្រធានគណៈប្រតិភូកម្ពុជា បានលើកឡើង ដោយសង្កត់ធ្ងន់ពី ឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រកាន់ខ្ជាប់នូវគោលជំហរមិនឱ្យមានកងទ័ពបរទេស នៅលើទឹកដីរបស់ខ្លួន ជាដាច់ខាត នាពេលខាងមុខ ហើយកម្ពុជា ក៏មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃដែរ។ តែ ទេព ផន ក៏បានបញ្ជាក់ដែរថា ទៅថ្ងៃអនាគត សុំកុំឱ្យមានការចាប់កំហុសចំពោះកម្ពុជា នៅក្នុងករណីកម្ពុជា ស្វែងរកមធ្យោបាយ ដើម្បីការពារខ្លួនឯង ខណៈគេពុំបានផ្តល់យុត្តិធម៌ដល់កម្ពុជា និងក្នុងពេលគេធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីរារាំងកម្ពុជា មិនឱ្យរស់នៅក្នុងអព្យាក្រឹតភាព សេរីភាព និងសន្តិភាព នោះ។

ជូ អេនឡាយ បានលើកឡើងថា ថ្វីបើគេកំពុងធ្វើការពិចារណាអំពីកម្លាំងតស៊ូនៅកម្ពុជា និងលាវ ព្រមទាំងការដកកងទ័ពបរទេសចេញពីប្រទេសទាំង២នេះ តាមសំណើរបស់ពួកវៀតមិញ កាលពីថ្ងៃទី១០ ខែឧសភា ក៏ដោយ ក៏គេត្រូវតែយល់ថា លក្ខណៈសម្បត្តិនៅក្នុងប្រទេសនីមួយៗ នៅឥណ្ឌូចិន គឺវាមានលក្ខណៈខុសៗគ្នា ដូច្នេះមិនត្រូវអនុញ្ញាតឱ្យមានមូលដ្ឋានកងទ័ពបរទេសណាមួយ នៅឥណ្ឌូចិន ទៀតឡើយ។

ប៉ុន្តែ តំណាងពួកវៀតមិញ នៅតែលើកឡើងយ៉ាងវែងអន្លាយពីភាពចាំបាច់នៃការទទួលស្គាល់ចលនាតស៊ូខ្មែរឥស្សរៈ នៅប្រទេសកម្ពុជា និងចលនាតស៊ូប៉ាថេតឡាវ នៅប្រទេសឡាវ ដូចនៅក្នុងអង្គប្រជុំមុនៗដដែល។

តំណាងប្រទេសបារាំង បានសម្តែងនូវការគាំទ្រចំពោះសេចក្តីថ្លែងការណ៍ចុងក្រោយរបស់តំណាងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីជំហរមិនឱ្យកងទ័ពបរទេសបោះទីតាំងនៅលើទឹកដីខ្លួន ហើយសន្យាថា ខ្លួននឹងអនុវត្តឱ្យបាន តាមជំហររបស់រាជរដ្ឋាភិបាលរបស់ខ្លួន។

នៅល្ងាចថ្ងៃទី២០ ខែកក្កដា ជូ អេនឡាយ អវត្តមានក្នុងអង្គប្រជុំ គណៈប្រតិភូ

សហភាពសូវៀត បានប្រជុំជាមួយជាគណៈប្រតិភូបារាំង និងអង់គ្លេស ដោយបានឯកភាពគ្នាឱ្យបញ្ចូលឃ្លាមួយទៅក្នុងខ្លឹមសារនៃកិច្ចព្រមព្រៀងថា កម្ពុជា អាចអនុញ្ញាតឱ្យបង្កើតមូលដ្ឋានកងទ័ពបរទេស នៅក្នុងប្រទេសរបស់ខ្លួន ក្នុងករណីមានការគំរាមកំហែងណាមួយ។

មុនថ្ងៃបញ្ចប់នៃសន្និសីទនេះ សម សារី តំណាងប្រទេសកម្ពុជា បានឡើងស្នើសុំដោយទទូចថា ពេលនេះ ប្រទេសកម្ពុជា មានឯករាជ្យពេញលេញពិតប្រាកដហើយ ដូច្នេះសូមកុំឱ្យប្រទេសណាមួយ មកហាមឃាត់កម្ពុជា មិនឱ្យស្វែងរកជំនួយយោធាពីបណ្តាប្រទេសផ្សេងទៀត ។ អង្គសន្និសីទ ក៏ទទួលយល់ព្រមតាមការស្នើសុំរបស់សម សារី នេះ។

ពេលនោះ តំណាងរាជរដ្ឋាភិបាលកម្ពុជា បានប្រកាសថា ខ្លួនបានប្រកាន់យកគោលនយោបាយអព្យាក្រឹត និងប្តេជ្ញាថា នឹងមិនចូលរួមជាមួយសម្ព័ន្ធភាពយោធាណាមួយឡើយ ជាពិសេស បើមិនស្របទៅនឹងគោលការណ៍ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ហើយនឹងមិនអនុញ្ញាតឱ្យមានមូលដ្ឋានទ័ពបរទេសណា នៅលើទឹកដីរបស់ខ្លួនដែរ លុះត្រាតែមានការគំរាមកំហែងរំលោភបំពានពីបរទេសណាមួយ។

៧៥
ពិធីចុះហត្ថលេខា លើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ



ញឹក ជូឡុង តំណាងគាគីកចន័ពខ្មែរ និងអ្នកតំណាងគាគីកចន័ពវៀតណាមខាងជើង ចុះហត្ថលេខាដកកចន័ពវៀតមិញ្ញ ចេញពីកម្ពុជា

សន្និសីទក្រុងហ្សឺណែវ ដែលចាប់ផ្តើមដំណើរការ តាំងពីថ្ងៃទី១៦ ខែមេសា មកនោះ នៅទីបំផុត ក៏បានឈានចូលដល់ការចុះហត្ថលេខា នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ ដោយសម្រេចឱ្យបែងចែកប្រទេសវៀតណាម ជាពីរប្រទេសជាបណ្តោះអាសន្ន នៅត្រង់ខ្សែស្របទី១៧ គឺទឹកដីនៃភាគខាងជើងខ្សែស្រប ស្ថិតក្រោមការគ្រប់គ្រងរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងទឹកដីនៃភាគខាងត្បូងខ្សែស្រប ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋវៀតណាម និងតម្រូវមានការរៀបចំបោះឆ្នោត ដើម្បីបង្រួបបង្រួមប្រទេសទាំងពីរឱ្យទៅជាប្រទេសតែមួយវិញ នៅក្នុងខែកក្កដា ឆ្នាំ១៩៥៦ ខាងមុខ ។

ទន្ទឹមនឹងនេះ កងទ័ពវៀតមិញទាំងអស់ កំពុងបោះទីតាំងនៅលើទឹកដីវៀតណាមខាងត្បូង ត្រូវទម្លាក់អាវុធ និងត្រលប់ទៅវៀតណាមខាងជើង វិញ។

ក៏ប៉ុន្តែ ផែនការរៀបចំការបោះឆ្នោត នៅវៀតណាមនេះ ត្រូវបានច្រានចោល ដោយ

ភាគីរដ្ឋវៀតណាម (វៀតណាមខាងត្បូង) និងសហរដ្ឋអាមេរិក ជាសម្ព័ន្ធមិត្ត។ ង៉ូ ឌិញយៀម នាយករដ្ឋមន្ត្រីនៃរដ្ឋវៀតណាម (វៀតណាមខាងត្បូង) បានប្រកាសថា នឹងមិនចូលរួមក្នុងការបោះឆ្នោតនោះទេ ហើយក៏មិនព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្និសីទក្រុងហ្សឺណែវនោះដែរ។ ឯសហរដ្ឋអាមេរិក បានលើកហេតុផលថា ដើម្បីធានាឱ្យការបោះឆ្នោតនោះប្រព្រឹត្តទៅដោយសេរីនិងមានយុត្តិធម៌ត្រឹមត្រូវ ខ្លួនក៏បានទាមទារឱ្យអង្គការសហប្រជាជាតិជាអ្នករៀបចំការបោះឆ្នោតនោះ។ ប៉ុន្តែ សហភាពសូវៀត ជាសម្ព័ន្ធមិត្តរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង)បានប្រឆាំងជំទាស់ចំពោះបញ្ហានេះ។

ង៉ោ ឌិញយៀម បានលើកហេតុផល ដោយដាក់ជាសំណួរថា តើការបោះឆ្នោតនៅវៀតណាម អាចប្រព្រឹត្តឡើងទៅបានដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែរឬទេ បើនៅវៀតណាមភាគខាងជើង កំពុងស្ថិតនៅក្រោមការកាន់កាប់ទាំងស្រុងរបស់ពួកកុម្មុយនិស្តទៅហើយនោះ?

ដូចការយល់ឃើញរបស់ង៉ូ ឌិញយៀម នេះដែរ ផ្ទៃត៍ ឌី. អៃសិនហាវើរ ប្រធានាធិបតីសហរដ្ឋអាមេរិក ក៏បានសម្តែងការព្រួយបារម្ភថា ប្រសិនបើមានការបោះឆ្នោតនៅវៀតណាម ប្រជាជនវៀតណាម ប្រមាណ៨០ភាគរយ នឹងបោះឆ្នោតគាំទ្រពួកកុម្មុយនិស្ត ហូ ជីមិញ ជាមិនខាន ហើយព្រះចៅ បាវ៉ៃដាយ និងង៉ូ ឌិញយៀម នឹងអាចមានការគាំទ្រប្រហែល ២០ ភាគរយ តែប៉ុណ្ណោះ។

ចំណែកនៅប្រទេសឡាវ កិច្ចព្រមព្រៀងក្រុងហ្សឺណែវ សម្រេចឱ្យកងទ័ពកុម្មុយនិស្តប៉ាថេតឡាវ ត្រួតត្រាកាន់កាប់ខេត្តចំនួន២ គឺខេត្តសាំនឿ និងខេត្តផុង សាលី នៅជាប់ព្រំដែនវៀតណាមខាងជើង និងចិន ព្រមទាំងឱ្យមានការបោះឆ្នោត ផងដែរ។

ចំពោះប្រទេសកម្ពុជា កិច្ចព្រមព្រៀងក្រុងហ្សឺណែវ មិនអនុញ្ញាតឱ្យកងទ័ពខ្មែរឥស្សរៈសឹង ង៉ុកមិញ ត្រួតត្រាកាន់កាប់ខេត្តស្រុកណាមួយ និងមិនឱ្យមានការប្រមូលផ្តុំកងទ័ពអ្វីឡើយ គឺត្រូវទម្លាក់អាវុធ ទៅរួមរស់ក្នុងសង្គមជាតិវិញ និងមានសិទ្ធិបង្កើតគណបក្សនយោបាយស្របច្បាប់ ដើម្បីចូលរួមក្នុងការបោះឆ្នោតមួយ ក្រោមការត្រួតពិនិត្យរបស់គណៈកម្មការ

ត្រួតពិនិត្យអន្តរជាតិមួយ ដូចនៅប្រទេសវៀតណាម និងឡាវ ដែរ។ ចំណែកឯកងទ័ពបារាំង និងកងទ័ពវៀតមិញ ក៏ត្រូវដកចេញពីប្រទេសកម្ពុជា ទាំងអស់ដែរ ។

ជាមួយគ្នានេះ កិច្ចព្រមព្រៀងក្រុងហ្សឺណែវ ក៏បានបង្កើតគណៈកម្មការត្រួតពិនិត្យ បទឈប់បាញ់ និងការដកទ័ពផងដែរ ប៉ុន្តែគណៈប្រតិភូអាមេរិក បានធ្វើពហិការ មិនព្រម ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះទេ។

សូមបញ្ជាក់ថា ពេលសន្និសីទក្រុងហ្សឺណែវ កំពុងប្រព្រឹត្តឡើងនោះ នង សួន ជា មេដឹកនាំខ្មែរឥស្សរៈស្និទ្ធនឹងវៀតមិញសំខាន់ម្នាក់ដែរ ត្រូវបានមេដឹកនាំវៀតមិញ បញ្ជូន ទៅទីក្រុងហាណូយ ដើម្បីត្រៀមខ្លួនឱ្យទៅចូលរួមប្រជុំនៅក្នុងសន្និសីទ ជាមួយ ម៉ី ផូ និង កែវ មុនី តំណាងរដ្ឋាភិបាលខ្មែរឥស្សរៈ នោះដែរ តែដោយសាររដ្ឋមន្ត្រីការបរទេសវៀតណាម ខាងជើង ផាំ វ៉ាន់ដុង មិនអាចទាមទារឱ្យមេខ្មែរឥស្សរៈទាំង២នាក់នេះ ចូលរួមក្នុងសន្និសីទ នោះ សម្រេចដូចការគ្រោងទុក នង សួន ក៏បានទៅរនៅត្រឹមទីក្រុងហាណូយ ប៉ុណ្ណោះ។

ក្រោយពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ប្រហែល៣ថ្ងៃ នង សួន បានជួបជាមួយ វ៉ ង្វៀងយ៉ាប់ មេទ័ពកំពូល របស់ពួកវៀតមិញ ។

ពេលនោះ វ៉ ង្វៀងយ៉ាប់ សួរ នង សួន ថា តើសមមិត្តសប្បាយចិត្តឬទេ នៅពេល ឃើញបារាំង បញ្ចប់ការធ្វើអាណានិគម នៅកម្ពុជា? នង សួន ឆ្លើយថា សប្បាយចិត្តដែរ តែ ទាស់ត្រង់គេឱ្យពួកគាត់ជាអ្នកតស៊ូខ្មែរឥស្សរៈ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្តេចសីហនុ ដូច្នេះ ពួកគាត់ប្រាកដជាត្រូវស្តេចសីហនុ ធ្វើបាបជាមិនខាន។

វ៉ ង្វៀងយ៉ាប់ បានប្រាប់ នង សួន ថា ពួកខ្លួន (វៀតមិញ) មិនអាចធ្វើអ្វីឱ្យខុសពី កិច្ចព្រមព្រៀង នៅក្រុងហ្សឺណែវ នោះបានទេ ហើយថា បញ្ហាគាត់ព្រួយបារម្ភខ្លាចស្តេច សីហនុ ធ្វើបាបនោះ មិនថ្វីទេ ព្រោះគណៈកម្មការត្រួតពិនិត្យអន្តរជាតិ នឹងមកដល់ប្រទេស កម្ពុជា ក្នុងពេលឆាប់ៗខាងមុខនេះហើយ។

៨ថ្ងៃ ក្រោយចុះហត្ថលេខាកិច្ចព្រមព្រៀង នៅទីក្រុងហ្សឺណែវ គឺនៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៥៤ ព្រះមហាក្សត្រសីហនុ បានបង្កើតរាជរដ្ឋាភិបាលថ្មីមួយ ដោយបានតែងតាំង

ប៉ែន នុត ជានាយករដ្ឋមន្ត្រី ដដែល, ទេព ផន ជារដ្ឋមន្ត្រីមហាផ្ទៃ ការបរទេស និងសន្និសីទ, អូ ឈឺន ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងផែនការ, យ៉ែម សំបូរ ជារដ្ឋមន្ត្រីថវិកា ពាណិជ្ជកម្ម និងឧស្សាហកម្ម, ប៉ុក ធួន ជារដ្ឋមន្ត្រីយុត្តិធម៌, ស៊ឹម វ៉ា ជារដ្ឋមន្ត្រីសាធារណការ ទូរគមនាគមន៍ និងកសិកម្ម, ផូ ព្រឿង ជារដ្ឋមន្ត្រីអប់រំជាតិ និងវិចិត្រសិល្បៈ, ង៉ោ ហ៊ូ ជារដ្ឋមន្ត្រីការពារជាតិ និងសាធារណសុខាភិបាល, ទ្រង់នរោត្តម រ៉ិយ៉ោ ជារដ្ឋលេខាធិការការពារលើផ្ទៃប្រទេស និងសន្តិសុខជាតិ, ប៉ាល់ ជូន ជារដ្ឋលេខាធិការធម្មការ ព័ត៌មាន ការងារ និងសង្គមកិច្ច, ប្រាក់ សារិន ជាអនុរដ្ឋលេខាធិការការបរទេស និងសន្និសីទ, អេង ហ៊ុន ជាអនុរដ្ឋលេខាធិការពាណិជ្ជកម្ម និងឧស្សាហកម្ម, ទេព យុទ្ធ ជាអនុរដ្ឋលេខាធិការកសិកម្ម និងយូ ឈិន ជាអនុរដ្ឋលេខាធិការសាធារណសុខាភិបាល។

នៅថ្ងៃបង្កើតរាជរដ្ឋាភិបាលនេះ ស្រាប់តែកងទ័ពថៃ បានលើកគ្នាចូលមកឈ្លានពាន និងបោះទីតាំងនៅតំបន់ប្រាសាទព្រះវិហារ របស់ខ្មែរ យ៉ាងព្រហើនកោងកាចបំផុត។

ដើម្បីអនុវត្តកិច្ចព្រមព្រៀងសន្តិភាព នៅក្រុងហ្សឺណែវ គណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC= International Control Commission) ត្រូវបានបង្កើតឡើង ដោយមានប្រទេសឥណ្ឌា ជាប្រទេសអព្យាក្រឹត ធ្វើជាប្រធាន, ប្រទេសកាណាដា តំណាងឱ្យបណ្តាប្រទេសសេរី និងប្រទេសប៉ូឡូញ តំណាងឱ្យបណ្តាប្រទេសកុម្មុយនិស្តជាសមាជិក។

មន្ត្រីជាន់ខ្ពស់ឥណ្ឌា ឈ្មោះឌុត្ត (Dutt) ត្រូវបានតែងតាំងជាប្រធានគណៈកម្មការត្រួតពិនិត្យអន្តរជាតិនេះ បានរៀបចំកិច្ចប្រជុំមួយ នៅទីក្រុងញូវ ដេលី (New Dalhi) ប្រទេសឥណ្ឌា ដើម្បីបង្កើតគណៈកម្មការរយោធាចម្រុះជាតិសាសន៍មួយផងដែរ ។

ពេលនោះ ព្រះមហាក្សត្រសីហនុ បានត្រាស់បង្គាប់ឱ្យ សឺន សាន ជាមន្ត្រីស៊ីវិលសុទ្ធសាធ មិនដែលកាន់កាំភ្លើងម្តងណា តាំងពីដើមមក ឱ្យធ្វើជាប្រធានគណៈប្រតិភូយោធាកម្ពុជា និងបានប្រទានឋានន្តរស័ក្តិជាវរសេនីយ៍ឯក (ស័ក្តិ៥) ដល់គាត់ទៀតផង។ ឯសាក់ ស៊ុត សាខន ពេលនោះ មានឋានន្តរសក្តិជាអនុសេនីយ៍ឯក និងជានាយទាហានមានជំនាន់ត្រឹមត្រូវ ព្រះអង្គត្រាស់បង្គាប់ឱ្យធ្វើជាអនុប្រធានគណៈប្រតិភូ ដើម្បីទៅចូលរួមការបង្កើត



សឺន សាន

គណៈកម្មការយោធា នៅទីក្រុងញូវដេលី(New Dalhi)នោះ។

ក្រោយពីបង្កើតគណៈកម្មការយោធាចម្រុះជាតិសាសន៍ នោះមក ឌុត្ត (Dutt) ប្រធានគណៈកម្មការត្រួតពិនិត្យអន្តរជាតិ មានគម្រោងឱ្យគណៈកម្មការយោធានេះ ធ្វើដំណើរតាមយន្តហោះពីទីក្រុងញូវដេលី ត្រង់ទៅទីក្រុងហាណូយតែម្តង។

ពេលនោះ ភាគីយោធាកម្ពុជាបានស្នើសុំឱ្យគណៈកម្មការយោធានេះចូលឈប់សំចតនៅទីក្រុងភ្នំពេញសិន រួចចាំបន្តដំណើរទៅទីក្រុងហាណូយទៀត។ តែឌុត្ត(Dutt) មិនព្រមជាដាច់ខាត។

ឆ្លៀតឱកាសនោះ គណៈប្រតិភូយោធាកម្ពុជា ដឹកនាំដោយសឺន សាន ក៏បានសុំចូលជួបសម្តែងការគួរសមចំពោះនាយករដ្ឋមន្ត្រីឥណ្ឌា ហ្សាវី ហាវ៉ឡាល់ នេរូហ៍ (Jawi harlal Nehru) ផងដែរ ។ ពេលនោះ នាយករដ្ឋមន្ត្រីរូបនេះ ក៏បានបញ្ជាក់ប្រាប់គណៈប្រតិភូយោធាកម្ពុជាថា មូលហេតុប្រទេសឥណ្ឌា មិនទាន់ទទួលស្គាល់ឯករាជ្យរបស់ប្រទេសកម្ពុជានោះ គឺដោយសារគាត់ចង់ឱ្យកម្ពុជា មានឯករាជ្យពេញលេញសិន។ ជាមួយគ្នានោះ គាត់បានផ្តាំផ្ញើឱ្យ សឺន សាន ទូលថ្វាយព្រះមហាក្សត្រសីហនុ ផងថា ប្រទេសឥណ្ឌា នឹងទទួលស្គាល់ឯករាជ្យរបស់កម្ពុជា នៅក្នុងពេលដ៏ខ្លីខាងមុខនេះហើយ។

ចុងក្រោយ តាមសំណូមពររបស់គណៈប្រតិភូយោធាកម្ពុជា នាយករដ្ឋមន្ត្រីឥណ្ឌាក៏បានប្រាប់ឱ្យឌុត្ត (Dutt) ប្រធានគណៈកម្មការត្រួតពិនិត្យអន្តរជាតិ ជួយសម្រួលការធ្វើដំណើរតាមយន្តហោះរបស់គណៈកម្មការយោធាចម្រុះជាតិសាសន៍នោះ ដោយចុះសំចត

នៅទីក្រុងភ្នំពេញសិន រួចចាំបន្តដំណើរទៅទីក្រុងហាណូយ ទៀត។

ក្រៅពីបង្កើតគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) ដើម្បីត្រួតពិនិត្យនូវការអនុវត្ត កិច្ចព្រមព្រៀងក្រុងហ្សឺណែវ នៅឥណ្ឌូចិនទាំងមូល ក៏មានការបង្កើតគណៈកម្មការត្រួតពិនិត្យ អន្តរជាតិ ប្រចាំនៅតាមប្រទេសនីមួយៗផងដែរ។

គណៈកម្មការត្រួតពិនិត្យអន្តរជាតិ ប្រចាំនៅប្រទេសកម្ពុជា មានឧត្តមសេនីយ៍ ជាជនជាតិឥណ្ឌា ឈ្មោះ ខេ អិល ប៊ិនដ្រា (K. L. Bindra)ជាប្រធាន។

ដោយអនុវត្តតាមកិច្ចព្រមព្រៀងសន្និសីទក្រុងហ្សឺណែវ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៥៤ គណៈកម្មការអន្តរជាតិព្រំដែន បានចុះមកឈរជើងប្រចាំការ នៅក្នុងខេត្តស្វាយរៀង។

ដោយសារបារម្ភខ្លាចប្រទេសកម្ពុជា ធ្លាក់ទៅក្នុងកណ្តាប់ដៃពួកកុម្មុយនិស្តវៀតមិញ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៥៤ រដ្ឋាភិបាលសហរដ្ឋអាមេរិក ក៏បានបញ្ជូនក្រុមជំនាញការ ខាងយោធា ហិរញ្ញវត្ថុ សេដ្ឋកិច្ច និងវប្បធម៌ ជាច្រើនរូប មកកាន់ទីក្រុងភ្នំពេញ ដើម្បីជួយ រៀបចំប្រទេសកម្ពុជា ជំនួសបារាំង វិញម្តង។

នៅថ្ងៃទី២៧ ខែសីហា នោះដែរ ព្រះមហាក្សត្រ នរោត្តម សីហនុ បានរុះរើផ្លាស់ប្តូរ សមាសភាពសមាជិករាជរដ្ឋាភិបាលមួយចំនួន ដោយប៉ែន នុត នៅជានាយករដ្ឋមន្ត្រី ដដែល តែមានការផ្លាស់ប្តូរ និងផ្ទេរភារកិច្ចរដ្ឋមន្ត្រីមួយចំនួនក្នុងនោះមាន អូ ឈឺន ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងផែនការ, ទេព ផន ជារដ្ឋមន្ត្រីមហាផ្ទៃ ការបរទេស និងសន្និសីទ, ប៉ុក ធួន ជារដ្ឋមន្ត្រីយុត្តិធម៌, យ៉ែម សំបូរ ជារដ្ឋមន្ត្រីថវិកា ពាណិជ្ជកម្ម និង ឧស្សាហកម្ម, ស៊ឹម វ៉ា ជារដ្ឋមន្ត្រីសាធារណការ ទូរគមនាគមន៍ និងកសិកម្ម, ផូ ព្រឿង ជា រដ្ឋមន្ត្រីអប់រំជាតិ និងវិចិត្រសិល្បៈ, ង៉ោ ហូ ជារដ្ឋមន្ត្រីការពារជាតិ និងសាធារណសុខាភិបាល, ទ្រង់ នរោត្តម រ៉ីយ៉ោ ជារដ្ឋលេខាធិការការពារជាតិ ការងារ និងសង្គមកិច្ច, ប្រាក់ សារិន ជា អនុរដ្ឋលេខាធិការការបរទេស និងសន្និសីទ, អេង ហ៊ុន ជារដ្ឋលេខាធិការពាណិជ្ជកម្ម និង ឧស្សាហកម្ម, ទេព យុទ្ធ ជាអនុរដ្ឋលេខាធិការកសិកម្ម និងយូ ឈិន ជាអនុរដ្ឋលេខាធិការ សាធារណសុខាភិបាល។

៧៦
សហរដ្ឋអាមេរិក អូសទាញកម្ពុជា ឱ្យចូលអង្គការសេអាតូ (SEATO)



កិច្ចប្រជុំអង្គការសេអាតូ (SEATO) **ឆ្នាំ១៩៥៥**

នៅថ្ងៃទី០៨ ខែកញ្ញាឆ្នាំ១៩៥៤ សហរដ្ឋអាមេរិក បានផ្តួចផ្តើមឱ្យមេដឹកនាំប្រទេសជាសម្ព័ន្ធមិត្តរបស់ខ្លួន មករួមប្រជុំនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ក្នុងនោះរួមមាន៖ សហរដ្ឋអាមេរិក ខ្លួនឯង ប្រទេសហ្វីលីពីន(ជាម្ចាស់ផ្ទះ) ប្រទេសអង់គ្លេស ប្រទេសបារាំង ប្រទេសថៃ ប្រទេសប៉ាគីស្ថាន ប្រទេសអូស្ត្រាលី និងប្រទេសនូវែលហ្សេឡង់ដ៍ ក្នុងគោលបំណងប្រជុំពិភាក្សាគ្នា និងចុះហត្ថលេខាបង្កើតអង្គការយោធាមួយ ហៅថា អង្គការកតិកាសញ្ញាអាស៊ីអាគ្នេយ៍ (The Southeast Asia Treaty Organization) ហៅកាត់ជាភាសាបារាំងថា អង្គការសេអាតូ (SEATO)។

គោលបំណងសំខាន់ក្នុងការបង្កើតអង្គការសេអាតូ(SEATO) នេះ គឺដើម្បីទប់ស្កាត់លទ្ធិកុម្មុយនិស្ត ដែលកំពុងរីករាលដាលយ៉ាងខ្លាំង ចេញពីប្រទេសចិន នៅក្នុងតំបន់អាស៊ីទាំងមូល។



ផុតួ សារ៉ៈសុិន

អង្គការសេអាតូ (SEATO) បានលេចចេញជារូបរាងឡើង នៅឆ្នាំ១៩៥៥ មានទីស្នាក់ការកណ្តាល នៅរាជធានីបាង-កកប្រទេសថៃដោយមានអ្នកនយោបាយ និងជាអ្នកការទូតជនជាតិថៃ ម្នាក់ឈ្មោះ ផុត្ន សារ៉ៈសុិន (Pote Sarasin) ជាអគ្គ-លេខាធិការ នៅឆ្នាំ១៩៥៧។

ផុត្ន សារ៉ៈសុិន (Pote Sarasin) ធ្លាប់បម្រើការជារដ្ឋមន្ត្រីការបរទេសថៃ ពីឆ្នាំ ១៩៤៩ ដល់ឆ្នាំ១៩៥០ និងធ្លាប់ធ្វើជាឯកអគ្គរាជទូត ប្រចាំសហរដ្ឋអាមេរិក កាលពីឆ្នាំ ១៩៥២ ។

តែគួរកត់សម្គាល់ថា នៅតំបន់អាស៊ីអាគ្នេយ៍ មានតែប្រទេសចំនួន២ប៉ុណ្ណោះ គឺប្រទេសថៃ និងហ្វីលីពីន បានចូលជាសមាជិករបស់អង្គការនេះ ដោយសារតែប្រទេសទាំង ២នេះ មានទំនាក់ទំនងជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក ជាពិសេស ហ្វីលីពីន ដែលកំពុងប្រឈមមុខនឹងការបះបោររបស់ពួកកុម្មុយនិស្ត ខណៈប្រទេសថៃ ក៏កំពុងរងការធ្វើវិទ្ធង្សនាដោយចលនាតស៊ូរបស់ពួកកុម្មុយនិស្តថៃ ផងដែរ។

ប្រទេសប៉ាគីស្តាន ស្ថិតនៅក្នុងតំបន់អាស៊ីខាងត្បូង បានចូលជាចូលជាសមាជិករបស់អង្គការនេះ ដោយសារសង្ឃឹមថា នឹងទទួលបានជំនួយពីអង្គការសេអាតូ (SEATO) នេះ ដើម្បីទប់ទល់នឹងការរំលោភឈ្លានពានរបស់ប្រទេសឥណ្ឌា តែប៉ុណ្ណោះ។

ដោយឡែក បណ្តាប្រទេសផ្សេងៗទៀតក្នុងតំបន់ ដូចជា ប្រទេសកូមា និងប្រទេសឥណ្ឌូណេស៊ី មិនបានចូលជាសមាជិករបស់អង្គការនេះ ដោយសារប្រទេសទាំង ២នេះ យកចិត្តទុកដាក់ខ្លាំង ចំពោះបញ្ហាស្ថិរភាពផ្ទៃក្នុង ជាជាងការគំរាមកំហែងពីឥទ្ធិពលរបស់

លទ្ធិកុម្មុយនិស្ត។ ជាមួយគ្នានេះ ប្រទេសម៉ាឡេស៊ី និងសិង្ហបុរី មិនចូលជាសមាជិករបស់អង្គការនេះ ដោយសារតែពួកគេមានទំនាក់ទំនងយ៉ាងល្អ ជាមួយចក្រភពអង់គ្លេស ហើយគេជឿថា អង់គ្លេស អាចជួយការពារពួកគេពីឥទ្ធិពលកុម្មុយនិស្ត បាន។

ចំណែកវៀតណាមខាងជើង វៀតណាមខាងត្បូង កម្ពុជា និងឡាវ ទើបនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ មិនត្រូវអនុញ្ញាតឱ្យមានការចូលរួមជាមួយអង្គការបក្សសម្ព័ន្ធយោធាអន្តរជាតិណាមួយឡើយ ពិសេសកម្ពុជា បានប្រកាសខ្លួនឯងថា ជាប្រទេសអព្យាក្រឹតហើយដែរ។

ក្រៅពីមានគោលដៅសហការគ្នាលើវិស័យយោធាជាសំខាន់ អង្គការសេអាតូ (SEATO) មានគោលបំណងជួយរៀបចំប្រព័ន្ធអប់រំ និងកសាងសេដ្ឋកិច្ច ដល់បណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ផងដែរ ក្រោមហេតុផលថា បើសិនជាប្រជាជននៅអាស៊ីអាគ្នេយ៍ មានជីវភាពដ៏ល្អប្រសើរ ពួកគេនឹងមិនមានជំនឿលើលទ្ធិកុម្មុយនិស្ត នោះឡើយ។

ក្រោយសន្និសីទក្រុងហ្សឺណែវ ព្រះមហាក្សត្រ នរោត្តម សីហនុ មានបំណងចង់ផ្សារទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ឱ្យកាន់តែជិតស្និទ្ធថែមទៀតដែរ។ តែអ្នក នយោបាយខ្មែរឆ្វេងនិយម បានអូសទាញថា បើព្រះអង្គផ្សារទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ឱ្យកាន់តែជិតស្និទ្ធថែមទៀតនោះ ទៅអនាគតអាចនាំនូវគ្រោះថ្នាក់ធ្ងន់ធ្ងរជាមិនខាន។

ពួកអ្នកនយោបាយឆ្វេងនិយម(ពួកកុម្មុយនិស្ត) មានការព្រួយបារម្ភថា អស់ពីបារាំងជាពួកអាណានិគមចាស់ ចាកចេញពីប្រទេសកម្ពុជាអស់ទៅ សហរដ្ឋអាមេរិកជាពួកចក្រពត្តិនិយមថ្មី នឹងចូលមកជំនួសវិញ ហើយពួកគេគិតថាព្រះមហាក្សត្រសីហនុ នឹងដាក់ប្រទេសឱ្យនៅក្រោមឆត្រការពាររបស់អង្គការសេអាតូ(SEATO) ដែលសហរដ្ឋអាមេរិក បានបង្កើតឡើងនោះ ជាមិនខាន។ តែទោះបីយ៉ាងណា ពេលនោះ ព្រះអង្គមិនបានសម្រេចព្រះទ័យក្នុងការជ្រើសរើសយកមាគ៌ានយោបាយណាមួយ ក្រៅពីមាគ៌ានយោបាយអព្យាក្រឹត ដើម្បីដឹកនាំប្រទេសនោះឡើយ។

នៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៥៤ រ៉ូប៊ែរ ម៉ាក់ គ្លិនតុក (Robert Mc Clintock) ដែល



ឆាយកសេរីអា ឈ្មោះ អាល្លេន វែល ឌុល្លេស
ជាអ្នកប្រុសរបស់ចន ហ្វូស្ទ័រ ឌុល្លេស

រដ្ឋាភិបាលសហរដ្ឋអាមេរិក ទើប តែតែងតាំងជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកថ្មី ប្រចាំនៅប្រទេសកម្ពុជា បានចូលថ្វាយសារតាំងដល់ព្រះមហាក្សត្រសីហនុ ហើយស្ថានទូតសហរដ្ឋអាមេរិក ត្រូវបានផ្លាស់ប្តូរទីតាំង ចេញពីបរិវេណសណ្ឋាគារ ឡឺរ៉ូយ៉ាល់ ទៅកាន់កន្លែងធំទូលាយជាងមុន និងមានបុគ្គលិកកាន់តែច្រើនថែមទៀត ។

នៅពេលបារាំង ត្រូវដកខ្លួនចេញពីប្រទេសវៀតណាមខាងត្បូង តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ មិនបានប៉ុន្មានថ្ងៃផង ថ្ងៃទី២៤ ខែតុលាឆ្នាំ១៩៥៤ ប្រធានាធិបតីអាមេរិក ដ្វៃ ឌី. អៃសិនហាវើរ បានផ្តល់ជំនួយសេដ្ឋកិច្ចជាច្រើន ដល់ប្រទេសវៀតណាមខាងត្បូង។

បន្ទាប់មកទៀតនៅក្នុងខែកុម្ភៈឆ្នាំ១៩៥៥ សហរដ្ឋអាមេរិក បានបញ្ជូននាយទាហានជំនាញៗរបស់ខ្លួន ឱ្យមកជួយបង្ហាត់បង្រៀនក្បួនយុទ្ធសាស្ត្រដល់កងទ័ពវៀតណាមខាងត្បូងទៀតផង។ ជាមួយគ្នានេះដែរ សហរដ្ឋអាមេរិក កាន់តែអន្ទះអន្ទែងចង់ជាក់ប្រទេសកម្ពុជា

ឱ្យនៅក្រោមឆត្រការពាររបស់អង្គការសេអាតូ(SEATO) នេះ ខ្លាំងឡើងៗ។

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៥៥ ចន ហ្វូស្ទ័រ ឌុលេស (John Foster Dulles) រដ្ឋមន្ត្រីក្រសួងការបរទេស នៃរដ្ឋបាលប្រធានាធិបតីសហរដ្ឋអាមេរិកឌ្វៃ ឌី. អៃសិនហាវើ (Dwight D. Eisenhower) បានធ្វើដំណើរមកបំពេញទស្សនកិច្ចនៅរាជធានីភ្នំពេញ ក្នុងគោលបំណងបញ្ចុះបញ្ចូលព្រះមហាក្សត្រសីហនុ ឱ្យដាក់ប្រទេសកម្ពុជា នៅក្រោមកឆត្រការពាររបស់អង្គការសេអាតូ (SEATO=SouthEast Asia Treaty Organization) ដូចប្រទេសវៀតណាមខាងត្បូង និងឡាវ ដែរ តែព្រះអង្គមិនយល់ព្រម គឺនៅតែរក្សាជំហរអព្យាក្រឹតដដែល។

បន្ទាប់មកទៀត នាយកអង្គភាពភ្នាក់ងារសម្ងាត់សេអ៊ីអា (CIA = Central Intelligence Agency)របស់អាមេរិក ឈ្មោះ អាល្លេន វែល ឌុលេស (Allen Welsh Dulles) ជាប្អូនប្រុសរបស់ចន ហ្វូស្ទ័រ ឌុលេស (John Foster Dulles) រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ក៏បានមកបំពេញទស្សនកិច្ច នៅរាជធានីភ្នំពេញ ដែរ។

ពេលនោះ នាយកភ្នាក់ងារសម្ងាត់សេអ៊ីអារូបនេះ បានព្យាយាមនិយាយបញ្ចុះបញ្ចូលសម្តេចសីហនុ ឱ្យដាក់ប្រទេសកម្ពុជា នៅក្រោមឆត្រការពាររបស់អង្គការសេអាតូ (SEATO) ដើម្បីទប់ស្កាត់ឥទ្ធិពលកុម្មុយនិស្ត នៅអាស៊ីអាគ្នេយ៍ ជាថ្មីម្តងទៀត។ ប៉ុន្តែ សម្តេចសីហនុនៅតែបដិសេធ ដោយមានបន្ទូលតបវិញថា៖ «កម្ពុជា គ្មានបំណងក្នុងការភ្ជាប់ខ្លួនចូលទៅផ្នែកណាមួយរបស់អង្គការសេអាតូ (SEATO) នេះទេ ហើយកម្ពុជា អាចការពារខ្លួនឯងបានពីលទ្ធិកុម្មុយនិស្ត ក្នុងនាមជាប្រទេសអព្យាក្រឹត និងជាអ្នកគោរពប្រតិបត្តិតាមព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន»។ បន្ទូលខាងខាងលើនេះ ធ្វើឱ្យនាយកភ្នាក់ងារសម្ងាត់សេអ៊ីអា អាល្លេន វែល ឌុលេស (Allen Welsh Dulles) គ្មានអ្វីដែលនិយាយជាមួយព្រះអង្គតទៅទៀតទេ គឺមានតែឡើងយន្តហោះត្រលប់ទៅក្រុងវ៉ាស៊ីងតោន វិញទាំងខកចិត្តប៉ុណ្ណោះ។

ចាប់ពីពេលនោះមក សហរដ្ឋអាមេរិក បានចាប់ផ្តើមអនុវត្តនយោបាយដាក់សម្ពាធមកលើប្រទេសកម្ពុជា ជាកោះសន្តិភាពមួយ ដើម្បីឱ្យបោះបង់ចោលនូវគោលនយោបាយ

អព្យាក្រឹតភាពរបស់ខ្លួន ដើម្បីងាកទៅរកប្តូកលោកសេរីវិញ ហើយប្រទេសថៃ ជាសមាជិក អង្គការសេអាតូ និងវៀតណាមខាងត្បូង ដែលអង្គការសេអាតូ នេះ បានដាក់ឱ្យនៅក្រោម ឆត្រការពាររបស់ខ្លួន ក៏ចាប់ផ្តើមធ្វើទុក្ខបុកម្នេញតាមព្រំដែនរបស់ប្រទេសកម្ពុជា និងបាន ព្យាយាមចូលជ្រៀតជ្រែកដល់កិច្ចការផ្ទៃក្នុងកម្ពុជា តាមរយៈការគាំទ្រអ្នកប្រឆាំងនឹងសម្តេច សីហនុ តាំងពីពេលនោះមក ដោយចំហតែម្តង ។

ចំណែកសម្តេចសីហនុ ក៏បានចាត់ទុកអង្គការសេអាតូ (SEATO) នេះថា ជាអង្គការ សម្ព័ន្ធមិត្តយោធាមួយ សម្រាប់តែដើរបង្ករឿង ឈ្លានពានទៅលើប្រទេសជិតខាង ដែល ផ្ទុយស្រឡះពីការប្រកាន់ជំហរអព្យាក្រឹត របស់ព្រះអង្គ។

តែទោះជាបីយ៉ាងនេះក៏ដោយ ក៏នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៥៥ រាជរដ្ឋាភិបាល កម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលជំនួយយោធា និងសេដ្ឋកិច្ច អប់រំ កសិកម្ម សុខាភិបាល ពីសហរដ្ឋអាមេរិក ដោយក្នុងមួយឆ្នាំៗទទួលប្រាក់ជំនួយ ចំនួន៥០លាន ដុល្លារសហរដ្ឋអាមេរិក ដែរ។

៧៧
ប៉ែន សុវណ្ណ និងខ្មែរឥស្សរៈជាង១០០០នាក់ ចេញទៅជាមួយកងទ័ពវៀតមិញ



កងទ័ពវៀតមិញ ឥលនៅវៀតណាមតាតខាងជើងវិញ

ដោយអនុវត្តតាមកិច្ចព្រមព្រៀងនៅក្រុងហ្សឺណែវ កាលពីខែកក្កដា នោះ នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៥៤ កងទ័ពវៀតមិញ ស្ថិតនៅក្នុងប្រទេសវៀតណាមខាងត្បូង ត្រូវទម្លាក់អាវុធ និងលៃត្រលប់ទៅកាន់ជីវភាពជាជនស៊ីវិលវិញ ឬត្រូវធ្វើដំណើរចាកចេញទៅវៀតណាមខាងជើង។

ពួកខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ ដែលកិច្ចព្រមព្រៀងនៅក្រុងហ្សឺណែវ មិនអនុញ្ញាតឱ្យមានបែងចែកទឹកដីនៅក្នុងប្រទេសកម្ពុជាមួយចំណែកណា ដើម្បីត្រួតត្រាកាន់-កាប់ ដូចនៅប្រទេសឡាវនោះ មេដឹកនាំរបស់ពួកគេមួយចំនួន បានទម្លាក់អាវុធ ទៅបង្កើតគណបក្សនយោបាយស្របច្បាប់ ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ដែលត្រូវ

រៀបចំឡើងនៅពេលខាងមុខ ខ្លះទៀតបានសម្រេចចិត្តទៅរស់នៅជួបជុំឪពុកម្តាយ បងប្អូនក្រុមគ្រួសារ ក្នុងឋានៈជាជនស៊ីវិលវិញ។

ដោយឡែក ពួកគេជាង១០០០នាក់ផ្សេងទៀត បានសម្រេចចិត្តចាកចេញពីមាតុ-ប្រទេស ធ្វើដំណើរទៅវៀតណាមភាគខាងជើង ជាមួយនឹងកងទ័ពវៀតមិញ ត្រូវដកចេញពីទឹកដីកម្ពុជានោះដែរ ដោយនៅក្នុងចំណោមកងទ័ពខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ ទាំងអស់នោះ ក៏មានយុទ្ធជន ប៉ែន សុវណ្ណ ម្នាក់ដែរ។

ប៉ែន សុវណ្ណ បានរំឭកពីដំណើរចាកចេញទៅកាន់ប្រទេសវៀតណាមភាគខាងជើងនោះថា អង្គភាពលេខ១៦០របស់គាត់ ពីមុនមានកងទ័ពចម្រុះខ្មែរ និងវៀតមិញ ត្រូវបែង-ចែកជាពីរផ្នែក គឺមួយផ្នែក ជាជនជាតិខ្មែរ និងមួយផ្នែកទៀត ជាជនជាតិវៀតណាម ក្នុងនោះ កងទ័ពវៀតណាម ត្រូវត្រៀមខ្លួនចាកចេញពីទឹកដីកម្ពុជា រួចត្រលប់ទៅប្រទេសវៀតណាមខាងជើង វិញ។

ចំណែកពួកគាត់ជាកងទ័ពខ្មែរឥស្សរៈ ត្រូវចែកចេញជា៣ក្រុម បន្តទៀត គឺក្រុមទី១ ត្រូវនៅធ្វើសកម្មភាពតស៊ូជាសម្ងាត់ក្នុងប្រទេសបន្តទៀត។ ក្រុមទី២ ត្រូវរួលត្រលប់ទៅរក ក្រុមគ្រួសារនៅឯស្រុកកំណើតវិញ និងក្រុមទី៣ ត្រូវធ្វើដំណើរទៅប្រទេសវៀតណាមភាគខាងជើង ដើម្បីត្រៀមលក្ខណៈធ្វើបដិវត្តន៍ ទៅថ្ងៃក្រោយទៀត។

ប៉ែន សុវណ្ណ បញ្ជាក់ថា ព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៥៤ នៅក្នុងភូមិស្រែចែង ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត មេបញ្ជាការអង្គភាពរបស់គាត់ បានបើកអង្គប្រជុំធំមួយដើម្បីផ្សព្វផ្សាយពីជ័យជម្នះលើសមរភូមិរបស់ប្រទេសទាំង៣ នៅឥណ្ឌូចិន និងបានបញ្ជាក់ថា ដោយសារសន្និសីទនៅក្រុងហ្សឺណែវ ភ្លើងសង្គ្រាមត្រូវបានបញ្ចប់ហើយ។

នៅក្នុងអង្គប្រជុំនោះ ប៉ែន យុទ្ធ គណៈដឹកនាំភូមិភាគនិរតី និងជ័យ សួន (នង សួន) កម្មាភិបាលគណៈមជ្ឈិមបក្ស ជាអធិបតីបានប្រកាសថា គាត់ (ប៉ែន សុវណ្ណ) មានឈ្មោះត្រូវចាកចេញពីមាតុប្រទេស ដើម្បីទៅសិក្សានៅក្រៅប្រទេស ជាមួយកងទ័ពខ្មែរឥស្សរៈនៅតាមអង្គភាពផ្សេងៗទៀត សរុបជាង១០០០នាក់ទៀត ។


ប៉ែន សុវណ្ណ

មេដឹកនាំទាំង២នាក់ ក៏បានឡើងមានមតិផ្តាំផ្ញើកងទ័ពដែលត្រូវចាកចេញទាំងអស់នោះ ឱ្យបានដឹងថា មុនដំបូងពួកគាត់ត្រូវធ្វើដំណើរដោយថ្មើរជើង។ បន្ទាប់មកត្រូវជិះទូកឆ្លងទន្លេ រួចត្រូវបន្តដំណើរតាមនាវាចម្បាំងរបស់បារាំង និងប្រទេសប៉ូឡូញ ឆ្លងកាត់សមុទ្រ ឆ្ពោះទៅកាន់ប្រទេសវៀត-ណាមខាងជើង តែម្តង។

ដើមខែវិច្ឆិកា ឆ្នាំ១៩៥៤ ក្នុងពេលកំពុងត្រៀមខ្លួនចេញដំណើរ មានយុទ្ធជនម្នាក់ បានមកហៅប៉ែន សុវណ្ណ ឱ្យទៅជួប ទូ សាមុត អនុលេខាគណៈកម្មាធិការមជ្ឈិមបក្ស កំពុងអង្គុយលើអង្រឹង ក្រោមដើមឈើមួយ។

ក្រោយពីសួរសុខទុក្ខបន្តិចមក ទូ សាមុត ក៏បានប្រាប់ប៉ែន សុវណ្ណ ថា តាមរយៈកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ភ្លើងសង្គ្រាម នៅក្នុងប្រទេសយើងត្រូវបានបញ្ចប់ ហើយពួកបារាំងក៏ត្រូវដកចេញអស់ដែរ។ ប្រទេសយើងបានឯករាជ្យ និងសន្តិភាព ក៏ពិតមែន តែប្រជាជនខ្មែរមិនទាន់មានសិទ្ធិសេរីភាពទេ ព្រោះសង្គមជាតិយើងត្រូវពួកសក្តិភូមិឆ្លៀតឱកាសដណ្តើមអំណាច មកគ្រប់គ្រងបន្តទៀត។ ដូច្នេះតាងនាមបក្ស និងប្រជាជនខ្មែរ ខ្ញុំប្រគល់ភារកិច្ចឱ្យសមមិត្តទៅសិក្សាបណ្តុះបណ្តាលនៅប្រទេសវៀតណាមខាងជើង ដើម្បីអនាគតនៃមាតុភូមិកម្ពុជា យើង។

មិនយូរប៉ុន្មាន ក្រោមការចាត់ចែងរបស់គណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) កងទ័ពខ្មែរឥស្សរៈរបស់សឺង ង៉ុកមិញ ចំនួន១០៤០នាក់ បានធ្វើដំណើរតាមនាវាចម្បាំង

ជាច្រើនគ្រឿង របស់ប្រទេសប៉ូឡូញ ទៅដល់ប្រទេសវៀតណាមខាងជើង។


ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៥៤ ប៉ែន សុវណ្ណ និងមិត្តរួមអាវុធទាំងអស់ បានទៅដល់ជំរំកងទ័ពមួយ នៅវៀតណាមភាគខាងជើង។

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៥៥ ប៉ែន សុវណ្ណ បានចូលរៀនភាសាវៀតណាម និងជំនាញនយោបាយថ្នាក់មូលដ្ឋានរយៈពេលមួយឆ្នាំ។ នៅទីនោះ ប៉ែន សុវណ្ណ បានជួបបងប្រុសបង្កើតរបស់គាត់ឈ្មោះ គីម ជាអតីតយុទ្ធជននៅក្នុងអង្គភាពកងទ័ពឥស្សរៈខ្មែរ-វៀតមិញ លេខ ៦៤០ ធ្លាប់តស៊ូប្រឆាំង នឹងបារាំង នៅក្នុងប្រទេសកម្ពុជា តាំងពីមុនមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នោះផងដែរ។

ក្រោយពីបញ្ចប់ការសិក្សាផ្នែកនយោបាយថ្នាក់មូលដ្ឋានបានមួយឆ្នាំ ប៉ែន សុវណ្ណ ក៏បានស្នើសុំ សឺង ង៉ុកមិញ(អាចារ្យមៀន) ជាលេខាគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរ កំពុងរស់នៅប្រទេសវៀតណាមខាងជើងនោះ ចូលរៀននៅសាលាបណ្តុះ-បណ្តាលកងទ័ពជើងគោក រយៈពេល៥ឆ្នាំបន្តទៀត។

ក្រោយបញ្ចប់ការសិក្សា នៅសាលាកងទ័ពជើងគោក នោះមក សឺង ង៉ុកមិញ ក៏បានចាត់តាំង ប៉ែន សុវណ្ណ ឱ្យទៅរៀននៅវិទ្យាស្ថាននយោបាយ សេដ្ឋកិច្ច និងយោធា អស់រយៈពេល៥ឆ្នាំបន្ថែមទៀត។

៧៨
សម្តេចសីហនុ មិនព្រមឱ្យ សឺង ង៉ុកថាញ់ ចូលជួប



ព្រះមហាក្សត្រសីហនុ (**រូបថត** gettyimages)

ដើមឆ្នាំ១៩៥៤ គឺក្រោយពេលសម្តេចសីហនុ ប្រកាសឯករាជ្យ បានប្រហែល១ខែ គណៈកម្មាធិការនាយកប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ បានបើកសម័យប្រជុំមួយ ដើម្បីពិភាក្សាពីបញ្ហាឯករាជ្យរបស់ប្រទេសជាតិ និងបញ្ហាវិលមករួមរស់ក្នុងសង្គមជាតិវិញ។

ពេលនោះ អង្គប្រជុំបានសម្រេចថា កម្លាំងតស៊ូរបស់ខ្លួនទាំងអស់ ត្រូវតែទម្លាក់អាវុធទៅចូលរួមក្នុងសង្គមជាតិវិញ ប៉ុន្តែ ត្រូវបែងចែកជា២វគ្គ គឺវគ្គទី១ ត្រូវចូលរួមក្នុងសង្គមជាតិវិញ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥៤ ដោយមាន អៀ ស៊ីចូវ ជាអ្នកដឹកនាំ និងសហការីរបស់គាត់ រួមមាន ហង្ស ធុនហាក់, សាឡុត ឆាយ (បងបង្កើតរបស់សាឡុត ស), អ៊ុម ស៊ីម, អ៊ឹង ម៉ែងគ្រុយ, ស្រី ឫទ្ធី, សាង សាវាត, អនុសេនីយ៍ទោដួង ចន្ទសាវាត, ឃី តាំងលឹម, ប៉ែន គិត (ជំនាញខាងវិទ្យុផ្សាយសំឡេង) ព្រមទាំងកងកម្លាំងមកពីភាគទក្សិណទិស (ខេត្តកំពង់ស្ពឺ) និងកងកម្លាំងមកពីភាគឦសានទិស។

មូលហេតុ ដែលសឺង ង៉ុកថាញ់ សម្រេចចិត្តឱ្យ អៀ ស៊ីចូវ ដឹកនាំកងកម្លាំងតស៊ូទៅចូលរួមក្នុងសង្គមជាតិ មុនគាត់នោះ គឺគាត់ចង់ឲ្យអៀ ស៊ីចូវ ទៅបកស្រាយពន្យល់ដល់រាជរដ្ឋាភិបាល ជាពិសេសសម្តេចសីហនុ កុំឲ្យមានការភាន់ច្រឡំថា ចលនាតស៊ូរបស់គាត់នៅតែធ្វើសកម្មភាពប្រឆាំងនឹងរាជរដ្ឋាភិបាល និងព្រះអង្គបន្តទៀត សំខាន់ពួកគាត់ចង់បានតែឯករាជ្យមួយពិតប្រាកដតែប៉ុណ្ណោះ។

ចំណែក សឺង ង៉ុកថាញ់, ឡឹក សំអឿន, កៅ តក់, ងួន ហុង និងកងកម្លាំងនៅភាគឧត្តរទិស(ខេត្តសៀមរាប)និងនៅភាគបស្ចិមទិស(ខេត្តបាត់ដំបង) មិនទាន់ចូលមករួមរស់នៅក្នុងសង្គមជាតិទេ គឺនៅរង់ចាំមើល ក្រែងមានហេតុការណ៍អ្វី អាចនឹងកើតមានឡើងក្នុងអំឡុងពេលមានការចរចាគ្នាជាលក្ខណៈអន្តរជាតិ ស្តីពីបញ្ហាឥណ្ឌូចិន នៅសន្និសីទក្រុងហ្សឺណែវ នោះសិន។

លុះដល់ខែកញ្ញា ឆ្នាំ១៩៥៤ បន្ទាប់ពីឮវិទ្យុប៊ីប៊ីស៊ី (BBC) របស់ប្រទេសអង់គ្លេសបានផ្សាយព័ត៌មាន ស្តីពីការប្រកាសសេចក្តីសម្រេចចិត្តរបស់សន្និសីទក្រុងហ្សឺណែវ នោះមក សឺង ង៉ុកថាញ់ យល់ឃើញថា ប្រទេសកម្ពុជា បានទទួលឯករាជ្យពិតប្រាកដហើយ គាត់ក៏បានរៀបចំធ្វើពិធីអបអរសាទរចំពោះលទ្ធផលនៃកិច្ចព្រមព្រៀងសន្និសីទក្រុងហ្សឺណែវនោះ ព្រមទាំងបានប្រមូលកងកម្លាំង នៅភាគឧត្តរទិស(ខេត្តសៀមរាប)និងនៅភាគបស្ចិមទិស(ខេត្តបាត់ដំបង) ឱ្យមកជួបជុំគ្នា នៅលើភ្នំដងរែក ដើម្បីត្រៀមខ្លួនទម្លាក់អាវុធ មកចូលរួមរស់ក្នុងសង្គមជាតិវិញ ដែលជាវគ្គទី២ ដូចការគ្រោងទុកនោះដែរ។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥៤ កងកម្លាំងតស៊ូរបស់ សឺង ង៉ុកថាញ់ ដែលត្រូវវិលមករួមរស់ក្នុងសង្គមជាតិវិញ ជាលើកទី២នោះ បានធ្វើដំណើរពីលើភ្នំដងរែក ឆ្ពោះទៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ ពេលនោះ សឺង ង៉ុកថាញ់ ក៏មានបំណងចង់សុំចូលគាល់ព្រះ-មហាក្សត្រសីហនុ ដើម្បីជួបពិភាក្សាគ្នាពីបញ្ហាប្រទេសជាតិផងដែរ តែសម្តេចសីហនុ មិនអនុញ្ញាតឱ្យចូលគាល់។ សឺង ង៉ុកថាញ់, ឡឹក សំអឿន និងងួន ហុង ក៏សម្រេចចិត្តវិលត្រលប់ទៅរស់នៅលើភ្នំដងរែក វិញ និងបានចាប់ផ្តើមកាប់គាស់ឈូសឆាយដីព្រៃនៅតំបន់អូរស្មោច់

ក្នុងស្រុកសំរោងចុងកាល់ ជាមួយយុទ្ធជនចំនួន៤៥ នាក់ទៀត ធ្វើស្រែចម្ការចិញ្ចឹមសត្វ និងធ្វើជំនួញជួញដូរចេញចូលប្រទេសថៃ ដើម្បីរង់ចាំឱកាសល្អ នឹងធ្វើការតស៊ូបន្តទៀត។

ចំណែកកៅ តក់ និងសហការីមួយចំនួន ក៏បានវិលត្រលប់ទៅរស់នៅក្នុងតំបន់ប្រាសាទតាមាន់ និងតំបន់គូ នៅជាប់បន្ទាយឆ្មារ ជាទីតាំងតស៊ូចាស់របស់គាត់វិញ ដោយនាំគ្នាធ្វើស្រែ និងចិញ្ចឹមសត្វ ផងដែរ។

ពេលនោះ ឡឹក សំអឿន យល់ឃើញថា សម្តេចសីហនុ មិនព្រមទទួលឲ្យសឺង ង៉ុកថាញ់ ចូលគាល់ព្រះអង្គ ដើម្បីពិភាក្សាពីបញ្ហានយោបាយប្រទេសជាតិជាមួយព្រះអង្គនោះ មានមូលហេតុសំខាន់៤ គឺ៖

ទី១. ព្រះអង្គមានការច្រណែននឹងសឺង ង៉ុកថាញ់ ដែលមានប្រជាប្រិយភាពខ្លាំង និងសមត្ថភាពខាងនយោបាយក្នុងការបម្រើប្រទេសជាតិ ខ្ពស់ជាងព្រះអង្គឆ្ងាយពេក។

ទី២. ព្រះអង្គខ្លាច សឺង ង៉ុកថាញ់ ដណ្តើមអំណាចបាន រំលាយរាជសម្បត្តិរបស់ព្រះអង្គចោល។

ទី៣. មន្ត្រីនៅជុំវិញព្រះអង្គ ភាគច្រើនជាមនុស្សពុករលួយ ពូកែតែខាងលុតក្រាបយកគាប់យកគួរ ពួកអែបអប ដើម្បីបុណ្យស័ក្តិ ពិសេសមានពួកញុះញង់ ផ្តុំត្រចៀកព្រះអង្គ កុំឱ្យយកសឺង ង៉ុកថាញ់ មកជួយកិច្ចការនយោបាយប្រទេសជាតិ ដូចសម័យឆ្នាំ១៩៤៥ បើមិនដូច្នេះទេ ពួកគេប្រាកដជាខូចខាតផលប្រយោជន៍ផ្ទាល់ខ្លួន ឬអាចនឹងរលាយបាត់បង់បុណ្យស័ក្តិផង ក៏អាចថាបាន។

ទី៤. ក្រុមស្រីស្រស់រូបឆើត (ប្រហែលចង់សំដៅទៅរកអ្នកម្នាងម៉ូនិក ក៏មិនដឹង?) មានឥទ្ធិពលខ្លាំងបំផុត ទៅលើសម្តេចសីហនុ អាចធ្វើឲ្យព្រះអង្គហ៊ានប្រឆាំងនឹងការណែនាំទូន្មានរបស់ព្រះរាជមាតាបិតារបស់ព្រះអង្គ ហើយមិនត្រឹមតែកិច្ចការសាមញ្ញ ក្នុងរាជវង្សប៉ុណ្ណោះទេ គឺរហូតដល់កិច្ចការជាអាយុជីវិតរបស់ប្រទេសជាតិទៀតផង ក៏ក្រុមស្រីស្រស់រូបឆើតនេះ អាចធ្វើបានដែរ។

ប៉ុន្តែអ្វីដែលក្រុមសឺង ង៉ុកថាញ់ ចោទប្រកាន់ថា សម្តេចសីហនុ មានការច្រណែន

និន្នានឹងសឹង ង៉ុកថាញ់ ដែលមានប្រជាប្រិយភាពខ្លាំង និងសមត្ថភាពខាងនយោបាយ ខ្ពស់ជាងព្រះអង្គឆ្ងាយ ទើបព្រះអង្គមិនឱ្យសឹង ង៉ុកថាញ់ ចូលរួមក្នុងបម្រើសង្គមជាតិវិញនោះ ហាក់ដូចជាពុំត្រឹមត្រូវទេ ព្រោះនរណាក៏ដឹងដែរថា តាំងពីឆ្នាំ១៩៤៩មក សម្តេចសីហនុ បានស្នើសុំបារាំង ឱ្យលើកលែងទោសសឹង ង៉ុកថាញ់ និងឱ្យបានវិលត្រលប់មកមាតុភូមិវិញ ជាច្រើនលើក ច្រើនសាមកហើយ។ នៅទីបំផុត សឹង ង៉ុកថាញ់ បានវិលត្រលប់មកដល់មាតុភូមិ ក្នុងខែតុលា ឆ្នាំ១៩៥១ ហើយព្រះមហាក្សត្រសីហនុ ក៏មានបំណងឱ្យសឹង ង៉ុកថាញ់ ចូលមកកាន់តំណែងជារដ្ឋមន្ត្រី នៅក្នុងក្រសួងណាមួយដែរ តែគាត់បានបដិសេធ។

ពិសេសទោះបី សឹង ង៉ុកថាញ់ រត់ចេញពីទីក្រុងភ្នំពេញ ក្នុងខែមីនា ឆ្នាំ៩៥២ ទៅបង្កើតចលនាតស៊ូ ដើម្បីប្រឆាំងព្រះអង្គ យ៉ាងណាក្តី ក៏នៅក្នុងខែមិថុនា ឆ្នាំ១៩៥៣ ពេលព្រះអង្គបំពេញព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង ជិតបានសម្រេចហើយនោះ ក៏ព្រះអង្គបានទាក់ទងតាមរយៈសម្តេចសង្ឃរាជហួត តាត ក្នុងបំណងចង់ឱ្យសឹង ង៉ុកថាញ់ វិលត្រលប់មកជួយដឹកនាំ និងកសាងប្រទេស ជាមួយព្រះអង្គ វិញដែរ តែសឹង ង៉ុកថាញ់ នៅតែមិនព្រម...។

ជាមួយគ្នានោះ ក្រុមប្រជាចលនាខ្មែរបម្រើជាតិរបស់សឹង ង៉ុកថាញ់ ក៏បានវាយប្រហារថា តាំងពីប្រទេសជាតិបានឯករាជ្យមក គេមិនដែលឃើញស្តេចសីហនុ ធ្វើនយោបាយបង្រួបបង្រួម ឱ្យមានសាមគ្គីជាតិម្តងណាទេ ផ្ទុយទៅវិញ ព្រះអង្គមានតែញុះញង់បំបែកបំបាក់ ធ្វើឱ្យមានការប្រេះឆានៅក្នុងសង្គមជាតិ ដើម្បីងាយស្រួលព្រះអង្គត្រួតត្រាជិះជាន់សង្កត់សង្កិនតែប៉ុណ្ណោះ។

ជាមួយគ្នានោះ ឡឹក សំអឿន បានលើកសរសើរថា សឹង ង៉ុកថាញ់ មានបំណងចង់ឃើញប្រជាជាតិខ្មែរ មានសាមគ្គីធម៌ជានិច្ច ព្រោះគាត់យល់ច្បាស់ថា មានតែសាមគ្គីធម៌នេះទេ ធ្វើឱ្យប្រជាជាតិខ្មែរយើងអាចរួបរួមគ្នាប្រឈមមុខតទល់នឹងគ្រោះមហន្តរាយ ដោយសារហូ ជីមិញ មេដឹកនាំពួកកុម្មុយនិស្តវៀតណាម មានគោលបំណងលេបយកទឹកដីខ្មែរ។ ឡឹក សំអឿន បានបន្តថា សឹង ង៉ុកថាញ់ បានព្យាយាមគ្រប់មធ្យោបាយក្នុងការស្វែងរកការរួបរួម

គ្នាជាមួយសម្តេចសីហនុ ដោយបានទាក់ទងតាមរយៈព្រះរាជមាតាបិតារបស់ព្រះអង្គ និង សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ផងដែរ ក៏នៅតែពុំបានសម្រេច។

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៥៤ នាយករដ្ឋមន្ត្រីឥណ្ឌា ហ្សាវី ហារឡាល់ នេរូហ៍ (Jawi harlal Nehru) បានធ្វើដំណើរមកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីផ្សព្វផ្សាយ គោលនយោបាយបញ្ចសិលា (ជាតិ សាសនា ភាតរភាព យុត្តិធម៌ និងប្រជាធិបតេយ្យ) និង លើកទឹកចិត្តឱ្យព្រះមហាក្សត្រ សីហនុ ប្រកាន់យកមាគ៌ាអព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ ធ្វើជាគោលនយោបាយសម្រាប់ដឹកនាំប្រទេស ផងដែរ។

ថ្ងៃទី២ វិច្ឆិកា នាយករដ្ឋមន្ត្រីឥណ្ឌារូបនេះ បានធ្វើដំណើរទៅទស្សនាប្រាង្គប្រាសាទ អង្គរ នៅខេត្តសៀមរាប។ នៅទីនេះ គាត់មានបំណងចង់ជួបពិភាក្សាជាមួយសឺង ង៉ុកថាញ់ កំពុងបន្តដឹកនាំចលនាតស៊ូនៅភ្នំដងរែក ដោយគាត់មានបំណងចង់ឱ្យសឺង ង៉ុកថាញ់ ធ្វើការ សម្របសម្រួលជាមួយព្រះមហាក្សត្រសីហនុ ដែរ តែត្រូវព្រះអង្គបដិសេធ ។

ចំណែក អៀ ស៊ីចូវ ដែលដឹកនាំកម្លាំងមួយចំនួនចូលទៅក្នុងទីក្រុងភ្នំពេញ តាំងពី ដើមឆ្នាំ១៩៥៤នោះ បានរៀបចំបង្កើតគណបក្សនយោបាយថ្មីមួយ ដើម្បីចូលរួមក្នុងការ បោះឆ្នោត ដោយសេរី និងយុត្តិធម៌ តាមកិច្ចព្រមព្រៀងសន្តិសីទក្រុងហ្សឺណែវ ដែរ តែក្រុម នគរបាលសម្ងាត់របស់សម្តេចសីហនុ ដឹងច្បាស់ថា នៅក្រុងភ្នំពេញ ពួកគាត់ធ្វើសកម្មភាព អ្វីៗនៅក្រោមបញ្ជារបស់សឺង ង៉ុកថាញ់ ដែលនៅភ្នំដងរែក នោះ គេក៏ដាក់ក្រុមគាត់ក្នុង បញ្ជីខ្មៅ គឺពុំឱ្យមានសិទ្ធិបង្កើតគណបក្សនយោបាយបានឡើយ។

ការពិត ពេលនោះចលនាតស៊ូប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ របស់សឺង ង៉ុកថាញ់ បានបំបែកគ្នាជា២ក្រុម គឺ មួយក្រុម ដឹកនាំដោយ អៀ ស៊ីចូវ ចូលមករួមរស់ក្នុងសង្គមជាតិ វិញ តាំងពីដើមឆ្នាំ១៩៥៤ មានរហស្សនាមថា ក្រុមដងរែកភ្នំពេញ និងក្រុមមួយទៀត មាន រហស្សនាមថា ក្រុមដងរែកជាយដែន ដឹកនាំដោយសឺង ង៉ុកថាញ់។ ដោយសារពុំមានសិទ្ធិ បង្កើតគណបក្សនយោបាយបាននោះ អៀ ស៊ីចូវ បានដឹកនាំក្រុមដងរែកភ្នំពេញ ទៅចូលរួម សហការជាមួយគណបក្សប្រជាធិបតេយ្យ ចំពេលគណបក្សដ៏ល្បីល្បាញនេះ កំពុងរៀបចំ

ក្បាលម៉ាស៊ីនដឹកនាំជាថ្មីឡើងវិញ។

ពេលនោះ គណបក្សប្រជាធិបតេយ្យ មានអតីតពួកបញ្ញវន្ត នៅក្នុងក្លឹបម៉ាក្សស៊ីស (Marxism) មួយចំនួន មកពីប្រទេសបារាំង ដូចជា កេង វ៉ាន់សាក់ និងជួន មុម្ម ជាដើម បានចូលរួមផងដែរ ព្រោះទាំងអស់គ្នាសុទ្ធតែមានគោលដំហរនយោបាយស្របគ្នា គឺជានាវ៉ាប់រងឯករាជ្យរបស់ប្រទេសកម្ពុជា ដោយមិនចាំបាច់ទទួលជំនួយអាមេរិក ។


ក្រុមដងវែកភ្នំពេញ ដឹកនាំដោយអៀ ស៊ីចូវ បានបង្កើតសារព័ត៌មានជាភាសាខ្មែរមួយ ឈ្មោះខ្មែរថ្មី និងបានទាក់ទងក្នុងចំណោមមជ្ឈដ្ឋានអ្នករាជការ ទាំងស៊ីវិល ទាំងប៉ូលិសទាហាន ព្រះសង្ឃ គ្រហស្ថ និងកសិករ រហូតដល់អ្នករាជការក្នុងព្រះបរមរាជវាំង។

ជាមួយគ្នានេះ អៀ ស៊ីចូវ បានរួមគ្នាបង្កើតអនុវិទ្យាល័យឯកជនមួយឲ្យឈ្មោះថា អនុ-វិទ្យាល័យកម្ពុជបុត្រ សម្រាប់ទាក់ទងប្រមូលកម្លាំងសិស្សានុសិស្ស ដើម្បីឱ្យគាំទ្រគណបក្សប្រជាធិបតេយ្យ ទៀតផង។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥៥ កៅ តក់ ជាក្រុមដងវែកនៅជាយដែន បានចេញមកឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រគណបក្សប្រជាធិបតេយ្យ នៅមណ្ឌលបោះឆ្នោតមួយក្នុងខេត្តសៀមរាប។ តែត្រូវដាប ឈួន មេបញ្ជាការកងខេមរភូមិន្ទ ប្រចាំខេត្តសៀមរាប ដែលតែងតែប្រើអំណាចដូចស្តេចត្រាញ់នោះ បានបញ្ជាឲ្យទាហាននៅក្រោមបញ្ជារបស់គាត់ទៅស្ទាក់បាញ់សម្លាប់ កៅ តក់ ខណៈកំពុងធ្វើដំណើរពីស្រុកក្រឡាញ់ ទៅកាន់ទីរួមខេត្តសៀមរាប គឺនៅត្រង់ចន្លោះទីប្រជុំជនសសរស្តម្ភ និងទីប្រជុំជនពួក។

នៅក្នុងខែកុម្ភៈ ដដែលនោះដែរ សារព័ត៌មានខ្មែរថ្មី របស់ក្រុមភ្នំដងវែកភ្នំពេញ របស់អៀ ស៊ីចូវ ត្រូវអាជ្ញាធរបិទទ្វារ និងចាប់ចាងហ្វាងយកទៅឃុំឃាំង។ នៅក្នុងខែមីនា ឆ្នាំ១៩៥៥ ក្រុមភ្នំដងវែកភ្នំពេញ ក៏បានបង្កើតសារព័ត៌មានមួយទៀត ឈ្មោះទៅមុខ ប៉ុន្តែត្រូវអាជ្ញាធរបិទទ្វារ នៅក្នុងខែមិថុនា ឆ្នាំដដែលនោះ ហើយចាងហ្វាង ក៏ត្រូវអាជ្ញាធរចាប់ដាក់គុកទៀត។

៧៩
ព្រះមហាក្សត្រសីហនុ យាងទៅបំពេញព្រះរាជទស្សនកិច្ច នៅប្រទេសថៃ និងភូមា ឆ្នាំ១៩៥៤



ព្រះមហាក្សត្រថៃ ភូមិពល អតុល្យតេជ និងព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ

ក្រោយពីទាមទារឯករាជ្យជូនមាតុភូមិកម្ពុជា ដោយជោគជ័យមក ព្រះមហាក្សត្រ សីហនុ ត្រូវបានថ្នាក់ដឹកនាំបណ្តាប្រទេសនានា នៅលើពិភពលោក ផ្ញើលិខិតមកថ្វាយ សុំ យាងព្រះអង្គទៅបំពេញព្រះរាជទស្សនកិច្ច ជាបន្តបន្ទាប់ ដើម្បីផ្សារទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការ ដោយស្មើភាពគ្នា។

ក្នុងឆ្នាំ១៩៥៤ ពេលព្រះអង្គយាងទៅបំពេញព្រះរាជទស្សនកិច្ចជាផ្លូវការនៅប្រទេស ថៃ រាជរដ្ឋាភិបាលប្រទេសមួយនេះ បានទទួលស្វាគមន៍ព្រះអង្គយ៉ាងអធិកអធម និងបាន រៀបចំធ្វើពិធីប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយសមួយថ្វាយព្រះអង្គ នៅសាកលវិទ្យាល័យ នៅ ក្រុងបាងកក ដើម្បីសម្តែងការកោតសរសើរ ចំពោះព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពី បារាំង ដោយជោគជ័យរបស់ព្រះអង្គ កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នោះ ទៀតផង។

ផ្ទុយស្រឡះ កាលពីមុននេះមួយឆ្នាំ ពេលព្រះអង្គយាងទៅទីក្រុងបាងកក ដើម្បីយោសនាទាក់ទាញសហគមន៍អន្តរជាតិ ឱ្យចាប់អារម្មណ៍ពីព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង រាជរដ្ឋាភិបាលប្រទេសមួយនេះ មិនត្រឹមតែហាមព្រះអង្គមិនឱ្យធ្វើនយោបាយ នៅក្នុងប្រទេសរបស់ខ្លួនប៉ុណ្ណោះទេ គឺថែមទាំងបានចាត់ទុកព្រះអង្គ ជាជននិរទេស ទៀតផង។

ក្នុងពេលបំពេញព្រះរាជទស្សនកិច្ចនោះដែរ ព្រះអង្គក៏មានកម្មវិធីយាងទៅទស្សនាទីក្រុងឈៀងម៉ៃ ផងដែរ តែមិនទាន់បានយាងទៅផង ស្រាប់តែមានការសែតក្រុងបាងកក ចុះផ្សាយថា ព្រះមហាក្សត្រខ្មែរ យាងមកប្រទេសថៃ នាពេលនេះ គឺគ្មានបំណងអ្វី ក្រៅតែពីរកបវរកញ្ញាម្នាក់ នៅទីក្រុងឈៀងម៉ៃ ដើម្បីដាក់បញ្ចូលទៅក្នុងបញ្ជីស្នេហារបស់ព្រះអង្គតែប៉ុណ្ណោះ ពោលគឺព្រះអង្គមិនមែនចង់ទៅទស្សនាសោភណភាពទីក្រុងឈៀងម៉ៃ ដ៏ស្រស់បំព្រងនោះទេ។

ដោយសារការសែតក្រុងបាងកក ចុះផ្សាយខុសស្រឡះពីព្រះទ័យពិតដូច្នេះ ព្រះអង្គក៏សម្រេចព្រះទ័យលុបចោលកម្មវិធីយាងទៅបំពេញទស្សនកិច្ច នៅទីក្រុងឈៀងម៉ៃ នោះវិញ។

ប៉ុន្តែយ៉ាងណាក៏ព្រះអង្គមានព្រះរាជកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតដោយព្រះមហាក្សត្រថៃ ភូមិពល អតុល្យតេជ បានយាងព្រះអង្គឱ្យចូលគាល់ នៅក្នុងព្រះបរមរាជវាំង និងរៀបចំព្រះរាជពិធីប្រគំតន្ត្រីមួយ ដោយមានព្រះអង្គជាអ្នកផ្គុំសាក់សូហ្វូនអាល់តូ ឯព្រះមហាក្សត្រថៃ ជាអ្នកផ្គុំសាក់សូហ្វូនក្លារីណេត ហើយព្រះអង្គក៏បានច្រៀងចម្រៀងមួយបទថ្វាយដល់ព្រះជាយាព្រះមហាក្សត្រថៃ ផងដែរ។

ព្រះមហាក្សត្រថៃ ភូមិពល អតុល្យតេជ សប្បាយព្រះទ័យ ក្នុងការប្រគំតន្ត្រីជាមួយព្រះមហាក្សត្រ សីហនុ រហូតដល់ម៉ោង៥ភ្លឺ ទើបបញ្ចប់។

ពេលនោះដែរ នាយករដ្ឋមន្ត្រីថៃសេនាប្រមុខ ផ្លែក ភិបូនសុង្គ្រាម (Plaek Phibunsongkhram) ក៏បានសម្តែងកាយវិការគោរពព្រះមហាក្សត្រកម្ពុជា មើលទៅគួរឱ្យស្រលាញ់រាប់អានបំផុត។ កាយវិការនេះ គឺផ្ទុយស្រឡះ កាលពីព្រះមហាក្សត្រសីហនុ យាងទៅក្រុង

បាងកក ដើម្បីឃោសនាទាក់ទាញសហគមន៍អន្តរជាតិ ឱ្យចាប់អារម្មណ៍ពីព្រះរាជបូជនីយ-កិច្ចទាមទារឯករាជ្យពីបារាំង កាលពីមុនពេលទទួលបានឯករាជ្យ នាយករដ្ឋមន្ត្រីថៃរូបនេះ បានសម្តែងនូវឫកពាក្រអឺតក្រទម ដោយផ្តាំផ្ញើមកព្រះអង្គថា ប្រសិនបើព្រះអង្គមានសំណូមពរ អ្វីចំពោះគេ ព្រះអង្គអាចយាងទៅជួបរូបគេផ្ទាល់ នៅខុទ្ទកាល័យរបស់គេ។ បន្ទាប់មក នៅក្នុងរាត្រីសមោសរ រៀបចំថ្វាយជា កិត្តិយសដល់ព្រះអង្គ មានឈុតរបាំមួយសម្តែងដោយ សិល្បករ សិល្បការិនីថៃ មើលទៅឃើញកាយវិការរាំនោះ ដូចអ្នកប្រដាល់មួយក្រុមបញ្ចេញ ក្បាច់គុននៅជុំគ្នានោះ ពួកគេបែរជាប្រកាសថា នេះជារបាំព្រះរាជទ្រព្យខ្មែរ ។ តែឆាកឈុតក្រោយៗ មកទៀត គឺជារបាំព្រះរាជទ្រព្យ មានលក្ខណៈដូចរបាំព្រះរាជទ្រព្យខ្មែរសុទ្ធសាធ នោះ ស្រាប់តែគេបែរជាប្រកាស ថា នេះជារបាំព្រះរាជ្យទ្រព្យថៃ ទៅវិញ។

បន្ទាប់មកទៀត ព្រះអង្គបានយាងទៅបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសភូមា ដើម្បីតែចំណងមិត្តភាពជាមួយមេដឹកនាំ អ៊ូ នូ ពេលនោះកំពុងកាន់តំណែងជានាយក រដ្ឋមន្ត្រី។

នៅទីក្រុងរ៉ង់ហ្គូន រាជរដ្ឋាភិបាលប្រទេសភូមា បានទទួលស្វាគមន៍ព្រះអង្គយ៉ាង អធិកអធម និងបានរៀបចំធ្វើពិធីប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយសមួយ ថ្វាយព្រះអង្គ ដើម្បីសម្តែងនូវការគោរព និងកោតសរសើរចំពោះព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពី បារាំង របស់ព្រះអង្គ ដូចនៅទីក្រុងបាងកក ប្រទេសថៃ ដែរ។

នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៤៨ ប្រទេសភូមា បានប្រកាសឯករាជ្យភាពរបស់ខ្លួន ពី ប្រទេសអង់គ្លេស បង្កើតជាសហភាពភូមា។ ពេលនោះ អ៊ូ នូ បានក្លាយជានាយករដ្ឋមន្ត្រីនៃ សហភាពភូមា ទី១ ចាប់ពីថ្ងៃទី៤ ខែមករា ឆ្នាំ១៩៤៨ ដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ១៩៥៦ ហើយគាត់បានក្លាយជានាយករដ្ឋមន្ត្រីនៃសហភាពភូមា បន្តទៀត ចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៥៧ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៥៨ និងចុងក្រោយ ចាប់ពីថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៦០ ។

លុះដល់ ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៦២ នាយករដ្ឋមន្ត្រីអ៊ូ នូ ត្រូវឧត្តមសេនីយ៍ ណេ វិន



នាយករដ្ឋមន្ត្រីភូមា អ៊ូ នូ និង អគ្គលេខាអង្គការសហប្រជាជាតិ អ៊ូ ថាន់ ចូលជួបប្រធានាធិបតីអាមេរិក អាយសិនហាវើរ

ធ្វើរដ្ឋប្រហារដណ្តើមយកអំណាច និងចាប់ខ្លួនគាត់យកទៅឃុំទុកក្នុងបន្ទាយកងទ័ពមួយ នៅក្រៅទីក្រុងរ៉ង់ហ្គូន អស់រយៈពេលប្រមាណ៤ឆ្នាំ ពោលគឺ រហូតដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៦៦ ទើបដោះលែងគាត់ពីការឃុំឃាំងវិញ ។

បន្ទាប់ពីបានរួចពីការឃុំឃាំង អតីតនាយករដ្ឋមន្ត្រីអ៊ូ នូ ក៏បានធ្វើដំណើរមករាជធានីភ្នំពេញ ចូលគាល់ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ដើម្បីសម្តែងសក្ខីភាពចំពោះមិត្តភាពរបស់គាត់ដ៏ស្មោះត្រង់ចំពោះព្រះអង្គ ផងដែរ។

អតីតនាយករដ្ឋមន្ត្រីភូមា រូបនេះ ជាអ្នកកាន់ព្រះពុទ្ធសាសនាដ៏ខ្ជាប់ខ្ជួន និងជឿជាក់បំផុត។ នៅពេលឧត្តមសេនីយ៍ ណេ វិន ចាប់គាត់យកទៅឃុំឃាំងនោះ គេបានសួរគាត់ថា តើគាត់ចង់បានអ្វី? គាត់ប្រាប់គេវិញថា គាត់គ្មានត្រូវការអ្វី ក្រៅពីធូប និងទៀន ដើម្បីទុកឱ្យថ្វាយបង្គំព្រះពុទ្ធ ជាទីសក្ការៈរបស់គាត់នោះទេ។

អ៊ូ នូ កើតនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩០៧ និងទទួលមរណភាពទៅវិញ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៥ ក្នុងជន្មាយុ ៨៨ឆ្នាំ។

ពេលយាងទៅបំពេញព្រះរាជទស្សនកិច្ច នៅទីក្រុងបាងកក និងទីក្រុងវ៉ង់ហ្គូន នោះដែរ ព្រះមហាក្សត្រសីហនុ មានការភ្ញាក់ផ្អើលក្នុងព្រះទ័យថា នៅរាជធានីភ្នំពេញ ព្រះអង្គហាក់ដូចជាសាំទៅហើយ ចំពោះការដៀលត្មះ និងរិះគន់ពីសំណាក់សិស្ស និងនិស្សិតភាគច្រើនដើរតាមពួកអ្នកនយោបាយប្រឆាំងនឹងព្រអង្គ។ ប៉ុន្តែ ពេលយាងទៅទីក្រុងបាងកក និងទីក្រុងវ៉ង់ហ្គូន ព្រះអង្គមានការសប្បាយរីករាយក្នុងព្រះទ័យយ៉ាងខ្លាំង ព្រោះឃើញសិស្ស និស្សិតរបស់ថៃ និងឡាវ នាំគ្នាមកទទួលស្វាគមន៍ព្រះអង្គយ៉ាងច្រើនកុះករ និងកក់ក្តៅបំផុត។

ផ០
សម សារី បង្កឱ្យរាំងស្ទះដល់កិច្ចប្រជុំ សន្និសីទចតុកាគី ស្តីពីបញ្ហារបិយវត្ថុនៅឥណ្ឌូចិន



សម សារី និងសឺន សាន (រូបភ្ជុចរង្វង់)

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៥៤ ព្រះមហាក្សត្រសីហនុ បានតែងតាំង ចាន់ ណាក ជាអតីតនាយករដ្ឋមន្ត្រី កាលពីខែវិច្ឆិកា ឆ្នាំ១៩៥៣ ដល់ខែមេសា ឆ្នាំ១៩៥៤ ឱ្យដឹកនាំ គណៈប្រតិភូមួយក្រុម ក្នុងនោះមាន សម សារី និងសឺន សាន ផងដែរ ទៅចូលរួមក្នុង សន្និសីទចតុកាគី បារាំង កម្ពុជា វៀតណាមខាងត្បូង ឡាវ នៅទីក្រុងប៉ារីស ដើម្បីដោះ-ស្រាយបញ្ហារបិយវត្ថុ នៅឥណ្ឌូចិន ក្រោយពីប្រទេសបារាំង ប្រគល់ឯករាជ្យឱ្យមកវិញ ។

ពេលនោះ សម សារី មានតួនាទីជាលេខាធិការរបស់គណៈប្រតិភូកម្ពុជា បានប្រើ ពាក្យសម្តីមិនគួរគប្បី ទៅលើគណៈប្រតិភូប្រទេសផ្សេងៗទៀត ធ្វើឱ្យសន្និសីទនោះត្រូវ ផ្អាកទៅវិញ។

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៥៤ ព្រះមហាក្សត្រសីហនុ ក៏បានយាងទៅបំពេញព្រះរាជទស្សនកិច្ច នៅក្រុងប៉ារីសដែរ។ ក្រោយពីបានដឹងរឿងនេះ ព្រះអង្គបានគ្រាស់បង្គាប់ឱ្យ ចាន់ ណាក ជាប្រធានគណៈប្រតិភូ រកវិធីយ៉ាងណា ដើម្បីឱ្យសន្និសីទចតុកាគី ស្តីពីបញ្ហារបៀយវត្តុនៅឥណ្ឌូចិន ជាប់គាំងដោយសារសម សារី ប្រើពាក្យសម្តីមិនគួរគប្បីទៅលើគណៈប្រតិភូប្រទេសផ្សេងទៀត ជាច្រើនខែមកហើយនោះ បានបើកដំណើរការប្រជុំឡើងវិញ ឱ្យបានឆាប់រហ័សបំផុត ។

១៦ថ្ងៃក្រោយមក គឺនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៥៤ សន្និសីទចតុកាគី ស្តីពីបញ្ហារបៀយវត្តុនៅឥណ្ឌូចិន នៅក្រុងប៉ារីស នោះ បានចាប់ផ្តើមដំណើរការឡើងវិញ។

ពេលនោះដែរ នាយករដ្ឋមន្ត្រី ប៉ែន នុត បានផ្ញើសារទូរលេខមួយច្បាប់ ពីទីក្រុងភ្នំពេញ ទៅប្រាប់សឺន សាន ជាសមាជិកគណៈប្រតិភូ កំពុងស្ថិតនៅក្នុងក្រុងប៉ារីស នោះ ឱ្យបានដឹងថា ព្រះមហាក្សត្រសីហនុ សព្វព្រះទ័យតែងតាំងគាត់(សឺន សាន) ជាអគ្គទេសាភិបាលធនាគារជាតិកម្ពុជា ដែលត្រូវបង្កើតឡើង នៅពេលខាងមុខនេះហើយ។

មុននេះ សម សារី មានតួនាទីជាលេខាធិការគណៈប្រតិភូខ្មែរ ទៅចូលរួមសន្និសីទនៅក្រុងប៉ារីសនោះ សង្ឃឹមថា គាត់នឹងត្រូវទទួលការតែងតាំងជាអគ្គទេសាភិបាលធនាគារជាតិកម្ពុជា នោះ។ ប៉ុន្តែមិនដឹងមូលហេតុអ្វី ស្រាប់តែព្រះមហាក្សត្រសីហនុ បែរជាផ្លាស់ប្តូរព្រះទ័យតែងតាំង សឺន សាន ទៅវិញ។

មតិខ្លះយល់ថា មូលហេតុដែលព្រះមហាក្សត្រសីហនុ ប្តូរព្រះទ័យតែងតាំង សឺន សាន ជាអគ្គទេសាភិបាលធនាគារជាតិកម្ពុជា វិញដូច្នេះ ដោយសារ សម សារី ធ្វើឱ្យសន្និសីទនោះ ត្រូវស្ទះដំណើរការប្រជុំ តាំងពីដំបូងទីមក។

នៅថ្ងៃទី២៩ខែធ្នូ ឆ្នាំ១៩៥៤ សន្និសីទចតុកាគីនោះ បានឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពីរ គឺ៖

ទី១. ស្តាប័នបោះពុម្ពប្រាក់ នៅឥណ្ឌូចិន ត្រូវបញ្ចប់សកម្មភាពជាស្ថាពរ ហើយចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥ តទៅ ប្រទេសកម្ពុជា វៀតណាមខាងត្បូង និងឡាវ ជាអ្នក

កំណត់របបរូបិយវត្ថុ តាមប្រទេសរៀងៗខ្លួន។

ទី២. លុបចោលការិយាល័យប្តូរប្រាក់ នៅឥណ្ឌូចិន ហើយត្រូវផ្ទេរការិយាល័យប្តូរប្រាក់នេះ ទៅឱ្យប្រទេសទាំង៣ គឺកម្ពុជា វៀតណាមខាងត្បូង និងឡាវ វិញដែរ។

ក្រោយមក អេង ហ៊ិន ពេលនោះមានតួនាទីជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម ក៏ត្រូវបានតែងតាំងជានាយកការិយាល័យជាតិប្តូរប្រាក់ មុនគេបង្អស់នៅប្រទេសកម្ពុជា ។

ជាមួយគ្នានោះ សន្និសីទចតុភាគីនេះ ក៏បានសម្រេច លែងឱ្យមានរតនាគារ និងហឹបប្រាក់ស្វយ័ត នៅឥណ្ឌូចិន តទៅទៀត ហើយប្រាក់ដែលមាននៅក្នុងរតនាគារ និងហឹបប្រាក់ស្វយ័តនោះទាំងប៉ុន្មាន ត្រូវបែងចែកទៅឱ្យប្រទេសកម្ពុជា វៀតណាម និងឡាវទាំងអស់។

នៅថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៥៥ សម សារី រួមទាំង ប៉ែន នុត និងឃឹម ទិត ផងដែរ ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សារាជបល្ល័ង្ក។ ដោយឡែក សម សារី ក៏មានតួនាទីជាអ្នកនិពន្ធព្រះរាជដីវប្រវត្តិរបស់សម្តេចសីហនុ ផងដែរ។

៨១
កែវ មាស, នង សួន, និងប៉ែន យុទ្ធ បង្កើតគណបក្សប្រជាជន



កែវ មាស

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៥៤ អតីតខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ រាប់សិបនាក់នៅខេត្តព្រៃវែង ត្រូវអាជ្ញាធរចាប់យកទៅសួរចម្លើយ ពីរឿងលាក់អាវុធទុក ដើម្បីធ្វើសកម្មភាពបដិវត្តបន្តទៀត ហើយភាគច្រើនអ្នកត្រូវចាប់ខ្លួននោះ មានខ្លះត្រូវគេយកទៅសម្លាប់ចោលដោយស្ងាត់ៗទៀតផង។

ចំណែកនៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ អតីតខ្មែរឥស្សរៈ៣៦នាក់ ក៏ត្រូវអាជ្ញាធរចាប់ដាក់គុក ពីបទបង្កើតសមាគមមួយ ដើម្បីធ្វើសកម្មភាពប្រឆាំងនឹងព្រះមហាក្សត្រសីហនុ និងដើរបំផុសបំផុលដំណឹងមិនពិត។

ព្រះមហាក្សត្រ សីហនុ បដិសេធ មិនធ្វើការសម្របសម្រួលដាច់ខាត ជាមួយពួកអតីតមេដឹកនាំខ្មែរឥស្សរៈណាទាំងអស់ គឺមានតែការបង្ក្រាបប៉ុណ្ណោះ។

ពេលនោះដែរ មេដឹកនាំខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ បានបង្កើតគណៈកម្មការ

មួយសម្រាប់អនុវត្តកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ហៅថា គណៈកម្មការខ្មែរឥស្សរៈ ដោយមានង្វៀន ថាញ់សឺន អតីតមេដឹកនាំបក្សកុម្មុយនិស្តឥណ្ឌូចិន ប្រចាំវៀតណាមខាងត្បូង កាលពីចុងទសវត្សឆ្នាំ១៩៤០ ក្រោយមក បានដូរឈ្មោះមកជា សឺន ស៊ីចាន់ ជាប្រធាន, នង សួន, កែវ មាស, សុខ សាផាយ, រស់ សម័យ, ណុប បូផាន់, ប៉ែន យុទ្ធ, ជូ ជេត និងនិស្សិតទើបមកពីប្រទេសបារាំង ២នាក់ទៀត គឺ សៀន អាន និងជឺ គីមអាន ជាសមាជិក។

តែដោយសារគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) មិនទទួលស្គាល់ជាផ្លូវការ គណៈកម្មការនេះ ត្រូវគេបញ្ជូលឱ្យទៅនៅជាមួយគណៈកម្មការរបស់ពួកវៀតមិញ ស្ថិតនៅក្រោមការការពាររបស់គណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) មានតួនាទីជាអ្នកឃ្លាំមើល និងធ្វើការសម្របសម្រួលក្នុងការដកកងទ័ពបារាំង និងកងទ័ពវៀតមិញ ចេញពីប្រទេសកម្ពុជា តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នោះវិញ។

ប៉ុន្តែ ទោះបីជាគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) មានវត្តមាននៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ពួកមេដឹកនាំខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ នៅតែមានការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់ពួកគេដែរ ព្រោះកាលពីខែតុលា សឺង ង៉ុកមិញ ជាមេដឹកនាំកំពូលរបស់ពួកគេ បានផ្ញើសារទូរលេខមួយមកឱ្យ សឺន ស៊ីចាន់ និងអ្នកតស៊ូខ្មែរឥស្សរៈទាំងអស់ឱ្យដកខ្លួនទៅវៀតណាមខាងជើង បើពុំដូច្នេះទេ សត្រូវជាអាជ្ញាធរ នៅក្នុងប្រទេស ពិសេសគឺស្តេចសីហនុ នឹងកម្ទេចពួកគេចោលអស់ជាមិនខាន។

ឆ្លើយតបនឹងសារទូរលេខនេះ កែវ មាស និងនង សួន បានបញ្ជាក់ប្រាប់ សឺន ស៊ីចាន់ ថា ពួកគាត់មិនព្រមចាកចេញទៅវៀតណាមភាគជើង តាមបញ្ជារបស់សឺង ង៉ុកមិញ នោះទេ គឺពួកគាត់ត្រូវរស់នៅក្នុងប្រទេស ដើម្បីធ្វើការតស៊ូខាងនយោបាយបន្តទៅទៀត។

ជាមួយគ្នានោះ នង សួន បានផ្ញើសារទូរលេខមួយ តបមក សឺង ង៉ុកមិញ វិញថា ពួកគាត់មិនទៅណាទេ គឺត្រូវរស់នៅក្នុងប្រទេស ដើម្បីតស៊ូខាងនយោបាយបន្តទៅទៀត ហើយសឺង ង៉ុកមិញ ក៏មិនបង្ខំគាត់ដែរ។

ក្រោយមក នង សួន និងប៉ែន យុទ្ធ បានចូលមករស់នៅក្នុងទីក្រុងភ្នំពេញ ជា

លក្ខណៈលួចលាក់។ នង សួន មិនសូវហ៊ានដើរចេញទៅណាឆ្ងាយទេ ព្រោះគាត់គ្មានអត្តសញ្ញាណប័ណ្ណ ហើយគាត់ក៏មិនហ៊ានចេញទៅកេការងារធ្វើដែរ។

ប៉ុន្តែមិនយូរប៉ុន្មាន កែវ មាស មានតួនាទីជាសមាជិកគណៈកម្មការរបស់ពួកវៀតមិញ ស្ថិតនៅក្រោមការការពាររបស់គណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC)នោះ រកវិធីជួយធ្វើអត្ត-សញ្ញាណប័ណ្ណឱ្យ នង សួន បានកាន់ដូចប្រជាជនខ្មែរទូទៅដែរ ហើយគាត់បានចូលធ្វើការនៅក្នុងអាកាសយានដ្ឋានពោធិ៍ចិនតុង បានរយៈពេលមួយខែ គាត់ក៏សុំលាឈប់វិញ ព្រោះខ្លាចមានហេតុការណ៍អាក្រក់ណាមួយ កើតឡើងនៅទីនោះ គេចោទថា គាត់ជាអ្នកបង្ក។ ឯ ប៉ែន យុទ្ធ ក៏បានចូលបម្រើការងារជាគ្រូបង្រៀន នៅអនុវិទ្យាល័យឯកជនកម្ពុជបុត្រ។

ចំណែក កងទ័ពខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ ជាង១០០០នាក់ ត្រូវធ្វើដំណើរចាកចេញទៅវៀតណាមភាគខាងជើងនោះ ក៏មានមេដឹកនាំសំខាន់ៗមួយចំនួនដែរ ដូចជា សោ ភឹម, នៃ សារ៉ាន់, ព្រំ សាមិត្ត, លាវ កែវមុនី, សុះ ម៉ាន, ហុង ឈុន, ញ៉ែម ស៊ុន (មេបញ្ជាការផ្នែលរបស់ប៉ែន សុវណ្ណ), ជា កែវ, ចាន់ សម័យ ព្រមទាំងនិស្សិតទើបបញ្ចប់ការសិក្សានៅប្រទេសបារាំង ចំនួន៤នាក់ទៀត គឺយន់ សឿន, ហេង ណារិន, វ័ន្ត សមឿន និងហែម ផន។

ពេលនោះ សឺង ង៉ុកមិញ ជាមេដឹកនាំកំពូល កំពុងស្ថិតនៅទីក្រុងហាណូយស្រាប់។ ចំណែកមុី ផ្ង និងកែវ មុនី បានធ្វើដំណើរជាមួយ ផាំ វ៉ាន់ដុង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស ទៅរួមប្រជុំនៅក្រុងហ្សឺណែវ នោះ ក៏បានត្រលប់មកក្រុងហាណូយ វិញ ជាមួយគណៈប្រតិភូវៀតមិញ ហើយពួកគាត់ក៏បានស្នាក់នៅទីនោះ តែម្តងទៅ។

ស៊ីវ ហេង ជាមេដឹកនាំគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរ និងជារដ្ឋមន្ត្រីការពារជាតិ រដ្ឋាភិបាលខ្មែរឥស្សរៈ ក៏បានជិះយន្តហោះរបស់គណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) ជាមួយមេដឹកនាំវៀតមិញ នៅក្នុងប្រទេសកម្ពុជា ចេញទៅទីក្រុងហាណូយដែរ។

ប៉ុន្តែ មិនយូរប៉ុន្មាន ស៊ីវ ហេង, សោ ភឹម និងនៃ សារ៉ាន់ បានសម្រេចចិត្តវិលត្រលប់មកមាតុប្រទេសវិញ ដើម្បីមករួមគ្នាជាមួយទូ សាមុត ធ្វើការតស៊ូនយោបាយបន្តទៀត។

ពេលនោះដែរ នួន ជា ត្រូវគេបញ្ជូនទៅរៀនផ្នែកមនោគមន៍វិជ្ជានយោបាយ នៅវៀតណាមខាងជើង រយៈពេលប្រហែលមួយឆ្នាំមកហើយនោះ ក៏បានវិលត្រលប់មកមាតុ-ប្រទេសវិញដែរ។

ដើមឆ្នាំ១៩៥៥ នង សួន, កែវ មាស និងប៉ែន យុទ្ធ បានជម្នះគ្រប់ឧបសគ្គ បង្កើតគណបក្សមួយឈ្មោះគណបក្សខ្មែរតស៊ូ ដើម្បីចូលរួមការបោះឆ្នោតជាសាកល តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ។ ប៉ុន្តែ រាជរដ្ឋាភិបាលរបស់ព្រះមហាក្សត្រសីហនុ បានរារាំងមិនព្រមចុះឈ្មោះគណបក្សខ្មែរតស៊ូ ទៅក្នុងបញ្ជីបេក្ខភាពឡើយ។ ពេលនោះ កែវ មាស បានដាក់ពាក្យបណ្តឹងទៅគណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) ឱ្យជួយដោះស្រាយពីបញ្ហានេះដែរ តែមិនបានលទ្ធផលអ្វីឡើយ។

រាជរដ្ឋាភិបាលរបស់សម្តេចសីហនុ ទាមទារឱ្យ កែវ មាស ដូរឈ្មោះរបស់គណបក្សខ្មែរតស៊ូ នោះចេញ ព្រោះថា ពេលនេះ ប្រទេសកម្ពុជា បានឯករាជ្យហើយ មិនត្រូវយកពាក្យថា ខ្មែរតស៊ូ មកដាក់ឈ្មោះគណបក្សរបស់ខ្លួនដូច្នេះទេ។

នៅទីបំផុត ដើម្បីបានចុះឈ្មោះជាបេក្ខភាពនៅក្នុងបញ្ជីបោះឆ្នោត កែវ មាស, នង សួន និងប៉ែន យុទ្ធ ក៏បានសម្រេចដូរឈ្មោះគណបក្សខ្មែរតស៊ូ មកជាគណបក្សប្រជាជនមានរូបនង្គ័ល ជានិមិ្មតសញ្ញាវិញ។

ដោយឡែក ស៊ីវ ហេង, ទូ សាមុត, នួន ជា, សោ ភឹម, និងនៃ សារ៉ាន់ បានរួមគ្នាបង្កើតចលនាតស៊ូសម្ងាត់មួយផ្សេងទៀត ក្រោមការដឹកនាំរបស់គណៈកម្មាធិការមជ្ឈិមបណ្តោះអាសន្នមួយ មាន ស៊ីវ ហេង ជាប្រធាន និងបានបង្កើតគណៈកម្មាធិការតស៊ូ ចំនួន១៨ទៀត ក្នុងនោះ មានគណៈកម្មាធិការតស៊ូនៅតំបន់ជនបទ តាមខេត្តនានា ចំនួន១៧ខេត្ត ដឹកនាំដោយ ទូ សាមុត និងគណៈកម្មាធិការតស៊ូមួយទៀត ប្រចាំនៅក្នុងទីក្រុងភ្នំពេញ ដឹកនាំដោយ ស៊ីវ ហេង ផ្ទាល់។

៨២
កេង វ៉ាន់សាក់ និងជួន មុម្ម ក្លាយជាមនុស្សសំខាន់ របស់គណបក្សប្រជាធិបតេយ្យ



កេង វ៉ាន់សាក់ និងរៀង សារី កាលរៀននៅប្រទេសបារាំង

នៅក្នុងឆ្នាំ១៩៥០ ជួន មុម្ម កំពុងសិក្សានៅសាលាពហុបច្ចេកទេស នៅប្រទេសបារាំង បានចូលសម្រាកព្យាបាលជំងឺសួត ជាជំងឺប្រចាំកាយរបស់គាត់ នៅក្នុងមន្ទីរពេទ្យមួយ ស្ថិតនៅលើភ្នំកុមប្លីក (Combloux) ក្នុងប្រទេសបារាំង ក្បែរព្រំដែនប្រទេសស្វីស និងអ៊ីតាលី។ ដូច្នេះហើយ បានជានៅពេលសមាគមនិស្សិតខ្មែរ (AEK) ដែលគាត់ជាអ្នកផ្តួចផ្តើមគំនិតបង្កើតឡើង តាំងពីឆ្នាំ១៩៤៦មក ប្រជុំបោះឆ្នោតជ្រើសតាំងមេដឹកនាំថ្មីរបស់សមាគម នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៥០ ហើយ វ័ណ្ណ មោលីវ័ណ្ណ បានជាប់ឆ្នោតជាប្រធាន និងកេង វ៉ាន់សាក់ បានជាប់ឆ្នោតជាអនុប្រធាន គឺពេលនោះ គាត់មិនបានចូលរួមទេ។

នៅពាក់កណ្តាលឆ្នាំ១៩៥៣ ជួន មុម្ម បានចូលសម្រាកព្យាបាលជំងឺប្រចាំកាយរបស់គាត់ជាលើកទី២ នៅក្នុងមន្ទីរពេទ្យនៅលើភ្នំកុមប្លីក (Combloux)នោះ អស់រយៈពេល

ប្រហែលមួយឆ្នាំទៀត។

ក្រោយពីបានជាសះស្បើយ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៥៤ ជួន មុម្ម បានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីជនជាតិបារាំង ឈ្មោះម៉ូនិក ជាវេជ្ជបណ្ឌិតឯកទេសជំងឺកុមារនៅទីនោះ។ នៅពេលរៀបអាពាហ៍ពិពាហ៍នោះ ម្តាយបង្កើតរបស់គាត់ ឈ្មោះប៊ុណ្ណា ចន្ទម៉ូលី និងម្តាយមីងរបស់គាត់ ឈ្មោះប៊ុង៉ា ក៏បានទៅចូលរួមដែរ។

ក្រោយពេលរៀបអាពាហ៍ពិពាហ៍បានប្រហែល១ខែ ជួន មុម្ម ក៏បានជូនដំណើរម្តាយបង្កើត និងម្តាយមីង ទៅចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់នោះ រីឯត្រលប់មកប្រទេសខ្មែរវិញ និងមានបំណងរកការងារធ្វើ នៅស្រុកខ្មែរ ផងដែរ។ តែប្រពន្ធគាត់ ម៉ូនិក កំពុងចាប់ផ្តើមមានផ្ទៃពោះ មិនបានមកជាមួយទេ។

គាប់ជួនពេលគាត់មកស្នាក់នៅជាមួយម្តាយ នៅក្នុងទីក្រុងភ្នំពេញ នោះ សន្និសីទក្រុងហ្សឺណែវ តម្រូវឱ្យមានការបោះឆ្នោត នៅខែមេសា ឆ្នាំ១៩៥៥ ខាងមុខ គាត់ក៏បានសម្រេចចិត្តចូលប្រឡូកក្នុងឆាកនយោបាយ ជាមួយកេង វ៉ាន់សាក់ និងអតីតនិស្សិតខ្មែរនៅប្រទេសបារាំង ជាច្រើននាក់ទៀត នៅក្នុងខែមករា ឆ្នាំ១៩៥៥ នោះ តែម្តងទៅ។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៥៥ គណបក្សប្រជាធិបតេយ្យ បានបើកមហាសន្និបាតគណបក្សរបស់ខ្លួន ដោយមានសមាជិកគណៈកម្មាធិការនាយក ជាស្ថាបនិកគណបក្សចាស់ៗ និងបញ្ញវន្តក្មេងៗ ទើបមកពីប្រទេសបារាំង ព្រមទាំងមេដឹកនាំគណៈកម្មាធិការបក្សមកពីគ្រប់ខេត្ត និងគ្រប់ស្រុក នៅទូទាំងប្រទេស ចូលរួមដែរនោះ ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយកថ្មី។ ពេលនោះ ពួកបញ្ញវន្ត មកពីប្រទេសបារាំង ដោយមានកេង វ៉ាន់សាក់ និងជួន មុម្ម ជាអ្នកនាំមុខ បានធ្វើសកម្មភាពយ៉ាងខ្លាំងក្លា ក្នុងបំណងដណ្តើមយកតួនាទីដឹកនាំនៅក្នុងជួរគណៈកម្មាធិការនាយករបស់គណបក្សប្រជាធិបតេយ្យ ត្រូវជ្រើសរើសសាជាថ្មីនោះ។

នៅខែកុម្ភៈ ឆ្នាំ១៩៥៥ គណបក្សប្រជាធិបតេយ្យ បានរៀបចំគណៈកម្មាធិការនាយកថ្មីរបស់ខ្លួន ដោយមានព្រះអង្គម្ចាស់នរោត្តម ភូវិស្សារ៉ា ជាប្រធាន និងកេង វ៉ាន់សាក់

ជាអគ្គលេខាធិការ ហើយសមាសភាពនៅក្នុងជួរគណៈកម្មាធិការនាយក ចំនួន១១នាក់ មានពួកឆ្វេងនិយមជាបញ្ញវន្ត មកពីប្រទេសបារាំង ចំនួន៦នាក់ គឺ កេង វ៉ាន់សាក់, ជួន មុម្ម, សុិន ខេមកូ, អិន ផុន, តាក ហោង និងជ័យ ជុំ។ ក្នុងនោះ ក៏មាន អ៊ឹង ម៉េងគ្រុយ មកពីក្រុមដងរែកភ្នំពេញ របស់សឺង ង៉ុកថាញ់ ជាសមាជិកគណៈកម្មាធិការនាយកម្នាក់ដែរ។ តែយ៉ាងណា ព្រះអង្គម្ចាស់នរោត្តម ភូវិស្សារ៉ា ជាប្រធានគណបក្ស មិនសូវមានសកម្មភាព និងប្រជាប្រិយ ដូចកេង វ៉ាន់សាក់ ជាអគ្គលេខាធិការនោះទេ។

ពេលនោះ ជួន មុម្ម មានគំនិតផ្ទុយពីកេង វ៉ាន់សាក់ ដោយគាត់ចង់ឱ្យពួកបញ្ញវន្ត ជាឈាមថ្មីរបស់គណបក្ស និងសមាជិកស្ថាបនិកចាស់ៗរបស់គណបក្ស រួបរួមគ្នាជាធ្លុងមួយ ហើយ គាត់ក៏មិនចង់ឱ្យមានការឃោសនាវាយប្រហារទៅលើបុគ្គលណាម្នាក់ ពិសេស ឃោសនាវាយប្រហារទៅលើអតីតសមាជិកស្ថាបនិកចាស់ៗ របស់គណបក្សប្រជាធិបតេយ្យ ដែលនាំគ្នាទៅចូលរួមជាមួយចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ដែរ។ តែដល់ពេលបើកយុទ្ធនាការឃោសនា កេង វ៉ាន់សាក់ ស្រែកជេរសហរដ្ឋអាមេរិក ផង និងនៅតែឃោសនាវាយប្រហារទៅលើអតីតសមាជិកស្ថាបនិកចាស់ៗរបស់គណបក្សប្រជាធិបតេយ្យ ដូចជា សឺន សាន និងឈាន រ៉ែម (បងថ្លៃជួន មុម្ម) ជាដើមផង ។

ជួន មុម្ម បានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រម្នាក់ដែរ បានឱ្យដឹងថា ពេលនោះ កេង វ៉ាន់សាក់ និងសាឡុត ស (ក្រោយមក ប្រែឈ្មោះមកជា ប៉ុល ពត) មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ដោយបានទទួលទានបាយជាមួយគ្នា ស្ទើរតែព្រឹកល្ងាច ។ តែ សាឡុត ស មិនបានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ នៅក្នុងមណ្ឌលបោះឆ្នោតណាមួយទេ។

នៅក្នុងខែមីនា ឆ្នាំ១៩៥៥ ជួន មុម្ម បានទទួលសារទូរលេខពីម្តាយក្មេកគាត់ ឈ្មោះ អេវីយើ (Hervieux) ជាសាស្ត្រាចារ្យ នៅប្រទេសបារាំង មកប្រាប់ថា កូនប្រុសទី១ របស់គាត់ នៅក្នុងផ្ទៃប្រពន្ធគាត់ បានសម្រាលហើយ តែម៉ូនិក ជាប្រពន្ធរបស់គាត់ត្រូវវះកាត់២ដង នៅក្នុងពេលសម្រាលនោះ។

ពេលនោះ បើទោះបីមានវត្តមានរបស់គណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) ក៏

ពិតមែន ក៏បេក្ខជន និងសកម្មជនគណបក្សប្រជាធិតេយ្យ និងគណបក្សប្រជាជន ត្រូវរង ការគំរាមកំហែង ការចាប់ខ្លួន រហូតដល់មានការបាញ់សម្លាប់ទៀតផង។

ជួន មុម្ម បានឱ្យដឹងថា គាត់ត្រូវបានសម្តេចសីហនុ ប្រធានចលនាសង្គមរាស្ត្រនិយម កំពុងកាន់អំណាច បញ្ជាឱ្យរកចាប់ខ្លួនគាត់ដែរ។ តែព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុម: ធ្លាប់តែស្រលាញ់រាប់អានក្រុមគ្រួសារគាត់ តាំងពីដើមរៀងមកនោះ បានលួចប្រាប់ម្តាយ គាត់ ធ្វើយ៉ាងណាឱ្យគាត់ចាកចេញពីប្រទេសវិញភ្លាម។។

ពេលនោះ មានមិត្តភក្តិជិតស្និទ្ធរបស់គាត់ម្នាក់ ធ្លាប់ទៅរៀន នៅទីក្រុងហាណូយ ជាមួយគ្នា តាំងពីមុនឆ្នាំ១៩៤៥ ឈ្មោះកែវ ម៉ុងគ្រី មានតួនាទីជាអគ្គនាយកគយ និងរដ្ឋាករ បានលួចរត់ការ ធ្វើលិខិតឆ្លងដែនស្ងាត់។ ដើម្បីឱ្យគាត់បានចេញទៅទីក្រុងព្រៃនគរ ហើយ ឱ្យគាត់ប្រើប្រាស់លិខិតឆ្លងដែនសហព័ន្ធបារាំង ឡើងយន្តហោះ វិលទៅជួបប្រពន្ធកូន របស់គាត់ នៅប្រទេសបារាំង វិញ។

ពេលទៅដល់ប្រទេសបារាំង វិញ ក្មួយស្រីគាត់ម្នាក់ ឈ្មោះចន្ទ សូរី ហៅម៉ារីណែត ជាមហេសីព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្ស (ព្រះបិតុលារបស់ព្រះមហាក្សត្រសីហនុ) ពេលនោះ ជាឯកអគ្គរាជទូតខ្មែរ ប្រចាំនៅប្រទេសបារាំង បានលួចខ្សឹបប្រាប់គាត់ថា អាជ្ញាធរខ្មែរ បាន សុំឱ្យអាជ្ញាធរបារាំង ចាប់ខ្លួនគាត់ បញ្ជូនមកប្រទេសខ្មែរ វិញដែរ តែអាជ្ញាធរបារាំង មិនបាន ចាប់ខ្លួនគាត់ទេ ព្រោះគ្មានភស្តុតាង ហើយម៉្យាង គាត់ក៏មិនបានធ្វើអ្វីខុសនឹងច្បាប់បារាំង ផងដែរ។

ទាក់ទងដល់ករណីសុគតរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុគ្គវង្ស ជាប្រធានគណបក្ស ប្រជាធិបតេយ្យ និងជានាយករដ្ឋមន្ត្រី កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤៧នោះ ជួន មុម្ម បានអះអាងថា ពេលនោះ ទេសាភិបាលជាន់ខ្ពស់បារាំង នៅទីក្រុងភ្នំពេញ បានផ្ញើសំបុត្រ មួយមកឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅក្រុងប៉ារីស ដោយបានសរសេរថា ត្រូវបំបាត់ស៊ីសុវត្ថិ យុគ្គវង្ស ចេញពីឆាកនយោបាយខ្មែរ ដោយដំបូង បារាំង បានឱ្យប្រាក់កាសទ្រង់ជាច្រើន ដើម្បីឱ្យទ្រង់ចាកចេញទៅព្យាបាលជំងឺ នៅប្រទេសបារាំង តែទ្រង់មិនព្រម។ លុះពេល

ទ្រង់ចូលសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត គ្រូពេទ្យបារាំង ក៏មិនទុកទ្រង់ឱ្យរស់បានយូរដែរ។ បន្ទាប់មក ក៏មានព្រឹត្តិការណ៍គប់បែកគ្រាប់បែក សម្លាប់អៀវ កើស បន្តទៀត។

តែយ៉ាងណា បើតាមប្រភពព័ត៌មានគួរឱ្យជឿទុកចិត្ត បានឱ្យដឹងថា ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស សុគតនៅមន្ទីរពេទ្យកាល់ម៉ែត ដោយសារទ្រង់មានជំងឺរបេង ពោលគឺគ្មានគ្រូពេទ្យបារាំងណាចាក់ថ្នាំ ដើម្បីធ្វើគុតទ្រង់នោះទេ។

៨៣
គណបក្សប្រជាធិបតេយ្យ ចុះឃោសនារកសំឡេងឆ្នោត



គណបក្សប្រជាធិបតេយ្យ ចុះឃោសនារកសំឡេងឆ្នោត

នៅក្នុងអំឡុងពេលពួកបញ្ញវន្តក្មេងៗ ទើបមកពីប្រទេសបារាំង ជាឈាមថ្មី ចូលមកដឹកនាំគណបក្សប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៥៥នោះ សឺម វ៉ា និងសមាជិកស្ថាបនិកគណបក្សប្រជាធិបតេយ្យសំខាន់មួយចំនួនទៀត យល់ថា ពួកបញ្ញវន្តក្មេងៗ ទើបមកពីប្រទេសបារាំង មិនអាចដឹកនាំគណបក្សបានទេ ព្រោះពួកគេខ្វះបទពិសោធក្នុងការធ្វើនយោបាយ គាត់ក៏សម្រេចចិត្តដើរចេញពីគណបក្សប្រជាធិបតេយ្យ ទៅចូលរួមជាមួយចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ទើបបង្កើតថ្មីវិញ។

ចំណែក ង៉ែត ហ៊ាន ជាសមាជិកស្ថាបនិកគណបក្សប្រជាធិបតេយ្យ បានជាប់ឆ្នោតជាតំណាងរាស្ត្រ នៅមណ្ឌលកណ្តាលជ្រំ ខេត្តកំពង់ចាម តាំងពីអាណត្តិទី១ និងធ្លាប់រងគ្រោះ ដោយសារការគប់គ្រាប់បែកដៃ ជាមួយប្រធានគណបក្ស អៀវ កើស កាលពីថ្ងៃទី១៤

ខែមករា ឆ្នាំ១៩៥០នោះ ក៏មានការអន់ចិត្តនឹងពួកបញ្ញវន្តក្មេងៗឡើងមកដឹកនាំគណបក្ស នោះដែរ តែក៏គាត់មិនបានចាកចេញពីគណបក្សទេ ហើយគាត់ក៏មិនត្រូវបានគេជ្រើសរើស ឱ្យឈរឈ្មោះជាបេក្ខជន នៅមណ្ឌលណាមួយដែរ។

ប៉ុន្តែ ដោយសារនៅមណ្ឌលកំពង់ក្តី ខេត្តសៀមរាប គ្មានមន្ត្រីគណបក្សណាម្នាក់ ហ៊ានទៅឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ព្រោះខ្លាចអំណាចយោរយៅរបស់អតីតមេ ខ្មែរឥស្សរៈ ដាប ឈួន ដែលសម្តេចសីហនុ តែងតាំងជាមេបញ្ជាការកងយោធពលខេមរភូមិន្ទ នៅតំបន់ស្វយ័តសៀមរាប និងកំពង់ធំ តាំងពីគាត់មកចុះចូលក្នុងសង្គមជាតិវិញ កាលពីខែ តុលា ឆ្នាំ១៩៤៩នោះ មន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាធិបតេយ្យម្នាក់ ឈ្មោះមិញ ណាគ្រី ធ្លាប់ជាប់ឆ្នោតតំណាងរាស្ត្រជាមួយគ្នាកាលពីអាណត្តិទី១ បានទៅដល់ផ្ទះគាត់ និងអង្វរ គាត់ ឱ្យទៅឈរជាបេក្ខជនតំណាងរាស្ត្រ នៅមណ្ឌលកំពង់ក្តី ដើម្បីកុំឱ្យគេពេបជ្រាយថា គណបក្សប្រជាធិបតេយ្យ ជាគណបក្សធំជាងគេ ធ្លាប់ឈ្នះឆ្នោតភ្លូកទឹកភ្លូកដី តែរកបេក្ខជន មកឈរឈ្មោះ នៅមណ្ឌលកំពង់ក្តី ម្នាក់មិនបាន។ ម្យ៉ាង ដើម្បីកុំឱ្យអាប់ឱនដល់គណបក្ស ផងដែរ គាត់ក៏យល់ព្រមទៅឈរឈ្មោះជាបេក្ខជន នៅមណ្ឌលកំពង់ក្តី នោះ។

ង៉ែត ហ៊ាន ក៏ដឹងដែរថា ដាប ឈួន ជាមនុស្សសាហាវយោរយៅ ល្បីល្បាញខាង កាប់សម្លាប់ តាំងពីគាត់នៅជាមេខ្មែរឥស្សរៈម៉្លេះ ពិសេសសូម្បីតែ កៅ តក់ ធ្លាប់ជាមិត្តភក្តិ រួមអាវុធតស៊ូជាមួយគ្នា តាំងពីទសវត្សរ៍ឆ្នាំ១៩៤០ មកនោះ នៅពេលកៅ តក់ ឈរឈ្មោះ ជាបេក្ខជនរបស់គណបក្សប្រជាធិបតេយ្យ នៅមណ្ឌលបោះឆ្នោតមួយ ក្នុងខេត្តសៀមរាប ក៏ត្រូវ ដាប ឈួន បញ្ជាឱ្យទាហាននៅក្រោមបង្គាប់ ទៅស្នាក់បាញ់សម្លាប់យ៉ាងសាហាវ យោរយៅបំផុតដែរ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥៥ ។

កៅ តក់ មានកូនស្រីតែមួយគត់ ក្រោយមកបានក្លាយជាភរិយារបស់ហង្ស ធុនហាក់ ជាអតីតអ្នកតស៊ូជាមួយសឺង ង៉ុកថាញ់។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ ហង្ស ធុនហាក់ បានឡើងឋានៈជានាយករដ្ឋមន្ត្រី ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧២ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៣។

ពេលបើកយុទ្ធនាការឃោសនារកសំឡេងឆ្នោត ដំបូង ទោះបី ង៉ែត ហ៊ាន មានឈ្មោះជាបេក្ខជន នៅមណ្ឌលកំពង់ក្តី ខេត្តសៀមរាប ក៏ពិតមែន តែគាត់ត្រូវថ្នាក់ដឹកនាំបញ្ជូនឱ្យទៅជួយឃោសនាឱ្យបេក្ខជន ឃួន ណៃ នៅខេត្តកំពង់ចាម ទៅវិញ។ តែគាត់ក៏មិនបដិសេធដែរ ព្រោះគាត់ស្រលាញ់ឧត្តមគតិរបស់ឃួន ណៃ ជាមន្ត្រីជើងចាស់ម្នាក់របស់គណបក្ស និងធ្លាប់កាន់តំណែងជារដ្ឋមន្ត្រី ច្រើនក្រសួងមកហើយ។ ក្នុងពេលឃោសនារកសំឡេងឆ្នោតដំបូងនោះ តាមការស្ទាបស្ទង់ មើលទឹកចិត្តប្រជារាស្ត្រ នៅមណ្ឌលនោះ ង៉ែត ហ៊ាន គិតថាយ៉ាងច្រើន មានប្រជារាស្ត្រ៣០ភាគរយប៉ុណ្ណោះ បោះឆ្នោតគាំទ្របេក្ខជនគណបក្សប្រជា-ធិបតេយ្យ។

ពេលត្រលប់មកពីខេត្តកំពង់ចាម វិញ គាត់ត្រូវបានថ្នាក់ដឹកនាំចាត់ឱ្យជួយឃោសនាបេក្ខជន ម៉ម លន នៅមណ្ឌលមួយ ក្នុងខេត្តកណ្តាល បន្តទៀត ហើយគាត់បានវាយតម្លៃថានៅក្នុងមណ្ឌលនោះ ប្រជារាស្ត្រអាចបោះឆ្នោតឱ្យបេក្ខជនរបស់គណបក្សប្រជាធិបតេយ្យយ៉ាងច្រើន បានប្រហែល១០ភាគរយ ប៉ុណ្ណោះ។

បន្ទាប់មកទៀត គាត់ត្រូវបានថ្នាក់ដឹកនាំចាត់ឱ្យទៅឃោសនា រកសំឡេងឆ្នោត នៅមណ្ឌលជីក្រែង ក្នុងខេត្តសៀមរាបដែលគាត់ឈរឈ្មោះជាបេក្ខជននោះ។ នៅខេត្តសៀមរាប គណបក្សណាក៏បាក់បបខ្ពបខ្ពាចមេទ័ពកំណាច ដាប ឈួន ដែរ បើមន្ត្រីគណបក្សណាហ៊ានចុះទៅឃោសនារកសំឡេងឆ្នោត នៅខេត្តនោះ ច្បាស់ជាត្រូវ ដាប ឈួន រករឿង គំរាមកំហែង ឬបញ្ជាឱ្យកូនទាហានរបស់គាត់បាញ់សម្លាប់ចោលមិនខាន។

ពេលក្បួនរថយន្តឃោសនារបស់ពួកគាត់ជាង១០គ្រឿង ដឹកនាំដោយមន្ត្រីជាន់ខ្ពស់របស់គណបក្ស ឈ្មោះសោម ថាំង ធ្វើដំណើរទៅដល់ទីរួមខេត្តសៀមរាប អភិបាលខេត្ត ឈ្មោះហ៊ុយ ម៉ោង ក៏បានទទួលស្វាគមន៍ពួកគាត់ ក្នុងនាមជាគណៈកម្មការឃោសនារបស់គណបក្សប្រជាធិបតេយ្យ ដោយក្តីរីករាយរាក់ទាក់ដែរ ប៉ុន្តែ អភិបាលខេត្តរូបនេះ បានហាមឃាត់ពួកគាត់ មិនឱ្យចុះទៅធ្វើការឃោសនាទេ ព្រោះបើនៅតែចចេស ពិតជាមានការបង្ហូរឈាមគ្នាជាមិនខាន។

ជំនួសដោយការមិនឱ្យចុះទៅធ្វើការយោសនានោះ អភិបាលខេត្ត ហ៊ុយ ម៉ោង បាននាំពួកគាត់ទៅទស្សនាប្រាង្គប្រាសាទអង្គរ វិញ។

លុះត្រលប់មកពីទស្សនាប្រាង្គប្រាសាទអង្គរ វិញ ពួកគាត់ក៏បានចូលទៅជួបគណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) ប្រចាំខេត្តសៀមរាប តវ៉ាថា ពួកគាត់មកនេះ ដើម្បីចុះយោសនាពន្យល់ប្រជារាស្ត្រពីកម្មវិធីនយោបាយរបស់គណបក្សប្រជាធិបតេយ្យ ក្នុងការ បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។ តែឥឡូវនេះ មានគេហាមឃាត់មិនឱ្យពួកគាត់ចុះយោសនាដូច្នេះមានន័យថា គណបក្សប្រជាធិបតេយ្យ គ្មានសេរីភាពក្នុងការយោសនារកសំឡេងឆ្នោតទេ ផ្ទុយទៅវិញ មានតែចលនាសង្គមរាស្ត្រនិយមមួយប៉ុណ្ណោះ មានសិទ្ធិធ្វើអ្វីៗបានគ្រប់យ៉ាង។

ពួកគាត់បានសុំឱ្យគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) ប្រចាំខេត្តសៀមរាប ធ្វើកំណត់ហេតុ និងប្តឹងទៅប្រធានសន្និសីទក្រុងហ្សឺណែវ ដើម្បីឱ្យជួយដោះស្រាយរឿងនេះផង។

៨៤
មូលហេតុអ្វី គណបក្សប្រជាធិបតេយ្យ ធ្លាប់តែឈ្នះឆ្នោត បែរជាត្រូវបរាជ័យ ?



កេង ង៉ាន់សាក់(រូបពាក់អាវស) និងសុន សេន (ពាក់វ៉ែនតា)

គណៈកម្មការឃោសនារបស់គណបក្សប្រជាធិបតេយ្យ ដឹកនាំដោយមន្ត្រីជាន់ខ្ពស់របស់គណបក្ស ឈ្មោះសោម ថាំង បានទៅសម្រាកនៅក្នុងសណ្ឋាគារមួយយប់ ដើម្បីរង់ចាំដល់ពេលព្រឹកឡើង នឹងវិលត្រលប់មកទីក្រុងភ្នំពេញ វិញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ ឆ្លងកាត់តាមខេត្តកំពង់ធំ។

យប់នោះ ក៏មានឪពុករបស់ទាហានម្នាក់ នៅក្រោមបញ្ជាដាប ឈួន ជាមិត្តជិតស្និទ្ធរបស់សមាជិកគណៈកម្មការឃោសនាម្នាក់ ឈ្មោះសុត ចំរើន បានលួចចូលមកជួបក្នុងសណ្ឋាគារ និយាយប្រាប់សុត ចំរើន ថា ស្អែកនេះ ដាប ឈួន មានផែនការសម្លាប់ក្រុមឃោសនារបស់គណបក្សប្រជាធិបតេយ្យទាំងអស់ នៅពេលធ្វើដំណើរវិលត្រលប់ទៅទីក្រុង

ភ្នំពេញ វិញ។

ប្រហែលជាម៉ោង៣ទៀបភ្លឺទៅហើយ ង៉ែត ហៀន ឡើងទៅបត់ជើងតូច ស្រាប់តែឃើញសុត ចំរើន កំពុងខ្សឹបខ្សៀវជាមួយលោកតាជាឪពុករបស់ទាហានជាប ឈួន នោះ សុត ចំរើន ក៏ប្រាប់គាត់ពីអាថ៌កំបាំងនេះ ឱ្យបានដឹង។

ង៉ែត ហៀន បានប្រាប់ទៅសុត ចំរើន វិញថា សូមកុំឱ្យបែកការរឿងនេះ ដល់ពួកគាត់ផ្សេងទៀតឱ្យសោះ ហើយទុករឿងនេះឱ្យគាត់ជាអ្នកដោះស្រាយ ទើបរួចផុតគ្រោះថ្នាក់។

ម៉ោង៥ភ្លឺ ង៉ែត ហៀន និងសុត ចំរើន ក៏ដាស់សមាជិកគណៈកម្មការយោសនាទាំងអស់ ឱ្យក្រោកពីដំណេក ហើយប្រាប់ថា ពេលចេញដំណើរវិលត្រលប់មកភ្នំពេញ វិញ គឺរថយន្តគាត់ជាអ្នកនាំមុខ ដូច្នេះ បើឃើញរថយន្តគាត់ បើកទៅតាមផ្លូវណា រថយន្តទាំងអស់នៅខាងក្រោយ ត្រូវតែបើកតាមរថយន្តគាត់ឱ្យជាប់ៗគ្នា។

លុះដល់ម៉ោង៧ព្រឹក ពួកគាត់បានចូលស្រស់ស្រូបអាហារពេលព្រឹក នៅក្នុងហាងគុយទាវមួយ ដោយមានអភិបាលខេត្ត ហ៊ុយ ម៉ោង មកចូលរួម និងជួយចេញលុយថ្លៃគុយទាវទាំងអស់ ជាកិច្ចជូនដំណើរផងដែរ។

ក្រោយពេលជម្រាបលាអភិបាលខេត្ត ហ៊ុយ ម៉ោង មក រថយន្តង៉ែត ហៀន ក៏ចេញដំណើរនាំមុខគេ ដោយបើកបរយឺតៗ ធ្វើឱ្យគេឃើញថា ពួកគាត់ពិតជាតម្រង់ទិសដៅ ចេញតាមផ្លូវជាតិលេខ៦ ទៅមណ្ឌលកំពង់ក្តី ស្រុកជីក្រែង រួចបន្តដំណើរទៅទីរួមខេត្តកំពង់ធំ ប្រាកដមែន។

ង៉ែត ហៀន បានរម្លឹកថា ពេលរថយន្តពួកគាត់ មិនទាន់ចេញផុតពីក្រុងសៀមរាបផង ស្រាប់តែឃើញរថយន្តធុនធំចំនួន៤គ្រឿង ដឹកទាហាន បើកបរចេញពីក្រុងសៀមរាប ក្នុងទិសដៅទៅតាមផ្លូវជាតិលេខ៦ ឆ្ពោះទៅមណ្ឌលកំពង់ក្តី ស្រុកជីក្រែង នោះដែរ ធ្វើឱ្យពួកគាត់មានការសង្ស័យ គិតថា ពួកទាហាននៅលើរថយន្តធុនធំទាំង៤គ្រឿងនោះ នឹងទៅស្ទាក់ក្បួនរថយន្តពួកគាត់ នៅកំពង់ក្តី ស្រុកជីក្រែង ដើម្បីធ្វើបាបពួកគាត់ ដូចឪពុករបស់ទាហានម្នាក់ នៅក្រោមបញ្ជាជាប ឈួន បានលួចមកប្រាប់នៅក្នុងសណ្ឋាគារ នាពេលយប់

មិញនោះ ពិតប្រាកដមែន។

ពេលនោះ រថយន្តង៉ែត ហៀន កំពុងនាំមុខគេ ក៏បើកបង្វែងដាន ទៅព័ទ្ធផ្សារសៀមរាប មួយដុំ រួចបន្ថែមល្បឿន ទៅរកទិសដៅទីប្រជុំជនសិរីសោភ័ណ តែម្តង។ បើទោះបីមានរថយន្តហ្សៃអឹមសេ (GMC) ដឹកទាហាន ២គ្រឿងទៀត ដេញតាមពីក្រោយយ៉ាងណា ក៏ក្បួនរថយន្តពួកគាត់ នៅតែបោះពួយមកដល់ទីប្រជុំជនសិរីសោភ័ណ ស្ថិតនៅតាមដងផ្លូវជាតិលេខ៥ រួចបន្តដំណើរទៅដល់ទីរួមខេត្តបាត់ដំបង ដោយសុវត្ថិភាព។

ក្រោយពីមកដល់គេហដ្ឋាននៅទីក្រុងភ្នំពេញ មិនបានប៉ុន្មានថ្ងៃផង គាត់បានចំណាយពេលវេលាជាងមួយសប្តាហ៍បើកបររថយន្តផ្ទាល់ខ្លួន ដឹកក្រុមគ្រួសារទៅខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត និងខេត្តកំពង់ស្ពឺ ដើម្បីទៅដើរកម្សាន្តផង និងដើម្បីពិនិត្យមើលសភាពការណ៍ឃោសនាបោះឆ្នោតផងដែរ។

បន្ទាប់មក គាត់ក៏បានធ្វើដំណើរទៅពិនិត្យមើលសភាពការណ៍ឃោសនាបោះឆ្នោតនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង បន្តទៀត។

នៅទីបំផុត គាត់អាចវាយតម្លៃបានថា គណបក្សប្រជាធិបតេយ្យ មិនអាចឈ្នះចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ បានទេ ហើយគាត់ចង់ឱ្យមេដឹកនាំគណបក្សប្រជាធិបតេយ្យ ដកខ្លួនចេញពីការបោះឆ្នោតនោះវិញ ដើម្បីកុំឱ្យចំណាយលុយកាក់សម្រាប់ឃោសនា និងខាតបង់ពេលវេលា អត់ប្រយោជន៍។ ពិសេស គាត់គិតថា បើគណបក្សទាំងអស់ដកខ្លួនចេញពីការបោះឆ្នោត ហើយនៅសល់តែចលនាសង្គមរាស្ត្រនិយមមួយនោះ សាធារណៈមតិជាតិ និងអន្តរជាតិ ក៏មើលឃើញថា ការបោះឆ្នោតតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នៅកម្ពុជា គ្មានយុត្តិធម៌ត្រឹមត្រូវនោះទេ គឺមានតែការគំរាមកំហែងប៉ុណ្ណោះ ដូច្នេះហើយទើបគណបក្សប្រជាធិបតេយ្យរបស់គាត់ ដកខ្លួនចេញពីការបោះឆ្នោតនេះ។

ង៉ែត ហៀន បានប្រាប់មិត្តភក្តិជិតស្និទ្ធជាមន្ត្រីជាន់ខ្ពស់របស់គណបក្សជាមួយគ្នា គឺ ស្វាយ សូ (អតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ), ចាប សុំ និងយិន ឆៃ ថា តាមការពិនិត្យពីទឹកចិត្តរបស់ប្រជារាស្ត្រជាម្ចាស់ឆ្នោត គឺគណបក្សប្រជាធិបតេយ្យយើង មិនអាចឈ្នះចលនា

សង្គមរាស្ត្រនិយមរបស់សម្តេចសីហនុបានឡើយ។ មិត្តភក្តិជិតស្និទ្ធទាំង៣នាក់នោះ ក៏មើលឃើញដូចនេះដែរ តែពួកគេបានប្រាប់គាត់វិញថា បើគណបក្សប្រជាធិបតេយ្យយើងមិនចូលរួមការបោះឆ្នោតនេះ ក៏មិនកើតដែរ ព្រោះគណបក្សសេរីភាព គណបក្សតម្កើងប្រជាជាតិ និងគណបក្សផ្សេងៗទៀត គេចូលរួមអស់ហើយ។

ក្រោយមក ង៉ែត ហៀន ក៏បានទៅជួបមិត្តភក្តិជិតស្និទ្ធម្នាក់ទៀត គឺវេជ្ជបណ្ឌិត នាល ផ្លែង ជាមន្ត្រីជើងចាស់របស់គណបក្ស និងជាអតីតរដ្ឋមន្ត្រីក្រសួងសុខាភិបាល ច្រើនដងមកហើយ ដើម្បីសួរយោបល់ថា បើគណបក្សប្រជាធិបតេយ្យរបស់យើង ដកខ្លួនចេញពីការបោះឆ្នោត តើគណបក្សសេរីភាព គិតយ៉ាងម៉េចដែរ? វេជ្ជបណ្ឌិត នាល ផ្លែង បានឆ្លើយតបមកវិញ យ៉ាងខ្លីថា បើគណបក្សប្រជាធិបតេយ្យរបស់យើង ដកខ្លួនចេញពីការបោះឆ្នោត គណបក្សសេរីភាព និងគណបក្សតម្កើងប្រជាជាតិ ក៏ដកខ្លួនចេញដូចគ្នាដែរ។

ក្រោយពីធ្វើការស្ទាបស្ទង់ឃើញថា គណបក្សប្រជាធិបតេយ្យ មិនអាចឈ្នះចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ក៏មានមន្ត្រីគណបក្សមួយចំនួនចង់ឱ្យគណបក្សប្រជាធិបតេយ្យដកខ្លួនចេញពីការបោះឆ្នោតនោះដែរ ហើយង៉ែត ហៀន ក៏បានធ្វើរបាយការណ៍ស្តីពីបញ្ហានេះ ទៅជូនគណៈកម្មាធិការកណ្តាលរបស់គណបក្ស ដើម្បីសម្រេច។

តែគណៈកម្មាធិការកណ្តាល បានឆ្លើយមកវិញថា បញ្ហានេះ មានតែកេង វ៉ាន់សាក់ ជាអគ្គលេខាគណបក្សទេ ទើបអាចសម្រេចបាន។

ង៉ែត ហៀន និងឃិន ឆែ ក៏នាំគ្នាធ្វើដំណើរទៅដល់គេហដ្ឋានរបស់កេង វ៉ាន់សាក់ ដើម្បីពិភាក្សាគ្នាពីបញ្ហានេះភ្លាមៗដែរ តែកេង វ៉ាន់សាក់ បានប្រតិកម្មនឹងពួកគាត់វិញថា ការវាយតម្លៃទៅលើគណបក្សប្រជាធិបតេយ្យមិនអាចឈ្នះចលនាសង្គមរាស្ត្រនិយម របស់សម្តេចសីហនុ បាននោះ គឺជាការវាយតម្លៃច្រឡំហើយ។ ការពិត គណបក្សប្រជាធិបតេយ្យនឹងឈ្នះចលនាសង្គមរាស្ត្រនិយម របស់សម្តេចសីហនុ ដល់ទៅ៧០ភាគរយឯណោះ។

ឮដូច្នេះ ង៉ែត ហៀន និងឃិន ឆែ នាំគ្នាហួសចិត្ត គិតថា កេង វ៉ាន់សាក់ ជាអគ្គលេខាគណបក្ស មានសញ្ញាបត្រជាន់ខ្ពស់ពិតមែន តែគាត់មិនស្គាល់ទឹកចិត្តរបស់ប្រជារាស្ត្រ ដែល

តែងតែមានស្វាមីភក្តិចំពោះព្រះមហាក្សត្រ តាំងពីយូរលង់ណាស់មកហើយនោះទេ ។

ពួកគាត់គិតថា ចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ កំពុងកាន់អំណាច បានធ្វើសកម្មភាពគំរាមកំហែងបំភិតបំភ័យ បំបិទសិទ្ធិសេរីភាពគណបក្សផ្សេងៗទៀត ពិសេសគណបក្សប្រជាធិបតេយ្យ មិនឱ្យចុះឃោសនា ហើយបើគណបក្សប្រជាធិបតេយ្យប្រកាសដកខ្លួនចេញពីការបោះឆ្នោតនោះ គណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) នឹងជួយរកវិធីឱ្យគណបក្សប្រជាធិបតេយ្យ និងគណបក្សផ្សេងៗទៀតបានចុះទៅឃោសនា ដោយគ្មានការគំរាមកំហែង និងបាញ់សម្លាប់ទៀតដែរ។

ក្រោយប្រកាសលទ្ធផលបោះឆ្នោត ង៉ែត ហៀន បានបន្ទោសថា គណបក្សប្រជា-ធិបតេយ្យ ត្រូវបរាជ័យ រកតែអាសនៈ១នៅក្នុងសភាមិនបាននោះ មកពីមេដឹកនាំគណបក្សជាពួកបញ្ញវន្តក្មេងៗ ទើបមកពីប្រទេសបារាំង មិនស្តាប់មន្ត្រីចាស់ៗជាសមាជិកស្ថាបនិក។ បើពួកគេស្តាប់តាមមន្ត្រីចាស់ៗ ទោះបីបោះឆ្នោតចាញ់ចលនាសង្គមរាស្ត្រនិយម ក៏ល្អមើលដែរ។

៨៥
គម្រោងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវបរាជ័យ



ព្រះមហាក្សត្រ សីហនុ

នង សួន មេដឹកនាំគណបក្សប្រជាជន ក៏ដូចជាពួកមេដឹកនាំជំនាន់ថ្មីរបស់គណ-បក្សប្រជាធិបតេយ្យដែរ ពួកគេយល់ស្របតាមគោលនយោបាយអព្យាក្រឹតរបស់សម្តេចសីហនុ និងប្រឆាំងដាច់ខាត មិនឱ្យដាក់ប្រទេសកម្ពុជា ឱ្យនៅក្រោមឆត្រអង្គការសេអាតូ (SEATO) ដែលបង្កើតឡើងដោយសហរដ្ឋអាមេរិកនោះឡើយ។ ប៉ុន្តែក្នុងជួរដឹកនាំដែលមានវ័យចំណាស់ៗ របស់គណបក្សប្រជាធិបតេយ្យ ហាក់ដូចជាពុំមានគោលជំហរច្បាស់លាស់ឡើយ។

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៥៥ ព្រះមហាក្សត្រសីហនុ បានរំលាយរាជរដ្ឋាភិបាល ប៉ែន នុត ហើយរៀបចំរាជរដ្ឋាភិបាលថ្មី មួយទៀត ដោយមាន ឡុង ង៉ែត ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស, ផូ ព្រឿង រដ្ឋមន្ត្រីហិរញ្ញវត្ថុ, ប្រាក់ ប្រព្រឿង (អតីតមេប៉ូលិស ដែលល្បីថា ជាមនុស្សកំណាច) ជារដ្ឋមន្ត្រីមហាផ្ទៃ និងការពារលើផ្ទៃប្រទេស, ព្រះអង្គ ម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជារដ្ឋមន្ត្រីការពារប្រទេស, នាល ផ្លែង (ជាមន្ត្រីជើងចាស់របស់ គណបក្សប្រជាធិបតេយ្យ) ជារដ្ឋមន្ត្រីសាធារណការ ទូរគមនាគមន៍ និងផែនការ, ជួប

សំឡុត ជារដ្ឋមន្ត្រីយុត្តិធម៌, ម៉ៅ ចយ ជារដ្ឋមន្ត្រីព័ត៌មាន សង្គមកិច្ច និងការងារ, យ៉ែម សំបូរ ជារដ្ឋមន្ត្រីសេដ្ឋកិច្ច, ព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា ជារដ្ឋមន្ត្រីអប់រំជាតិ, អ៊ុំ ឈាងស៊ុន ជារដ្ឋមន្ត្រីសាធារណសុខាភិបាល និងម៉ី ណោសី ជារដ្ឋមន្ត្រីធម្មការ។

សមាសភាពរបស់គណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនេះ សុទ្ធតែជាមន្ត្រីមានទឹកចិត្តស្មោះត្រង់ជាមួយព្រះមហាក្សត្រ ហើយរាជរដ្ឋាភិបាលនេះ ក៏បានរៀបចំការធ្វើប្រជាមតិមួយដើម្បីចង់ដឹងថា តើព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យរបស់ព្រះមហាក្សត្រ សីហនុ ប្រកបដោយជោគជ័យកន្លងមកថ្មីៗនេះ ប្រជារាស្ត្រខ្មែរមានការគាំទ្រពេញចិត្តដែរឬទេ?

តាមរយៈការធ្វើប្រជាមតិ នៅទូទាំងប្រទេស នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៥៥ បានបង្ហាញឱ្យឃើញច្បាស់ថា ប្រជារាស្ត្រខ្មែរ ចំនួន៩៩,៨០ភាគរយ បានសម្តែងការគាំទ្រ និងពេញចិត្តចំពោះព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យនេះ ទាំងស្រុង។

មិនតែប៉ុណ្ណោះ ប្រជារាស្ត្រនៅតាមបណ្តាខេត្តជិតឆ្ងាយទាំងអស់ ក៏បានចាត់តាំងតំណាងពួកគេ ជាក្រុមៗ ឱ្យធ្វើដំណើរទៅទីក្រុងភ្នំពេញ ដើម្បីទូលសុំដោយទទូចឱ្យព្រះ-មហាក្សត្រសីហនុ ចុះមកដឹកនាំប្រទេស ដោយផ្ទាល់ទៀតផង។ តែព្រះអង្គបានបដិសេធនឹងការស្នើសុំនេះ ហើយព្រះអង្គបានសន្យាថា នឹងរៀបចំឱ្យមានរដ្ឋធម្មនុញ្ញថ្មីមួយទៀតសម្រាប់ដឹកនាំប្រទេស ដោយរដ្ឋធម្មនុញ្ញថ្មីនេះ មិនមែនជាប្រព័ន្ធប្រជាធិបតេយ្យ តាមបែបបស្ចិមប្រទេស ដែលពុំសមស្របតាមសភាពការណ៍ជាក់ស្តែង នៅក្នុងសង្គមខ្មែរ នោះទេ។

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៥៥ ព្រះអង្គបានអញ្ជើញអង្គទូតនានា, គណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) របស់សន្និសីទក្រុងហ្សឺណែវ, សមាជិករាជរដ្ឋាភិបាល និងសមាជិកក្រុមប្រឹក្សារាជបល្ល័ង្កទាំងអស់ មករួមប្រជុំនៅក្នុងព្រះបរមរាជវាំង។

ពេលនោះ ព្រះអង្គមានបន្ទូលថា ព្រះអង្គនឹងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីប្រែ-ក្លាយរបបនយោបាយ តាមបែបលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស មានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ នោះស្រាប់ ឱ្យទៅជារបបលទ្ធិប្រជាធិបតេយ្យបែបថ្មីមួយ ដែលប្រជារាស្ត្រខ្មែរអាចយល់បាន ដោយងាយស្រួល និងមិនឱ្យសង្គមជាតិ មានការបែកបាក់គ្នាដោយសារតែ

រឿងគាំទ្រគណបក្សនយោបាយខុសគ្នានោះទៀតទេ។

ព្រះមហាក្សត្រសីហនុ បញ្ជាក់ថា ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៧នោះ គឺរាជរដ្ឋាភិបាលត្រូវតែទទួលខុសត្រូវនៅចំពោះព្រះកក្រ្តរបស់ព្រះមហាក្សត្រ គឺមិនមែនទទួលខុសត្រូវ នៅចំពោះមុខរដ្ឋសភា ដូចមុនទៀតទេ។ ធ្វើដូច្នេះ ទើបរដ្ឋសភា គ្មានសិទ្ធិបោះ-ឆ្នោតគាំទ្រ ឬទម្លាក់រាជរដ្ឋាភិបាល ហើយរដ្ឋសភា គ្រាន់តែជាអង្គការពិគ្រោះពិភាក្សាធម្មតាប៉ុណ្ណោះ ។

ជាមួយគ្នានេះ ព្រះអង្គក៏ចង់ឱ្យមានប្រព័ន្ធបោះឆ្នោតថ្មីមួយ មានសភាថ្នាក់ខេត្ត ដោយសមាជិកសភាថ្នាក់ខេត្តនេះ ត្រូវបោះឆ្នោតគាំទ្រពីប្រជារាស្ត្រ នៅតាមខេត្តនីមួយៗ ដោយផ្ទាល់តែម្តង ហើយសមាជិកសភាខេត្តដែលជាប់ឆ្នោត ត្រូវបោះឆ្នោតអសាកល ជ្រើសរើសតំណាងរាស្ត្រ នៅក្នុងរដ្ឋសភា បន្តទៀត។ អ្នកមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ សភា នៅថ្នាក់ខេត្ត គឺជាជនទាំងឡាយណាបានរស់នៅក្នុងមណ្ឌលដែលខ្លួនឈរឈ្មោះជាបេក្ខជននោះ យ៉ាងតិច រយៈពេល៣ឆ្នាំ មុនថ្ងៃបោះឆ្នោត។

ព្រះមហាក្សត្រសីហនុ បានស្នើសុំឱ្យមានការរៀបចំធ្វើប្រជាមតិមួយ ពីបញ្ហាធ្វើវិសោធ-នកម្មរដ្ឋធម្មនុញ្ញនេះ ឱ្យបានមុនការបោះឆ្នោតតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ គ្រោងធ្វើឡើង នៅក្នុងខែមេសា ខាងមុខ ។

ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ ធ្វើឱ្យពួកអ្នកនយោបាយប្រឆាំង (គណបក្សប្រជាធិបតេយ្យ) ពិសេស អតីតពួកមេដឹកនាំខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ គឺគណបក្សប្រជាជនយល់ថា នេះជាល្បិចកលរបស់សម្តេច សីហនុ ដើម្បីប្រមូលអំណាចទាំងខាងរដ្ឋបាល និងខាងយោធា ឱ្យមកនៅក្នុងកណ្តាប់ដៃរបស់ព្រះអង្គ តែប៉ុណ្ណោះ។ ពួកគេបានប្រតិកម្ម ប្រឆាំងជំទាស់ចំពោះគម្រោងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ យ៉ាងប្តូរផ្តាច់។


ចំណែកបញ្ហានីតិវិធី និងរូបមន្តនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសភា នៅថ្នាក់ខេត្ត ក៏ធ្វើឱ្យអតីតពួកខ្មែរឥស្សរៈស្និទ្ធនឹងវៀតមិញ ភាគច្រើន បានចូលមករួមរស់ក្នុងសង្គមជាតិវិញ ត្រូវបាត់បង់សិទ្ធិឈរឈ្មោះជាបេក្ខជន ព្រោះពួកគេភាគច្រើន ទើបតែ

ចេញពីតស៊ូនៅក្នុងព្រៃ មករស់នៅក្នុងភូមិស្រុកវិញ មិនទាន់បានរយៈពេល១ឆ្នាំផងនោះ នឹងត្រូវដល់ពេលបោះឆ្នោត ដូច្នេះ ពួកគេគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រនៅថ្នាក់ខេត្តនោះទេ ព្រោះច្បាប់ថ្មីរបស់សម្តេចសីហនុ បានកំណត់ថា អ្នកមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រសភាថ្នាក់ខេត្ត ទាល់តែបេក្ខជននោះ បានរស់នៅក្នុងមណ្ឌលដែលខ្លួនឈរឈ្មោះ យ៉ាងតិចរយៈពេល៣ឆ្នាំ មុនថ្ងៃបោះឆ្នោត។

មិនមែនតែមេដឹកនាំគណបក្សប្រជាធិបតេយ្យ និងមេដឹកនាំខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញទេ សូម្បីគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) កំពុងមានវត្តមាននៅលើទឹកដីកម្ពុជា ក៏បានប្រឆាំងជំទាស់នឹងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នេះដែរ។

ដោយមានការប្រឆាំងជំទាស់ពីសំណាក់មជ្ឈដ្ឋានទាំងអស់នេះ ព្រះមហាក្សត្រសីហនុ ក៏សម្រេចព្រះទ័យបោះបង់ចោលគម្រោងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនោះចោល ហើយផ្លាស់ប្តូរយុទ្ធសាស្ត្រថ្មី គឺព្រះអង្គសម្រេចព្រះទ័យបង្កើតចលនានយោបាយមួយ ដើម្បីចូលរួមការបោះឆ្នោត តាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ នោះវិញ។

៨៦
ព្រះមហាក្សសីហនុ ប្រកាសដាក់រាជ្យ បង្កើតចលនាសង្គមរាស្ត្រនិយម



ព្រះមហាក្សត្រសុរាម្រិត និងព្រះមហាក្សត្រិយានីកុសុមៈ ឡើងគ្រងរាជសម្បត្តិ

នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥៥ ព្រះមហាក្សត្រនរោត្តម សីហនុ ប្រកាសដាក់រាជសម្បត្តិ ថ្វាយព្រះវររាជបិតានរោត្តម សុរាម្រិត និងព្រះវររាជមាតា ស៊ីសុវត្ថិ កុសុមៈ ដើម្បីចូលប្រឡូកក្នុងឆាកនយោបាយវិញ។

ក្រោយការដាក់រាជ្យមួយសប្តាហ៍ សម្តេច សីហនុ បានពន្យល់ហេតុផលថា ពីមុនព្រះអង្គកាន់អំណាចជាព្រះមហាក្សត្រ គឺជាការចាំបាច់បំផុត ដើម្បីព្រះអង្គមានលទ្ធភាពក្នុងការដឹកនាំប្រឆាំងនឹងការជិះជាន់របស់ពួកបរទេស និងប្រឈមមុខជាមួយបណ្តាប្រទេស

ជាមហាអំណាចនានា។ ប៉ុន្តែ ឥឡូវស្ថានភាពបានប្តូរផ្លាស់ហើយ បញ្ហាសំខាន់ៗ និងចម្បង បំផុត ត្រូវដោះស្រាយនោះ គឺបញ្ហាអភិវឌ្ឍរបស់ប្រទេសជាតិ។ ដូច្នេះ បើព្រះអង្គគង់នៅតែលើរាជបល្ល័ង្ក សំងំព្រះកាយ នៅតែក្នុងព្រះបរមរាជវាំងនោះ ព្រះអង្គក៏មិនអាចដឹងច្បាស់ ពីស្ថានភាពជីវភាពរស់នៅរបស់ប្រជារាស្ត្រព្រះអង្គ ដែលរងនូវការរំលោភបំពាននានានោះបានដែរ។

ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ ព្រះអង្គបានបង្កើតចលនាមួយ ឈ្មោះចលនាសង្គមរាស្ត្រនិយម មានព្រះអង្គផ្ទាល់ជាព្រះប្រធាន ហើយព្រះអង្គក៏ប្រកាសឱ្យមេដឹកនាំ និងសមាជិកគណបក្សផ្សេងៗទៀត ឱ្យមកចូលរួមក្នុងចលនានេះ ផងដែរ។

សម្តេចសីហនុ បានបញ្ជាក់ថា មូលហេតុនៃការបង្កើតចលនាសង្គមរាស្ត្រនិយមនេះឡើង គឺដោយសារព្រះអង្គមានព្រះរាជបំណងប្រមែប្រមូលខ្មែរទាំងអស់ កំពុងបែកបាក់ដោយសារតែការប្រកាន់គណបក្សនយោបាយរៀងៗខ្លួន ឱ្យទៅជាចលនារួបរួមជាតិដ៏ធំមួយ ឱ្យឈ្មោះថា ចលនាសង្គមរាស្ត្រនិយមនេះឯង។

សម្តេចសីហនុ បានប្រកាសថា ចលនាសង្គមរាស្ត្រនិយម មិនមែនជាគណបក្សនយោបាយទេ គឺជាចលនាបង្រួមបង្រួមជាតិមួយ ហើយបុគ្គលណាចង់មកចូលរួមក្នុងចលនានេះ ចាំបាច់ត្រូវតែលាលែងពីសមាជិកភាពរបស់គណបក្សនយោបាយរបស់ខ្លួន ពីមុននោះមកសិន។

ជាមួយនឹងគោលការណ៍បង្រួបបង្រួមជាតិនេះដែរ ចលនាសង្គមរាស្ត្រនិយម ក៏មានគោលការណ៍ប្រយុទ្ធប្រឆាំងនឹងអំពើអយុត្តិធម៌ អំពើពុករលួយ ការរំលោភបំពាន ការជិះជាន់សង្កត់សង្កិន និងអំពើក្បត់ទាំងឡាយនៅក្នុងសង្គមជាតិផងដែរ ហើយបាវចនារបស់ចលនាសង្គមរាស្ត្រនិយមគឺ ជាតិ សាសនា ព្រះមហាក្សត្រ។ ចលនាសង្គមរាស្ត្រនិយមបានសន្យាថា នឹងកសាងប្រទេសឱ្យបានរីកចម្រើនដូចបស្ចិមប្រទេស។

ដោយសារចលនាសង្គមរាស្ត្រនិយមនេះ ទើបបង្កើតថ្មី គោលនយោបាយមិនទាន់ជ្រួតជ្រាបដល់ប្រជារាស្ត្រនៅទូទាំងប្រទេសនៅឡើយ សម្តេចសីហនុ បានសុំពន្យារកាល

បរិច្ឆេទនៃការបោះឆ្នោត ដែលគ្រោងធ្វើឡើង នៅក្នុងខែមេសានោះ សុំលើកទៅបោះឆ្នោតដល់ខែកញ្ញា ខាងមុខវិញ ដើម្បីព្រះអង្គមានឱកាសប្រមូលកម្លាំង និងផ្សព្វផ្សាយគោលនយោបាយរបស់ចលនាសង្គមរាស្ត្រនិយម ឱ្យប្រជារាស្ត្របានជ្រួតជ្រាបសិន។

ក្រោយពីការប្រកាសបង្កើតចលនាសង្គមរាស្ត្រនិយមនេះមក មានមេដឹកនាំគណបក្សមួយចំនួន ដូចជា អ៊ុម ឈាងស៊ុន មេដឹកនាំគណបក្សប្រជាធិបតេយ្យជាតិ (មិនមែនគណបក្សប្រជាធិបតេយ្យទេ) និងជាអតីតនាយករដ្ឋមន្ត្រី (ពីថ្ងៃទី០៣ ខែមីនា ដល់ថ្ងៃទី១៣ ឧសភា ឆ្នាំ១៩៥១), លន់ នល់ មេដឹកនាំគណបក្សខេមរប៉ុណ្ណាការ, សម សារី មេដឹកនាំគណបក្សប្រជារាស្ត្រ, ដាប ឈួន មេដឹកនាំគណបក្សឧត្តរមានជ័យ ព្រមទាំងសមាជិកស្ថាបនិកគណបក្សប្រជាធិបតេយ្យ តាំងពីឆ្នាំ១៩៤៦ គឺ ស៊ឹម វ៉ា, សឺន សាន និងឥស្សរជនមួយចំនួនទៀត បាននាំគ្នាមកចូលរួមក្នុងចលនាសង្គមរាស្ត្រនិយម ដែលទើបបង្កើតថ្មីនេះជាបន្តបន្ទាប់ ។

ជំបូង សម្តេចសីហនុ តែងតាំងស៊ឹម វ៉ា ជាអគ្គលេខាធិការចលនាសង្គមរាស្ត្រនិយម លុះដល់ខែធ្នូ ឆ្នាំ១៩៥៥ ព្រះអង្គបានតែងតាំងសម សារី ជាអគ្គលេខាធិការជំនួសវិញ ព្រោះសម សារី មានសមត្ថភាព និងល្បិចក្នុងការធ្វើឱ្យគណបក្សនយោបាយជាគូប្រកួតផ្សេងៗទៀត ចុះខ្សោយ ដោយមានប្រសិទ្ធភាពបំផុត។

ចំណែកមេដឹកនាំគណបក្សប្រជាធិបតេយ្យ,គណបក្សប្រជាជន,គណបក្សសេរីភាព, គណបក្សតម្កើងជាតិ, គណបក្សពលករកម្ពុជា និងគណបក្សខ្មែរឯករាជ្យ មិនចូលរួមជាមួយចលនាសង្គមរាស្ត្រនិយម បង្កើតឡើងដោយសម្តេចសីហនុ នោះទេ។

៨៧
ក្រោយពីជួបនាយករដ្ឋមន្ត្រីឥណ្ឌា ព្រះមហាក្សត្រសីហនុ ប្រកាន់យកគោលជំហរអព្យាក្រឹត



ព្រះមហាក្សត្រសីហនុ និងព្រះជាយា ព្រមទាំងបុត្រី ពេលជួបនាយករដ្ឋមន្ត្រីឥណ្ឌា នេរូ

ឆ្លើយតបតាមការយោងរបស់នាយករដ្ឋមន្ត្រីឥណ្ឌា ហ្សាវ៉ា ហារឡាល់ នេហរុ (Jawa harlal Nehru) នៅក្នុងខែមីនា ឆ្នាំ១៩៥៥ សម្តេចសីហនុ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់មួយក្រុម ទៅបំពេញព្រះរាជកិច្ច នៅទីក្រុងញូវដេលី។

ក្នុងជំនួបរវាងមេដឹកនាំប្រទេសទាំងពីរ នាយករដ្ឋមន្ត្រីឥណ្ឌា បានប្រកាសទទួលស្គាល់ឯករាជ្យរបស់កម្ពុជា ជាផ្លូវការ ហើយគាត់បានផ្តល់យោបល់ថ្វាយសម្តេចសីហនុថា ចំពោះប្រទេសតូចៗនៅលើពិភពលោក ដូចជាប្រទេសឥណ្ឌា (តាមពិតប្រទេសឥណ្ឌា មិនមែនជាប្រទេសតូចទេ) និងកម្ពុជា ជាដើម ប្រទេសមហាអំណាចផ្សេងៗទៀតគេស្តាប់យើង តែនៅពេលណាប្រទេសយើងមានសុខសន្តិភាពប៉ុណ្ណោះ ហើយមធ្យោបាយដ៏ល្អបំផុត ដើម្បី

ធ្វើឱ្យមានសុខសន្តិភាពនោះ គឺយើងត្រូវតែនៅជាអព្យាក្រឹត។

ពេលយាងត្រលប់មកមាតុប្រទេសវិញ នៅក្នុងខែមេសា សម្តេចសីហនុ ក៏បានប្រកាសថា ប្រទេសកម្ពុជា ប្រកាន់គោលជំហរអព្យាក្រឹត ដូចការថ្វាយយោបល់របស់នាយករដ្ឋមន្ត្រីឥណ្ឌា នោះមែន។ មិនតែប៉ុណ្ណោះ ព្រះអង្គបានចាត់ទុកនាយករដ្ឋមន្ត្រី ហ្សាវ៉ា ហា-ឡាល់ នេហរុ ជាគ្រូរបស់ព្រះអង្គទៀតផង។

ក្នុងអំឡុងពេលឃោសនារកសំឡេងឆ្នោត គណបក្សប្រជាជន បានបង្កើតកាសែតមួយ ឈ្មោះកាសែតប្រជាជន និងបានចេញផ្សាយ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៥៥ ដោយចុះផ្សាយពីគោលនយោបាយរបស់ខ្លួនផង និងធ្វើការវាយប្រហារទៅលើគណបក្សជាគូប្រកួតរបស់ខ្លួនផង ពិសេសវាយប្រហារទៅលើចលនាសង្គមរាស្ត្រនិយម និងសម្តេចសីហនុ ជាប្រធានចលនានេះ។

ក្រោយពីចេញផ្សាយបានចំនួន១៩លេខ នៅថ្ងៃទី១០ ខែមិថុនា ជី គីមអាន និពន្ធនាយករបស់កាសែតប្រជាជន ត្រូវអាជ្ញាធរចាប់ខ្លួន យកទៅដាក់ពន្ធនាគារ។

ដើមឆ្នាំ១៩៥៥ នោះ ចលនាតស៊ូរបស់សឹង ង៉ុកថាញ់ នៅភាគខាងជើងប្រទេស បានបង្កើតក្រុមសម្ងាត់មួយឈ្មោះថា ក្រុមដងរែកភ្នំពេញ ដឹកនាំដោយអៀ ស៊ីចូវ និងបានទៅជ្រកក្រោមស្លាកគណបក្សប្រជាធិបតេយ្យនោះ បានចេញផ្សាយកាសែតចំនួន៤ផ្សេងៗគ្នា ចុះផ្សាយអត្ថបទវាយប្រហារទៅលើសម្តេចសីហនុ និងផ្សព្វផ្សាយពីចលនាតស៊ូរបស់ខ្លួនខ្លះៗផងដែរ តែក្រោយពីចេញផ្សាយបានពីរបីលេខដំបូង ក៏ត្រូវអាជ្ញាធរបិទលែងឱ្យចេញ ផ្សាយជាបន្តបន្ទាប់។

តែទោះបីយ៉ាងនេះក៏ដោយ ក៏ក្រុមដងរែកភ្នំពេញ ព្យាយាមបង្កើតកាសែតថ្មីមួយទៀត គឺកាសែតសាមគ្គី មាន សាឡុត ឆាយ (បងប្រុសសាឡុត ស) ជានិពន្ធនាយក ដើម្បីឃោសនាផ្សព្វផ្សាយគោលនយោបាយរបស់ចលនាតស៊ូរបស់ខ្លួនបន្តទៀត។

ក្រោយពេលកាសែតសាមគ្គីនេះ ចេញផ្សាយបានរយៈពេល១០ថ្ងៃ សាឡុត ឆាយ ជានិពន្ធនាយក ត្រូវកម្លាំងសមត្ថកិច្ចតាមរកចាប់ខ្លួន។ គាត់ក៏បានរត់ទៅពួនសំងំលាក់ខ្លួន

នៅក្នុងផ្ទះបងប្រុសគាត់ ឈ្មោះសាឡុត សួង ជាមន្ត្រីបម្រើការងារនៅក្នុងព្រះបរមរាជវាំង តាំងពីរជ្ជកាលព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស មកម្ល៉េះនោះ។ ប៉ុន្តែ ក្រោយពីមានព្រះរាជបញ្ជាពីព្រះមហាក្សត្រនរោត្តម សុរាម្រិត ទើបនឹងឡើងគ្រងរាជសម្បត្តិ កាលពីថ្ងៃទី០៥ មីនា នោះ សាឡុត សួង ក៏ព្រមប្រគល់សាឡុត ឆាយ ជាប្អូនប្រុសរបស់គាត់ ទៅឱ្យសមត្ថកិច្ចប៉ូលិស តាមសម្រួល។

ក្រោយពីអាជ្ញាធរលែងឱ្យចេញផ្សាយកាសែតប្រជាជន ព្រមទាំងចាប់ខ្លួននិពន្ធនាយក ជី គីមអាន មក នៅថ្ងៃទី២៤ ខែមិថុនា គណបក្សប្រជាជន ក៏បានបង្កើតកាសែតថ្មី មួយទៀត គឺកាសែតប្រជាជាតិ ដោយមាន ប៉ែន យុទ្ធ ជានិពន្ធនាយក ផ្ទាល់តែម្តង។

ក្រោយការចេញផ្សាយកាសែតប្រជាជាតិនេះ បានប្រហែល៣ខែ នៅថ្ងៃទី២៤ ខែតុលា អាជ្ញាធរ ក៏លែងឱ្យកាសែតនេះចេញផ្សាយទៀត ហើយ ប៉ែន យុទ្ធ ជានិពន្ធនាយក ក៏ត្រូវចាប់ខ្លួនទៀតដែរ។

ជី គីមអាន និពន្ធនាយកកាសែតប្រជាជន, ប៉ែន យុទ្ធ និពន្ធនាយកកាសែតប្រជាជាតិ ជាមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជន ព្រមទាំង សាឡុត ឆាយ និពន្ធនាយកកាសែតសាមគ្គី និងនិពន្ធនាយកកាសែតមួយទៀត ឈ្មោះទៅមុខ ដែលលម្អៀងទៅរកចលនាតស៊ូប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ របស់សឺង ង៉ុកថាញ់ ត្រូវតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារម្នាក់ៗ រយៈពេល៣ខែ ដោយក្នុងនោះ និពន្ធនាយកកាសែតខ្លះ ត្រូវចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិតថា ប្រទេសកម្ពុជា ទទួលបានឯករាជ្យពិតប្រាកដនោះ គឺតាមរយៈសន្និសីទនៅក្រុងហ្សឺណែវ ហើយនិពន្ធនាយកកាសែតខ្លះទៀត ត្រូវចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិតថា ប្រទេសកម្ពុជាទទួលបានឯករាជ្យ ដោយសារមានការតស៊ូរបស់ពួកខ្មែរឥស្សរៈ និងការចូលរួមរបស់ប្រជារាស្ត្រខ្មែរទាំងមូល គឺពុំមែនបានមកដោយសារសម្តេចសីហនុ បានប្រកាសនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នោះទេ។

និពន្ធនាយកកាសែតខ្លះទៀត ត្រូវចោទប្រកាន់ពីបទប្រមាថសម្តេចសីហនុ និងរបបរាជានិយមហើយខ្លះទៀតត្រូវចោទប្រកាន់ពីបទចុះផ្សាយខុសការពិត ពីរឿងរាជរដ្ឋាភិបាល

ចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលជំនួយយោធា និងសេដ្ឋកិច្ច ពីសហរដ្ឋអាមេរិក ថ្ងៃទី ១៦ ខែឧសភា។

ប៉ុន្តែ ប៉ុន្មានសប្តាហ៍ក្រោយមក ដោយមានការបំផុសបំផុលពីក្រុមអ្នកនយោបាយ ឆ្វេងនិយម សិស្សានុសិស្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិ បាននាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងរាជ-រដ្ឋាភិបាលដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលជំនួយយោធាពីសហរដ្ឋអាមេរិក ជាបន្តបន្ទាប់។

៨៨
សឺង ង៉ុកថាញ់ រៀបផែនការបង្កអសន្តិសុខ



ព្រះតិក្ខ ខៀវ ដុំ



សឺង ង៉ុកថាញ់

ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតនោះ នៅទីក្រុងភ្នំពេញ ក្រុមដងរែកភ្នំពេញរបស់អៀ សុីថូវដែលរួមសហការជាមួយគណបក្សប្រជាធិតេយ្យ និងគណបក្សជំទាស់ផ្សេងៗទៀត បានដាក់ពាក្យប្តឹងតវ៉ាពីហេតុការណ៍ផ្សេងៗដែលទាក់ទងដល់ការបង្ក្រាប និងការរំលោភបំពាន បំបិទសិទ្ធិសេរីភាពដោយសម្តេចសីហនុ ប្រធានចលនាសង្គមរាស្ត្រនិយមទៅគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) ឱ្យជួយដោះស្រាយដែរ។ តែគណៈកម្មការអន្តរជាតិមួយនេះ ហាក់ដូចជាធ្វើព្រងើយកន្តើយចំពោះហេតុការណ៍ទាំងអស់នោះ ទៅវិញ។

ពេលនោះ ចលនាតស៊ូក្រៅច្បាប់របស់សឺង ង៉ុកថាញ់ កំពុងស្ថិតនៅលើភ្នំដងរែក បានចោទប្រកាន់ចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ថា បានប្រើកិច្ចកលដ៏គម្រក់ថោកទាប និងប្រើអំពើសាហាវព្រៃផ្សៃយង់ឃ្នងបំផុត ដូចជាប្រើកម្លាំងប៉ូលិសទាហាន និងក្រុមគិញសម្ងាត់ ឲ្យទៅធាវៅអុកឡុកវាយដំប្រំធាក់បេក្ខជនរបស់គណបក្សផ្សេងទៀត និងចាប់ចងអ្នកសារព័ត៌មាន យកទៅឃុំឃាំងយ៉ាងអយុត្តិធម៌ជាទីបំផុតផងដែរ។

សឺង ង៉ុកថាញ់ យល់ឃើញថា ការបោះឆ្នោតដែលត្រូវប្រព្រឹត្តឡើង នៅថ្ងៃទី១១ ខែកញ្ញា ខាងមុខនោះ ប្រាកដជាគ្មានយុត្តិធម៌ត្រឹមត្រូវអ្វីឡើយ ដូច្នេះមានផ្លូវតែមួយគត់ អាចទប់ទល់នឹងអំពើព្រៃផ្សៃថោកទាបរបស់ចលនាសង្គមវាស្ត្រនិយមនោះបាន គឺត្រូវតែធ្វើសកម្មភាពបំផ្លាញការបោះឆ្នោត កុំឲ្យប្រព្រឹត្តទៅបានដូចការគ្រោងទុក។ សឺង ង៉ុកថាញ់ ក៏មានគំនិតចាប់ផ្តើមរៀបចំផែនការបង្កអសន្តិសុខ នៅតាមមណ្ឌលបោះឆ្នោតនានា ចាប់ពីពេលនេះតទៅ ប្រសិនបើអាចធ្វើទៅបាន ពិសេសបង្កអសន្តិសុខ នៅតាមមណ្ឌលបោះឆ្នោត ធ្លាប់នៅក្រោមការគ្រប់គ្រងរបស់អតីតចលនាខ្មែរឥស្សរៈ ពីមុនៗមក។

សឺង ង៉ុកថាញ់ បញ្ជាក់ថា គោលដៅនៃផែនការបង្កអសន្តិសុខនេះ ធ្វើឡើងដើម្បីទាក់ទាញអារម្មណ៍គណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) ឲ្យយកចិត្តទុកដាក់ក្នុងការបំបាត់អំពើសាហាវព្រៃផ្សៃ ថោកទាប ឃោរឃៅ អយុត្តិធម៌ ដែលសម្តេចសីហនុ ជាប្រធានចលនាសង្គមវាស្ត្រនិយម បានបង្កឡើងនោះ បើមិនដូច្នេះទេ ការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ តាមសេចក្តីសម្រេចរបស់កិច្ចព្រមព្រៀងសន្តិភាពក្រុងហ្សឺណែវ បានឡើយ។

ដើម្បីអនុវត្តផែនការបង្កអសន្តិសុខ អុកឡុកដល់ការបោះឆ្នោតនេះ សឺង ង៉ុកថាញ់ បានឱ្យសហការីរបស់គាត់ទៅហៅ ឡឹក សំអឿន កំពុងគ្រប់គ្រងជំរំប្រាសាទតាមាន់ និងជំរំគូ នៅស្រុកបន្ទាយឆ្មារ (អតីតជំរំរបស់ កៅ តក់ ត្រូវដាប ឈួន បញ្ជាឱ្យកូនទាហានរបស់គាត់បាញ់សម្លាប់ កៅ តក់ នោះ) មកជួប ដើម្បីឱ្យយកផែនការនេះ ទៅជួបពិភាក្សាជាមួយ អៀ ស៊ីចូវ ជាមេដឹកនាំចលនាតស៊ូក្រុមដងវែកភ្នំពេញ។

១០ថ្ងៃ មុនពេលបោះឆ្នោត ឡឹក សំអឿន បានធ្វើដំណើរចេញពីជំរំគូ ទៅទីក្រុងភ្នំពេញ ដោយមានសហការី៥នាក់ជូនដំណើរទៅដល់ស្រុកក្រឡាញ់ ខេត្តសៀមរាប និងរង់ចាំនៅទីនោះ រហូតគាត់វិលត្រលប់មកពីទីក្រុងភ្នំពេញ វិញ។ នៅថ្ងៃទី១ ខែកញ្ញា គាត់បានបន្តដំណើរ ដោយជិះរថយន្តឈ្នួលតែម្នាក់ឯង ទៅដល់ក្រុងបាត់ដំបង ហើយបានសម្រាកមួយយប់ នៅផ្ទះខ្សែរយៈសម្ងាត់របស់គាត់ម្នាក់ ជាខ្មែរកម្ពុជាក្រោម និងមានតួនាទី

ជាប្រធានស្ថានីយរថភ្លើងក្នុងក្រុងបាត់ដំបងនោះ។

ស្អែកឡើង គាត់ឡើងជិះរថភ្លើងបន្តដំណើរទៅដល់ទីក្រុងភ្នំពេញ និងបានស្នាក់នៅផ្ទះរបស់ក្រុមគ្រួសារសឹង ង៉ុកថាញ់ ដោយនៅក្នុងផ្ទះនោះ ក៏មានមិត្តភក្តិធ្លាប់រួមការងារជាមួយគ្នា នៅភ្នំដងរែក ២នាក់ គឺ អ៊ឹង ម៉េងគ្រុយ និងម៉ៅ ថេន។

ថ្ងៃទី៣ ខែកញ្ញា ឡឹក សំអឿន បានទៅជួប អៀ ស៊ីចូវ នៅឯផ្ទះរបស់គាត់ និងបានពិភាក្សាគ្នាពីផែនការរបស់សឹង ង៉ុកថាញ់ ដាក់ឱ្យនោះ អស់រយៈពេលចំនួនមួយម៉ោង។ តែ អៀ ស៊ីចូវ បានប្រាប់ឡឹក សំអឿន ថា ក្រុមដងរែកភ្នំពេញ របស់គាត់ មិនអាចធ្វើតាមផែនការរបស់សឹង ង៉ុកថាញ់ នោះបានទេ ព្រោះវានឹងធ្វើឱ្យមានគ្រោះថ្នាក់កាន់តែធំឡើងថែមទៀត ដល់ពួកគាត់ កំពុងនៅក្នុងទីក្រុងភ្នំពេញ។

តែយ៉ាងណា គាត់ក៏មិនបដិសេធផែនការនេះដែរ ដោយគាត់សុំឲ្យយកផែនការនេះទៅអនុវត្ត នៅក្រោយពេលបោះឆ្នោតរួចហើយសិន។ ប្រសិនបើចលនាសង្គមរាស្ត្រនិយមឈ្នះឆ្នោតច្រើនដាច់ខាត ត្រូវនាំគ្នាបះបោរតវ៉ាថា ការបោះឆ្នោតនោះ មិនមានយុត្តិធម៌ត្រឹមត្រូវទេ ព្រោះមានការគំរាមកំហែង បាញ់សម្លាប់ ឬកេងបន្លំសន្លឹកឆ្នោត ជាដើម។

ស្អែកឡើង ឡឹក សំអឿន ក៏បានធ្វើដំណើរទៅជួបហង្ស ធុនហាក់ ដើម្បីសុំឱ្យគាត់ជួនទៅជួបវេជ្ជបណ្ឌិតជួន ជឿន (រដ្ឋមន្ត្រីក្រសួងសុខាភិបាល សម័យរបបខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យ) ដើម្បីឱ្យជួយពិនិត្យ និងព្យាបាលជំងឺគ្រុនចាញ់របស់គាត់។ លុះពិនិត្យរួចវេជ្ជបណ្ឌិតជួន ជឿន ក៏ផ្តល់ថ្នាំពេទ្យឱ្យគាត់មួយចំនួន។

ឆ្លៀតឱកាសធ្វើដំណើរទៅទីក្រុងភ្នំពេញ នោះដែរ ឡឹក សំអឿន ក៏បានធ្វើដំណើរបង្ហួស ទៅដល់ទីរួមខេត្តស្វាយរៀង ដើម្បីជួបសួរសុខទុក្ខឪពុកម្តាយ បងប្អូនរបស់គាត់ដែលបានភៀសខ្លួនចេញពីស្រុកកំណើត នៅឯភូមិមេសថ្ងក(មេ.ស.ថ្ងក) ឃុំមេសថ្ងក ស្រុកស្វាយទាប (បច្ចុប្បន្នជាស្រុកចន្ទ្រា) មកនៅទីរួមខេត្ត ដោយសារតែពួកវៀតមិញ ចូលមករាតត្បាត។ មុនថ្ងៃបោះឆ្នោត មួយថ្ងៃ ឡឹក សំអឿន បានត្រលប់មកដល់ទីក្រុងភ្នំពេញ វិញ។

នៅថ្ងៃទី១១ ខែកញ្ញា វេលាម៉ោង៦ល្ងាច ខណៈការបោះឆ្នោត បានបញ្ចប់ទៅហើយ

នោះ ស្រាប់តែ អ៊ឹង ម៉េងគ្រុយ ជាមិត្តភក្តិធ្លាប់រួមការងារជាមួយគ្នា នៅភ្នំដងរែក និងជាសមាជិកគណៈកម្មការនាយករបស់គណបក្សប្រជាធិបតេយ្យ បានប្រាប់ថា ឡឹក សំអឿន ឯង មានដីកាតាមចាប់ខ្លួនហើយ។

ពេលនោះ អ៊ឹង ម៉េងគ្រុយ ក៏នាំឡឹក សំអឿន ទៅស្នាក់នៅបណ្តោះអាសន្ន នៅសណ្ឋាគារអាស៊ី ក្នុងបន្ទប់ជាមួយអនុសេនីយ៍ត្រី ថាច់ ត្នាន់។ ពេលនោះថាច់ ត្នាន់ ជានិស្សិតពេទ្យទាហាន នៅមហាវិទ្យាល័យកូមិន្ទសុខាភិបាល ហើយក្រសួងការពារជាតិ បានជួលសណ្ឋាគារអាស៊ីនេះ សម្រាប់ឱ្យពួកនាយទាហាន ស្នាក់នៅក្នុងអំឡុងពេលមករៀនសូត្រជំនាញពេទ្យនោះ។ ថ្វីបើអនុសេនីយ៍ត្រី ថាច់ ត្នាន់ ជានាយទាហានកងទ័ពរបស់រាជរដ្ឋាភិបាល ក៏ពិតមែន តែគាត់ជាមនុស្សស្រលាញ់រាប់អានគ្នា ដោយស្មោះត្រង់បំផុតជាមួយ អ៊ឹង ម៉េងគ្រុយ ជាមេដឹកនាំចលនាតស៊ូប្រឆាំងនឹងសម្តេចសីហនុ ផងដែរ។

វេលាម៉ោង៨យប់ អនុសេនីយ៍ត្រី ថាច់ ត្នាន់ បានបបួលឡឹក សំអឿន ទៅទទួលទានបាយជាមួយ នៅភោជនីយដ្ឋានថ្មដា នៅមិនឆ្ងាយប៉ុន្មាន ពីសណ្ឋាគារអាស៊ី នោះ។ តែឡឹក សំអឿន ឆ្លើយថា គាត់ទទួលទានបាយរួចហើយ សូមអញ្ជើញទៅតែម្នាក់ឯងចុះ។

ក្រោយពេលអនុសេនីយ៍ត្រី ថាច់ ត្នាន់ ចេញទៅបាត់ ឡឹក សំអឿន ក៏ចូលងូតទឹករួចក៏មកអង្គុយអានកាសែត នៅក្នុងបន្ទប់តែម្នាក់ឯង។ លុះដល់ម៉ោង៨ ស្រាប់តែមានស្នូរគោះទ្វារបន្ទប់ គាត់ក៏ក្រោកឡើងទៅបើកទ្វារ ព្រោះនឹកស្មានថា អនុសេនីយ៍ត្រី ថាច់ ត្នាន់ ត្រលប់មកពីទទួលទានបាយវិញ ស្រាប់តែឃើញអនុសេនីយ៍ទោ គីម ត្រាង ជានាយទាហាននៅការិយាល័យទី២ នៃអគ្គសេនាធិការកងខេមរភូមិន្ទ ទៅវិញ។

ពេលនោះ ពួកគាត់ទាំង២នាក់ មានការភ្ញាក់ផ្អើលស្រឡាំងកាំង ដាក់គ្នាទៅវិញទៅមកមួយសន្ទុះ ទើបអនុសេនីយ៍ទោ គីម ត្រាង ស្ទុះមកឱបឡឹក សំអឿន ដោយក្តីនឹករឭក រួចទាញយកលិខិតចាប់ខ្លួនមកបង្ហាញឡឹក សំអឿន ដោយនិយាយទាំងញ័រមាត់ថា តើបងឱ្យខ្ញុំធ្វើម៉េចទៅ? ឡឹក សំអឿន ក៏តបទៅវិញថា ធ្វើតាមតួនាទីរបស់ប្អូនឯងចុះ ហើយឡឹក សំអឿន សួរបញ្ជាក់ថា តើចាប់ខ្លួនគាត់ មកពីរឿងអ្វី?

គឹម ត្រាង ប្រាប់ថា កាលពីថ្ងៃ៨ ខែកញ្ញា(មុននេះ៣ថ្ងៃ) កងរាជតម្រួត នៅស្រុក បន្ទាយឆ្មារ បានសហការជាមួយពួកទាហាននៅបន្ទាយថ្មពួក ទៅហ៊ុមព័ទ្ធជំរំគូ (ជំរំរបស់ ឡឹក សំអឿន ទៅគ្រប់គ្រងជំនួសកៅ តក់ ក្រោយដាប ឈួន ឱ្យគេបាញ់សម្លាប់កៅ តក់) ហើយរឹបអូសយកទ្រព្យសម្បត្តិ នៅក្នុងជំរំនោះទាំងប៉ុន្មាន រួមមាន គោ ក្របី ជ្រូក មាន់ ទា ស្រូវ អង្ករ ហើយថែមទាំងចាប់បានអ្នកតស៊ូពីរនាក់ នាំយកមកសួរចម្លើយ ទើបដឹងច្បាស់ថា ឡឹក សំអឿន ជាមេខ្លោងនៅជំរំនោះ តែបានធ្វើដំណើរចេញទៅទីក្រុងភ្នំពេញ តាំងពីដើមខែកញ្ញា អគ្គសេនាធិការកងខេមរភូមិន្ទ ក៏ចេញលិខិតឱ្យតាមចាប់ខ្លួនឡឹក សំអឿន តែម្តងទៅ។

អនុសេនីយ៍ទោ គឹម ត្រាង បញ្ជាក់ថា មុននេះ គាត់ក៏បានឲ្យអ៊ឹង ម៉េងគ្រុយ មើលលិខិតតាមចាប់ខ្លួននេះដែរ។ ឡឹក សំអឿន តបទៅវិញថា ហ្នឹងហើយ! ក្រោយពីបានឃើញលិខិតតាមចាប់ខ្លួននេះមក អ៊ឹង ម៉េងគ្រុយ បាននាំគាត់មកលាក់ខ្លួន នៅសណ្ឋាគារអាស៊ីនេះ។

មុនពេលចាកចេញទៅវិញ អនុសេនីយ៍ទោ គឹម ត្រាង បានផ្តាំផ្ញើឡឹក សំអឿន ថា ទោះយ៉ាងណា កុំឱ្យប្រាប់អនុសេនីយ៍ត្រី ថាច់ ត្នាន់ ដឹងរឿងនេះឱ្យសោះ។ រួចគាត់ក៏ប្រញាប់ចាកចេញពីបន្ទប់នោះវិញភ្លាម។

លុះព្រឹកឡើង ម៉ោង៥ភ្លឺ ឡឹក សំអឿន ក្រោកឡើងស្លៀកពាក់រួចហើយ អ៊ឹង ម៉េងគ្រុយ ក៏មកដល់ល្មម ឡឹក សំអឿន ក៏លាអនុសេនីយ៍ត្រី ថាច់ ត្នាន់ និងអ៊ឹង ម៉េងគ្រុយ ធ្វើដំណើរទៅស្ថានីយរថភ្លើង ដើម្បីចេញដំណើរទៅក្រុងបាត់ដំបង វិញ។

ពេលល្ងាច ទៅដល់ក្រុងបាត់ដំបង គាត់បានស្នាក់នៅផ្ទះរបស់ខ្សែរយៈសម្ងាត់របស់គាត់ ជាខ្មែរកម្ពុជាក្រោម និងជាប្រធានស្ថានីយរថភ្លើងក្រុងបាត់ដំបង នោះ ដូចកាលគាត់បានស្នាក់នៅ កាលពីយប់ថ្ងៃទី១ ខែកញ្ញា ពេលចេញដំណើរពីជំរំគូ មកក្រុងភ្នំពេញ ដែរ។

នៅវេលាម៉ោង៨យប់ ស្រាប់តែសហការី២នាក់ គឺឈ្មោះញ៉ឹក ញ៉ុក និងគ្រូពេទ្យ ឈ្មោះផាន បានធ្វើដំណើរតាមរថយន្តផ្ទាល់ខ្លួន ពីភ្នំពេញ មករកគាត់នៅផ្ទះរបស់ខ្សែរយៈ

សម្ងាត់នោះ ដើម្បីដួនដំណើរគាត់ឲ្យទៅដល់ទីដៅ ព្រោះពួកគេបានទទួលព័ត៌មានថា កម្លាំង សម្ងាត់របស់សមត្ថកិច្ចជាច្រើន បាននាំគ្នាចេញស្នាក់ផ្លូវទៅខេត្តបាត់ដំបង និងសៀមរាប នៅពេលដឹងថា ឡឹក សំអឿន បានចាកចេញពីភ្នំពេញ កាលពីព្រឹកមិញនោះ។ ម៉ោង ១០ យប់ ដោយសារខ្សែរយៈសម្ងាត់ជាម្ចាស់ផ្ទះ ចេះតែទទួចបបួលពួកគាត់ទាំង៣នាក់ ទៅរក ទទួលទានបង្អែមសៀម នៅឯផ្សារបាត់ដំបង ខ្លាំងពេក ពួកគាត់ក៏សុខចិត្តទៅជាមួយ។

ក្រោយពេលអង្គុយនៅកន្លែងលក់បង្អែមសៀមនោះ បានមួយសន្ទុះ ស្រាប់តែឃើញ បុរសម្នាក់ ជិះម៉ូតូមកឈប់នៅខាងមុខ រួចចុះដើរចូលមករកទទួលទានបង្អែម នោះដែរ។ ឡឹក សំអឿន ស្គាល់បុរសម្នាក់នោះច្បាស់ គឺអនុសេនីយ៍ទោ ឡុក ធិក ជាមិត្តភក្តិរបស់គាត់ កាលនៅរៀនវិទ្យាល័យព្រះស៊ីសុវត្ថិ ជាមួយគ្នា។ ពេលឃើញ ឡឹក សំអឿន ភ្លាម អនុសេ-នីយ៍ទោ ឡុក ធិក ក៏ស្ទុះមកឱបដោយក្តីនឹករឭក រួចនិយាយសំណេះសំណាលគ្នាក្នុងរយៈ ពេលខ្លី គាត់ក៏សុំលាឡឹក សំអឿន ទៅផ្ទះវិញបាត់ទៅ។

បន្តិចក្រោយមក ក៏មានរថយន្តហ្សីប មួយគ្រឿង មកឈប់ នៅខាងមុខកន្លែងលក់ បង្អែមសៀមនោះ ជាបន្តទៀត។ ពួកគេមានគ្នា៤នាក់ ចុះដើរចូលមក ដោយ៣នាក់ដើរទៅ អង្គុយនៅតុមួយផ្សេង ឯម្នាក់ទៀត ដើរតម្រង់មករកតុឡឹក សំអឿន រួចទាញកៅអី មក អង្គុយជិត ទើបឡឹក សំអឿន ស្គាល់ច្បាស់ថា គឺជាអតីតសហការី តស៊ូជាមួយគាត់ តែគេ បានចុះចូលជាមួយរាជរដ្ឋាភិបាលរបស់សម្តេចសីហនុ វិញហើយ។ បន្ទាប់ពីបានចុះចូល ជាមួយរាជរដ្ឋាភិបាលវិញ គេម្នាក់នេះ ត្រូវជាក្បួយរបស់ស្នងការនគរបាលខេត្តសៀមរាប ផង នោះ បានចូលបម្រើក្នុងអង្គភាពកងទ័ពពិសេសរបស់លន់ នល់ ពេលនោះ ជាអភិបាល ខេត្តបាត់ដំបង និងជាមេបញ្ជាការយោធភូមិភាគទី៣។

គេបានខ្សឹបប្រាប់ឡឹក សំអឿន ថា ពួកគេទាំង៤នាក់ បានទទួលបញ្ជាឲ្យតាមចាប់ ខ្លួនគាត់(ឡឹក សំអឿន) ដោយមានលិខិតចាប់ខ្លួនគាត់មកជាមួយផង។ ពួកគេត្រូវបែងចែក គ្នា ដោយ២នាក់ទៅចាំស្នាក់ចាប់នៅច្រកទ្វារប៉ោយប៉ែត ម្នាក់ទៀត ចាំស្នាក់ចាប់នៅសិរី-សោភ័ណ។ ចំណែករូបគេត្រូវទៅចាំស្នាក់ចាប់ នៅស្រុកព្រះនេត្រព្រះ និងស្រុកក្រឡាញ់។

គេបានសួរឡឹក សំអឿន ថា តើបងប្រុងចេញទៅតាមផ្លូវណា? គាត់ប្រាប់ដោយត្រង់ថា ទៅតាមស្រុកក្រឡាញ់។ គេថា ដូច្នេះស្រួលហើយ ព្រោះបេសកកម្មរបស់គេក៏ត្រូវទៅស្រុកក្រឡាញ់ នៅព្រឹកស្អែកនេះ តាមរថយន្តឈ្នួល ពីខេត្តបាត់ដំបង ទៅខេត្តសៀមរាបដែរ។

ពេលនោះ ឡឹក សំអឿន ក៏បានស្នើថា ដូច្នេះ បើប្អូនឯងអាចធ្វើដំណើរតាមរថយន្តជាមួយពួកបងបាន វាជាការប្រសើរណាស់ ព្រោះអាចជួយការពារ ពេលជួបកម្លាំងសមត្ថកិច្ចឆែកឆេររថយន្តរបស់ពួកបងតាមផ្លូវ។ បើប្អូនយល់ព្រម ម៉ោង៥ភ្លឺ សូមប្អូនមករង់ចាំបងនៅកន្លែងលក់បង្អែមនេះ។ លុះណាត់គ្នារួចហើយ ឡឹក សំអឿន ក៏នាំគ្នាគាត់ត្រលប់មកសម្រាកនៅផ្ទះខ្សែរយៈសម្ងាត់របស់គាត់វិញ។ តែដោយបារម្ភថា ភ្នាក់ងារសមត្ថកិច្ច ជាអតីតសហការីម្នាក់នោះ មិនហ៊ានចាប់គាត់ ដោយខ្លួនគេផ្ទាល់ ហើយប្រើល្បិចឲ្យគ្នាគេផ្សេងមកចាប់គាត់វិញនោះ ឡឹក សំអឿន មិនហ៊ានសម្រាកនៅផ្ទះខ្សែរយៈសម្ងាត់របស់គាត់នោះទេ គាត់សម្រេចចិត្តចេញទៅសម្រាកនៅផ្ទះខ្សែរយៈសម្ងាត់របស់គាត់ម្នាក់ទៀត ជាប្រធានស្ថានីយរថភ្លើងនៅប៉ោយប៉ែត ក្បែរគ្នានោះវិញ។

លុះព្រឹកឡើង ម៉ោង៥ភ្លឺស្រាងៗ ពួកគាត់ទាំង៣នាក់ ក៏លាម្ចាស់ផ្ទះ បើករថយន្តទៅផ្សារបាត់ដំបង រួចឈប់ត្រង់ខាងមុខកន្លែងលក់បង្អែម ជាកន្លែងណាត់ជួបគ្នា ក៏ឃើញអតីតសហការី ជាភ្នាក់ងារសម្ងាត់របស់លន់ នល់ ម្នាក់នោះនៅរង់ចាំមែន ក៏ហៅឡើងរថយន្តចេញដំណើរទាំងអស់គ្នា តែម្តងទៅ។

រហូតទៅដល់ស្ពានតាប៉ុន ជិតទៅដល់ប៉ុស្តិ៍ឆែកឆេរ នៅស្រុកក្រឡាញ់ ក៏ឈប់នៅទីនោះ ហើយឡឹក សំអឿន ក៏លា ញ៉ឹក ញ៉ុក និងគ្រូពេទ្យ ឈ្មោះផាន ព្រមទាំងអតីតសហការីជាភ្នាក់ងារសម្ងាត់របស់លន់ នល់ ម្នាក់នោះ ចុះដើរតែម្នាក់ឯងសំដៅទៅភូមិថ្មី ជាទីដែលគាត់បានណាត់ឱ្យសហការីរបស់គាត់៥នាក់ ជាអ្នកជូនដំណើរគាត់ទៅក្រុងភ្នំពេញ តាំងពីថ្ងៃទី១ ខែកញ្ញា ឱ្យមករង់ចាំគាត់ នៅភូមិថ្មី នោះ ។

៨៩
អំពើក្បត់របស់មេក្រុមឈ្មោះ ស្វី អឿន

ក្រោយពីបានជួបគ្នា ដូចការគ្រោងទុកមក ឡឹក សំអឿន ក៏ចាត់ឱ្យសហការី២នាក់នោះ ធ្វើដំណើរទៅភូមិត្រុំ ស្រុកសំរោងចុងកាល់ ប្រមូលសហការីឲ្យបាន១០នាក់ រួចឱ្យនាំគ្នាធ្វើដំណើរទៅជំរំប្រាសាទតាមាន់។ ចំណែកគាត់ និងសហការី៣នាក់ ទៅប្រមូលសហការីផ្សេងទៀត នៅភូមិថ្មគោល បានចំនួន៥ រួចបន្តដំណើរទៅដល់ភូមិគោកខ្ពស់ នៅវេលាម៉ោង ១០យប់ ប្រមូលសហការីបាន៥នាក់ថែមទៀត ហើយសម្រាកនៅភូមិគោកខ្ពស់នោះ មួយយប់។

លុះថ្ងៃរះឡើង ពួកគាត់ចាប់ផ្តើមចេញដំណើរ រហូតដល់ម៉ោង៩យប់ ទើបទៅដល់តំបន់ប្រាសាទតាមាន់ នៅលើភ្នំដងរែក ក៏ជួបនឹង សុខ មាន និងសហការី១១នាក់ ព្រមទាំងអ្នកចំណូលថ្មីម្នាក់ទៀត គឺអាចារ្យទុម ជាអតីតខ្មែរ-វៀតមិញ ទើបតែរត់គៀសខ្លួនពីការតាមចាប់របស់រាជការសម្តេចសីហនុ មកចូលជាមួយពួកគាត់។

ពេលនោះ សុខ មាន បានរាយការណ៍ប្រាប់គាត់ថា មុនថ្ងៃបោះឆ្នោត៣ថ្ងៃ កម្លាំងកងរាជអាវុធហត្ថនៅបន្ទាយឆ្មារ និងពួកទាហាននៅថ្មពួក បានលើកគ្នាមកហ៊ឹមព័ទ្ធជំរំគូនេះ។ តែគាត់បានដឹងមុន ក៏បាននាំគ្នាដកថយមកនៅជំរំប្រាសាទតាមាន់នេះ ដោយទុកតែសហការី ២នាក់ ឲ្យនៅចាំជំរំនោះ។ បន្តិចក្រោយមក កម្លាំងកងរាជអាវុធហត្ថនៅបន្ទាយឆ្មារ និងពួកទាហាននៅថ្មពួក ក៏បានលើកគ្នាមកព័ទ្ធជំរំគូ នោះមែន ហើយចាប់បានសហការី ២នាក់នោះ និងប្រមូលយកស្រូវប្រមាណ៥០០ថាំង រទេះ៤គ្រឿង ក្របី៤នឹម គោ៤នឹម ជ្រូក ១២ក្បាល និងមាន់ទា ជាច្រើនក្បាលទៀត។

សុខ មាន បានបញ្ជាក់ថា ហេតុការណ៍នេះ គាត់បានរាយការណ៍ទៅសឹង ង៉ុកថាញ់រួចហើយ ហើយសឹង ង៉ុកថាញ់ ក៏បានបញ្ជូនដំណឹងនេះទៅក្រុមដងរែកភ្នំពេញ ដឹកនាំដោយ អៀ ស៊ីចូវ ដើម្បីឱ្យជួយតវ៉ា ឱ្យរាជការសម្តេចសីហនុ ដោះលែងសហការី២នាក់នោះ

មកវិញ។

ក្រោយពីសម្រាកពេលបាយថ្ងៃត្រង់រួចមក នៅវេលាម៉ោង២រសៀល ឡឹក សំអឿន និងសហការី២រូបទៀត បានជិះសេះទៅជួបសឹង ង៉ុកថាញ់ នៅកន្លែងសម្ងាត់មួយ ចម្ងាយ ៥គីឡូម៉ែត្រ ពីជំរំអូរស្មាច់ ដោយមិនអ្នកណាដឹង ក្រៅពីអ្នករួមដំណើរ២នាក់នោះ។

ពេលទទួលទានបាយល្ងាច រួមមាន សឹង ង៉ុកថាញ់ ងួនហុង និងសហការីរបស់សឹង ង៉ុកថាញ់ ៤នាក់ទៀត ឡឹក សំអឿន បានរាយការណ៍ជូនសឹង ង៉ុកថាញ់ ពីសភាពការណ៍នៅទីក្រុងភ្នំពេញ ព្រមទាំងសំណើរបស់ក្រុមដងវែកភ្នំពេញ សុំកុំឲ្យបង្កការអុកឡុកនៅក្នុងពេលបោះឆ្នោត តែត្រូវធ្វើការបះបោរតវ៉ា ក្រោយពេលបោះឆ្នោតរួចនោះវិញ។

ក្រុមដងវែកភ្នំពេញ បានស្នើសុំថា ២អាទិត្យដំបូង សុំឱ្យយកបញ្ជីរាយឈ្មោះប្រជា-ពលរដ្ឋ នៅតាមមណ្ឌលបោះឆ្នោតនីមួយៗបញ្ជូនទៅឱ្យពួកគេនៅទីក្រុងភ្នំពេញ ដើម្បីធ្វើការតវ៉ា ហើយ២អាទិត្យក្រោយមកទៀត សូមឱ្យកម្លាំងតស៊ូនៅភ្នំដងវែក ចេញទៅឃោសនាប្រាប់ប្រជារាស្ត្រឱ្យបានដឹងថា ពួកសង្គមរាស្ត្រនិយមបានរំលោភបំពានទៅលើសិទ្ធិប្រជា-ពលរដ្ឋ និងបេក្ខជនរបស់គណបក្សប្រជាធិបតេយ្យ និងគណបក្សដទៃទៀត យ៉ាងអយុត្តិធម៌សាហាវយង់ឃ្នងបំផុត។

ស្អែកឡើង ក្រោយស្រស់ស្រូបអាហារពេលព្រឹករួច ឡឹក សំអឿន នាំគ្នាត្រលប់មកជំរំប្រាសាទតាមាន់ វិញ។ គាប់ជួនពេលនោះ មានសហការីរបស់គាត់ចំនួន១០នាក់ នៅចុងកាល់ បានមកដល់ដែរ។ គាត់ប្រជុំពិភាក្សាគ្នារៀបចំចេញដំណើរទៅឃោសនាតាមផែនការដូចបានគ្រោងទុក។ គាត់បានចែកគ្នាជា៨ក្រុមតូចៗ ក្នុងមួយក្រុមៗមានគ្នា៥នាក់ ហើយ ៤ក្រុមដឹកនាំដោយសុខ មាន ត្រូវចេញទៅមណ្ឌលបោះឆ្នោតនៅបន្ទាយឆ្មារ ខេត្តបាត់ដំបង។ ឯ៤ក្រុមទៀត មានរូបគាត់ផ្ទាល់ជាអ្នកដឹកនាំ ត្រូវចេញទៅមណ្ឌលបោះឆ្នោតនៅសំរោង ចុងកាល់ និងក្រឡាញ់ទឹកដោរ ក្នុងខេត្តសៀមរាប។

ឡឹក សំអឿន បានបញ្ជាក់ប្រាប់សហការីគាត់ថា ក្នុងរយៈពេល២អាទិត្យ ត្រូវស្រង់បញ្ជីស្រង់ឈ្មោះប្រជាពលរដ្ឋជាអ្នកបោះឆ្នោតឱ្យបាន ហើយយកប្រគល់មកឲ្យគាត់នៅភូមិ

ជីរក្រែង ស្រុកក្រឡាញ់ ខេត្តសៀមរាប ដើម្បីឲ្យគាត់ធ្វើរបាយការណ៍ និងបញ្ជីទាំងនោះ ទៅឱ្យក្រុមដងរែកភ្នំពេញ បន្តទៀត។

ក្នុងរយៈពេលតែ២អាទិត្យ ពួកគាត់ទាំង៨ក្រុម បានស្រង់បញ្ជីស្រង់ឈ្មោះប្រជាពលរដ្ឋជាអ្នកបោះឆ្នោតមណ្ឌលបន្ទាយឆ្មារ ព្រមទាំងមណ្ឌលសំរោងចុងកាល់ និងក្រឡាញ់ទឹកជោរ បានសម្រេចតាមផែនការ។ ក្រោយពីបញ្ជូនរបាយការណ៍ និងបញ្ជីទាំងនោះ ទៅឱ្យក្រុមដងរែកភ្នំពេញ រួចរាល់ហើយ ឡឹក សំអឿន និងសុខ មាន ព្រមទាំងសហការី៦នាក់ទៀត ក៏បានធ្វើដំណើរវិលត្រលប់ទៅដំរំប្រាសាទតាមាន់ វិញ និងបន្តធ្វើការយោសនាពីភូមិមួយទៅភូមិមួយទៀត ដើម្បីឱ្យអ្នកភូមិបានដឹងពីអំពើអយុត្តិធម៌ និងសកម្មភាពសាហាវឃោរ-ឃៅព្រៃផ្សៃរបស់ចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ក្នុងអំឡុងពេលយុទ្ធនាការយោសនារកសំឡេងឆ្នោត តាមការស្នើសុំពីក្រុមដងរែកភ្នំពេញ នោះ។

មិនយូរប៉ុន្មាន ស្រាប់តែមានហេតុការណ៍ក្បត់មួយ បានកើតឡើងនៅលើភ្នំដងរែក ដោយនៅជំរំអូរស្មាច់ មានមេក្រុមម្នាក់ឈ្មោះ ស្វី អឿន បានលួចទៅទាក់ទងជាមួយទាហានដាប ឈួន នៅបន្ទាយសំរោង។

ស្វី អឿន មានស្រុកកំណើតនៅភូមិសំរោង ស្រុកសំរោងចុងកាល់ ខេត្តសៀមរាប មានមុខរបរជាអ្នកជំនួញជួញដូរចុះឡើងទៅប្រទេសថៃ តាមរយៈឪពុកមារបស់គេម្នាក់រស់នៅស្រុកប្រាសាទ ខេត្តសុរិន្ទ។

ជំបូង ស្វី អឿន បានចូលបម្រើក្នុងក្រុមឥស្សរៈ កៅ តក់ មាននាទីជាមេកងទទួលបន្ទុកខាងសេដ្ឋកិច្ច។ នៅពេលប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ១៩៥២ ជននេះ បានចូលរៀនសាលាអប់រំនាយទាហានជំនាន់ទី២ ហើយមានតួនាទីជាមេក្រុមស្បៀង នៅទីបញ្ជាការកណ្តាល តាំងពីពេលនោះមក។

ស្វី អឿន មានប្អូនប្រុសម្នាក់ ឈ្មោះស្វី ធឿន ពីមុនមក ពុំដែលបានចូលបម្រើចលនាតស៊ូនេះទេ ទើបតែពេលថ្មីៗនេះ ស្វី អឿន បានហៅប្អូនប្រុសគេម្នាក់នេះឲ្យមកជួយការងាររបស់គាត់ នៅក្នុងក្រុមស្បៀង។ មុនបែកធ្លាយហេតុការណ៍ក្បត់នោះ ឡឹក សំអឿន កំពុង

ដើរយោសនានៅភូមិស្រីស្នំ ចម្ងាយពីភូមិចុងកាល់ ប្រហែល៦គីឡូម៉ែត្រ តាមដងស្ទឹងស្រែង គាត់បានទទួលដំណឹងថា សឹង ង៉ុកថាញ់ បានបញ្ជាមេកង ឈ្មោះស្វី អឿន ឱ្យដឹកនាំកម្លាំង ពីតំបន់អូរស្មោច់ ចំនួន៣០នាក់ ទៅជួយយោសនាគាត់។

ឮដូច្នេះ ឡឹក សំអឿន មានការងឿងឆ្ងល់យ៉ាងខ្លាំង ដ្បិតដឹងថា នៅតំបន់អូរស្មោច់ ទាំងមូល មានគ្នាតែ៤២នាក់ប៉ុណ្ណោះ ចុះបើ សឹង ង៉ុកថាញ់ បញ្ជូនកម្លាំងដល់ទៅ៣០នាក់ ឱ្យមកជួយយោសនាគាត់បែបនេះ គឺនៅសល់តែកម្លាំងតែ១២នាក់ប៉ុណ្ណោះ។ រឿងនេះ ដូចជាមិនសមហេតុផលសោះ ហើយសឹង ង៉ុកថាញ់ មិនគួរឱ្យស្វី អឿន នាំកម្លាំងដល់ទៅ ៣០នាក់ មកជួយគាត់ដូចនេះសោះ?

ដោយមានការសង្ស័យ ឡឹក សំអឿន ក៏បានចាត់សហការីគាត់ម្នាក់ មានមិត្តកក្តិ នៅក្នុងរបស់ក្រុមស្វី អឿន នោះដែរ ទៅប្រាប់ស្វី អឿន ឱ្យឈប់សម្រាកនៅភូមិតាវ៉ាក់ មាន ចម្ងាយ១៥គីឡូម៉ែត្រ ពីភូមិស្រីស្នំ ជាភូមិគាត់កំពុងស្នាក់នៅនោះសិន ដើម្បីស៊ើបការណ៍ ឱ្យដឹងច្បាស់ថា តើសឹង ង៉ុកថាញ់ ពិតជាបានបញ្ជូនកម្លាំង៣០នាក់នោះ ឱ្យមកជួយយោសនា គាត់ពិតមែនឬអត់?។

ពេលនោះ មិត្តកក្តិរបស់សហការីគាត់ម្នាក់ នៅក្នុងក្រុមនោះ បានរៀបរាប់ថា ពេល ស្វី អឿន នាំពួកគេចេញដំណើរពីដំរអូរស្មោច់មកនោះ មានគ្នា១៨នាក់ ក្នុងនោះមានស្វី ធឿន ជាប្អូនរបស់ស្វី អឿន ម្នាក់ដែរ ដោយទុកសហការី២នាក់ ឱ្យនៅចាំដំរ។ លុះមកដល់ ដំរអូរពក ស្វី អឿន ក៏យកកម្លាំង នៅអូរពកនោះ ចំនួន១២នាក់ មកជាមួយបន្ថែមទៀត។

លុះធ្វើដំណើរមកដល់ភូមិខ្ញុំ ក៏នាំគ្នាឈប់សម្រាក។ ពេលនោះ ស្វី អឿន និងស្វី ធឿន ក៏ប្រាប់ពួកគេថា ពួកគាត់ចូលទៅភូមិសំរោង ដើម្បីសួរសុខទុក្ខគ្រួសារបន្តិច ដោយ ទុកឱ្យពួកគេទាំងអស់ សម្រាកនៅក្នុងភូមិខ្ញុំ នោះ។ រហូតដល់ពេលល្ងាច ទើបបងប្អូន ទាំងពីរនាក់នោះ ត្រលប់មកវិញ។ ព្រឹកឡើង ស្វី អឿន ក៏នាំពួកគេចេញដំណើរទៅរកឡឹក សំអឿន កំពុងនៅភូមិស្រីស្នំ ។ តែមកដល់ភូមិតាវ៉ាក់ ក៏បានទទួលបញ្ជាពីឡឹក សំអឿន ឱ្យ ឈប់សម្រាកនៅភូមិតាវ៉ាក់ នេះមួយយប់សិន ។

ក្រោយពីបានដឹងរឿងនេះមក ស្មែកឡើង ឡឹក សំអឿន ក៏បានទៅជួបស្វី អឿន នៅភូមិតាវ៉ាក់ នោះ និងឲ្យយោបល់ថា ដើម្បីងាយស្រួលក្នុងការដោះស្រាយស្បៀងអាហារ យើងត្រូវតែបំបែកកម្លាំង។ ម៉្យាងទៀត ពួកយើងមកនេះ គឺគ្រាន់តែធ្វើការយោសនាប៉ុណ្ណោះ គឺមិនប្រើអាវុធបង្ហូរឈាមខ្មែរគ្នាឯងទេ។ បន្ទាប់មក ឡឹក សំអឿន ក៏បញ្ជាឱ្យស្វី អឿន ដឹកនាំកម្លាំងរបស់គេទាំង៣០នាក់នោះ ទៅដើរយោសនានៅតាមភូមិមួយចំនួន នៅម្តុំថ្មគោល រួចហើយឱ្យត្រលប់ទៅជំរំអូរស្មាច់ វិញ។ ចំណែកខ្លួនគាត់(ឡឹក សំអឿន) ត្រូវនាំកម្លាំងចេញទៅដើរយោសនានៅភូមិគោគរមៀត រួចបន្តទៅភូមិអន្លង់វែង ទៀត ទើបវិលត្រលប់ទៅជំរំអូរស្មាច់ វិញដែរ។

ក្រោយពេលដាក់បញ្ជារួច ឡឹក សំអឿន ក៏ចេញដំណើរទៅភូមិគោករមៀត មានចម្ងាយ៥គីឡូម៉ែត្រ ពីភូមិតាវ៉ាក់ នោះ ហើយនៅថ្ងៃនោះដែរ មានមីងម្នាក់ឈ្មោះយុន ជាអតីតមេក្រុមនារីក្លាហានរបស់ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ បានមកជួបសួរសុខទុក្ខកូនគាត់ ជាយុទ្ធជននៅក្នុងក្រុមស្វី អឿន ក្នុងភូមិតាវ៉ាក់ នោះដែរ បានឆ្លៀតឱកាសទៅជួប ឡឹក សំអឿន នៅតាមដងស្ទឹងស្រែង ខាងលើភូមិគោករមៀត ហើយប្រាប់ថា គាត់បានឃើញស្វី អឿន ចូលរួមបាយទឹកថ្ងៃត្រង់ជាមួយអនុសេនីយ៍ឯក ឈ្មោះស្រី ជាប្អូនរបស់ ដាប ឈួន និងជាមេបញ្ជាការទាហាន នៅបន្ទាយសំរោង ធ្វើឱ្យឡឹក សំអឿន កាន់តែមានការសង្ស័យខ្លាំងថែមទៀត។

ពេលនោះ ឡឹក សំអឿន គិតថា ស្វី អឿន ចូលរួមបាយទឹកថ្ងៃត្រង់ជាមួយអនុសេនីយ៍ឯក ឈ្មោះស្រី ជាប្អូនរបស់ ដាប ឈួន ដែលមីងយុន ប្រាប់នោះ ជារឿងពិតតែបើសិនជាគាត់នាំកម្លាំងទាំងអស់ កាត់ព្រៃតម្រង់ទៅភ្នំដងរែក តែម្តង ច្បាស់ជាមានបញ្ហាស្បៀងជាមិនខាន។ ម៉្យាងទៀត បើហ៊ានតតាំងជាមួយស្វី អឿន ដោយកម្លាំងអាវុធ ក៏ពុំអាចធ្វើទៅកើតដែរ។ គាត់ក៏សម្រេចចិត្តបញ្ជូនកម្លាំងរបស់គាត់២៤នាក់ ឱ្យទៅរួមសហការជាមួយកម្លាំងរបស់ស្វី អឿន នៅភូមិតាវ៉ាក់ នោះវិញ តែក្នុងចំណោមកម្លាំង២៤នាក់នោះ គាត់បានចាត់ឱ្យសហការីជំនិតរបស់គាត់២នាក់ ធ្វើជាកម្លាំងបង្កប់ ដើម្បីស៊ើបការណ៍ពីស្វី

អឿន ផងដែរ។

មិនយូរប៉ុន្មាន អ្នកស៊ើបការណ៍២នាក់របស់គាត់នោះ បានលួចមកប្រាប់គាត់ថា ពួក ស្វី អឿន បានចូលរួមជប់លៀងផឹកស៊ីរាំរែកយ៉ាងគគ្រឹកគគ្រែង ជាមួយអនុសេនីយ៍ឯក ឈ្មោះស្រី ជាប្អូនដាប ឈួន នៅភូមិតាប៉ាក់ នោះពិតមែន។

ឡឹក សំអឿន ក៏ប្រាប់សហការីជំនិតរបស់គាត់២នាក់នោះថា បើសិនជាពួកស្វី អឿន នាំកម្លាំងធ្វើដំណើរទៅភ្នំដងរែក ឯងទាំង២នាក់ ត្រូវតែទាក់ទងគ្នាយើងនៅជំរំខ្លាឃ្មុំ។ រួចគាត់ក៏ឱ្យសហការីជាអ្នកស៊ើបការណ៍ ២នាក់នោះត្រលប់ទៅភូមិតាប៉ាក់ ដែលស្វី អឿន កំពុងស្នាក់នៅនោះវិញ។

៩០
ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ត្រូវរលាយទាំងស្រុង



ឡឹក សំអឿន

ចំណែក ឡឹក សំអឿន និងសហការី៥នាក់ទៀត ក៏បានធ្វើដំណើរឡើងតាមច្រកគោកព្រីង ទៅដល់ជំរំអូរស្មាច់ នៅវេលាម៉ោង៤ទៀបភ្លឺ ស្រាប់តែឃើញជំរំអូរស្មាច់ ក្លាយទៅជាគំនរផេះ ដោយសារភ្លើងឆេះខ្ទេចខ្ទីអស់ទៅហើយ គាត់ក៏បន្តដំណើរទៅជំរំខ្លាឃ្មុំ ជាជំរំរបស់ ងួន ហុង ស្នាក់នៅ ក៏ឃើញភ្លើងឆេះអស់ នៅសល់តែគំនរផេះដូចជំរំអូរស្មាច់ ដែរ។

ពួកគាត់ក៏នាំគ្នាសម្រាកក្នុងព្រៃក្បែរនោះមួយយប់ រួចចាត់ឱ្យសហការី២នាក់ លួចចូលទៅក្នុងភូមិដាន នៅក្នុងទឹកដីថៃ ជាភូមិមួយមានគ្រួសារ កៅ តក់ និងអតីតខ្មែរឥស្សរៈមួយក្រុមរស់នៅ។

លុះម៉ោង៦ព្រឹក សហការី២នាក់នោះ ត្រលប់មកវិញ មានទាំងសហការីរបស់ងួន ហុង ម្នាក់ មកជាមួយផង ទើបដឹងថា ជំរំអូរស្មាច់ និងជំរំខ្លាឃ្មុំ ត្រូវភ្លើងឆេះនៅសល់តែគំនរផេះនោះ គឺពួកគាត់ជាអ្នកដុតបំផ្លាញចោល ដោយខ្លួនឯង ដើម្បីគេចខ្លួនទៅរកកន្លែងថ្មី ក្រោយពីដឹងច្បាស់ជាមុនថា ក្រុមស្វី អឿន នាំកម្លាំងរាជរដ្ឋាភិបាល ចូលមកវាយកម្ទេច ។

ឡឹក សំអឿន ក៏បានធ្វើដំណើរទៅរកកន្លែងថ្មីរបស់ងួន ហុង ស្ថិតនៅត្រង់អតីតទីតាំងស្ថានីយវិទ្យុផ្សាយសំឡេងភ្នំដងរែក ពីមុននោះ ឃើញតែ ងួន ហុង សៃហ្វឃីម និង សឹង ផាត ជាដើម។ តែពុំឃើញ សឹង ង៉ុកថាញ់ ទេ ពីព្រោះគាត់បានកៀសខ្លួន ចូលទៅក្នុងទឹកដីសៀម តាំងពីថ្ងៃដឹងថា ស្វី អឿន ក្បត់នោះ ។

ពេលរត់កៀសខ្លួន ចូលទៅក្នុងទឹកដីថៃ សឹង ង៉ុកថាញ់ ក៏នាំយករថយន្តហ្សេអឹមសេ ចំនួន៣គ្រឿង, រថយន្តកាត់កាត់(4×4) ១គ្រឿង, រថយន្តហ្ស៊ីប ១គ្រឿង ព្រមទាំងគោ ៣០ ក្បាល ទៅជាមួយ ដោយមានក្នាក់ងារសម្ងាត់ថៃ ម្នាក់ជួយសម្របសម្រួលជាមួយទាហានថៃ នៅព្រំដែនផងដែរ។ តែសឹង ង៉ុកថាញ់ បានឱ្យក្រុមងួន ហុង នៅរង់ចាំទទួលក្រុមឡឹក សំអឿន ត្រលប់ពីឃោសនាវិញ នៅត្រង់អតីតទីតាំងស្ថានីយវិទ្យុផ្សាយសំឡេងភ្នំដងរែកនេះ។

នៅថ្ងៃដដែលនោះ ឡឹក សំអឿន បានចាត់ឱ្យ សឹង ផាត ទៅជួបសឹង ង៉ុកថាញ់ នៅក្នុងទឹកដីសៀម ដើម្បីរាយការណ៍ និងទទួលផែនការថ្មី ត្រូវធ្វើបន្តទៀតដែរ តែក្នុងពេលនោះ ក៏បានទទួលដំណឹងថា ស្វី អឿន បាននាំកម្លាំងរាជរដ្ឋាភិបាល ឡើងមកលើភ្នំដងរែកហើយដែរ។ ពីរថ្ងៃក្រោយមក សហការីជំនិតរបស់គាត់២នាក់ ជាកម្លាំងបង្កប់នៅក្នុងក្រុមក្បត់ស្វី អឿន បានលួចមកជួបគាត់នៅជំរំខ្លាឃ្មុំ តាមផែនការដែលគាត់បានដាក់ឱ្យពីមុននោះ ហើយបានរាយការណ៍ប្រាប់គាត់ថា ស្វី អឿន និងកម្លាំងក្បត់ចុះចូលជាមួយរាជរដ្ឋាភិបាលទាំងអស់ ព្រមទាំងកងរាជតម្រួត១២នាក់ទៀត បានចូលមកដល់ជំរំអូរស្មោច់ និងជំរំខ្លាឃ្មុំ ដែលនៅសល់តែគំនរផេះនោះហើយ និងកំពុងរុករកកន្លែងកប់អាវុធរបស់ពួកគាត់ និងសាងសង់បន្ទាយកងរាជតម្រួតមួយ នៅលើទីតាំងនៅសល់តែគំនរផេះនោះទៀតផង។

ពេលនោះ ឡឹក សំអឿន ក៏បានសួរបញ្ជាក់ពីទីកន្លែង ស្វី អឿន ដេកសម្រាកពេលយប់ផងដែរ កម្លាំងបង្កប់របស់គាត់ទាំង២នាក់នោះ ប្រាប់ថា ស្វី អឿន និងស្វី ធឿន តែងតែដេកសម្រាកជាមួយកងរាជតម្រួត១២នាក់ទៀត នៅខាងលិចអូរ ក្រោមដើមស្វាយព្រៃមួយដើម ចម្ងាយប្រហែល១០ម៉ែត្រពីថ្មដាមួយផ្ទាំង។

ក្រោយពីដឹងពីទីកន្លែង ស្វី អឿន ដេកសម្រាកពេលយប់ហើយ គាត់ក៏ប្រាប់កម្លាំងបង្កប់របស់គាត់ទាំង២នាក់នោះថា យប់នេះ គាត់នឹងនាំគ្នាទៅបាញ់សម្លាប់ ស្វី អឿន នៅកន្លែងដេកសម្រាកនៅក្រោមដើមស្វាយព្រៃនោះ ដូច្នេះបើឮសូរផ្ទុះគ្រាប់កាំភ្លើង ត្រូវនៅស្ងៀមទៅបានហើយ មិនចាំបាច់ធ្វើអ្វីទៀតទេ។

បន្ទាប់មក នៅវេលាម៉ោង៨យប់ ឡឹក សំអឿន បាននាំ ងួន ហុង សៃហ្វយីម និងយុទ្ធជន៣នាក់ទៀត ទៅលបបង្កប់ខ្លួន នៅក្នុងព្រៃខាងលិចអូរ ខាងជើងរោងជំរំឆេះអស់នោះ។ លុះដល់ម៉ោង១០យប់ ក៏នាំគ្នាលូនចូលទៅត្រង់ថ្មជាមួយផ្នាំងធំនោះ ហើយបាញ់រះដោយកាំភ្លើងស្វ័យប្រវត្តិ គ្រប់ៗគ្នា និងចោលគ្រាប់បែកដៃបន្ថែមទៀត ទៅក្រោមដើមស្វាយព្រៃ ដែលកម្លាំងបង្កប់បានប្រាប់ថា ស្វី អឿន ដេកសម្រាកនៅខាងក្រោមនោះ រួចក៏នាំគ្នាដកថយវិញភ្លាមៗ។

ស្អែកឡើង រហូតដល់វេលាម៉ោង៦ព្រលប់ ទើបកម្លាំងបង្កប់នោះរាយការណ៍មកថា ក្នុងការលបបាញ់ប្រហារនោះ មាននាយតម្រួតម្នាក់ស្លាប់ តម្រួត២នាក់ទៀត ត្រូវរបួស។ ចំណែក ស្វី អឿន និងស្វី ធឿន ក្នុងពេលពួកគាត់បាញ់ប្រហារនោះ ពួកគេទាំង២នាក់បានចុះទៅបាញ់សត្វ នៅខាងជើងភ្នំ បាត់អស់ទៅហើយ តែរបស់របរនៅកន្លែងពួកគេដេកសម្រាកនោះ ត្រូវឆ្ពុះឆ្លាយខ្ទេចខ្ទីអស់ ដោយត្រូវគ្រាប់កាំភ្លើង។

ក្រោយពីការលបទៅបាញ់ប្រហារនោះ ស្វី អឿន ខឹងខ្លាំងណាស់ បម្រុងនឹងរៀបចំកងកម្លាំងមករកតាមកម្ទេចពួកឡឹក សំអឿន វិញដែរ តែមិនដឹងថា ពួកឡឹក សំអឿន លាក់ខ្លួននៅកន្លែងណា។ បីថ្ងៃ ក្រោយមកទៀត សឹង ផាត ក៏បានត្រលប់មកពីទឹកដីថៃវិញ ដោយនាំយកសំបុត្រមួយច្បាប់ពីសឹង ង៉ុកថាញ់ មកជាមួយផង។ នៅក្នុងសំបុត្រនោះ សឹង ង៉ុកថាញ់ បានសរសេរបញ្ជាឲ្យឡឹក សំអឿន រំសាយកងទ័ពទាំងអស់ ឲ្យទៅរស់នៅតាមស្រុកកំណើតរបស់ពួកគេវិញ ហើយឱ្យជីកដីកប់លាក់អាវុធទាំងអស់ ឱ្យបានត្រឹមត្រូវ។

ចំណែកកងទ័ពណាមិនអាចត្រលប់ទៅស្រុកកំណើតខ្លួនវិញបាន គប្បីធ្វើការទាក់ទងគ្នា ដើម្បីឱ្យពួកគេបានចូលទៅរស់នៅក្នុងភូមិដាន ក្នុងទឹកដីថៃ។ បន្ទាប់មក ឡឹក សំអឿន

បានសរសេរលិខិតមួយប្រគល់ឲ្យសហការីរបស់គាត់៥នាក់ មានលំនៅភូមិគោគខ្ពស់ ដើម្បីយកទៅឱ្យ សុខ មាន នៅជំរំប្រាសាទតាមាន់ ហើយគាត់ក៏បានទាក់ទងជាមួយកម្លាំងបង្កប់របស់គាត់២នាក់ កំពុងនៅជាមួយក្រុមក្បត់ ស្វី អឿន ឲ្យបានដឹងពីរឿងនេះដែរ។

នៅថ្ងៃទី៧ ខែ វិច្ឆិកា ឆ្នាំ១៩៥៥ ឡឹក សំអឿន និងសហការី១១នាក់ បានឆ្លងព្រំដែន ចូលទៅស្នាក់នៅក្នុងភូមិដាន ក្នុងទឹកដីថៃ ព្រោះក្នុងចំណោមសហការីរបស់គាត់ទាំង១១ នាក់ មាន៨នាក់ មានក្រុមគ្រួសាររស់នៅក្នុងភូមិដាន នោះ តែម្តង។

បន្ទាប់មកទៀត ឡឹក សំអឿន, ងួន ហុង, សៃហ្វយីម និងសឹង ផាត បានធ្វើដំណើរទៅដល់ក្រុងបាងកក នៅថ្ងៃទី៩ ខែ វិច្ឆិកា ដោយបានស្នាក់នៅកុដិរបស់លោកគ្រូអាចារ្យ ចន្ទ ក្នុងវត្តស៊ីសាកេត ដោយនៅទីនោះ មានឈ្មោះខៀវ ណយ ជាប្អូនប្រុសរបស់លោកគ្រូអាចារ្យខៀវ ជុំ កំពុងស្នាក់នៅផងដែរ។

ស្អែកឡើង ទើបពួកគាត់ទាំង៤នាក់ នាំគ្នាធ្វើដំណើរទៅជួបសឹង ង៉ុកថាញ់។ ពេលនោះ សឹង ង៉ុកថាញ់ បាននិយាយថា ៖

ទី១. គាត់ស្តាយណាស់ ដោយសារគាត់មានពេលវេលាខ្លីពេក ក្នុងការតស៊ូក្នុងព្រៃ ពុំអាចមានពេលវេលាអប់រំប្រជាពលរដ្ឋយើងឲ្យមានការភ្ញាក់រឭក ឲ្យមានស្មារតីសតិសម្បជញ្ញៈជាអ្នកស្នេហាជាតិ ឱ្យបានទូលំទូលាយ។

ទី២. ក្រោយប្រទេសយើងទទួលបានឯករាជ្យ គាត់សង្ឃឹមថា ខ្មែរយើងអាចនឹងរួបរួមគ្នាគ្រប់និន្នាការនយោបាយក្នុងសង្គមជាតិ អាចពិភាក្សាគ្នារៀបចំគោលនយោបាយជាតិមួយ ឲ្យស្របទៅនឹងគោលបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរ កំពុងមានការខ្វះខាត ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ពោលគឺនយោបាយដោះស្រាយបញ្ហាទុក្ខវេទនារបស់ជាតិខ្មែរ នៅក្នុងប្រទេស ព្រមទាំងបញ្ហានៅក្រៅប្រទេស ត្រូវធ្វើនយោបាយមួយឱ្យមានដំណើរសមស្រប ទៅនឹងស្ថានការណ៍នយោបាយក្នុងតំបន់ ព្រមទាំងឱ្យសមស្របទៅនឹងស្ថានការណ៍នយោបាយសកលលោក ផងដែរ។

ទី៣. កំហុសធ្ងន់របស់ពួកយើង គឺយើងខ្លាចស្លាប់ពេក មិនហ៊ានចេញមុខឲ្យច្បាស់

ក្នុងសម័យបោះឆ្នោត កាលពីខែកញ្ញាកន្លងទៅ យើងស្នាក់ស្នើរមិនចូលប្រកួតប្រជែងជាមួយនឹងគេ។ ឥឡូវ យើងចាញ់គេហើយនោះ តើយើងនៅតវ៉ាអ្វីទៀត?

ដោយសារហេតុផលដូចខាងលើនេះហើយ បានជាគាត់(សឺង ង៉ុកថាញ់) សុខចិត្តសោយកងទ័ពចោល ហើយទុកឱកាសឲ្យក្រុមដងរែកភ្នំពេញ នាំគ្នារួបរួមជួយធ្វើការរាជរដ្ឋាភិបាលរបស់សម្តេចសីហនុ ទៅចុះ។ តែបើថ្ងៃណាមួយ ចលនាសង្គមរាស្ត្រនិយម ក្រោមការដឹកនាំរបស់សម្តេចសីហនុ ដើរនយោបាយខុស នាំឲ្យប្រទេសជាតិខ្មែរធ្លាក់ចុះទៅក្នុងក្រឡាអុករបស់យួនវៀតមិញ បានដៅទុកនោះ ពួកគាត់នឹងនាំគ្នារិះរកមធ្យោបាយធ្វើសកម្មភាពសាជាថ្មីទៀត ដើម្បីតម្រែតម្រង់ឲ្យរាជរដ្ឋាភិបាល ដើរត្រង់ជ្រុងត្រង់ជ្រោយឡើងវិញ។

សឺង ង៉ុកថាញ់ បញ្ជាក់ថា ស្ថានការណ៍ស្រុកទេសយើងនាពេលនេះ ពួកគាត់ទាំងអស់គ្នា មិនអាចចូលទៅរួមរស់នៅក្នុងសង្គមជាតិបានទេ ដូច្នេះ ត្រូវតែលាក់ខ្លួនពួនអាត្មានៅប្រទេសថៃ ជាបណ្តោះអាសន្នរៀងៗខ្លួនសិន តាមការដែលអាចធ្វើទៅបាន ហើយទៅថ្ងៃក្រោយ បើមានហេតុការណ៍អ្វីកើតឡើង គាត់នឹងធ្វើការទាក់ទងឲ្យជឹងគ្រប់គ្នា។

នេះជាទីបញ្ចប់នៃការតស៊ូរបស់ប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ដឹកនាំដោយសឺង ង៉ុកថាញ់ ជាចលនាអ្នកជាតិនិយម តស៊ូដើម្បីយកឯករាជ្យជូនមាតុប្រទេសផង ហើយក៏ប្រឆាំងនឹងសម្តេចសីហនុ ផងដែរ។

តែទោះបីប្រជាចលនាឥស្សរៈខ្មែរបម្រើជាតិ ត្រូវបញ្ចប់សកម្មភាពរបស់ខ្លួនទៅហើយក៏ដោយ ក៏តុលាការសឹកនៅក្រុងភ្នំពេញ បានប្រកាសកាត់ទោសកំបាំងមុខឱ្យឡឹក សំអឿន ជាប់ពន្ធនាគារយៈពេល២៥ឆ្នាំដែរ។

៩១
សម្តេចសីហនុ ជួប ជូ អេនឡាយ ជាលើកដំបូង



សម្តេចសីហនុ និងជូ អេនឡាយ ព្រមទាំងមេដឹកនាំប្រទេសផ្សេងទៀត ក្នុងសន្និសីទនៅទីក្រុងបានឌុង

នៅថ្ងៃទី១៨ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៥ សម្តេចសីហនុ ដោយមានប៉ែន នុត, សឺន សាន និងឥស្សរជនមួយចំនួនទៀត អមព្រះរាជដំណើរ ព្រមទាំងមាន ភួង ម៉ាហ្គាំង ជាអ្នកបកប្រែផងនោះ បានយាងទៅចូលរួមសន្និសីទរបស់ប្រជាជាតិអាស៊ី និងអាហ្វ្រិក ប្រារព្ធធ្វើឡើង នៅទីក្រុងបានឌុង(Bandung) ប្រទេសឥណ្ឌូណេស៊ី។ សន្និសីទនៅទីក្រុង បានឌុង(Bandung) នេះ មានប្រទេសចំនួន២៥ ចូលរួម គឺប្រទេសកម្ពុជា, ឡាវ, សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម(វៀតណាមខាងជើង), រដ្ឋវៀតណាម (វៀតណាមខាងត្បូង), អាហ្វហ្កានីស្តាន, សាធារណរដ្ឋប្រជាមានិតចិន, អេហ្ស៊ីប, អេត្យូពី, ហ្គោលខូស្ត (Gold Coast), អឺរ៉ុង់, អ៊ីរ៉ាក់, ជប៉ុន, ហ៊្សកដង់, លីបង់, លីបេរីយ៉ា, លីប៊ី, ស៊ីរី, ថៃ, តួកគី, យេម៉ែន, នេប៉ាល់, ហ្វីលីពីន, អាប៉ាប៊ីសាអូឌីត និងឥណ្ឌូណេស៊ី ជាម្ចាស់ផ្ទះ។

សន្និសីទនេះ កើតឡើងដោយគំនិតផ្តួចផ្តើមរបស់ប្រទេសឥណ្ឌូណេស៊ី ឥណ្ឌា ប៉ាគីស្ថាន និងស្រីលង្កា ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច និងវប្បធម៌ រវាងបណ្តាប្រទេសនៅទ្វីបអាស៊ី និងបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក ឱ្យកាន់តែល្អប្រសើរថែមទៀត និងរួមគ្នាប្រឆាំងចំពោះអាណានិគមនិយមបែបថ្មី ព្រមទាំងប្រឆាំងចំពោះប្រទេសបារាំង កំពុងធ្វើអាណានិគមលើប្រទេសមួយចំនួន នៅទ្វីបអាហ្វ្រិក ពិសេស នៅប្រទេសអាល់ហ្សេរី។ ជាមួយគ្នានោះ សន្និសីទរបស់ប្រជាជាតិអាស៊ី និងអាហ្វ្រិក ក៏បានបោះដំហានដ៏សំខាន់មួយ ឆ្ពោះទៅរកការបង្កើតចលនាបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធផងដែរ។

តាមរយៈសន្និសីទនោះដែរ មេដឹកនាំចិន ក៏បានឆ្លៀតឱកាសពង្រីកទំនាក់ទំនងការទូត ជាមួយបណ្តាប្រទេសនៅអាស៊ី បានមួយចំនួនថែមទៀត សំខាន់គឺប្រទេសកម្ពុជា។

ពេលយាងទៅចូលរួមក្នុងសន្និសីទនេះ សម្តេចសីហនុ ទើបតែចុះពីលើរាជបល្ល័ង្កថ្មីៗ ដើម្បីចូលប្រឡូកក្នុងឆាកនយោបាយ បានថ្លែងប្រាប់ជូ អេនឡាយ នាយករដ្ឋមន្ត្រីចិន និង ផាំ វ៉ាន់ដុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមថា ថ្វីដ្បិតតែព្រះអង្គយល់ព្រមទទួលជំនួយយោធា និងសេដ្ឋកិច្ចពីសហរដ្ឋ អាមេរិក ក៏ពិតមែន តែពុំមែនបានន័យថា ព្រះអង្គអនុញ្ញាតឱ្យមានវត្តមានកងទ័ពអាមេរិក នៅលើទឹកដីកម្ពុជានោះទេ ហើយព្រះអង្គក៏មិនចង់ដាក់ប្រទេសកម្ពុជា ឱ្យស្ថិតនៅក្រោមឆត្រការពាររបស់អង្គការសេអាតូ (SEATO) ជាអង្គការប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត នៅអាស៊ីអាគ្នេយ៍នោះដែរ។ សម្តេចសីហនុ បានក្លាយជាសមាជិកស្ថាបនិកទី៥ របស់ចលនាបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធ ហើយមានព្រះកិត្តិយសលេចធ្លោជាងគេ នៅក្នុងសន្និសីទ នោះ។

នៅទីបំផុត អង្គសន្និសីទទាំងមូល បានអនុម័តគោលការណ៍ដ៏រឹងមាំទាំង៥ ស្តីពីការរួមរស់ជាមួយគ្នា ដោយសុខសន្តិភាព ឬហៅថាគោលការណ៍បញ្ចសីលា រួមមានជំនឿសាសនា ជាតិនិយម ភាតរសាកល យុត្តិធម៌សង្គម និងលទ្ធិប្រជាធិបតេយ្យ។

ដោយសារសន្និសីទ នៅក្រុងបានឌុង នេះហើយ ទើបសម្តេចសីហនុ មានឱកាស

បានជួបជាលើកដំបូង ជាមួយនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ និងឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីការបរទេសវៀតណាមខាងជើង ផាំ វ៉ាន់ដុង ។

នៅក្នុងជំនួបទ្វេភាគី នៅក្រុងបានឌុង នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានទូល សួរសម្តេចសីហនុ ថា៖ « តើព្រះអង្គអនុញ្ញាតឱ្យសហរដ្ឋអាមេរិក កសាងមូលដ្ឋានយោធា ឬចុះហត្ថលេខាចងជាសម្ព័ន្ធមិត្តជាមួយអាមេរិក ដែរឬទេ ?» សម្តេចសីហនុ បានឆ្លើយតប ថា ព្រះអង្គមិនអនុញ្ញាតឱ្យមានការកសាងមូលដ្ឋានយោធាណាមួយរបស់សហរដ្ឋអាមេរិក នៅលើទឹកដីកម្ពុជា ដែលធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យជាតិ និងអព្យាក្រឹតភាពរបស់កម្ពុជា ជាជាច់ខាត »។

ជូ អេនឡាយ បានសម្តែងការពេញចិត្តយ៉ាងខ្លាំង ចំពោះចម្លើយរបស់សម្តេចសីហនុ ដូចខាងលើនេះ ហើយបានបញ្ជាក់តបមកព្រះអង្គវិញថា៖ «កម្ពុជា មានសិទ្ធិពេញលេញ ក្នុងការការពារមាតុភូមិរបស់ខ្លួន និងអាចអំពាវនាវស្នើសុំជំនួយពីបរទេសបាន»។

ជំនួបរវាងសម្តេចសីហនុ ជាមួយនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ជាលើកដំបូង នេះ អាចចាត់ទុកថា ជាចំណុចផ្តើមនៃការអនុវត្តគោលនយោបាយអព្យាក្រឹតរបស់ព្រះអង្គ ដើម្បីឱ្យមានតុល្យភាពស្តីពីទំនាក់ទំនងរវាងប្លុកមនោគមន៍វិជ្ជាទាំងពីរ គឺប្លុកលោកសេរី និង ប្លុកកុម្មុយនិស្ត ហើយក៏ជាថ្ងៃដំបូង ដែលសម្តេចសីហនុ ចាប់ផ្តើមផ្សារទំនាក់ទំនងជាមួយ សាធារណរដ្ឋប្រជាមានិតចិន ផងដែរ ។

៩២
យុទ្ធនាការយោសនា
កេង វ៉ាន់សាក់ រងការបាញ់ប្រហារ



កេង វ៉ាន់សាក់ យោសនារកសំឡេងឆ្នោត

នៅពេលការសែតរបស់គណបក្សប្រជាជន ត្រូវអាជ្ញាធរ លែងឱ្យចេញផ្សាយ និងចាប់និពន្ធនាយក យកទៅកាត់ទោសដាក់ពន្ធនាគារនោះ កាសែតប្រជាធិបតេយ្យរបស់គណបក្សប្រជាធិបតេយ្យ មិនមានបញ្ហាអ្វីទេ គឺនៅចេញផ្សាយជាធម្មតា។ ប៉ុន្តែ បេក្ខជនតំណាងរាស្ត្រគណបក្សប្រជាធិបតេយ្យ ឈ្មោះ សារិន តុង ត្រូវកម្លាំងសមត្ថកិច្ចចាប់ខ្លួន ហើយមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀត ក៏ត្រូវរងការគំរាមកំហែងផងដែរ។

នៅក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាធិបតេយ្យ មានមួយក្រុម ជាអ្នកប្រកាន់និន្នាការស្តាំនិយម និងមួយក្រុមទៀត ជាអ្នកប្រកាន់និន្នាការឆ្វេងនិយម។ ពួកឆ្វេងនិយមនេះ ក៏មានគំនិតដូចមេដឹកនាំ គណបក្សប្រជាជនដែរ ពួកគេយល់ឃើញថា បើឈ្នះឆ្នោត ពួកគេនឹងធ្វើការអភិវឌ្ឍប្រទេស ដោយឈរលើមូលដ្ឋានលទ្ធិសង្គមនិយម និងពង្រីកទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសសង្គមនិយមទាំងអស់ នៅលើសាកលលោក។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ មានប្រៀបជាងគណបក្សនយោបាយទាំងអស់ ជាគូប្រកួតរបស់ខ្លួនដែរ សូម្បីតែគណបក្សប្រជាធិបតេយ្យ ធ្លាប់តែឈ្នះឆ្នោតភ្លូកទឹកភ្លូកដី តាំងពីឆ្នាំ១៩៤៧ មកនោះ ក៏មានការស្រុតចុះនៅសល់អ្នកគាំទ្របន្តិចបន្តួចប៉ុណ្ណោះ ដោយសារតែចលនាសង្គមរាស្ត្រនិយមមានរាជរដ្ឋាភិបាលកាន់អំណាច មានកម្លាំងកងទ័ព និងនគរបាលទាំងអស់ នៅក្នុងកណ្តាប់ដៃស្រាប់។

ជាមួយគ្នានោះ មន្ត្រីរាជការនៅតាមក្រសួងនានា ជាសកម្មជនរបស់គណបក្សប្រជាធិបតេយ្យ ជាង១០០នាក់ ត្រូវបាត់បង់តំណែង និងតួនាទី ដោយសារតែពួកគេរឹងទទឹងមិនព្រមចូលរួមក្នុងចលនាសង្គមរាស្ត្រនិយម។ សម្តេចសីហនុ បានប្រកាសប្រាប់ប្រជារាស្ត្រថា មេដឹកនាំគណបក្សប្រជាជនទាំងអស់ សុទ្ធតែជាពួកកុម្មុយនិស្តគ្មានសាសនា ។

នៅក្នុងការឃោសនារកសំឡេងឆ្នោត បេក្ខជនឈរឈ្មោះតំណាងរាស្ត្ររបស់គណបក្សប្រជាធិបតេយ្យ និងគណបក្សប្រជាជន ព្រមទាំងអ្នកបោះឆ្នោតគាំទ្រផងដែរ ត្រូវរងនូវការគំរាមកំហែង និងចាប់ខ្លួន។

បេក្ខជនរបស់គណបក្សប្រជាជន ៣រូប ត្រូវចាប់ដាក់ពន្ធនាគារ ហើយសកម្មជនរបស់គណបក្សប្រជាជន ២០នាក់ទៀត ត្រូវបានគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) រាយការណ៍ថា ត្រូវបានអាជ្ញាធរចាប់ខ្លួន ក្នុងនោះមានឈ្មោះ ត្រឡាយ និងសឺន ស៊ីចាន់ ។

ចំណែកស្នាក់ការរបស់គណបក្សប្រជាធិបតេយ្យ នៅខេត្តបាត់ដំបង ត្រូវគេចូលលុកលុយវាយបំផ្លាញ ខណៈស្នាក់ការធំរបស់គណបក្សនៅក្រុងភ្នំពេញ ត្រូវកម្លាំងប៉ូលិសឡោមព័ទ្ធ។

កាសែតរបស់គណបក្សប្រឆាំង បានចុះផ្សាយថា ប្រជារាស្ត្រមានសិទ្ធិបោះឆ្នោតនៅតាមភូមិស្រុកនានា ត្រូវរងនូវការបំភិតបំភ័យ ធ្វើបាប ឬអាចនឹងសម្លាប់ចោលទៀតផង ប្រសិនបើនរណាមិនបោះឆ្នោតគាំទ្រចលនាសង្គមរាស្ត្រនិយម។ ប្រជារាស្ត្រទូទៅ ត្រូវគេបង្ខំឱ្យចូលជាសមាជិករបស់ចលនាសង្គមរាស្ត្រនិយម ហើយបើគេដឹងថា នរណាម្នាក់មានបំណងបោះឆ្នោតឱ្យគណបក្សផ្សេងទៀត អ្នកនោះ មុខជាត្រូវរងនូវការធ្វើទុក្ខបុកម្នេញ ជា

មិនខាន។

កាសែតរបស់គណបក្សប្រឆាំង ផ្សាយរិះគន់ទៀតថា ចលនាសង្គមរាស្ត្រនិយម បានប្រើល្បិចមួយទៀត គឺឱ្យប្រជារាស្ត្រនៅតាមភូមិស្រុកនានា ទៅស្បថចំពោះមុខវត្ថុស័ក្តិសិទ្ធិទាំងឡាយថា បើសិនពួកគេ មិនបោះឆ្នោតឱ្យចលនាសង្គមរាស្ត្រនិយមទេ សូមឱ្យវត្ថុស័ក្តិសិទ្ធិទាំងនោះ បំផ្លាញពួកគេទៅចុះ...។

កាសែតអាអេហ្វប៉េ(AFP = Agence France Press) របស់បារាំង ក៏បានចុះផ្សាយពីការចាប់ខ្លួនរបស់មេដឹកនាំប្រឆាំងឆ្វេងនិយម និងការរាយកម្លាំងប៉ូលិស នៅគ្រប់ទិសទី ពិសេស នៅក្បែរៗស្ថានីយបោះឆ្នោត។

តែទោះបីជាយ៉ាងណាក៏ដោយ ក៏គណបក្សប្រជាធិបតេយ្យ បានរៀបចំការឃោសនារកសំឡេងឆ្នោត នៅតាមបណ្តាខេត្តនានា បានយ៉ាងល្អ ដោយមានវាគ្មិនភាគច្រើន សុទ្ធតែអ្នកមានបទពិសោធខាងនយោបាយ និងមានចំណេះដឹងខ្ពស់។ ចំណែកវាគ្មិនវ័យក្មេងៗ ជាពួកឆ្វេងនិយមរបស់គណបក្សប្រជាធិបតេយ្យ ធ្លាប់មានទំនាក់ទំនងជាមួយគណបក្សប្រជាជន (អតីតពួកខ្មែរឥស្សរៈស្និទ្ធនឹងពួកវៀតមិញ) បានឃោសនារិះគន់សម្តេចសីហនុ បានចុះហត្ថលេខាព្រមព្រៀង ទទួលជំនួយយោធា និងសេដ្ឋកិច្ច របស់សហរដ្ឋអាមេរិក កាលពីខែឧសភានោះ ផងដែរ ហើយពួកគេឃោសនាថា ការទទួលជំនួយនោះ នឹងធ្វើឱ្យប្រទេសកម្ពុជា ស្ថិតនៅក្រោមចំណុះរបស់សហរដ្ឋអាមេរិក។

ចំណែកពួកវាគ្មិនរបស់គណបក្សប្រជាធិបតេយ្យ មានវ័យចាស់ៗ បានសម្តែងនូវការយល់ស្របចំពោះការប្រកាន់ជំហរអព្យាក្រឹត និងគោលការណ៍បញ្ចសីលា មិនចូលបក្សសម្ព័ន្ធរបស់សម្តេចសីហនុ ក៏ពិតមែន តែបានបង្ហាញឱ្យឃើញនូវនិន្នាការទោរទន់របស់ពួកគេ ទៅរកសហរដ្ឋអាមេរិក និងបារាំង ហើយពួកគេក៏មិនចង់ឱ្យសម្តេចសីហនុ ភ្ជាប់ទំនាក់ទំនងជាមួយបណ្តាប្រទេសកុម្មុយនិស្ត ដែរ។

ក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោត អាជ្ញាធររាជធានី និងខេត្ត បានធ្វើការគាបសង្កត់ទៅលើប្រជារាស្ត្រណាដែលគេដឹងច្បាស់ថា មិនគាំទ្រចលនាសង្គមរាស្ត្រនិយម ហើយ

វិទ្យុជាតិ បានក្លាយជាកម្មសិទ្ធិផ្តាច់មុខរបស់ចលនាសង្គមរាស្ត្រនិយម តែម្នាក់ឯង។

សម សារី អគ្គលេខាធិការរបស់ចលនាសង្គមរាស្ត្រនិយម រងការចោទប្រកាន់ថា បានគំរាមកំហែងធ្វើបាបសកម្មជនរបស់គណបក្សប្រជាធិបតេយ្យ និងគណបក្សប្រជាជន ដោយបានប្រើដៃជើងរបស់គាត់ឱ្យមកបាញ់ទៅលើ កេង វ៉ាន់សាក់ ជាអគ្គលេខាធិការរបស់គណបក្សប្រជាធិបតេយ្យ ពេលកំពុងឃោសនាវាយប្រហាររបបរាជានិយម និងសម្តេច សីហនុ នៅខាងមុខទីស្តីការក្រសួងឃោសនាការ ស្ថិតនៅខាងជើងទីលានប្រជាធិបតេយ្យ សព្វថ្ងៃ។ ប៉ុន្តែសំណាងល្អ កេង វ៉ាន់សាក់ បានរួចជីវិត ដោយសារគ្រាប់កាំភ្លើងរបស់ឃាតករ បាញ់ខុសគោលដៅ ទៅត្រូវអ្នកបើកបររថយន្តឱ្យសាំសុង ហ្វៃរណង់ដេស ទៅវិញ។

ពេលនោះ កាសែតរបស់បក្សពលករវៀតណាម(វៀតណាមខាងជើង) ក៏បានអំពាវនាវឱ្យបញ្ឈប់ជាបន្ទាន់ នូវការចាប់ខ្លួន និងគំរាមកំហែងមកលើគណបក្សប្រជាជន នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត នៅក្នុងប្រទេសកម្ពុជា ផងដែរ។

៩៣
ចលនាសង្គមរាស្ត្រនិយមឈ្នះឆ្នោត ទទួលបានអាសនៈក្នុងសភា ៩១លើ៩១



គណៈរដ្ឋមន្ត្រីដំបូងរបស់ចលនាសង្គមរាស្ត្រនិយម

ការបោះឆ្នោតតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ដែលអាចចាត់ទុកថា ជាការបោះឆ្នោតសកានីតិកាលទី៣ នៅប្រទេសកម្ពុជា នោះ រួមមាន អាសនៈចំនួន៩១ បានប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ តាមប្រព័ន្ធឯកត្តនាម ដោយមានគណបក្សនយោបាយ ចំនួន ០៨ ចូលរួម គឺចលនាសង្គមរាស្ត្រនិយម មានរូបសញ្ញាព្រះឆាយាល័ក្ខណ៍របស់សម្តេចសីហនុ, គណបក្សប្រជាធិបតេយ្យ មានរូបសញ្ញាក្បាលដំរីត្រកងផ្កាឈូក, គណបក្សប្រជាជន មានរូបសញ្ញានង្គ័ល, គណបក្សខ្មែរឯករាជ្យ មានរូបសញ្ញាផ្កាឈូក, គណបក្សសេរីភាព

មានរូបសញ្ញាប្រាសាទអង្គរវត្ត, គណបក្សតម្កើងជាតិ មានរូបសញ្ញាហនុមាន, គណបក្ស
ពលករកម្ពុជា មានរូបសញ្ញាកម្រងផ្កា និងគណបក្សឯករាជ្យ មានរូបសញ្ញាសៀវភៅរដ្ឋ-
ធម្មនុញ្ញ ដាក់លើជើងពាន។

គណៈកម្មាធិការរៀបចំការបោះឆ្នោត បានប្រកាសជាផ្លូវការនូវលទ្ធផលបោះឆ្នោត
នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ នោះ ថា ក្នុងចំណោមសន្លឹកឆ្នោតបានការ សរុប ៧៦១៩៥៨
នាក់ ចលនាសង្គមរាស្ត្រនិយម ទទួលបានការគាំទ្រ ចំនួន៦៣០៦២៥សំឡេង ស្មើនឹង៨៣
ភាគរយ, គណបក្សប្រជាធិបតេយ្យ ទទួលបានការគាំទ្រ ចំនួន៩៣៩១៩សំឡេង ស្មើនឹង
១២ ភាគរយ, គណបក្សប្រជាជន ទទួលបានការគាំទ្រ ចំនួន៣១០៣៤សំឡេង ស្មើនឹង៤
ភាគរយ។

ក្រៅពីនេះ គណបក្សសេរីភាពទទួលបានការគាំទ្រ ចំនួន៥៤៨៨សំឡេង, គណបក្ស
តម្កើងជាតិ ទទួលបានការគាំទ្រ ចំនួន១១៥៤សំឡេង, គណបក្សខ្មែរឯករាជ្យ ទទួលបានការ
គាំទ្រ ចំនួន៧៩៤សំឡេង, គណបក្សឯករាជ្យ ទទួលបានការគាំទ្រ ចំនួន១៨៦សំឡេង
និងគណបក្សពលករកម្ពុជា ទទួលបានការគាំទ្រ ចំនួន២៦៩សំឡេង ។

ក្រោយការប្រកាសលទ្ធផលបោះឆ្នោត ចលនាសង្គមរាស្ត្រនិយម រងការចោទប្រកាន់
ថា លួចបន្លំសន្លឹកឆ្នោត។

នៅក្នុងមណ្ឌលបោះឆ្នោត ក្នុងស្រុកមេមត់ ខេត្តកំពង់ចាម(បច្ចុប្បន្នខេត្តត្បូងឃ្មុំ)
ជាកន្លែងចលនាតស៊ូខ្មែរឥស្សរៈ និងពួកវៀតមិញ ធ្វើសកម្មភាពយ៉ាងខ្លាំងក្លាជាងគេ តាំងពី
ទសវត្សរ៍ឆ្នាំ១៩៤០ និងទទួលបានការគាំទ្រពីសំណាក់កម្មករចម្ការកៅស៊ូយ៉ាងច្រើនសន្ធឹក
សន្ធាប់នោះ លទ្ធផលបោះឆ្នោតនៅមណ្ឌលនោះ បែរជាបេក្ខជនរបស់គណបក្សប្រជាជន
ឈ្មោះសុខ សាផាយ គ្មានទទួលបានការគាំទ្រ សូម្បីមួយសំឡេង ក៏គ្មានផង។ ឯចលនា
សង្គមរាស្ត្រនិយម ទទួលបាន ៦១៤៩សំឡេង និងគណបក្សប្រជាធិបតេយ្យ ទទួលបាន
៩៩សំឡេង។ ជាមួយគ្នានោះដែរ នៅស្រុកត្បូងឃ្មុំ គណបក្សប្រជាជន ក៏មិនមានសន្លឹកឆ្នោត
គាំទ្រ សូម្បីមួយសន្លឹក ដូចនៅក្នុងស្រុកមេមត់ ដែរ។

ចំណែកនៅស្រុកស្នួល ខេត្តក្រចេះ ជាតំបន់ចម្ការកៅស៊ូ នៅក្បែរគ្នានោះ បេក្ខជនរបស់គណបក្សប្រជាជន ឈ្មោះព្រំ ជួនមាលា ទទួលបានការគាំទ្រចំនួន ២៨៥៥សំឡេង។

ទោះបីជាយ៉ាងណាក្តី សុខ សាផាយ និងព្រំ ជួនមាលា ត្រូវអាជ្ញាធរចាប់យកទៅដាក់គុក តាំងពីមុនថ្ងៃបោះឆ្នោតមកម្ល៉េះ។

នៅស្រុកកំចាយមារ ខេត្តព្រៃវែង អតីតមេខ្មែរឥស្សរៈបានចោទប្រកាន់មន្ត្រីរៀបចំការបោះឆ្នោតនៅទីនោះ ថា បានបោះសន្លឹកឆ្នោតគាំទ្ររបស់គណបក្សប្រជាជនចោល ទៅក្នុងហឹបឆ្នោតផ្សេង មិនមែនជាហឹបឆ្នោតផ្លូវការ។ លុះដល់ពេលរាប់សន្លឹកឆ្នោត នៅក្នុងហបឆ្នោតជាផ្លូវការ គេប្រកាសថា ចលនាសង្គមរាស្ត្រនិយម ជាអ្នកឈ្នះឆ្នោត ទៅវិញ ។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏គណបក្សប្រជាជន នៅស្រុកកំចាយមារ នៅតែទទួលបានសន្លឹកឆ្នោតគាំទ្រ ចំនួន ២៤៥៧សំឡេង ដែរ។

នៅឃុំជាច ស្រុកកំចាយមារ ក្នុងខេត្តព្រៃវែង និងឃុំជូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ប្រជារាស្ត្រភាគច្រើន នៅតាមភូមិឆ្ងាយៗពីផ្លូវជាតិ បានបោះឆ្នោតគាំទ្រគណបក្សប្រជាជន។ ឯប្រជារាស្ត្រភាគច្រើននៅតាមភូមិនានា នៅជាប់នឹងផ្លូវជាតិ បោះឆ្នោតគាំទ្រចលនាសង្គមរាស្ត្រនិយម។

នៅស្រុកឈូក ខេត្តកំពត សកម្មជន៦នាក់របស់គណបក្សប្រជាជន ត្រូវអាជ្ញាធរចាប់ខ្លួន ក្នុងនោះមាន២នាក់ ត្រូវបាញ់សម្លាប់។ ជាមួយគ្នានោះ មនុស្សចំនួន១៦៣នាក់នៅតាមខេត្តផ្សេងៗទៀត ត្រូវចាប់ខ្លួនពីបទបម្រើសកម្មភាពឱ្យពួកវៀតមិញ។

នៅភាគខាងត្បូងខេត្តបាត់ដំបង អតីតមេខ្មែរឥស្សរៈឈ្មោះអាចារ្យវ៉ន ជាបេក្ខជនរបស់គណបក្សប្រជាជន និងសហការីរបស់គាត់២នាក់ទៀត គឺអាចារ្យប៊ូ និងជួន ព្រលិត ត្រូវទាហានរាជរដ្ឋាភិបាលបាញ់សម្លាប់ មុនពេលបោះឆ្នោត។ ប៉ុន្តែទោះបីអាចារ្យវ៉ន ត្រូវគេបាញ់សម្លាប់ទៅហើយក៏ដោយ ក៏លទ្ធផលនៃការបោះឆ្នោត បានឱ្យដឹងថា អាចារ្យវ៉ន បានទទួលសំឡេងគាំទ្រ ចំនួន២៩១០សំឡេងឯណោះ ខណៈការបោះឆ្នោតកាលពីឆ្នាំ១៩៥១នៅទីនោះ គណបក្សប្រជាធិបតេយ្យទទួលបានការគាំទ្រ តែ១៨៣១សំឡេងប៉ុណ្ណោះ។

សំឡេងគាំទ្ររបស់គណបក្សប្រជាជន នៅមណ្ឌលអាចារ្យវ៉ែន ឈរឈ្មោះជាបេក្ខជន នេះ គឺជាសំឡេងគាំទ្រច្រើនជាងគេបង្អស់របស់គណបក្សប្រជាជន បើប្រៀបធៀបជាមួយ មណ្ឌលផ្សេងៗទៀត នៅទូទាំងប្រទេស។

គណបក្សប្រជាជន បានតវ៉ាថា ប្រសិនបើការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ គ្មានការគំរាមកំហែង និងគ្មានការបន្លំសន្លឹកឆ្នោត យ៉ាងហោចណាស់ គណបក្សប្រជាជន ក៏ទទួលបានអាសនៈ នៅក្នុងរដ្ឋសភា ចំនួន៦ ឬ៧អាសនៈដែរ។

ដោយឡែក នៅក្នុងចំណោមមណ្ឌលទាំង៥ នៅទីក្រុងភ្នំពេញ បេក្ខជនរបស់គណ-បក្សប្រជាធិបតេយ្យ ទទួលបានសំឡេងគាំទ្រច្រើនជាងគេ គឺ កេង វ៉ាន់សាក់ ទទួលបាន សំឡេងគាំទ្រប្រមាណ ២៤ភាគរយ នៅក្នុងមណ្ឌលគាត់ឈរឈ្មោះជាបេក្ខជន។

នៅខេត្តកំពត វិញ តូច កឿន (ក្រោយមក ជារដ្ឋមន្ត្រីក្រសួងសាធារណការ នៅក្នុង របបកម្ពុជាប្រជាធិបតេយ្យ) ក្នុងមណ្ឌលគាត់ឈរឈ្មោះជាបេក្ខជន ទទួលបានសំឡេង គាំទ្រ ២៥ភាគរយ, មុី ផាត ក្នុងមណ្ឌលគាត់ឈរឈ្មោះជាបេក្ខជន គាត់ទទួលបានសំឡេង គាំទ្រ ២៤ ភាគរយ, នង សួន (ក្រោយមក ជារដ្ឋមន្ត្រីក្រសួងកសិកម្ម នៅក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ) ក្នុងមណ្ឌលគាត់ឈរឈ្មោះជាបេក្ខជន គាត់ទទួលបានសំឡេងគាំទ្រ ២៣ ភាគរយ និងប៉ែន យុទ្ធ ក្នុងមណ្ឌលគាត់ឈរឈ្មោះជាបេក្ខជន គាត់ទទួលបានសំឡេងគាំទ្រ ២៤ភាគរយ ។

ចំណែកនៅខេត្តស្វាយរៀង កែវ មាស ក្នុងមណ្ឌលគាត់ឈរឈ្មោះ គាត់ទទួលបាន សំឡេងគាំទ្រ ២០ភាគរយ និងនៃ សាវ៉ាន់ ហៅយ៉ា (ក្រោយមក ជាលេខាបក្សភូមិភាគ ឦសាន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ក្នុងមណ្ឌលដែលគាត់ឈរឈ្មោះ គាត់ទទួល បានការគាំទ្រ តែ៨៧សំឡេងប៉ុណ្ណោះ ក្នុងចំណោមសន្លឹកឆ្នោតបានការចំនួន៨០០០ សន្លឹក។

លទ្ធផលចុងក្រោយនៃបោះឆ្នោតនាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ គណៈកម្មាធិការ រៀបចំការបោះឆ្នោត បានប្រកាសជាផ្លូវការថា ចលនាសង្គមរាស្ត្រនិយម ទទួលបានអាសនៈ នៅក្នុងរដ្ឋសភា ៩១ លើ៩១ ។ គណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) បានប្រកាសថា

ការបោះឆ្នោតថ្ងៃទី១១ ខែកញ្ញា បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ក្រោយបោះឆ្នោត២ថ្ងៃ គឺនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៥៥ កេង វ៉ាន់សាក់ អគ្គលេខាធិការគណបក្សប្រជាធិបតេយ្យ ត្រូវកម្លាំងសមត្ថកិច្ចរបស់សម្តេចសីហនុ ចាប់យកទៅដាក់ពន្ធនាគារ រហូតដល់ថ្ងៃទី១០ ខែតុលា ទើបដោះលែងឱ្យមានសេរីភាពវិញ ។

១ថ្ងៃ ក្រោយពីកម្លាំងសមត្ថកិច្ចចាប់ខ្លួន កេង វ៉ាន់សាក់ គឺនៅថ្ងៃទី១៤ ខែកញ្ញា ប្រទេសកម្ពុជា បានចូលជាសមាជិករបស់អង្គការសហប្រជាជាតិ ចាប់ពីពេលនោះមក។

ក្រោយពីការប្រកាសលទ្ធផលនៃការបោះឆ្នោតនោះ រដ្ឋាភិបាលក្រុងហាណូយ បានចោទប្រកាន់រាជរដ្ឋាភិបាលរបស់ចលនាសង្គមរាស្ត្រនិយមថា បានរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ និងចាត់ទុកថាការបោះឆ្នោតនោះ មិនបានប្រព្រឹត្តទៅដោយសេរី និងពុំមានយុត្តិធម៌ត្រឹមត្រូវ តាមបែបលទ្ធិប្រជាធិបតេយ្យឡើយ គឺមានតែគំរាមកំហែង ចាប់សកម្មជនគណបក្សប្រឆាំងទៅដាក់គុក ហើយទាំងមានការលួចបន្លំសន្លឹកឆ្នោតទៀតផង។

តែសម្តេចសីហនុ មិនត្រឹមតែមិនបានបញ្ចេញប្រតិកម្មអ្វី ទៅលើការចោទប្រកាន់របស់រដ្ឋាភិបាលក្រុងហាណូយនោះវិញទេ ព្រះអង្គបែរជាស្នើសុំតាមរយៈគណៈកម្មការត្រួតពិនិត្យអន្តរជាតិ (ICC) ឱ្យមានទំនាក់ទំនងបេសកកម្មនយោបាយជាមួយក្រុងហាណូយ ទៅវិញ។

រយៈពេលពីរសប្តាហ៍ក្រោយមក រដ្ឋាភិបាលក្រុងហាណូយ បានប្រកាសទទួលស្វាគមន៍សំណើរបស់សម្តេចសីហនុ ក្នុងការបង្កើតទំនាក់ទំនងបេសកកម្មនយោបាយនោះ ហើយនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៥៥ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) ក៏បានស្នើសុំឱ្យគណៈកម្មការត្រួតពិនិត្យអន្តរជាតិ(ICC) នាំពាក្យទៅថ្វាយសម្តេចសីហនុ វិញថា ក្រុងហាណូយ បានយល់ព្រមចំពោះការស្នើសុំបង្កើតទំនាក់-ទំនងបេសកកម្មនយោបាយរបស់ព្រះអង្គនោះហើយ។

៩៤
សម សារី ឡើងតំណែង
ឧបនាយករដ្ឋមន្ត្រី បានតែ៣ខែ



សម សារី

ក្រោយចលនាសង្គមរាស្ត្រនិយម ទទួលបានអាសនៈនៅក្នុងរដ្ឋសភា ៩១លើ៩១ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៥៥ រាជរដ្ឋាភិបាលថ្មីមួយ ត្រូវបានបង្កើតឡើង ដោយមានសម្តេចសីហនុ ជាប្រធានចលនាសង្គមរាស្ត្រនិយម ជាអ្នកឈ្នះឆ្នោតនោះ ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស, សម សារី អគ្គលេខាធិការចលនាសង្គមរាស្ត្រនិយម ជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ចជាតិ ហិរញ្ញវត្ថុ ផែនការ និងអប់រំជាតិ, លន់ នល់ ជារដ្ឋមន្ត្រីការពារជាតិ, ជួប សំឡុត ជារដ្ឋមន្ត្រីយុត្តិធម៌ និងធម្មការ, គូ រុន ជារដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៍, ហួត សម្ផាត ជារដ្ឋមន្ត្រីសុខាភិបាល និងព័ត៌មាន, ហឿ ឡាយអ៊ីន ជារដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារសង្គមកិច្ច និងបោសសម្អាតទូទៅ, ញៀន គ្រឿន ជារដ្ឋលេខាធិការកសិកម្ម និងកិច្ចការកសិករ, លី ជិនលី ជារដ្ឋលេខាធិការកសិកម្ម និងឧស្សាហកម្ម, ហួត សម្បត្តិ ជារដ្ឋលេខាធិការអប់រំជាតិ។

សម សារី ដែលគណបក្សប្រជាធិបតេយ្យ និងគណបក្សប្រជាជន ចោទប្រកាន់ថា ជាអ្នកបញ្ជាឱ្យមានការបាញ់សម្លាប់ គំរាមកំហែងធ្វើបាបទៅលើបេក្ខជន សកម្មជន និងអ្នកគាំទ្ររបស់ពួកគេ បានទទួលតំណែងជាឧបនាយករដ្ឋមន្ត្រី ដែលជាតំណែងមួយខ្ពស់បំផុត បន្ទាប់ពីសម្តេចសីហនុ ហើយគាត់ក៏ចាប់ផ្តើមមានមុខមាត់កិត្តិយស កេរ្តិ៍ឈ្មោះខ្ពស់ត្រដែតតាំងពីពេលនោះមក។

ជាមួយគ្នានេះដែរ លន់ នល់ ចាប់ផ្តើមលេចមុខនៅក្នុងឆាកនយោបាយ តាមរយៈសម្តេចសីហនុ ប្រទានតំណែងជារដ្ឋមន្ត្រីការពារជាតិ ផងដែរ។

ក្រោយពីចលនាសង្គមរាស្ត្រនិយម ឈ្នះឆ្នោតបានឡើងកាន់អំណាច នៅទីស្តីការគណៈរដ្ឋមន្ត្រី ក៏មានរៀបចំពិធីប្រគល់ថវិកាមួយចំនួន ជាជំនួយរបស់សហរដ្ឋអាមេរិក ដល់រាជរដ្ឋាភិបាលថ្មីនោះផងដែរ។

ពេលនោះ សម្តេចសីហនុ ជានាយករដ្ឋមន្ត្រី កំពុងបំពេញព្រះរាជទស្សនកិច្ច នៅក្រៅប្រទេស ដូច្នេះ សម សារី ជាឧបនាយករដ្ឋមន្ត្រី ក្នុងនាមនាយករដ្ឋមន្ត្រីស្តីទី ជាអ្នកទទួលថវិកានោះ ពីឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក រ៉ូប៊ែរ ម៉ាក់ គ្លីនតុក (Robert McClintock) នៅកន្លែងប្រារព្ធពិធី ដោយឯកអគ្គរដ្ឋទូតរូបនោះ បានដាក់មូលប្បទានបត្រមួយសន្លឹក នៅ ក្នុងហោប៉ៅអាវធំរបស់គាត់រួចជាស្រេច។

តែមុននឹងប្រគល់មូលប្បទានបត្រនៅក្នុងហោប៉ៅអាវធំរបស់គាត់នោះ មកឱ្យសម សារី ជានាយករដ្ឋមន្ត្រីស្តីទីនោះ ឯកអគ្គរដ្ឋទូតរូបនេះ បានដាក់លក្ខខណ្ឌតឹងរឹងជាលក្ខណៈគាបសង្កត់មិនទំនងមួយចំនួន ធ្វើឱ្យសម សារី មានការខឹងសម្បា ក៏មានការឈ្លោះប្រកែកគ្នាមួយប្រាវ រហូតដល់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក សម្រេចចិត្តចាកចេញពីកន្លែងប្រារព្ធពិធី ដោយយកទាំងមូលប្បទានបត្រនោះ ទៅជាមួយផង។

ក្រោយមក បើតាមការអះអាងរបស់សឺន សាន បានឱ្យដឹងថា ក្រោយពីមានជម្លោះជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក នោះមក សម សារី ក្នុងនាមរាជរដ្ឋាភិបាល បានសុំចូលគាល់ព្រះមហាក្សត្រនរោត្តម សុរាម្រិត និងព្រះមហាក្សត្រិយានីស៊ីសុវត្ថិ កុសុមៈ នារីរតន៍

សិរីវឌ្ឍនា ដោយមានរូបគាត់(សឺន សាន) ទើបទទួលតំណែងជាប្រធានធនាគារជាតិ និង មន្ត្រីជាន់ខ្ពស់ម្នាក់ទៀត ទៅជាមួយផង ដើម្បីទូលថ្វាយព្រះអង្គទាំងទ្វេ ឱ្យបានដឹងពីបញ្ហា ជម្លោះជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក រូបនោះ។

ក្រោយពីបានស្តាប់របាយការណ៍របស់សម សារី ទូលថ្វាយមក ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ក៏បានឱ្យគាត់ពាំនាំនូវព្រះសារនីយ៍របស់ព្រះអង្គ ទៅជម្រាបឯកអគ្គរដ្ឋទូត អាមេរិក រ៉ូប៊ែរ ម៉ាក់ គ្លីនតុក (Robert McClinTock) ផងថា ប្រជារាស្ត្រខ្មែរចាត់ទុកសហរដ្ឋ អាមេរិក ជាទេវតាចុះមកជួយប្រជារាស្ត្រខ្មែរទាំងអស់គ្នា។ តែបើឯកអគ្គរដ្ឋទូតអាមេរិក នៅ តែប្រកាន់ខឹង មិនព្រមប្រគល់ថវិកា ជាជំនួយរបស់សហរដ្ឋអាមេរិក មកឱ្យរាជរដ្ឋាភិបាល ខ្មែរបែបនេះ ព្រះអង្គនឹងបង្ខំព្រះទ័យប្រាប់ប្រជារាស្ត្រខ្មែរវិញថា អាមេរិក មិនមែនជាទេវតា ទេ គឺជាពួកយក្សពាក់មុខធ្វើជាទេវតា...។

សឺន សាន បានអះអាងបន្តថា បន្ទាប់ពីពួកគាត់ចូលគាល់ព្រះមហាក្សត្រសុរាម្រិត និងព្រះមហាក្សត្រិយានីកុសុមៈ មក នៅល្ងាចថ្ងៃដដែលនោះ គាត់(សឺន សាន)បានទៅ ជួបឯកអគ្គរដ្ឋទូតអាមេរិក រ៉ូប៊ែរ ម៉ាក់ គ្លីនតុក (Robert McClinTock) នៅក្នុងពិធីជប់លៀង មួយ។

ពេលនោះ ឯកអគ្គរដ្ឋទូតអាមេរិក បានរៀបរាប់ប្រាប់គាត់ ពីរឿងឈ្លោះប្រកែកគ្នា ជាមួយឧបនាយករដ្ឋមន្ត្រី សម សារី រហូតដល់ខកខានមិនបានប្រគល់មូលប្បទានបត្រ នៅក្នុងពិធីទទួលជំនួយជាថវិការបស់សហរដ្ឋអាមេរិកនោះ ហើយបានចោទប្រកាន់ថា សម សារី បានយកកាំភ្លើងខ្លី មកភ្ជង់ក្បាលលោក...។

សឺន សាន បានពាំនាំនូវព្រះសារនីយ៍របស់ព្រះមហាក្សត្រិយានីកុសុមៈ ជម្រាប ឯកអគ្គ-រដ្ឋទូតអាមេរិក ឱ្យបានជ្រាប និងសំណូមពរឱ្យលោកឈប់ប្រកាន់ខឹងតទៅទៀត។ ឯកអគ្គរដ្ឋទូតអាមេរិករូបនោះ ក៏យល់ព្រមធ្វើតាមសំណូមពររបស់ព្រះមហាក្សត្រិយានី កុសុមៈ វិញដែរ។

ក្នុងអំឡុងពេល សម សារី កាន់តំណែងជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ច

ជាតិ ហិរញ្ញវត្ថុ ផែនការ និងអប់រំជាតិ នោះដែរ គាត់មានរឿងអាស្រូវពុករលួយមួយ គឺការនាំចេញគ្រាប់ម្រេចច្រើនតោន តាមនាវាទៅក្រៅប្រទេស តែពួកមន្ត្រីគយនៅក្រោមការគ្រប់-គ្រងរបស់គាត់ បែរជាធ្វើលិខិតស្នាមបន្លំ ដាក់គ្រាប់ម្រេចនោះថា ជាគ្រាប់គទៅវិញ ធ្វើឱ្យបាត់បង់ ប្រាក់ពន្ធចូលថវិការដ្ឋ ជាច្រើន។

ក្រោយពីសម្តេចសីហនុ យាងត្រលប់មកពីបំពេញព្រះរាជទស្សនកិច្ចនៅបរទេសវិញ ទំនងមកពីរឿង សម សារី បង្កជម្លោះជាមួយឯកអគ្គរដ្ឋទូតអាមេរិក រ៉ូប៊ែរ ម៉ាក់ គ្លីនតុក (Robert McClinTock) ផង និងរឿងអាស្រូវពុករលួយនាំចេញគ្រាប់ម្រេច បន្លំដាក់ថាជាគ្រាប់គនោះផង ព្រមទាំងមានកំហុសធ្ងងមួយចំនួនទៀត សម សារី កាន់តំណែងជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ចជាតិ ហិរញ្ញវត្ថុ ផែនការ និងអប់រំជាតិ បានរយៈពេលតែ៣ខែប៉ុណ្ណោះ ក៏ត្រូវបានសម្តេចសីហនុ ដកចេញពីតំណែងនោះវិញ ហើយក៏ត្រូវបាត់ឈ្មោះពីគណៈរដ្ឋមន្ត្រី ចាប់ពីពេលនោះមកដែរ។

តែទោះបីគាត់បាត់បង់តំណែងនៅក្នុងជួរគណៈរដ្ឋមន្ត្រី ក៏ពិតមែន តែតំណែងសមាជិកក្រុមប្រឹក្សារាជបល្ល័ង្ក ដែលព្រះមហាក្សត្រតែងតាំង កាលថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៥៥នោះ ត្រូវបានរក្សាទុកជូនគាត់ដដែល។

នៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៥៦ សម្តេចសីហនុ បានរៀបចំគណៈរដ្ឋមន្ត្រីរបស់ចលនាសង្គមរាស្ត្រនិយមថ្មីមួយទៀត ដោយបានតែងតាំង អ៊ុម ឈាងស៊ុន ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីមហាផ្ទៃ, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជារដ្ឋមន្ត្រីការពារជាតិ និងការពារលើផ្ទៃប្រទេស, ខៀវ វ៉ាន ជារដ្ឋមន្ត្រីការបរទេស, ប្រាក់ សារិន ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ផ្លែក ភឹន ជារដ្ឋមន្ត្រីផែនការ កសិកម្ម និងចិញ្ចឹមសត្វ, វ៉ាយ លុត ជារដ្ឋមន្ត្រីពាណិជ្ជកម្ម ឧស្សាហកម្ម និងទូរគមនាគមន៍, ម៉ៅ ចយ ជារដ្ឋលេខាធិការសង្គមកិច្ច ទទួលបន្ទុកការងារ, មិន ធុច ជារដ្ឋលេខាធិការសាធារណការ, ជា អ៊ួម ជារដ្ឋលេខាធិការសិក្សាធិការជាតិ, មាស យ៉ង់ ជារដ្ឋលេខាធិការសាធារណសុខាភិបាល និងទ្រិញ វ៉ាញ រដ្ឋលេខាធិការឃោសនាការ និងធម្មការ។

៩៥
សភាឯកបក្សរបស់សង្គមរាស្ត្រនិយម ធ្វើអ្វីបានតាមចិត្ត



សម្តេចសីហនុ

ចាប់ពីខែមេសា ឆ្នាំ១៩៥៦មក តាមរយៈរដ្ឋសភាឯកបក្សរបស់ចលនាសង្គមរាស្ត្រនិយមទាំង៩១រូប សម្តេចសីហនុ ក៏ចាប់ផ្តើមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៧ តាមអ្វីដែលព្រះអង្គចង់បាន ដោយគ្មានអ្វីត្រូវរាំងស្ទះទៀតឡើយ។

ព្រះអង្គមានគោលការណ៍ឱ្យមានការកំណត់អំណាចរបស់សភា និងការបង្កើតឱ្យមានលទ្ធិប្រជាធិបតេយ្យពាក់កណ្តាលផ្ទាល់(Semi-disecte)មួយ ពោលគឺការដោះស្រាយបញ្ហាធំៗរបស់ប្រទេសជាតិ ត្រូវតែមានការពិភាក្សាគ្នាជាអចិន្ត្រៃយ៍ រវាងព្រះអង្គជាមួយរាជរដ្ឋាភិបាល ព្រមទាំងប្រជារាស្ត្រ ផងដែរ។

ព្រះរាជក្រមលេខ៦៥ ន.ស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥៦ បានប្រកាសជាផ្លូវការ

ឱ្យបង្កើតសភាប្រជារាស្ត្រនៅតាមបណ្តាខេត្តទាំងអស់ និងរាជធានីភ្នំពេញ ដើម្បីឱ្យប្រជារាស្ត្រ បានដឹងពីកិច្ចការរាជរដ្ឋាភិបាល និងកិច្ចការរបស់ប្រទេសជាតិ។ ដើម្បីអនុវត្តគោលការណ៍ នេះ ព្រះអង្គបង្កើតឱ្យមានសមាជជាតិ ក្នុងរយៈពេល៦ខែម្តង និងអនុញ្ញាតឱ្យប្រជារាស្ត្រ ខ្មែរប្រុសស្រី ដោយគ្មានប្រកាន់និន្នាការនយោបាយ ចូលរួមមានមតិ ជជែកពិភាក្សា រិះគន់ ទិតៀន ចោទសួរទៅលើការអនុវត្តគោលនយោបាយរបស់ចលនាសង្គមរាស្ត្រនិយម ដែល មានព្រះអង្គជាប្រធាន ដោយមានសិទ្ធិលើកឡើងពីចំណុចខ្វះខាតទាំងឡាយរបស់រាជរដ្ឋា-ភិបាល ហើយសមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែឡើងឆ្លើយបំភ្លឺចំពោះការរិះគន់ ទិតៀន និងចោទសួរនោះ ដោយមិនអាចគេចវេះ ឬខកខានបានឡើយ។

ទីបំផុត បើមានសំណូមពរ ឬមានការសម្រេចដំណោះស្រាយពីបញ្ហាអ្វីមួយ សមាជិក អង្គសមាជជាតិទាំងមូល ជាអ្នកធ្វើការអនុម័តដោយលើកដៃ រួចហើយត្រូវបញ្ជូនសំណូមពរ ឬការសម្រេចដំណោះស្រាយដែលសមាជជាតិទាំងមូល ធ្វើការអនុម័តហើយនោះ ទៅឱ្យ រដ្ឋសភាធ្វើការពិភាក្សា និងអនុម័តបន្តទៀត។

សមាជជាតិដំបូងបង្អស់ រៀបចំឡើងដោយចលនាសង្គមរាស្ត្រនិយម បានប្រព្រឹត្តទៅ នៅថ្ងៃទី២៥ និងទី២៦ ខែកញ្ញា ឆ្នាំ១៩៥៥ ដោយមានសម្តេចសីហនុ ទ្រង់គង់ជាព្រះអធិបតី ដើម្បីស្តាប់រាល់មតិលើកឡើងរបស់វាគ្មិន និងគ្រប់ភាគីមានសំណូមពរ ឬដំណោះស្រាយពី បញ្ហាអ្វីមួយ រួចហើយព្រះអង្គមានព្រះតម្រិះលើកហេតុផលផ្សេងៗ មុននឹងព្រះអង្គស្នើសុំ ឱ្យអង្គសមាជទាំងមូលធ្វើការអនុម័តនូវសំណូមពរ ឬដំណោះស្រាយអ្វីមួយនោះ។

ក្នុងឱកាសបើកសមាជជាតិដំបូងបង្អស់នោះ អង្គសមាជទាំងមូល បានសម្រេចលែង ឱ្យប្រើប្រាស់ភាសាបារាំង នៅក្នុងលិខិតស្នាមកិច្ចការរដ្ឋបាលទាំងអស់ តាំងពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់រាជរដ្ឋាភិបាល ដូចកាលសម័យនៅក្រោមអាណានិគមបារាំង តទៅទៀត ពោលគឺត្រូវប្រើអក្សរខ្មែរ ជំនួសវិញ។

ជាមួយគ្នានោះ អង្គសមាជ ក៏បានសម្រេចឱ្យជនជាតិខ្មែរ ជាស្ត្រីភេទមានសិទ្ធិបោះ ឆ្នោតដូចបុរសដែរ ហើយសម្រេចឱ្យប្រជារាស្ត្រជាម្ចាស់ឆ្នោត មានសិទ្ធិដកហូតតំណាងរាស្ត្រ

រូបណាមានកំហុសធ្ងន់ធ្ងរ ចេញពីតំណាងរបស់ខ្លួននៅក្នុងរដ្ឋសភាទៀតផង ទោះបីកំពុងស្ថិតនៅក្នុងនីតិកាលរបស់ខ្លួនក៏ដោយ។

ពិសេសអង្គសមាជទាំងមូល ក៏បានលើកដៃគាំទ្រជាឯកច្ឆន្ទ ចំពោះគោលនយោបាយប្រកាន់យកមាគ៌ាអព្យាក្រឹត របស់ចលនាសង្គមរាស្ត្រនិយម មកដឹកនាំប្រទេស។

ក្រោយពីបង្កើតឱ្យមានសមាជជាតិមក សម្តេចសីហនុ ក៏មានគម្រោងបង្កើតឱ្យមានសភាប្រជារាស្ត្រនៅតាមបណ្តាខេត្តនីមួយៗផងដែរ។ សភានៅតាមបណ្តាខេត្តនេះ មានតួនាទីសំខាន់ក្នុងការងាយស្រួលធ្វើទំនាក់ទំនងរវាងប្រជារាស្ត្រស់នៅតាមតំបន់ជនបទជាច់ស្រយាល ជាមួយនឹងរាជរដ្ឋាភិបាល ហើយសមាជិកសភានៅបណ្តាខេត្តនេះមានសិទ្ធិផ្តល់មតិយោបល់ផ្សេងៗ ទាក់ទងនឹងកិច្ចការរដ្ឋទាំងឡាយ និងមានសិទ្ធិត្រួតពិនិត្យទៅលើមន្ត្រីរាជការទាំងអស់ នៅក្នុងខេត្តរបស់ខ្លួន ទៀតផង។

ប៉ុន្តែគម្រោងបង្កើតសភានៅតាមបណ្តាខេត្តនេះ ក៏ជួបបញ្ហាចម្រូងចម្រាសខ្លាំងដែរ ដោយមតិខ្លះបានលើកហេតុផលថា ធម្មតាប្រជារាស្ត្រក្រីក្រ គ្មានលទ្ធភាពឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ នៅសភាខេត្តនោះទេ គឺមានតែពួកអ្នកមានប៉ុណ្ណោះ មានលទ្ធភាពឈរឈ្មោះ។ ដូច្នេះ មតិខ្លះមានការព្រួយបារម្ភ ខ្លាចពួកអ្នកមានទាំងនោះ ក្រោយពីបានជាប់ឆ្នោតជាសមាជិកសភាខេត្តទៅ ពួកគេបម្រើតែផលប្រយោជន៍ឱ្យវណ្ណៈរបស់ពួកគេ ជាពួកអ្នកមានប៉ុណ្ណោះ មិនបម្រើផលប្រយោជន៍ប្រជារាស្ត្រក្រីក្រ។ រីឯមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៅក្នុងខេត្តនីមួយៗ ក៏មិនចង់នៅក្រោមការត្រួតត្រារបស់សមាជិកសភាខេត្តនេះដែរ។ ដូច្នេះ សម្តេចសីហនុ ក៏បានលុបចោលគម្រោងបង្កើតសភានៅតាមបណ្តាខេត្តនេះវិញ។

ពេលនោះដែរ ទោះបីតំណាងរាស្ត្រភាគច្រើនលើសលប់នៅក្នុងរដ្ឋសភា សុទ្ធតែជាសមាជិករបស់ចលនាសង្គមរាស្ត្រនិយម ក៏ពិតមែន តែបើនិយាយពីអតីតភាពរបស់ពួកគេធ្វើឱ្យសម្តេចសីហនុ មិនសូវទុកព្រះទ័យប៉ុន្មានឡើយ ព្រោះពួកគេភាគច្រើនជាពួកពាណិជ្ជករ ជាអ្នកគ្មានគោលជំហរស្មោះត្រង់នឹងចលនាសង្គមរាស្ត្រនិយម និងគ្មានទស្សនៈនយោបាយពិតប្រាកដ ។

របត់នយោបាយ

ចលនាសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ដឹកនាំប្រទេសនាពេលនោះ មានមជ្ឈដ្ឋានខ្លះចាត់ថា ប្រទេសកម្ពុជា កំពុងគ្រប់គ្រងតាមបែបរបបសង្គមនិយម(កុម្មុយនិស្ត) បែបថ្មីមួយ គឺរបបសង្គមនិយមមួយ មានព្រះមហាក្សត្រ និងការគោរពព្រះពុទ្ធសាសនា ដោយសារព្រះអង្គបានបង្កើតរាជសហករណ៍ ដើម្បីលក់ដូរមុខទំនិញផ្សេងៗនៅតាមបណ្តាមូលដ្ឋាននានា ដើម្បីការពារកុំឱ្យមានពួកឈ្មួញរកស៊ីជួញដូរ កេងយកចំណេញលើប្រជាកសិករដូចមុនៗទៀត។ ពិសេស សូម្បីតែពួកមន្ត្រីជាន់ខ្ពស់ពីមុនៗមក មានងារជាអស់លោកឯកឧត្តម ឬលោកស្រី លោកជំទាវ សម្តេចសីហនុ ក៏បានដូរងារថ្មី មកហៅត្រឹមតែសហជីវិន ឬសហជីវិនីវិញ ដើម្បីឱ្យស្មើភាពគ្នា។

៩៦
ហ្វីលីពីន អូសទាញសម្តេចសីហនុ ឱ្យចូលអង្គការសេអាតូ



សម្តេចសីហនុ យាងទៅបំពេញព្រះរាជទស្សនកិច្ច នៅប្រទេសហ្វីលីពីន

តាមការយោងរបស់ប្រធានាធិបតី រ៉ាម៉ូន ម៉ាក់សាយសាយ (Ramon Magsaysay) ពីថ្ងៃទី៣០ ខែមករា ដល់ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៥៦ សម្តេចសីហនុ បានយាងទៅបំពេញព្រះរាជទស្សនកិច្ច នៅប្រទេសហ្វីលីពីន ជាសមាជិក (SEATO) និងជាសម្ព័ន្ធមិត្តដ៏ជិតស្និទ្ធបំផុតរបស់សហរដ្ឋអាមេរិក។ នៅទីក្រុងម៉ានីល ព្រះទីនាំងរបស់ព្រះអង្គ ត្រូវបានហែហមដោយក្បួនរថយន្ត និងទោចក្រយានយន្ត ជាច្រើនគ្រឿង គគ្រឹកគគ្រេង អធិកអធម ខុសប្លែកពីធម្មតា។

ពេលឆ្លងកាត់មហាវិថីនានា ប្រជាពលរដ្ឋហ្វីលីពីន ដ៏ច្រើនកុះករ បាននាំគ្នាគ្រវីបាច់ផ្កានៅតាមសងខាងផ្លូវ និងនៅតាមមាត់បង្អួចនៃគេហដ្ឋានរបស់ពួកគេគ្រប់គ្នា ដើម្បីអបអរសាទរស្វាគមន៍ ដោយទឹកចិត្តសប្បាយរីករាយ។

មេដឹកនាំប្រទេសហ្វីលីពីន បានយាងព្រះអង្គឱ្យទៅថ្លែងសុន្ទរកថាមួយ នៅវិមានរដ្ឋសភា ដោយមានសមាជិករដ្ឋសភា និងព្រឹទ្ធសភា ចូលរួមស្តាប់ពេញសាលប្រជុំ។

ជាដំបូង ប្រធានព្រឹទ្ធសភានៃប្រទេសហ្វីលីពីន បានឡើងថ្លែងសុន្ទរកថាស្វាគមន៍ចំពោះព្រះរាជវត្តមានរបស់ព្រះអង្គ ជាភាសាអង់គ្លេស ដោយបានសម្តែងនូវការគោរព និងកោតសរសើរចំពោះការតស៊ូដ៏ឈ្លាសវៃរបស់ព្រះអង្គ ក្នុងការទាមទារឯករាជ្យពីបារាំង រហូតទទួលបានជោគជ័យ ដោយសន្តិវិធី។

បន្ទាប់មក នៅក្នុងសុន្ទរកថារបស់ប្រធានព្រឹទ្ធសភាហ្វីលីពីន បានបង្ហាញឱ្យឃើញពីចេតនា ចង់ឱ្យព្រះអង្គបោះបង់ចោលនូវមាគ៌ានយោបាយអព្យាក្រឹតរបស់ព្រះអង្គ ហើយមកឈរនៅខាងអង្គការសេអាតូ(SEATO) វិញ។

ជាការឆ្លើយតប ព្រះអង្គបានរកវិធីដោះស្រាយដ៏សមរម្យមួយ ដោយព្រះអង្គបង្ហាញឱ្យឃើញថា ព្រះអង្គនៅតែប្រកាន់ខ្ជាប់នូវគោលជំហរអព្យាក្រឹត ក្នុងការដឹកនាំប្រទេសដដែល។ តែព្រះអង្គក៏មិនធ្វើឱ្យមានភាពល្អក់កករដល់មេដឹកនាំប្រទេសហ្វីលីពីន ជាម្ចាស់ផ្ទះដែរ។

ល្ងាចថ្ងៃដដែលនោះ ពេលសម្តេចសីហនុ ជួបសន្ទនាជាមួយប្រធានាធិបតីហ្វីលីពីន រ៉ាម៉ូន ម៉ាក់សាយសាយ ប្រធានាធិបតីរូបនេះ បានយកឯកសារមួយចេញពីបណ្ណាល័យរបស់គាត់ មកបើកមើល ហើយនិយាយរំឭកពីគុណបំណាច់របស់ប្រជាពលរដ្ឋហ្វីលីពីនទៅកាន់ព្រះអង្គថា កាលពីសម័យមុន ប្រជាពលរដ្ឋហ្វីលីពីន មានដើមកំណើតអេស្ប៉ាញ៉ុល ត្រូវបានគេចាប់បង្ខំឱ្យទៅបម្រើក្នុងជួរកងទ័ព ដើម្បីទៅវាយបណ្តេញពួកសត្រូវឈ្លានពានឱ្យចេញពីប្រទេសកម្ពុជា។

សម្តេចសីហនុ ក៏មានបន្ទូលតបទៅវិញថា បើថ្ងៃណាមួយ ប្រទេសហ្វីលីពីន មានសត្រូវចូលឈ្លានពានប្រទេសហ្វីលីពីននោះ ព្រះអង្គធានាថា នឹងបញ្ជូនកងទ័ពរបស់ព្រះអង្គចូលមករួមចំណែកជួយវាយបណ្តេញពួកសត្រូវឈ្លានពាននោះ ឱ្យចេញពីប្រទេសហ្វីលីពីនវិញដែរ។ ពេលនេះ ប្រធានាធិបតីហ្វីលីពីន មិនបាននិយាយពីបញ្ហាអព្យាក្រឹត ឬមិនអព្យាក្រឹតអ្វីនោះទេ សំខាន់ គាត់បាននិយាយថា គាត់ឈរនៅខាងប្រទេសកម្ពុជា។ តែសម្តេច



មេដឹកនាំហ្វីលីពីន យកស្រីស្អាតៗ ឱ្យមកចោមរោមសម្តេចសីហនុ

សីហនុ បានបញ្ជាក់ប្រាប់ប្រធានាធិបតីហ្វីលីពីន ថា ចំពោះព្រះអង្គផ្ទាល់ ពាក្យថាអព្យាក្រឹត ពុំមែនមានន័យថា អត្តទត្ថនិយម ឬអកតញ្ញូនោះទេ។

នៅថ្ងៃបន្ទាប់ៗ មកទៀត ឥស្សរជនហ្វីលីពីនខ្លះ បានប្រើវិធីលួងលោមបញ្ចុះបញ្ចូលព្រះអង្គដោយស្ងាត់ៗ និងត្រង់ៗ ដើម្បីឱ្យព្រះអង្គបោះបង់ចោលគោលជំហរអព្យាក្រឹត ឬយ៉ាងហោចណាស់ ឱ្យព្រះអង្គឱ្យកែសម្រួលគោលជំហរអព្យាក្រឹតនោះខ្លះៗ ដើម្បីឱ្យមានទំនាក់ទំនងល្អជាមួយអង្គការសេអាតូ (SEATO)។

ឥស្សរជនហ្វីលីពីនខ្លះទៀត បានស្នើសុំព្រះអង្គឡើងថ្លែងសុន្ទរកថា នៅបណ្ឌិត្យសភាយោធា ដោយបានស្នើសុំឱ្យព្រះអង្គរឹតចំណងសាមគ្គីភាពជាមួយបណ្តាប្រទេសជាសមាជិកអង្គការសេអាតូ និងទទួលយកឥទ្ធិពលរបស់អង្គការនេះ ក្នុងការការពារប្រទេសកម្ពុជាផងដែរ។

លើសពីនេះទៅទៀត មេដឹកនាំហ្វីលីពីន បានយកស្រីស្អាតៗ ឱ្យមកចោមរោមព្រះអង្គ ទាក់ទាញព្រះអង្គឱ្យទន់ព្រះទ័យ ដើម្បីងាយស្រួលក្នុងការបញ្ចុះបញ្ចូលឱ្យព្រះអង្គបោះបង់ចោលគោលជំហរអព្យាក្រឹត នោះ ទៀតផង។

តែទោះបីជាយ៉ាងណា ក៏ព្រះអង្គមិនអាចងាកចេញពីគោលនយោបាយអព្យាក្រឹតដូចព្រះអង្គបានប្រកាសនៅក្នុងសន្និសីទ នាក្រុងបានឌុង និងងាកចេញពីចលនាមិនចូលបក្សសម្ព័ន្ធ តាមគោលការណ៍បញ្ចសិលាសហវិជ្ជមាន ដែលបានព្រមព្រៀងជាមួយនាយករដ្ឋមន្ត្រី ឥណ្ឌា ហ្សាវ៉ា ហារឡាល់ នេរូហ៍ (Jawa harlal Nehru) នៅទីក្រុងញូវដេលី (New Delhi) នោះ បានដែរ។

ក្រោយមក នៅក្នុងសន្និសីទកាសែតមួយ ធ្វើឡើងនៅក្នុងស្នាក់ការក្លឹបអ្នកកាសែត

ហ្វីលីពីន មានអ្នកកាសែតម្នាក់ បានចោទសួរព្រះអង្គថា ព្រះអង្គបានប្រាប់ពួកយើងថា ព្រះអង្គ ប្រកាន់យកគោលជំហរអព្យាក្រឹត ប៉ុន្តែ ពួកយើងមិនជឿថា នៅលើពិភពលោកយើងនេះ មានមេដឹកនាំណាប្រកាន់យកគោលជំហរអព្យាក្រឹត ពិតប្រាកដ បាននោះទេ។ ដូច្នេះសូម ព្រះអង្គសម្តែងការស្មោះត្រង់មក តើនៅក្នុងជម្រៅព្រះហឫទ័យពិតប្រាកដ ព្រះអង្គស្ថិតនៅ ខាងលោកសេរី ឬខាងកុម្មុយនិស្ត?

ពេលនោះ អ្នកកាសែតប្រុសស្រីដ៏ច្រើនកុះករ នៅពីមុខព្រះភក្ត្ររបស់ព្រះអង្គ នាំគ្នា អ៊ូអរខ្សឹបខ្សៀវដោយពេញចិត្តនឹងសំណួរនេះ និងគិតថា ព្រះអង្គពិតជាលំបាកក្នុងការឆ្លើយ នឹងសំណួរនេះ ជាមិនខាន។

តាមពិតទៅ សំណួរនេះ មានចម្លើយនៅក្នុងព្រះទ័យព្រះអង្គតាំងពីយូរមកហើយ។ ភ្លាមនោះ ព្រះអង្គឆ្លើយយ៉ាងខ្លីថា លោកសេរី ក៏ព្រះអង្គមិនយក, កុម្មុយនិស្ត ក៏ព្រះអង្គមិន យក គឺយកតែប្រទេសកម្ពុជា របស់ព្រះអង្គប៉ុណ្ណោះ។ ចម្លើយនេះ ធ្វើឱ្យពួកអ្នកកាសែត ទាំងអស់ នាំគ្នានាំគ្នាទះដៃអបអរសាទរយ៉ាងយូរ។

ក្រោយពីព្រះអង្គយាងត្រលប់មកមាតុប្រទេសវិញ ពួកអ្នកនយោបាយហ្វីលីពីន មួយ-ចំនួន ក៏ចោទប្រកាន់ព្រះអង្គថា ព្រះអង្គបាននិយាយមួលបង្កាច់ពួកអ្នកនយោបាយហ្វីលីពីន ប្រាប់អ្នកកាសែតថា ពួកអ្នកនយោបាយហ្វីលីពីន បានបង្ខំឱ្យព្រះអង្គបោះបង់គោលនយោ-បាយអព្យាក្រឹតរបស់ព្រះអង្គ ដើម្បីដាក់ប្រទេសកម្ពុជា ឱ្យនៅក្រោមឆត្រការពាររបស់អង្គការ សេអាតូ (SEATO) ។

ទោះបីជាយ៉ាងនេះក្តី ក៏ក្រោយមកទៀត ប្រធានាធិបតីហ្វីលីពីន ឈ្មោះ ដ្យូស្តាដូ ម៉ាកាប៉ាហ្គាល់ (Diosdado Macapagal) - (1961-1965) គឺជាជាមេដឹកនាំរបស់ប្រទេស ហ្វីលីពីនតែម្នាក់គត់ ដែលបានរឹតចំណងមិត្តភាពពិតប្រាកដ ជាមួយប្រទេសកម្ពុជា។ ចំណែក សមាជិកសភា និងកាសែតហ្វីលីពីន នៅតែវាយប្រហារមកលើសម្តេចសីហនុ បន្តទៀត ដោយចាត់ទុកថាព្រះអង្គ ជាមនុស្សកូតកុហក និងជាសត្រូវរបស់ប្រជាពលរដ្ឋហ្វីលីពីន ទៀតផង។

សូមរង់ចាំអានភាគ៣ បន្តទៀត
សូមអរគុណ

ឯកសារយោង ៖

1. Le Cambodge de Sihanouk Espoir, Désillusions et Amertume. par Richard Sola .
2. Le mal Cambodge Histoire D'une société traditionnelle Face à ses Leaders Politiques 1946 – 1987. par Marie Alexandrine Martin .
3. Pol Pot Frère Numéro Un. par Davidp – Chandler.
4. Le Cambodge dans la tourmente: Le troisième conflit indochinois, 1978-1991. par Nicolus Regaud .
5. Cambodge : Rêves et Réalités. par Vandy Kaonn.
6. Histoire du Cambodge 1863 – 1992. par Vandy Kaonn .
7. Cambodia: Year Zero by Francois Ponchaud
8. Hun Sen strongman of Cambodia. by Harrish C. Metha Julie B. metha.
9. When the War Was Over by Elizabeth Becker
10. How Pol Pot to come Power. By Ben Kiernan .
11. Wikipedia The free encyclopedia .
12. Wikipedia Org. wiki.
13. DP. Pedia org. page.
14. Wikiwand.
15. U.S. Embassy in Cambodia document.
16. Cold war international history Project.
17. The New York Times newspaper.
18. Times Magazine.
19. The Far Eastern Economic Review Magazine.
20. Le Figaro newspaper.

21. Le Monde newspaper.

22. Les Echos newspaper.

23. Le Parisien newspaper.

24. L´ humanite newspaper.

25. Liberation newspaper.

26. Washington Post newspaper.

27. Pol Pot by Philip Short.

28. The Gate by Francois Bizot.

29. Haing Ngor: A Cambodian Odyssey by Haing S. Ngor with Roger Warner.

30. My War With the CIA by Norodom Sihanouk .

31. War and Hope: The Case for Cambodia by Norodom Sihanouk .

32. Flying Tigers Over Cambodia by Larry Partridge.

33. The United States and Cambodia, 1870-1969 By Kenton Clymer.

34 .L´histoire terrible mais inachevée de Norodom Sihanouk, roi du Cambodge (THEATRE) (French Edition).

35. Souvenir doux et amers par Norodom Sihanouk.

36. គុកនយោបាយ ដោយ ប៊ុណ្ណ ចន្ទម៉ុល.


37. ឧត្តមគតិ លោកអៀវ កើស ដោយ ង៉ែត ហៀង.

38. លោកព្រឹទ្ធាចារ្យ បណ្ឌិតជួន មុម្ម ដោយបណ្ឌិតពុទ្ធី ទត់.

39. ជីវប្រវត្តិសង្ខេប ប៉ែន សុវណ្ណ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា ដោយប៉ែន សុវណ្ណ និងនាង សារុន.

40. Des racines dans lapierre par Sam raingsy

ជីវប្រវត្តិសង្ខេបរបស់អ្នកសិក្សាស្រាវជ្រាវ



រូបថត ឆ្នាំ១៩៨៥



រូបថត បច្ចុប្បន្ន

ឈ្មោះ **ឈឹម សេរីភ្ជន** កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៤ ។ ឪពុកឈ្មោះ **ឈឹម ប៉ាវ** មានស្រុកកំណើតនៅខេត្តព្រៃវែង មុខរបរជាអ្នកថែសួននៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត។ ម្តាយឈ្មោះ **ទេព ឌុន** មានស្រុកកំណើតនៅខេត្តស្វាយរៀង មុខរបរជាមេផ្ទះ។ មានបង៣នាក់(ស្រី១ប្រុស២) និងប្អូន៣នាក់(ស្រី២ប្រុស១)។

ឆ្នាំ១៩៦២ - ៦៣ ចូលរៀនថ្នាក់ទី១២ សាលាបឋមសិក្សាឯកជនសង្គមមានជ័យ នៅមុំខាងក្រោយ សាលាបច្ចេកទេសថៃទាំវេជ្ជសាស្ត្រសព្វថ្ងៃ ។

ឆ្នាំ១៩៦៣ - ៦៩ រៀននៅសាលាបឋមសិក្សាចង្រ្កានតាព្រហ្មមានជ័យ (វត្តចង្រ្កានតាព្រហ្មស្ទឹងមានជ័យ)

ឆ្នាំ១៩៦៩ - ៧៤ រៀននៅវិទ្យាល័យឥន្ទ្រទេវី (វិទ្យាល័យទួលគោក)

ឆ្នាំ១៩៧៤ - ៧៥ រៀនថ្នាក់ទីបញ្ចប់ផ្នែកទស្សនវិជ្ជា នៅវិទ្យាល័យកែវ សង់គីម (វិទ្យាល័យ១៨មីនា ១៩៧០ ឬវិទ្យាល័យព្រះយុគន្ធរ)។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ត្រូវជម្លៀសជាមួយក្រុមគ្រួសារទៅរស់នៅក្នុង

សង្កាត់ព្រៃរំដេង ស្រុកមេសាងតំបន់២០ ភូមិភាគបូព៌ា។

ដើមឆ្នាំ១៩៧៦ ត្រូវដម្លៀសបន្តតែម្នាក់ឯង ទៅរស់នៅក្នុងសង្កាត់តាប្រុក ស្រុកចម្ការលើ តំបន់៤២ ភូមិភាគឧត្តរ (ក្រោយមក នៅឆ្នាំ ១៩៧៧ ដូរឈ្មោះជាភូមិភាគកណ្តាល) ហើយត្រូវពួកខ្មែរក្រហមបញ្ជូលជាកងចល័តតំបន់៤២ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ឪពុកម្តាយ និងបងប្អូនបង្កើតទាំង៦នាក់ ព្រមទាំងក្មួយៗប្រមាណ១០នាក់ទៀត ត្រូវពួកខ្មែរក្រហមប៉ុល ពត សម្លាប់ចោលទាំងអស់ កាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ពីឆ្នាំ១៩៧៩ ដល់ដើម១៩៩៣ ៖

-បម្រើការងារជា ជាបុគ្គលិករដ្ឋ នៅស្រុកមេសាង ខេត្តព្រៃវែង។

-ឆ្នាំ១៩៩៣ ជាជំនួយការមន្ត្រីរៀបចំការបោះឆ្នោតអ៊ុនតាក់(UNTAC)ប្រចាំស្រុក មេសាង ខេត្តព្រៃវែង។

-ឆ្នាំ១៩៩៤ ជាមន្ត្រីនគរបាលនៅនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាន នគរបាលជាតិ ក្រសួងមហាផ្ទៃ។

ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០២១៖

-ជាអ្នកនិពន្ធអត្ថបទវិភាគនយោបាយឱ្យកាសែតចក្រវាឡ កាសែតអរិយធម៌ កាសែតសំឡេងនិស្សិត ទស្សនាវដ្តីកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-ជានិពន្ធនាយកទស្សនាវដ្តីអង្គរធំ, ជានិពន្ធនាយកទស្សនាវដ្តីខេមរា, ជានិពន្ធនាយកទស្សនាវដ្តីសោភ័ណ, ជានិពន្ធនាយករងទស្សនាវដ្តីរថយន្ត, ជាទីប្រឹក្សាកាសែតនគរធំ, ជានិពន្ធនាយកគេហទំព័រTVFB, ជានិពន្ធនាយកគេហទំព័រKBN និងជាប្រធានផ្នែកព័ត៌មាន SBM News ។

UNITED NATIONS
UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA (UNTAC)

NATIONS UNIES
AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE (APRONUC)

CERTIFICATE OF OUTSTANDING SERVICE

This certifies that Mr. Chhim Sery Phuon worked with UNTAC Electoral Component at the District of Mesang for more than eight months at different capacities. Initially, he was recruited as a Registration Team Leader (RTL) for four months. As he extraordinarily completed his contract as RTL, his contract was extended for two more months as Senior Election Assistant (SEA). Finally, after the completion of his contract as SEA, he was re-employed as a Presiding Officer for UNTAC Election in May 1993 in Combodia.

As a RTL, Mr. Chhim worked out Training Manual in Khemer, Trained the Local Staff about Registration Process and was a Team Leader of Eight other Registration Teams. I was really impressed with Mr. Chhim's training capabilities. Because of his fine training skill, we had no complains from the higher authorities regarding registration, despite complex and long procedures. His profound ability to teach others was also reflected during civic education campaign. He trained all the assistants for civic education regarding Paris Peace Agreement, UNTAC Electoral Law, Human Rights etc. so well that 99.3 % people turned over to express their opinion during the Election. He was the best PO in respect of due completion of all the technicalities during the election.

I am very much impressed of his originality, managerial skill and sincerity at work. In brief, he is a multidimensional personality with whom every one would love to work. I give him my highest regards and wish every success in his future assignments.

Sincerely,

H. Prasad

Hari Prasad, DES
Mesang, Prey Veng
COMBODIA

June 7, '93



លិខិតថ្លែងអំណរគុណ

ឯកសារប្រវត្តិសាស្ត្រមានចំណងជើងថា របត់នយោបាយ (សីហនុ - លន់ ន៎ល់ - ប៉ុល ពត - ហ៊ុន សែន) ត្រូវបានរៀបចំចងក្រងបោះពុម្ពជាសៀវភៅនេះឡើង ក្រោមការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីសំណាក់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អ្វីដែលធ្វើខ្ញុំបាទជាអ្នកសិក្សាស្រាវជ្រាវឯកសារប្រវត្តិសាស្ត្រនេះ មានការរំភើបរីករាយ និងមានកិត្តិយសបំផុតនោះ គឺនៅក្នុងលិខិតជាក់ជូនសុំអនុសាសន៍ស្តីពីជម្រើសនៃការបោះពុម្ព សម្តេចបានចារបញ្ជាក់មកវិញ ប្រកបដោយគតិបណ្ឌិត និងមនសិការប្រវត្តិសាស្ត្រជាតិ គួរឱ្យគោរពកោតសរសើរបំផុត ថាៈ ...ជម្រើសណាក៏បាន សំខាន់ចង់បានសៀវភៅប្រវត្តិសាស្ត្រមួយនេះ ទុកឲ្យកូនចៅរៀនសូត្រ ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងប្រសិទ្ធិពរជ័យជូនសម្តេច សូមប្រកបដោយពលានុភាពខ្លាំងក្លា បញ្ញាញាណភ្លឺថ្លា សុខភាពល្អបរិបូរណ៍ អាយុយឺនយូរ និងទទួលបានជោគជ័យគ្រប់ភារកិច្ចដឹកនាំប្រទេសជាតិ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត

ឈឹម សេរីភ្ឿន

9 789924 930006